ព្រះរាជាណាចក្រ កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

ករអស

យ

ជ

ក

ក



# យុទ្ធសាស្ត្រ ជាតិ

# កាត់បន្ថយ ភាពក្រីក្រ

## ២០០៣ ‐ ២០០៥

២០ ធ្នូ ២០០២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាមានមោទនភាពដោយបានផលិត និងបង្ហាញជូននូវយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រលើកទីមួយ (យ.ជ.ក.ភ ) ។ យ.ជ.ក.ភ ត្រូវបានរៀបចំឡើងដោយការប្តេជ្ញាទាំងស្រុង, ការដឹកនាំ, ការទទួលខុសត្រូវ និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ។ លើសពីនេះទៅទៀត យ.ជ.ក.ភ គឺជាផលិតផលនៃកិច្ចដំណើរការចូលរួមដែលពាក់ព័ន្ធការពិគ្រោះយោបល់ និងពិភាក្សាជាមួយអ្នកដែលរួមចំណែកទាំងអស់ដោយរួមមាន ស្ថាប័នរដ្ឋាភិបាល អង្គការនិតិបញ្ញត្តិ និងតុលាការ ស្ថាប័នផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ស្ថាប័នអប់រំ អ្នកស្រាវជ្រាវ វិស័យឯកជនសហជីពកម្មករ ប្រព័ន្ធពត៌មាន និងអ្នកក្រីក្រ ។

រាជរដ្ឋាភិបាលបានចាត់ទុកការកាត់បន្ថយភាពក្រីក្រ និងវិសមភាពឱ្យបានឆាប់រហ័ស ដែលជាផ្នែករួមដ៏សំខាន់មួយនៅក្នុងបេសកកម្មដើម្បីសំរេចឱ្យបាននូវការផ្សះផ្សារជាតិ និងការស្តារជាថ្មីនូវវប្បធម៌ជាតិ ព្រមទាំងបុរេលក្ខខ័ណ្ឌ សំរាប់រក្សាឱ្យបាននូវស្ថេរភាពនយោបាយ និងសង្គម ។ ព្រមជាមួយគ្នានេះ ការកាត់បន្ថយភាពក្រីក្រ និងវិសមភាព នឹងជួយរាជរដ្ឋាភិបាលឱ្យសំរេចបានជាបណ្តើរៗ ទៅកាន់គោលដៅអភិវឌ្ឍន៏សហស្សវត្ស ។

កិច្ចដំណើរការការចូលរួមក្នុងការរៀបរៀង យ.ជ.ក.ភ មិនត្រឹមតែធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងពីទំហំភាពក្រីក្រ និងវិសមភាពប៉ុណ្ណោះទេ តែវាបានធ្វើឱ្យការរៀបចំយុទ្ធសាស្ត្រកាន់តែសំបូរបែបដែលធានាបាននូវការជ្រើសរើសត្រឹមត្រូវនូវសកម្មភាពជួយអ្នកក្រីក្រ ព្រមទាំងធានានូវការពិចារណាការបារម្ភនានា របស់អ្នករួមចំណែកទាំងអស់ក៏ដូចជាពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនិងអ្នករួមចំណែកទាំងអស់ក្នុងការប្រយុទ្ធប្រឆាំងភាពក្រីក្រ និងវិសមភាព ។

យ.ជ.ក.ភ នឹងត្រូវបានប្រើប្រាស់ដោយរាជរដ្ឋាភិបាល ដើម្បីសំរេចទិសដៅកាត់បន្ថយភាពក្រីក្រ និងវិសមភាព ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា យ.ជ.ក.ភ លើកទីមួយនេះពុំទាន់មានភាពល្អឥតខ្ចោះនៅឡើយ ហើយមតិយោបល់ទាំងអស់របស់អ្នករួមចំណែកក៏ពុំទាន់បានបញ្ចូលអស់ទាំងស្រុងដែរ ។ យ៉ាងណាក្តីដោយសារយុទ្ធសាស្ត្រនេះជាផែនការរំកិលនោះវាត្រូវបានកែលំអឡើងថែមទៀតនៅពេលអនាគត ហើយយើងក៏ត្រូវការកិច្ចខិតខំប្រឹងប្រែងបន្តពីអ្នករួមចំណែកទាំងអស់ ដើម្បីសំរេចទិសដៅយុទ្ធសាស្ត្រនេះ ។

ហេតុនេះរាជរដ្ឋាភិបាលរំពឹងរង់ចាំការផ្តល់ការគាំទ្រ និងការចូលរួមយ៉ាងសកម្មបន្ថែមទៀតពីអ្នករួមចំណែកទាំងអស់ក្នុងការអនុវត្តន៏ ការតាមដាន និងការវាយតំលៃ យ.ជ.ក.ភ ។

រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណដល់អ្នករួមចំណែកទាំងអស់ ចំពោះការខិតខំប្រឹងប្រែងក្នុងការជួយរាជរដ្ឋាភិបាលឱ្យសំរេចបាននូវឯកសារ យ.ជ.ក.ភ នេះ ហើយរាជរដ្ឋាភិបាលសង្ឃឹមថា ការប្តេជ្ញារបស់ខ្លួន និងកិច្ចខិតខំប្រឹងប្រែងនេះនឹងនៅតែមានជាបន្តទៀត ។



**ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា**

# ខ្លឹមសារសង្ខេប

# កម្ពុជា: យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

រាជរដ្ឋាភិបាលកម្ពុជាគឺបានធ្វើការប្តេជ្ញាកាត់បន្ថយភាពក្រីក្រ និងវិសមភាពដើម្បីធ្វើអោយការរស់នៅរបស់ប្រជាជនកម្ពុជាមានភាពប្រសើរឡើងជាមួយនឹងកំណើនប្រជាជនយ៉ាងឆាប់រហ័សនេះ ។ ដូច្នេះប្រជាជនយើងនឹងទទួលបាននូវអត្ថប្រយោជន៍យ៉ាងច្រើនពីការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍នេះ ។

## ១. ចក្ខុវិស័យរាជរដ្ឋាភិបាលកម្ពុជា សំរាប់ការកាត់បន្ថយភាពក្រីក្រ

សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុនសែន** បានប្រកាសនូវយុទ្ធសាស្ត្រត្រីកោណសំរាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាបន្ទាប់ពីការបោះឆ្នោត ឆ្នាំ ១៩៩៨ ដែលមានសេចក្តីជាអាទិ៍ដូចតទៅ:

- ការកសាងសន្តិភាព ស្ថេរភាព និងសន្តិសុខ
- ការធ្វើសមាហរណកម្មពេញលក្ខណៈភាពរបស់កម្ពុជាចូលទៅក្នុងទំនាក់ទំនងតំបន់ និងអន្តរជាតិ ។
- ការលើកស្ទួយកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចតាមរយៈនូវការអនុវត្តន៍កម្មវិធីកំណែទំរង់នានានៅក្នុងស្ថានភាពមួយដែលត្រូវបានបង្កើតឡើងដូចបានកំណត់ក្នុងគោលនយោបាយខាងលើ ។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការកាត់បន្ថយភាពក្រីក្រអោយបានឆាប់រហ័សជាចំណែករួមមួយ នៃយុទ្ធសាស្ត្ររបស់ខ្លួន។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាគឺចង់បានសង្គមមួយមានសាមគ្គីភាពស្អិតរមួត, មានការអប់រំ និងមានវប្បធម៌រស់រវើក ដោយពុំមានភាពក្រីក្រ ភាពអត់ឃ្លាន អវិជ្ជា និងសុខភាពទ្រុឌទ្រោម ។ ដើម្បីសំរេចបាននូវចក្ខុវិស័យនេះរាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តន៍នូវផែនការសេដ្ឋកិច្ចសង្គមកិច្ចលើកទី២ (SEDP2) និងយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ (យ.ជ.ក.ភ) ដោយមានការគាំទ្រពេញលេញពីសំណាក់អ្នករួមចំណែកទាំងអស់។

យ.ជ.ក.ភ នេះគឺពិតជាលទ្ធផលមួយនៃការខិតខំប្រឹងប្រែងរបស់ជាតិ ដែលបានឆ្លុះបញ្ចាំងពីចំណេះដឹង និងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការអនុវត្តន៍ជាបន្តទៀតនូវដំណើរការបែបនេះនឹងធ្វើអោយគុណភាពនៃ យ.ជ.ក.ភ កាន់តែប្រសើរឡើងថែមទៀត ។ ចំណែក ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ចាប់ពីឆ្នាំ ២០០៥ តទៅ នឹងដាក់បញ្ចូលនូវ យ.ជ.ក.ភ ផងដែរ ដែលនឹងទទួលបាននូវជោគជ័យយ៉ាងត្រចះត្រចង់តាមរយៈការសិក្សាយកបទពិសោធន៍ពីការកាត់បន្ថយភាពក្រីក្រនៅពេលនេះ ។

## ២. កិច្ចដំណើរការចូលរួមនៃការរៀបចំ យជកភ

ដំណើរការនៃការរៀបចំចងក្រងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រចាប់ផ្តើមឡើងនៅដើមខែឧសភាឆ្នាំ២០០០ គឺស្របពេលជាមួយនិងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ដែរ ។ យុទ្ធសាស្ត្របណ្តោះអាសន្នសំរាប់ការកាត់បន្ថយភាពក្រីក្រត្រូវបានធ្វើការសំរបសំរួលដោយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រីឯ SEDP2 ត្រូវបានរៀបចំ និងដឹកនាំគ្រប់គ្រងរបស់ក្រសួងផែនការ។ ហើយ SEDP2 ត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រីក្នុងខែធ្នូ ឆ្នាំ ២០០១ និងដោយសភាជាតិនៅក្នុងខែមិថុនាឆ្នាំ ២០០២ ។

ការទទួលខុសត្រូវក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រត្រូវបានផ្ទេរសិទ្ធទៅក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច (CSD)ជាអង្គភាពអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងផែនការជាប្រធាន ។ CSD ត្រូវបានជួយ

សំរបសំរួលក្នុងភារកិច្ចរបស់ខ្លួន ដោយអគ្គលេខាធិការដ្ឋានដែលត្រូវបានបង្កើតឡើងកាលពីខែ សីហា ឆ្នាំ២០០១ ដែលធ្វើការដឹកនាំដោយអនុរដ្ឋលេខាធិការ នៃក្រសួងផែនការ ។ ការពិគ្រោះយោបល់និងសកម្មភាពចូលរួមត្រូវបានរៀបចំឡើងដោយអគ្គលេខានៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច (GSCSD) ។

- នៅខែមេសា ឆ្នាំ២០០២ សិក្ខាសាលាជាតិស្តីអំពី PRSP លើកទីមួយបានពិភាក្សាអំពីកិច្ចដំណើរការពិគ្រោះយោបល់ដោយមានការចូលរួមយ៉ាងច្រើន និងសកម្មពីបណ្តាអង្គការក្រៅរដ្ឋាភិបាលនានា
- សិក្ខាសាលាជាតិលើកទី២ នាថ្ងៃទី ២៨-២៩ ឧសភា ឆ្នាំ ២០០២ បានស្តាប់នូវបទបង្ហាញរបស់ក្រសួងជំនាញនានាស្តីអំពីតារាង ម៉ាទ្រីសពង្រាងរបស់គេសំរាប់យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។
- ការិយាល័យបច្ចេកទេសវិភាគនិងតាមដានភាពក្រីក្រ (PMATU) របស់ក្រសួងផែនការបានរៀបចំវេទិកាជាតិស្តីអំពីភាពក្រីក្រ នៅដើមខែកក្កដាដើម្បីពិភាក្សាផែនការសំរាប់ការតាមដាន និងការវិភាគភាពក្រីក្រ ។
- សេចក្តីព្រាងលើកទី១ នៃឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រត្រូវបានចែកផ្សាយក្នុងអង្គសិក្ខាសាលាជាតិលើកទី៣ នាថ្ងៃទី ២៦-២៧ ខែសីហាឆ្នាំ ២០០២ ដែលមានការចូលរួមពីសំណាក់អ្នកចូលរួមជាង ២០០នាក់ ។
- NGO Forum នៃកម្ពុជាបានរៀបចំវេទិកាពិភាក្សាស្តីអំពីបញ្ហាអភិវឌ្ឍន៍ដែលបញ្ចប់ទៅនៅក្នុងការរៀបចំសិក្ខាសាលា NGOថ្នាក់ជាតិមួយនាថ្ងៃទី ២៤-២៥ ខែតុលាឆ្នាំ២០០០ ហើយដែលមានការចូលរួមពីតំណាង NGO ប្រហែល ៨៥ រូបដែលភាគច្រើនជាកម្ពុជា ។
- ឯកសារពង្រាងនៃយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រលើកទី២ ត្រូវបានបង្ហាញជូននៅឯសិក្ខាសាលាជាតិលើកទី ៤ និងជាសិក្ខាសាលាជាតិលើកចុងក្រោយបង្អស់នៅថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ២០០២ ដើម្បីផ្តល់នៅការចូលរួមបន្ថែមទៀតក៏ដូចជាយោបល់ដើម្បីបញ្ចប់ យ.ជ.ក.ភ និងពិភាក្សារួមគ្នាពីជំហានបន្ទាប់ក្នុងការអភិវឌ្ឍន៍ យ.ជ.ក.ភ ។

## ៣. ពហុទំហំនៃភាពក្រីក្រនៅកម្ពុជា

នៅក្នុងឆ្នាំ ១៩៩០ ដែលជាឆ្នាំទី ១ នៃរបាយការណ៍អភិវឌ្ឍន៍មនុស្ស សន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា ត្រូវបានគេគណនា មានតំលៃត្រឹមតែ ០,៥០១ ដែលជាចំណាត់ថ្នាក់មានការអភិវឌ្ឍន៍មនុស្សទាប ។ បច្ចុប្បន្ន នៅឆ្នាំ ២០០២នេះ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាមានតំលៃស្មើនឹង ០,៥៤៣ ដែលមានចំណាត់ថ្នាក់ប្រសើរជាងមុន គឺកម្ពុជាស្ថិតក្នុងប្រភេទប្រទេសដែលមានការអភិវឌ្ឍន៍មនុស្សមធ្យម ដែលឈរនៅលំដាប់ទី ១៣០ ក្នុងចំណោមប្រទេសទាំង ១៧៣ ។ ទោះជាយ៉ាងនេះក្តី ភាពក្រីក្រនៅកម្ពុជាក៏នៅតែមានទំហំធំនៅឡើយ ។

- ប្រជាជនកម្ពុជាប្រមាណជា ៣៦ ភាគរយកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រដែលមានតំលៃជាសាច់ប្រាក់ស្មើនឹង ០,៤៦ -០,៦៣ ដុល្លាតាមអត្រាប្តូរប្រាក់បច្ចុប្បន្ន ។
- ភាពក្រីក្រនៅប្រទេសកម្ពុជាត្រូវបានកើតឡើងភាគច្រើនដោយសារតែកំណើនប្រជាជនខ្ពស់ កង្វះកាលានុវត្តន៍ភាព កង្វះសុវត្ថិភាព អសន្តិសុខ ការរើសអើងនៅក្នុងសង្គម និងភាពងាយរងគ្រោះ ។
- ទោះបីជាប្រជាជនកម្ពុជា ជាង ៧០ភាគរយ ត្រូវបានប្រកបរបរនៅក្នុងវិស័យផលិតកកម្មកសិកម្មក៏ដោយ ប្រជាជនប្រមាណពី ១២ ទៅ១៥ភាគរយពុំមានដីកសិកម្មនៅឡើយ ។
- លទ្ធភាពរបស់អ្នកក្រីក្រក្នុងការប្រើប្រាស់ធនធានធម្មជាតិដ៏ទៃទៀតដូចជាៈ ព្រៃឈើ និងជលផលក៏នៅមានកំរិតនៅឡើយ ។
- អ្នកក្រីក្រភាគច្រើន (៧៩ភាគរយ) គឺជាអ្នកដែលមានមេគ្រួសារប្រកបរបរនៅក្នុងវិស័យកសិកម្ម ។

- នៅក្នុងរយៈពេលរវាងឆ្នាំ ១៩៩៣ និងឆ្នាំ ២០០០អត្រាកំណើនជាមធ្យមនៃមុខរបរក្នុងវិស័យកសិកម្មមានត្រឹមតែ ១,៦ ភាគរយ ប៉ុណ្ណោះ។ កាលានុវត្តន៍ភាពការងារនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មក៏នៅមានកំរិត (មានត្រឹមតែ ៨ និង ១៨ ភាគរយប៉ុណ្ណោះ) កំណើនការងារជាមធ្យមសំរាប់វិស័យសេវាកម្មគឺមានតែ ១,០៨ ភាគរយ រីឯ កំណើនការងារជាមធ្យមក្នុងវិស័យឧស្សាហកម្មមានកំរិតច្រើនគួរអោយកត់សំគាល់រហូតដល់ ៤៣,២៩ ភាគរយក្នុង រយៈពេលឆ្នាំ ១៩៩៨-២០០០ ទោះបីជាមានការរីកលូតលាស់ក្នុងវិស័យឧស្សាហកម្មដូច្នេះក៏ដោយ គឺមាន ប្រជាជនប្រមាណតែ ៨,៤ ភាគរយប៉ុណ្ណោះដែលបានទទួលផលពីការរីកលូតលាស់នេះ។
- សុខភាពទ្រុឌទ្រោមគឺជាមូលហេតុដ៏ចំបងនៃភាពក្រីក្រ និងការបាត់បង់សមត្ថភាពដ៏ទៃទៀតក្នុងសង្គម (ឧទាហរណ៍ ការបាត់បង់ឱកាសសិក្សា និងឱកាសការងារ)។ វដ្តនៃភាពក្រីក្រ សុខភាពទ្រុឌទ្រោម និងការចំណាយលើការថែទាំ សុខភាពខ្ពស់ ដែលជាឧបសគ្គដ៏លំបាករបស់គ្រួសារក្រីក្រ។
- អត្រាភាពក្រីក្រមានកំរិតខ្ពស់ចំពោះមេគ្រួសារពុំមានការអប់រំជាផ្លូវការ ឬក៏មានការសិក្សាថ្នាក់បឋមសិក្សាតិចតួច។ ចំណែកភាគរយនៃការចំណាយលើការអប់រំរបស់គ្រួសារក្រីក្រមានកំរិតទាប តិចជាង ១,១ភាគរយ។
- អ្នកក្រីក្រមានលទ្ធភាពតិចតួចដើម្បីទទួលបាននូវសេវាកម្ម និងការប្រើប្រាស់នូវមូលដ្ឋានសំភារៈសង្គមកិច្ច ។ ប្រជាជនប្រហែល ២១ ភាគរយនៅក្រុមបញ្ចភាគ អ្នកក្រីក្របំផុតបានចំណាយពេលធ្វើដំណើរក្នុងរយៈចំងាយ លើសពី ៥គីឡូម៉ែត្រ ទៅកាន់មណ្ឌលថែទាំសុខភាព។ ប្រហែលជា ២៦ ភាគរយ នៃប្រជាជនក្រីក្រក្នុងបញ្ចភាគ ២ ក្រោមបំផុត នៃអ្នកក្រីក្ររស់នៅក្នុងរយៈចំងាយលើសពី ៥ គីឡូម៉ែត្រ ពីផ្លូវដែលនៅជិតបំផុត។
- អវិជ្ជាគឺជារបាំងរាំងស្ទះមួយសំរាប់អ្នកក្រក្នុងការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅ ដោយពួកគេត្រូវស្ថិតក្នុង ភាពរើសអើង និងនៅក្រៅរង្វង់នៃដំណើរការអភិវឌ្ឍន៍។
- ស្ត្រីនៅក្នុងប្រទេសកម្ពុជាពុំទទួលបាននូវសិទ្ធិស្មើភាពគ្នាក្នុងការអប់រំ, ប្រាក់ឈ្នួលតិច, ខ្វះកម្មសិទ្ធិដីធ្លី និងសិទ្ធិលើ ទ្រព្យសម្បត្តិនានា។ ស្ត្រីក៏រងគ្រោះអំពីកង្វះខាតនូវសេវាថែទាំសុខភាពបន្តពូជផងដែរ។ ពួកគេជាទូទៅ ច្រើនស្ថិតក្នុង ស្ថានភាពបាត់បង់នូវផលប្រយោជន៍ទាំងក្នុងសង្គមគ្រួសារក៏ដូចជាសង្គមទូទៅ។
- ជនជាតិភាគតិចក៏ត្រូវបាត់បង់ផលប្រយោជន៍ដោយសារកង្វះតំណាងភាពរបស់ខ្លួននៅថ្នាក់គ្រប់គ្រង និងថ្នាក់និតិ បញ្ញត្តិ ហើយមូលហេតុរបាំងភាសារផងដែរ។
- កង្វះលទ្ធភាពក្នុងការទទួលបានពត៌មានរបស់រដ្ឋាភិបាល និងការសំរេចចិត្តរបស់រដ្ឋាភិបាលបានរារាំងអ្នកក្រីក្រ មិនអាចអោយបានចូលរួមនៅក្នុងសកម្មភាពការងារសហគមន៍ ដែលធ្វើឱ្យមានគំលាតរវាងគោលនយោបាយរបស់ រដ្ឋាភិបាល និងការអនុវត្តន៍គោលនយោបាយទាំងអស់នោះ។
- កង្វះលទ្ធភាពក្នុងការប្រើប្រាស់ និងសិទ្ធិ ក៏ជាបញ្ហាមួយធ្ងន់ធ្ងរពីព្រោះថាអ្នកក្រីក្រមិនបានយល់ដឹងពីច្បាប់ និងសិទ្ធិ របស់ពួកគេ ដែលជាកត្តាងាយរងគ្រោះដោយសារការកេងប្រវ័ញ្ច ។

## ៤. សកម្មភាពអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រ

សកម្មភាពជាអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រមានដូចតទៅ:

- ការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
- ការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅតាមជនបទ
- ការពង្រីកកាលានុវត្តភាពការងារ

- ការបង្កើនសមត្ថភាពប្រជាជន
- ការពង្រឹងស្ថាប័ន និងធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច
- ការកាត់បន្ថយនូវភាពងាយរងគ្រោះ និងកាត់បន្ថយភាពរើសអើងនៅក្នុងសង្គម
- ការលើកស្ទួយសមភាព យេនឌ័រ
- និងការផ្តោតការយកចិត្តទុកដាក់ចំពោះប្រជាជន

## ការរក្សានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច

គោលបំណងស្នូលនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺចង់លើកស្ទួយនៅកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងដោយមានតួនាទីនាំមុខរបស់ផ្នែកឯកជនយ៉ាងសំខាន់។ កំណើនសេដ្ឋកិច្ចគឺជាកត្តាស្នូលក្នុងការបង្កើនប្រាក់ចំណូលដល់អ្នកក្រីក្រ។ ដូចចែងក្នុង SEDP២ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំរេចឱ្យបាននូវអត្រាមានចីរភាពពិតនៃកំណើនសេដ្ឋកិច្ចពី ៦ ទៅ ៧ ភាគរយ ក្នុងមួយឆ្នាំ។ ការសំរេចបាននូវសមិទ្ធិផលបែបនោះមានន័យថា ប្រាក់ចំណូលសំរាប់មនុស្សម្នាក់ៗ (គិតក្នុងតំលៃឆ្នាំ ២០០០) ប្រហែលជា ៣២០ ដុល្លានៅចុងឆ្នាំ ២០០៥ ។ នេះមានន័យថាអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៅក្នុងប្រាក់ចំណូលរបស់មនុស្សម្នាក់ៗ មានដល់ ៣.៥ ភាគរយ។

ការសំរេចបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ពី ៦-៧ ភាគរយ និងទាមទារវិធានការណ៍ច្បាស់លាស់ក្នុងការអនុវត្តន៍កម្មវិធីកំណែទំរង់ និងគោលនយោបាយគាំទ្រដ៏ទៃទៀត។ ទាំងនេះរួមមានៈ

- ការមិនធ្វើរូបនីយណីយកម្មនៃឱនភាពថវិកា
- ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយលក្ខណៈត្រឹមត្រូវ
- ពង្រឹងថែមទៀតនូវកំណែទំរង់ផ្នែកធនាគារ
- ការធ្វើអោយប្រសើរឡើងនូវប្រាក់ចំណូលជាតិ
- បង្កើនការចំណាយសំរាប់វិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច និងការគ្រប់គ្រងអោយបានល្អត្រឹមត្រូវនូវថវិកា និងរតនាគារ
- ការធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌវិនិយោគ
- កំណែទំរង់ក្របខ័ណ្ឌស៊ីវិល
- កំណែទំរង់ច្បាប់ និងតុលាការ។

## ការធ្វើអោយប្រសើរឡើងនូវជីវិតជីវភាពជនបទ

គោលនយោបាយស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុដែលល្អត្រឹមត្រូវមានលក្ខណៈសំខាន់ចាំបាច់ណាស់ ប៉ុន្តែទាំងអស់នេះមិនអាចធានាបាននូវការធ្វើអោយប្រសើរឡើងនូវជីវភាពរបស់ប្រជាជននៅទីជនបទ ដែលភាគច្រើនជាអ្នកក្រីក្ររស់នៅបានឡើយ។ យ.ជ.ក.ភ បានកំណត់នូវកត្តារាំងស្ទះនានា និងធ្វើការកំណត់ជាកម្មវិធីគោលនយោបាយ ព្រមជាមួយទិសដៅដើម្បីធ្វើការបង្កើនប្រាក់ចំណូលដល់ប្រជាជនដែលរស់នៅតំបន់ជនបទដូចជាៈ ដីធ្លី ទឹក កសិកម្ម ព្រៃឈើ និងជលផល ព្រមទាំងការដឹកជញ្ជូន ។ ការធ្វើអោយប្រសើរឡើងនូវផ្នែកទាំងអស់នេះនឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រក្នុងផ្នែកផ្សេងៗពីគ្នា ជាឧទាហរណ៍ តាមរយៈនៃការធ្វើប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់សេវាជាមូលដ្ឋាន ។ ទន្ទឹមនេះទំនាក់ទំនងរវាងសកម្មភាពក្នុងផ្នែកដ៏ទៃទៀត ក៏មានសារៈសំខាន់ផងដែរ ដូចជាវិមជ្ឈការ និងជីវភាពជនបទ។

ជីវភាពជនបទបានប្រសើរឡើង គឺអាស្រ័យផងដែរទៅលើទំហំនៃភាពក្រីក្រមានការថយចុះ ។ សុខភាពទ្រុឌទ្រោម កង្វះការសិក្សា កង្វះហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងផលិតភាពទាប ដែលជាហេតុធ្វើអោយប្រជាជននៅជនបទធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រ ។

## បង្កើនកាលានុវត្តភាពការងារ

រយៈពេលធ្វើការវែង ដោយបានប្រាក់ចំណូលតិច ផលិតផលភាពក៏ទាប ហើយសន្តិសុខក៏មានកំរិត ។ ដូច្នេះការកែប្រែស្ថានភាពការងារ និងលក្ខខណ្ឌការងារ គឺជាកក្តាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ ។ រាជរដ្ឋាភិបាលមានគោលនយោបាយ និងធ្វើឱ្យប្រសើរឡើងនូវកាលានុវត្តន៍ភាពការងារតាមរយៈ

- ការអភិវឌ្ឍន៏វិស័យឯកជន
- ការពង្រីកការនាំចេញ
- ការពង្រីកវិស័យទេសចរណ៏ ។

វិសាលភាពនៃគោលនយោបាយទាំងអស់នេះ នឹងមានប្រសិទ្ធិភាពជាក់ស្តែងដែលនាំមកនូវជោគជ័យក្នុងការបង្កើនសមត្ថភាព (ដូចជា ការអប់រំ, ជំនាញ និងសុខភាព) ដល់ប្រជាជន ក៏ដូចជាការធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ច និងតំលាភាព ។

## ការធ្វើអោយប្រសើរឡើងនូវសមត្ថភាព

យ.ជ.ក.ភ បានឆ្លុះបញ្ចាំងនូវអាទិភាពដែលពិតជាមានឥទ្ធិពលលើអ្នក ក្រីក្រកម្ពុជានៅក្នុងវិស័យអប់រំសុខភាព និងអាហារូបត្ថម្ភ ។

- ដើម្បីសំរេចអោយបាននូវការអប់រំសំរាប់មនុស្សគ្រប់ៗរូប នោះពោលគឺការសំរេចឱ្យបាននូវការអប់រំជាមូលដ្ឋាន ៩ ឆ្នាំ សំរាប់មនុស្សគ្រប់ៗគ្នា វិស័យអប់រំនឹងធ្វើការដោះស្រាយទាំងការផ្គត់ផ្គង់ និងតំរូវការនិងគុណភាពដោយផ្តោតជាពិសេសទៅលើក្រុមប្រជាជនក្រីក្របំផុត និងក្រុមដែលស្ថិតក្នុងភាពងាយរងគ្រោះ ។ គោលនាយាបាយអប់រំ និងសំរបសំរួលឱ្យមានកំណើនសេដ្ឋកិច្ចតាមរយៈបង្កើនឱ្យបាននូវភាពស្មើគ្នាក្នុងទទួលបាននូវគុណភាពអប់រំ និងការកែប្រែប្រព័ន្ធដើម្បីជួយដល់អ្នកក្រីក្រ ។
- សេចក្តីថ្លែងការណ៏គោលនយោបាយសុខាភិបាលឆ្នាំ ២០០៣-២០០៧ បានស្វះស្វែងរកការផ្តល់អោយនូវសេវាសុខភាពដោយមានគុណភាពខ្ពស់ និងផ្អែកលើភស្តុតាងដែលប្រកបដោយសមភាព និងពុំមានការប្រកាន់ភេទ, អាយុ, ទីកន្លែងស្នាក់នៅឬក៏លទ្ធភាព បង់ថ្លៃសេវាដែលត្រូវតែនិយមអ្នកក្រីក្រ ដោយធ្វើការផ្អែកទៅលើជំនឿទុកចិត្តរវាងអ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវា ។
- ដើម្បីដោះស្រាយនូវបញ្ហាជាក់លាក់នៃកង្វះអាហារូបត្ថម្ភ ការផ្តល់យកចិត្តទុកដាក់ និងការតំរង់ទិស វានឹងជួយការពារមិនអោយមានកង្វះអាហារូបត្ថម្ភនៅអាយុដំបូងៗនៃជីវិតដោយធ្វើអន្តរាគមន៍មុនពេលចាប់កំណើត និងផ្តោតទៅលើរយៈពេល ២ ឆ្នាំ ដំបូងនៃជីវិតរបស់ក្មេង ។ ជាការចាំបាច់ផងដែរដែលត្រូវធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភដល់ស្រ្តីភេទដែលមានអាយុបន្តពូជ និងស្រ្តីភេទដែលមានផ្ទៃពោះដើម្បីសុខភាពរបស់ពួកគេបានល្អ ហើយដើម្បីការពារមិនឱ្យមានការលូតលាស់យឺតក្នុងប្រព័ន្ធបង្កកំណើត ។

## ការពង្រឹងស្ថាប័ន និងការធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ច

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តន៍នូវផែនការសកម្មភាពអភិបាលកិច្ច ជាក្របខ័ណ្ឌយុទ្ធសាស្ត្រកំពុលដែលនឹងផ្តល់វិធានការណ៍មួយដែលមានលក្ខណៈស្រប និងតំលាភាពដើម្បីសំរបសំរួលដល់កិច្ចខិតខំប្រឹងប្រែងក្នុងផ្នែកអាទិភាពទាំង ៨:

- កំណែទំរង់ច្បាប់ និងតុលាការ
- កំណែទំរង់រដ្ឋបាល និងវិសហមជ្ឈការ
- វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន
- កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ
- ប្រឆាំងអំពើពុករលួយ
- សមភាពយេនឌ័រ
- ការរំសាយនិងកំណែទំរង់កងកំលាំងប្រដាប់អាវុធ
- កំណែទំរង់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ (ដីធ្លី ព្រៃឈើ និងជលផល)

ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយគឺជាកត្តាសំខាន់បំផុតក្នុងការកាត់បន្ថយភាពក្រីក្រ ។ ប្រទេសកម្ពុជាកំពុងប្រឈមមុខចំពោះបញ្ហាដ៏ពិបាក១ ក្នុងការសំរេចឱ្យបាននូវគោលបំណងទាំងនេះ ។ ការប្រកួតប្រជែងសំរាប់ការវិនិយោគប្រាកដជាមានលក្ខណៈដ៏ពិបាកក្នុងចំណោមប្រទេសនានាក្នុងចំណោមវិស័យឧស្សាហកម្ម។ ហើយប្រទេសកម្ពុជាបានគ្រប់គ្រងនូវប៉ារ៉ាម៉ែត្រជោគជ័យតែមួយចំនួនប៉ុណ្ណោះ។ កត្តាមួយដែលខ្លួនអាចគ្រប់គ្រងបានហើយដែលអាចធ្វើឱ្យមានឥទ្ធិពលទៅលើបញ្ហាភាពក្រីក្រគឺការអនុលោមទៅតាមអភិបាលកិច្ចល្អ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ រាជរដ្ឋាភិបាលបានសំរេចជ្រើសរើសក្នុងការដោះស្រាយអំពើពុករលួយដោយមានវិធានការណ៍រួម ដែលធ្វើការគិតគូរដល់ឬសគល់ជាប្រភពរបស់អំពើពុករលួយ។ ការបង្កើនឡើងនូវការប្រថុយប្រថាន (ហានិភ័យ) ដែលមានជាមួយនឹងការប្រព្រឹត្តអំពើពុករលួយគឺជាផ្នែករួមមួយនៃយុទ្ធសាស្ត្រនេះ។ ប៉ុន្តែក្រមនិយ័តកម្ម និងច្បាប់មិនអាចដំណើរការតែឯកឯងបានឡើយ។ យន្តការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌ត្រូវតែមានលក្ខណៈចាំបាច់ក្នុងការបំពេញបន្ថែមទៅលើក្របខ័ណ្ឌច្បាប់។ រាជរដ្ឋាភិបាលកំពុងតែកសាងយ៉ាងសកម្មនូវសកម្មភាពបែបនេះហើយដែលខ្លួននឹងសំរេចជាចុងក្រោយ ថាតើអ្វីដែលនឹងក្លាយជាក្របខ័ណ្ឌច្បាប់អាចអនុវត្តន៍ទៅបាន។

## ការកាត់បន្ថយភាពងាយរងគ្រោះ និងការពង្រឹងការចូលរួមក្នុងសង្គម

ការបង្កើនឡើងនូវនិរន្តរភាពបរិស្ថាន និងការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិ គឺជាគន្លឹះមួយនៅក្នុងការកាត់បន្ថយភាពងាយរងគ្រោះ។ បញ្ហាសំខាន់ៗក្នុងនេះមាន :

- ការគ្រប់គ្រងគ្រោះមហន្តរាយ ជាពិសេសទាក់ទងទៅនឹងទឹកជំនន់
- ការបោសសំអាតមីន ដែលជាកេរ្តិ៍មរតកនៃសង្គ្រាមដ៏រ៉ាំរ៉ៃ
- ភាពងាយរងគ្រោះនៃជនពិការ អ្នកដែលរងគ្រោះដោយជំងឺអេដស៍ កុមារកំព្រា កុមាររស់តាមចិញ្ចើមថ្នល់ និងកុមារដែលគេបោះបង់ និងជនដែលគ្មានផ្ទះសំបែង
- សន្តិសុខស្បៀង
- បណ្តាញកម្មវិធីសុវត្ថិភាពសង្គម ដោយផ្អែកលើកំរិតថវិកា និងសមត្ថភាពរបស់រដ្ឋាភិបាល។

## ការបង្កើនសមធម៌យេនឌ័រ

អាស្រ័យដោយ ៦៥ ភាគរយនៃកំលាំងការងារកសិកម្ម និង ៧៥ ភាគរយ ផលិតកម្មក្នុងវិស័យជលផល គឺស្ថិតក្នុងកណ្តាប់ដៃរបស់ស្ត្រី ភាពក្រីក្រនឹងមិនអាចកាត់បន្ថយបានឡើយប្រសិនបើគោលនយោបាយ និងកម្មវិធីមិនបានដោះស្រាយបញ្ហាសមភាពសំរាប់ស្ត្រីកម្ពុជា។ អាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន ក្រសួងកិច្ចការនារី និងអតីយុទ្ធជនជាអ្នកដឹកនាំមានដូចតទៅៈ

- ដើម្បីកាត់បន្ថយភាពខុសគ្នាផ្នែកយេនឌ័រ នឹងធ្វើឱ្យប្រសើរឡើងនូវសមភាពយេនឌ័រក្នុងបញ្ហាសុខភាព ការអប់រំ ការគ្រប់គ្រងធនធានកសិកម្ម ការពង្រឹងសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយ និងការការពារផ្នែកច្បាប់
- ធានាឱ្យបានថាស្ត្រី និងកុមារីទទួលបាននូវការការពារផ្នែកច្បាប់ពេញលក្ខណៈក៏ដូចជាការអប់រំផ្នែកច្បាប់ទាក់ទងទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់ពួកគេ ដូចជាលទ្ធភាពក្នុងការទទួលបាននូវសិទ្ធិកាន់កាប់ដីធ្លី និងការប្រើប្រាស់ធនធានធម្មជាតិ
- ការលើកស្ទួយបញ្ហាយេនឌ័រនៅក្នុងនាយកដ្ឋានរបស់រដ្ឋាភិបាលទាំងអស់
- ការសហប្រតិបត្តិការណ៍ជាមួយក្រសួងសុខាភិបាលសំរាប់កិច្ចការសុខភាព ក្រសួងអប់រំ យុវជន និងកីឡា សំរាប់កិច្ចការអប់រំ និងក្រសួងកសិកម្ម ក្រសួងធនធនទឹក និងក្រសួងអភិវឌ្ឍន៍ជនបទសំរាប់ការងារកសិកម្ម និងការបង្កើនប្រាក់ចំណូលនៅជនបទ
- ដោះស្រាយរបាំងផ្នែកច្បាប់សំរាប់សិទ្ធិស្មើភាពរបស់ស្ត្រីភេទ
- ដឹកនាំការងារអប់រំផ្នែកយេនឌ័រ និងលើកស្ទួយការយល់ដឹងផ្នែកយេនឌ័រដល់មន្ត្រី របស់រាជរដ្ឋាភិបាលកម្ពុជា គ្រប់លំដាប់ថ្នាក់។

រាជរដ្ឋាភិបាលកម្ពុជាជំរុញគ្រប់គណបក្សនយោបាយដាក់ស្ត្រីភេទបញ្ចូលទៅក្នុងបញ្ជីគណបក្សនៅក្នុងតួនាទីផ្សេង ៗ ដែលនឹងអនុញ្ញាត្តអោយពួកគេមានឱកាសស្មើភាពជាមួយនឹងបុរសក្នុងការ ដែលទទួលបានបោះឆ្នោតជ្រើសរើសធ្វើជាសមាជិកសភា។ រដ្ឋាភិបាលនឹងអនុម័តនូវគោលនយោបាយ សកម្មភាពវិជ្ជមានមួយក្នុងការជ្រើសរើសនិងលើស្ទួយស្ត្រីអោយចូលទៅក្នុងថានៈ តួនាទីជាអ្នកសំរេចចិត្តក្នុងសេវាសាធារណៈ។ រដ្ឋាភិបាលនឹងធានាថា នៅក្នុងកិច្ចដំណើរការពិគ្រោះយោបល់ទាំងអស់ និងនៅក្នុងក្រុមវាយតំលៃនិងតាមដាននឹងត្រូវមានចំនួនស្ត្រីឱ្យស្មើគ្នានឹងចំនួនបុរស។

## អាទិភាពផ្តោតលើវិស័យប្រជាជន

យ.ជ.ក.ភ ទទួលស្គាល់នូវតួនាទីកណ្តាលសំខាន់ និងមានទំនាក់ទំនងទូលំទូលាយនៃបញ្ហាប្រជាជន ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីដំបូងបី ដែលមានការផ្តោតការយកចិត្តតុកដាក់ជាអាទិភាពទៅលើៈ

- ការផ្តោតជាពិសេសទៅលើការងារផ្នែកសុខភាពបន្តពូជ និងការងារធ្វើផែនការគ្រួសារសំរាប់អ្នកក្រីក្រដែលត្រូវអនុវត្តន៍ដោយក្រសួងសុខាភិបាល
- ការបង្កើនឡើងនូវការចូលរៀនថ្នាក់បឋមសិក្សាសំរាប់អ្នកក្រដែលត្រូវអនុវត្តន៍ដោយក្រសួងអប់រំ
- ការបង្កើនកាលានុវត្តភាពការងារនៅទីជនបទ សំរាប់អ្នកក្រីក្រដែលត្រូវអនុវត្តន៍ឡើងដោយក្រសួងដែលពាក់ព័ន្ធក្នុងវិស័យអភិវឌ្ឍន៍ជនបទ។

## ៥. តំរូវការ និងការគ្រប់គ្រងធនធានសាធារណៈ

ផ្នែកដ៏សំខាន់នៃការអនុវត្តន៍ យ.ជ.ក.ភ គឺ:

- ការវិភាគថវិកាត្រូវតែឱ្យស្របគ្នាជាមួយនឹងសកម្មភាពរបស់ យ.ជ.ក.ភ
- ការអនុវត្តន៍ និងការគ្រប់គ្រងថវិកាត្រូវតែអនុលោមទៅតាមការកំណត់។

ការប្រមូលផ្តុំនូវប្រាក់ចំណូល គឺជាចំណុចគន្លឹះនៅក្នុងគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តន៍នូវកំណែទំរង់យ៉ាងតឹងរឹង ដែលមានគោលដៅសំរេចអោយបាននូវការបង្កើនឡើងនូវប្រាក់ចំណូល ដែលមានផលធៀបពី ៩ ភាគរយនៃផលិតផលក្នុងស្រុកសរុប (ផសស)នៅឆ្នាំ ១៩៩៨ រហូតដល់ ១៤ ភាគរយនៅឆ្នាំ ២០០៥។ ការសំរេចបាននូវគោលដៅប្រាក់ចំណូល ១៤ ភាគរយនៃ ផសស ឆ្នាំ ២០០៥ គឺមានលក្ខណៈចាំបាច់ណាស់សំរាប់ការអនុវត្តន៍នូវកម្មវិធីកាត់បន្ថយភាពក្រីក្រៈ

- ក្នុងរយៈពេល ៣ឆ្នាំខាងមុខនេះកម្ពុជាមានគោលបំណងបង្កើនប្រាក់ចំណូលឱ្យបាន ២ ភាគរយនៃ ផសស ដើម្បីទ្រទ្រង់ជាហិរញ្ញប្បទាននូវការបង្កើនការចំណាយលើផ្នែកសង្គមកិច្ច និងការទូទាត់បំណុល។ កិច្ចការនេះនឹងទាមទារអោយមានការអនុវត្តន៍ស្របគ្នាទៅតាមវិធានការណ៍សារពើពន្ធដែលមាន (ចំណូលពន្ធដារ និងមិនមែនពន្ធដារ) និងការធ្វើឱ្យប្រសើរឡើងក្នុងការងារអភិបាលកិច្ច
- ចំណាយសរុបសំរាប់ផែនការការងារ យ.ជ.ក.ភ ក្នុងរយៈពេល ៣ឆ្នាំ ២០០៣-២០០៥ ត្រូវបានប៉ាន់ស្មានក្នុងតំលៃប្រហែល ១,៥៣ពាន់ លានដុល្លា។ រដ្ឋាភិបាលត្រូវចំណាយយ៉ាងតិច ៥០០លានដុល្លាក្នុងមួយឆ្នាំដើម្បីសំរេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។ ការចំណាយដែលបានគ្រោងទាំងនេះនឹងត្រូវទទួលការគាំទ្រជាហិរញ្ញប្បទានពីប្រភពថវិកាផ្ទាល់របស់រាជរដ្ឋាភិបាល (២៣០ លានដុល្លា) ការវិនិយោគផ្ទាល់ពីបរទេស (២៥០ លានដុល្លា) និងជំនួយឧបត្ថម្ភពីបរទេស (១,០៨ពាន់លានដុល្លា)
- រដ្ឋាភិបាលគ្រោងចំណាយលើសពី ១.០០០ លានដុល្លាក្នុងរយៈពេល ៣ឆ្នាំដើម្បីពង្រីកកាលានុវត្តន៍ភាពការងារ និងពង្រឹងសមត្ថភាពរបស់អ្នកក្រីក្រដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យសុខាភិបាល និងអប់រំ។
- ដើម្បីបង្កើនកាលានុវត្តភាព យ.ជ.ក.ភ បានស្នើឱ្យមានការវិនិយោគបន្ថែមទៅក្នុងវិស័យថាមពលដែលមួយចំណែកអាចទទួលបានពីការឧបត្ថម្ភហិរញ្ញប្បទានពីវិស័យឯកជនតាមរយៈគំរោង BOT ។ យ.ជ.ក.ភ ស្នើអោយមានការចំណាយចំនួន ២១៦ លានដុល្លាលើ ក្នុងការបង្កើនកាលានុវត្តន៍ភាពប្រាក់ចំណូល ជាពិសេសលើគំរោងសាងសង់ផ្លូវ និងការដឹកជញ្ជូន។
- លើសពីនេះរដ្ឋាភិបាលគ្រោងចំណាយ ១០២ លានដុល្លា និង ១៧៤លានដុល្លា ទៅលើការពង្រឹងស្ថាប័ន និងអភិបាលកិច្ចល្អព្រមទាំងការកាត់បន្ថយភាពងាយរងគ្រោះ។

## ៦. ការតាមដាន និងការវាយតំលៃ

ការតាមដាន និងការវាយតំលៃ និងសកម្មភាពបណ្តុះបណ្តាលសមត្ថភាពដែលទាក់ទងទៅនឹងភាពក្រីក្រ ការវិភាគផលប៉ះពាល់ដល់សង្គមកិច្ចគឺជាផ្នែកមួយដ៏សំខាន់នៃការងាររបស់ យ.ជ.ក.ភ ។ សកម្មភាពទាំងអស់នេះមានលក្ខណៈចាំបាច់ប្រសិនបើត្រូវកែប្រែ និងធ្វើអោយប្រសើរឡើងនូវឯកសារ យ.ជ.ក.ភ និងបង្កើតឱ្យបានមូលដ្ឋានមួយដែលមានលក្ខណៈចីរភាព ។ ក្របខ័ណ្ឌស្ថាប័នសំរាប់ការវិភាគ និងការតាមដានភាពក្រីក្រត្រូវបានបង្កើតឡើងនៅដើមឆ្នាំ ២០០២។

កិច្ចដំណើរការតាមដាន និងវាយតំលៃ យ.ជ.ក.ភ និងធ្វើឱ្យមានការចូលរួមពីសំណាក់ក្រុមអ្នករួមចំណែកទាំងអស់។ ការចូលរួមនេះនឹងត្រូវបំពេញបន្ថែមដោយការកំណត់បញ្ជាក់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវផ្នែក ស្ថាប័ននៃអង្គភាពថ្នាក់ជាតិ និងអង្គភាពរដ្ឋបាលថ្នាក់មូលដ្ឋានដែលប្រកបដោយតំលាភាព។ អ្នករួមចំណែកទាំងអស់នឹងមានលទ្ធភាពសេរីក្នុងការប្រើប្រាស់ទាំងពតិមានពីរៈពតិមានដំបូង និងពតិមានហិរញ្ញវត្ថុ និងទិន្នន័យ ដែលពួកគេត្រូវការដើម្បីបំពេញតួនាទីភារកិច្ចរបស់ពួកគេ ។

កិច្ចដំណើរការតាមដាន និងវាយតំលៃក៏ទាមទារឱ្យមានការបង្កើត និងការពង្រឹងនូវសមត្ថភាពរបស់ស្ថាប័នដែលពាក់ព័ន្ធផងដែរ។

- ក្រសួងផែនការគឺជាស្ថាប័នស្នូលដែលទទួលខុសត្រូវក្នុងការសំរបសំរួលកិច្ចការងារតាមដានរបស់ យ.ជ.ក.ភ។
- នៅក្នុងក្រសួងផែនការវិជ្ជាស្ថានជាតិស្ថិតិទទួលខុសត្រូវក្នុងការរៀបចំ និងដឹកនាំការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច រីឯអគ្គនាយកដ្ឋានផែនការទទួលលើការវិភាគគោលនយោបាយ។
- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចទទួលខុសត្រូវក្នុងការជំរុញ សំរបសំរួលតាមដានការរៀបចំគោលនយោបាយព្រមទាំងកម្មវិធីដែលពាក់ព័ន្ធគោលដៅកាត់បន្ថយភាពក្រីក្រ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចមានសមាជិក ១៤ រូបដែលជារដ្ឋលេខាធិការរបស់ក្រសួងនានា។ នៅពេលអនាគតនឹងមានសមាជិក ៩ រូបបន្ថែមទៀតដែលតំណាងអោយក្រសួង ៨ ដ៏ទៃទៀតព្រមទាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ក៏នឹងត្រូវចូលរួមនៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច។
- ការិយាល័យបច្ចេកទេសវិភាគ និងតាមដានភាពក្រីក្រគឺជាសាខាស្រាវជ្រាវរបស់លេខាធិការដ្ឋានសំរាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ហើយការិយាល័យនេះនឹងសំរបសំរួលពីការប្រមូល និងវិភាគទិន្នន័យព្រមទាំងជួយពង្រឹងសមត្ថភាពនៅថ្នាក់ជាតិក្នុងការប្រមូល និងការវិភាគទិន្នន័យ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងត្រួតពិនិត្យការអនុវត្តន៍ និងការប្រតិបត្តិថវិកានៃក្របខ័ណ្ឌរយៈពេលមធ្យមនៃការចំណាយ (MTEF) ពោលគឺនៅក្នុងការតាមដានថាតើថវិកាហិរញ្ញវត្ថុដែលត្រូវការចាំបាច់បានផ្តល់ឱ្យទៅដល់ក្រសួងជំនាញនានាដើម្បីឱ្យក្រសួងទាំងអស់នោះអាចអនុវត្តន៍សកម្មភាពសាធារណៈជាអាទិភាពបានដែរឬទេ
- ក្រសួងជំនាញនានា និងស្ថាប័នរដ្ឋាភិបាលដ៏ទៃទៀតទទួលខុសត្រូវក្នុងការអនុវត្តន៍ SEDP២ និង យ.ជ.ក.ភ នៅក្នុងវិស័យ របស់ក្រសួងជំនាញរៀងៗខ្លួន និងត្រូវចូលរួមនៅក្នុងការអនុវត្តន៍ការតាមដានអំពីប្រតិបត្តិការងាររបស់ពួកគេទាក់ទងទៅនឹងបរិក្ខារតំរូវការ និងលទ្ធផលផលិតផល ព្រមទាំងទទួលខុសត្រូវក្នុងការប្រមូល និងរក្សាទុកនូវទិន្នន័យដែលត្រូវការចាំបាច់
- ក្រសួងជំនាញសំខាន់ ៤ ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលឱ្យមានតួនាទីជាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រដោយរួមមានៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងអភិវឌ្ឍន៍ជនបទ ។ ក្រសួងគន្លឹះទាំងអស់នេះបានបង្កើតក្រុមការងាររបស់ខ្លួនដើម្បីបង្កើត និងពង្រឹងអង្គភាពបច្ចេកទេសរបស់ខ្លួននៅក្នុងការងារតាមដានការអនុវត្តន៍ផ្ទាល់របស់ក្រសួង ការប្រមូលទិន្នន័យ និងការងារជាមួយ GSCSD ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តន៍ យ.ជ.ក.ភ ។
- លើមូលដ្ឋានយុទ្ធសាស្ត្រជារួម ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងវាយតំលៃទៅលើប្រសិទ្ធភាពនៃ យ.ជ.ក.ភ និងផ្តល់នូវអនុសាសន៍កែតំរូវចាំបាច់ទៅជូននាយករដ្ឋមន្ត្រី។

- រដ្ឋសភា និងព្រឹទ្ធសភានឹងមានតួនាទីទទួលខុសត្រូវក្នុងការពិនិត្យតាមដានការរីកចំរើននៃការអនុវត្តន៍ យ.ជ.ក.ភ និងផ្តល់នូវយោបល់ឆ្លើយតបក៏ដូចជាអនុសាសន៍ក្នុងការកែតំរូវចាំបាច់សំរាប់ យ.ជ.ក.ភ ដែរ។ រដ្ឋសភា និងព្រឹទ្ធសភានឹងចូលរួមផងដែរនៅក្នុងកិច្ចប្រជុំ និងអង្គសិក្ខាសាលា និងវេទិកាភាពក្រីក្រថ្នាក់ជាតិដែលរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និង GSCSD ។
- ក្រុមប្រឹក្សាឃុំសង្កាត់ និងសង្គមស៊ីវិលនឹងមានតំណាងនៃក្រុមអ្នកទទួលផល ដែលនឹងផ្តល់ឱ្យនូវចំលើយតប នានាក៏ដូចជាប្រភពនៃការផ្តល់សញ្ញានៅក្នុងប្រព័ន្ធជូនដំបូន្មានដំបូងក្នុងការអនុវត្តន៍ យ.ជ.ក.ភ ។ ក្រុមប្រឹក្សាឃុំសង្កាត់ និងសង្គមស៊ីវិលក៏ចូលរួមផ្តល់ផងដែរនូវពត៌មានពីគ្រោះធម្មជាតិ។
- អង្គការក្រៅរដ្ឋាភិបាលរួមមានអង្គការជាតិ និងអង្គការអន្តរជាតិនឹងត្រូវចូលរួមជាដៃគូរនៅក្នុងការតាមដាន និងវាយតំលៃ យ.ជ.ក.ភ ។ បន្ថែមពីលើការផ្តល់ជាយោបល់ស្តីអំពីលទ្ធផលនៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច និងការតាមដានការរីកចំរើននៃការអនុវត្តន៍ យ.ជ.ក.ភ អង្គការក្រៅរដ្ឋាភិបាលនឹងត្រូវផ្តល់ជាពត៌មានដែលមានប្រយោជន៍ និងទិន្នន័យផ្សេងៗអំពីការសិក្សានៅថ្នាក់ទាបរបស់ពួកគេ និងការសិក្សាវាយតំលៃ។
- រាជរដ្ឋាភិបាលកម្ពុជាផ្តោតការយកចិត្តទុកដាក់លើវិស័យឯកជន តាមរយៈអង្គការនានាដូចជាសភាពាណិជ្ជកម្ម និងសហជីព ក៏ដូចជាសហព័ន្ធកម្មករ និងមានតួនាទីជាសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រជាពិសេសក្នុងការបង្កើតការងារ។
- ចុងក្រោយបំផុតប្រព័ន្ធសារពត៌មាននឹងមានតួនាទីជាគន្លឹះក្នុងការតាមដានភាពក្រីក្រ។ ប្រព័ន្ធសារពត៌មាននឹងអាចមានលទ្ធភាពផ្តល់ពត៌មានជាប្រចាំអំពីការរីកចំរើន និងបញ្ហាដែលបានជួបប្រទះនៅក្នុងការអនុវត្តន៍ យ.ជ.ក.ភ ក៏ដូចជាឥទ្ធិពលភ្លាមៗដែលកើតមានឡើងអំពីការអនុវត្តន៍ យ.ជ.ក.ភ ដែរ។

## ការតាមដាន យជកភ និងសូចនាករ

ការតាមដានអំពីការរីកចំរើនប្រចាំឆ្នាំឆ្ពោះទៅរកគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ យ.ជ.ក.ភ គឺជាកត្តាគន្លឹះសំរាប់កិច្ចដំណើរការ យ.ជ.ក.ភ ។ សូចនាករក៏ដូចជាគោលដៅសមស្របនានា សំរាប់សកម្មភាពសាធារណៈជាអាទិភាពនៅក្នុង យ.ជ.ក.ភ នឹងត្រូវរៀបចំឡើងជាលំអិតតាមភេទ ហើយបើសិនជាអាចធ្វើទៅបាន នឹងត្រូវធ្វើអោយស៊ីសង្វាក់ជាមួយនឹងសូចនការនៅក្នុងឯកសារផែនការគន្លឹះរបស់រាជរដ្ឋាភិបាល (SEDP2, MTEF) ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្ស រយៈពេលវែងផងដែរ។

សូចនាករសំរាប់ការតាមដាន និងវាយតំលៃ យ.ជ.ក.ភ ដូចដែលបានបង្ហាញជូននៅក្នុងតារាងផែនការសកម្មភាព និងក្របខ័ណ្ឌការងារតាមដាន និងវាយតំលៃត្រូវបានជ្រើសរើសឡើងដោយផ្អែកលើមូលដ្ឋាន:

- ធនធានដែលទទួលបានពីប្រភពរបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ
- លទ្ធភាពផ្តល់សេវារបស់ស្ថាប័ន
- រយៈពេលកំណត់របស់ យ.ជ.ក.ភ
- លក្ខណៈដែលអាចវាស់ស្ទង់ និងតាមដានបាន
- ភាពឆ្លើយតបទៅនឹងភាពក្រីក្ររបស់សូចនាករ
- ពត៌មានគោល
- សមត្ថភាពរបស់ស្ថាប័នជំនាញនៅក្នុងការប្រមូល ការក្សា និងការវិភាគពត៌មានដែលពាក់ព័ន្ធ។

របាយការណ៍រីកចំរើនប្រចាំឆ្នាំស្តីអំពីការអនុវត្តន៍នៃ យ.ជ.ក.ភ និងត្រូវរៀបរៀងឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច។

## ៧. សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់

យ.ជ.ក.ភ បានចែងនូវអាទិភាពគន្លឹះ៧សំរាប់កម្ពុជាដើម្បីអនុវត្តន៍ក្នុងរយៈពេល ៣ ឆ្នាំខាងមុខដើម្បីសំរេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ យ.ជ.ក.ភ បានសំរេចយកនូវវិធានគ្រប់ជ្រុងជ្រោយមួយដែលគូសបង្ហាញអំពីសកម្មភាពនិយមអ្នកក្រីក្រដើម្បីធ្វើឱ្យប្រសើរនូវជីវភាពនៅជនបទ លើកស្ទួយកាលានុវត្តន៍ភាពការងារ ធានាឱ្យបានសុខភាពល្អប្រសើរ អាហារូបត្ថម្ភ និងការអប់រំល្អ និងការកាត់បន្ថយភាពងាយរងគ្រោះ ។

រដ្ឋាភិបាលបានគិតថាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកក្រោយ និង យ.ជ.ក.ភ ត្រូវតែដាក់បញ្ចូលគ្នានិងរៀបរាងឡើងក៏ដូចជា បង្ហាញចេញជាឯកសាតែមួយនៅឆ្នាំ ២០០៥ ដោយរៀបចំឡើងផ្អែកលើជោគជ័យ និងមេរៀនជាបទពិសោធន៍ដែលបានទទួលតាមរយៈនៃកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នក្នុងការកាត់បន្ថយភាពក្រីក្រ ដែលត្រូវចាត់ចែងដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច។ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នឹងអនុវត្តន៍តួនាទីរបស់ខ្លួនស្របទៅតាមសមត្ថកិច្ចរបស់ខ្លួនដែលត្រូវផ្តល់ការឧបត្ថម្ភគាំទ្រទៅជូននាយករដ្ឋមន្ត្រី នៅក្នុងផ្នែករៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយ ដើម្បីចូលរួមវិភាគទានទៅក្នុងការងារ យ.ជ.ក.ភ ២ ដែលទាក់ទងទៅនឹងការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយរួម។ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចនឹងចាត់ចែងនូវការតាមដានអំពីសកម្មភាពប្រតិបត្តិ និងការអនុវត្តន៍ កិច្ចដំណើរការពិគ្រោះយោបល់ដែលនឹងធានាបានថា យ.ជ.ក.ភ នៅតែបន្តការងារដែលមានលក្ខណៈចូលរួមជាសាធារណៈនៅក្នុងការរៀបចំក៏ដូចជាការអនុវត្តន៍។

# មាតិកា


អារម្ភកថា ..... i

ខ្លឹមសារសង្ខេប ..... ii

មាតិកា ..... xiii

បញ្ជីតារាង ..... xv

បញ្ជីតួលេខ ..... xvi

ពាក្យកាត់ ..... xvii

ជំពូក ១: ចក្ខុវិស័យសំរាប់ការកាត់បន្ថយភាពក្រីក្រ ..... 1

ជំពូក ២: ដំណើរការនៃការចូលរួម ..... 5

២.១ សេចក្តីផ្តើម ..... 5

២.២ មេរៀនពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ និង ឯកសារបឋមនៃយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្រ ..... 6

២.៣ រចនាសម្ព័ន្ធសំរាប់ការចូលរួម: ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និងអគ្គលេខាធិការដ្ឋាន និងយន្តការពិគ្រោះយោបល់ ..... 7

៣.២.១ ការទាក់ទាញអ្នករួមចំណែក: ដំណើរការចូលរួម ..... 7

សិក្ខាសាលាជាតិ ..... 7

កិច្ចប្រជុំក្រុមពិគ្រោះយោបល់ មិថុនា ២០០២ ..... 8

វិស័យ និង បណ្តាក្រសួង ..... 8

ការពិគ្រោះយោបល់ថ្នាក់ខេត្ត ..... 9

ការពិគ្រោះយោបល់ជាមួយអ្នកក្រ ..... 9

វេទិកាលើការតាមដាន យជកក ..... 10

២.៣.២ អ្នករួមចំណែកសង្គមស៊ីវិល: ការចូលរួមនៃអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងម្ចាស់ជំនួយក្នុង យជកក ..... 10

វេទិកាអង្គការមិនមែនរដ្ឋាភិបាល ..... 10

វិស័យឯកជន ..... 11

ការពាក់ព័ន្ធនៃម្ចាស់ជំនួយ ..... 11

សមាជិកសភា ..... 11

សហជីព ..... 12

ប្រព័ន្ធពត៌មាន ..... 12

ជំនួយមូលនិធិ យជកក ..... 12

២.៤ សន្និដ្ឋាន ..... 13

ជំពូក ៣: ទំហំនៃភាពក្រីក្រ ..... 14

៣.១ ពហុទំហំនៃភាពក្រីក្រ ..... 14

៣.១.១ កង្វះកាលានុវត្តភាព ..... 15

៣.១.២ កង្វះសមត្ថភាព ..... 16

៣.១.៣ ការស្ថិតនៅក្រៅសង្គម ..... 22

៣.១.៤ កង្វះអភិបាលកិច្ចល្អ ..... 23

៣.១.៥ ភាពងាយទទួលរងគ្រោះ ..... 26

៣.២ និយមន័យនៃភាពក្រីក្រចំណូល/ចំណាយ ..... 32

៣.២.១ បន្ទាត់ភាពក្រីក្រ ..... 33

៣.២.២ សន្ទស្សន៍ភាពក្រីក្រ ..... 33

៣.៣ ការប៉ាន់ស្មាន ភាពក្រីក្រចំណូល/ចំណាយ ..... 35

៣.៤ គំលាតយេនឌ័រ ..... 38

ជំពូក ៤: សកម្មភាពកាត់បន្ថយភាពក្រីក្រជាអាទិភាព ..... 42

៤.១ ការជំរុញកាលានុវត្តភាព ..... 44

៤.១.១ ការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ... 44
៤.១.២ ការកែលំអជីវភាពរស់នៅតាមជនបទ ... 56
កែលំអការកាន់កាប់ដីធ្លី ... 57
ការអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងបុព្វបទនៃការកាត់បន្ថយភាពក្រីក្រ... 59
ជំរុញចលនាភូមិមួយ ផលិតផលមួយ ... 68
ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព និងការដោះទឹក ... 69
ផ្លូវថ្នល់ និងការដឹកជញ្ជូន... 75
៤.២ ការពង្រីកកាលានុវត្តភាពការងារ ... 80
៤.២.១ ការអភិវឌ្ឍន៍ផ្នែកឯកជន... 80
៤.២.២ ការអភិវឌ្ឍន៍ពាណិជ្ជកម្ម... 82
៤.២.៣ ការអភិវឌ្ឍន៍ទេសចរណ៍ ... 87
៤.២.៤ ប្រៃសណីយ៍ និងទូរគមនាគមន៍... 91
៤.២.៥ មីក្រូហិរញ្ញវត្ថុ... 93
៤.២.៦ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ... 95
៤.២.៧ ការអភិវឌ្ឍន៍ឧស្សាហកម្ម ... 96
៤.២.៨ ការអភិវឌ្ឍន៍ទីក្រុង ... 98
៤.៣ លើកកំពស់សមត្ថភាព ... 104
៤.៣.១ សុខាភិបាល ... 105
៤.៣.២ អាហារូបត្ថម្ភ ... 109
៤.៣.៣ អប់រំ ... 111
៤.៣.៤ ទឹកស្អាត និងអនាម័យ ... 115
៤.៤ ពង្រឹងសមត្ថភាពស្ថាប័ន និងកែលំអអភិបាលកិច្ច... 116
៤.៤.១ កំណែទំរង់វិស័យតុលាការ ... 117
៤.៤.២ កំណែទំរង់រដ្ឋបាល និងមុខងារសាធារណៈ ... 121
កំណែទំរង់បៀវត្ស... 126
យុទ្ធសាស្ត្រ ... 127
៤.៤.៣ កម្មវិធីវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន ... 129
៤.៤.៤ ការប្រឆាំងអំពើពុករលួយ ... 134
៤.៥ ការកាត់បន្ថយភាពងាយរងគ្រោះ និងការពង្រឹងការចូលក្នុងសង្គម... 138
៤.៥.១ សន្តិសុខស្បៀង... 139
៤.៥.២ កិច្ចការពារសង្គម និងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស... 141
៤.៥.៣ ជំងឺហ៊ីវ/អេដស៍... 143
៤.៥.៤ ការគ្រប់គ្រងគ្រោះមហន្តរាយ ... 145
៤.៥.៥ សកម្មភាពកំចាត់មីនៈ សកម្មភាពដែលប្រឆាំងទៅនឹងគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ... 147
៤.៥.៦ ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានដោយនិរន្តរភាព ... 151
៤.៥.៧ ជនជាតិភាគតិច ... 153
៤.៦ បង្កើតសមធម៌យេនឌ័រ... 154

ជំពូក ៥: តំរូវការ និង ការគ្រប់គ្រងធនធានសាធារណៈ... 156
៥.១ ការគៀងគរចំណូល... 156
៥.២ តំរូវការប៉ាន់ស្មាន និងគម្រោងបែងចែកថវិកា ... 158
៥.៣ វិធានការកែលំអការគ្រប់គ្រងថវិកា (ការអនុវត្តន៍ និងការបើកផ្តល់ថវិកា)... 168
៥.៤ ចំណងទាក់ទងរវាង យជកអ ទៅនឹងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយសាធារណៈ រយៈពេលមធ្យម ... 172

ជំពូក ៦: ការតាមដាន និងការវាយតំលៃ ... 182
៦.១ ការរៀបចំស្ថាប័នសំរាប់តាមដាន និងវាយតំលៃ ... 182
៦.១.១ ក្រសួងផែនការ... 183

៦.១.២ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ..... 184
៦.១.៣ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ..... 184
៦.១.៤ អង្គភាពបច្ចេកទេសតាមដាននិងវិភាគភាពក្រីក្រ ..... 185
៦.១.៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ..... 185
៦.១.៦ បណ្ដាក្រសួង ..... 185
៦.១.៧ បណ្ដាក្រសួងសំខាន់ ..... 185
៦.១.៨ រដ្ឋសភា/ព្រឹទ្ធសភា ..... 186
៦.១.៩ ក្រុមប្រឹក្សាឃុំសង្កាត់ និងសង្គមស៊ីវិល ..... 186
៦.១.១០ អង្គការមិនមែនរដ្ឋាភិបាល ..... 186
៦.១.១១ ដៃគូអភិវឌ្ឍន៍ ..... 186
៦.១.១២ ប្រព័ន្ធព័ត៌មាន ..... 186
៦.២ ការតាមដាន យជកក ..... 187
៦.២.១ សូចនាករ យជកក ..... 187
៦.២.២ ចំណុចដៅ យជកក ..... 188
៦.៣ ការវាយតំលៃផលប៉ះពាល់ភាពក្រីក្រ ..... 188
៦.៤ របាយការណ៍រីកចំរើនប្រចាំឆ្នាំនៃការអនុវត្តន៍ ..... 189
៦.៥ បញ្ហាប្រឈមសំរាប់ការតាមដាន និងវាយតំលៃ យជកក ..... 189

ជំពូក៧: សន្និដ្ឋាន និង ជំហានបន្ត ..... 199

ឧបសម្ព័ន្ធ១: ផែនទីភាពក្រីក្រនៃកម្ពុជា ..... 201
ឧបសម្ព័ន្ធ២: ការប៉ាន់ស្មានការវាស់ភាពក្រីក្រថ្នាក់ខេត្ត ..... 202
ឧបសម្ព័ន្ធ៣: ម៉ាទ្រីសផែនការសកម្មភាព ..... 204
ឧបសម្ព័ន្ធ៤: គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ..... 285


# បញ្ជីតារាង


តារាង ១.១ គោលដៅសំរាប់ការកាត់បន្ថយភាពក្រីក្រ ..... 4
តារាង ៣.១ ចំនួនបុគ្គលិកតាមវិស័យសេដ្ឋកិច្ច ..... 16
តារាង ៣.២ ការប្រៀបធៀបសូចនាករគន្លឹះនៃការអភិវឌ្ឍន៍មនុស្សក្នុងកម្ពុជា និងតំបន់ប៉ាស៊ីហ្វិកខាងលិច ១៩៩៨ ..... 16
តារាង ៣.៣ មូលហេតុនៃការបោះបង់សាលា ..... 21
តារាង ៣.៤ តំលៃរូបិយវត្ថុនៃបន្ទាត់ភាពក្រីក្រ ..... 33
តារាង ៣.៥ សន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រ ..... 34
តារាង ៣.៦ តំលៃមធ្យម និងអត្រាចំណាយលើទំនិញប្រើប្រាស់ប្រចាំគ្រួសារ ..... 36
តារាង ៣.៧ ជំរើសសូចនាករនៃភាពក្រីក្រ ..... 37
តារាង ៤.១ វិធីជាសង្ខេបនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ២០០២-២០០៥ ..... 42
តារាង ៤.២ កម្ពុជា: សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ២០០០-២០០៧ ..... 49
តារាង ៤.៣: កម្ពុជា: ផែនការសារពើពន្ធរយៈពេលមធ្យម ២០០៣-២០០៥ ..... 54
តារាង ៤.៤ ការប្រមាណចំនួនប្រជាជនរបស់ក្រុងភ្នំពេញរាប់បញ្ចូលទាំងអ្នកក្រុងក្រីក្រ ..... 103
តារាង ៤.៥ សំណើរបស់រាជរដ្ឋាភិបាល ដើម្បីផ្ទេរទៅឱ្យឃុំ-សង្កាត់ ឆ្នាំ ២០០១-២០០៥ ..... 133
តារាង ៥.១ កំណើនមាណភាគ នៃក្រសួងអាទិភាព ដែលមានការធ្លាក់ចុះផ្នែកការពារ និងសន្តិសុខ ..... 162
តារាង ៥.២ ចំណាយថវិកាតាមក្រសួង ឆ្នាំ ១៩៩៩-២០០៣ ..... 163
តារាង ៥.៣ តំលៃ យជកក នៃផែនការសកម្មភាពឆ្នាំ ២០០៣-២០០៥ ..... 166
តារាង ៥.៤ ចំណាយសរុប និងកំរិតអតិបរមានៃវិភាជន៍ ..... 174
តារាង ៥.៥ ការបែងចែកតាមវិស័យ និងក្រសួងអាទិភាព ..... 174
តារាង ៥.៦ ហិរញ្ញប្បទានរដ្ឋាភិបាលសំរាប់វិស័យអប់រំ ២០០១-២០០៥ ..... 175

តារាង ៥.៧ គោលដៅ និងសន្ទស្សន៍ដែលបានសំរេចដោយជ្រើសរើស ឆ្នាំ ២០០៣-២០០៥ ..... 176
តារាង ៥.៨ ថវិកាចរន្តរដ្ឋាភិបាលសំរាប់ឆ្នាំសារពើពន្ធ ២០០៣-២០០៥ (សុខាភិបាល) ..... 177
តារាង ៦.១ សូចនាករប្រើប្រាស់សំរាប់តាមដាននិងវាយតម្លៃយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ ..... 191

## បញ្ជីតួលេខ

រូបភាព ១ ក្រុមដែលទទួលអាំងស៊ីដង់ផលចំណេញ ..... 105
រូបភាព ២ ការបែងចែកមូលនិធិរបស់ឃុំសង្កាត់ ..... 180
រូបភាព ៣ ការរៀបចំស្ថាប័នសំរាប់តាមដាននិងវាយតំលៃភាពក្រីក្រ ..... 183

## បញ្ជីប្រអប់

ប្រអប់ទី ១: កូនអ្នកក្រ និងឱកាសសំរាប់សិក្សា ..... 21
ប្រអប់ទី ២: តើពេលណាទើបដឹងថាអំពើពុករលួយលេចឡើងក្នុងប្រទេសកម្ពុជា? ..... 25
ប្រអប់ទី ៣: តើការចំណាយលើអំពើពុករលួយចំពោះប្រទេសកម្ពុជាមានតំលៃប៉ុន្មាន? ..... 26
ប្រអប់ទី ៤: អ្នកក្រ និងគ្រោះធម្មជាតិ ..... 30
ប្រអប់ទី ៥: តើសន្ទស្សន៍ភាពក្រីក្រ (HCI) មួយណាគួរត្រូវប្រើ? ..... 34
ប្រអប់ទី ៦: បញ្ហាប្រឈមផ្នែកប្រជាជន ..... 44
ប្រអប់ទី ៧: ការវិភាគស្ថេរភាពបំណុល ..... 51
ប្រអប់ទី ៨: គណៈកម្មការអភិវឌ្ឍន៍ភូមិ និងការចែករំលែកអំណាចទៅអោយរដ្ឋបាលមូលដ្ឋាន ..... 131
ប្រអប់ទី ៩: ការទាក់ទងរវាងយុទ្ធសាស្ត្រតាមផ្នែកជាមួយថវិកា និង MTEF ករណីផ្នែកអប់រំ ..... 159
ប្រអប់ទី ១០: កម្មវិធីពន្លឿនការអភិវឌ្ឍន៍ថ្នាក់ស្រុក និងផែនការសកម្មភាពអាទិភាព ..... 169

# ពាក្យកាត់

| | |
|---|---|
| ACHR | សហគមន៍ពលកម្មអាស៊ានដើម្បីសិទ្ធិផ្ទះសំបែង |
| ACO | មន្ត្រីកិច្ចសហប្រតិបត្តិការកសិកម្ម |
| ACT | កិច្ចព្រមព្រៀងស្តីពីសំលៀកបំពាក់ និងវាយនភ័ណ្ឌ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADD | ល្បឿននៃការអភិវឌ្ឍន៍ថ្នាក់ស្រុក |
| AE | ប្រសិទ្ធភាពនៃការបែងចែក |
| AEA | ការវិភាគប្រព័ន្ធអាគ្រូ-អេកូ |
| AFD | ចង្កោមនៃបែបបទសារពើពន្ធ |
| AIT | វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ាន |
| ANC/AN | ការថែរក្សាគភ៌ |
| APIP | គំរោងបង្កើនផលិផលកសិកម្ម |
| AUSAID | ភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍សហប្រជាជាតិ |
| BMI | សន្ទស្សន៍បឌីមាស |
| bn | ពាន់លាន |
| cal | កាឡូរី |
| CAP | សហគមន៍ផែនការសកម្មភាព |
| CAR | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| CC | ក្រុមប្រឹក្សាភូមិ |
| CCC | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDC | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| CDMC | គណៈកម្មាធិការគ្រប់គ្រង-អភិវឌ្ឍន៍ភូមិ |
| CDRI | វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CF | ឥណទានភូមិ |
| CFB | ក្រុមប្រឹក្សាឥណទានភូមិ |
| CG | ក្រុមពិគ្រោះយោបល់ |
| CGA | ភ្នាក់ងារកិច្ចសហប្រតិបត្តិការណែនាំ |
| CIDA | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា |
| CL&JR | ក្រុមប្រឹក្សាកំណែទំរង់ច្បាប់-តុលាការ |
| CLP | ក្រុមប្រឹក្សាកំណែទំរង់គោលនយោបាយដីធ្លី |
| CMAA | អាជ្ញាធរមីនកម្ពុជា |
| CMAC | មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា |
| COM | ក្រុមប្រឹក្សារដ្ឋមន្ត្រី |
| CSD | ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |

| | |
|---|---|
| CSES | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| CSO | អង្គការសមាគមន៍ស៊ីវិល |
| DAHP | នាយកដ្ឋានបសុពេទ្យ និងផលិតកម្ម |
| DANIDA | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| DFID | នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ |
| DFW | នាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ |
| DHS | អង្កេតសង្គមកិច្ច និងសុខភាព |
| DOF | នាយកដ្ឋានជលផល |
| DPSIC | នាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ |
| EFA | ការអប់រំទាំងអស់គ្នា |
| EPZ | ការនាំចេញក្នុងតំបន់ |
| ESIA | បរិដ្ឋាន និងផលប៉ះទង្គិចដល់សង្គម |
| ESSP | កម្មវិធីទ្រទ្រង់វិស័យអប់រំ |
| EU | សហគមន៍អឺរ៉ុប |
| EW | បង្កើនកំលាំងកម្មករ |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម |
| FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| FFS | សាលាកសិករ |
| FPL | បន្ទាត់ភាពក្រីក្រនៃស្បៀងអាហារ |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក |
| FX | ប្រាក់បំរុងបរទេស |
| g | រង្វាស់ជាក្រាម |
| GA | រដ្ឋបាលទូទៅ |
| GAP | ផែនការសកម្មភាពរបស់រដ្ឋាភិបាល |
| GDP | ផលិផលក្នុងស្រុកសរុប |
| GSCSD | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |
| HCI | សន្ទស្សន៍រាប់ |
| HRMIS | ប្រព័ន្ធគ្រប់គ្រងពត៌មានធនធានមនុស្ស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IMTC | គណៈកម្មាធិការបច្ចេកវិទ្យាតាមក្រសួងនានា |
| IO | អង្គការអន្តរជាតិ |
| IPM | ការគ្រប់គ្រងជំងឺប៉េស |
| IPRSP | ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្របណ្តោះអាសន្ន |
| IQ | កូតាអ៊ីនធើលីចិន |
| IT | បច្ចេកវិទ្យាពត៌មាន |
| JICA | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| kg | រង្វាស់ទំងន់ គិតជាគីឡូក្រាម |
| kV | គីឡូវ៉ាត់ |

| | |
|---|---|
| LD | ការអភិវឌ្ឍន៍មូលដ្ឋាន |
| LTU | អង្គភាពបង់ពន្ធធំ |
| M&E | តាមដាន និងវាយតំលៃ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MAG | ក្រុមផ្តល់យោបល់មីន |
| MDG | ការអភិវឌ្ឍន៍សហស្សវត្ស |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFI | វិទ្យាស្ថានឥណទានជនបទ |
| MFN | ប្រទេសមានការលើកទឹកចិត្ត |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MLMUPC | ក្រសួងគ្រប់គ្រងដែនដី ផែនការ និងសំណង់ |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOE | ក្រសួងបរិដ្ឋាន |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| MOJ | ក្រសួងយុត្តិធម៌ |
| MOP | ក្រសួងផែនការ |
| MOSALVY | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវ និងយុវជន |
| MOT | ក្រសួងទេសចរណ៍ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MOWVA | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| MPP | សាលាក្រុងភ្នំពេញ |
| MPTC | ក្រសួងប្រៃសណីយ និងទូរគមនាគមន៍ |
| MPWT | ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| mt | ម៉ែត្រទ្រីកតោន |
| MTBF | គំរោងថវិការយៈពេលមធ្យម |
| MTEF | គំរោងចំណាយរៈពេលមធ្យម |
| MTFF | គំរោងសារពើពន្ធរយពេលមធ្យម |
| MTU | អង្គភាពពន្ធដារមធ្យម |
| NAA | អាជ្ញាធរជាតិកំចាត់ជំងឺអេដស៍ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| NCSC | គណកម្មាធិការគ្រប់គ្រងភូមិ |
| NFE | ការអប់រំក្រៅផ្លូវការ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NPAR | កម្មវិធីកំណែទំរង់រដ្ឋបាលជាតិ |
| NPFS | កម្មវិធីសន្តិសុខស្បៀងអាហារថ្នាក់ជាតិ |

| | |
|---|---|
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| NTFP | ផលិតផលមិនធ្វើពីឈើ |
| OD | ប្រតិបត្តិស្រុក |
| OE | ប្រតិបត្តិប្រកបដោយប្រសិទ្ធភាព |
| OPL | បន្ទាត់នៃភាពក្រីក្រជាទូទៅ |
| PADEK | ភាគីដើម្បីអភិវឌ្ឍន៍កម្ពុជា |
| PAP | កម្មវិធីសកម្មភាពជាអាទិភាព |
| PER | ការត្រួតពិនិត្យការចំណាយសាធារណៈ |
| PFO | ការិយាល័យរុក្ខាប្រមាញ់ខេត្ត |
| PGI | គំលាតនៃភាពក្រីក្រ |
| PIP | កម្មវិធីវិនិយោគសាធារណៈ |
| PMATU | អង្គភាពបច្ចេកទេសត្រួតពិនិត្យ និងវិភាគភាពក្រីក្រ |
| PMG | ក្រុមបេសកម្មអាទិភាព |
| POLA | នាយកដ្ឋានរដ្ឋបាលមូលដ្ឋានខេត្ត |
| PPA | ការចូលរួមដំណើរការនៃភាពក្រីក្រ |
| PRDC | ការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្ត |
| PSI | ការត្រួតពិនិត្យមុនដឹកជញ្ជូន |
| PTP | កម្មវិធីការងារភាពក្រីក្រ |
| R&R | ច្បាប់ និងបទបញ្ជា |
| RCAF | កងយុទ្ធពលខេមរភូមិន្ទ |
| RDB | ធនាគារអភិវឌ្ឍន៍ជនបទ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SAO | ក្រុមអាស៊ានខាងត្បូងឈាងខាងកើត |
| SCSR | ក្រុមប្រឹក្សាកំពូលដើម្បីកំណែទំរង់ |
| SEDP2 | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី ២ |
| SIDA | ភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SME | សហគ្រាសធុនតូច និងមធ្យម |
| SPFS | កម្មវិធីពិសេសសំរាប់សន្តិសុខស្បៀង |
| SNEC | ក្រុមប្រឹក្សាកំពូលសេដ្ឋកិច្ច |
| SRI | ប្រព័ន្ធបង្កើនផលិតផលស្រូវ |
| SSWG | ក្រុមការងារលើវិស័យសង្គមកិច្ច |
| SUPF | សហព័ន្ធអ្នកក្រីក្រនៅទីក្រុង |
| TNA | តំរូវការការបណ្តុះបណ្តាល និងវិភាគ |
| TOT | អ្នកធ្វើការបណ្តុះបណ្តាល |
| TVET | បច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌សហប្រជាជាតិ |
| UNFPA | មូលនិធិសហប្រជាជាតិសំរាប់ប្រជាជន |

| | |
|---|---|
| UNICEF | មូលនិធិសហប្រជាជាតិសំរាប់កុមារ |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នអន្តរជាតិនៅកម្ពុជា |
| UPDF | មូលនិធិអភិវឌ្ឍន៍អ្នកក្រីក្រនៅទីក្រុង |
| UPRS | យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅទីក្រុង |
| UPRU | អង្គភាពកាត់បន្ថយភាពក្រីក្រទីក្រុង |
| US$ | ដុល្លាអាមេរិក (រូបិយវត្ថុអាមេរិក) |
| USG | ក្រុមការងារទីក្រុង |
| UXO | គ្រាប់មិនទាន់ផ្ទុះ |
| VAD | វិតាមីនអា |
| VAHW | បសុពេទ្យភូមិ |
| VAT | ពន្ធបន្ថែមលើតំលៃ |
| VDC | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| WB | ធនាគារពិភពលោក |
| WFP | កម្មវិធិស្បៀងអាហារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# ជំពូក ១: ចក្ខុវិស័យសំរាប់ការកាត់បន្ថយភាពក្រីក្រ

ភាពលំបាកជាចំបងនៃការអភិវឌ្ឍន៍ប្រឈមមុខដោយរាជរដ្ឋាភិបាលគឺ ការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាដែលមានកំណើនយ៉ាងលឿន។ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកភាពក្រីក្រ គឺជាការខាតបង់ផ្នែកសេដ្ឋកិច្ច ភាពមិនអាចទទួលយកបានខាងផ្នែកសីលធម៌ និងភាពបែកបាក់នៃសង្គម។ ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាបានក្លាយទៅជាទិសដៅអភិវឌ្ឍន៍ជាចំបងរបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់យ៉ាងម៉ឺងម៉ាត់នូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា និងប្រកបដោយនិរន្តរភាព ដើម្បីរំដោះប្រទេសកម្ពុជាពីនឹមនៃភាពក្រីក្រក្នុងគោលបំណងដើម្បីឱ្យប្រជាជនកម្ពុជាទាំងអស់អាចទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ច និងចូលរួមក្នុងដំណើរការអភិវឌ្ឍន៍។ ការកាត់បន្ថយភាពក្រីក្រយ៉ាងលឿនត្រូវបានចាត់ទុកថាជាផ្នែកមួយដ៏សំខាន់នៃដំណើរការបង្រួបបង្រួមជាតិ និងការស្តារឡើងវិញនៃវប្បធម៌ និងជាលក្ខខណ្ឌមុនគេបង្អស់សំរាប់រក្សានូវស្ថេរភាពនយោបាយ និងសង្គម។

ក្រោយពីការបោះឆ្នោតឆ្នាំ ១៩៩៨ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានកំណត់នូវរបៀបវារៈជាយុទ្ធសាស្ត្រមួយ គឺយុទ្ធសាស្ត្រត្រីកោណសំរាប់ទសវត្សរ៍បន្ទាប់សំរាប់ប្រទេសកម្ពុជា។ ផ្នែកទីមួយនៃយុទ្ធសាស្ត្រ គឺការកសាងសន្តិភាព ស្ថេរភាព និងសន្តិសុខសំរាប់ប្រជាជន។ ផ្នែកទីពីរនៃយុទ្ធសាស្ត្រគឺពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មប្រទេសកម្ពុជា ទៅក្នុងទំនាក់ទំនងក្នុងតំបន់ និងអន្តរជាតិ។ ផ្នែកទីបីនៃយុទ្ធសាស្ត្រគឺត្រូវជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមតាមរយៈការអនុវត្តន៍កម្មវិធីកំណែទំរង់នៅក្នុងបរិយាកាស ដែលបង្កើតឡើងដោយទិសដៅគោលនយោបាយដែលបានពោលខាងលើ។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺ ដើម្បីឱ្យមានប្រទេសកម្ពុជាមួយដែលសង្គមមានលក្ខណៈមិនប្រេះស្រាំ ការអប់រំដែលមានភាពជឿនលឿន និងវប្បធម៌រស់រវើក គ្មានភាពក្រីក្រ គ្មានអនក្ខរភាព គ្មានជំងឺ ដែលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់រស់នៅចុះសំរុងគ្នាដែលមានជីវភាពសមរម្យ និងគ្មានសេចក្តីស្រេកឃ្លាន គ្មានវិសមភាព គ្មានភាពស្ថិតនៅក្រៅសង្គម និងគ្មានភាពងាយរងគ្រោះ។ ការខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្របានរៀបចំឡើងចេញពី បទពិសោធន៍របស់រាជរដ្ឋាភិបាលចាប់តាំងពីបញ្ចប់ជំលោះជាងបីទសវត្សរ៍កន្លងមក ហើយរាជរដ្ឋាភិបាលបានស្វះស្វែងកាត់បន្ថយភាពក្រីក្រស្របជាមួយនឹងគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ដូចជាគោលដៅសន្តិភាព និងស្ថេរភាព។ ការលំបាក និងទិសដៅគោលនយោបាយត្រូវបានចែងក្នុងកម្មវិធីសំខាន់ៗ និងផែនការនានាតាំងពីឆ្នាំ ១៩៩៣[១] ហើយថ្មីៗនេះនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីពីរ ២០០១-២០០៥ ដែលចែងអំពីក្របខ័ណ្ឌទូលំទូលាយសំរាប់យុទ្ធសាស្ត្រនេះ។

ទោះបីជាមានភាពរីកចំរើនជាច្រើនដែលសំរេចបានជាង១០ឆ្នាំកន្លងមកហើយក៏ដោយ (ជាពិសេសអត្រាកំណើនសេដ្ឋកិច្ចដ៏លឿន និងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច) ក៏តួលេខប៉ាន់ស្មានដែលមាន (សូមមើលជំពូកទី៣) បង្ហាញថាដំណើរការកាត់បន្ថយភាពក្រីក្រមិនបានលឿនទៅមុខដូចដែលបានរំពឹងទុកឡើយ។

---

[១] សូមមើល កម្មវិធីជាតិដើម្បីស្តារ និងអភិវឌ្ឍកម្ពុជា (១៩៩៤), ការអនុវត្តន៍នូវ សូមមើល កម្មវិធីជាតិ ដើម្បីស្តារ និងអភិវឌ្ឍកម្ពុជា (១៩៩៥), ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី១, ១៩៩៦-២០០០, កម្មវិធីវេទិកានយោបាយរបស់រាជរដ្ឋាភិបាលសំរាប់អាណត្តិទី២, ១៩៩៨-២០០៣, ឯកសារបឋមនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (២០០១), និងឯកសារក្រុមពិគ្រោះយោបល់ (មិថុនា ២០០២)។

ភាពក្រីក្រនៅកម្ពុជាមានលក្ខណៈច្រើនសណ្ឋាន។ ដូចដែលបានបញ្ជាក់នៅក្នុងការសិក្សាពីការចូលរួម និងការពិគ្រោះយោបល់ដែលជួយដល់ការរៀបចំយុទ្ធសាស្ត្រនេះ ពាក្យថា ភាពក្រីក្រ មានន័យថាការខ្វះនូវការងារសមស្រប និងជីវភាពមិនគ្រប់គ្រាន់។ ភាពក្រីក្រក៏មានន័យថា សុខភាពមិនល្អ កង្វះអាហារូបត្ថម្ភ ការខ្វះខាតនូវការអប់រំ និងភាពងាយទទួលរងគ្រោះដោយគ្រោះធម្មជាតិ និងបរិស្ថាន ។ ភាពក្រីក្រក៏មានន័យផងដែរថាប្រជាជនមានភាពងាយទទួលរងគ្រោះដោយសារអំពើពុករលួយ និងភាពទន់ខ្សោយនៃអភិបាលកិច្ច។

ភាពស្មុគ្រស្មាញនៃមូលហេតុ និងឥទ្ធិពលនៃភាពក្រីក្រ បង្ហាញថាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងលាតសន្ធឹងយ៉ាងទូលំទូលាយ និងមានលក្ខណៈផ្សារភ្ជាប់គ្នាទៅវិញទៅមក។ កិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលនឹងត្រូវការចាំបាច់នូវការបំពេញបន្ថែមពីផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរ អភិវឌ្ឍន៍អន្តរជាតិ ក៏ដូចជាបំពេញបន្ថែមដោយប្រជាពលរដ្ឋខ្លួនឯងផងដែរ។

ឯកសារនេះបង្ហាញអំពីយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រលើកទីមួយរបស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ ត្រូវបានរៀបចំឡើងតាមរយៈដំណើរការនៃការចូលរួមអស់រយៈពេលជាងមួយឆ្នាំ ដែលចូលរួមដោយភ្នាក់ងារផ្សេងៗនៅក្នុងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍របស់កម្ពុជា ផ្នែកឯកជន និងអ្នកក្រីក្រខ្លួនឯង (ជំពូកទី២)។ យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ គឺជាយុទ្ធសាស្ត្ររំកិលដែលឯកសារនេះគ្របដណ្តប់រយៈពេល ២០០៣-២០០៥។

យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រត្រូវបានរៀបចំឡើង ដោយផ្អែកទៅលើឯកសារផែនការថ្មីៗដោយផ្ទាល់ដែលផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ រួមមាន ឯកសារបឋមស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលជាផែនទី បង្ហាញផ្លូវសំរាប់រៀបចំយុទ្ធសាស្ត្រពេញលេញ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីពីរ។ ប៉ុន្តែយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រមានលក្ខណៈទូលំទូលាយជាងឯកសារទាំងពីរ ដោយសារលក្ខណៈមួយចំនួនដើម្បីកំណត់ឱ្យបានកាន់តែច្បាស់ និងធ្វើឱ្យអាចដំណើរការបាននូវយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ ទីមួយៈ យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រមានបញ្ចូលនូវសូចនាករជាច្រើនដែលឆ្លុះបញ្ចាំងអំពីការអនុវត្តន៍ជាក់ស្តែង និងបង្កើតនូវយន្តការសំរាប់តាមដានភាពជឿនលឿនក្នុងការសំរេចបាននូវគោលដៅតាមពេលវេលាដែលវិវត្តទៅមុខ។ ទីពីរៈ យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រព្យាយាមកំណត់នូវ ការចំណាយទៅលើគោលនយោបាយជាអាទិភាពនិងកម្មវិធីនៃការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋា-ភិបាល ហើយផ្សារភ្ជាប់ការប៉ាន់ស្មានចំណាយទាំងនេះទៅនឹងថវិកាជាតិ។ សំខាន់ជាងនេះទៀតការអនុវត្តន៍នូវយុទ្ធសាស្ត្រនេះនឹងត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងថវិការជាតិ។ ទីបីៈ យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រត្រូវបានរៀបចំឡើងនៅលើមូលដ្ឋាននៃដំណើរការចូលរួមយ៉ាងទូលំទូលាយជាងឯកសារមុនៗទាំងអស់។

គួរកត់សំគាល់ផងដែរថា យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រមិនត្រូវបានរៀបចំឱ្យមានលក្ខណៈទូលំទូលាយដូចផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីពីរឡើយ ជាពិសេសនៅក្នុងវិសាលភាពនៃសកម្មភាពរបស់ក្រសួងពាក់ព័ន្ធ។ ផ្ទុយទៅវិញយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ កំណត់និងផ្តោតទៅលើផ្នែកមួយនៃគោលនយោបាយ និងកម្មវិធីដែល

ត្រូវបានចាត់ទុកថាមានសារៈសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រផ្តល់ការយកចិត្តទុកដាក់គោលនយោបាយ និងកម្មវិធីទាំងនោះដែលរួម ចំណែកដល់កំណើនសេដ្ឋកិច្ចទូទៅដោយមានការផ្តោតជាសំខាន់ទៅលើគោលនយោបាយ និងកម្មវិធីដែលបង្កើននូវ ឱកាសដោយផ្ទាល់ដល់អ្នកក្រីក្រដែលពួកគាត់នឹងទទួលបានពីផ្លែផ្កានៃកំណើនសេដ្ឋកិច្ចដ៏លឿន និងប្រកបដោយចិរភាព។

បន្ថែមទៅលើភាពសំខាន់ដែលជាឯកសារជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រក៏គឺសំខាន់ផងដែរពីព្រោះដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានចង្អុលបង្ហាញជាសកលថា គេទាំងនោះនឹងបង្កើនការផ្តល់ជំនួយឱ្យស្របទៅតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលរៀបចំដោយប្រទេសកម្ពុជាដោយផ្ទាល់។ តាមរយៈនៃការរៀបចំបញ្ចប់ និងការបន្តកែលំអយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកំពុងស្វែងរកនូវការគាំទ្រពីដៃគូនានាក្នុងការអនុវត្តន៍ដូចដែលបានកើតមានឡើងនៅក្នុងប្រទេសដែលមានចំណូលទាប គេសង្ឃឹមថាយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រនឹងផ្តល់នូវកំលាំងជំរុញឱ្យមានការផ្លាស់ប្តូរពីគំរោងដែលមានភាពរង្គោះរង្គើរទៅការគាំទ្រខាងផ្នែកថវិកា ។ ក្នុងគោលដៅនេះរាជរដ្ឋាភិបាលមានបំណងផ្សារភ្ជាប់ដំណើរការនៃការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ ទៅនឹងដំណើរការនៃក្រុមពិគ្រោះយោបល់។

គោលដៅដូចតទៅនេះសំរាប់យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ ដំបូងត្រូវបានអនុម័តយកពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទីពីរ។ គោលដៅទាំងនេះនឹងត្រូវបានទទួលយកថាសមស្របសំរាប់ឆ្នាំខាងមុខដែលជាលទ្ធផលនៃការធ្វើមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សឱ្យស្របទៅតាមលក្ខខណ្ឌរបស់ប្រទេសកម្ពុជា។

## តារាង ១.១ គោលដៅសំរាប់ការកាត់បន្ថយភាពក្រីក្រ

(ជា % បើមិនមានបញ្ជាក់ផ្សេងទៀត)

| ទិសដៅ និងសូចនាករ | បន្ទាត់មូលដ្ឋាន (ឆ្នាំ) | គោលដៅសំរាប់ ២០០៥ |
|---|---|---|
| សន្ទស្សន៍រាប់មនុស្សនៃភាពក្រីក្រ | ៣៦ (១៩៩៩) | ៣១ |
| អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកសរុបពិត | ៥.៤ (២០០០) | ៦-៧ (២០០១-២០០៥) |
| អត្រាមរណៈភាពរបស់ទារក | ៩៥ ក្នុង ១០០០ កំណើតរស់ (១៩៩៨) | ៩០ ក្នុង ១០០០ កំណើតរស់ |
| អត្រាស្លាប់របស់មាតា | ៤៣៧ ក្នុង ១០០,០០០ កំណើតរស់ (២០០០) | ៣៧២ ក្នុង ១០០,០០០ កំណើតរស់ |
| កុមារអាយុក្រោម ៥ឆ្នាំ គ្រេះថ្នាំធ្ងរ និងមធ្យម | ៤៤ (២០០០) | ៣៨ |
| អាយុ ១២ឆ្នាំដែលបញ្ចប់ថ្នាក់ទី៦ ដោយជោគជ័យ[8] | ៣៣ (១៩៩៨) | ៩០ |
| សមាមាត្រនៃប្រជាជនដែលមាន លទ្ធភាពទទួលបានទឹកស្អាតបរិភោគ | | |
| ជនបទ | ២៩ (១៩៩៩) | ៤០ |
| តំបន់ទីក្រុង | ៦៩.៥ (១៩៩៩) | ៨៧ |
| សមាមាត្រនៃប្រជាជនដែលមាន លទ្ធភាពចូលដល់កន្លែងផ្តល់សេវាអនាម័យ | | |
| ជនបទ | ៨.៦ (១៩៩៩) | ២០ |
| តំបន់ទីក្រុង | ៤៩ (១៩៩៩) | ៩០ |

ប្រភព: ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ៥ឆ្នាំលើកទីពីរ, ទំព័រ ៤៩។ សំគាល់: [8] អាចអាន និងរាប់លេខបាន

យុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រ គឺជាការខិតខំប្រឹងប្រែងយ៉ាងពិតប្រាកដរបស់រាជរដ្ឋាភិបាលដែលឆ្លុះបញ្ចាំងនូវស្ថានភាពអត្ថិភាពនៃចំណេះដឹង និងសមត្ថភាពដែលមានកំរិត។ ការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និងសមត្ថភាព ក៏ដូចជាមតិរិះគុណស្ថាបនា និងការសិក្សារៀនសូត្រពីបទពិសោធន៍នឹងធ្វើឱ្យយុទ្ធសាស្ត្រនេះកាន់តែល្អប្រសើរឡើងនាពេលអនាគត។ ការដាក់ស្នើឡើងនូវជំហានបន្ទាប់ត្រូវបានបង្ហាញនៅក្នុងជំពូកទី ៧។

យើងបានរំពឹងថាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្របន្តបន្ទាប់មកទៀតនឹងត្រូវរៀបចំធ្វើឡើងជាឯកសារតែមួយនៅឆ្នាំ ២០០៥ ដែលឯកសារនេះនឹងត្រូវរៀបចំឡើងផ្អែកទៅលើជោគជ័យ និងមេរៀនបទពិសោធន៍នៃកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រនាពេលបច្ចុប្បន្ននេះ។

# ជំពូក ២: ដំណើរការនៃការចូលរួម

*" ដំណើរការនៃការអភិវឌ្ឍន៍លើការចូលរួមនៃឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ជាការពិតសំរាប់ជាគំរូរបស់ប្រទេសកម្ពុជាតែប៉ុណ្ណោះ "* ***ODI*** 2002[1]

## ២.១ សេចក្តីផ្តើម

ដំណើរនៃការរៀបចំយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ព្រះរាជាណាចក្រកម្ពុជាបានប្រកាសនៅដើមខែ ឧសភា ឆ្នាំ ២០០០ ក្នុងខណៈពេលការរៀបចំសំរាប់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទី២ ។ ដំណើរការសំរាប់ឯកសារពង្រាងនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលមានសំរបសំរួលដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងត្រូវបានបំពេញទៅតាមកាលវិភាគក្នុងខណៈពេលដែលផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទី២ បានរៀបចំក្រោមការត្រួតពិនិត្យនៃក្រសួងផែនការ។ ក្នុងរយៈពេលតាមដានការពិគ្រោះយោបល់ និងការអនុម័តលើផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ ដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៅក្នុងខែធ្នូឆ្នាំ ២០០១ និងការអនុមត័របស់រដ្ឋសភាជាតិ ក្នុងខែ មិថុនា ឆ្នាំ ២០០២ ។

ដំណើរការសំរាប់ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ត្រូវបានប្រកាសកាលពីសិក្ខាសាលាថ្នាក់ជាតិអំពីឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ នៅថ្ងៃទី ២៥ និង ២៦ មេសាឆ្នាំ ២០០០។ នៅក្នុងសិក្ខាសាលាសំនួរជាមូលដ្ឋានបានលើកឡើងអំពីទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រផ្សេងៗ និងឧបករណ៍ពហុថវិកាប្រចាំឆ្នាំ។ មានសំនួរពិភាក្សាទៅលើការខុសគ្នារវាងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ និងអំពីរបៀបធ្វើអធិប្បាយអំពីតំលៃ និងលទ្ធភាពឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលទាក់ទងទៅនឹងគំរោងក្នុងផែនការវិនិយោគសាធារណៈ (PIP)។ ជាលទ្ធផលបានសំរេចយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ (NPRS) ត្រូវបានផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ និងការបង្កើនភាពរីកចំរើនស្របនឹងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងកង្វះខាតនៃការអនុវត្តន៍គោលនយោបាយសារពើពន្ធ និងដំណើការនៃការចូលរួម។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ ត្រូវបានប្រើជាមូលដ្ឋានគ្រឹះសំរាប់បង្កើត ឯកសារនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលមានៈ

- ការជំរុញយន្តការ ការត្រួតពិនិត្យនិងវាយតំលៃ
- ការបង្កើនអោយបានយល់ដឹងច្រើនអំពីសូចនាករ និងគោលដៅ
- ការបង្កើនគោលនយោបាយ តំលៃនៃលទ្ធភាពសាធារណៈនិងកម្មវិធី និងការផ្សារភ្ជាប់ទៅនឹងថវិកា។ និង
- ការធ្វើសមាហរណកម្មគំរោងម៉ាក្រូសេដ្ឋកិច្ច និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

សិក្ខាសាលាក៏បានសំណូមពរថានៅក្នុងឯកសារពេញលេញនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រលើកទី១ រាជរដ្ឋាភិបាលត្រូវការសំដៅលើសកម្មភាពគោលនយោបាយជាលទ្ធភាព និងការពង្រឹងដំណើរការធានាអោយការសំរបសំរួល និងការចូលរួម

[1] ODI: Oversea Development Institute (2002) លទ្ធផលតំរង់ទៅលើការគ្រប់គ្រងការចំណាយសាធារណៈក្នុងប្រទេសកម្ពុជា (សេចក្តីព្រាងរបាយការណ៍ ភាគទី១) ។

អោយបានល្អ។ ដូច្នេះរចនាសម្ព័ន្ធនៃការដាក់ចុះបានសំដៅទៅលើការពង្រឹង និងបានសំរេចគោលបំណងដោយផ្អែកលើក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និងអគ្គលេខាធិការដ្ឋាន។

## ២.២ មេរៀនពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ និង ឯកសារបឋមនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

មុនធ្វើការចាប់ផ្តើមនៃដំណើរការសំរាប់ការចូលរួមនៃឯកសារពេញលេញស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ត្រូវបានអនុម័តដូចគ្នានឹងបានបង្កើតឯកសារបណ្តោះអាសន្នស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (I-PRSP) និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចលើកទី២ ។ ការចាប់ផ្តើមនេះបានផ្តល់មូលដ្ឋានសំខាន់នៃការចូលរួមជាមួយនិងអ្នករួមចំណែកសំរាប់ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលមានសិក្ខាសាលារបស់អង្គការវេទិកាក្រៅរដ្ឋាភិបាលលើឯកសារបណ្តោះអាសន្ន ស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (I-PRSP តុលា ២000) វេទិកាជាតិលើ (SEDP2 មិនា ២00១) វេទិកាជាតិលើកទី២អំពី SEDP2 (១៥ តុលា ២00១) និង កិច្ចប្រជុំតុមូលស្តីពី "អភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ" របស់វិទ្យាស្ថានកម្ពុជាដើម្បីសហប្រតិបត្តិ និងសន្តិភាព (CICP) (២១ តុលា ២00១) ។ បច្ចុប្បន្ននេះការយល់ដឹងលើការប៉ាន់ប្រមាណនៃការចូលរួមកាត់បន្ថយភាពក្រីក្រដែលបានរៀបចំឡើងដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (ដូចមានបញ្ជាក់ខាងក្រោម)។ ថ្មីៗនេះ ដូចជាផ្នែកមួយនៃដំណើការលើ SEDP2 អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចបានរៀបចំវេទិការ "មតិ សាធារណៈ" នៅខេត្តកំពតដើម្បីផ្សព្វផ្សាយពតិមានអំពី SEDP2 ។

ការផ្តល់ចំលើយតបពីអ្នករួមចំណែកលើដំណើរការនៃការចូលរួមមានៈ ការផ្តល់យោបល់ជាច្រើន ដែលផ្តល់ក្នុងពង្រាងឯកសារសំរាប់ជាយោបល់ និងសិក្ខាសាលាដែលប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ និងដែលមិនមានពេលវេលាគ្រប់គ្រាន់សំរាប់ផ្តល់យោបល់ឡើយ។ មានចំនុចទិទ្បេនមួយចំនួនអំពី SEDP2 និង I-PRSP ដែលបានសរសេរជាភាសាអង់គ្លេស និងមិនមានពេលវេលា សំរាប់ការបកប្រែជាភាសាខ្មែរនោះឡើយ ។ ជាមេរៀនមួយដ៏សំខាន់លើការយល់ដឹងសមត្ថភាពរបស់អ្នករួមចំណែកក្នុងការធានាអោយមានការសន្ទនា។ ជាឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ត្រូវការជំនួយលើការយល់ដឹងពីដំណើរការ យ.ជ.ក.ភ ដែលគេអាចរួមវិភាគទានដ៏មានប្រសិទ្ធភាព ។ តែផ្ទុយទៅវិញមិនមានបញ្ហាណាដែលត្រូវបានដោះស្រាយក្នុងពេលដំណើរការនៃឯកសារ និងមិនអាចចែកចាយឯកសារជាខ្មែរបាន។

ផ្អែកលើបទពិសោធន៍មានសារៈសំខាន់នេះ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច បានរៀបចំ "ផែនការសកម្មភាពនៃការចូលរួម Participation Action Plan" នៅខែមករា ឆ្នាំ ២00២ ។ ផែនការនេះ បានប្រើដើម្បីកំណត់រាល់សកម្មភាពចូលរួមជាមួយនឹងក្រោមការភ្ជាប់ទៅនឹងការរៀបចំឯកសារពេញលេញអំពីយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ ផែនការសកម្មភាពនៃការចូលរួមមាន វិធានការណ៍ ដើម្បីរៀបចំការចូលរួមនៅថ្នាក់ខេត្ត និងថ្នាក់ភូមិ ភាពរីកចំរើននៃដំណើរការចូលរួមដែលរៀបចំដោយបណ្តាក្រសួងនានា និងផ្តល់ពេលវេលាច្រើនសំរាប់អ្នករួមចំណែកផ្តល់យោបល់ ។ ដំណើរការនៃការចូលរួមបានពិភាក្សា និងកំណត់ឡើងវិញពីសិក្ខាសាលាជាតិនៅខែ មេសា ២00២។

## ២.៣ រចនាសម្ព័ន្ធសំរាប់ការចូលរួមៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និងអគ្គលេខាធិការដ្ឋាន និងយន្តការពិគ្រោះយោបល់

ការទទួលខុសត្រូវសំរាប់ឯកសារពេញលេញនៃ PRSP ត្រូវបានផ្ទេរទៅក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច អន្តរៈក្រសួង ដែលក្រោមធិបតីរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ។ ក្រុមប្រឹក្សានេះត្រូវបានជួយដោយអគ្គលេខាធិការដ្ឋានដែលបានបង្កើតឡើងនៅខែ សីហា ២០០១ ដែលមានប្រធានជាអនុរដ្ឋលេខាធិការនៃក្រសួងផែនការ ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច បានរៀបចំការប្រជុំប្រចាំខែ ដោយមានការចូលរួម ពីបុគ្គលិកមកពីអង្គភាពត្រួតពិនិត្យ និងវាយតំលៃលើភាពក្រីក្រនៃក្រសួងផែនការ និងក្រុមការងារដែលចាត់តាំងដោយអង្គការមិនមែនរដ្ឋាភិបាល និងក្រុមការងារវិស័យសង្គមកិច្ច របស់អ្នកផ្តល់ទុន ។

ខែមករា ឆ្នាំ ២០០២ អ្នកផ្តល់ទីប្រឹក្សា លើការចូលរួមត្រូវបានចាប់ផ្តើមជួលសំរាប់អគ្គលេខាធិការដ្ឋាន GSCSD ជាបន្ថែមនៅក្នុងការប្រជុំប្រចាំខែរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវបានការចូលរួមរបស់អ្នកតំណាងមន្ត្រីរដ្ឋាភិបាល សង្គមស៊ីវិល បានបន្តការផ្សព្វផ្សាយ និងផ្តល់ចំលើយ ។

### ២.៣.១ ការទាក់ទាញអ្នករួមចំណែកៈ ដំណើរការចូលរួម

ការប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់ និងសកម្មភាពចូលរួមត្រូវបានបង្កើតដោយអគ្គលេខាធិការដ្ឋាននៃក្រុមបឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដែលបានកំណត់នៅក្នុងផែនការសកម្មភាពនៃការចូលរួមក្នុងនោះមានៈ សិក្ខាសាលាថ្នាក់ជាតិ, ការប្រជុំក្រុមពិគ្រោះយោបល់, ការពិគ្រោះយោបល់ដែលរៀបចំដោយបណ្តាក្រសួងផ្ទាល់ជាមួយអ្នកក្រ និងការប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត ។

### សិក្ខាសាលាជាតិ

នៅខែមេសា ២០០២ សិក្ខាសាលាថ្នាក់ជាតិលើកទី១ បានពិភាក្សាលើដំណើរការពិគ្រោះយោបល់ជាមួយនឹងភាពរឹងមាំ និងការចូលចិត្តក្នុងការចូលរួមនៃអង្គការមិនមែនរដ្ឋាភិបាល ។ យោបល់ពីមុនរបស់ក្រុមអង្គការមិនមែនរដ្ឋាភិបាលលើ IPRSP និង SEDP2 ត្រូវបានបែងចែកដល់សមាជិកនៅក្នុងសិក្ខាសាលាជាតិនេះ ។ អនុសាសន៍របស់អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ក្នុងសិក្ខាសាលាដែលបានអញ្ជើញចូលរួមដោយ GSCSD បានទទួលយល់ព្រម (ដែលបានបញ្ជាក់ខាងលើ) ។ នៅដំណាក់កាលនេះ បុគ្គលិក GSCSD បានទាក់ទងទៅជាបុគ្គលដល់ក្រុមអង្គការមិនមែនរដ្ឋាភិបាល និងបានជួបជាមួយអ្នកផ្តល់ជំនួយដើម្បីទាញយកទស្សនៈនៃ យ.ជ.ក.ភ ។

ការប្រជុំលើកទីមួយរបស់ GSCSD ធ្វើនៅដើមខែឧសភា ក្រសួងទាំងអស់បានត្រូវអញ្ជើញអោយបង្ហាញម៉ាទ្រីស ។ សម្បទានដែលអាចសំរេចនៅក្នុងការចូលរួមនៅសិក្ខាសាលាជាតិដែលប្រារព្ធនៅចុងខែឧសភា ដែលមានការចូលរួមដោយអង្គការមិនមែនរដ្ឋាភិបាលនិងជំនាញការរយៈពេលវែងលើគ្រប់វិស័យដើម្បីធ្វើការពិភាក្សាលើម៉ាទ្រីស ។ នៅ **សិក្ខាសាលាថ្នាក់ជាតិលើកទី២** នៅ ២៨-២៩ ខែឧសភា ២០០២ ដោយមានក្រសួងជាច្រើនបានបង្ហាញសេចក្តីព្រាងនៃ ម៉ាទ្រីស PRSP ។ វគ្គជាច្រើនបាន

បង្ហាញច្បាស់លាស់នូវទស្សនៈផ្សេងៗ ដែលអ្នកក្រមាន និងពីរបៀបដែលគេអាចបំពេញបានយ៉ាងល្អ។ ម៉ាទ្រីសបង្ហាញពីការងារដែលកំពុងតែឆ្ពោះទៅមុខតាមការសំរេចជាអាទិភាព។

សេចក្តីព្រាងលើកទីមួយនៃ PRSP បានផ្សព្វផ្សាយនៅ**សិក្ខាសាលាជាតិលើកទីបី** ថ្ងៃទី ២៦និង ២៧ ខែសីហា ឆ្នាំ២០០២ ដែលមានចំនួនអ្នកចូលរួមជាង២០០នាក់។ សិក្ខាសាលាបានផ្តល់នូវការលើកសំនួរ និងចំពោះអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជននៅពេលជាមួយគ្នា។ ហើយក្រុមនេះត្រូវបានបង្កើតឡើងនៅពេលដែលគេបានលើកឡើងនូវរឿងរ៉ាវសំខាន់ដែលទាក់ទងនឹងហិរញ្ញវត្ថុខ្នាតតូចដែលក្រោមឆត្ររបស់ធនាគារនិងរឿងរ៉ាវច្បាប់, សិទ្ធិដីធ្លី សុខភាព។ល។ ទាំងអស់នេះជាចំនុចស្នូលដែលផ្នែកឯកជនបានលើកឡើង។

សេចក្តីព្រាងលើកទី២នៃ PRSP បានបញ្ជូនចែកដល់សមាជិកសិក្ខាសាលាជាតិលើកទី៤ដែលប្រព្រឹត្តទៅនៅថ្ងៃទី១២ វិច្ឆិកា ឆ្នាំ ២០០២ ។ គោលបំណងរបស់សិក្ខាសាលាគឺសំរាប់មន្ត្រីរាជការ រាជរដ្ឋាភិបាលបានបង្ហាញ យ.ជ.កភ ពង្រាងលើកទី២ ក្រោយពីបាន បញ្ចូលរាល់យោបល់ដែលផ្តល់ដោយអ្នករួមចំណែកទាំងអស់ដើម្បីផ្តល់យោបល់អាទិភាព និងបញ្ចប់ PRS និងប្រមូលការពិភាក្សា សំរាប់ជំហានក្រោយនៅពេលអនុវត្តន៏។

## កិច្ចប្រជុំក្រុមពិគ្រោះយោបល់ មិថុនា ២០០២

ជាឱកាសមួយដ៏សំខាន់សំរាប់ការពិភាក្សាឯកសារ PRSP ការប្រជុំពិគ្រោះយោបល់នៅខែមិថុនា ឆ្នាំ២០០២។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច GSCSD បានបង្ហាញការលំបាកមួយចំនួនរបស់ក្រសួងទាំងអស់ដែលបានជួបប្រទះក្នុងការព្យាយាមដើម្បីសំរេចនូវសកម្មភាពអាទិភាព ។

សេចក្តីថ្លែងការរបស់អង្គការមិនមែនរដ្ឋាភិបាលនៃការប្រជុំក្រុមពិគ្រោះយោបល់ ដែលបានសំដៅលើការកាត់បន្ថយភាពក្រីក្រ និងដែលសេចក្តីថ្លែងការណ៏នេះ គួរមានប្រភពសំខាន់ថ្មីដាក់បញ្ចូលទៅក្នុង យ.ជ.ក.ភ ។

## វិស័យ និង បណ្តាក្រសួង

មេរៀនមួយដ៏សំខាន់ដែលបានពីរូបមន្តបទពិសោធន៏នៃ PRSP និង SEDP2 ជាការបំពេញបាននូវសកម្មភាពសំខាន់នៃការចូលរួមពីបណ្តាក្រសួង និងដើម្បីកសាងលើដំណើរការនៃការចូលរួមដែលមានរួចមកហើយ។ ឧទាហរណ៏ នៅខែកញ្ញា ឆ្នាំ ២០០២ ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការពិគ្រោះយោបល់ ដើម្បីរៀបចំនិងពិនិត្យសារឡើងវិញនូវផែនការយុទ្ធសាស្ត្ររបស់គេ។ សកម្មភាពដែលគេបានធ្វើនោះមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ទុន។ ជាការដែលបានមកពីការពិគ្រោះយោបល់នេះ និងពីការពិនិត្យឡើងវិញរបស់ក្រសួងដែលមានផែនការយុទ្ធសាស្ត្រទូលំទូលាយដែលទទួលបានពី យ.ជ.ក.ភ អប់រំជាមូលដ្ឋាន។ ដូចគ្នានេះ ក្រសួងសុខាភិបាលបានធ្វើការប្រជុំពិគ្រោះយោបល់បន្តជាមួយសង្គមស៊ីវិល និងម្ចាស់ទុនអន្តរជាតិដើម្បីបង្កើតផែនការយុទ្ធសាស្ត្រថ្មីលើវិស័យសុខភាព (សីហា ២០០២) ដោយផ្អែកលើការដាក់លទ្ធផលនៃ យ.ជ.ក.ភ ។

ក្រសួងដទៃទៀតក្នុងវិស័យអភិវឌ្ឍន៏ជនបទដែលរៀបចំសិក្ខាសាលាផ្ទៃក្នុង ដើម្បីបង្កើនការយល់ដឹងនិងភាពជាម្ចាស់ការនៃឯកសារ យ.ជ.ក.ភ របស់ក្រសួងគេផ្ទាល់។ ការធ្វើប្រជុំពិគ្រោះយោបល់ផ្ទៃក្នុងបានធ្វើជាលក្ខណៈមិនផ្លូវការ (ក្រសួងគ្រប់គ្រង

ដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងគ្រប់គ្រងធនធានទឹក) រឺការរៀបចំតាមរយៈការប្រជុំពិសេស (ក្រសួងអភិវឌ្ឍន៏ជនបទ ក្រសួងកសិកម្ម) ។ ជាមួយការឆ្លើយតបទៅនឹងរឿងរ៉ាវអន្តរវិស័យនៃយេនឌ័រ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនបានចូលរួមធ្វើការយ៉ាងសកម្មជាមួយនិង យ.ជ.ក.ភ ។ នៅឯកសារ PRSP "ផែនការសកម្មភាពនៃយេនឌ័រ" ត្រូវបានបង្កើតឡើងដោយគណៈប្រតិភូមួយក្រុមដែលបាននការឧបត្ថម្ភពីធនាគារពិភពលោក បានចូលរួមសន្និសិទថ្នាក់តំបន់ស្តីពី" និន្នាការយេនឌ័រថ្នាក់តំបន់ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" នៅទីក្រុងហាណូយប្រទេសវៀតណាមនៅខែមិនា ឆ្នាំ២០០២។ ជាបន្តក្រសួងនេះជាអ្នកអញ្ជើញដើម្បីជជែកពិភាក្សារវាងម្ចាស់ទុននិងអ្នកដឹកនាំ  អង្គការមិនមែនរដ្ឋាភិបាល លើឯកសារ PRSP និងបានផ្តល់យោបល់លើសេចក្តីព្រាងដែលមានមក។

## ការពិគ្រោះយោបល់ថ្នាក់ខេត្ត

តាមការប្រើទិន្នន័យដែលបានបង្ហាញ ផែនទីក្រីក្រដែលរៀបចំដោយអង្គការ ស្បៀងអាហារពិភពលោក អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សានៃអភិវឌ្ឍន៏សង្គមកិច្ច សំរេចរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តក្រុងបី គឺសៀមរាប ព្រៃវែង និងក្រុងកែប។ របាយការណ៏នៃសិក្ខាសាលាទាំងអស់នេះមាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៏សង្គមកិច្ចក្នុងការប្រឹងប្រែងធានាឱ្យស្ត្រីបានចូលរួមលើដំណើរការនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រនេះ "អង្គការចំរើនស្ត្រី" មានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារីបានរៀបចំឱ្យមានការពិគ្រោះយោបល់ដល់ស្ត្រីក្រីក្រនៅក្រុង ប៉ៃលិន បាត់ដំបង ពោធិសាត់ និងទីក្រុងភ្នំពេញ  នៅខែមិថុនា ២០០២ ។ មានការធ្វើបន្តពីនេះទៀតដោយការប្រជុំតុមូលស្តីពី "រឿងរ៉ាវយេនឌ័រក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ យ.ជ.ក.ភ "ដែលប្រារព្ធឡើងនូវ ថ្ងៃទី ២៩ តុលា ២០០២។ សិក្ខាសាលាតែក្នុងរយៈពេលមួយថ្ងៃដែលរៀបចំដោយ "អង្គការចំរើនស្ត្រី, អង្គការវេទិកាអង្គការមិនមែនរដ្ឋាភិបាល" និងក្រសួងកិច្ចការនារី និងអតីតយុទ្ធជនដែលបានរកឃើញពីកិច្ចពិគ្រោះយោបល់នៅថ្នាក់ក្រោម និងអនុសាសន៏មួយចំនួនដែលបង្ហាញទៅដល់ក្រុមការងារ PRSP ដែលមកពីក្រសួងអាទិភាពទាំងបួន។

## ការពិគ្រោះយោបល់ជាមួយអ្នកក្រ

តាមការសិក្សា និងស្វែងយល់ពីភូមិចំនួន ១៥៤ ភូមិ និងត្រូវបានបញ្ចប់នៅប៉ុន្មានខែមុននេះ (ធនាគារអភិវឌ្ឍន៏អាស៊ីបានធ្វើការប៉ាន់ប្រមាណដោយការចូលរួមលើភាពក្រីក្រ PPA) នៅចុងឆ្នាំ២០០១ ។ ជាសារៈសំខាន់ គុណភាពនៃការងារដោយផ្តល់ការឆ្លើយតបយ៉ាងត្រឹមត្រូវដល់ក្រសួងទាំងអស់ និងសំដៅដល់ការយកចិត្តទុកដាក់ លើការយល់ដឹងផ្ទាល់របស់គេពីបញ្ហាចែកចាយសេវាកម្មដល់អ្នកក្រ។

នៅចុងខែ មិថុនា/កក្កដា ២០០២, GTZ បានរួមសហការ និងការជួយរៀបចំឱ្យមានសិក្ខាសាលាពិគ្រោះយោបល់បន្តបន្ទាប់សំរាប់អ្នកក្រីក្រដែលធ្វើឡើងជាមួយក្រសួងសុខាភិបាលក្នុងខេត្តកំពង់ធំ និងអន្លង់ក្វានដែលជាតំបន់អ្នកក្រីក្រប្តូរទីតាំងពីទន្លេបាសាក់។ គោលបំណងចំបងសំរាប់អោយមន្ត្រីសុខាភិបាលបានចូលរួមក្នុងដំណើរការនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រដើម្បីបន្ត និងពង្រីកការយល់ដឹងរបស់គេផ្ទាល់ទៅលើតំរូវការរបស់អ្នកក្រីក្រ និងធ្វើយ៉ាងណាដើម្បីអោយដំណើរការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្របានឆ្លើយតបផ្ទាល់ដល់គេ។

### វេទិកាលើការតាមដាន យជគគ

ក្នុងខណៈនៃការពិគ្រោះយោបល់នីមួយៗដែលត្រូវបានធ្វើនៅថ្នាក់ជាតិ និងមូលដ្ឋាន នៅរាជធានីភ្នំពេញ អង្គភាពបច្ចេកទេសតាមដានត្រួតពិនិត្យ និងវិភាគភាពក្រីក្រនៃក្រសួងផែនការ ដោយមានការសហការជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចបានរៀបចំវេទិកាអ្នកក្រីក្រនៅដើមខែកក្កដា ដើម្បីពិភាក្សាពីផែនការសំរាប់ត្រួតពិនិត្យ និងវិភាគ និងរៀបរាប់ពីឧបករណ៍វិភាគដែលគេមានផែនការអនុវត្តន៍ ។ ពត៌មានលំអិតពីដំណើរការចូលរួមត្រួតពិនិត្យដោយអ្នករួមចំណែកមានបង្ហាញនៅជំពូកទី៦ ។

## ២.៣.២ អ្នករួមចំណែកសង្គមស៊ីវិលៈ ការចូលរួមនៃអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងម្ចាស់ជំនួយក្នុង យជគគ

### វេទិកាអង្គការមិនមែនរដ្ឋាភិបាល

អង្គការវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាបានរៀបចំវេទិការួមទាំងអង្គការជាតិ និងអន្តរជាតិ ដើម្បីស្វែងរកការពិភាក្សា និងមតិ ដែលទាក់ទងដល់អង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើការអភិវឌ្ឍន៍នៅកម្ពុជា ។

សកម្មភាព/របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលរួមមានៈ

- ធ្វើសំភាសន៍ និងសិក្ខាសាលានៅភ្នំពេញ និង ៤ខេត្ត ជាមួយនឹងអង្គការដើម្បីពិភាក្សា លើ PRSP។ ការប្រឹងប្រែងនេះបានធ្វើឡើង ដើម្បីជួបជាមួយសង្គមស៊ីវិលផ្សេងទៀតដែលបានទទួលដំណឹងនេះ ដូចជាអ្នកដឹកនាំនៅតំបន់ជនជាតិ កម្មកររោងចក្រ អ្នករកស៊ីផ្លូវភេទ និងអ្នកដឹកនាំសហគមន៍ក្រីក្រក្នុងទីក្រុង។ សកម្មភាពក្នុងរយៈពេល២ខែបានកើនឡើងខ្ពស់បំផុតក្នុងសិក្ខាសាលាជាតិ ដែលរៀបចំឡើងនៅថ្ងៃទី ២៤-២៥ តុលា ២000 ដែលមានអង្គការមិនមែនរដ្ឋាភិបាល ៨៥ បានចូលរួមហើយភាគច្រើនជាកម្ពុជា។
- របាយការណ៍របស់វេទិកា"សេចក្តីព្រាងនៃយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ" មានមតិរបស់អង្គការ នៅក្នុងនោះ? Cambodia's Draft Poverty Reduction Strategy Paper has NGOs input be include? ខែកញ្ញា ២00២) បានសង្ខេបយ៉ាងច្រើនលើការទាក់ទិនទៅនឹងការដាក់បញ្ចូលរបស់អង្គការ នៅក្នុងទីនោះ។ ទាំងអស់នោះមានៈ
    - o លទ្ធផលនៃ ការផ្តួចផ្តើមពិភាក្សាក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិលលើយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រនៅកម្ពុជា (ខែវិច្ឆិកា ២000) ការបោះពុម្ពផ្សាយនៃវេទិកាអង្គការ NGO Forum នៅកម្ពុជាត្រូវបានផលិតឡើងពីរខែក្រោយនៃការពិភាក្សា និងរៀបចំសិក្ខាសាលាជាតិលើឯកសារ IPRSP នៅខែតុលា ២000 ដែលមានអ្នកចូលរួម ៨៥នាក់ ជាតំណាងអង្គការ។
    - o លទ្ធផលនៃការពិភាក្សារបស់អង្គការ លើសេចក្តីព្រាងរបស់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច (ខែសីហា ២00១) ត្រូវបានផលិតទៅតាមការប្រជុំរបស់អ្នកតំណាងអង្គការ ៣៥រូបមកពីវិស័យផ្សេងៗ ក្នុងខែកក្កដា។

- o សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលឆ្នាំ ២០០២ ដែលសំរាប់អង្គប្រជុំពិគ្រោះយោបល់នៅខែមិថុនា ២០០២ ( មើលខាងលើ) ។
- o អនុសាសន៍របស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីបង្កើនភាពជោគជ័យនៃផែនការសកម្មភាពកម្ពុជា ( មិថុនា ២០០២) , ការបោះពុម្ពផ្សាយរបស់អង្គការវេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ។

- ចុងបញ្ចប់ការប្រៀបធៀបយ៉ាងលឿននៃសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ដែលរៀបចំសំរាប់ការប្រជុំពិគ្រោះយោបល់ឆ្នាំ ២០០២ និងសេចក្តីព្រាងលើកទី២ នៃឯកសារ PRSP នៅកម្ពុជាដែលបានបំពេញជាមួយការប្រើដើម្បីពិនិត្យឡើងវិញនៃសេចក្តីព្រាងចុងក្រោយនៃឯកសារ យ.ជ.ក.ភ អង្គការមិនមែនរដ្ឋាភិបាល សកម្មលើការចូលរួមជាមួយសិក្ខាសាលាជាតិនិង
- ការប្រជុំប្រចាំខែដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

## វិស័យឯកជន

វិស័យឯកជនមានអ្នកទំនាក់ទំនងស្នូលជាមួយ GSCSD ដែលជាមធ្យោបាយដ៏ល្អក្នុងការជួយផ្សព្វផ្សាយការប្រជុំទៅដល់កសិ-ឧស្សាហកម្ម ។

## ការពាក់ព័ន្ធនៃម្ចាស់ជំនួយ

ក្រុមការងារម្ចាស់ជំនួយនៃវិស័យសង្គមកិច្ចបានបញ្ជូនតំណាង ( មកពី UNICEF, ស្បៀងអាហារពិភពលោក UNESCO និងអង្គការសុខភាពពិភពលោក) ចូលរួមប្រជុំប្រចាំខែដែលរៀបចំដោយ GSCSD ដើម្បីជួយផ្តល់បច្ចេកទេស ។ ហើយចាប់ពីខែឧសភា ២០០២ បុគ្គលិក GSCSD បានទៅជួបជាមួយម្ចាស់ជំនួយផ្សេងៗ។ អង្គការសហប្រតិបត្តិការកាណាដាបានយល់ព្រមផ្តល់ថវិកាសំរាប់អ្នកពិគ្រោះយោបល់ដែលអាចជាទំនាក់ទំនងរវាង GSCSD និងបណ្តាក្រសួងដើម្បីធានាអោយបន្តផ្តល់យោបល់មក GSCSD ។ ហើយ UNFPA ផ្តល់ជំនួយការដល់អគ្គលេខាធិការ និងយល់ព្រមផងដែរសំរាប់ជំនួយជាមធ្យោបាយដឹកជញ្ជូន និងសំភារៈការិយាល័យតិចតួច។ UNESCO បានជួយអ្នកពិគ្រោះយោបល់ដើម្បីធ្វើការជាមួយក្រសួងអប់រំ និងយល់ព្រមផងដែរក្នុងការផ្តល់ថវិកាដល់មន្ត្រីក្រសួងអប់រំយុវជន និងកីឡា រាល់គ្រប់គំរិតដើម្បីជួយផ្សព្វផ្សាយសិក្ខាសាលាដល់ខេត្តផ្សេងៗ។

## សមាជិកសភា

នៅថ្ងៃទី ២៨ និង២៩ តុលា ២០០២ អង្គការស៊ីដា កាណាដា និងកិច្ចសហការជាមួយអង្គការ UNDP និងស្ថាប័នធនាគារពិភពលោកបានរៀបចំសិក្ខាសាលាមួយស្តីពីតួនាទីរដ្ឋសភាជាតិ និង PRSP ដែលមានសមាជិករដ្ឋសភា ព្រឹទ្ធសភា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន និងអ្នកតំណាងជនក្រីក្រមកពីខេត្តតាកែវ ពោធិសាត់ កំពង់ធំ ក្រចេះ កំពង់ស្ពឺ ចូលរួមផងដែរ។ ប្រជាជនក្រីក្របានបង្ហាញលើវិស័យផ្សេងៗដែលមានសារៈសំខាន់សំរាប់ស្បៀងដែលក្នុងនោះមាននិយាយពីធនធានព្រៃឈើ, ធន-ធាននេសាទ ដំណាំស្រូវ ជំនួញផ្លូវភេទ ប្រើថ្នាំញៀន និងរោងចក្រកាត់ដេរ។ សិក្ខាសាលាបានរៀបរាប់ដោយត្រួសៗអំពីដំណើរការ យ.ជ.ក.ភ នៅកម្ពុជាដោយមន្ត្រីខ្មែរដែលធ្វើការនៅធនាគារពិភពលោក ឯកឧត្តមអគ្គលេខាធិការ GSCSD និងអគ្គលេខារង

នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាអ្នកបានចូលរួមក្នុងដំណើរការនៃ យ.ជ.ក.ភ សមាជិកអង្គសិក្ខាសាលាបានពិភាក្សាជាត្រួសៗលើខ្លឹមសារ និងអត្ថន័យសំខាន់ៗនៃ យ.ជ.ក.ភ។ សិក្ខាសាលាក៏ធ្វើការពិចារផងដែរអំពីការងាររបស់ រដ្ឋសភា ជាតិក្នុងដំណើរការនៃ យ.ជ.ក.ភ និងការកសាងសមត្ថភាពរបស់គេ។

## សហជីព

ថ្មីៗនៅខែសីហា២០០២ សិក្ខាសាលាជាតិបានយល់ព្រមអោយសហជីពកម្មកររៀបចំជា "ក្រុមការងារសំរាប់ PRSP"។ គណៈកម្មាការបានចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះ និងធ្វើការជួបប្រជុំគ្នាជារៀងរាល់ខែដើម្បីលើកពីទស្សនៈរបស់គេក្នុងសិក្ខាសាលាជាតិចុងក្រោយនេះ ដែលគេបានរៀបចំយោបល់ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងលើកទី២នៃ យ.ជ.ក.ភ ការរួមវិភាគទានរបស់គេនេះបានសង្កត់ទៅលើស្ថានភាពពលកម្ម (ជាពិសេសទាក់ទងទៅនឹងការថយចុះនៃថ្លៃឈ្នួលការងារ) និយោជក និងអំពើពុករលួយ។

## ប្រព័ន្ធពត៌មាន

ក្រុមផ្សព្វផ្សាយក៏បានដាក់បញ្ចូលអ្នករួមចំណែកជាមួយដំណើរការ យ.ជ.ក.ភ ដែរ។ អ្នកសារពត៌មានក៏ត្រូវបានអញ្ជើញមកចូលរួមក្នុងសិក្ខាសាលាជាតិ និងព្រឹត្តិការណ៍សំខាន់ៗមួយចំនួននៃដំណើរការ យ.ជ.ក.ភ ដែលបានចុះក្នុងអត្ថបទសារពត៌មានក្នុងស្រុក។ ការផ្សព្វផ្សាយមានតួនាទីសំខាន់ក្នុងការតាមដានត្រួតពិនិត្យការអនុវត្តន៍ យ.ជ.ក.ភ ។

## ជំនួយមូលនិធិ យជកភ

មួយចំណែកធំនៃថវិកាដែលដាក់ស្នើទៅ Trust Fund បានសំដៅជាពិសេសលើការពង្រីកសមត្ថភាពយ៉ាងទូលាយដល់អ្នករួមចំណែកដើម្បីរួមវិភាគទានក្នុងការអភិវឌ្ឍន៍ ការអនុវត្តន៍ និងការត្រួតពិនិត្យឯកសារ យ.ជ.ក.ភ។ ថវិកាដែលបានស្នើសុំដើម្បីសំរបសំរួលការផ្លាស់ប្តូររវាងអ្នកពាក់ព័ន្ធផ្សេងៗលើបច្ចេកទេស និងបទពិសោធន៍ជាមួយនឹងការធ្វើផែនការ ការអនុវត្តន៍ និងសកម្មភាពប៉ាន់ប្រមាណការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងអន្តរជាតិ។ ជាបន្ថែមការគាំទ្របានស្នើសុំសំរាប់ការចូលរួមធ្វើការត្រួតពិនិត្យលើទិដ្ឋភាពនៃអន្តរៈវិស័យ នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលក្នុងនោះមានថវិកាសំរាប់ប្រតិបត្តិការធ្វើអោយបានដល់សេវាកម្មគុណភាពសេវាកម្ម ការចូលរួមលើដំណើរការនៃការធ្វើផែនការ ភាពឆ្លើយតបទៅការស្នើឡើងរបស់មូលដ្ឋាន ។ល។ អ្នករួមចំណែកដែលទទួលថវិកាជំនួយនឹងត្រូវទទួលខុសត្រូវលើការធ្វើរបាយការណ៍ពីការរីកចំរើន និងលទ្ធផលនៃសកម្មភាពទូទៅរបស់ GSCSD ។ ជាបន្ថែមលើការអនុវត្តន៍នូវសកម្មភាពពិសេសដែលបានបើកចំហសំរាប់អ្នករួមចំណែកពីក្រៅរាជរដ្ឋាភិបាលដែលមានគុណភាពដែលក្នុងនោះមានអង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងផ្នែកឯកជន។ ថវិកាដែលជាការគិតទុកថា ៤៥ភាគរយនៃ Trust Fund នឹងគាំទ្រសកម្មភាពផ្សេងៗ ក្រៅក្រសួងផែនការ និង២០ភាគរយសំរាប់ក្រៅរាជរដ្ឋាភិបាល។

## ២.៤ សន្និដ្ឋាន

ទាក់ទងទៅនឹងការចាប់ផ្តើមនៃខែឧសភា ឆ្នាំ២០០២ ដែលមានអត្ថន័យរីកចំរើន បានធ្វើឡើងដើម្បីប្រតិបត្តិការចូលរួមរវាងរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ ក្នុងពេលដំណើរការរបស់ PRSP អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចបានសំរេចនូវសារៈប្រយោជន៍យ៉ាងសំខាន់ដោយមានការចូលរួមពីបណ្តាក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ម្ចាស់អំណោយ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ ផ្នែកឯកជន សហគមន៍អ្នកក្រីក្រ និងសង្គមស៊ីវិលផ្សេងទៀត។ ជាងនេះទៀតសំរាប់ធនាគារពិភពលោកដែលជាដៃគូរគន្លឹះរបស់រដ្ឋាភិបាល រួមទាំង UNFPA ,UNDP, WHO, DFID, CIDA និង GTZ ដែលសកម្មក្នុងការគាំទ្រលើដំណើរការ យ.ជ.ក.ភ ។ កន្លងមកដំណើរនេះធានាភាពជាម្ចាស់បានទូលំទូលាយ និងពង្រីកការពិគ្រោះយោបល់ជាមួយអ្នករួមចំណែក ។ ប៉ុន្តែ សកម្មភាពទាំងអស់នៅក្នុងផែនការសកម្មភាពនៃការចូលរួមមិនបានយកមកអនុវត្តន៍ទាំងអស់ទេ បណ្តាលមកពីពេលវេលាមានកំណត់ និង មានកង្វះខាតធនធានហិរញ្ញវត្ថុ និង ភាពរាំងស្ទះលើសមត្ថភាព។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចនឹងបន្ត ដំណើរការជាយន្តការសំរបសំរួលជាមួយបណ្តាក្រសួង រួមចំណែក អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងម្ចាស់ទុនឱ្យបានយល់ដឹងពីឱកាសសំរាប់ជួយ និងផ្តល់ថវិកាគាំទ្រសកម្មភាព។

# ជំពូក ៣: ទំហំនៃភាពក្រីក្រ

## ៣.១ ពហុទំហំនៃភាពក្រីក្រ

*“ស្ថិតនៅក្នុងភាពក្រីក្រ មិនគ្រាន់តែមានម្ហូបអាហារគ្រប់គ្រាន់សំរាប់ហូបនោះទេ ស្ថិតនៅក្នុងភាពក្រីក្រក៏ដូចជាការស្ថិតក្នុងភាពល្ងង់ខ្លៅ ដែលធ្វើឱ្យគេមើលងាយលើយើងហើយមិនអាចឧបត្ថម្ភ ក្នុងគ្រួសារផ្ទាល់ខ្លួនបាន”*

ប្រទេសកម្ពុជាស្ថិតនៅសំដាប់ទី ១៣០ ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស គឺទាបជាងប្រទេសភូមា និងឥណ្ឌា ។ ហើយចំនួននោះកាន់តែប្រសើរឡើងក្នុងរយៈពេលឆ្នាំ ១៩៩០-២០០០ គឺកើនពី ០,៥០១ ទៅ ០,៥៤៣ និងកំរិតអភិវឌ្ឍន៍យ៉េនឌ័រគឺ ០,៥៣៧ គឺទាបជាងគេនៅទ្វីបអាស៊ី និងកំរិតនៃភាពក្រីក្រគឺ ៤៣,៣ ភាគរយ ។ ហើយជាមធ្យមប្រជាជនកម្ពុជាមានអាយុ ៥៦.៤ ឆ្នាំ និង ៦៧,៨ ភាគរយនៃប្រជាជនមានសមត្ថភាពអាចអានអក្សរបាន ។ តាមការព្យាករណ៍ ចំណូលរបស់ប្រជាជនកម្ពុជាម្នាក់ៗនៅឆ្នាំ ២០០១ គឺ ២៥៩ ដុល្លាអាមេរិក ។

ក្នុងចំណោមកត្តាផ្សេងៗជាច្រើន សង្គ្រាមស៊ីវិល អូសបន្លាយជាច្រើនឆ្នាំ ការភៀសសឹក និងការរើសអើង ដំណើរការអភិវឌ្ឍន៍ គឺជាហេតុបណ្តាលចំបងនៃភាពក្រីក្រក្នុងប្រទេសកម្ពុជា ។ សព្វថ្ងៃនេះមានការទទួលស្គាល់យ៉ាងទូលំទូលាយភាពក្រីក្រគឺជាបញ្ហាពហុមុខ និងគួរតែសំលឹងមើលក្នុងបរិបទទូលំទូលាយមួយជាងពាក្យ កំណត់ភាពក្រីក្រដែលគ្រាន់តែសំដៅលើកំរិតទាបនៃការប្រើប្រាស់ និងចំណូលតែម្យ៉ាង ។ កង្វះខាតម្ហូបអាហារ ភាពប្រែប្រួលនៃការទទួលបាននូវធនធានធម្មជាតិ ភាពគ្មានអំណាច និងភាពអស់សង្ឃឹម ការស្ថិតនៅក្រៅសង្គម កង្វះការអប់រំ ។ល។ ទាំងអស់នេះគឺជាចំនុចសំខាន់ៗដែលត្រូវបានឱ្យក្នុងនិយមន័យនៃភាពក្រីក្រក្នុងឯកសារការវាយតំលៃនៃភាពក្រីក្រដោយមានការចូលរួមក្នុងប្រទេសកម្ពុជា បោះពុម្ពដោយធនាគារអភិវឌ្ឍន៍អាស៊ី នាឆ្នាំ ២០០១ (PPA2001) ។

ក្នុងប្រទេសកម្ពុជាភាពក្រីក្រ បានកើនឡើងយ៉ាងច្រើនដែលមានអត្រាពី ៣៦% នៃប្រជាជនកម្ពុជារស់ នៅក្រោមបន្ទាត់នៃភាពក្រីក្រ[៣] ចំពោះ ០,៤៦ ទៅ ០,៦៣ ដុល្លានៃអត្រាប្តូរប្រាក់បច្ចុប្បន្ន ។ ជាទូទៅអ្នកខ្លះទៀតបានរួចផុតពីភាពក្រីក្រ ។ ប្រការនេះនឹងធ្វើឱ្យមានការលំបាកក្នុងការកំណត់និយមន័យនៃបន្ទាត់ភាពក្រីក្រ ។ ដូច្នេះការបង្កើនចំណេះដឹង ស្តីពីខួប រដូវកាល និងការចូលមកដល់នៃវិបត្តិដោយមិនបានដឹងជាមុនមានសារៈសំខាន់ណាស់ ។ បច្ចុប្បន្នកំរិតនៃភាពក្រីក្រយ៉ាងខ្ពស់ គឺមកពីកំណើនប្រជាជនខ្ពស់កង្វះកាលានុវត្តភាព សមត្ថភាពទន់ខ្សោយ អសន្តិសុខ ការស្ថិតនៅក្រៅសង្គម និងភាពងាយរងគ្រោះ ។ ដូច្នេះមុននឹងយើងវាស់វែងភាពក្រីក្រតាមលក្ខណៈបច្ចេកទេសដំបូងយើងត្រូវតែស្គាល់ឱ្យបានច្បាស់ អំពីសារជាតិ បញ្ហាពហុមុខនៃភាពក្រីក្រ ។ សំរាប់ពេលនេះយើងផ្តោតអារម្មណ៍ទៅលើការគ្មានកាលាវត្តនុភាព កង្វះសមត្ថភាព ការស្ថិតនៅក្រៅសង្គម និងភាពងាយទទួលរងគ្រោះនៅក្នុងផ្នែកបន្ទាប់ខាងក្រោម ។ ការវាស់វែងភាពក្រីក្រ តាមលក្ខណៈបច្ចេកទេសនឹងទាក់ទងក្នុងផ្នែក ៣.២ ។

---

[៣] ក្រសួងផែនការ(២០០១) : របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស ។

## ៣.១.១ គន្លះភាពលាតុវត្តភាព

*“ជាធម្មតាគ្រួសារដែលក្រ គឺគ្រាន់តែផ្អែកលើការធ្វើស្រែហើយដែលការប្រមូលផលបានតិចតួច. PPA 2001.P14”*

ច្រើនជាង ៧០% នៃប្រជាជនកម្ពុជា ធ្វើការដើម្បីផលិតផលកសិកម្ម[4] (តារាង៣.១) ទោះជាយ៉ាងណា ១២-១៥% នៃកសិករពុំមានដីសំរាប់ប្រកបរបរកសិកម្ម។ ឯកសារពិគ្រោះយោបល់លេខ ១៦ បានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០០០ ដោយប្រើទិន្នន័យខុសគ្នាដែលបានបង្កើតឡើងតាមខ្សែកោង Loren និងគណនាតាមមេគុណ Gini សំរាប់ការបែងចែកដីធ្លី ។ ខ្សែកោងនេះបានបង្ហាញថាលំដាប់មនុស្ស ដែលក្របំផុតស្ទើរតែមិនមានដីកសិកម្មហើយមេគុណ Gini ក៏បានគណនាលើមូលដ្ឋានទិន្នន័យផ្សេងៗដែលដាក់ជាជួរ ០,៤៧-០,៦៦ ។ ឯកសារបានកត់សំគាល់ថា ការបែងចែកដីនៅកម្ពុជាពុំមានសមភាព ដោយអ្នកមានមួយចំនួនតូចកាន់កាប់ដីមានទំហំធំៗ ក្នុងខណៈដែលអ្នកក្រ ដ៏ច្រើនលើសលុបរស់នៅលើដីមានចំណែកតូចៗ ។ ខណៈនេះដែរអ្នកក្រមានសិទ្ធិកាន់កាប់ដី និងសិទ្ធិទទួលផលពីប្រភពធនធានធម្មជាតិផ្សេងៗ ដូចជា: ព្រៃឈើ និងត្រី មានកំណត់។ អតីតកងទ័ពខ្មែរក្រហមម្នាក់នៅខេត្តបន្ទាយមានជ័យបានដកស្រង់សំដី ក្នុង PPA 2001បាន និយាយថា: ខ្ញុំរស់នៅក្នុងគ្រួសារដ៏ក្រមួយដែលមានសមាជិកគ្រួសារ ១២នាក់ម្តាយខ្ញុំបានឈឺច្រើនឆ្នាំមកហើយ ។ យើងពុំមានអ្វីទាំងអស់រួមទាំងដីកសិកម្ម សត្វពាហនៈ ។ ដើម្បីរក្សាជីវិតម្តាយ យើងត្រូវតែលក់របស់ទាំងនោះដើម្បីចំណាយទៅលើថ្លៃថ្នាំពេទ្យសំរាប់ព្យាបាលគាត់ ។ ក្រោយពីនោះមកយើងក្លាយជាអ្នកស៊ីស្នូលលក់កំលាំងពលកម្មឱ្យគេហើយទន្ទឹមនឹងនោះយើងក៏បានចូលព្រៃដើម្បីកាប់ឈើយកទៅលក់ ។ ក៏ប៉ុន្តែអីឡូវនេះរដ្ឋាភិបាលមិនអនុញ្ញាតិឱ្យពួកយើងធ្វើដូច្នេះទៀតឡើយ ហើយយើងក៏មិនដឹងធ្វើអ្វីតទៅទៀតដែរ (PPA 2001)។ នៅក្នុងកំឡុងឆ្នាំ ១៩៩៨ និង២០០០ អត្រាកំនើនមធ្យមនៃការងារក្នុងវិស័យកសិកម្មគឺមានកំរិតទាបណាស់ (១,៦%) ។ ភាគច្រើនបំផុតនៃអ្នកក្រ (៧៩%) គឺជាក្រុមដែលមេគ្រួសារធ្វើការក្នុងវិស័យកសិកម្ម ។ ដូច្នេះហើយយុទ្ធសាស្ត្រដែលគាំទ្រអ្នកក្រ គឺជាជំរើសមួយដែលល្អ ក្នុងវិស័យកសិកម្ម ដែលអាចកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន ។ កាលានុវត្តន៍ភាពនៃការងារក្នុងវិស័យឧស្សាហកម្ម និង សេវាកម្មគឺនៅមានកំរិត (៨%និង១៨%នៃវិស័យទាំងពីតែប៉ុណ្ណោះ) ។ មានន័យថាវិស័យកសិកម្មដែលមានផលិតផលទាប និងបន្តស្រូបយកនូវកំលាំងពលកម្មដែលមានសក្តានុពលរហូតដល់វិស័យឧស្សាហកម្មនិងសេវាកម្មបានរីករាលដាល ។ ក្នុងវិស័យសេវាកម្មអត្រាកំណើនជាមធ្យមនៃការងារគឺមានកំរិតណាស់ ក្នុងខណៈពេលដែលក្នុងវិស័យឧស្សាហកម្មមានការកើនឡើងយ៉ាងច្រើន ក្នុងកំឡុងពេល ១៩៩៨-២០០០ (តារាង៣.១) និងសមាជិកគ្រួសារណាដែលមានមេគ្រួសារធ្វើការក្នុងវិស័យឧស្សាហកម្ម និងកសិកម្មហាក់ដូចជាមិនក្រទេ (៣,៨% និង ១១%នៃវិស័យទាំងពីរ ) ។

នៅក្នុងឆ្នាំ ១៩៩៩ មានប្រជាពលរដ្ឋកម្ពុជាតែ ១៥% ប៉ុណ្ណោះដែលប្រកបការងារដោយបានទទួលប្រាក់បៀវត្ស ។ អត្រានេះបែងចែកដូចតទៅ: នៅទីក្រុងភ្នំពេញមានរហូតដល់ ៩៣% ហើយនៅជនបទមានតែ១១% ប៉ុណ្ណោះ ។ ប្រាក់បៀវត្សជាមធ្យមប្រចាំខែគឺ ៤៣ដុល្លាអាមេរិច ។ មនុស្សចំនួន៤៦% បានប្រកាសខ្លួនឯងថាជាអ្នក ដែលធ្វើការនៅក្នុងគ្រួសារដោយគ្មានប្រាក់បៀវត្ស[5] ។ បើពិនិត្យតាមចំណាត់ថ្នាក់នៃភាពក្រីក្រតាមប្រភេទនៃការងារអត្រាក្រីក្រ ក្នុងចំណោមអ្នកធ្វើការដោយខ្លួនឯងមាន

[4] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) (២០០១) : សិទ្ធិកាន់កាប់ដីធ្លីក្នុងប្រទេសកម្ពុជា “ ធ្វើឱ្យមានបច្ចុប្បន្នភាពនៃ ទិន្នន័យ ” (ឯកសារពិភាក្សាលេខ ១៩)

[5] ក្រសួងផែនការ(២០០០) : របាយការណ៍ស្តីពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ១៩៩៩ ។

កំរិតខ្ពស់ជាងគេស្មើនឹង៣៩% ហើយអត្រាក្រីក្រក្នុងចំណោមមន្ត្រីរាជការមានកំរិតទាបជាងគេ[៦] ។ ស្ត្រីជាច្រើនដែលមានចំនួន ២០% នៅទីក្រុងភ្នំពេញ និងចំនួន ៦៨% នៅទីជនបទជាអ្នកធ្វើការក្នុងគ្រួសារដោយគ្មានប្រាក់បៀវត្សមានចំនួនតិចជាងគឺៈ ចំនួន ២៧% ក្នុងកំរិតប្រទេសទាំងមូល ៦% នៅភ្នំពេញ និង ៣០% នៅទីក្រុងជនបទ ។

**តារាង ៣.១ ចំនួនបុគ្គលិកតាមវិស័យសេដ្ឋកិច្ច**

| វិស័យ | ភាគរយនៃចំនួនបុគ្គលិកសរុប, ២០០០ ក | ការលូតលាស់ជាមធ្យម ១៩៩៨-២០០០ ខ | ភាគរយនៃភាពក្រីក្រតាមរយៈមេគ្រួសារ, ១៩៩៩ គ |
|---|---|---|---|
| កសិកម្ម | ៧៣.៧ | ១.៥៥ | ៧៨.៩ |
| ឧស្សាហកម្ម | ៨.៤ | ៤៣.២៩ | ៣.៨ |
| សេវាកម្ម | ១៧.៩ | ១.០៨ | ១១.០ |
| សរុប | ១០០ | ៣.៦៦ | |

**សំគាល់:** ក. ក្រសួងផែនការៈ ស្ថិតិប្រជាជនកម្ពុជា ២០០១, ខ. ការគណនាផ្អែកតាមទិន្នន័យរបស់ក្រសួងផែនការៈ ស្ថិតិប្រជាជន ២០០១, គ. ការគណនាផ្អែក តាមទិន្នន័យរបស់ក្រសួងផែនការៈ របាយការណ៏នៃភាពក្រីក្រកម្ពុជា ១៩៩៩ ដោយពុំមានតួលេខអត់ការងារ និងបាត់បង់កំលាំងពលកម្មរបស់មេគ្រួសារ

## ៣.១.២ កង្វះសមត្ថភាព

*“ ប្រសិនបើអ្នកចង់រស់នៅដោយគ្មានការលំបាក, ការខំសិក្សាគឺជាគន្លឹះមួយ, កុំរៀនតិចពេក, កុំមើលស្រាលនិងការសិក្សា, ប្រសិនបើអ្នកមានចំណេះដឹងគ្រប់គ្រាន់, ប្រាក់និងរត់រកអ្នកទោះបីអ្នកមិនដែលនឹកឃើញចង់បានវាក៏ដោយ ។ ង៉ុយ ភីរម្យ[៧] ,១៩៦៥-១៩៣៦ ( ច្បាប់ក្រមង៉ុយ ,វិជ្ជាស្ថានព្រះពុទ្ធសាសនា ១៩៩៨, P .7) “*

កង្វះនៅសមត្ថភាពតែងតែរាំងអ្នកក្រពីការខិតខំប្រឹងប្រែងរបស់គេឱ្យរួចផុតពីភាពក្រីក្រ ។ សូចនាករដែលពាក់ពន្ធ័នឹងសមត្ថភាពនៅក្នុងប្រទេសកម្ពុជា ដូចជាសុខភាព, អាហារូបត្ថម្ភ អត្រាមរណៈភាព, អត្រាការចូលរៀន ។ល។ ជាទូទៅនៅអន់ជាងគេបើប្រៀបធៀបជាមួយប្រទេសមួយចំនួននៅក្នុងតំបន់ ។ សូចនាករនេះ មានបង្ហាញនៅក្នុងតារាង ៣.២ ។

**តារាង ៣.២ ការប្រៀបធៀបសូចនាករគន្លឹះនៃការអភិវឌ្ឍន៍មនុស្សក្នុងកម្ពុជា និងតំបន់ប៉ាស៊ីហ្វិកខាងលិច ១៩៩៨**

| សូចនាករ | ប្រទេសកម្ពុជា ក. | តំបន់ប៉ាស៊ីហ្វិកខាងលិច ខ. |
|---|---|---|
| ថ្នាក់បឋមសិក្សា | ៧៨ | ៩៧.៨ |

[៦] ក្រសួងផែនការ( ២០០០ ) : ស្ថានភាពក្រីក្រនៅប្រទេសកម្ពុជា ១៩៩៩ ( ពង្រាង)

[៧] ង៉ុយ ភីរម្យ( ១៨៦៥-១៩៣៦ ) គឺជាកំណាព្យដែលល្បីល្បាញ ក្នុងប្រវត្តិសាស្ត្រសម័យទំនើបកម្ពុជា ។ ស្នាដៃនិពន្ធរបស់គាត់គឺតែងតែប៉ងទៅលើប្រពន្ធ័អប់រំទូទៅក្នុងប្រទេសកម្ពុជា ។

| | | |
|---|---|---|
| ថ្នាក់មធ្យមសិក្សា | ១៤ | ៥៨.៣ |
| អត្រាប្រជាជនអាចអានអក្សរ | ៧១ | ... |
| អត្រាកូនក្មេងស្លាប់ | ៨០ ដ. | ៣៨ |
| អាយុជាមធ្យមរបស់ប្រជាជន | ៥៤ | ៧៣ |
| កុមារពុំគ្រប់ទំងន់ ក្រោមអាយុ ៥ឆ្នាំ | ៤០ | ... |
| អត្រាមានទឹកស្អាតប្រើប្រាស់ | ២៥ ដ. | ... |

សំគាល់: ក. ក្រសួងសុខាភិបាល ១៩៩៩. ការវិភាគសុខាមាលភាពប្រជាជន ១៩៩៨ និងទិសដៅសំរាប់ការអភិវឌ្ឍន៍សុខាភិបាល ១៩៩៩-២០០៣. ខ. UNDP របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្ស ១៩៩៩. គ. MEYS/ UNESCO របាយការណ៍អង្កេតអត្រាអាចអានអក្សរបាន ៣៧ ភាគរយ. ឃ. ក្រសួងផែនការ ១៩៩៩: ជំរឿនប្រជាជនកម្ពុជា

## សុខភាពមានជំងឺ

*"យើងកើតមកសំរាប់តែស្លាប់ អ្នកឃើញទេក្នុងភូមិនេះមានមនុស្សចាស់ជាច្រើន និងក្មេងកំព្រាដោយគ្មានការឧបត្ថម្ភពីអ្នកណាទាំងអស់ ។ ឥឡូវនេះនៅក្នុងភូមិស្ទើរតែស្លាត់ជ្រងុំដោយសារឥទ្ធិពលអាក្រក់នៃជំងឺPPA 2001, P41"*

ការធ្លាក់ខ្លួនឈឺមានការទំនាក់ទំនងជាច្រើនដែលអាចបណ្តាលឱ្យមានភាពក្រីក្រ ។ សុខភាពខ្សោយគឺបណ្តាលអោយធ្លាក់ខ្លួនក្រ និងទំរង់ផ្សេងៗ ទៀតនៃការបាត់បង់សិទ្ធិក្នុងសង្គម (ឧទារណ៍: ការបាត់បង់ឱកាសនៃការសិក្សានិងការងារ) ។ វដ្តនៃភាពក្រីក្រ, ជំងឺ និងការចំណាយថៃទាំសុខភាពខ្ពស់នៃគ្រួសារនីមួយៗ (១១% PDP) គឺជាការបាត់បង់ប្រាក់សន្សំរបស់គ្រួសារកម្ពុជានីមួយៗ ។ ទស្សនាវដ្តីសុខាភិបាលដែលមានការចូលរួមឆ្នាំ ២០០០ បានរកឃើញថាធនធានគ្រួសារដែលរឹងមាំនៃបណ្តាញក្នុងវិស័យសុខាភិបាលពុំដែលប្រើប្រាស់ឱ្យមានប្រសិទ្ធភាពឡើយ ។

អ្នកក្រជានិច្ចកាលតែងតែមានសុខភាពពុំល្អ ។ ប្រជាជនកម្ពុជាដែលក្រមានបន្ទុកយ៉ាងធ្ងន់ធ្ងរនៃជំងឺ ។ អ្នកក្រហាក់ដូចជាពុំបានយល់ដឹងពីសុខភាពល្អ និងអនាម័យ ហើយប្រហែលជាកង្វះធនធានដើម្បីធានាការរស់នៅ នៅប្រកបដោយសុខភាពល្អ ។ ឧទាហរណ៍: ទឹកស្អាត អនាម័យ ការជ្រើសរើសម្ហូបអាហារ ការបង្ការជំងឺ ។ល។ ពួកគេទំនងជារស់នៅក្នុងលក្ខខ័ណ្ឌគ្មានអនាម័យ និងមនុស្សអ៊ូអរ ។ បញ្ហាចំបងៗដែលអាចការពារបាន ប៉ុន្តែជំងឺបានគំរាមកំហែងជីវិតជាញឹកញាប់ដែលអ្នកក្រភាគច្រើនបាននឹងប្រឈមមុខរួមមាន: ជំងឺគ្រុនចាញ់ រោគរបេង ជំងឺគ្រុនឈាម និង HIV/AIDS ។ អត្រាប្រេវ៉ាឡង់ខ្ពស់នៃជំងឺទាំងនេះជាបន្ទុកយ៉ាងធ្ងន់ដល់មនុស្សគ្រប់រូប ហើយជាពិសេសទៅលើអ្នកក្រ ។

*"កូនខ្ញុំពីរនាក់កើតជំងឺគ្រុនចាញ់ដែលបណ្តាលមកពីមូសខាំ ។ ខ្ញុំបានចំណាយអស់លុយកាក់ដើម្បីព្យាបាលពួកគេ ប៉ុន្តែពួកគេនៅតែពុំជា ទីបំផុតពួកគេបានស្លាប់ ហើយឥឡូវនេះខ្ញុំគ្មានទាំងកូនជាទីពឹង ខ្វះលុយកាក់ទៀតផង ។ PPA 2001,P26"*

**ជំងឺគ្រុនចាញ់** គឺជាគ្រោះបណ្តាល ដ៏ចំបងនៃជំងឺ និងមរណៈភាពជាពិសេសចំពោះអ្នកដែលមានលំនៅដ្ឋានក្នុងព្រៃ និងដើមកំណើតជាជនជាតិភាគតិច ។ គេបានប៉ាន់ប្រមាណថាចំនួនបាត់បង់ នៃការស្លាប់ពិតប្រាកដដោយសារជំងឺគ្រុនចាញ់គឺពី ៥-១០ ដងនៃតួលេខដែលបានស្រង់ជាផ្លូវការ ។ ការស្លាប់ដោយជំងឺគ្រុនចាញ់កើតឡើងជាញឹកញាប់ចំពោះគ្រួសារដែលក្រមែនទែនដោយរស់នៅតំបន់ដាច់ស្រយាល ។

**រោគរបេង** ថ្មីៗនេះគេបានប៉ាន់ប្រមាណនូវអត្រាគ្រោះថ្នាក់គ្រប់ប្រភេទនៃរោគ គឺ ៥៤០ ក្នុងចំណោម ១០០,០០០នាក់ ។ ចំនួននៃករណីថ្មីៗនៃរោគរបេងនៅទីកន្លែងសុខភាពសាធារណៈមានបីដងក្នុងកំឡុងពេលមួយទសវត្សកន្លងមកហើយ ។ រោគរបេងប៉ះពាល់ចំពោះអ្នកក្រដែលរស់នៅគ្មានអនាម័យ និងលក្ខខណ្ឌខ្វះអនាម័យ ។ ការរាលដាលនៃជំងឺហ៊ីវ បានកើតឡើងយ៉ាងខ្លាំងចំពោះអត្រាប្រេវ៉ាឡង់រោគរបេង ។ យោងតាមអង្គការសុខភាពពិភពលោក ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានបន្ទុកអត្រារោគរបេងខ្ពស់ដែលក្នុងចំណោមប្រទេស ២២ លើពិភពលោក ។ គ្រប់ទំរង់នៃករណីរោគរបេងអាចកើតឡើងពីរដងក្នុងប្រាំឆ្នាំបន្ទាប់ទៀត ។

**ហ៊ីវ/អេដស៍** ថ្វីបើបច្ចុប្បន្ននេះអត្រាប្រេវ៉ាឡង់ HIV/AIDS នៅក្នុងប្រទេសកម្ពុជាធ្លាក់ចុះក៏ពិតមែន ប៉ុន្តែនៅតែខ្ពស់បំផុតនៅក្នុងចំណោមប្រទេសអាស៊ី ។ ដោយឃើញថាការទទួលបាននូវសេវាសុខាភិបាលនៅមានកំរិតចំពោះអ្នកក្រ, តំលៃកាន់តែខ្ពស់ចំពោះជំងឺ រ៉ាំរ៉ៃ ដែលមានជាបន្តបន្ទាប់, ជំងឺដែលគំរាមគំហែងដល់ជីវិតដែលមានទំនាក់ទំនងជាមួយ HIV/AIDS គឺទំនងជាមានបន្ទុកយ៉ាងធ្ងន់ធ្ងរទៅលើអ្នកក្រ ។ ភាពក្រីក្រ និង HIV/AIDS គឺជាបញ្ហាដែលទាក់ទងគ្នា ហើយនឹងត្រូវបានបកស្រាយតទៅទៀតនៅផ្នែក ១.១.៤ ។

## មរណៈភាព និង កង្វះអាហារូបត្ថម្ភ

អត្រាមរណៈភាពម្តាយ, ទារក និងអាយុក្រោម៥ឆ្នាំ គឺខ្ពស់នៅក្នុងប្រទេសកម្ពុជា ។ អត្រាមរណៈភាពទារកគឺ ៩៥ ក្នុងកំណើត ១០០០ នាក់ និងអត្រាមរណៈភាពក្មេងក្រោមអាយុ ៥ឆ្នាំ គឺ ១២៤ ក្នុង ១០០០ នាក់ ក្នុងខណៈពេលដែលអត្រាមរណៈភាពម្តាយគឺ ៤៣៧នាក់ ស្លាប់ក្នុងចំណោម ១០០ ០០០ ដងនៃការសំរាលកូន។ គេបានសន្មតថាអត្រាទាំងនេះ នៅតែខ្ពស់ជាងក្នុងចំណោមប្រទេសដែលក្រនៅលើពិភពលោក ។ អត្រាមរណៈភាពទារកនៃប្រទេសដែលក្រគឺ ១១០ ក្នុងកំណើតទារក ១ ០០០ ដែលប្រៀបធៀបជាមួយប្រទេសអភិវឌ្ឍន៍គឺ ៥០ ក្នុងកំណើតទារក ១ ០០០ (DHS 2000 ) ។

ថ្វីបើប្រទេសកម្ពុជាបច្ចុប្បន្នបានប្រកាសផ្តល់ថ្នាំស្វិតដៃជើងដោយមិនគិតថ្លៃ ប៉ុន្តែជំងឺនិងមរណៈភាពក្មេងក្រោមអាយុ ៥ឆ្នាំ នៅកម្ពុជាស្ទើរតែ ២ដង នៅប្រទេសឥណ្ឌូនេស៊ី និង៣ដង នៅប្រទេសវៀតណាម រឺពីលីពីន គឺនៅមានកំរិតខ្ពស់នៅឡើយ ។ នេះបណ្តាលមកពីតំបន់គ្របដន្តប់នៃការចាក់ថ្នាំបង្ការនៅទាប ហើយការទទួលការបណ្តុះបណ្តាលអ្នកផ្តល់សេវាកម្មថ្នាំពេទ្យសំរាប់ព្យាបាលជំងឺកុមារនៅមានកំរិត ។ ឧទាហរណ៍: ៣៨% ប៉ុណ្ណោះនៃប្រជាជនក្រីក្រជនបទបានគ្របដណ្តប់ដោយកម្មវិធីការចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹល ប្រៀបធៀបជាមួយ ៦៣% នៅជនបទ និង ៦៦% នៅទីប្រជុំជននៃប្រទេសអភិវឌ្ឍន៍ (DHS 2000 ) ។ ជាការព្រួយបារម្ភភាគរយនៃក្មេងស្រីក្នុងនៃប្រជាជនដែលក្របំផុតគឺនៅប្រហែល ៣៥% នៅឡើយ ។

**កង្វះអាហារូបត្ថម្ភ ថាមពល ប្រូតេអ៊ីន** គឺជាបញ្ហាយ៉ាងធំក្នុងប្រទេសកម្ពុជាដែលជះឥទ្ធិពល ៤៥% នៃកុមារអាយុ ៦-៥៩ខែ ហើយយ៉ាងហោចណាស់ ២០% ទៅលើស្ត្រី ។ កង្វះអាហារូបត្ថម្ភ គឺគ្រោះអាសន្នយ៉ាងស្ងប់ស្ងាត់មួយដែលអាចបណ្តាលឱ្យបាត់បង់ផ្នែកសេដ្ឋកិច្ចគ្រួសារ និងការបាត់បង់ជីវិត ។ ទាំងនេះវាគឺជាបញ្ហាចំបងពីរ ទាំងហេតុផលចំបង និងទាំងលទ្ធផលនៃភាពក្រីក្រ ។ នៅអាយុ២ឆ្នាំ ស្ទើរតែពាក់កណ្តាលនៃកូនក្មេងកម្ពុជា គឺស្ថិតនៅក្នុងភាពកង្វះអាហារូបត្ថម្ភរួចជាស្រេច និងកង្វះខាតមីក្រូអាហារសំបូរជីវជាតិប៉ូវ ។ ជាទូទៅកូនក្មេងដែលរស់នៅក្នុងគ្រួសារដែលក្រនៅជនបទ គឺជាសភាពស្គមខុសខ្នាត

(១៦%) ជាងគ្រួសារដែលមាន ហើយរស់នៅតាមជនបទ (៦%) រឺទីប្រជុំជន (៥%) (DHS 2000 ) ។ ក្មេងស្រីដែលមានគ្រួសារក្រ គឺជាក្រុមដែលជះឥទ្ធិពលខ្លាំងបំផុត (១៩%) ។

គេបានប៉ាន់ស្មានថាអត្រាមរណៈភាពក្មេងក្រោមអាយុ៥ឆ្នាំ ២នាក់ក្នុងចំណោម ៣នាក់ គឺទាក់ទង និងកង្វះអាហារូបត្ថម្ភ ។ ក្នុងចំណោមស្ត្រីដែលស្ថិតនៅអាយុបង្កើតកូន សន្ទស្សន៍មាសមាឌនៃខ្លួនមនុស្សទាប (BMI<18,5kg/m2) បានរាយការណ៏ថាមាន ២០% (CDHS 2000) ។ ទារកដែលមានទំងន់ស្រាល (តិចជាង២៥០ក្រាម) ដែលជាសូចនាករមួយនៃសុខភាពខ្សត់ខ្សោយ និងស្ថានភាពអាហារូបត្ថម្ភរបស់ម្តាយមិនគ្រប់គ្រាន់នាំឱ្យការលូតលាស់នៃទារកយឺត រឺក៏អត្រាមរណៈភាពទើបនឹងកើតខ្ពស់ និងអត្រាមរណៈរបស់ទារកខ្ពស់ដែលបានរាយការណ៏ប្រហែល ១៥% ។ តួលេខទាំងនេះត្រូវបានប៉ាន់ប្រមាណដោយឱ្យភាគរយទាបនៃទារកទើបកើតដែលមានទំងន់ ។ កង្វះអាហារូបត្ថម្ភចាប់ផ្តើមភ្លាមក្នុងជីវិត ហើយវាជាប់ទាក់ទងនឹងចិត្តវិទ្យា និងការរីកលូតលាស់ខួរក្បាលនៃក្មេង ។ កង្វះអាហារូបត្ថម្ភរាំងពួកគេពីការរីកលូតលាស់ដ៏ល្អបំផុត ហើយរួមមានទាំងសមត្ថភាពរបស់ពួកគេក្នុងការប្រយុទ្ធនៃភាពក្រីក្រ ។ ការស្វែងរកភាពឆ្លាតវៀងវៃក្នុងដំណាក់កាលចុងក្រោយចុងក្រោយនៃជីវិតនឹងមិនដែលបានបញ្ចប់ ។ ការហូបមិនគ្រប់គ្រាន់គឺជាកត្តាមួយដែលបាត់បង់ចំណេះដឹងយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ដូចជា ប្រទេសកម្ពុជាជាដើម ។ កង្វះអាហារូបត្ថម្ភថាមពលប្រូតេអ៊ីន គឺ មានការជាប់ទាក់ទង និងការខ្វះខាតមីក្រូអាហារសំបូរជីវជាតិប៉ូវ ។

**កង្វះខាតវីតាមីនអា (VAD)** គឺជាបញ្ហាសុខភាពសាធារណៈក្នុងចំណោមក្មេង និងស្ត្រីនៃខេត្តមួយចំនួន ។ ទិន្នន័យជាតិស្តីពីជំងឺខ្វាក់មាន់ ក្នុងចំនោមស្ត្រីមានគិភគឺ ៨% ។ កង្វះខាតវីតាមីនអា គឺជាហេតុដែលបណ្តាលឱ្យក្មេងមានជំងឺខ្វាក់មាន់ដែលអាចការពារបានហើយវាក៏មូលហេតុចំពោះសមាមាត្រដ៏ធំនៃជំងឺ និងការស្លាប់របស់កូនក្មេង និងមូលហេតុផ្សេងៗទៀតដែលចំណាយថវិកាយ៉ាងខ្ពស់ ។

**ភាពស្លេកស្លាំង កង្វះជាតិដែក** អត្រាប្រេវ៉ាឡង់នៃភាពស្លេកស្លាំងនៃកង្វះខាតជាតិដែក ចំពោះកូនក្មេងអាយុ ក្រោម៥ឆ្នាំ គឺ ៦៣%, អត្រាសំរាប់ស្ត្រីគឺ ៥៨% និងសំរាប់ស្ត្រីមានគិភគឺខ្ពស់ជាង ៦៦% វាគឺជាកត្តាមួយដែលជាប់ទាក់ទង និងអត្រាមរណៈភាពម្តាយខ្ពស់ ។ ជាទូទៅកូនក្មេងដែលមានភាពស្លេកស្លាំងខ្ពស់ចំពោះប្រជាជនដែលក្រ ។ ក្នុងខណៈពេលដែល ៧០% នៃកូនក្មេងដែលក្ររស់នៅជនបទបានប្រឈមមុខ និងភាពស្លេកស្លាំង តែ ៤៨% ប៉ុណ្ណោះ ហើយ ៥០% នៃកូនក្មេងដែលមានរស់នៅជនបទ និងទីប្រជុំជនដែលប្រឈមមុខ និងភាពស្លេកស្លាំងនេះ (DHS 2000) ។

**កង្វះជាតិអ៊ីយ៉ូដ** អាចកាត់បន្ថយភាពឆ្លាតវាងវៃ ច្រើនដូចជា ១៣ ទៅ ២១ នៃ IQ ចំនុច ។ ការធ្វើអង្កេតជាតិលើកទី១ ស្តីពីជំងឺពកក (MOH 1997 ) បានរាយការណ៏ថា ការធ្វើអត្រាជំងឺពកកសរុបគិតជាមធ្យមប្រហែល១២% នៅក្នុងក្រុមអាយុ ៨-១២ឆ្នាំ ប៉ុន្តែមានតំបន់មួយចំនួនគឺមានអត្រាជំងឺពកកច្រើនដល់ ៤៥% ។ ការទទួលបាននូវមានក៏រិត រឺក៏កង្វះខាតការប្រើប្រាស់អំបិលអ៊ីយ៉ូដ គឺជាកត្តាជំងឺជំងឺពកកមួយក្នុងចំណោមកត្តាផ្សេងៗទៀត ។ ទិន្នន័យ (DHS 2000)បានបង្ហាញថា ៨% នៃអ្នកក្រនៅជនបទបានទទួលអំបិលអ៊ីយ៉ូដ ធៀបនឹង ២៩% នៃអ្នកមាននៅជនបទ និង៣៩% នៃអ្នកមាននៅទីប្រជុំជន។

### កង្វះការអប់រំ និង មុខជំនាញ

ប្រជាជនខ្មែរនិយាយថា *"ចំណេះដឹងការសិក្សាគឺប្រសើរជាងការប្រើកំលាំងដោយដៃ"* ជនក្រីក្រភាគច្រើនមានមេគ្រួសារដែលទទួលបាននូវការអប់រំតិចតួចជាងកម្រិតមធ្យម ។ អត្រានៃភាពក្រីក្រមានកំរិតខ្ពស់នៅក្នុងគ្រួសារ ទាំងឡាយដែលមេគ្រួសារដែលពុំបានរៀនសូត្រនៅសាលា (៣៨%) ឬក៏រៀនបានត្រឹម តែបឋមសិក្សា(៣៩%) ។ ប្រភេទធំទាំង ពីរនេះមានសមាមាត្រស្មើនឹង ៧៧% នៃជនក្រីក្រ ។ អត្រានៃភាពក្រីក្រនៅក្នុងគ្រួសារដែលមេគ្រួសារបានបញ្ចប់មធ្យមសិក្សាកំរិតមួយធ្លាក់មកនៅត្រឹម ៣២% និងមេគ្រួសារដែលរៀនចប់មធ្យមសិក្សាកំរិតពីរគឺ ២៤% ។ នៅក្នុងគ្រួសារដែលមេគ្រួសាររៀនចប់ថ្នាក់ឧត្តមសិក្សានោះអត្រានៃ ភាពក្រីក្រចុះមកនៅត្រឹម ៧% ប៉ុណ្ណោះ ។

នៅតំបន់ជនបទលំដាប់អ្នកក្រីក្របំផុតបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាមានអត្រា៥០% ទាបជាងយ៉ាងច្រើន ៧៥% នៃលំដាប់ថ្នាក់អ្នកមានបំផុត ។ តិចជាង ៥% នៃកុមារនៅជនបទដែលមានអាយុពី ១២-១៤ ឆ្នាំក្នុងលំដាប់ថ្នាក់អ្នកក្របំផុតបានចុះឈ្មោះចូលរៀននៅសាលាអនុវិទ្យាល័យមានកំរិតទាបជាង បើប្រៀបធៀបក្នុងលំដាប់ថ្នាក់អ្នកមានបំផុតគឺ ២៥% ។ ការចុះឈ្មោះចូលរៀននៅទាប និងការសំរេចចិត្តរបស់កុមារក្រីក្រនៅដំណាក់កាលនេះ បានបង្ហាញថាភាពក្រីក្រនឹងឆ្លងកាត់រយៈពេលយ៉ាងវែងពីការកើនឡើងប្រាក់ចំណូលទៅថ្ងៃអនាគត ។

បញ្ហានានាដែលជាឧបសគ្គបានកើនឡើងពីការចុះឈ្មោះចូលរៀន និងសំរេចចិត្តរបស់កុមារក្រីក្រត្រូវប្រឈមមុខបញ្ហាជាច្រើន ។ កុមារទាំងនោះ គឺមានកំរិតទាប ទាំងធនធានសាធារណៈ និងឯកជន ឬគ្រួសារ, ហើយការបោះបង់ចោលសាលារៀន, ប្រៀបធៀបទៅនឹងកុមារអ្នកមានពេលដែលពួកគេបានចុះឈ្មោះចូលរៀនមានកំរិតខ្ពស់ (ឧទាហរណ៍: ការចុះឈ្មោះរៀនពុំបង្ហាញពីភាពខុសគ្នាខ្លាំងទេ ។ ការចែករំលែកនៃការអប់រំនៅក្នុងគ្រួសារ ការចំណាយលើការប្រើប្រាស់របស់អ្នកក្រ គឺតិចជាង ១,១% បើប្រៀបធៀបទៅប្រហែល ១,៥% ចំពោះគ្រួសារអ្នកមាន (ការវាយតំលៃភាពក្រីក្រកម្ពុជាដោយធនាគារពិភពលោក១៩៩៩) ។ បញ្ហាផ្សេងទៀត គឺដោយកុមារក្រីក្រ ឬការងាររកប្រាក់ចំណូលដើម្បីទ្រទ្រង់គ្រួសារនិងជីវិត រស់នៅរបស់ពួកគេ (មើលប្រអប់ ១)

មូលហេតុផ្សេងៗ ទៀតចំពោះការចូលរៀនបានរីកចំរើន ក្នុងចំណោមកុមារក្រីក្រត្រូវបានគេរាយការណ៍ដោយ MOEYS/UNESCO ២០០០ រាប់បញ្ចូលទាំងភាពក្រីក្ររបស់ឳពុកម្តាយ សេចក្តីត្រូវការនៅផ្ទះ ការបង្រៀនខ្សត់ខ្សោយ ចំងាយផ្លូវទៅសាលាឆ្ងាយ ការរៀនសូត្រពុំមានប្រយោជន៍ និងការផ្លាស់ប្តូរទីកន្លែងរបស់គ្រួសារ ចំពោះបញ្ហាផ្សេងៗ ទាំងនេះមានក្នុង (តារាង៣.៣) ។ ការធ្វើអង្កេតនេះបានរកឃើញផងដែលថាការអប់រំក្មេងជំទង់ដោយធ្វើទឹកចិត្តឱ្យមានការអប់រំកុមារ ។ គេបានរាយការណ៍ថា "មនុស្សដែលរស់នៅបរិស្ថានមិនចេះអក្សរមាននិន្នាការសំដៅឆ្ពោះទៅរកអ្វី ដែលពួកគេបានរៀននៅឯសាលាហើយក៏ធ្លាក់ទៅក្នុងអនក្ខរភាព " ។ ផ្ទុយទៅវិញ ការបោះបង់ចោលសាលាជាញឹកញាប់មានតែបន្តិចបន្តួច ហើយពួកគេចងចាំបានយូរអង្វែង ដោយពួកគេក៏អរគុណចំពោះគ្រួសារពួកគេដែលផ្តល់ឱកាសឱ្យពួកគេចេះអានបាន និងរក្សាទុកចំណេះដឹងដែលបានទទួល" ។ ដូច្នេះកម្មវិធីអប់រំល្អៗ គួរធានាការចុះឈ្មោះចូលរៀន និងបន្តចុះឈ្មោះឱ្យកុមារក្រីក្រ ទៅតាមការចង្អុលបង្ហាញគ្រប់បញ្ហាដែលជាប់ពាក់ព័ន្ធទំនងដ៏ទៃទៀត ។

### ប្រអប់ទី១: កូនអ្នកក្រ និងឱកាសសំរាប់ការសិក្សា

ពលកម្មកុមារមានសារៈសំខាន់ណាស់ចំពោះគ្រួសារ ប៉ុន្តែត្រូវបានគេពិចារណាពីផលប៉ះពាល់ចំពោះអនាគតរបស់កុមារ និងមានកត្តារាំងស្ទះដែលជះឥទ្ធិពលដល់ការកាត់បន្ថយភាពក្រីក្រ ។ ក្នុងចំណោមបណ្តាប្រទេសអាស៊ីអាគ្នេយ៍កម្ពុជាមានសមាមាត្រកុមារដែលមានអាយុ ១០-១៤ ឆ្នាំ សំខាន់ជាងគេដែលសកម្មក្នុងវិស័យសេដ្ឋកិច្ច (MOP/HDR, 2000) ។ ដូច្នេះសមាមាត្រ នេះគឺពិតជាខ្ពស់ជាងថៃ ០,១% នៃចំណុច ។ របាយការណ៍នេះបានរកឃើញថាសមាមាត្រកុមារដែលអាយុ ៥-៩ ឆ្នាំ ដែលបានធ្វើ ឬមានការងារប្រហែល៣% ខណៈដែល១០% នៃកុមារមានអាយុ១០-១៣ ឆ្នាំ បានធ្វើគឺមានការងារធ្វើក្នុងកំឡុងពេលធ្វើអង្កេត ។ នេះបញ្ជាក់ថាកុមារជាច្រើន បានបាត់បង់ឱកាសចូលរៀនដោយសារតែ គេធ្វើការ ដើម្បីទ្រទ្រង់គ្រួសាររបស់ពួកគេ ។

NIS/ LFS 2000 បានប៉ាន់ប្រមាណថា អត្រាចូលរួមកំលាំងពលកម្មកុមារដែលមានអាយុ ១០-១៤ ឆ្នាំមាន៩,១% ។ NIS/ LFS បានរាយការណ៍ថាអត្រាចូលរួមកំលាំងពលកម្មក្នុងតំបន់ជនបទគឺខ្ពស់ជាង១១% បើប្រៀបធៀបទៅនឹងតំបន់ទីក្រុងហើយបានសរុប សន្និដ្ឋានថាការចូលរួមខ្ពស់ជាងក្នុងវិស័យកសិកម្ម ហើយសមាមាត្រនៃការចូលរួមក្នុងការរៀនសូត្រក្នុងតំបន់ជនបទទាបជាងអាចមកពីមូលហេតុខ្លះខុសៗគ្នា ។ MOP/HDR បានរាយការណ៍ផងដែលថានៅអាយុលើស៥-៩ ឆ្នាំ អត្រាការចូលរៀនរបស់កុមារដែលធ្វើការគឺមានកំរិតទាបជាងកុមារដែលមិនធ្វើការងារ ។ ហើយកុមារប្រទេសនេះបានបង្ហាញថាកុមារ កម្ពុជាភាគច្រើនមានអាយុ ១០-១៧ ឆ្នាំជាពិសេសកុមារីដែលមិនបានចូលសាលា ។ ដូច្នេះកុមារក្រីក្រត្រូវបានគេរំខានយ៉ាងពេញទំហឹងនូវឱកាសសិក្សារបស់ពួកគេ ។ ទោះបីជាយ៉ាងណាក៏ដោយក៏ស្ថានភាពបែបនេះនឹងនៅតែបន្ត ។

### តារាង ៣.៣ មូលហេតុនៃការបោះបង់សាលា

| មូលហេតុ | ប្រុស(%) | ស្រី (%) |
|---|---|---|
| ឪពុកម្តាយក្រីក្រ | ២២,៣ | ១៩,០ |
| តំរូវការនៅផ្ទះ | ២១,៦ | ២១,១ |
| ការបង្រៀនអ្នកក្រ | ០,៤ | ០,៤ |
| ចំងាយទៅសាលា | ២,៩ | ២,៩ |
| ការរៀនសូត្រគ្មានប្រយោជន៍ | ០,៤ | ០,៣ |
| គ្រួសារបំលាស់ទី | ៣,៩ | ៣,៩ |
| មូលហេតុផ្សេងៗ | ១១,០ | ៨,៨ |
| មិនឆ្លើយតប | ៣៧,៥ | ៤៣,៦ |

ប្រភព: MOEYS/UNESCO(2000) :របាយការណ៍ពីការវាយតំលៃរបស់កំរិតចេះអក្សរតាមតួនាទីរបស់ ប្រជាជន នៅកម្ពុជា ។

**គ.ខ.ការទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន**

*"នៅរដូវវស្សាមានទឹកភ្លៀងច្រើនណាស់ ដូច្នេះហើយយើងត្រូវតែភ្ញាក់ពីព្រលឹមដើម្បីប្រកួតប្រជែងជាមួយអ្នកផ្សេងទៀត ដើម្បីឱ្យបាននូវដែលទឹកភ្លៀងមាន ។ ទឹកភ្លៀងឥឡូវនេះមិនសូវជាស្អាតទេ ជួនកាលកូនៗរបស់ យើងមានជំងឺរាគរូសដោយសារផឹកទឹកមិនស្អាត, PPA 2001 , P.30"*

នៅក្នុងប្រទេសកម្ពុជាអ្នកក្រមានលទ្ធភាពតិចតួចដើម្បីទទួលនូវសេវាកម្មសង្គមកិច្ច បើប្រៀបធៀបជាមួយនឹងអ្នកមានទ្រព្យសម្បត្តិ ។ ប្រជាជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ក្រីក្រជាងគេ ចំនួន ២១% ត្រូវធ្វើដំណើរជាង ៥គីឡូម៉ែត្រ ដើម្បីទៅដល់មជ្ឈមណ្ឌលសុខភាព ក្នុងខណៈពេលដែលប្រជាជនស្ថិតនៅក្នុងលំដាប់ថ្នាក់មានជាងគេដែលអត្រានេះមានក៏រិត ១៤% ។ ប្រជាជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ក្រីក្រជាងគេចំនួន ៦% រស់នៅចូលឆ្ងាយពីផ្លូវចំនួន៥គីឡូម៉ែត្រ បើធៀបទៅនឹងប្រជាជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់មានជាងគេ ដែលអត្រានេះមានចំនួន ១,៤% ។ ការវាយតំលៃភាពក្រីក្រដែលមានការចូលរួមរបស់គេ ឆ្នាំ២០០១ បានរកឃើញថាមានមណ្ឌលសុខភាពដែលមិនដំណើរ ៨៥% ក្នុងចំណោម ១៥៤ នៃភូមិក្រដែលបានអង្កេត ។ ហើយតិចជាង៣០% នៃមណ្ឌលទាំងនោះអាចទៅដល់ដោយយានយន្តនៅរដូវវស្សា ។ ប្រជាជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ក្រីក្រជាងគេចំនួន ៤% បានទទួលនូវការប្រើប្រាស់ទឹកម៉ាស៊ីន បើធៀបទៅនឹងប្រជាជនដែលស្ថិនៅក្នុងលំដាប់ថ្នាក់មានជាងគេ ដែលអត្រានេះមានចំនួន ១៧% ។ ក្នុងខណៈពេលដែលប្រជាជននៅជនបទ ដែលស្ថិតនៅក្នុងលំដាប់ថ្នាក់មានជាងគេ ២០% បានទទួលភ្លើងបំភ្លឺឯកជនដែលតិចជាង ១% នៃប្រជាជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ក្រីក្រជាងគេដែលទទួលសេវាដូចគ្នា ។ ដូចគ្នានេះដែរ អ្នកក្រទទួលបានភាពងាយស្រួលនៃអនាម័យនៅមានក៏រិត រឺក៏អត់មានតែម្តង ។ នៅក្នុងតំបន់ជនបទភាគច្រើននៃអ្នកក្ររស់នៅប្រហែលជា ៨៤% មិនបានប្រើប្រាស់ រឺគ្មានបង្គន់អនាម័យត្រឹមត្រូវ ។

## ៣.១.៣ ការស្ថិតនៅក្រៅសង្គម

តាមទិន្នន័យការស្ថិតនៅក្រៅសង្គមគឺជារបាំងដែលរារាំងអ្នកក្រីក្រ មិនឱ្យចូលរួមពេញលេញនៅក្នុងចរន្តរបស់សង្គមដោយសារកត្តាទាំងឡាយដូចជាភាពអវិជ្ជា ការគ្មានលទ្ធភាពចូលរួមក្នុងការសំរេចចិត្តនានា និងច្បាប់ ការរើសអើងដោយឈរលើមូលដ្ឋាននៃយេនឌ័រ និងជាតិសាសន៍, អំពើពុករលួយ ។ល។

**អនក្ខរកម្ម** គឺជារនាំងចំពោះអ្នកក្រ ដើម្បីបង្កើតនូវជីវិតរបស់ពួកគេស្ថិតនៅក្រៅដំណើរការអភិវឌ្ឍន៍ទាំងចេតនា រឺអចេតនា ។ ថ្វីត្បិតតែអនក្ខរជនត្រូវបានគេមើលងាយយ៉ាងខ្លាំងក្នុងសង្គមកម្ពុជា ហើយខ្លួនឯងមានអារម្មណ៍ថា ជាអ្នកស្ថិតនៅក្រៅសង្គមដោយខ្លួនឯង ។ ធាតុពិតគឺថាអ្នកអវិជ្ជាបានដឹងថាខ្លួនជាអ្នកខ្ជិល ហើយតែងតែមានអារម្មណ៍ថាបានប្រព្រឹត្តិអំពើអបាយមុខផ្សេងៗ ។ នៅក្នុងកំណាព្យរបស់លោក ង៉ុយ ភិរម្យ បានតែងដូចខាងក្រោម *"មនុស្សម្នាក់ដែលអវិជ្ជាពីព្រោះការខ្ជិលច្រអូសរបស់គាត់ គាត់មើលទៅមានកាយសម្បទាទរឹងមាំ ហើយសង្ហាក៏ប៉ុន្តែល្ងង់ខ្លៅ ប្រសិនបើគាត់មិនចេះអក្សរ ប្រសិនបើប្រៀបធៀបការសិក្សាគឺជាចៅហ្វាយនាយ ហើយអនក្ខរភាព គឺជាអភ័ព្វ និងគ្មានកិត្តិយស"* ។

**ស្ត្រី** ក្នុងប្រទេសកម្ពុជាមិនបានសប្បាយ និងការទទួលបានស្មើភាពគ្នាចំពោះការសិក្សា, ការងារដែលមានប្រាក់បៀវត្ស, សិទ្ធិកាន់កាប់ដីធ្លី និងសិទ្ធិទ្រព្យសម្បត្តិផ្សេងៗ ។ ស្ត្រីក៏ទទួលរងនូវសេវាកម្មសុខភាពបន្តពូជតិចតួចផងដែរ ។ ពួកគេជាទូទៅស្ថិតនៅក្នុងការចាញ់ប្រៀបនៃគ្រួសារ និងសង្គម ។ បញ្ហាយេនឌ័រនេះ និងពន្យល់ច្រើនតទៅទៀតនៅផ្នែក ៣.៦ ។

**ជនជាតិភាគតិច** គឺច្រើនតែស្ថិតនៅគុណវិបត្តិនៃដំណើរអភិវឌ្ឍន៍ ដោយសារតែកង្វះអ្នកតំណាងក្នុងកិរិតគ្រប់គ្រង និងបញ្ញាត្តិ ។ ពួកគេក៏ជាក្រុមបាត់បង់ផលប្រយោជន៏ និងក្រុមបន្ទាប់បន្សំដោយសារតែឧបសគ្គនៃភាសារផ្លូវការ ។ ឧទាហរណ៏ ភាគច្រើននៃជនជាតិភាគតិចនៅកម្ពុជា លើកលែងតែវៀតណាម និងចាម ភាសារសរសេរខ្លួនឯងហើយនិយាយបន្តិចបន្តួច រឺគ្មានភាសារខ្មែរជាផ្លូវការ ។ នេះដូចជាការខ្ទប់នូវសំលេងព្រួយបារម្ភរបស់ពួកគេ ។ ឯកសារការវាយតំលៃភាពក្រីក្រដោយមានការចូលរួម ២00១ បានស្រង់សំដីជនជាតិភាគតិចកួយថា "ពីរឺបីនាក់ ក្នុងចំណោមពួកយើង និយាយភាសារខ្មែរបានល្អគ្រប់គ្រាន់ក្នុងប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមន្ត្រីរាជរដ្ឋាភិបាលថ្វីបើយើងចង់" ។ ជនជាតិភ្នង ក៏បានសំដែងសេចក្តីព្រួយបារម្ភ ដូចគ្នានេះដែរ PPA 2001 ។

**ហ៊ីវ/អេដស៍** អស់រយៈពេលមួយទសវត្សកន្លងមកហើយ HIV/AIDS បានធ្វើឱ្យជនរងគ្រោះបាត់បង់នូវសេចក្តីសង្ឃឹមទៅថ្ងៃអនាគតរបស់ពួកគេ ហើយនិងលទ្ធភាពរស់នៅស្មើសិទ្ធិដូចពលរដ្ឋធម្មតា ។ ការសែតភ្នំពេញប៉ុស្តិចេញផ្សាយ ១៩ ខែ កក្កដា ទៅ ១ សីហា ឆ្នាំ២00២ បានបង្ហាញរូបភាពស្ត្រីម្នាក់ អាយុ ២៦ឆ្នាំ រង់គ្រោះដោយជំងឺ អេដស៏ដែលត្រូវបានបោះបង់ដោយគ្រួសាររបស់នាង ហើយក្លាយទៅជាអ្នកគ្មានផ្ទះសំបែងរស់នៅលើចិញ្ចើមថ្នល់ក្នុងទីក្រុងភ្នំពេញ ឆ្នាំ ២000 ។ បញ្ហា HIV/AIDS និងមានបរិយាយច្រើនតទៅទៀតនៅផ្នែក ៣.១.៤ ។

## ៣.១.៤ កង្វះអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អត្រូវមានៈ តម្លាភាព ការធានាអះអាង និងការព្យាករណ៏ទុកជាមុន ។ ដូច្នេះ អ្វីដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងកន្លងមកត្រូវកែលំអ អភិបាលកិច្ចក្នុងស្ថាប័នសាធារណៈធាតុផ្សំទាំងនេះត្រូវប្រឈមមុខនឹងភាពខ្វះចន្លោះខ្លះនៅកម្ពុជា ។ ភាពខ្វះចន្លោះនៃអភិបាលកិច្ចល្អមានការផលប៉ះពាល់យ៉ាងខ្លាំងពិតប្រាកដទៅលើភាពក្រីក្រ ហើយធ្វើឱ្យរាំងស្ទះចំពោះការប្រយុទ្ធប្រឆាំងភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។ បញ្ហាមួយចំនួននៃអភិបាលកិច្ច ដែលបានអះអាងមានដូចខាងក្រោមនេះ

**កង្វះការទទួលបានពត៏មានពីរាជរដ្ឋាភិបាល និងការធ្វើសេចក្តីសំរេច** បានរាំងអ្នកក្រពីការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គម ការផ្តល់ឱ្យនូវចន្លោះខ្វះខាតពីគោលនយោបាយ និងការអនុវត្តន៏របស់រាជរដ្ឋាភិបាល និងផលដែលសំរេចបាន ។ ហើយគោលនយោបាយនោះមានការប៉ះទង្គិចដល់ប្រជាជននៅមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន និងចំណង់ចំណូលចិត្តរបស់ឈ្មួញឯកជន ។ ជំលោះទាំងនេះតែងតែកៀបសង្កត់សិទ្ធិអ្នកក្រ ច្រើនជាងជួយពួកគាត់ ។ ក្រុមហ៊ុនកាប់ព្រៃឈើនេះមកឃុំរបស់យើង ហើយប្រាប់ពួកយើងថា គេមានសិទ្ធិផ្តាច់មុខនៃការកាប់ឈើក្នុងព្រៃនេះ ។ គេបានបង្ហាញយើងនូវឯកសារមួយដែលមានចុះហត្ថលេខាពីរាជរដ្ឋាភិបាលដែលយើងមិនបានដឹង ។ តិចជាងមួយខែក្រោយមកទាហានដែលធ្វើការក្នុងក្រុមហ៊ុននេះបានដុត

រទេះគោជាច្រើនរបស់អ្នកភូមិ ហើយបានបាញ់សំលាប់ម្នាក់ ។ យើងមានការភ័យខ្លាចយ៉ាងខ្លាំង ប៉ុន្តែយើងមិនអាចធ្វើអ្វីគេបានទាំងអស់ PPA ២០០១ ។

ប្រជាជនកម្ពុជាបញ្ចេញសំដីបន្ថែមចំពោះបញ្ហានេះថា "ពីមុនយើងមានគ្រប់គ្រាន់ដើម្បីលើកកំពស់កូន ប៉ុន្តែគ្រួសាររបស់ខ្ញុំបានធ្លាក់ខ្លួនក្រដោយសារយើងមានកូន ៨នាក់ ហើយយើងមិនអាចចែកដីដល់ពួកគេគ្រប់គ្នាច្រើនទេ" PPA 2001 ។

**កង្វះការទទួលបាននូវច្បាប់ និងសិទ្ធិ** គឺជាបញ្ហាមួយដ៏ធ្ងន់ធ្ងរសំរាប់អ្នកក្រ ។ មានច្បាប់ និងនិយកម្មជាច្រើនត្រូវបានអនុម័តដោយគ្មានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ។ អ្នកភូមិម្នាក់ត្រូវបានគេដកស្រង់សំដីមកថា " ថ្មីៗនេះយើងបានឮថាច្បាប់ដីធ្លីត្រូវបានគេធ្វើពង្រាងឡើងវិញ ។ យើងចង់មានការពិចារណាអំពីការព្រួយបារម្ភរបស់ពួកយើង ហើយបញ្ចូលទៅក្នុងច្បាប់ដីធ្លីថ្មីនេះ ដើម្បីធ្វើកិច្ចការកើតឡើង យើងត្រូវការអង្គការពីខាងក្រៅ ដើម្បីជួយពួកយើងទាក់ទងនិងរដ្ឋាភិបាល ពីព្រោះយើងកំរឃើញមន្ត្រីរដ្ឋាភិបាលនៅក្នុងភូមិរបស់យើង ។ ដោយលោក ចន្ទី និង Gabrielle នៅកម្ពុជា ការសើរើឡើងនៃច្បាប់ដីធ្លីក្នុងការផ្សព្វផ្សាយសំរាប់យុត្តិធម៌សង្គម Kumarian Press ២០០១ ។

ម្យ៉ាងវិញទៀតអ្នកក្រមិនត្រូវបានគេផ្តល់ឱ្យនូវលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលបាននូវច្បាប់ និងសិទ្ធិរបស់ពួកគេ ។ ពីព្រោះពួកគេមានការសិក្សាខ្សត់ខ្សោយឬស្ទើរតែអវិជ្ជា ពួកគេមិនអាចយល់ពីច្បាប់និងមិនអាចដោះស្រាយបញ្ហាច្បាប់ដោយខ្លួនឯងបាន ។ ដូច្នេះហើយ ផលប្រយោជន៍របស់អ្នកក្រតែងតែមិនត្រូវបានគេការពារ ។ មានបណ្តឹងជាច្រើនដែលអ្នកក្របាត់បង់ករណីរបស់ពួកគេក្នុងតុលាការ ឧទាហរណ៍ ការរឹបអូសយកដី ។

**អំពើពុករលួយ** មានស្ទើរតែគ្រប់កន្លែងទាំងអស់នៅលើពិភពលោក ។ ប្រទេសកម្ពុជាមិនមែនជាករណីលើកលែងឡើងដូចភស្តុតាងខ្មែរនិយាយថា "ទន្សោង និង គោព្រៃ មានន័យថា ធំស៊ីតាមធំ, តូចស៊ីតាមតូច" ។ អំពើពុករលួយបានរាលដាលពេញផ្ទៃប្រទេសកម្ពុជា ហើយបានធ្វើឱ្យប្រទេសបាត់បង់ប្រាក់រាប់លានដុល្លារលំឆ្នាំ ។ ប្រជាជនកម្ពុជា ៨0% បានជឿថាការសូកប៉ាន់ គឺជាវិធីសាមញ្ញនៃការធ្វើអាជីវកម្មក្នុងវិស័យជាច្រើនដូចជា វិស័យអប់រំ, ការថែទាំ, សុខភាព, ចរាចរ និងតុលាការ (ការធ្វើអង្កេតថ្នាក់ជាតិស្តីពីអាកប្បកិរិយាដែលនាំឱ្យមានអំពើពុករលួយសាធារណៈជាច្រើន, ប្រជាជនកម្ពុជាត្រូវចំណាយប្រាក់ក្រោមតុយ៉ាងខ្ពស់និងចំណាយលើថ្លៃផ្សេងៗ ទៀត ។ អំពើពុកលួយត្រូវបានលើកឡើងថាជាបញ្ហាសំខាន់ជាងគេនៅក្នុងប្រទេសកម្ពុជា នៅក្នុងចំណោមបញ្ហាសំខាន់ៗ ដ៏ទៃទៀតដូចជាអភិបាលកិច្ចអន់ខ្សោយ បញ្ហាសុវត្ថិភាព និងឧក្រិដ្ឋកម្មចំណាយលើការរស់នៅខ្ពស់ ចំណាយខ្ពស់លើការថែទាំសុខភាព អស្ថេរភាពនយោបាយ ចំណាយលើការអប់រំខ្ពស់ និងការរត់ពន្ធគ្រឿងញៀនជាដើម[៨] ។ អំពើពុករលួយបានបង្វែទិសរដ្ឋាភិបាលកម្ពុជា និងសង្គមកម្ពុជាពីខិតខំប្រឹងប្រែងប្រយុទ្ធនិងភាពក្រីក្រ ។

---

[៨] ប្រទេសកម្ពុជា : ការកំនត់វិនិច្ឆ័យ ពីការអភិបាលកិច្ច និងអំពើពុករលួយ : ភស្តុតាងពីការអង្កេតប្រជាពលរដ្ឋ សហគ្រិន មន្ត្រីសាធារណៈធនាគារពិភពលោក ខែឧសភា ២០០០ ។

## ប្រអប់ទី២: តើពេលណាទើបដឹងថាមានអំពើពុករលួយលេចឡើងក្នុងប្រទេសកម្ពុជា?

ការិយាល័យធិបតេយ្យបែបបស្ចឹមប្រទេសដ៏ទូលំទូលាយ បានចូលនៅសតវត្សទី១៩ ជាមួយជនជាតិបារាំង។ នៅឆ្នាំ ១៩៤៥ គេបានបញ្ចូលគំនិតបោះឆ្នោត (មកកម្ពុជា)តែមិនមែនការបោះឆ្នោតមែនទែនទេ ។ ដោយចង់ធ្វើឱ្យរបបរបស់ខ្លួនទៅជាស្របច្បាប់,លោក សឺង ង៉ុកថាញ់ បានរៀបចំធ្វើប្រជាមតិជាតិមួយ ដោយចោទសួរពលរដ្ឋខ្មែរប្រុស១ថា តើចង់អោយបារាំងត្រលប់មកវិញ ឬទេ? ដោយសេរី ដូចជាគេនៅក្នុងរាជព្រះបាទជ័យវរ្ម័ន(១១៧៨-១២២០)" (Chandler 1991:13) ។ ការបោះឆ្នោតនោះមានសំឡេងគាំទ្រ ៥៤០.០០០ ទល់នឹង១ ប្រឆាំងរដ្ឋាភិបាល សឺន ង៉ុក ថាញ់ ។ បើតាមឯកសារ Chandler, ការបោះឆ្នោតនោះមានតែបន្តិចបន្តួចទេ។ ផ្ទុយទៅវិញអភិបាលខេត្តទាំងឡាយបានបញ្ចូលលទ្ធផលដែលសង្ឃឹមទុកនៅវិមានរដ្ឋសភាក្នុងនាមមណ្ឌលរបស់ខ្លួន (ដោយមិនចាំបាច់អោយមានការបោះឆ្នោត) នេះជាសញ្ញានៃរឿងរ៉ាវដែលនឹងកើតមានក្រោយទៀត ។

រំលងពីនោះពីរបីឆ្នាំ រឿងអាស្រូវនានាបានបានផ្ទុះឡើងអំពីបញ្ហាមន្រ្តីរាជការលក់របបអំបោះខុសច្បាប់ អាជ្ញាប័ណ្ណនេសាទ នៅទន្លេសាប និងបញ្ហាដ៏ទៃទៀត ។ ការស៊ើបអង្កេតត្រូវជាប់គាំង ហើយឯកសារត្រូវគេបំផ្លាញចោល ។ នៅវវាងដើមទសវត្ស ឆ្នាំ១៩៦០ ប្រជាជនតាមជនបទជាច្រើនបានចាត់ទុកពាក្យថា "រាជការ"ជាវេចនៈ (ពាក្យសំរាប់ផ្លាស់ប្តូរ) នឹងពាក្យថា "ពុករលួយ" ។ ដើម្បីទាក់ទង់ កិច្ចការរាជការអ្វីមួយ គេត្រូវប្រើលុយ ។ គ្រាមភាសារខ្មែរហៅទំនាក់ទំនងនេះថា "រលាក់ដៃ" (bon jour) ។ ឧទាហរហ៍ នៅឆ្នាំ ១៩៦៨ ក្នុងកំឡុងសករាជនៃសម្តេច នរោត្តម សី ហនុ ប័ណ្ណសមាជិកគណៈបក្សសង្គមរាស្រ្តនិយមដែលគេទាមទារពីអ្នករាជការ មានតម្លៃ ១០០០៛ (សម័យនោះ) គឺប្រហាក់ប្រហែលនឹងបៀវត្សមួយសប្តាហ៍សំរាប់វិស្វករស៊ីវិល (Chandler 1991) ។

ឱកាសថ្មីសំរាប់អំពើពុករលួយបានកើតឡើង នៅពេលដែលសហរដ្ឋអាមេរិកចាប់ផ្តើមចេញថ្លៃចំណាយថវិកាយោធារបស់ កម្ពុជា។ ពួកទាហានបានពង្រីកបញ្ជីបើកប្រាក់ខែរបស់ខ្លួន ដោយបន្ថែមឈ្មោះទាហានខ្មោច និងដោយមិនរាយការណ៍ទាហានដែលស្លាប់ និងដែលរត់ចោលជួរ ។ នៅឆ្នាំ១៩៧២ អ្នកនាំពាក្យយោធាទាំងឡាយបានសារភាពថា រៀងរាល់ខែពួកមេបញ្ជាការយោធាបានប្រមូលដាក់ហោប៉ៅ នូវប្រាក់យុទ្ធជន និងយុទ្ធនារីចំនួន ១.០០០ ដែលគ្មានជាក់ស្តែង ។ នៅឆ្នាំ១៩៧៣ ខេត្តថ្មីមួយចំនួនត្រូវបានគេបង្កើតឡើង ដើម្បីប្រមូលប្រាក់សំណូកពីអ្នកសុំធ្វើអភិបាលខេត្ត ដូច្នេះពួកគេអាចបង្ហូរយកប្រាក់ពីសហរដ្ឋអាមេរិកបាន។ ទាហាន និងអ្នកនយោបាយបានលក់កាំភ្លើង ប្រេងឥន្ធនៈ សំភារៈបរិក្ខា និងគ្រឿងផ្គត់ផ្គង់ ផ្សេងទៀតឱ្យទៅអ្នកដែលហ៊ានឱ្យតំលៃខ្ពស់បំផុតទោះជាជននោះក្នុងភាគីណាក៏ដោយ (Chandler ,1991) ។ ទីភ្នាក់ងារស៊ើបអង្កេតមួយប្រហែលត្រូវបានបង្កើតឡើងដែរ ប៉ុន្តែគ្មានប្រសិទ្ធិភាព (ម.អ.ស ១៩៩៥ )។អំពើពុករលួយបានចុះថយទៅជាមួយ នឹងការបំបាត់ក្រដាសប្រាក់នៅសម័យ ប៉ុល ពត ។ ប៉ុន្តែ មាស រតនវត្ថុ និងរបស់របបដ៏ទៃទៀត ត្រូវបានគេយកទៅដូរដោះយកជីវិត ឬអង្ករជាបន្តមកទៀត ។ ការចាយវាយប្រាក់មានចំនួនកំណត់, ពួកអ្នករកស៊ីធំ១ ពុំសូវមានប្រសិទ្ធិភាព និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវខ្ទេចខ្ទាំស្ទើរតែទាំងអស់ បានបិទច្រកអំពើពុករលួយក្នុងបណ្តាឆ្នាំក្រោយមកទៀត (ក្រោយឆ្នាំ ១៩៧៩)។ ប៉ុន្តែបន្ទាប់ ពីការចុះហត្ថលេខាលើសន្ធិសញ្ញាទីក្រុងប៉ារីសនៅដើមទសវត្សឆ្នាំ ១៩៩០, សង្រ្គាមក្នុងបានស្ងប់ទៅ និងការដួលរលំនៃសហភាពសូវៀត, កម្ពុជាបានចាប់ផ្តើមផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចទីផ្សារសេរី ហើយឱកាសអំពើពុករលួយក៏បានស្ទុះឡើងយ៉ាងរហ័ស។ នៅឆ្នាំ ១៩៨៦ រាជរដ្ឋាភិបាលបានចាប់ផ្តើមលើកទឹកចិត្តសកម្មភាពសេដ្ឋកិច្ចឯកជន ។ បីឆ្នាំក្រោយមករដ្ឋាភិបាលបានស្តារកម្មសិទ្ធិឯកជន ឡើងវិញព្រមទាំងបានអនុញ្ញាតឱ្យកសិករលក់ផលិតផលលើសតំរូវការក្នុងផ្សារសេរី ។ មន្រ្តីរាជការក៏បានចាប់ផ្តើមទទួលប្រាក់កាសជំនួយផលកំរៃ ឧបត្ថម្ភផ្សេង១ (IMF ១៩៩៤ ) ។ ការបណ្តាក់ទុនផ្នែកឧស្សាហកម្មរួមគ្នារវាងរដ្ឋ និងផ្នែកឯកជន (ច្រើនតែបរទេស) ត្រូវបានរៀបចំឡើង។ នៅដើមទសវត្សឆ្នាំ ១៩៩០ ការបន្ធូរបន្ថយវឹតបន្តឹងដីធ្លីសំណង់បានធ្វើអោយការជួសជុល និងកសាងជាថ្មីផ្ទុះឡើង ។ សកម្មភាពកសាងបានកើតឡើងជាមួយការលក់សម្ភារៈសំណង់។ ជាអកុសលឈើហ៊ុបជាច្រើន ត្បូង ត្រីងៀត ត្រីឆ្អើ និងទំនិញនាំចេញជាច្រើនទៀតបានហូរចូលទៅប្រទេសថៃ និងវៀតណាមដោយខុសច្បាប់។ តែមួយពព្រិចភ្នែក ការខូចខាតបរិដ្ឋានស្ទើរតែចូលដល់ទ្វារនៃគ្រោះមហន្តរាយ (Chandler 1993)។ អ្នកខ្លះបកស្រាយសកម្មភាពរីកវរគួបផ្សំជាមួយការរីកស្ទុះស្ពាយនៃអំពើពុករលួយថា ជាលទ្ធផលផ្នែកចិត្តសាស្រ្តដែលកើតឡើងពីការដកហូតកម្មសិទ្ធិនៅក្រោមរបប ប៉ុល ពត ។

**ប្រអប់ទី៣: តើការចំណាយលើអំពើពុករលួយចំពោះកម្ពុជាមានតម្លៃប៉ុន្មាន?**

១៩៩៥ មានសុទ្ធរកថានៅឯសន្និសីទពីអំពើពុករលួយ និងផលប៉ះពាល់របស់វាលើការស្តាររចនាសម្ព័ន្ធជាតិឡើងវិញ និងការផ្សះផ្សារឡើងវិញ ។ ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ បានប៉ាន់ប្រមាណថារដ្ឋកំពុងបាត់បង់ទឹកប្រាក់លើស ១០០លានដុល្លារក្នុងមួយឆ្នាំៗ ចំពោះអំពើពុករលួយជាដំបូងដោយសារតែការប្រព្រឹត្តខុសច្បាប់ ការនាំចេញជ័រកៅស៊ូ និងវិស័យជលផល (CSD,1995) ។ ក្នុងឆ្នាំ ១៩៩៧ មូលនិធិរូបិយវត្ថុអន្តរជាតិ (PMF) បានលុបចោលកំចី ៦០ លានដុល្លា សំរាប់កម្ពុជាដោយសារតែអំពើពុករលួយក្នុងវិស័យព្រៃឈើ ។ ធនាគារពិភពលោក ( World Bank) បានបដិសេធន៍ដើម្បីកែតំរូវការគាំទ្រថវិការបស់គេឡើងវិញ។ ជាងរយៈពេល ៣ឆ្នាំ ការទ្រទ្រង់ថវិកាបានគណនាដោយត្រួសៗ ៨៥ លានដុល្លារ (Reuter 9/3/97 )។ Global Witness ក្រុមបរិស្ថានអង់គ្លេស មួយបានចោទទាហានរដ្ឋាភិបាលថាបានរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើសអាណាធិបតេយ្យព្រៃឈើខុសច្បាប់ (Reuter ,2/6/98)។ ទន្ទឹមពេលគ្នានេះដែរ នាយករដ្ឋមន្ត្រីទី២ សម្តេច ហ៊ុន សែន បានព្រមានថាមានមន្ត្រីពី ១០០០ ទៅ ២០០០ ដែលពួកគេបាន ប្រថុយប្រថាន នឹងការបាត់បង់ការងារ ប្រសិនបើពួកគេនៅតែបន្តការកេងបន្លំចំណូលពន្ធដារប្រទេស ។ យោងតាមសម្តេច ហ៊ុន សែន ការចំណាយការអនុវត្តបែបនេះអស់រាប់លានដុល្លារក្នុង ១ឆ្នាំៗ (Associated Press, 10/17/97) ។

ថ្មីៗ នេះរឿងអាស្រូវអំពីអំពើពុករលួយត្រូវគេរាយការណ៍ក្នុងសារពត៌មានក្នុងស្រុក ដែលមានការទាក់ទងនឹងប្រាក់រាប់លានដុល្លា។ ការបង្ហាញនូវអំពើពុករលួយចំពោះធនាគារពិភពលោក បានផ្តល់មូលនិធិគំរោងការរំសាយទ័ពត្រូវបានគេរាយការណ៍។ គំរោងការរបស់ (Supervision Mission Finding ) និង កិច្ចព្រមព្រៀងរួមគ្នារវាងធនាគារពិភពលោក និងក្រុមប្រឹក្សាសំរាប់រំសាយកងកំលាំងប្រដាប់អាវុធ ចំពោះគំរោងការរំសាយទ័ពនៅកម្ពុជា និងគំរោងការសមាហរណ៍កម្មឡើងវិញបានកំណត់កាលបរិច្ឆេទ ខែតុលា ឆ្នាំ២០០២ បានរាយការណ៍ ពីបញ្ហាមួយចំនួនដែលអាចទាក់ទងទៅនឹងអំពើពុករលួយ ។ គេនៅឃើញថាការប្រកួតប្រជែង ដើម្បីឱ្យមានការបញ្ចូលក្នុងបញ្ជីរំសាយទ័ព គឺខ្ពស់ ហើយលទ្ធផលបានបង្ហាញក្នុងវិស័យទ័ព ការទូទាត់ត្រូវរាប់បញ្ចូលទាំងទាហាននៅក្នុងបញ្ជីដែលត្រូវបានរំសាយ ។ ការរកឃើញផ្សេងទៀតទាក់ទងបញ្ហាតារាងទិន្នន័យ ។ តារាងទិន្នន័យបានរកឃើញគ្រប់ទាហានដែលបានចុះបញ្ជីហើយឈ្មោះមានក្នុងតារាងទិន្នន័យ ហើយការកាន់អត្តសញ្ញាណដោយស្របច្បាប់ ត្រូវបានគេទទួលស្គាល់ថាជាទាហាន ។ ដូច្នេះមានការរីកចំរើនខាងភស្តុតាង រាប់បញ្ចូលទាំងការ ស្វែងរកនូវវិស័យនិមួយៗ ដោយបេសកកម្មធនាគារនានា ហើយសំណើរគ្មានប្រសិទ្ធិភាពមួយចំនួននៃទាហានមានលើតារាងទិន្នន័យ ដែលមិនដែលចូលបំរើក្នុងជួរកងទ័ពប្រដាប់អាវុធ រឹទទួលប្រាក់បៀវត្សពីទាហាន ហើយអ្នកផ្សេងទៀតបានបំរើក្នុងជួរកងកំលាំងប្រដាប់អាវុធ ប៉ុន្តែ មិនបានទទួលប្រាក់បៀវត្សពេញលេញ ។

ប្រភព (ឃ្លា ១-៣) មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (១៩៩៧) ។ អង្កេតជាតិអំពីឥរិយាបទ សាធារណៈឆ្ពោះទៅរកអំពើពុករលួយ ។

## ៣.១.៥ ភាពងាយទទួលរងគ្រោះ

ថ្វីបើបច្ចុប្បន្ននេះប្រទេសកម្ពុជាមានសន្តិភាព និងស្ថេរភាព និងរីកលាយជាមួយនឹងសមិទ្ធិផលនៃការអភិវឌ្ឍន៍ ក៏ប្រជាជនកម្ពុជាភាគច្រើនស្ថិតនៅក្នុងសភាពងាយនឹងទទួលការរងគ្រោះដោយសារភាពក្រីក្រ និងអសន្តិសុខស្បៀង ។ ក្រុមដែលងាយទទួលរងគ្រោះជាងគេមានអ្នកភៀសសឹក ជនមាតុភូមិនិវត្តន៍ ជនរងគ្រោះ HIV/AIDS, ស្ត្រីមេម៉ាយដោយសារសង្គ្រាម និងមេគ្រួសារ

ដែលជាស្ត្រី ក្មេងកំព្រា ក្មេងអនាថា សំណង់អនាធិបតេយ្យ ជនពិការ និងជនជាតិភាគតិចរស់នៅតំបន់ដាច់ស្រយាល ។ ក្រុមងាយទទួលរងគ្រោះផ្សេងទៀតរួមមាន អ្នកទាំងឡាយណាដែលរស់នៅតំបន់មានមីន និងមានគ្រាប់មិនទាន់ផ្ទុះ (UXOs) និងតំបន់ដែលជួបនូវគ្រោះមហន្តរាយធម្មជាតិ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ។

## អសន្តិសុខស្បៀង

គ្រួសារដែលក្រមិនដែលមានអាហារហូបគ្រប់គ្រាន់ឡើយ PPA ២០០១, P.14 ។ សន្តិសុខស្បៀង និងភាពក្រីក្រមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ។ អ្នកចូលរួមសំភាសន៍ ទាំងអស់ក្នុង PPA ២០០១ បានបញ្ជាក់ច្បាស់ថា ភាពក្រីក្រគឺ ជាការជំនះនិងភាពអត់ឃ្លាន, លក្ខខ័ណ្ឌដ៏អាក្រក់ដែលអ្នកក្រីក្រមិនអាចជៀសផុតប្រហែលជាលើកលែងនៅពេលមានមូលដ្ឋានអាសន្នណាមួយ ។ ដោយសារតែភាពអត់ឃ្លានពួកគេមិនអាចបំពេញបំណងនូវតំរូវការជាមូលដ្ឋានផ្សេងៗ ទៀតបាន ។ ដូចជាបញ្ជូនកូនឱ្យទៅរៀនចំណាយលើសេវាសុខភាពដែលចាំបាច់ និងពិធីបុណ្យផ្សេងៗ ។

នៅក្នុងជនបទនៃប្រទេសកម្ពុជា មានស្រូវគ្រប់គ្រាន់ និងចំណីអាហារដើម្បីហូប ១២ខែ ក្នុងមួយឆ្នាំ គឺមានន័យថាមានរឺមានសន្តិសុខស្បៀង ។ អសន្តិសុខស្បៀងអាចកើតទាំងភាពរ៉ាំរ៉ៃ រឺភាពបណ្តោះអាសន្ន ។ ក្រុមដែលប៉ះពាល់ដោយភាពរ៉ាំរ៉ៃនៃអសន្តិសុខស្បៀងរួមមានៈ កសិករដែលមានស្បៀងត្រឹមចិញ្ចឹមជីវិត កង្វះដីធ្លី រឺអ្នកដែលមានដីធ្លីបន្តិចបន្តួច អ្នកក្រនៅទីប្រជុំជន និងក្រុមងាយទទួលរងគ្រោះផ្សេងៗទៀត ។ ឧទាហរណ៍ៈ ស្ត្រីដែលក្លាយជាម្តាយនិងឪពុក ក្មេងក្រោមអាយុ៥ឆ្នាំ និងមនុស្សចាស់ ។ ក្រុមដែលប៉ះពាល់ដោយភាពបណ្តោះអាសន្នរួមមានៈ អ្នកដែលប្រឈមមុខ និងគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ។

នៅក្នុងកំឡុងឆ្នាំ ១៩៩៨/៩៩-២០០១/០២ ប្រទេសកម្ពុជា បានផលិតអតិរេកស្រូវទំហំពី ៣០.០០០-៣៦៤.១៤៨តោន ។ ក៏ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាគ្មាននរណាម្នាក់មានអង្ករគ្រប់គ្រាន់ដើម្បីហូបឡើយ បន្ទាប់ពីសន្តិសុខស្បៀងមានទំនាក់ទំនង និងកត្តាស្មុគស្មាញជាច្រើន ហើយបានឃ្លាតពីផលិតផលកសិកម្ម ។ នេះជាការពិតសំរាប់អ្នកក្រជាងគេហើយជាពិសេសគឺក្រុមអសន្តិសុខស្បៀង និងក្រុមទទួលងាយទទួលរងគ្រោះនៅតំបន់ជនបទ ។ ការសិក្សាថ្មីៗនេះបានបង្ហាញឱ្យឃើញថា ថ្វីបើមានផលិតផលស្រូវច្រើននៅខេត្តមួយចំនួន ៣០% នៃឃុំនិមួយៗប្រឈមមុខនឹងការខ្វះខាតអាហារជាប្រចាំ ។ អ្នកក្រមិនអាចទទួលបាននូវអតិរេក ពីព្រោះពួកគេគ្មានអំណាចក្នុងការទិញ ហើយជាញឹកញាប់ស្ថិតក្នុងបំណុលខ្ពស់ដែលមិនអាចទទួលបានឥណទានគ្រប់គ្រាន់ ។ លើសពីនេះទៅទៀតការទទួលបាននូវម្ហូបអាហារ ក៏មានការរារាំងផងដែរដោយប្រពន្ធ័ទីផ្សារខ្សោយ រឺប្រពន្ធ័នៃការបែងចែកនៅមានកំរិតទាប បំរែបំរួលតំលៃមធ្យោបាយធ្វើដំណើរពិបាក និងការតភ្ជាប់ពីផ្លូវមួយទៅផ្លូវមួយទៀត ឱកាសការងារក្រៅពីកសិកម្មនៅមានកំរិត និងការវិនិយោគក្នុងវិស័យកសិកម្មនៅទាប ។

## ក្មេងអនាថា

ក្មេងអនាថាគឺជាក្រុមមួយងាយទទួលរងគ្រោះបំផុត ជាទូទៅបានប្រមូលផ្តុំគ្នានៅក្នុងទីក្រុងភ្នំពេញ ដែលជាទីក្រុងមានសកម្មភាពសេដ្ឋកិច្ចខ្ពស់ ។ តាមការប៉ាន់ស្មាននាពេលបច្ចុប្បន្ននេះ ចំនួនក្មេងអនាថាដែលរស់នៅតាមចិញ្ចើមថ្នល់នៅ ទីក្រុងភ្នំពេញ

មានប្រមាណពី ១០.០០០ ទៅ ២០.០០០[៩] ដែលក្នុងនោះក្មេងក្នុងចំនួន ៩៧៦ នាក់ ត្រូវបានគ្រួសារបោះបង់ចោល ។ ក្មេងដែលត្រូវគេបោះចោលចំនួន ២/៣ មានប្រភពមកពីបណ្តាខេត្ត ។ បាតុភូតនេះបណ្តាលមកពីការបែកបាក់គ្រួសារ និងភាពក្រីក្រ ។ កុមារទាំងនេះប្រឈមមុខជាមួយនឹងបញ្ហាជាច្រើនដូចជា ការប្រើប្រាស់គ្រឿងញៀន[១០] សកម្មភាព "ក្រុមបងធំ" ជំងឺ HIV/AIDS ពេស្យាចារ បញ្ហាសុខភាព និងភាពគ្មានអនាគតព្រមទាំងការរស់នៅក្រៅសង្គម ។

ខាងក្រោមនេះជាការស្រង់សំដីរបស់ក្មេងអនាថាក្នុងឯកសារ PPA ២០០១ ថាភាគច្រើននៃពួកយើងត្រូវម្តាយបោះបង់ចោលតាំងពីនៅតូចៗ ។ ឥឡូវនេះយើងរស់នៅលើចិញ្ចើមថ្នល់ ជួនកាលធ្វើពួកយើងមានការតក់ស្លុតក្នុងជីវិត ប៉ុន្តែបញ្ហានេះបាត់បង់នៅពេលដែលយើង ហឺតកាវ និងផឹកគ្រឿងស្រវឹងដែលសេសសល់ពីគេ ។

**ហ៊ីវ-អេដស៍**

ចាប់តាំងពីករណីលើកទីមួយ នៃជំងឺរាតត្បាតក្នុងឆ្នាំ ១៩៩២, គេបានប៉ាន់ប្រមាណថា បច្ចុប្បន្នប្រជាជនកម្ពុជា ១៦៩.០០០នាក់ មានផ្ទុកមេរោគ HIV និងអេដស៍ ក្នុងចំណោមប្រជាជនជាង ១១លាននាក់ ។ ស្ថិតិរបស់អង្គការកាញ្ញា (KHANA) បានបង្ហាញថាក្មេង ៣០,០០០នាក់ ត្រូវបានក្លាយទៅជាកុមារកំព្រាដោយសារជំងឺអេដស៍ ហើយបញ្ហានេះអាចកើតឡើងដល់ ១៤០,០០០នាក់នៅ ឆ្នាំ ២០០៥ ។ នៅឆ្នាំ១៩៩៧ គេបានប៉ាន់ស្មានថាអត្រាប្រេវ៉ាឡង់នៃ HIV/AIDS គឺ ៣,៩ និងឆ្នាំ ២០០១ គឺ ២,៨ ក្នុងចំណោមយុវវ័យអាយុពី ១៥ ទៅ ៤៩ ឆ្នាំ ។

កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ ២០០០ សំគាល់ថាមេរោគហ៊ីវ អេដស៍រុករានសុខភាព និងបន្ទាប់មកជីវភាពបឋមរបស់ប្រជាជនក្នុងផលិតផលជាច្រើនឆ្នាំ (១៥-៥០ឆ្នាំ) កម្មវិធីស្បៀងអាហារពិភពលោកលើកឡើងថាបញ្ហានេះវាកៀបសង្កត់លើឥទ្ធិពលធំធេងនៃសន្តិសុខស្បៀងដែលមានផលប៉ះពាល់ជាច្រើនទៅលើបុគ្គលនិងគ្រួសារ។ មានគ្រួសារជាច្រើន ហ៊ីវ/អេដស៍ បានធ្វើអោយថយចុះនូវការរកចំនូលតាមរយៈសភាពជំងឺនិងការស្លាប់ របស់មនុស្សម្នាក់ ឬច្រើននាក់នៃសមាជិកគ្រួសារ។ សំរាប់គ្រួសារនៅជនបទ សភាពជំងឺមានផលប៉ះពាល់ដល់ផលិតផលកសិកម្ម ដូចគ្នា នឹងគេបង្ខំឱ្យធ្វើការចែកជាថ្មីទៀតនូវពលកម្មបានមកពីកសិកម្មដើម្បីថែទាំជំងឺ ។ ការបង្កើតជំងឺដូចគ្នា និងហេតុផលនៃចំណាយធំសំរាប់ថែទាំ និងព្យាបាលជំងឺ ការអ្វីក៏ដោយធ្វើឡើងសំរាប់អាហារ ។ កម្មវិធីសន្សំខ្នាតតូចនៃគ្រួសារតែមួយបានធ្វើឱ្យក្រយ៉ាងឆាប់ និងទ្រព្យសម្បត្តិត្រូវបានលក់។ ទ្រព្យសម្បត្តិត្រូវបាន លក់ដើម្បីបានប្រាក់សំរាប់ថែទាំអ្នកជំងឺ ឬជាការបាត់បង់ពលកម្ម។ ពេលណាដែលគ្រួសារជាច្រើនបាត់បង់ទ្រព្យសម្បត្តិបានបាត់បង់សន្តិសុខស្បៀងរបស់គេ សត្វពាហនៈ ដីធម្មជាតិ ទឹកដោះសំរាប់គ្រួសារ និងការសន្សំស្បៀង។

ឥឡូវនេះ ហ៊ីវ/អេដស៍ បានទទួលការយកចិត្តទុកដាក់ជាអាទិភាពពីរាជរដ្ឋាភិបាល/NGOs និងដៃគូ ជំនួយពីខាងក្រៅផ្សេងៗទៀតពីព្រោះការយល់ដឹងឱ្យបានប្រសើរពីជំងឺរាតត្បាត និងការទទួលស្គាល់ពីកំណើតនៃជំងឺដែលជះឥទ្ធិពលដល់សុវត្ថិភាពមនុស្សជាតិ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងស្ថេរភាពជាតិ ។

---

[៩] មិត្តសំឡាញ់ (២០០០) : ទិន្នន័យនេះរួមមាន : ក្មេងមានផ្ទះខ្លួនឯង ប៉ុន្តែត្រូវតែផ្អែកលើចិញ្ចើមថ្នល់ ដើម្បី ចិញ្ចឹមជីវិតដោយសារតែគ្រួររបស់របស់គេ ក្រពេក ។

[១០] មិត្តសំឡាញ់ : អង្កេតស្តីពីសារធាតុប្រើប្រាស់ ក្នុងចំណោមក្មេងអនាថា ក្នុងទីក្រុងភ្នំពេញ (២០០០)

គេក៏បានទទួលស្គាល់ផងដែរ ថាការងាយទទួលរងគ្រោះនៃជំងឺឆ្លង ជាពិសេសចំពោះស្ត្រីដែលជាលទ្ធផលនៃការជះឥទ្ធិ-ពលដល់កត្តាសង្គមវប្បធម៌ សេដ្ឋកិច្ចនិងនយោបាយ ។ កត្តាទាំងនេះរួមបញ្ចូល ទាំងការរើសអើង និងក្រុមមនុស្សឋានៈទាបមួយចំនួនដូចជាអ្នករកស៊ីផ្លូវភេទអ្នកផ្ទុកមេរោគ HIV/AIDS អ្នកអវិជ្ជា និងអ្នកដែលគ្មានឱកាសក្នុងការសិក្សា ។

ការសិក្សាជាច្រើនឥទ្ធិពលរបស់នៃមេរោគហ៊ីវ និងជំងឺអេដស៍មានទំនាក់ទំនងមិនគ្រប់គ្រាន់នឹងយន្តការការពារសង្គមបច្ចុប្បន្ន ស្នើសុំតំរូវការសំរាប់សំណើរ គោលនយោបាយពិសេស( សេដ្ឋកិច្ច នៃហ៊ីវ និងអេដស៍ មានករណីនៃប្រទេសអាស៊ីខាងត្បូង និងអាគ្នេយ៍) លោក ប៊្លូម និង លោក ហ្គូដវិន អ្នកនិពន្ធ Oxford University of Press EDS, AIP, ១៩៩៧។ ចំណោមការរៀបរាប់មកនេះ ជាសំណើជំរុញអោយបានដល់អ្នកក្រីក្រនូវការថែទាំសុខភាពដោយសេរី ឬផ្គត់ផ្គង់អោយដល់ការថែទាំសុខភាព និងសេវាសង្គមជាមូលដ្ឋាន ដើម្បីបង្កើនឥណទានទីផ្សារ និងពង្រីកធនធានផ្លូវការ ដែលមានសំរាប់ឥណទានបង្កើនប្រពន្ធ័ធានា-រ៉ាប់រងការពារសិទ្ធិមនុស្សដោយការថែទាំដោយសុវត្ថិភាព និងដោយសំងាត់ចំពោះពតិមានជំងឺ (ដូចនេះការអនុញ្ញាតដល់អ្នកជំងឺហ៊ីវវិជ្ជមានបន្តធ្វើការងារអោយបានយូរតាមដែលអាចធ្វើទៅបាន) និងផ្តួចផ្តើមរាជរដ្ឋាភិបាលនិងអ្នកជំនួយដល់ការផ្សព្វផ្សាយប្រឆាំងនិងការរើសអើងនឹងអ្នកផ្ទុកមេរោគហ៊ីវ ។

## គ្រោះធម្មជាតិ

សុភាសិតខ្មែរពោលថា *"ទឹកឡើងត្រីស៊ីស្រមោចទឹកហោចស្រមោចស៊ីត្រី"* ។ ក្រៅពីភាពងាយទទួលរងគ្រោះលំបាកប្រចាំថ្ងៃ និងការប៉ះទង្គិចកើតឡើងជាច្រើនដែលអាចវាយប្រហារបុគ្គលម្នាក់ៗ និងប្រទេសទាំងមូលបានអ្នកក្រីក្រងាយទទួលរងគ្រោះយ៉ាងខ្ពស់ចំពោះមហន្តរាយធម្មជាតិ ជាទឹកជំនន់ និងគ្រោះរាំងស្ងួត ។ គ្រោះមហន្តរាយនេះកើតឡើងជាញឹកញាប់អស់រយៈពេល ៧ឆ្នាំ កន្លងមកហើយ ។ ការកើតឡើងនូវគ្រោះមហន្តរាយនេះបានធ្វើឱ្យជុំវិញអ្នកក្រីក្រធ្លាក់ចុះទាំងស្រុង "គ្រួសារក្នុងភូមិនេះភាគច្រើនសុទ្ធតែជាអ្នកក្រីក្រ" យើងមានដីតែមួយចំណែកតូចហើយគ្រួសារខ្លះមានសត្វពាហនៈមួយក្បាល រឺពីរក្បាល ។ គ្រួសារខ្លះមានសំណាងអាចមានបាយ រឹបបរហូបរាល់ថ្ងៃក្រោយពីគ្រោះធម្មជាតិ ។ គ្រួសារអភព្វ័មួយចំនួនត្រូវតែលក់ រឺបញ្ចាំដីរបស់គេ រឺលក់សត្វពាហនៈ ។ នៅទីបញ្ចប់គេក្លាយជាអ្នកគ្មានដីធ្លី ហើយក្រទៅៗ (របាយការណ៍ មិនបោះពុម្ពផ្សាយរបស់ WHO ស្តីអំពីការសិក្សាលើគ្រោះមហន្តរាយនៃឃុំជ្រើសរើសមួយចំនួនក្នុងប្រទេសកម្ពុជា ឆ្នាំ២០០១) ។

**ប្រអប់ទី ៤: អ្នកក្រីក្រ និងគ្រោះធម្មជាតិ**

ប្រវត្តិសាស្ត្រផ្តើមចេញពីការប្រមូលផលរបស់អ្នកក្រ ។ ជនក្រីក្រទាំងនេះពឹងពាក់ទាំងស្រុងទៅលើការប្រមូលផល ផលវិបាកនៃគ្រោះទឹកជំនន់ធ្វើឱ្យចលាចល ដែលមានឥទ្ធិពលលើស្ថានភាពសន្តិសុខស្បៀងរបស់គ្រួសារពួកគេរយៈពេលពេញមួយឆ្នាំ ។ នៅពេលដែលពួកគាត់ប្រឈមមុខនឹងកង្វះស្បៀងអាហារ អ្នកក្របានខ្ចីស្បៀងពីគ្រួសារដទៃដែលប្រសើរជាង ដែលអ្នកទាំងនោះជាញឹកញាប់យកបញ្ចាំអត្រាខ្ពស់ ។ មានតិចណាស់ដែលពួកគាត់ខ្ចីបុលគេដោយសង្ឃឹមថាឆ្នាំក្រោយ ពួកគេនឹងប្រមូលផល ប្រសើរជាង ហើយពួកគាត់អាចសងបំណុលវិញបាន ។ ប៉ុន្តែ សំណាងអាក្រក់ពួកគេត្រូវទឹកជំនន់វាយប្រហារម្តងទៀត ដូច្នេះសំណងវាកើនឡើងទាំងការប្រាក់ និងបំណុលពួកដោះស្រាយដោយលក់សត្វពាហនៈដែលជាកំលាំងអូសទាញ ។ ហើយប្រសិនបើ ពួកគាត់មានសំណាង (គ្មានទឹកជំនន់) ពួកគាត់មានដីដាំដុះ ប៉ុន្តែពួកគាត់ត្រូវចំណាយទ្វេដងនូវកំលាំង ពលកម្មក្នុងការដោះដូរ ចំពោះការខ្ចីសត្វជាកំលាំងអូសទាញពីអ្នកដទៃ។ ប៉ុន្តែប្រសិនបើគ្រោះទឹកជំនន់ កើនឡើងម្តងទៀតនៅពេលនោះពួកគាត់ពុំមានជំរើសផ្សេងក្រៅពីបញ្ចាំដី និងលក់កំលាំងពលកម្មដើម្បីរកស្បៀង ។ ដោយកង្វះម្ហូបអាហារ និងសហគមន៏នៅទន់ខ្សោយ ពួកគាត់មិនអាចធ្វើការកើតពេលមិនមានអាហារបរិភោគ ដូច្នេះពួកគាត់លក់ដី ដើម្បីប្តូរយកអាហារ និងរក្សាសុខភាព ។ ប្រសិននៅតែមិនប្រសើរឡើងពួកគាត់នឹងឈានទៅដល់លក់ផ្ទះ ខណៈនោះស្ថានភាពរបស់ពួកគាត់មួយចំនួន អាចដល់ទីបញ្ចប់ដោយរស់នៅលើទូកតូចមួយ ហើយអាស្រ័យលើការនេសាទប្រចាំថ្ងៃជួនកាលភៀសខ្លួនទៅភ្នំពេញ កោះកុង ជាយថាហេតុទៅដល់ប្រទេសថៃ ហើយរឿងបែបនេះបន្តរហូត។

## ចំការមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

គ្រួសារខ្ញុំមានដីប្រហែល ២០ហិចតា ត្រាក់ទ័រ៣ គ្រែស្នែងមួយ ម៉ូតូមួយ និងឧបករណ៏កសិកម្មគ្រប់មុខ ។ ថ្ងៃមួយអ្នកធ្វើការឱ្យខ្ញុំបានបើកត្រាក់ទ័រកិនមីនប្រឆាំងនិងរថក្រោះដែលយើងមិនបានដឹងហើយត្រាក់ទ័រត្រូវបានបំផ្លាញ ។ ក្រោយមកអ្នកបើកបរបានស្លាប់យើងត្រូវលក់ទ្រព្យសម្បត្តិរបស់យើងដើម្បីសងទៅគ្រួសាររបស់គាត់ និងរៀបចំពិធីបុណ្យឱ្យគាត់ ។ បន្ទាប់មកមិនយូរប៉ុន្មានប្តីរបស់ខ្ញុំធ្លាក់ខ្លួនឈឺដោយសារទុកកង្វល់រួចក៏បានស្លាប់ទៅ ។ យើងមិនអាចធ្វើអ្វីបានក៏ក្លាយខ្លួនជាអ្នកក្រ (PPA 2001 –P .27 ) ។

បន្ទាប់ពីសង្គ្រាមពាទសវត្សមកចំការមីនគឺជាបញ្ហាឧបសគ្គដែលរារាំងអ្នកក្រមិនឱ្យរានដីធ្វើកសិកម្ម និងបង្កើតនូវភាពងាយទទួលការរងគ្រោះដល់ប្រជាជនដែលរស់នៅជនបទ ។ តាមការប៉ាន់ស្មានមានមីនប្រឆាំងមនុស្ស មីនប្រឆាំងរថក្រោះ និងគ្រាប់មីនមិនទាន់ផ្ទុះ (UXOs) ប្រមាណពី៤ទៅ៦លានគ្រាប់ និងរួមបញ្ចូលប្រហែល ៥៣៩,១២៩ តោនគ្រាប់នៃគ្រាប់បែកបង្កៃ បានដាក់កប់ក្នុងដី និងមានរាយប៉ាយពាសពេញដីក្នុងប្រទេស ។ យោងតាមការធ្វើអង្កេតជាតិក៏រិតទី១របស់ CMAA ប្រហែល ២.៥% នៃផ្ទៃដីកម្ពុជាត្រូវបានរងគ្រោះដោយចំការមីន និងគ្រាប់មីនមិនទាន់ផ្ទុះ ។ គេរាយការណ៏មកថាមានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដែលមានគ្រោះថ្នាក់ប្រហែល ៥៤,៤00 គ្រាប់ នៅរវាងឆ្នាំ ១៩៧៩ ដល់ខែកញ្ញា ២00២ ។ ការរងគ្រោះថ្នាក់ច្រើនតែកើតឡើងនៅក្នុងព្រៃ (៣៣%) ភូមិក្នុងតំបន់អតីតតំបន់ប្រយុទ្ធគ្នា (២៤%) រឺដីស្រែ ។ គ្រោះថ្នាក់ដោយសារមីនបង្កើតឱ្យមាននូវក្រុមជនដែលងាយ នឹងទទួលការរងគ្រោះមួយប្រភេទទៀត គឺជនពិការ ។ ទិន្នន័យនៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៩ បានឱ្យដឹងថាជនពិការដោយសារការផ្ទុះមីនមានចំនួន ១១% នៃជនពិការ ចំនួន ១៦៩000នាក់ ឬ ១,៥% នៃប្រជាជនសរុប ។

## ការបង្កើនផលប្រយោជន៍ជាអតិបរមានៃការអភិវឌ្ឍន៍

ក្នុងដំណើរការអភិវឌ្ឍន៍ ដើម្បីធនធានឱ្យបាននូវធនធានអតិបរិមា និងផលប្រយោជន៍ខ្ពស់នៃគោលបំនងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយមាននិន្នាការប្រុងប្រយ័ត្នតិចដោយអចេតនា ទៅលើសហគមន៍ពិតប្រាកដណាមួយ ។ ជាការពិតថាសហគមន៍ទាំងនេះមានចំនួនប្រជាជនតិច តំបន់ដាច់ស្រយាល រឺតំបន់ដែលមិនអាចទៅដល់ដោយសារហេដ្ឋារចនាសម្ព័ន្ធពិបាក ដូច្នេះហើយការជះឥទ្ធិពលនៃអភិវឌ្ឍន៍មិនសូវមានសារៈសំខាន់គ្មានលទ្ធភាព និងអនុវត្តន៍ និងការចំណាយលើការអភិវឌ្ឍន៍មិនមានប្រសិទ្ធភាព ។ ជាទូទៅសហគមន៍ទាំងនេះនៅតែជាក្រុមមានការលំបាក និងមានសកម្មភាពអភិវឌ្ឍន៍បន្តិចបន្តួច រឺគ្មានសកម្មភាពអភិវឌ្ឍន៍ ។

## កង្វះមូលធនសង្គម

កង្វះមូលធនធ្វើឱ្យអ្នកក្រីក្របាត់បង់ឱកាសរបស់គេក្នុងការប្រយុទ្ធ និងភាពក្រីក្រ ។ មូលធនសង្គមជាទំរង់នៃបទដ្ឋានជំរឿនដែលជាបណ្តាញទាក់ទងគ្នាទៅវិញទៅមកជាមួយសហគមន៍តាមប្រពៃណី ដែលមានការទទួលស្គាល់ស្របច្បាប់ និងចំណងមិត្តភាពសង្គមដែលអាចបន្ថយភាពងាយទទួលរងគ្រោះនៃអ្នកក្រីក្រ ។ នៅក្នុងសង្គមកម្ពុជាមូលធនសង្គមត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងដោយរបបខ្មែរក្រហម និងសង្គ្រាមស៊ីវិលអូសបន្លាយស្ថានភាពអាក្រក់បំផុតដែលសហគមន៍ រឺហេដ្ឋារចនាសម្ពន្ធ័សង្គមកំពុងខ្វះខាតនេះ ។

## ការប្រមូលផ្តុំភាពក្រីក្រតាមតំបន់ភូមិសាស្ត្រ

ការប្រមូលផ្តុំភាពក្រីក្រតាមតំបន់ភូមិសាស្រ្តៈ ផែនទីភាពក្រីក្រត្រូវផ្តួចផ្តើមបង្កើតនៅក្នុងប្រទេសកម្ពុជាដោយមានការខិតខំប្រឹងប្រែងចូលរួមពីអង្គការស្បៀងអាហារពិភពលោក និងក្រសួងផែនការ (តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា) នាឆ្នាំ ២០០១ ដែលឥឡូវបានក្លាយទៅជាកិច្ចការមួយត្រឹមត្រូវ ។ កិច្ចការនេះដំបូងព្យាយាមបង្ហាញពីតំបន់ស្នូលនៃអ្នកក្រីក្រក្នុងប្រទេសកម្ពុជាដោយប្រើប្រាស់ "បច្ចេកទេសប៉ាន់ប្រមាណតំបន់តូច"[១១] ។ ប្រទេសកម្ពុជាជាប្រទេសទី១ក្នុងប្រទេសអាស៊ី បានប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីទទួលបានការវាស់វែងភាពក្រីក្រតាមការបែងចែកតំបន់ភូមិសាស្ត្រដល់កំរិតឃុំ ដែលសំរេចបានតាមរយៈការបញ្ចូលគ្នានៃទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ ១៩៩៧ ជំរឿនប្រជាជនទូទៅនៅកម្ពុជាឆ្នាំ ១៩៩៨ និងប្រព័ន្ធពត៌មានភូមិសាស្ត្រ (GIS) ។ ការប៉ាន់ប្រមាណបានផ្តល់ឱ្យនូវស្ថានភាពនៃភាពក្រីក្រខាងការប្រើប្រាស់ក្នុងឆ្នាំជំរឿន ១៩៩៨ [១២] ។ លទ្ធផលនៃផែនទីភាពក្រីក្រត្រូវបានគេប្រើសំរាប់តំរូវការឱ្យចំគោលដៅនៃការអន្តរាគមន៍ស្បៀង និងការប្រតិបត្តិសង្គ្រោះបន្ទាន់របស់អង្គការស្បៀងពិភពលោក តាមរយៈរដ្ឋាភិបាលកម្ពុជាផែនទីនៃភាពក្រីក្រ និងរបាយការណ៍ដែលទាក់ទង "ការប៉ាន់ប្រមាណអត្រាភាពក្រីក្រដល់កំរិតឃុំក្នុងប្រទេសកម្ពុជា" បានបញ្ចប់ពេលថ្មីៗនេះនឹងបានបោះពុម្ព ហើយនិងចែកចាយនៅដើម ខែវិច្ឆិកា ឆ្នាំ២០០២នេះ ។

[១១] បច្ចេកទេសត្រូវបានបង្កើតឡើងថ្មីៗនេះ ដោយក្រុមអ្នកស្រាវជ្រាវមួយក្រុមនៅធនាគារពិភពលោកហើយត្រូវបានគេប្រើប្រាស់ប្រទេសមួយចំនួនលើពិភពលោក

[១២] ដើម្បីត្រួតពិនិត្យការផ្លាស់ប្តូរ ស្ថានភាព ភាពក្រីក្រនៃឆ្នាំថ្មីៗនេះ ដោយសារតែការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាង លឿន ក្នុងតំបន់មួយចំនួន និងគ្រោះរាំងស្ងួត និងទឹកជំនន់នាពេលថ្មីៗ ក្រសួងផែនការ និងអង្គការកម្មវិធីម្ហូប អាហារពិភពលោក កំពុងតែធ្វើផែនការដើម្បីឱ្យដឹងឱ្យដឹងភាពពិតនៅថ្នាក់ក្រោមបានឆាប់ ។

ប្រជាជនក្រីក្រភាគច្រើននៅក្នុងប្រទេសកម្ពុជារស់នៅតំបន់ជនបទ ហើយអ្នកធ្វើស្រែពឹងផ្អែកលើអាកាសធាតុ ។ ផែនទីនៃភាពក្រីក្រ (MOP/WFP 2002) ឆ្លុះបញ្ចាំងឱ្យឃើញថាភាពក្រីក្រជាទូទៅប្រមូលផ្តុំនៅក្នុងជនបទ ប៉ុន្តែមិនមែនទាំងអស់ទេ វាបានបង្ហាញថា ១០៤ ឃុំនៅក្នុងតំបន់ជនបទ មានជាង ៧៥% នៃអ្នកក្រក្នុងខណៈពេលដែល ៣៩៤ ឃុំផ្សេងទៀតមានពី ៥០ ទៅ ៧៥% នៃអ្នកក្រ ដែលសរុបប្រហែល ២៧% នៃអ្នកក្រនៅក្នុងឃុំទាំងអស់នៃប្រទេសកម្ពុជា ។

យោងតាមការប៉ាន់ប្រមាណអត្រាភាពក្រីក្រនៅកំរិតឃុំរបស់ WFP ខេត្ត ដែលមានគ្រោះថ្នាក់នៃភាពក្រីក្រខ្ពស់ (៣៩.១ ទៅ ៥៣.៧%) លើសកំរិតមធ្យមភាគជាតិ រួមមាន ឧត្តរមានជ័យ បន្ទាយមានជ័យ សៀមរាប កំពង់ចាម ពោធិសាត់ ព្រៃវែង ស្វាយរៀង និងក្រុងកែប ។ ក្រុងប៉ៃលិនមានគ្រោះថ្នាក់នៃភាពក្រីក្រសំរាប់ពេលក្រោយៗទៀត នៃខេត្តប៉ៃលិនអាចមិនមានភាពច្បាស់លាស់ដោយការពិតថាខេត្តនេះនាពេលបច្ចុប្បន្នទើបតែត្រូវបានបញ្ចូលទៅ ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ហើយវាមិនត្រូវបានគ្របដណ្តប់ជាតំណាងក្នុងខេត្តទាំងមូលដោយការអង្កេតនានា និងរួមទាំងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ ១៩៩៧ ប្រើដោយ MOP/WFP ដើម្បីទាញយកការប៉ាន់ប្រមាណអត្រាភាពក្រីក្រ និងព្យាករណ៍ការចំណាយប្រើប្រាស់សំរាប់គ្រប់គ្រួសារទាំងអស់ក្នុងខេត្ត ។

ភាគច្រើននៃខេត្ត សៀមរាប ឧត្តរមានជ័យ និងបន្ទាយមានជ័យ ដែលមានអ្នកក្រច្រើន ប្រហែលជាដោយសារការពិតថាខេត្តទាំងនេះស្ថិតក្នុងអតីតតំបន់ប្រយុទ្ធដែលប្រជាជនរស់នៅក្នុងស្ថានភាពសង្គ្រាមយូរជាងខេត្តផ្សេងៗទៀត លើកលែងតែក្រុងប៉ៃលិន មួយភាគនៃខេត្តបាត់ដំបង កំពត និងពោធិសាត់ ដែលមានចំនួនប្រជាជនជាច្រើនជាអ្នកមាតុភូមិនិវត្តន៍ ហើយដីភាគច្រើនសំបូរទៅដោយមីន ។ ផ្នែកជាច្រើននៃខេត្តកំពង់ឆ្នាំង និងពោធិសាត់ ក៏ជួបបញ្ហាគ្រាប់មីននេះដែរ ។ សំរាប់ខេត្ត ស្វាយរៀង និងខេត្តព្រៃវែង ភាពពិតនៃអត្រាភាពក្រីក្រខ្ពស់ គឺប្រហែលមកពីការកាន់កាប់ដីកសិកម្មតិចតួច និងមិនអាចទទួលបានធនធានធម្មជាតិប្រចាំឆ្នាំ ។ ការពិតផ្សេងៗទៀត នៃខេត្តទាំងនេះ គឺថាដីកសិកម្មនៃខេត្តទាំងនេះស្ទើរតែគ្មានជីជាតិ ។ ក្នុងខណៈពេលដែលប្រជាជនភាគច្រើនរស់នៅជាកសិករ ហើយពួកគេជាញឹកញាប់ជួបប្រទះនឹងគ្រោះមហន្តរាយធម្មជាតិ ជាពិសេសទឹកជំនន់ និងគ្រោះរាំងស្ងួត ។

## ៣.២ និយមន័យនៃភាពក្រីក្រចំណូល/ចំណាយ

ពហុបញ្ហានៃភាពក្រីក្រធ្វើអោយមានភាពស្មុគស្មាញយ៉ាងខ្លាំងដល់បញ្ហាការវាស់វែង និងការតាមដានការអភិវឌ្ឍន៍នៃការកាត់បន្ថយភាពក្រីក្រ ។ ជាដំបូងសំរាប់កម្មវត្ថុនេះការវាស់វែងភាពក្រីក្រដោយពឹងផ្អែកទៅលើចំណាយប្រើប្រាស់ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីតាមដានដំណើរវិវត្តន៍ក្នុងការកាត់បន្ថយភាពក្រីក្របច្ចុប្បន្ន ។ គោលបំណងនៃការវាស់វែងទាំងនេះ គឺមិនគ្រាន់តែចង់បានត្រឹមតែភាពជាក់លាក់ និងការប៉ាន់ស្មានតាមការយល់ដឹងសំរាប់ពេលវេលាណាមួយនោះប៉ុណ្ណោះទេក៏ប៉ុន្តែចង់បាននូវការអភិវឌ្ឍន៍មួយប្រកបដោយឯកសណ្ឋាន ដើម្បីវាស់វែងនូវរាល់ការផ្លាស់ប្តូរតាមពេលហើយក៏ដើម្បីកត់ត្រានូវលក្ខណៈខុសគ្នានៃអត្រាភាពក្រីក្រក្នុងចំណោមក្រុមប្រជាជនសំខាន់ៗតាមផ្នែក។ ការវាស់វែងខ្លះក្នុងចំណោមការវាស់វែងទាំងនេះត្រូវបានបញ្ជាក់ដូចខាងក្រោម ។

## ៣.២.១ បន្ទាត់ភាពក្រីក្រ

បន្ទាត់ភាពក្រីក្រ គឺជាបន្ទាត់ផ្នែកខាងក្រោមដែលកំណត់ប្រជាជនរស់នៅក្នុងភាពក្រីក្រ។ វាជាបន្ទាត់បញ្ជាក់អំពីចំណូលជាក់លាក់មួយសំរាប់បុគ្គលម្នាក់ ដើម្បីចំណាយទៅលើអាហារដែលអាចផ្គត់ផ្គង់តិចបំផុត២១០០កាឡូរីនៃ ថាមពលប្រចាំថ្ងៃគួបផ្សំនិងចំណាយបន្តិចបន្តួចទៅលើផ្នែកមិនមែនជាអាហារដូចជា ផ្ទះសំបែង និងសំលៀកបំពាក់ជាដើម។

ជាធម្មតាបន្ទាត់ភាពក្រីក្រពីរត្រូវបានគេលើកឡើងជាអាទិគឺ បន្ទាត់ភាពក្រីក្រផ្នែកអាហារ និងបន្ទាត់ភាពក្រីក្រសរុប។ បន្ទាត់ភាពក្រីក្រផ្នែកអាហារមិនគិតអំពីចំណាយលើផ្នែកមិនមែនអាហារឡើយ។ តំលៃថវិកាសំរាប់បន្ទាត់ភាពក្រីក្រវាប្រែប្រួលទៅតាមពេលវេលាទៅតាមតំបន់ និងអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ច។ តារាង ៣.៣ ខាងក្រោមគឺ ជាតំលៃថវិកានៃបន្ទាត់ភាពក្រីក្រសំរាប់តំបន់ផ្សេងៗ គ្នានៅក្នុងប្រទេសកម្ពុជាតាមអត្រាប្តូរប្រាក់បច្ចុប្បន្ន។ តំលៃបន្ទាត់ភាពក្រីក្រនៅតំបន់ជនបទ ជាទូទៅវាទាបជាងតំលៃបន្ទាត់ភាពក្រីក្រនៅតំបន់ប្រជុំជនដទៃ និងភ្នំពេញដោយយោងទៅតាមកំរិតជីវភាពផ្សេងៗគ្នា។

**តារាង ៣.៤ តំលៃរូបិយវត្ថុនៃបន្ទាត់ភាពក្រីក្រ**

| តំបន់ | បន្ទាត់ភាពក្រីក្រអាហារ | | បន្ទាត់ភាពក្រីក្រសរុប | |
|---|---|---|---|---|
| | ប្រាក់រៀល | ដុល្លាអាមេរិក | ប្រាក់រៀល | ដុល្លាអាមេរិក |
| ភ្នំពេញ | ១៧៣៧ | ០,៤៥ | ២៤៧០ | ០,៦៣ |
| ប្រជុំជនដទៃ | ១៥៨៣ | ០,៤១ | ២០៩៣ | ០,៥៤ |
| ជនបទ | ១៣៧៩ | ០,៣៥ | ១៧៧៧ | ០,៤៦ |

**ប្រភព:** លក្ខណៈភាពក្រីក្រនៃកម្ពុជា ១៩៩៩ (ក្រសួងផែនការ)

## ៣.២.២ សន្ទស្សន៍ភាពក្រីក្រ

បុគ្គលម្នាក់ដែលចំណាយផ្ទាល់ខ្លួនរបស់គាត់នៅក្រោមបន្ទាត់ភាពក្រីក្រ គឺត្រូវចាត់ទុកថាជាអ្នកក្រ។ សូចនាករមួយចំនួនត្រូវបានយកមកប្រើក្នុងបំណងពិពណ៌នា និងប្រៀបធៀបស្ថានភាព ។ សូចនាករដែលប្រើប្រាស់ជាញឹកញាប់ រួមមានសន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រ (Headcount Index) សន្ទស្សន៍គំលាតនៃភាពក្រីក្រ (Poverty Gap Index) និងសន្ទស្សន៍វិសមភាពនៃភាពក្រីក្រ (Poverty Severity Index)។

សន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រផ្តល់នូវភាគរយនៃប្រជាជនដែលចាត់ទុកថាជាអ្នកក្រ។ យោងតាមរបាយការណ៍អភិវឌ្ឍន៍មនុស្ស ២០០១ របស់ក្រសួងផែនការ សន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រសំរាប់ឆ្នាំ ១៩៩៩ គឺស្ថិតនៅ ចន្លោះ ៤០ និង ៤៥ ភាគរយ ។ តារាង ៣.៤ ខាងក្រោមផ្តល់នូវការប៉ាន់ប្រមាណសន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រក្នុងប្រទេសកម្ពុជាតាមតំបន់សំរាប់ឆ្នាំ ១៩៩៣/៩៤ ១៩៩៧ និង ១៩៩៩។

### តារាង ៣.៥ សន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រ

| ឆ្នាំ / តំបន់ | 1993/94 | | 1997 Ektrv | | 1999 CT2 | | 1999 TagBrC | |
|---|---|---|---|---|---|---|---|---|
| | បន្ទាត់ភាពក្រីក្រសរុប | បន្ទាត់ភាពក្រីក្រអាហារ | បន្ទាត់ភាពក្រីក្រសរុប | បន្ទាត់ភាពក្រីក្រអាហារ | បន្ទាត់ភាពក្រីក្រសរុប | បន្ទាត់ភាពក្រីក្រអាហារ | បន្ទាត់ភាពក្រីក្រសរុប | បន្ទាត់ភាពក្រីក្រអាហារ |
| **ភ្នំពេញ** | 11.4 | 6.2 | 11.1 | 3.4 | 9.7 | 3.3 | 14.6 | 5.2 |
| **ទីប្រជុំជនទៃ** | 36.6 | 19.6 | 29.9 | 15.4 | 25.2 | 13.7 | 42.4 | 28.4 |
| **ទីជនបទ** | 43.1 | 21.9 | 40.1 | 20.0 | 40.1 | 12.1 | 56.1 | 31.5 |
| **កម្ពុជា** | 39.0 | 20.0 | 36.1 | 17.9 | 35.9 | 11.5 | 51.1 | 28.9 |

**ប្រភព:** លក្ខណៈភាពក្រីក្រនៃកម្ពុជា ១៩៩៩ និង ១៩៩៧ ( ក្រសួងផែនការ)

ដោយឡែកចេញពីការប៉ាន់ស្មានដោយផ្អែកលើជុំទាំងពីរនៃ SES99, វាបង្ហាញអោយឃើញថាភាគរយនៃប្រជាជនក្រីក្រថយចុះបន្តិចបន្តួច ( លើកលែងតែតំបន់ជនបទក្នុងឆ្នាំ ១៩៩៧ ng1999 ដែលសន្ទស្សន៍នៃការរាប់ចំនួនអ្នកក្រនៅថេរដដែល គឺ ៤០,១%) ។ ក៏ប៉ុន្តែតួលេខផ្សេងៗ នៃការអង្កេតទាំងបីដែលត្រូវបានគេប្រើប្រាស់ខាងលើវាពិបាកនឹងផ្តល់នូវសេចក្តីសន្និដ្ឋានអំពីការវិវត្តន៍នៃភាពក្រីក្រក្នុងកំឡុងទសវត្សទី ៩០ ណាស់[១៣] ។ តាមការប្រៀបធៀបភាពក្រីក្រថយចុះយ៉ាងលឿននៅប្រទេសវៀតណាមក្នុងកំឡុងទសវត្សទី ៩០ ពោលគឺចេញពីកំរិតយ៉ាងខ្ពស់។ នៅឆ្នាំ ១៩៩៩ ភាគរយប្រជាជនក្រីក្រដែលបានប៉ាន់ស្មានចំពោះប្រទេសវៀតណាម និងកម្ពុជា គឺប្រហាក់ប្រហែលគ្នា។

**ប្រអប់ទី ៥: តើសន្ទស្សន៍ភាពក្រីក្រ** ( HCI ) **មួយណាគួរត្រូវប្រើ ?**

របាយការណ៍ស្តីពីការអភិវឌ្ឍន៍មនុស្សនៅកម្ពុជានៃក្រសួងផែនការឆ្នាំ២០០១ ត្រូវបានគេផ្អែកលើទិន្នន័យជាមូលដ្ឋានពីអង្កេតសេដ្ឋកិច្ចសង្គមសេដ្ឋកិច្ចរបស់កម្ពុជាឆ្នាំ ១៩៩៩, គុណភាពទិន្នន័យបានជឿថាគឺមិនប្រាកដ ។ ការអង្កេតត្រូវបានអនុវត្តក្នុងពីជុំ ។ ជុំទី១ បានរៀបចំក្នុងកំឡុង ខែ មករា-មិនា ១៩៩៩ និង ជុំទី២ ពី ខែមិថុនា-សីហា ១៩៩៩ ។

សន្ទស្សន៍តាមការរាប់ចំនួនមនុស្សនេះ បានរាយការណ៍ផ្អែកលើការប្រើទិន្នន័យពី ជុំ១ និងជុំទី២នៃការអង្កេត មាន៦៤,៤ និង ៣៥,៩ ដោយឡែកពីគ្នា។ សន្ទស្សន៍ការរាប់ចំនួនមនុស្សនេះបានគណនាលើមូលដ្ឋានទិន្នន័យមកពីជុំទាំងពីរ (ឧទាហរណ៍ទិន្នន័យបញ្ចូលគ្នា) មាន ៥,១.១% ។ ផ្អែកលើមូលដ្ឋានការប៉ាន់ប្រមាណនៃរបាយការណ៍ស្តីពីការអភិវឌ្ឍន៍មនុស្សនៅកម្ពុជានៃក្រសួងផែនការឆ្នាំ២០០១ សន្និដ្ឋានថាចន្លោះពី ៤០-៤៥ ភាគរយនៃប្រជាជនកម្ពុជាបង្ហាញនៅក្រោម ខ្សែបន្ទាត់ភាពក្រីក្រ និងដែលមិនមានភស្តុតាងថាស្ថានភាព នេះកំពុងកែលំអ។ ដូច្នេះតាមបង្ហាញខាងលើភាពគួរឱ្យជឿជាក់បាននៃទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចនៃកម្ពុជាឆ្នាំ១៩៩៩ អាចចោទជាសំនួរ។ ចំណោមបញ្ហាចំបង ៧ នៃគុណភាពទិន្នន័យរបស់ CSES 1999 មានបញ្ចូលភាពមិច្បាស់លាស់ក្នុងការវាស់វែងការប្រើប្រាស់រវាងជុំទាំងពីរ នៃការអង្កេត។ ការមិនច្បាស់លាស់ ដូចគ្នានឹងស្ថានភាពក្រីក្ររបស់នៅកម្ពុជានៃក្រសួងផែនការបានកត់សំគាល់ថា ការចង្អុលប្រាប់ពីសក្តានុពលដ៏ទូលំទូលាយ និងការខុសឆ្គងប្រព័ន្ធវាស់វែង។ គេបានកត់សំគាល់បន្ថែមទៀតថា "ទោះបីមានការរើកញែកថាទិន្នន័យលើជុំទី២គួរឱ្យជឿជាក់ជាង" មូលហេតុរបស់ពួកគេបានផ្តល់អោយមិនធ្វើឱ្យជឿជាក់យ៉ាងពេញលេញដើម្បីធានាការជ្រើសរើសជុំទី២ លើជុំទី១។ ជំរើសផ្សេងទៀតនៃជុំទាំងពីរ ឬទាំងពីរមានលក្ខណវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងតាមការពេញចិត្ត។

ទោះបីជាមានការសង្កេតឃើញដែរថា ការប៉ាន់របស់សន្ទស្សន៍រាប់មនុស្សផ្អែកលើជុំទីពីរនៃ CSES 1999 បានប៉ាន់ប្រមាណតែងតែត្រូវបានគេពេញចិត្តយ៉ាងទូលំទូលាយដូចជាគេបានប៉ាន់ស្មានលើមូលដ្ឋានជុំទី១ និងទិន្នន័យដែលបានបញ្ចូលគ្នា។ ទិន្នន័យនេះប្រហែលសំរាប់ភាពប្រាកដប្រជានៃជុំទីពីរ និងបានឆ្លុះបញ្ចាំងនូវទិដ្ឋភាព និងស្ថានភាពចុងក្រោយនៃគ្រួសារនានាដែលបានធ្វើអង្កេតនៅថ្នាក់ជាតិ ទាំងមូល។

សន្ទស្សន៍គំលាតនៃភាពក្រីក្រវាស់វែងពីគំលាតមធ្យមរវាងកំរិតចំណូលរបស់អ្នកក្រ និងបន្ទាត់ភាពក្រីក្រ ហើយគិតជាភាគរយធៀបនឹងបន្ទាត់ភាពក្រីក្រ។ គំលាតនៃភាពក្រីក្រគឺអាចបង្ហាញពីតំលៃតិចបំផុតសំរាប់កាត់បន្ថយភាពក្រីក្រ ជាឧទាហរណ៍ ភាគរយនៃចំណូលសរុបរបស់គ្រួសារ (ទាក់ទងនឹងបន្ទាត់ភាពក្រីក្រ) ដែលគួរតែត្រូវផ្តល់អោយដើម្បីអោយចំណូលរបស់គ្រួសារក្រីក្រនិមួយៗ កើនឡើងស្មើនឹងបន្ទាត់ភាពក្រីក្រ (ឧបមាថាការផ្តល់អោយនោះមានគោលដៅត្រឹមត្រូវ)។ សន្ទស្សន៍គំលាតនៃភាពក្រីក្រដែលបានប៉ាន់ស្មានផ្អែកលើជុំទាំងពីរនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៩ គឺ ១៥,៤។ ការប៉ាន់ស្មានផ្អែកលើទិន្នន័យនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៩ ជុំទីពីរ គឺ ៦,៥ គឺថយចុះពី ៨,៧ នៅក្នុងឆ្នាំ ១៩៩៧។ សន្ទស្សន៍វិសមភាពនៃភាពក្រីក្រដែលបានប៉ាន់ស្មានផ្អែកលើទិន្នន័យនៃអង្កេត សេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ ១៩៩៩ ជុំទីពីរគឺ ២,០ សំរាប់ភ្នំពេញ ៦,៨ សំរាប់ទីប្រជុំជនដទៃ និង ៦,៩ សំរាប់ទីជនបទ។

សន្ទស្សន៍វិសមភាពនៃភាពក្រីក្រងាយអោយយើងដឹងអំពីបំណែងចែកនៃកំរិតជីវភាពរបស់អ្នកក្រ។ ដូច្នេះវាដាក់ទម្ងន់កាន់តែធ្ងន់ឡើងចំពោះអ្នកក្របំផុតក្នុងចំណោមអ្នកក្រ ។ សន្ទស្សន៍នេះនៅថេរក្នុងកំរិត ៣,១ ក្នុងឆ្នាំ ១៩៩៣-៩៤ ហើយឋិតក្នុងលំដាប់សំរាប់ឆ្នាំក្រោយៗ ពី ០,៦ នៅភ្នំពេញ ទៅ ២,៧ នៅទីជនបទដទៃ និង ៣,៤ នៅទីជនបទ ។ កំណត់សំគាល់ជាគន្លឹះចេញពីការប៉ាន់ស្មានតាមសន្ទស្សន៍ទាំងនេះគឺថាជាមធ្យមអ្នកក្រច្រើនរស់នៅក្បែរបន្ទាត់ភាពក្រីក្រ ហើយជាលទ្ធផលគឺមានសក្តានុពលគួរអោយកត់សំគាល់សំរាប់ការកាត់បន្ថយភាពក្រីក្រតាមកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។

## ៣.៣ ការប៉ាន់ស្មាន ភាពក្រីក្រចំណូល/ចំណាយ

ការវាស់វែងជាក់លាក់នៃភាពក្រីក្រ គឺត្រូវពឹងផ្អែកលើកំរិតចំណូលរបស់បុគ្គលម្នាក់ទាក់ទងទៅនឹងកំរិតទាបបំផុតនៃចំណូលផ្សេងទៀតហៅថា "បន្ទាត់ភាពក្រីក្រ" ។ បន្ទាត់ភាពក្រីក្រជាទូទៅឆ្លុះបញ្ចាំងពីបំរែបំរួលនៃកំរិតជីវភាពតាមតំបន់ ឧទាហរណ៍ ភ្នំពេញ ទីប្រជុំជនដទៃ និងទីជនបទ។ ជំហានដំបូងក្នុងការបង្កើតការប៉ាន់ស្មានភាពក្រីក្រផ្អែកទៅលើចំណាយប្រើប្រាស់ គឺជាការគណនាបន្ទាត់ភាពក្រីក្រដ៏សមរម្យ។ ជំហានទីពីរគឺគណនាសូចនាករមួយចំនួនដែលបញ្ជាក់ពីលក្ខណៈចំណូលរបស់ប្រជាជនទាក់ទងទៅនឹងបន្ទាត់ភាពក្រីក្រ។ ការប៉ាន់ស្មានភាពក្រីក្រជាក់លាក់ត្រូវធ្វើឡើងទាន់ពេលដោយប្រមូលទិន្នន័យថ្មីៗ ស្តីពីចំណូល ហើយដោយប្រៀបធៀបចំណូលរបស់បុគ្គលនិមួយៗ ទៅនឹងបន្ទាត់ភាពក្រីក្រថ្មីៗតាមការប្រែប្រួលនៃតំលៃទីផ្សារ។

លក្ខណៈមួយនៃលក្ខណៈជាច្រើនរបស់អ្នកក្រ ហើយមានការសំខាន់ក្នុងការបញ្ចូលនៃគ្រឿងប្រើប្រាស់ និងអ្វីដែលធ្វើឱ្យមានការខុសគ្នាចំពោះអ្នកមិនក្រ ។ ឧទាហរណ៍ តាមការរៀបរាប់មុខរបស់គ្រឿងប្រើប្រាស់សំខាន់ៗ ដោយគ្រួសារក្រីក្រ វាប្រហែលជាអាចលើកគំរោងដោយមិនចំពោះទៅក្នុងកំណែទំរង់ពន្ធដារ ដែលជៀសវាងការកើនឡើងហួសហេតុក្នុងតម្លៃជីវភាពសំរាប់អ្នកក្រ ។ ដូចជាគំរោងដែលមានប្រយោជន៍សំរាប់ប្រទេសដែលខ្វះការយល់ដឹងក្នុងការរកចំណូលដោយពន្ធ និងក្នុងការប្តូរប្រព័ន្ធ ។ ជាមួយនឹងការប្រើដោយទូទាត់សងវិញសំរាប់បន្ទុកពន្ធដារដោយមិនចំពោះ និងការទទួលបន្ទុករបស់រាជរដ្ឋាភិបាល ។ ផលចំណេញ យូរអង្វែងមួយទៀត នៃការរៀបរាប់របស់ប្រើប្រាស់ដែលសំខាន់ៗដោយអ្នកក្រ វាអាចជួយដល់យុទ្ធសាស្ត្រស្រាវជ្រាវ និងវិនិយោគ ដើម្បីគាំទ្រដល់ការខ្វះខាតរបស់អ្នកក្រ ។ ឧទាហរណ៍ ការវិនិយោគលើផលិតផល ឬបច្ចេកទេស សំរាប់ធ្វើអាហារ

ទុកបានយូរ ចំពោះការប្រើប្រាស់ទោះជាផ្តោតយកចិត្តទុកដាក់ដ៏ខ្លាំងក្នុងចំណោមអ្នកក្រ ដែលអាចកាត់បន្ថយការខុសគ្នាក្នុងស្ថានភាពជីវភាពរស់នៅ ។

វិធីមួយដែលបានរកឃើញជាមួយនឹងមុខទំនិញ ដែលទាក់ទិនយ៉ាងសំខាន់ទៅលើការប្រើប្រាស់នៃអ្នកក្រជាការប្រៀបធៀបលើមធ្យមភាគថវិកាចែកចាយសំរាប់គ្រួសារក្រ និងមិនក្រ ។ ក្នុងការបង្កើនតំលៃនៃមុខរបស់ដែលមានការចែកចាយយ៉ាងទូលំទូលាយក្នុងថវិកានៃអ្នកក្រ ប៉ុន្តែការចែកចាយមានទំហំតូចក្នុងថវិការបស់អ្នកមិនក្រ ដែលដូចគ្នានឹងមូលហេតុនៃការកើនឡើងយ៉ាងខ្លាំងនៃតំលៃជីវភាពរស់នៅសំរាប់អ្នកក្រដែលទាក់ទិន នឹងអ្នកផ្សេងទៀត ។

តារាង ៣.៦ បង្ហាញចំនួនរបស់របបដែលបានជ្រើសរើសនានា ដែលផ្តល់នូវចំណែកនៃភាពខុសគ្នាដ៏សំខាន់រវាងការប្រើប្រាស់របស់អ្នកក្រ និងអ្នកមិនក្រ ។ របស់របបដែលខុសគ្នាធំជាងគេរវាងអ្នកក្រ និងអ្នកមិនក្រ គឺស្រូវ ។ ស្រូវបានកើនឡើងពី២៥-៣២%នៃការចំណាយសរុប (រាប់បញ្ចូលទាំងតម្លៃវត្ថុធាតុដើមសំរាប់ការប្រើប្រាស់ក្រៅពីអំណោយ និងផលិតផលខ្លួនឯង) សំរាប់គ្រួសារអ្នកក្រក្នុងជុំទាំងពីរ, ប៉ុន្តែមានប្រហែលតែ ១៦%នៃការចំណាយចំពោះគ្រួសារអ្នកមិនក្រ។ ក្នុងជុំទី១ ភាពខុសគ្នារវាងការប្រើប្រាស់របស់អ្នកក្រ និងអ្នកមិនក្រមាន ១៧%, ហើយក្នុងជុំទី២ គម្លាតមាន ៩ភាគរយ។ របស់របបប្រើប្រាស់ផ្សេងទៀត ដាក់ក្នុងការបែងចែកផងដែរក្នុងការចំណាយរបស់អ្នកក្រធំជាង អ្នកមាន ដែលរាប់បញ្ចូលទាំងត្រី និងបន្លែស្រស់។ ហើយយ៉ាងខ្លាំងបំផុត របស់របបសំខាន់មានតិចបំផុតគេក្នុងការចំណាយរបស់អ្នកក្រ, បន្តែការកាន់កាប់នូវការបែងចែកក្នុងការចំណាយដោយអ្នកមិនក្រមានថ្លៃឈ្នួលផ្ទះ និងថែរក្សាសុខភាព ការដឹកជញ្ជូន និងទូរគមនាគមន៍។

**តារាង ៣.៦ តំលៃមធ្យម និងអត្រាចំណាយលើទំនិញប្រើប្រាស់ប្រចាំគ្រួសារ**

| ទំនិញ | ការចំណាមធ្យមប្រចាំគ្រួសារ (ជារៀល/ថ្ងៃ) | | ការខុសគ្នាក្នុងការអត្រាចំណាយនៃអ្នកក្រ និងអ្នកមិនក្រ (%) | |
|---|---|---|---|---|
| | ជុំ១ | ជុំ២ | ជុំ១ | ជុំ២ |
| ស្រូវ(គ្រប់ប្រភេទ) | ២៣៤៣ | ២៤៩២ | ១៦,៧៨ | ៩,១៧ |
| ត្រី (ស្រស់,ប្រហុក,ទ្បៀន ,កំប៉ុង ។ល។) | ១១៨៧ | ១៤១១ | ១,៩២ | ១,១៤ |
| បន្លែស្រស់ (ត្រកួន . ស្ពៃក្តោប ។ល។) | ៥០០ | ៦៨០ | ១,១ | ១,០៦ |
| មធ្យោបាយដឹកជញ្ជូន និងគមនាគមន៍ | ៤៤៧ | ៤៥៥ | -១,៨៦ | -១,៥៧ |
| ថៃទាំងវេជ្ជសាស្ត្រ (តំលៃវេជ្ជបណ្ឌិត, ថ្នាំ ។ល។) | ៨៧២ | ៨១៨ | -៤,៤១ | -២,៨២ |
| ឈ្នួលផ្ទះ (ដែលក្នុងនោះមានអ្នកពិការ ) និងជួសជុល | ១៤១៩ | ១៧៨៤ | -៣,៤៧ | -២,៨៥ |

ប្រភព : ស្ថានភាពក្រីក្រនៅកម្ពុជា,១៩៩៩

នៅឆ្នាំ១៩៩៩ តំលៃនៅភ្នំពេញ, ដោយខ្សែបន្ទាត់ភាពក្រីក្រដោយស្បៀងអាហារបានប្រើប្រាស់ដោយការប្រែប្រួល

ភាពក្រីក្រមានភាពងាយស្រួល ដែលអាចធ្វើបាន ការអង្កេតយ៉ាងតូចប៉ាន់ប្រមាណយ៉ាងល្បឿនអាចនឹងធ្វើបាន ដើម្បីប៉ាន់ស្ថានភាពក្រីក្រ នៃទំហំធំធេងរបស់ប្រជាជនដោយមិនមានតំរូវការសំរាប់តំលៃ និងពេលវេលា ផលិតបញ្ចូលទៅការអង្កេតគ្រួសារ ។ សូចនាករភាពក្រីក្រជាឧទាហរណ៍មានប្រយោជន៍ និងសារៈសំខាន់សក្តានុពលភាពសំរាប់តាមដានការរីកចំរើនក្នុងការ

កាត់បន្ថយភាពក្រីក្រ និងកម្មវិធីកំណត់គោលដៅកាត់បន្ថយភាពក្រីក្រ ។ តារាង ៣.៧ ដែលមានជំរើសស្ថិតិ អធិប្បាយអំពីសូនាករ សំរាប់មធ្យមភាគជនក្រីក្រ និងមធ្យមសំរាប់ជន មិនក្រីក្រដែលមាំមួនរវាងជុំទាំងពីរ នៃការអង្កេត សង្គមកិច្ច សេដ្ឋកិច្ចនៅកម្ពុជា (CSES)១៩៩៩ ។ នេះគ្រាន់តែជាគំរូមួយ សំរាប់បញ្ជីយល់ដឹងក្នុងផ្នែក៧ នៃស្ថានភាពក្រីក្រ នៅកម្ពុជាឆ្នាំ១៩៩៩ (Cambodia Poverty Profile) អត្ថន័យ និងខ្នាត (ស្តង់ដារ) ខុសសំរាប់សូចនាករបានគណនា ដោយស្ថានភាពក្រីក្រស្បៀងអាហារក្រោមបន្ទាត់ក្រីក្រ (ក្រស្បៀង) រវាងស្បៀងអាហារនៅបន្ទាត់ក្រីក្រ និងបន្ទាត់ក្រីក្រ (ក្រផ្សេងទៀត ) ពីបន្ទាត់ក្រីក្រ (មិនក្រ) និងប្រជាជនទូទៅ ។

ចំពោះនិយោជិក និងលក្ខណៈនៃការរកចំណូល មានភាគរយទាបសំរាប់ស្បៀងអាហារនៃសមាជិកគ្រួសារក្រីក្រដែលបានធ្វើការក្នុងអាទិត្យ សប្តាហ៍មុន ប្រៀបធៀបទៅនឹងអ្នកក្រ ។ ការខុសគ្នាប៉ុន្តែ មិនមានន័យថាអ្នកក្រនោះទេ ។ តំលៃនៃដីដែលមានម្ចាស់បានបង្ហាញនូវការខុសគ្នារវាងអ្នកក្រស្បៀង អ្នកក្រផ្សេងទៀត និងអ្នកមិនក្រ ។ ចំពោះតំលៃដីនៃអ្នកមានជារៀងរាល់ពេល មានតំលៃជាអ្នកក្រ ។ លក្ខណៈតាមកំរិតភូមិ ដូចគ្នាចំងាយទៅទីរួមស្រុក និងរយៈពេលធ្វើដំណើរទៅសាលាបឋមសិក្សា មិនមានន័យថាមានភាពខុសគ្នារវាងទីក្រុងៈ គ្រួសារអ្នកក្រស្បៀង គ្រួសារអ្នកផ្សេងទៀត និងគ្រួសារអ្នកមិនក្រ ។ អត្ថន័យខុសនេះមានន័យថា ការខុសគ្នារវាងអ្នកក្រ និងមិនក្រ អាចរកឃើញក្នុងសូចនាករសុខភាព ។ ឧទាហរណ៍. ចំនួនជាមធ្យមអ្នកពីក្រៅមក (មិនឈឺ) មកពិនិត្យមានច្រើនជាងក្នុងចំណោមអ្នកក្រ និងការខុសគ្នានេះមានសារៈប្រយោជន៍ ។ ចំនួនកុមារកើតចំពោះស្ត្រី ដែលមានអាយុយល់ដឹងពីកុមារ ក្នុងគ្រួសារក្រីក្រមានសារៈសំខាន់ខ្ពស់ជាងគ្រួសារមិនក្រីក្រ ។

## តារាង ៣.៧ ជំរើសសូចនាករនៃភាពក្រីក្រ

| **សេចក្តីអធិប្បាយនៃសូចនាករ** | **មធ្យមភាគ (តំលាតខុសគ្នា)** | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **អ្នកក្រ** | | | | **អ្នកមិនក្រ** | | **ទាំងអស់** | |
| | **ស្បៀងអាហា ក្រោមបន្ទាត់ក្រីក្រ** | | **ស្បៀងអាហា រវាង បន្ទាត់ក្រីក្រនិងបន្ទាត់ក្រីក្រ** | | | | | |
| | ជុំអង្កេត | | ជុំអង្កេត | | ជុំអង្កេត | | ជុំអង្កេត | |
| | ១ | ២ | ១ | ២ | ១ | ២ | ១ | ២ |
| ភាគរយនៃសមាជិកគ្រួសារអ្នកដែលធ្វើការលើសពីរសប្តាហ៍ | 48.9 (0.9) | 44.5 (1.3) | 50.1 (1.4) | 50.4 (1.2) | 51.2 (0.9) | 52.8 (0.8) | 49.9 (0.6) | 51.3 (0.6) |
| តំលៃដីដែលមានម្ចាស់(លាំនៅដ្ឋាន ចំការគិតជា លានរៀល) | 1.76 (0.31) | 2.91 (0.33) | 3.25 (057) | 2.72 (0.26) | 15.93 (3.61) | 10.71 (0.95) | 7.45 (1.40) | 8.11 (0.64) |
| មធ្យមភាគចំងាយទៅទីរួមស្រុក (គីឡូម៉ែត្រ) | 9.64 (0.62) | 8.40 (1.02) | 11.78 (1.07) | 11.83 (1.53) | 10.85 (1.28) | 10.21 (0.74) | 10.48 (0.70) | 10.40 (0.77) |
| មធ្យមភាគចំងាយធ្វើដំណើរទៅសាលាបឋមសិក្សាដែលនៅជិតជាងគេ (នាទី) | 20.19 (1.50) | 14.33 (1.28) | 20.05 (1.34) | 19.37 (1.32) | 18.05 (1.18) | 19.29 (1.28) | 19.32 (1.03) | 18.81 (1.05) |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំនួនអ្នកពីក្រៅមកទស្សនាក្នុង | 0.99 | 1.27 | 1.33 | 1.10 | 1.73 | 1.49 | 1.31 | 1.37 |
| ម្នាក់ ក្នុងមួយឆ្នាំ | (0.09) | (0.13) | (0.11) | (0.12) | (0.11) | (0.07) | (0.07) | (0.06) |
| កុមារដែលកើតពីស្ត្រីក្នុងអាយុ | 2.22 | 2.55 | 1.98 | 2.41 | 1.76 | 1.91 | 2.00 | 2.10 |
| ១៥-៤៩[២] | (0.07) | (0.15) | (0.12) | (0.10) | (0.07) | (0.06) | (0.05) | (0.05) |

ប្រភព: ស្ថានភាពក្រីក្រនៅកម្ពុជា ១៩៩៧

សំគាល់:លទ្ធទទួលបានពីការធ្វើអង្កេតចំណោម៣០០០គ្រួសារនៅជុំទី១ និង ចំណោម៣០០០គ្រួសារនៅជុំទី២នៃ ការធ្វើអង្កេតស្ថានភាពក្រីក្រនៅកម្ពុជា ១៩៩៩ ជាគំរូទម្ងន់នៃគ្រួសារក្រីក្របានប្រើប្រាស់សំរាប់គណនាភាគរយ ។ ស្តង់ដារ ខុស ក្នុង ( ) បានកែសំរាប់ផលនៃកំរង ជាយុទ្ធសាស្ត្រ និង ថ្លឹង ។

## ៣.៤ គំលាតយេនឌ័រ

*សុភាសិតខ្មែរពោលថា " បុរសដូចមាសទឹកដប់ ទោះបីជាធ្លាក់ក្នុងភក់ក៏នៅតែល្អ ប៉ុន្តែស្ត្រីគឺជាក្រណាត់ស ធ្លាក់ក្នុងភក់នឹងត្រូវប្រលាក់ខូច"*

តាមរយៈវេទិកា "ការកាត់បន្ថយភាពក្រីក្ររបស់ស្ត្រី" ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល "ចំរើនស្ត្រី" បានបង្ហាញយ៉ាងច្បាស់ថាស្ត្រីមានការកង្វល់ដូចបុរសដែរ ដូចជាសន្តិសុខស្បៀង ផ្លូវគមនាគមន៍ និងការដឹកជញ្ជូននៅជនបទ ការចែកចាយទឹក សិទ្ធិកាន់កាប់ដីធ្លីដែលស្ត្រីកំពុងដាំដំណាំ និងចំការមីន ។ ស្ត្រីបានបញ្ជាក់ថាបញ្ហាកង្វល់របស់គាត់ គឺការគ្មានសេវាសុខភាពនៅតាមជនបទ ហើយនៅក្នុងខេត្តបាត់ដំបងស្ត្រីបានបញ្ជាក់យ៉ាងច្បាស់អំពីការរីករាលដាលនៃការប្រើប្រាស់ថ្នាំ (យ៉ាម៉ា) និងផលប៉ះពាល់នៃថ្នាំញៀនដែលបណ្តាលអោយមានភាពក្រីក្រ និងអំពើហឹង្សាក្នុងគ្រួសារ ។ តំណាងប្រជាពលរដ្ឋក្រីក្រមកពីខេត្តតាកែវ ចូលរួមក្នុងសិក្ខាសាលាស្តីអំពីសភា និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលរៀបចំឡើងនៅព្រឹទ្ធិសភាពីថ្ងៃទី២៨ និង២៩ ខែតុលា ឆ្នាំ២០០២ បានរៀបរាប់រឿងរ៉ាវកំសត់របស់ខ្លួនថា "គ្រួសាររបស់ខ្ញុំក្រណាស់ បងប្រុសរបស់ខ្ញុំញៀនថ្នាំនៅពេលទៅធ្វើការនៅតាមព្រំដែនថៃ ។ សព្វថ្ងៃនេះ យើងត្រូវមើលថែទាំគាត់ទាំងថ្ងៃទាំងយប់ ។ យើងត្រូវចំណាយលុយជាច្រើនលើថ្នាំ គាត់មិនទាន់ជានៅឡើយ ។ យើងត្រូវនៅមើលថែទាំគាត់ ដូច្នេះហើយយើងគ្មានពេលគ្រប់គ្រាន់ទៅប្រកបរបរចិញ្ចឹមជីវិត ជីវភាពរបស់យើងកាន់តែយ៉ាប់យឺន" ។ នៅក្នុងតំបន់ខ្លះឪពុកម្តាយពុំហ៊ានអោយកូនទៅសាលារៀនឡើយ ពីព្រោះថានៅតំបន់នោះមានការប្រើថ្នាំញៀន ។ ឪពុកម្តាយរារែកក្នុងការបញ្ជូនកូនស្រីទៅរៀននៅសាលាឆ្ងាយពីផ្ទះដោយបារម្ភពីសុវត្ថិភាព និងដោយចង់អោយកូនស្រីទៅធ្វើការរកចំណូលសំរាប់គ្រួសារ និងនៅជួយធ្វើការងារផ្ទះ ។ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ទាំងនេះបញ្ជាក់យ៉ាងច្បាស់ថាស្ត្រី "ទទួលបន្ទុកបីយ៉ាង" គឺធ្វើការក្រៅផ្ទះចំអិនម្ហូប និងធ្វើការងារផ្ទះ និងមើលថែទាំកូន ចាស់ជរា និងអ្នកជំងឺ ។ ដូច្នេះហើយស្ត្រីក្រពេលវេលា" និងខ្វះខាតធនធានសម្ភារៈ ។

ភាពក្រីក្រនឹងមិនអាចកាត់បន្ថយបានឡើយ បើសិនជាគោលនយោបាយ និងកម្មវិធីមិនដោះស្រាយស្ថានភាពរបស់ស្ត្រីនៅកម្ពុជា ។ នេះគឺជាបញ្ហាយេនឌ័រ ដែលមាននៅក្នុងគ្រប់វិស័យជាច្រើន ។ ដូច្នេះការធ្វើអោយប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រី នឹងមិនត្រឹមតែដោះស្រាយបញ្ហាសមធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយ ពង្រឹង/ធ្វើអោយមានស្ថេរភាពនៃកិច្ចខិតខំប្រឹងប្រែងដើម្បីកិច្ចអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រទៀតផង ។ មានការទទួលស្គាល់ជាសកលថាការអប់រំរបស់ស្ត្រី និងការបង្កើនភាព

---

[2] ក្នុងនោះមានស្ត្រីដែលមិនមានកូន

អង់អាចដល់ស្ត្រី ផ្តល់លទ្ធផលជាវិជ្ជមានដែលធ្វើអោយកាន់តែប្រសើរឡើងនូវអាហារូបត្ថម្ភគ្រួសារ អត្រាស្លាប់របស់កុមារ និងការប្រើប្រាស់មធ្យោបាយពន្យារកំណើត ការសិក្សា និងសុខភាពរបស់កូនល្អប្រសើរ និងរកប្រាក់ចំណូលប្រចាំគ្រួសារបានច្រើន ។

**ប្រពៃណី** ដើរតួយ៉ាងសំខាន់ក្នុងការបន្តអោយមានគម្លាតយេនឌ័រ ។ ប្រពៃណីទំនៀមទំលាប់ និងរបៀបរស់នៅចាស់មានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រីអស់រយៈពេលជាយូរមកហើយ ។ សុភាសិតខ្មែរខាងលើនេះ បង្ហាញយ៉ាងច្បាស់នូវភាពលំអៀងយេនឌ័រ ។ គ្រួសារខ្មែរជាច្រើនយល់ឃើញថា ការសិក្សារបស់ក្មេងស្រីមិនអាចផ្តល់ផលប្រយោជន៍ដល់គ្រួសារឡើយ ពីព្រោះថាទោះបីជាក្មេងស្រីរៀនចប់ថ្នាក់ខ្ពស់ក៏ក្មេងស្រីត្រូវនៅធ្វើការងារផ្ទះដដែល ។ ប្រពៃណីបានបង្រៀនអោយស្ត្រីគោរពប្តី ទោះបីជាស្ត្រីជាអ្នករកស៊ីចិញ្ចឹមគ្រួសារក៏ដោយ ។ លើសពីនេះទៀតគ្រួសារខ្មែរជាច្រើនចាត់ទុកថាស្ត្រីមានលទ្ធភាពធ្វើការងារបានល្អ តែចំពោះការងារផ្ទះប៉ុណ្ណោះមិនបានជំរុញលើកទឹកចិត្តអោយស្ត្រីធ្វើការងារខាងក្រៅ ដូចជាចូលរួមក្នុងឆាកនយោបាយ សកម្មភាពសង្គម និងវប្បធម៌ឡើយ ។ ប្រពៃណី និងជំនឿទាំងនេះនៅតែកើតឡើងរហូតមកដល់បច្ចុប្បន្ននេះ យើងត្រូវតែផ្លាស់ប្តូរប្រពៃណី និងជំនឿទាំងនេះ ។ អ្នកដឹកនាំថ្នាក់ជាតិ និងសហគមន៍ ក៏ដូចជាអន្តរាគមន៍របស់រដ្ឋាភិបាលមានតួនាទីសំខាន់ណាស់ក្នុងការនាំមកនូវការផ្លាស់ប្តូរ និងជំនះរាល់ឧបសគ្គចំពោះស្ត្រី ។

**បន្ទុកការងារ** ជានិច្ចកាលដាក់ទំងន់ធ្ងន់ទៅលើស្ត្រី បើប្រៀបធៀបទៅនឹងបុរស ពីព្រោះស្ត្រីមានតួនាទីប្រកបរបរចិញ្ចឹមជីវិត និងបង្កកំណើត ។ បច្ចុប្បន្នស្ត្រីមានបន្ទុកការងារច្រើនជាងពីអតីតកាល ។ សង្គ្រាមស៊ីវិល និងការវិវាទរយៈពេលពីរសតវត្សបានធ្វើអោយស្ថានភាពស្ត្រីនៅកម្ពុជាធ្លាក់ចុះ ។ “បច្ចុប្បន្នស្ត្រីធ្វើការងារច្រើនជាងពីអតីតកាលដែលការងារទាំងនោះ មិនមែនជាតួនាទីប្រពៃណីដែលស្ត្រីធ្លាប់ធ្វើពីអតីតកាល ដូចជាភ្ជួររាស់ និងឡើងដើមត្នោតជាដើម (នេះជាសកម្មភាពគ្រោះថ្នាក់ដែលជាញឹកញាប់បណ្តាលអោយមានរបួស និងពេលខ្លះរហូតដល់ស្លាប់” ។ ស្ត្រីមេម៉ាយត្រូវធ្វើការងារប្រភេទនេះច្រើនជាងស្ត្រីមានស្វាមី ឬស្ត្រីដែលមានបុរសពេញកំលាំងនៅក្នុងគ្រួសារ ...” ដកស្រង់ចេញពីកិច្ចព្រមព្រៀងភាពជាដៃគូកាត់បន្ថយភាពក្រីក្រ ២០០១ ។

**ការងារ** របស់ស្ត្រីមិនសូវមានលក្ខណៈល្អឡើយ ។ ស្ត្រីកម្ពុជាមានចំនួនជាងពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋទាំងអស់ (៥១.៦ ភាគរយ) និងស្ត្រីជាសកម្មជនសេដ្ឋកិច្ចមាន ៦៥.៩ នៃសកម្មជនទាំងអស់ ។ ម្យ៉ាងទៀតគ្រួសារនៅកម្ពុជាចំនួន ១៩.៦ ភាគរយស្ត្រីជាមេផ្ទះ ។ តាមរយៈរបាយការណ៍ការងារពិភពលោកឆ្នាំ២០០១ បង្ហាញអោយឃើញថាប្រទេសកម្ពុជា មានអត្រាស្ត្រីចំនួន ៧៣.៥ ភាគរយ ចាប់ពីអាយុ១៥ឆ្នាំឡើងចូលរួមក្នុងកំលាំងពលកម្ម ដែលនេះជាអត្រាខ្ពស់បំផុតនៅក្នុងតំបន់ ។ ស្ត្រីចំនួន ៥៤ ភាគរយ ជាអ្នកប្រកបមុខរបរកសិកម្ម និងនេសាទ និងចូលរួមយ៉ាងសំខាន់ក្នុងវិស័យផ្សេងៗទៀតក្នុងផ្នែកសេដ្ឋកិច្ច ។ ស្ត្រីចំនួន ៧៥ ភាគរយនៃកំលាំង ពលកម្ម ប្រកបមុខរបរអាជីវកម្មលក់ដុំ និងលក់រាយ និងចំនួនពីរភាគបីនៃកំលាំងពលកម្ម ចូលរួមក្នុងការផលិត ។ ទោះបីជាយ៉ាងណាក៏ដោយការងារមួយចំនួនធំរបស់ស្ត្រី គឺមិនមែនជាផ្នែកផ្លូវការ ។ ជាញឹកញាប់ស្ត្រីធ្វើការក្នុងតួនាទីដែលមានប្រាក់ខែតិច ការងារគ្មានជំនាញ និងងាយទទួលការរងគ្រោះដោយសារការកេងប្រវ័ញ្ចនៅកន្លែងធ្វើការ ។ ស្ត្រីតែងតែមានទំនោរងាកទៅរកការទទួលខុសត្រូវចំពោះអាជីវកម្មនៅផ្ទះ ដែលស្ត្រីអាចរក្សាបាននូវតុល្យភាពរវាងតួនាទីទទួលខុសត្រូវមើលថែទាំកូន និងថែរក្សាផ្ទះជាមួយនឹងការប្រកបអាជីវកម្មរបស់ខ្លួន ។ ភាពក្រីក្ររបស់ស្ត្រី និងបុរសមានភាពខុសគ្នាដោយសារ

តម្រូវការរបស់ស្ត្រីដើម្បីបំពេញតួនាទីការងារផ្ទះ ការងារផលិតកម្ម និងសហគមន៏ "បន្ទុកបីយ៉ាង" ។ ដូច្នេះហើយដោយសារតម្រូវការទាំងនេះ ស្ត្រីជាអ្នក "ក្រពេលវេលា" ។

**ការសិក្សា** នៅមានកំរិតចំពោះស្ត្រី ។ គម្លាតយេនឌ័របង្ហាញយ៉ាងច្បាស់នៅក្នុងអត្រាមនុស្សវ័យជំទង់ ដែលមិនចេះអក្សរ (ស្ត្រី ៦១,១ភាគរយ និងបុរស ៨២,៩ភាគរយ) ។ នេះគឺជាទំនាក់ទំនងវិជ្ជមានរវាងកំរិតនៃការអប់រំរបស់នារីពេញវ័យនៅក្នុងគ្រួសារ និងភាពក្រីក្រនៅក្នុងគ្រួសារ ។ ចំនួនជាង ១៩,៦ ភាគរយនៃគ្រួសារនៅកម្ពុជា គឺស្ត្រីជាមេផ្ទះ ។ មានតែចំនួន ១២ ភាគរយ នៃស្ត្រីអាយុចាប់ពី២៥ឡើងប៉ុណ្ណោះបានរៀនលើកំរិតបឋមសិក្សា ។ គំលាតនេះនៅតែកំពុងកើនឡើង ដោយសារការមករៀនមិនបានទៀងទាត់របស់ក្មេងស្រីនៅក្នុងការអប់រំក្នុងប្រពន្ធ័ ហើយដែលក្នុងនោះអត្រានៃការចុះឈ្មោះចូលរៀនរបស់ក្មេងស្ត្រីអាយុ១៥ឆ្នាំមានចំនួនតិចជាងក្មេងប្រុសចំនួន ៥០ភាគរយ ។ នៅតំបន់ជនបទ អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសអាយុ៥-១៩ឆ្នាំ មាន ៥៥,៦ ភាគរយ ចំណែកឯអត្រារបស់ក្មេងស្រីគឺ ៤៥,៧ភាគរយ ។ នៅជនបទក្មេងអាយុ៥ឆ្នាំឡើងទៅដែល មិនបានរៀនបញ្ចប់កំរិតណាមួយសោះ ក្មេងប្រុសមានចំនួន២៨,១ភាគរយ និងក្មេងស្រីមាន ចំនួន៤១,៥ភាគរយ ។ ការអប់រំទាបរបស់ស្ត្រីបណ្តាលអោយមានផលវិបាកជាច្រើនដល់សុខមាលភាពរបស់គ្រួសារ និងការរកចំណូលប្រចាំគ្រួសារ ។

**សុខភាព** គឺជាបញ្ហាលំបាកសំរាប់ស្ត្រី ។ ស្ត្រីជានិច្ចកាលប្រឈមមុខនឹងអត្រាគ្រោះថ្នាក់ខ្ពស់ដោយសារសុខភាពមិនល្អ ។ នៅគ្រប់ដំណាក់កាលនៃជីវិតរបស់ស្ត្រី ស្ត្រីត្រូវប្រឈមមុខនឹងគ្រោះថ្នាក់សុខភាពជាប្រចាំ ជំងឺផ្សេងៗទៀត និងពេលខ្លះអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់ជីវិត (មានគភ៌ ឈឺពោះសំរាល និងសំរាល)។ តាមរបាយការណ៍ DHS ឆ្នាំ២០០០ បង្ហាញអោយឃើញថា នៅកម្ពុជាទារកដែលកើតដោយមិនបានធ្វើផែនការមាន ៣២ ភាគរយ និងមិនចង់បានមានចំនួន ២៤ ភាគរយ ។ ស្ត្រីចំនួន ៥ភាគរយ បានធ្វើការរំលូតកូនដែលក្នុងនោះ ១ ភាគរយ បានធ្វើការរំលូតកូនពីរដង ឬលើសពីនេះ ។ ជិត ៣០ ភាគរយនៃការរំលូតកូនធ្វើឡើងនៅផ្ទះ ។ តួលេខទាំងនេះគឺជាស្ត្រីទាំងអស់ ដូច្នេះបានន័យថាស្ថានភាពក្រីក្រគឺកាន់តែធ្ងន់ធ្ងរឡើងៗ ។ ការមានកូនញឹក និងការរំលូតកូនមិនត្រឹមត្រូវជានិច្ចកាលធ្វើអោយសុខភាពរបស់ស្ត្រីកាន់តែធ្លាក់ថយចុះ និងបណ្តាលអោយមានគ្រោះថ្នាក់ដល់ជីវិត ។ ស្ត្រីម្នាក់បាននិយាយថា "ខ្ញុំគិតថាខ្ញុំមានកូនច្រើនពេក... ជាការល្អណាស់បើសិនជាខ្ញុំមិនមានកូនបន្តបន្ទាប់គ្នាដូចនេះ ព្រោះវាធ្វើអោយខ្ញុំខ្សោយកំលាំង ប៉ុន្តែខ្ញុំមិនហ៊ានពិភាក្សាបញ្ហានេះជាមួយប្តីរបស់ខ្ញុំ " ដកស្រង់ចេញពីកិច្ចព្រមព្រៀងភាពជាដៃគូកាត់បន្ថយភាពក្រីក្រ ២០០១ ។ លើសពីនេះទៀតដោយសារភាពលំអៀងយេនឌ័រ និងអសមភាពក្នុងសង្គមស្ត្រីមិនសូវ មានអទិភាពក្នុងការទទួលបានសេវាសុខភាព ។ តាមទិន្នន័យរបស់ DHS ឆ្នាំ២០០០ បង្ហាញអោយឃើញថាក្មេងស្រីក្រីក្រចំនួនតែ ១២ ប៉ុណ្ណោះមកពិនិត្យសុខភាពនៅពេលមានជំងឺរាក និង ២៥ ភាគរយ នៅពេលមានជំងឺក្អក ។ សេវាថែទាំសុខភាពសំរាប់ ស្ត្រីជាទូទៅនៅមានកំរិត ។ តាមរបាយការណ៍ DHS ឆ្នាំ២០០០ បង្ហាញអោយឃើញអត្រានៃស្ត្រីដែលមិនអាចទទួលបានសេវាសុខភាពមានកំរិតខ្ពស់គឺ ៨៨,១ ភាគរយ ដោយសារបញ្ហាខ្វះថវិកា ។ មានភាពខុសគ្នាយ៉ាងខ្លាំង និងគួរអោយកត់សំគាល់នៃលទ្ធភាពការផ្តល់សេវាថែទាំម្តាយនៅតាមតំបន់នីមួយៗ ។ អត្រានៃស្ត្រីដែលមិនបានទទួលការថែទាំសុខភាពពេលមានគភ៌មានកំរិតខ្ពស់នៅខេត្តមណ្ឌលគីរី/ រតនះគីរី និងព្រៃវែង (៨០ភាគរយ និង៧៩ភាគរយ) និងទាបបំផុតគឺ១៦ភាគរយនៅភ្នំពេញ ។

ការរីករាលដាលនៃមេរោគ **អេដស៍/ហ៊ីវ** បន្ថែមបន្ទុកយ៉ាងធ្ងន់ធ្ងរលើស្ត្រី ។ ចាប់ពីឆ្នាំ១៩៩៨មក ស្ត្រីមានគភិ ចំនួន ២.៤ ភាគរយ អ្នករកស៊ីផ្លូវភេទចំនួន ៤២.៦ ភាគរយ និងអ្នករកស៊ីផ្លូវភេទ ដោយប្រយោលចំនួន ១៩.១ មានផ្ទុកមេរោគហ៊ីវ/អេដស៍ ។ ស្របពេលជាមួយគ្នានឹងការកើនឡើងនៃការប្រើស្រោមនៅក្នុងអាជីវកម្មផ្លូវភេទ ក៏មានការកើនឡើងនៃការរីករាលដាលនៃជំងឺអេដស៍នៅក្នុងចំណោមស្ត្រីរៀបការដែលជាក្រុមគោលដៅដែលយុទ្ធសាស្ត្រ និងកម្មវិធីអេដស៍/ហ៊ីវមិនគួរមើលរំលងឡើយ ។ ស្ត្រីមានតួនាទីថែទាំសមាជិកគ្រួសារដែលមានផ្ទុកមេរោគហ៊ីវ/អេដស៍ និងសមាជិកគ្រួសារដែលរងគ្រោះដោយសារគ្រាប់មីន ពិការ និងជំងឺ ។

**ការជួញដូរ និងអាជីវកម្មផ្លូវភេទ** ជានិច្ចកាលមានគោលដៅលើស្ត្រី និងកុមារដែលងាយទទួលរងគ្រោះ ។ ប្រទេសកម្ពុជាកំពុងក្លាយជាប្រទេសបញ្ជូនទទួល និងឆ្លងកាត់សំរាប់ការជួញដូរស្ត្រី និងកុមារ ។ តាមការប៉ាន់ប្រមាណ ស្ត្រីកម្ពុជាចំនួនប្រហែល ៨៨.០០០ នាក់ ត្រូវគេជួញដូរទៅប្រទេសថៃ ។ អ្នករកស៊ីផ្លូវភេទ ចំនួន៨០-៦០ភាគរយ (១៤.០០០នាក់) នៅកម្ពុជា និយាយថាពួកគេត្រូវគេបង្ខំ ឬចាញ់បោកគេ ។ ក្មេងស្រីមួយចំនួនទៀតប្តូរទៅប្រកបរបរផ្លូវភេទ ដោយសារពួកគេគ្មានជំរើស ។ ភាពក្រីក្រ ការធ្លាក់ចុះនៃសង្គម ហេដ្ឋារចនាសម្ព័ន្ធផ្លូវច្បាប់មិនទាន់រីកចំរើន និងការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ នាំទៅរកការកើនឡើងជាលំដាប់នូវឧស្សាហកម្មផ្លូវភេទ និងការជួញដូរស្ត្រី និងកុមារ ។

**អំពើហឹង្សាក្នុងគ្រួសារ** កំពុងតែកើនឡើង និងជាការគំរាមកំហែងចំពោះស្ត្រីនៅកម្ពុជា ។ តាមការសិក្សាស្រាវជ្រាវឆ្នាំ១៩៩៦ បង្ហាញអោយឃើញថាអំពើហឹង្សាក្នុងគ្រួសារប្រឆាំងស្ត្រី គឺជាបញ្ហាធ្ងន់ធ្ងរដែលស្ត្រី មួយចំនួនធំជួបប្រទះ ។ អ្នកចូលរួមក្រុមពិភាក្សាបាននិយាយថា "ជាទូទៅយើងគ្មានអាហារគ្រប់គ្រាន់ដើម្បីគ្រួសារទេ គ្រួសារខ្លះមានកូន១០នាក់ ។ ក្នុងកំឡុងពេល និងក្រោយគ្រោះមហន្តរាយយើងត្រូវប្រឹងប្រែងធ្វើការដើម្បីរកអាហារសំរាប់គ្រួសារ ។ កូនរបស់យើងនៅតែគ្មានអាហារហូបគ្រប់គ្រាន់ ពួកវាឃ្លានរហូត ។ យើងពិបាកចិត្តណាស់ ពេលខ្លះយើងឈ្លោះគ្នាខ្លាំងៗ ពេលខ្លះយើងវាយកូនព្រោះមិនអាចលួងវាបាន ។ ពេលខ្លះប្តីប្រពន្ធវាយគ្នា ប្រពន្ធជាអ្នករងគ្រោះធ្ងន់ជាងគេ " ដកស្រង់ពីរបាយការណ៍របស់អង្គការសុខភាពពិភពលោកឆ្នាំ ២០០១ ដែលមិនទាន់បោះពុម្ពផ្សាយនៅឡើយស្តីពីការសិក្សា អំពីគ្រោះមហន្តរាយនៅក្នុងសហគមន៍មួយចំនួនដែលបានជ្រើសរើសនៅកម្ពុជា ។ ក្នុងខណៈពេលដែលមានការលំបាកក្នុងការកំណត់អោយបានច្បាស់នូវរូបភាពពិតប្រាកដនៃអំពើហឹង្សាក្នុងគ្រួសារ សន្ទស្សន៍បង្ហាញអោយឃើញថា ករណីអំពើហឹង្សាក្នុងគ្រួសារកាន់តែកើនឡើង ។ តាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូកាត់បន្ថយភាពក្រីក្រ ២០០១ បានបង្ហាញអោយឃើញថា ៧៦ ភាគរយនៃអ្នកចូលរួមក្នុងក្រុមពិភាក្សាជឿថាបច្ចុប្បន្នអំពើហឹង្សាក្នុងគ្រួសារកើតឡើងច្រើនជាងពីអតីតកាល ។ ដំណើរការពិគ្រោះយោបល់ដែលបានរៀបចំឡើងសំរាប់ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្របង្ហាញអោយឃើញថាអំពើហឹង្សាក្នុងគ្រួសារ គឺកើតឡើងជាប្រចាំចំពោះស្ត្រី និងកើនឡើងយ៉ាងខ្លាំងនៅកន្លែងដែលមានការប្រើថ្នាំញៀន ។

# ជំពូក ៤: សកម្មភាពកាត់បន្ថយភាពក្រីក្រជាអាទិភាព

រាជរដ្ឋាភិបាលបានខិតខំស្វែងរកមូលហេតុនៃភាពក្រីក្រតាមរយៈ IPRSP និង SEDP2 បន្ទាប់ពីបានផ្សព្វផ្សាយ IPRSP នៅខែតុលា ឆ្នាំ ២០០០ ហើយគោលនយោបាយមួយចំនួនត្រូវបានបង្កើត និងអនុវត្តន៍ដោយរាប់បញ្ចូលទាំងការកែទំរង់វិស័យជលផល រុក្ខាប្រមាញ់ និងវិស័យផ្សេងៗ ទៀត ។

នៅជំពូកនេះមានបង្ហាញជូននូវតំរូវការជាអាទិភាព ដើម្បីរាជរដ្ឋាភិបាលយកទៅធ្វើជាយុទ្ធសាស្ត្រដើម្បីកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រជាអាទិភាពមានបួនចំនុចៈ ការបង្កើនអធិរេក, ការពង្រីកសមត្ថភាព, ការកាត់បន្ថយ ភាពងាយរងគ្រោះ, ធានានូវការចូលរួមក្នុងសង្គម និងបង្កើនអភិបាលកិច្ចល្អ ។ តារាង ៤.១ បង្ហាញពីការងារ និងយុទ្ធសាស្ត្រជាចង្កោមរបស់រដ្ឋាភិបាលក្នុងការកំណត់យុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយភាពក្រីក្រក្នុរយៈពេល ២០០៣-២០០៥ ។

សកម្មភាពកាត់បន្ថយភាពក្រីក្រជាអាទិភាពគួរត្រូវបានគេកត់សំគាល់ថា ជាយុទ្ធសាស្ត្របានបង្ហាញនៅក្នុងជំពូកនេះក្នុងករណីខ្លះវាទូទៅ និងទូលំទូលាយពេកតាមផ្នែក និងតាមទស្សនៈវិស័យនានា។ ដូច្នេះយុទ្ធសាស្ត្រ និងភាពវាស់វែងបាននូវសកម្មភាពនានាបានផ្តល់ឱ្យក្នុងម៉ាទ្រីសផែនការសកម្មភាព មានក្នុងឯកសារភ្ជាប់ទី៣ ដែលនឹងធានាឱ្យសំរេចនូវគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកំឡុងពីឆ្នាំ ២០០៣-២០០៥ ហើយត្រូវជ្រើសរើសភាគច្រើនជាជនក្រីក្រ និងទិសដៅ ឬសូចនាករដែលមានតំលៃត្រូវគេផ្តល់ឱ្យដោយសមស្រប។ ដូច្នេះម៉ាទ្រីសផែនការសកម្មភាពមិនចាំបាច់គ្របដណ្តប់លើគ្រប់អ្វីៗ ដែលបានបង្ហាញក្នុងអត្ថបទនេះទេ ។ ការអនុវត្តនឹងសំរេចអោយបាននូវយុទ្ធសាស្ត្រ និងការវាស់វែងសកម្មភាពត្រូវបានគេត្រួតពិនិត្យ និងវាយតម្លៃយ៉ាងទៀងទាត់ ។ បញ្ហានានានៃការគ្រប់គ្រងចំពោះការត្រួតពិនិត្យនិងវាយតម្លៃមានការរៀបចំក្នុងជំពូកទី៦ ហើយបានបង្កើតជាសំណើរចំពោះសូចនាករដោយត្រូវបានគេត្រួតនិងវាយតម្លៃ ហើយផ្តល់ឱ្យមានខ្សែបន្ទាត់ជាមូលដ្ឋានសំរាប់វិស័យមួយចំនួនឧទាហរណ៍ ការអប់រំ និងសុខភាព ។

**តារាង ៤.១ វិធីជាសង្ខេបនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ២០០២-២០០៥**

| មូលហេតុនៃភាពក្រីក្រ | គោលនយោបាយរបស់រដ្ឋាភិបាល |
|---|---|
| កង្វះកាលានុវត្តភាព | ការបង្កើតកាលានុវត្តភាព |
| កង្វះខាតដីធ្លី | កែទំរង់ដីធ្លី, ផ្តល់កម្មសិទ្ធដីធ្លី, ការសំអាតមីន |
| កង្វះខាតការងារ | បង្កើនតុល្យភាពការរីកចំរើនវិស័យសេដ្ឋកិច្ច, ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច, ពាណិជ្ជកម្ម, បង្កើនការវិនិយោគ (បង្កើនសេដ្ឋកិច្ចទេសចរណ៍) |
| កង្វះប្រភពធនធាន | បង្កើតសមាគមរុក្ខកម្ម និងជលផល, ពង្រឹងច្បាប់បរិដ្ឋាន និងបន្ថយកំណើនប្រជាជន ។ |
| កង្វះហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដល់អ្នកក្រីក្រ | បង្កើតផ្លូវជនបទ, បោសសំអាតមីន |

| មូលហេតុនៃភាពក្រីក្រ | គោលនយោបាយរបស់រដ្ឋាភិបាល |
|---|---|
| **ភាពងាយរងគ្រោះ** | **បង្កើនសន្តិសុខ** |
| ការខូចខាតផលដំណាំ | បង្កើតកម្មវិធីសន្តិសុខស្បៀង ( កម្មវិធីអង្ករពលកម្ម) |
| | បង្កើនប្រព័ន្ធស្រោចស្រព និងការដាំដុះ |
| ការប្រើអំពើហឹង្សាមកលើស្ត្រី, ការជួញដូរស្ត្រី និងកុមារ | កែទំរង់ប្រព័ន្ធច្បាប់ |
| ការប្រើកុមារមិនទាន់គ្រប់អាយុ | ផ្តល់អាហាររូបករណ៍ដល់កុមារក្រីក្រអោយចូលរៀនមធ្យមសិក្សា |
| សេវាថៃទាំសុខភាពមានតំលៃខ្ពស់ | ផ្តល់ការពិនិត្យដោយពុំមានបង់ប្រាក់, បង្កើតមូលនិធិដល់អ្នកក្រីក្រនៅឯមន្ទីរពេទ្យរដ្ឋ, និងការការពារនៃការឆ្លង HIV/AIDS |
| ការឆ្លង HIV/AIDS | ការការពារ HIV/AIDS និងផ្តល់អាទិភាពដល់ស្ត្រីភេទ |
| ចំការមីន និងUXOs | បោសសំអាតមីន, ការអប់រំ និងជួយដល់ជនរងគ្រោះ |
| **កង្វះសមត្ថភាព** | **ពង្រឹងសមត្ថភាព** |
| កង្វះការសិក្សាអប់រំ | ការសិក្សាដោយពុំមានបង់ប្រាក់សំរាប់អ្នកក្រីក្រ, ផ្លូវជនបទទំរង់ក្របខ័ណ្ឌមន្ត្រីរដ្ឋាភិបាល |
| កង្វះការពិនិត្យសុខភាព | បង្កើនការយកចិត្តទុកដាក់ដល់តំលៃសេវាសុខភាព |
| | បង្កើនប្រាក់បៀវត្សដល់មន្ត្រីសុខាភិបាល និងកែប្រែបែបបទមន្ត្រីរាជការ |
| | បង្កើនការផ្គត់ផ្គង់ទឹកស្អាត, អនាម័យ និងផ្លូវជនបទ |
| កង្វះជីវជាតិ | បង្កើនការធ្វើអន្តរាគមន៍ការអប់រំស្តីពីជីវជាតិ ( ជាផ្នែកមួយនៃកម្មវិធី សិក្សា) |
| **ការរើសអើងនៅក្នុងសង្គម** | **ការផ្តល់សិទ្ធដល់អ្នកក្រីក្រ** |
| ជាពិសេសភាពងាយរងគ្រោះដល់ប្រជាជន ដូចជាកូនក្មេង, អ្នកគ្មានផ្ទះសំបែង និងមេគ្រួសារស្ត្រីស្ត្រីភេទ និងក្រុមជនជាតិ | បង្កើតកម្មវិធីអប់រំពិសេស, ការបណ្តុះបណ្តាល និងនិតិសម្បទា និងការធានាស្ថេរភាពសង្គម |
| | បង្កើនការប្រើប្រាស់សេវាសុខាភិបាលរបស់រដ្ឋ និងសេវាអប់រំ |
| | ផ្តល់សិទ្ធធ្វើការសំរេចដល់ស្ត្រីភេទ និងក្រុមជនជាតិ |
| កង្វះការចូលរួមក្នុងសង្គម | បង្កើនចំនួនគណៈកម្មាការអភិវឌ្ឍន៍ ភូមិ (VCDs )ដល់ភូមិដ៏ទៃទៀត |

ស្ថាប័នរបស់រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវធ្វើការអភិវឌ្ឍន៍ និងអនុវត្តន៍យុទ្ធសាស្រ្តទាំងនេះ ដើម្បីរួមចំណែកផ្តល់អាទិភាពដល់ការកាត់បន្ថយភាពក្រីក្រសង្គម ។ ស្ថាប័នមួយចំនួនមានយុទ្ធសាស្រ្តទូលំទូលាយ ដូចជាក្រសួងកិច្ចការនារី និងអតីតយុទ្ធជន, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាកែទំរង់រដ្ឋបាលដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជនជាអ្នកទទួលខុសត្រូវ និងសម្របសម្រួលលើគោលនយោបាយកម្មវិធី Gender ហើយក្រសួងអភិវឌ្ឍន៍ជនបទជាអ្នកសម្របសម្រួល និងអនុវត្តន៍នូវទិស

ដៅកាត់បន្ថយភាពក្រីក្រនៅជនបទតាមរយៈការអនិវត្តន៍និងធ្វើសមាហរណកម្មគំរោងអភិវឌ្ឍន៍ជនបទ ។ ក្រសួងទាំពីរនេះបាននឹងកំពុងធ្វើការសហការជាមួយក្រសួងសុខាភិបាល ដើម្បីធ្វើសមាហរណកម្មកម្មវិធីសុខមាលភាពទៅក្នុងការអភិវឌ្ឍន៍សហគមន៍ ។

សារៈសំខាន់នៃការសហការរួមគ្នា គឺជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ ។ ជំងឺអេដស៍ក៏ជាបញ្ហាចំបងមួយដែលទាក់ទងដល់កំណើនប្រជាជន (សូមមើលប្រអប់ទី ៦)

**ប្រអប់ ទី៦: បញ្ហាប្រឈមផ្នែកប្រជាជន**

ជាធម្មតាប្រជាជនកើន ២,៤% ក្នុងមួយឆ្នាំ ដែលជាបន្ទុកធ្ងន់ដល់ការកាត់បន្ថយភាពក្រីក្រហើយការកើនឡើង យ៉ាងឆាប់នេះវាបានបង្កើននូវអត្រាអត់ការងារធ្វើទៀតផង។ ហើយវិស័យកសិកម្ម និងពលកម្មជនបទនៅពុំទាន់បានបង្កើនតាមបំណងប្រាថ្នា និងកង្វះការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណ ដោយពុំបានលើកទឹកចិត្តដល់វិស័យវិនិយោគឯកជន និងកង្វះការគ្រប់គ្រងដីធ្លី ដែលជះឥទ្ធិពលដល់ការបែងចែកដីធ្លីដល់កូនចៅ ។

ការប៉ាន់ស្មានពីកំណើនប្រជាជននាឆ្នាំក្រោយ វាគឺជាផែនការចំបងក្នុងការប្រើប្រាស់ផែនទីដីដែលជួយបង្កើនភាពយុត្តិធម៌ដល់ការបែងចែកដីធ្លីជាពិសេសដល់ដែកសិករផលិតកសិកម្ម ។ ម៉្យាងសន្តិសុខស្បៀងក៏ជាបញ្ហាចំបង ដែលជួយដល់កំណើនប្រជាជនយ៉ាងឆាប់រហ័សនេះ ។

ក្រសួងមួយចំនួនបានធ្វើកម្មវិធីជាន់គ្នា ដូចជាក្រសួងសុខាភិបាលបានធ្វើការងារផ្ទាល់ចំពោះលទ្ធភាពដែលអាចមានកូនច្រើន និងអត្រាមរណភាពខ្ពស់ (ដោយរាប់បញ្ចូលទាំងកុមារនិងការស្លាប់ពេលសំរាល) តាមរយៈការកែលំអនៅពេលសំរាលនិងសេវាសុខភាពកុមារ ដោយធ្វើការពន្យារកំណើត, សុវត្ថិភាពពេលសំរាលនិងពេលពន្លូតកូន, ការការពារជំងឺ, ផ្តល់អាហារមានជីវជាតិនិងការពារជំងឺកុមារ ។

## ៤.១ ការជំរុញការលូតលាស់សេដ្ឋកិច្ច

គោលដៅសំខាន់បំផុតនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺធ្វើអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងដោយមានផ្នែកឯកជនដើរតួនាទីនាំមុខ។ កំណើនសេដ្ឋកិច្ចមានសារៈសំខាន់ណាស់ ក្នុងការធ្វើអោយជនក្រីក្រមានឱកាសរកប្រាក់ចំណូល។

ផ្នែកនេះផ្តើមឡើងដោយបង្ហាញពីការអនុវត្តន៍ផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការដាក់ចេញនូវបណ្តាគោលនយោបាយដែលចាំបាច់សំដៅបង្កើតបរិយាកាសសំរាប់ការអភិវឌ្ឍន៍។ នេះជាវិធានការពេញលេញសំដៅលើកកំពស់កំរិតជីវភាពរបស់ប្រជាជនក្រីក្រ។

### ៤.១.១ ការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច

រូបមន្តសំរាប់ការគ្រប់គ្រងសេដ្ឋកិច្ចដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល គឺការបញ្ចូលរួមគ្នាដ៏ត្រឹមត្រូវនៃគោលនយោបាយលំនឹងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការកែទំរង់រចនាសម្ព័ន្ធមីក្រូសេដ្ឋកិច្ច។ និន្នាការថ្មីៗក្នុងការអនុវត្តន៍ម៉ាក្រូសេដ្ឋកិច្ចជាគន្លឹះមានសង្ខេបនៅក្នុងតារាង ៤.២។ ដូចដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមក្នុងដំណាក់ទីពីរ (SEDP2) រាជរដ្ឋាភិបាល

មានបំនងនឹងសំរេចអោយបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រាពិតពី ៦ ទៅ ៧ ភាគរយក្នុងមួយឆ្នាំ។ សមិទ្ធិកម្មនេះគឺបង្ហាញពីចំនូលក្នុងមនុស្សម្នាក់ៗ (មូលដ្ឋានគិតក្នុងឆ្នាំ២០០០) ប្រមាណជា ៣២០ ដុល្លា នៅចុងឆ្នាំ ២០០៥។ តួលេខនេះបង្ហាញអោយឃើញអត្រាកំណើន ប្រចាំឆ្នាំសំរាប់ចំណូលពិតក្នុងម្នាក់ៗមានចំនួន ៣.៥ ភាគរយ។

ចាប់តាំងពីឆ្នាំ ១៩៩៩ មកកម្ពុជាបានអនុវត្តន៏ និងធ្វើអោយមានការចំរើនជឿនលឿនយ៉ាងខ្លាំងក្នុងការអនុវត្តន៏គម្រោងម៉ាក្រូសេដ្ឋកិច្ចសំដៅសំរេចអោយបានកំណើនសេដ្ឋកិច្ចរយៈពេលវែង និងការអភិវឌ្ឍន៏ប្រកបដោយចីរភាព និងសមធម៌។ ការយកចិត្តទុកដាក់លើគម្រោងនេះ គឺបានរក្សាលំនឹងផ្នែកម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងស្ថាប័នហិរញ្ញវត្ថុ និងធនាគារ ការអនុវត្តន៏វិធានការកែទំរង់សារពើពន្ធ ធានាការគ្រប់គ្រងទ្រព្យសម្បត្តិសាធាណៈអោយបានត្រឹមត្រូវ និងការង្កើនការវិនិយោគសាធារណៈ ដើម្បីអភិវឌ្ឍន៏ធនធានមនុស្ស និងហេដ្ឋារចនាសម្ពន្ធ័សង្គម កាយវប្បកម្ម និងធនធានមនុស្សរបស់ប្រទេសជាតិយើង។ កម្ពុជាបានធ្វើដំណើរឈានទៅមុខយ៉ាងវែងគួរអោយរំភើបចិត្តក្នុងការពង្រឹងស្ថេរភាពសេដ្ឋកិច្ចនយោបាយ និងធ្វើសមាហរណកម្មរបស់ខ្លួន ឡើងវិញទៅក្នុងសហគមន៏អន្តរជាតិ។

ចំពោះរាជរដ្ឋាភិបាលកម្ពុជា កំណើនសេដ្ឋកិច្ចគឺជាអាវុធដ៏មានប្រសិទ្ធិភាពបំផុតសំរាប់ប្រយុទ្ធទល់នឹងភាពក្រីក្រ ។ កំណើននេះបង្ហាញនូវការតាំងចិត្តអនុវត្តគោលនយោបាយដែលជំរុញលំនឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច បង្វែរធនធានយកទៅប្រើប្រាស់លើផ្នែកសំខាន់ៗ និងការធ្វើសមាហរណកម្មក្នុងសេដ្ឋកិច្ចពិភពលោក។ ការធ្វើអោយសេដ្ឋកិច្ចមានលំនឹងឡើងវិញ ការមានសន្តិសុខមាំទាំនៅក្នុងប្រទេស និងជំហាននិងដំណើការស្តារសេដ្ឋកិច្ចក្នុងតំបន់បានជួយកម្ពុជាបង្រួមចូលគ្នានិងធ្វើអោយកាន់តែរីកធំ និងកាន់តែពេញលេញនៃការកែទំរង់ និងរក្សាល្បឿនសំរាប់ទ្រទ្រង់ការអភិវឌ្ឍន៏សេដ្ឋកិច្ចនិងសង្គម។

បណ្ដាចំនុចខាងក្រោមនេះពិនិត្យអំពីនិន្នាការ និងព្រឹត្តិការណ៍ថ្មីៗនៅក្នុងកំណើនសេដ្ឋកិច្ច បំណុលរូបិយវត្ថុ និងនយោបាយសារពើពន្ធ និងផ្នែកហិរញ្ញវត្ថុ ដោយផ្ដោតលើការប្រឈមមុខនានាជាសំខាន់ និងគោលនយោបាយឆ្លើយតបរបស់រដ្ឋាភិបាល។

## កំណើនសេដ្ឋកិច្ច

ចាប់តាំងពីការកកើតរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ១៩៩៣ កំណើនផលទុនសរុបក្នុងស្រុក (ផ.ស.ស) ជាមធ្យមគឺ ៥.៦ ភាគរយ និង ៧ ភាគរយរយៈពេលក្នុងបីឆ្នាំកន្លងទៅ។ កសិកម្មដែលជាផ្នែកមួយដ៏សំខាន់បានស្រូបយក ៤០ ភាគរយនៃ ផ.ស.ស និងមានចំនួនអ្នកបំរើការអោយផ្នែកនេះលើសពី ៧០ ភាគរយនៃកំលាំងពលកម្ម។ ផ្នែកកសិកម្មនេះមានកំណើនជាមធ្យម ៣.៦ ភាគរយ។ ប៉ុន្តែទិន្នផលកសិកម្មមានការប្រែប្រួលចុះឡើងច្រើន ឆ្លុះបញ្ចាំងអោយឃើញការវិនិយោគពុំគ្រប់គ្រាន់តាមផ្នែកការធ្វើអាជីវកម្មហួសប្រមាណលើធនធានធម្មជាតិ និងលក្ខខ័ណ្ឌធម្មជាតិប្រែប្រួលមិនទៀង។

ផ្នែកឧក្សាហកម្មមានកំណើននាំមុខគេ គឺកំណើនប្រចាំឆ្នាំជាមធ្យម ១៦ ភាគរយ។ ផ្នែកនេះមាន អនុផ្នែកផលិតកម្ម (៧៨.៥ ភាគរយ) និងអនុផ្នែកសំណង់ (១៨.៨ ភាគរយ)។ អនុផ្នែកវាយនភណ្ឌ និងសំលៀកបំពាក់កាត់ដេរ មានសន្ទុះរីកដុះដាលយ៉ាងខ្លាំង ហើយបង្ហាញនូវថាមភាពគួរអោយកត់សំគាល់។ ឧស្សាហកម្មកាត់ដេរកម្ពុជាបង្ហាញនូវការរីកចំរើនគួរអោយចាប់អារម្មណ៏ក្នុងការនាំចេញក្នុងរយៈពេលបួនឆ្នាំ កន្លងទៅបន្ទាប់ពីសហរដ្ឋអាមេរិកផ្ដល់ដល់កម្ពុជាឋានៈជាប្រទេសអនុគ្រោះពន្ធនាឆ្នាំ ១៩៩៦ និងប្រពន្ធ័ GSP នៅឆ្នាំ១៩៩៧។ ក្នុងសម័យកាលពីឆ្នាំ១៩៩៦ ដល់ ១៩៩៨ ការនាំចេញសំលៀកបំពាក់បានកើនឡើងពី

៧០ ទៅ ១៩០ ភាគរយ។ ប៉ុន្តែបានធ្លាក់ចុះពី ១៣ ទៅ ៧៥ ភាគរយ ចាប់ពីឆ្នាំ១៩៩៩ ដល់ ២០០១ បន្ទាប់ពី សហរដ្ឋអាមេរិក កំណត់បរិមាណទៅលើមុខទំនិញកាត់ដេរ ១២ ប្រភេទ។ អាស្រយ័ដោយផ្នែកនេះបានស្រូបយកអ្នកមានជំនាញភាគច្រើនជាពិសេសកម្មករស្ត្រីក្រីក្រគ្មានការធ្វើ និងអ្នកមានការងារធ្វើពុំគ្រប់គ្រាន់ ភាពមានការងារធ្វើក្នុងផ្នែកវាយនភណ្ឌ សំលៀកបំពាក់នាបណ្តាឆ្នាំថ្មីៗនេះបានក្លាយជាអានុភាពមានថេរភាពជាចំបងសំរាប់ពលរដ្ឋ និងសេដ្ឋកិច្ច។

ទិន្នផលផ្នែកសេវាកម្មបានថយចុះជាបណ្តើរៗក្នុងខណៈដែលផ្នែកឧស្សាហកម្មត្រូវបានពង្រីក។ វាធ្លាក់ចុះ ៣៩ ភាគរយនៃ ផ.ស.ស នៅឆ្នាំ១៩៩៣ គឺមកនៅត្រឹម ៣១ ភាគរយៈនៅ ២០០១។ បណ្តាសកម្មភាពដែលទាក់ទងផ្នែកទេសចរណ៍ ដូចជា សណ្ឋាគារ និងភោជនដ្ឋានបានកើនឡើងជាមធ្យមក្នុងអត្រាប្រចាំឆ្នាំ ៣០ ភាគរយក្នុងចាប់ពីឆ្នាំ ១៩៩៤ ដល់ ឆ្នាំ១៩៩៥។ ហើយវាក៏បានធ្លាក់ចុះក្នុងសម័យកាលពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ១៩៩៨ ប៉ុន្តែបានកើនឡើងវិញចំនួន ២០ ភាគរយក្នុងឆ្នាំ១៩៩៩។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ការអភិវឌ្ឍន៏វិស័យឧស្សាកម្មទេសចរណ៏បានចូលរួមចំណែកយ៉ាងសំខាន់ដល់កំណើនលូតលាស់សេដ្ឋកិច្ចដោយវាបានទាក់ទាញវិនិយោគពីក្រៅប្រទេសបង្កើតអោយមានការងារធ្វើ និងបង្កើនចំនូលដល់ប្រជាជនតាមមូលដ្ឋាន។ ផ្នែកឧស្សាហកម្មទេសចរណ៍ គឺជាផ្នែកមួយក្នុងចំណោមបណ្តាផ្នែកនានា នៃសេដ្ឋកិច្ចដែលអាចនឹងមានជោគជ័យដោយវាមានសក្តានុពលភាពដ៏ធំធេងដល់កំណើនសេដ្ឋកិច្ច និងមានអានុភាពជាច្រើនទៀតដល់ផ្នែកនានានៃសេដ្ឋកិច្ច។

កម្ពុជានឹងប្រឈមការលំបាកធ្ងន់ធ្ងរនាបណ្តាឆ្នាំខាងមុខនេះ។ យើងឃើញមាននិន្នាការធ្លាក់ចុះនៃការនាំចេញសំលៀកបំពាក់អាស្រ័យដោយការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក និងដោយសហរដ្ឋអាមេរិកបានផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដល់បណ្តាប្រទេសដទៃរួមមានប្រទេសវៀតណាមផងដែរ។ លើសពីនេះទៀតការបន្ថយបរិមាណភាគក្រោមកិច្ចព្រមព្រៀង WTO លើសំលៀកបំពាក់ និងវាយនភណ្ឌក្នុងឆ្នាំ២០០៥ នឹងមានការប្រែប្រួលធំធេងដល់ឧស្សាហកម្មកាត់ដេរកម្ពុជា។

ជាគោលគោលការណ៍ ការលប់ចោលបរិមាណផលិតផល អាចទុកកម្ពុជាអោយក្លាយជាទីផ្សារមិនរ៉ាប់រងដល់ការនាំចេញសំលៀកបំពាក់។ ហេដ្ឋារចនាសម្ពន្ធ័របស់កម្ពុជាក៏នៅទន់ខ្សោយនៅឡើយ ហើយសោហ៊ុយទឹកភ្លើងទៀតសោធក៏នៅមានកំរិតខ្ពស់។ ម្យ៉ាងទៀតនៅពេលដែលឈានដល់កំរិតមួយមានកំលាំងពលកម្មថោក និងអោយផលខ្ពស់សំរាប់រក្សា និងទាក់ទាញវិនិយោគថ្មីពីក្រៅប្រទេស នោះកម្ពុជានឹងជួបការលំបាកជា ច្រើនក្នុងការប្រកួតប្រជែងជាមួយបណ្តាប្រទេសអ្នកផលិតធំៗ ដូចជា ចិន រឺ ឥណ្ឌា។

កម្ពុជាប្រឈមនឹងបញ្ហាជាច្រើនទាក់ទិនទៅនឹងការលុបចោលបរិមាណភាគសំលៀកបំពាក់ ក្នុងនោះមានៈ (១) ការធ្លាក់ចុះនៃការប្រកួតប្រជែង (២) ក្តីសង្ឃឹមមានតែលើការទទួលបរិមាណភាគនៃប្រភេទទំនិញ (បរិមាណសំលៀកបំពាក់នាំចេញក្រោមបរិមាណភាគធ្លាក់ចុះ ៦០ ភាគរយ និងបរិមាណសំលៀកបំពាក់នាំចេញមិនស្ថិត ក្រោមបរិមាណភាគបានធ្លាក់ចុះតែ ៤០ ភាគរយប៉ុណ្ណោះ) (៣) ការប្រមូលផ្តុំខ្ពស់លើទីផ្សារតែមួយចំនួន និង (៤) ផលលិតកម្មពឹងផ្អែកភាគច្រើនលើវត្ថុធាតុដើមនាំចូល។

និន្នាការបច្ចុប្បន្ននៅក្នុងឧស្សាហកម្មកាត់ដេរបង្ហាញនូវការធ្លាក់ចុះក្នុងកំណើនទីផ្សារដែលអាចមានគ្រោះ ថ្នាក់ដល់ឧស្សាហកម្មទាំងមូល បើវិធានការទាំងឡាយពុំបានយកមកអនុវត្តដើម្បីទប់ស្កាត់និន្នាការថយចុះនេះ។ ជាងនេះទៀតគួរតែផ្តោតការយកចិត្តទុកដាក់លើការចំណាយកំលាំងពលកម្មនៅក្នុងរយៈពេលបីឆ្នាំខាងមុខ។ សោហ៊ុយចំណាយលើអគ្គិសនីខ្ពស់ បើប្រៀបធៀបជាមួយបណ្តាប្រទេសដទៃទៀតនៅក្នុងអាស៊ី។

កម្ពុជាចាំបាច់រក្សាការមានប្រៀបខាងការប្រកួតប្រជែងក្នុងឋានៈជាមណ្ឌលផលិតកម្មមានថ្លៃដើមថោក ដោយចាប់ផ្តើមពិនិត្យដោះស្រាយលើសោហ៊ុយចំណាយខ្ពស់ខាងមធ្យោបាយដឹកជញ្ជូន ទឹក អគ្គិសនី ការលើកដាក់ទំនិញនៅកំពង់ផែ។ យន្តការជួយសម្រួលការកើនឡើងប្រាក់បៀវត្សគួរតែផ្តោតការយកចិត្តទុកដាក់ផងដែរ។ ការពង្រីកទីផ្សារ និងប្រភេទផលិតផលក្នុងវង្វង់ឧស្សាហកម្មមួយប្រភេទនេះគឺមានសារៈសំខាន់ណាស់ក្នុងករណី ឧស្សាហកម្មនេះនៅបន្តរីកចំរើនទៅមុខ។ គួរយកចិត្តទុកដាក់ពង្រីកថែមទៀតនូវការផលិតសំលៀកបំពាក់ក្រៅប្រពន្ធ័បរិភោគ។

ការជំរុញការអភិវឌ្ឍន៏ឧស្សាហកម្មផលិតកែច្នៃវត្ថុធាតុដើម គឺជាការសំខាន់ណាស់ក្នុងការកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាទៅលើវត្ថុធាតុដើមនាំចូល។ ក្នុងករណីនេះត្រូវគាំទ្រដល់ឧស្សាហកម្មដែលមានមុខងារ ផលិតគ្រឿងឧបករណ៏សំរាប់បំរើការផលិតសំលៀកបំពាក់ និងឧស្សាហកម្មកែច្នៃក្រណាត់នាំចូល។

ទោះបីជាកម្ពុជាសំបូរកំលាំងពលកម្ម ក៏ភាពស្ទាត់ជំនាញនៅមានកំរិតក្នុងការឈានទៅប្រើប្រាស់ម៉ាស៊ីន ដែលមានកំរិតបច្ចេកទេសខ្ពស់ក្នុងឧស្សាហកម្ម។ កន្លងមកមានការបណ្តុះបណ្តាលតិចតួច។ បុគ្គលិកមានជំនាញកាន់តែស្ទាត់ល្អ ធ្វើអោយគេពេញចិត្តនឹងបំពេញការងារ ហើយគេក្លាយទៅជាអ្នករួមចំណែកក្នុងការបង្កើនផលិតផល។

ការធ្វើអោយមានឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ច្រើនបែបផ្សេងៗគ្នា ព្រមទាំងមានឧស្សាហកម្មកើតឡើងថ្មីៗផង គឺមានសារៈសំខាន់ ដើម្បីបំរើផលប្រយោជន៏ដល់ប្រជាជនកម្ពុជា ការបង្កើតឧស្សាហកម្មថ្មីៗ គួរតែមានយុទ្ធសាស្ត្ររក្សាចីរភាព និងអាចវាយតំលៃបាន។ ការមានប្រភេទផលិតផលផ្សេងៗគ្នាក៏ជាការសំខាន់ដែរ។ ការបង្កើនគុណភាពផលិតផលខ្ពស់តំរូវអោយមានការវិនិយោគផ្នែកបច្ចេកវិទ្យា ការហ្វឹកហ្វឺន និងការត្រួតពិនិត្យគុណភាព។

ទោះបីយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើតអោយមានឧស្សាហកម្មច្រើនប្រភេទជាបន្ទាន់ ដើម្បីកាត់បន្ថយការពឹងផ្អែកទាំងស្រុងលើពាណិជ្ជកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់។ ក្នុងពេលជួបជាមួយ វិនិយោគិនកាលពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០២ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានបង្ហាញពីយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតអោយមានប្រភេទឧស្សាហកម្មច្រើនមុខផ្សេងៗគ្នានៃសេដ្ឋកិច្ចកម្ពុជា។ សម្តេចបានសង្កត់ធ្ងន់ថាក្រៅពីការជួយអភិវឌ្ឍន៏ និងជួយសម្រួលដល់ឧស្សាហកម្មកាត់ដេរ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់អាទិភាពដល់ការអភិវឌ្ឍន៏សហគ្រាសដែលប្រើប្រាស់អតិផលពលកម្មដូចជាប្រដាប់ប្រដារក្មេងលេង ស្បែកជើង ឧបករណ៏ប្រើប្រាស់ និងគ្រឿងអគ្គិសនី សំរាប់ប្រើប្រាស់ក្នុងឧស្សាហកម្ម និងក្នុងស្រុក។

ហេតុដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយដ៏ទូលំទូលាយមួយសំដៅបង្កើនការប្រកួតប្រជែងជាអន្តរជាតិរបស់កម្ពុជា ដោយផ្តោតលើការអភិវឌ្ឍន៏ និងលើកកំពស់ហេដ្ឋារចនាសម្ព័នកាយវប្បកម្ម ដើម្បីឆ្លើយតបអោយមានប្រសិទ្ធភាពដល់ការបង្កើនសេចក្តីត្រូវការផ្នែកមូលដ្ឋានសេវា ដូចជាសេវាហិរញ្ញវត្ថុ ទូរគមនាគមន៏ ពតិមាន និងថាមពលអគ្គិសនី និងទឹកដែលមានតំលៃថោក។

ជារួមគោលនយោបាយឧស្សាហកម្មរបស់រាជរដ្ឋាលកម្ពុជាយកចិត្តទុកដាក់លើបណ្តាចំនុចដូចខាងក្រោមៈ

ទី១: បន្តអភិវឌ្ឍឧស្សាហកម្មដែលប្រើអតិផលពលកម្មដូចជា ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ប្រដាប់ប្រដារក្មេងលេង និងស្បែកជើង ។

ទី២: ជំរុញការអភិវឌ្ឍន៍ពាណិជ្ជកម្មកសិកម្ម ដោយពង្រឹងក្របខណ្ឌច្បាប់សំរាប់ការគ្រប់គ្រងដីធ្លីរយៈពេលវែង។ លើសពីនេះ រដ្ឋាភិបាលនឹងលើកទឹកចិត្តដោយសំរាលពន្ធដារដល់បង្កើតរោងចក្រកែច្នៃផលិតផលកសិកម្ម ដូចជា កប្បាស ក្រចៅ ស្ករ ប្រេង ស្វាយចន្ទី កៅស៊ូ ដំឡូង និងផ្លែឈើ។

ទី៣: អភិវឌ្ឍន៍ផ្នែកឧស្សាហកម្មដែលប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការកែច្នៃប្រើប្រាស់ធនធានធម្មជាតិដែលកំពុងមាននៅក្នុងប្រទេស ដូចជាត្រីសាច់ ផលិតផលស៊ីម៉ងត៍ អិដ្ឋ និងក្បឿង។

ទី៤: ជំរុញផ្នែកសហគ្រាសធនតូច និងមធ្យម (SMEs) មីក្រូសហគ្រាស និងសិប្បកម្ម។

ទី៥: ជំរុញផ្នែកឧស្សាហកម្ម ដែលផលិតគ្រឿងប្រើប្រាស់ឧបករណ៍អគ្គីសនីសំរាប់បំរើអោយឧស្សាហកម្ម និងការប្រើប្រាស់ក្នុងស្រុក និងលើកស្ទួយគុណភាពផលិតផល។ វាជាការចាំបាច់ត្រូវបង្កើតអោយមានប្រព័ន្ធត្រួតពិនិត្យផលិតផលនាំចេញដើម្បីអោយមានខ្នាតអន្តរជាតិ និងដាក់អោយប្រើច្បាប់ ស្តីពីការការពារកម្មសិទ្ធិបញ្ញា។

ទី៦: បង្កើតតំបន់ឧស្សាហកម្ម និងតំបន់កែច្នៃដោយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័នលើកកំពស់គុណភាពសេវាកម្ម និងលើកទឹកចិត្តការវិនិយោគ។ តំបន់នេះអាចបង្កើតឡើងនៅតាមជាយក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តបន្ទាយមានជ័យ រឺខេត្តកោះកុង។ រាជរដ្ឋាភិបាលកម្ពុជា នឹងសាងសង់បណ្តាញផ្លូវថ្នល់ ប្រព័ន្ធថាមពល ទឹក ធានាដល់ការគ្រប់គ្រងកាកសំណល់ និងការការពារ បរិស្ថាន ផ្តល់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើកកំពស់សេវាសុខាភិបាល កសាងឃ្លាំងផ្ទុកទំនិញ និងកាត់បន្ថយបែបរដ្ឋបាលពន្ធគយ និងបណ្តាសកម្មភាពផ្សេងៗទៀតសំដៅធានានូវបរិយាកាសធ្វើអាជីវកម្មមានការរីកចំរើន និងមានប្រាក់ចំណេញ។

ទីប្រាំពីរ: បង្កើននូវបណ្តាផលិតកម្មទំនិញ ដែលនឹងជំនួសអោយផលិតកម្មទំនិញនាំចូល ដោយមានការលើកទឹកចិត្តដល់ឧស្សាហកម្មផលិតក្រដាស ជាតិគីមី ដូចជា ថ្នាំសំលាប់សត្វល្អិត អាស៊ីត ព្រមទាំងផលិតផលប្រើប្រាស់ប្រចាំថ្ងៃ ដូចជា សាប៊ូ ថ្នាំលាប គ្រឿងអគ្គីសនី ម៉ាស៊ីនបូមទឹក និង ឧបករណ៍ បំរើដល់ផ្នែកកសិកម្ម។ល។ ចំណុចចុងក្រោយ និងសំខាន់ដែរនោះគឺរាជរដ្ឋាភិបាលកម្ពុជាជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍វប្បធម៌ធម្មជាតិនៅកម្ពុជា។ កំណើនក្នុងបណ្តាផ្នែកទាំងនេះជួយស្រូបយកកំលាំងពលកម្មកម្ពុជាកាន់តែច្រើនឡើង។ ដើម្បីអោយជនក្រីក្រចាប់យកប្រយោជន៍ក្នុងឱកាសទាំងនេះគេត្រូវការភាពស្ទាត់ជំនាញ និងចលភាពកំលាំងពលកម្មចូលមកក្នុងផ្នែកនិងតំបន់អភិវឌ្ឍន៍។ រាជរដ្ឋាភិបាលនឹងធានាតាមរយៈនៃការបង្កើនចំណូលដែលបានដាក់ចេញនៅក្នុងជំពូក ៥ ថាផ្នែកឯកជនត្រូវអនុវត្តន៍កាតព្វកិច្ចបង់ពន្ធ ដូចនេះតំរូវអោយមានការបែងចែកឡើងវិញតាមរយៈថវិកាជាតិ។ ទាក់ទិននឹងយុទ្ធសាស្ត្រប្រកាសដោយនាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជាបានខំប្រឹងប្រែងយ៉ាងអស្ចារ្យស្មារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័នស្ពានថ្នល់ អាកាសយានដ្ឋាន កំពង់ផែ និងប្រព័ន្ធសំរបសំរួលដ៏ទៃទៀត ដូចជាការផ្គត់ផ្គង់ទឹក ប្រព័ន្ធចែកចាយអគ្គីសនីព្រមទាំងបណ្តាញគមនាគមន៍។

ទោះបីជាបញ្ហាទាំងនេះត្រូវបានលើកមកបរិយាយច្បាស់លាស់យ៉ាងណាក៏ដោយ ក៏នៅមានភាពគ្រោះថ្នាក់មួយចំនួនរារាំងដល់កំណើនសេដ្ឋកិច្ច រួមមានការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ការលុបចោលសមាណភាគបរិមាណ (បានពិភាក្សាខាងលើរួចហើយ) ហានិភ័យផ្នែកបរិយាកាស (ដូចជាទឹកជំនន់) និងការថយចុះវិនិយោគផ្ទាល់ពីក្រៅប្រទេស (FDI) នៅក្នុងអាស៊ីអា

គ្មេយ៍។ ទោះបីជា FDI រំពឹងថានឹងមានចំនួនប្រមាណពី ១០០ ទៅ ១៥០ លានដុល្លារ កម្ពុជាត្រូវតែជំរុញបរិយាគវិនិយោគបន្ថែមទៀតដើម្បីទាក់ទាញវិនិយោគអោយបានច្រើន។ ការប្រឹងប្រែងជាសំខាន់គឺតំរូវការកំណើនកំពស់មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ការផ្តល់សេវាពីរដ្ឋាភិបាលនិងបរិយាកាសអភិបាលកិច្ចទាំងមូល។ ក្នុងករណីពុំបានសង្កត់ធ្ងន់លើឧបសគ្គដូចដែលបានរៀបរាប់ខាងលើពោលគឺ ចំណាយអាជីវកម្មខ្ពស់ ភាពខ្សត់ខ្សោយហេដ្ឋារចនាសម្ព័ន្ធ និងចំណាយផ្សេងៗ វាហាក់ដូចជាប្រទេសយើងកំពុងបាត់បង់ឱកាសដែលជាហេតុនាំអោយមានការធ្លាក់ចុះអត្រាកំណើនប្រចាំឆ្នាំ ពី ១ ទៅ ១,៥ ភាគរយ នៃផ.ស.ស ។

រាជរដ្ឋាភិបាលក៏បង្ហាញនូវតំរូវការការពិភាក្សាបន្ថែមទៀតលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងបច្ច័យរបស់វាលើសង្គម ជាពិសេសលើជនក្រីក្រ និងទំនាក់ទំនងរបស់វាទៅនឹងការកាត់បន្ថយភាពក្រីក្រ ដើម្បីជាជំរើសសំរាប់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនាអនាគតរបស់កម្ពុជា។ កំនើន Scenario ខ្ពស់ចំនួន ៦ ភាគរយ នឹងធានានូវការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើន ។ ឱកាសរកចំណូលនឹងកើតមានដល់ជនក្រីក្រ ប្រសិនជាមានការគឺតគូរដល់ការអភិវឌ្ឍន៏ជនបទ និងកសិកម្ម។ ប្រសិនបើអត្រាកំណើន ផ.ស.ស ហើយការបែងចែកចំណូលរក្សាគ្មានភាពប្រែប្រួលនោះអាចនឹងប៉ាន់ស្មានថាកំណើនចំណូលក្នុងមនុស្សម្នាក់មាន ៣,៥ ភាគរយ ក្នុងមួយឆ្នាំ ។ ភាពក្រីក្រនឹងត្រូវកាត់បន្ថយពី ៣៦ ភាគរយ មកនូវត្រឹម ២០ ភាគរយនៅឆ្នាំ ២០០៥។ ដូចនេះ យជកភ ផ្តល់នូវវិធានការមួយចំនួនដើម្បីលើកកំពស់ការអភិវឌ្ឍន៏ជនបទ និងជាពិសេសកសិកម្ម (សូមអានខាងក្រោម) ។

ផ្ទុយទៅវិញ ប្រសិនបើអត្រាកំណើន GDP របស់ជនបទតាមមិនទាន់កំណើន GDP សរុបការកាត់ បន្ថយភាពក្រីក្រពុំបានច្រើនតាមការគិតទុកឡើយ។ សំរាប់រយៈពេលពីឆ្នាំ ២០០១ ដល់ ២០០៥ ផ.ស.ស ផ្នែកកសិកម្មរំពឹងថានឹងកើនក្នុងអត្រាប្រចាំឆ្នាំចំនួន ៣,៥ ភាគរយ នឹងស្មើនឹង ៦,១ ភាគរយ បើប្រៀបធៀបទៅនឹង ផ.ស.ស សរុប។ ឈរលើមូលដ្ឋាននេះ និងដោយមានការកើនឡើងភាពក្រីក្រដោយសារទឹកជំនន់ឆ្នាំ ២០០០ តួលេខនៃភាពក្រីក្ររំពឹងថានឹងធ្លាក់ចុះមកនៅត្រឹម ៣១ ភាគរយនាចុងឆ្នាំ ២០០៥ ។ បច្ច័យនៃកំណើនភាពក្រីក្រជាការពិត គឺផ្អែកទាំស្រុងលើអត្រាកំណើនប្រជាជនព្រមទាំងការបែងចែកចំណូល។

តារាង ៤-២ សង្ខេបអំពីប៉ារ៉ាម៉ែត្រ និងបំរែបំរួលគំរោងម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវយកមកពិភាក្សាខាងក្រោមៈ

### តារាង ៤.២ កម្ពុជាៈ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ២០០០-២០០៧

*(គិតជាភាគរយនៃGDP)*

| | **2000** | **2001** | **2002** | **2003** | **2004** | **2005** | **2006** | **2007** |
|---|---|---|---|---|---|---|---|---|
| កំណើន GDP , % | 7.7 | 6.3 | 4.5 | 5 | 6 | 6 | 6.3 | 6.5 |
| ប្រាក់ចំណូលក្នុងម្នាក់ៗ | 261 | 259 | 273 | 284 | 295 | 303 | 313 | 324 |
| GDP (រៀល ១០០លាន តំលៃថេរ) | 12932 | 13357 | 14377 | 15650 | 17087 | 18656 | 20426 | 22406 |
| GDP (US$, M, តំលៃថេរ ) | 3351 | 3404 | 3663 | 3891 | 4111 | 4357 | 4630 | 4933 |
| រៀល/US$, អត្រាផ្តូរការជាមធ្យម | 3859 | 3924 | 3925 | 4022 | 4156 | 4281 | 4409 | 4542 |
| CPI (% កំណើន, Q4/Q4) | 0.5 | -0.5 | 3.0 | 4 | 4 | 4 | 4 | 4 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណូលថវិកា | 11.2 | 11.7 | 12.1 | 12.7 | 13.4 | 13.9 | 14.3 | 14.5 |
| ចំណាយថវិកា | 16.4 | 17.7 | 18.9 | 19.0 | 19.1 | 19.4 | 19.7 | 20.2 |
| ឱនភាពថវិកាចរន្ត | 1.5 | 1.2 | 0.9 | 1.1 | 1.3 | 1.3 | 1.3 | 1.2 |
| ឱនភាពថវិកាសរុប | -5.2 | -6.0 | -6.8 | -6.3 | -5.7 | -5.5 | -5.5 | -5.6 |
| តុល្យភាពនីហរណ (US$, M) | 1,206 | 1,295 | 1,434 | 1,571 | 1,723 | 1,911 | 2,107 | 2,328 |
| តុល្យភាពអាហរណ (US$, M) | -1,664 | -1,777 | -1,880 | -2,041 | -2,242 | -2,462 | -2,705 | -2,977 |
| គណនីចរន្តក្រៅប្រទេស(US$, M) 1/ | (412) | (456) | (391) | (405) | (431) | (470) | (481) | (493) |
| គណនីចរន្តក្រៅប្រទេស/ GDP, US$ | -12.3 | -13.4 | -10.7 | -10.4 | -10.5 | -10.8 | -10.4 | -10.0 |
| មូលនិធិ FX ដុល្លា (US$, M) | 485 | 550 | 642 | 696 | 742 | 810 | 904 | 1011 |
| (មូលនិធិ FX , នាំចូលក្នុងខែ) | 2.8 | 2.9 | 3.3 | 3.3 | 3.2 | 3.2 | 3.3 | 3.4 |

សំគាល់ :១. មិនរាប់បញ្ចូលការបង្វែរផ្លូវការ

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ វិទ្យាស្ថានជាតិស្ថិតិ ធនាគារជាតិកម្ពុជា IMF (តំលៃម៉ាន់ស្មាន)

## គោលនយោបាយរូបិយវត្ថុ សារពើពន្ធ និងក្រៅប្រទេស

ការរីកចំរើនផ្នែករូបិយវត្ថុចាប់ពីឆ្នាំ ១៩៩៩ ដល់ ២០០២ បង្ហាញអោយឃើញនូវស្ថានភាពកាន់តែប្រសើរឡើងក្នុងផ្នែកសារពើពន្ធ។ បេសកម្មសំខាន់បំផុតរបស់ធនាគារជាតិកម្ពុជា (NBC) គឺកំណត់ និងដាក់ទិសគោលនយោបាយសំដៅរក្សាលំនឹងនៃតំលៃដើម្បីសំរួលការអភិវឌ្ឍន៏សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៏សេដ្ឋកិច្ច។ ការអនុវត្តន៏ដោយប្រុងប្រយ័ត្ននូវវិន័យសារពើពន្ធ និងនយោបាយរូបិយវត្ថុបានទទួលជោគជ័យ គឺជាការសំរេច និងធានាលំនឹងម៉ាក្រូសេដ្ឋកិច្ចដោយមានអត្រាអតិផរណាទាប។ ការអនុវត្តន៏នយោបាយ រូបិយវត្ថុនិង កិច្ចការក្រៅប្រទេសបានទទួលលទ្ធផលគួរជាទីគាប់ចិត្ត។

អតិផរណារក្សានៅក៏រិតទាបក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ នេះជាការសំខាន់មួយព្រោះថា អតិផរណាខ្ពស់គឺវាហុចផលអាក្រក់សំរាប់ជនក្រីក្រ។ តំលៃទំនិញកើនឡើង ២,៨ ភាគរយក្នុងរយៈពេល ១២ ខែ ដោយគិតត្រឹមចុងខែ តុលា ឆ្នាំ ២០០២។ តំលៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ដែលមានប្រមាណ ៤២,៦ ភាគរយ នៃចំណាយសរុបសំរាប់គ្រួសារបានកើន ២ ភាគរយ។ ចំណែកឯតំលៃអ្វីៗដ៏ទៃទៀត លើកលែងថ្លៃឈ្នួលផ្ទះចេញ ទឹក ភ្លើង (កើន ៦,៨%) និង ការគាំពារ បានធ្លាក់ចុះក្នុងរយៈពេលដដែល។

អតិផរណារំពឹងថានឹងស្ថិតនៅក្រោម ៣ ភាគរយ និងអត្រាប្តូរប្រាក់នឹងរក្សានៅដដែល។ បញ្ហាប្រឈមមុខសំរាប់នយោបាយសារពើពន្ធជាទូទៅរួមមានតំរូវការបង្កើនចំណូលក្នុងស្រុក លើកស្ទួយការគ្រប់គ្រងថវិកា និងជំរុញអភិបាលកិច្ច។ ការបង្កើនចំណូលមានសារៈសំខាន់ក្នុងការផ្តល់ហិរញ្ញវត្ថុដល់ការប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ (សូមអានជំពូកទី៥)។ សន្ទុះនៃការអភិវឌ្ឍន៏សេដ្ឋកិច្ចបែបនេះមានសារៈសំខាន់សំរាប់ការកាត់បន្ថយភាពក្រីក្រ។

តំលៃរូបិយវត្ថុក្នុងស្រុកមានលំនឹងជាទូទៅចាប់តាំងពីឆ្នាំ ១៩៩៩។ ភាពមានអត្រាអតិផរណាទាប ព្រមជាមួយការប្រើប្រាស់ប្រាក់ដុល្លារខ្ពស់នៅលើទីផ្សារ និងទីផ្សារប្តូរប្រាក់តូចៗនៅក្នុងប្រទេសបានជួយរក្សាលំនឹងតំលៃប្រាក់រៀល ក្នុងខណៈដែល

នយោបាយគ្រប់គ្រងអត្រាប្តូរប្រាក់អណ្តែតជួយទ្រទ្រង់ដល់ការប្រឹងប្រែងរបស់ NBC ដើម្បីបង្កើនទុនបំរុងអន្តរជាតិ។ ទៅអនាគត នយោបាយដែលកំពុងបានអនុវត្តន៍នេះនឹងត្រូវរក្សាទុកដដែល។

កម្ពុជាមានតុល្យភាពជញ្ជីងទូទាត់សរុបលើសពីតម្រូវការចំនួន ២០ លានដុល្លារនៅឆ្នាំ ២០០១។ ជាលទ្ធផលទុនបំរុងដុលក្រៅប្រទេសបានកើនឡើងដល់កំរិតគ្រប់គ្រាន់ល្មមក្នុងការផ្តល់ហិរញ្ញប្បទានប្រមាណ ២,៩ ខែនៃការនាំចូលសរុប។ ឱនភាពគណនីចរន្តសំរាប់ឆ្នាំ ២០០១ លើកលែងប្រាក់បង្វែរចេញបានកើនពី -១២,៣ ភាគរយ នៃ ផសស ទៅ -១៣,៤ នៃ ផសស ស្មើនឹង ៤៥៦ លានដុល្លា។

ប្រាក់បង្វែរផ្លូវការ (ក្រៅប្រទេស) ដែលបានទទួលក្នុងឆ្នាំ ២០០១ បានប៉ាន់ស្មានប្រមាណចំនួន ២៧៦ លានដុល្លារ គឺមានការកើនលើស ២,៩ ភាគរយបើប្រៀបធៀបនឹងឆ្នាំ ២០០០។ លំហូរវិនិយោគពីក្រៅប្រទេសបានប៉ាន់ស្មានមានប្រមាណចំនួន ៩៥ លានដុល្លារ មូលហេតុដោយមានការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកដែលបាន កើតមានតាំងពីមុនព្រឹត្តការណ៍ ថ្ងៃទី ១១ ខែកញ្ញា ។ ផ្អែកលើការប៉ាន់ស្មានទុកជាមុន និងរួមទាំងការអនុវត្តន៍នូវវិធានការណ៍ទាំងប៉ុន្មានខាងលើ ដើម្បីជំរុញបរិយាកាសវិនិយោគ ការវិនិយោគពីក្រៅប្រទេសរំពឹងថានិងកើនឡើងប្រហែលពី ១២០ ទៅ ១៥០ លានដុល្លារ។ មូលធនធនាគារបានកើន ២៧ លានដុល្លារ គឺជាការបង្ហាញនូវការប្រឹងប្រែងរបស់ផ្នែកធនាគារ ក្នុងការអនុវត្តន៍តាមដែលមានចែងក្នុងច្បាប់ធនាគារ ថ្មីដែលទាមទារអោយមូលនិធិតម្រូវការអតិបរមាមានចំនួនខ្ពស់។

## ប្រអប់ទី ៧: ការវិភាគស្ថេរភាពបំណុល

បច្ចុប្បន្នកាល វាមានការលំបាកក្នុងការកំណត់បំណុលជាក់ស្តែងដែលកម្ពុជាជំពាក់ប្រទេសដ៏ទៃ ដូចដែលអាជ្ញាធរកម្ពុជា ដឹកនាំការពិភាក្សាជាមួយសហព័ន្ធសូវៀត និងសហរដ្ឋអាមេរិក ដើម្បីរៀបចំកាលពេលវេលាជាថ្មីនៃកាតព្វកិច្ចហិរញ្ញប្បទានមុនឆ្នាំ ១៩៩៣ ។ បច្ចេកទេសនៃការពិភាក្សាគឺបានពិនិត្យឡើងវិញនូវបញ្ហាបំណុលពុំទាន់សង ។ ថ្មីៗនេះរដ្ឋាភិបាលបានសើរើរឯកសារបំណុលពីសហរដ្ឋអាមេរិកដើម្បីធ្វើការកំណត់បរិមាណបំណុលជាក់ស្តែង ដែលអាមេរិកពុំមានចុះកិច្ចសន្យាបំណុលណាមួយជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងកំឡុងពេលសង្គ្រាមឆ្នាំ ១៩៧០ ដល់ ១៩៧៥ ឡើយ ។

នៅទសវត្សឆ្នាំ ១៩៨០ សហភាពសូវៀតបានផ្តល់ជំនួយឥតសំណងដល់ប្រទេសកម្ពុជា ដើម្បីស្តារប្រទេសដែលរងទុក្ខដោយសង្គ្រាម និងរបបប្រល័យពូជសាសន៍ ។ សហព័ន្ធសូវៀតបានចូលជាសមាជិក ប៉ារីសក្លិប Paris Club ជាឥណទាយក ។ ប្រទេសដែលបានចូលជាសមាជិក និងនឹងចូលជាសមាជិកនៃ Paris Club នឹងទទួលបានសម្បទានបញ្ចុះតំលៃដល់ទៅ ៧០% ពី Paris Club ឥណទាយក ចំពោះប្រទេសដែលជំពាក់បំណុលសូវៀតកាលពីមុនឆ្នាំ ១៩៩២ ពេលដែលគេពុំទាន់បានចូលជាសមាជិក Paris Club ។

បរិមាណទឹកប្រាក់ដែលជំពាក់បន្ទាប់ពីការបញ្ចុះតំលៃ គឺត្រូវបានកំណត់ជារូបិយវត្ថុមួយដែលមានការឯកភាពគ្នា និងត្រូវបានកំណត់ជាបំណុលពាណិជ្ជកម្ម (មិនមែនជាសម្បទាន) តាមការលើកឡើងរបស់ Paris Club ។ ចំនួនទឹកប្រាក់ដែលនៅសល់បន្ទាប់ពីអត្រាប្តូរប្រាក់កំរិតទាប ត្រូវបានប្រទេសសូវៀតដាក់បញ្ចូលទៅក្នុង Nepale Term ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀង Paris Club ចំពោះប្រទេសស្ទើរតែទាំងអស់ មានទាំងប្រទេសដែលមិនក្រីក្របំផុតផងដែរ ។ បរិមាណទឹកប្រាក់ដែលនៅសល់ នឹងធ្វើការពិភាក្សាជាថ្មីដើម្បីៈ (១) កំណត់ពេលវេលាឡើងវិញ, (២) ធ្វើការផ្លាស់ប្តូរបំណុល (អត្រាកាប្រាក់, រយៈពេលបន្ថែម និងការសងបំណុល) ។

ទោះបីជាបរិមាណបំណុលមានភាពធូរស្រាលជាមួយប្រទេសសូវៀត តែបន្ទុកនៃសារពើពន្ធបំណុលគឺវាមានលក្ខណៈធ្ងន់ធ្ងរ (បន្ថយនូវអត្រាចំណូលដល់ ផសស) ជាមួយបរិមាណបំណុលលើសពី ១៥% ទៅ ២០% នៃប្រាក់ចំណូលសំរាប់រយៈពេល ១០ ឆ្នាំទៀត ។ ការរៀបចំពេលវេលាជាថ្មីដែលមានកំរិតទាបជាងគឺវាមានកំរិតនៃការគ្រប់គ្រងប្រសើរជាង ។

តាមការវិភាគដែលមានភាពជាក់ស្តែងវាបង្ហាញថា វិស័យក្រៅប្រទេសរបស់កម្ពុជា គឺវានឹងបន្តភាពងាយរងគ្រោះដល់ប្រទេស និងទាមទានូវការកែទំរង់គោលនយោបាយអោយមានភាពប្រសើរឡើង ។ កំណែទំរង់គោលនយោបាយអោយមានលក្ខណៈប្រសើរឡើង វាជាកត្តាចំបងដែលបន្ថយនូវបណ្តាសកម្មភាពសេដ្ឋកិច្ចពិភពលោក និងពន្យារនូវការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក, បន្ថយល្បឿនការនាំចេញ រីធ្វើអោយមានភាពធ្ងន់ធ្ងរលើវិស័យសេដ្ឋកិច្ច និងការជួយជ្រោមជ្រែងពីប្រទេសផ្តល់ជំនួយ និងសក្តានុពលនៃការហូរចូលវិនិយោគពីក្រៅប្រទេស ។ ម្យ៉ាងវិញទៀត បំណុលបន្ថែមវាមានឥទ្ធិពលអាក្រក់ទៅលើថវិកាជាតិ និងទិសដៅកាត់បន្ថយភាពក្រីក្រ ។ ជាលទ្ធផល បានបង្ហាញថាត្រូវមានការប្រុងប្រយ័ត្នចំពោះគោលនយោបាយគ្រប់គ្រងបំណុលបរទេស និងភាពប្រាកដនិយមជៀសវាងហិរញ្ញវត្ថុពុំមែនសម្បទាន ។

ដើម្បីទទួលបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងកំណើនសេដ្ឋកិច្ច ពី ៦-៧% ដូចពេលចាប់ផ្តើមពីដំបូង គឺតំរូវអោយមានការអនុវត្តន៏កម្មវិធីកំណែទំរង់ និងបណ្តាគោលនយោបាយគាំទ្រជាក់ច្បាស់។ នេះមានទាំងការមិនគ្រប់គ្រងរូបិយវត្ថុនៃឱនុភាពសារពើពន្ធ, ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ, ធ្វើការកែទរង់កិច្ចការធនាគារ, ការបង្កើនប្រាក់ចំណូល, បង្កើនការចំណាយទៅលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច, ការគ្រប់គ្រងថវិកា និងរតនាគារ, បង្កើនការវិនិយោគ, កែទំរង់មន្ត្រីរាជការស៊ីវិល និងធ្វើកំណែទំរង់ច្បាប់ និងតុលាការ ។

ការពង្រឹងគោលនយោបាយពន្ធ និងរដ្ឋបាលគឺដើម្បីៈ (១) បង្កើនចំណូលពន្ធ (២) កែលំអប្រព័ន្ធពន្ធដារ (៣) ពង្រឹងសមត្ថភាពក្នុងការវិភាគពន្ធ (៤) កែលំអរដ្ឋបាលអោយនៃរបបការងារជាក់ស្តែង (៥) កែលំអរដ្ឋបាលនៃការព្យាករណ៏ និង (៦) បង្កើនការបណ្តុះបណ្តាល និងសិក្សាការងាររដ្ឋបាលពន្ធ ។

ជាងនេះទៀត ការយកចិត្តទុកដាក់ពង្រឹងរដ្ឋបាលពន្ធគយគឺដើម្បីៈ (១)ទទួលបានចំណូលអតិបរមាពីប្រតិបត្តិការត្រួតពិនិត្យការដឹកជញ្ជូន (២)ពង្រឹងរដ្ឋបាលពន្ធគយទូទៅ (ច្បាប់ និងបទបញ្ជា, សមត្ថភាពយកពន្ធ, មានបែបបទទំនើប និងងាយស្រួល និងមានសំភារៈ ធនធានមនុស្ស អង្គភាពពិតប្រាកដ) និង (៣) ប្រតិបត្តិការនៃការគណនាពន្ធគយ ។

ការពង្រឹងការគ្រប់គ្រងថវិកាជាការងារយ៉ាងសំខាន់ដើម្បីសំរេចបានៈ (១) ភាពងាយស្រួល និងទំនើបនៃរចនាសម្ព័ន្ធនិងការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២) បង្កើនគុណភាពការងារថវិកា និងការអនុវត្តន៏ (៣) ភាពទំនើបការប្រតិបត្តិថវិកា (៤)បង្កើត និងអនុវត្តន៏ការងារសវនកម្មអោយមានប្រសិទ្ធភាពទាំងផ្ទៃក្នុង និងក្រៅ (៥) ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៦) ពង្រឹងថវិកាវិមជ្ឈការ និងការផ្តល់ថវិកាដល់វិស័យសុខាភិបាល ។

រាជរដ្ឋាភិបាល យល់ឃើញថាកិច្ចការស្ថាប័នគឺជាគន្លឹះនៃការអភិវឌ្ឍន៏ ដូច្នេះដើម្បីធ្វើសនិទានកម្មលើមន្ត្រីរាជការស៊ីវិល រដ្ឋាភិបាលកំពុងដំណើរការជំរឿន និងពិនិត្យការងារនៅគ្រប់ក្រសួងទាំងអស់ និងបើកប្រាក់បៀវត្សតាមប្រព័ន្ធកុំព្យូទ័រ អោយមានភាពងាយស្រួលក្នុងការត្រួតពិនិត្យថវិកា ។ ជាមួយនោះដែរ រដ្ឋាភិបាលបានបង្កើតប្រព័ន្ធបែងចែកកំរិតការងារថ្មី ដែលមាន៤ លំដាប់ថ្នាក់ដោយផ្អែកលើមូលដ្ឋានកំរិតនៃការសិក្សា និង "កំរិតថ្នាក់ពិសេស " សំរាប់ឧត្តមមន្ត្រី ។ ប្រព័ន្ធទូទាត់ថ្មីរួមមាន បៀវត្សមូលដ្ឋាន ជាមួយនិងសមាមាត្រ ៤,៥ និង ៥ប្រភេទនៃប្រាក់កំរៃ សំរាប់ការងារស្មុគស្មាញ, កំរិតនៃការទទួលខុសត្រូវ និងភាពលំបាក ។ ប្រព័ន្ធនេះ គឺបង្កើតឡើងដើម្បីបន្សីប្រាក់ឈ្នួលជាមធ្យមទៅនឹងកំរិតអប្បរមានៃប្រាក់ឈ្នួលរបស់ផ្នែកឯកជន ៤៥ ដុល្លាអាមេរិកនោះ ហើយប្រព័ន្ធនេះ គឺដើម្បីលើកកំពស់សមត្ថភាពដល់មន្ត្រីបច្ចេកទេស និងមន្ត្រីគ្រប់គ្រង ។ ចុងក្រោយនេះ

រដ្ឋាភិបាលមានផែនការធ្វើការវិភាគការងារចាំបាច់ ដើម្បីលើកជាជំរើសសំរាប់ប្រាក់បៀវត្ស និងកំណែទំរង់មន្ត្រីរាជការ ដោយប្រើយន្តការគាំទ្រពីម្ចាស់ជំនួយ និងសនិទានកម្មបៀវត្សបន្ថែម ។

កំណែទម្រង់ច្បាប់និងតុលាការ ត្រូវបានរំពឹងថានឹងមានផលប៉ះពាល់វិជ្ជមានទៅលើការកាត់បន្ថយភាពក្រីក្រនៅពេលដែលកំណែទម្រង់នេះ នឹងផ្តល់នូវការការពារតាមផ្លូវច្បាប់ដល់អ្នកក្រីក្រ ក៏ដូចជានឹងទាក់ទាញការវិនិយោគ ទុនជាច្រើនថែមទៀតមកកម្ពុជា។ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងតុលាការ ត្រូវបានបង្កើតឡើងដើម្បីដឹកនាំ និងគ្រប់គ្រងកម្មវិធីកែទម្រង់ ហើយក្រុមប្រឹក្សានេះត្រូវបានទ្រទ្រង់ដោយរចនាសម្ព័ន្ធអចិន្ត្រៃយ៍ ដែលដើរតួនាទី ជាយន្តការនៃការអនុវត្តន៍។ ចាប់តាំងពីឆ្នាំ១៩៩៣មក ចំនួនច្បាប់ដែលបានអនុម័តរួចហើយសរុបទំាងអស់មាន ១៩៤។ សេចក្តីព្រាងច្បាប់ចំនួន២៣ផ្សេងទៀតកំពុងរង់ចាំការអនុម័តពីសភាជាតិ។ ការយកចិត្តទុកដាក់ ក៏ត្រូវបានតម្រង់ទិសទៅរកច្បាប់សេដ្ឋកិច្ចនិងច្បាប់វិនិយោគផងដែរ ជាពិសេសទៅរកច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធនឹងសមាជិកភាពរបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ ទន្ទឹមនឹងនេះធនធានមនុស្សគឺជាកត្តាគន្លឹះនៅក្នុងការខិតខំប្រឹងរបស់យើងដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធតុលាការ។ ដើម្បីកែលំអការអនុវត្តន៍ការងាររបស់សាលាជំនុំជម្រះក្តី តុលាការពាណិជ្ជកម្មនិងតុលាការរដ្ឋបាលមួយនឹងត្រូវបង្កើតឡើង។ លើសពីនេះទៀត តុលាការគំរូមួយនឹងត្រូវដាក់ឱ្យអនុវត្តសាកល្បង ដើម្បីជម្រុញឱ្យមានភាពសុចរិតភាពមិនលម្អៀង និងមនសិការវិជ្ជាជីវៈនៃចៅក្រម។

ការចាប់ផ្តើមនូវក្របខ័ណ្ឌចំណាយរយៈពេលមធ្យម នឹងអាចផ្តល់នូវការធានាឱ្យមានភាពជាក់លាក់នៅក្នុងការចំណាយសម្រាប់វិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច ដែលជាកម្លាំងជម្រុញឱ្យមានកំណើន។ តារាងទី៤ បង្ហាញដោយសង្ខេបអំពីនិន្នាការវិវត្តថ្មីៗនិងកម្រិតដែលរំពឹងទុកជាមុននៃការចំណាយនិងចំណូលសាធារណៈគិតជាភាគរយនៃ ផសស ដូចដែលបានលើកឡើងនៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។ គោលដៅសារពើពន្ធទាំងនេះ អាចសម្រេចបានតែក្នុងករណីដែលមានការអនុវត្តន៍កម្មវិធីកំណែទម្រង់ដូចបានរៀបរាប់ពីខាងដើម។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវបានរៀបចំឡើងដើម្បីកែលំអស្ថានភាពសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា និងលើកកំពស់ការបែងចែកថវិកាឱ្យមានលក្ខណៈទ្រទ្រង់អ្នកក្រីក្រ។ ឱនភាពថវិកាសរុបនឹងថយចុះពី-៦.៨ភាគរយ នៃផសសនៅក្នុងឆ្នាំ២០០២ ដល់ ៥.៥ភាគរយ នៅក្នុងឆ្នាំ២០០៥។ កាចំណាយត្រូវបានរំពឹងថានឹងមានការកើនឡើងបន្តិចបន្តួច។ ផ្អែកលើការលំបាកផ្នែកថវិកា និងការកើនឡើងនៃតម្រូវការសម្រាប់សេវាសង្គមកិច្ច ដោយសារមានប្រជាជនមួយដែលមានវ័យក្មេងនិងកំពុងកើនឡើងយ៉ាងឆាប់រហ័ស រាជរដ្ឋាភិបាលកំពុងប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកលើបញ្ហាថាតើត្រូវបែងចែកនូវធនធានសាធារណៈឱ្យបានល្អប្រសើរតាមរបៀបណា។ ផ្អែកលើភាពស៊ីសង្វាក់គ្នានៃការងារអាទិភាពដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គោលបំណងនៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលបានស្នើឡើងគឺបែងចែកធនធានបន្ថែមទៀត ទៅដល់បណ្តាវិស័យអាទិភាព ដូចជាអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ។

ពន្ធដារដែលគិតជាភាគរយនៃផសស ត្រូវបានរំពឹងថានឹងកើនឡើងពី៨.៥ភាគរយនៅក្នុងឆ្នាំ២០០២ ដល់ ៨.៨ ភាគរយនាឆ្នាំ២០០៥ នៅពេលដែលការប្រឹងប្រែងរកចំណូលមិនមែនពន្ធដារ នឹងសម្រេចបានប្រមាណតែ៣.៥ ភាគរយពីចន្លោះឆ្នាំ២០០២ ដល់ ២០០៥។ ចំណូលសារពើពន្ធសរុបគិតជាភាគរយនៃផសស នឹងកើនឡើងបន្តិចម្តងៗ ទោះបីកើនឡើងយឺត ពី១២.១ភាគរយនៅក្នុងឆ្នាំ២០០២ ដល់ ១៣.៩ភាគរយនៅក្នុងឆ្នាំ២០០៥។ តាមការសន្និដ្ឋាន ការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងចំណូលសារ

ពើពន្ធគិតជាតម្លៃដាច់ខាត នឹងធ្វើឱ្យសម្រេចបានតាមរយៈកំណើនខ្ពស់និងមានចិរភាពនៃសេដ្ឋកិច្ចកម្ពុជា និងតាមរយៈការអនុវត្តន៍វិធានការកែទម្រង់ជាជាងតាមរយៈការកែលំអដ៏គួរកត់សម្គាល់មួយនៅក្នុងការប្រឹងប្រែងរកចំណូល ។

### តារាង ៤.៣: កម្ពុជា: ផែនការសារពើពន្ធរយៈពេលមធ្យម ២០០៣-២០០៥

(%នៃផសស. ១៩៩៩-២០០១ គឺជាទិន្នន័យជាក់ស្តែង. ២០០២-២០០៥ គឺជាទិន្នន័យដែលគ្រោងទុក)

| | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|---|---|
| ចំណូលសារពើពន្ធ | ១០.៦ | ១១.២ | ១១.៧ | ១២.១ | ១២.៧ | ១៣.៤ | ១៣.៩ |
| ក្នុងនោះ : ចំណូលពន្ធដារ | ៧.៧ | ៨.២ | ៨.៤ | ៨.៥ | ៨.៥ | ៨.៧ | ៨.៨ |
| ចំណូលមិនមែនពន្ធដារ | ២.៨ | ២.៨ | ៣.២ | ៣.៥ | ៣.៦ | ៣.៦ | ៣.៤ |
| ចំណាយសរុប | ១៤.៧ | ១៦.៤ | ១៧.៧ | ១៨.៩ | ១៩.០ | ១៩.១ | ១៩.៤ |
| ចំណាយចរន្ត | ៨.៩ | ៩.៥ | ១០.៤ | ១១.១ | ១១.៤ | ១១.៩ | ១២.២ |
| ចំណាយមូលធន | ៥.៨ | ៦.៩ | ៧.៣ | ៧.៨ | ៧.៣ | ៧.២ | ៧.១ |
| អតិរេកចរន្ត | ១.៦ | ១.៥ | ១.២ | ០.៩ | ១.១ | ១.៣ | ១.៣ |
| អតិរេកសរុប/(ឱនភាព) | -៤.០ | -៥.២ | -៦.០ | -៦.៨ | -៦.៣ | -៥.៧ | -៥.៥ |

គិតជាភាគរយនៃផសស ចំណាយសរុបត្រូវបានរំពឹងទុកថានឹងកើនឡើងយ៉ាងសមស្រប ពី ១៨.៩ ភាគរយនៅក្នុងឆ្នាំ២០០២ ដល់ ១៩.៤ភាគរយនៅក្នុងឆ្នាំ ២០០៥ ។ កម្រិតដែលបានគ្រោងទុកនចំណាយនៃចំណាយមូលធន បង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ។ ចំណាយមូលធននឹងស្រូបយកសមាមាត្រប្រមាណ ៧.១ ទៅ ៧.៨ភាគរយ នៅក្នុងកំឡុងពេល៣ឆ្នាំ ។ ទាំងនេះគឺជាការយកចិត្តទុកដាក់គួរឱ្យកត់សម្គាល់ទៅលើការកំណត់កម្រិតអតិបរមានៃថវិកាសរុបឱ្យនៅទាប ។ ចំណាយមូលធនគិតជាភាគរយនៃ ផសស មានកម្រិតតិចជាងឆ្នាំ២០០១ និង ២០០២ បន្តិចដែលជាបណ្តាឆ្នាំនៃការកសាងឡើងវិញបន្ទាប់ទឹកជំនន់នៅក្នុងឆ្នាំ២០០០ និង២០០២ ប៉ុន្តែមានកម្រិតខ្ពស់ជាងនៅក្នុងបណ្តាឆ្នាំធម្មតា ។ ប្រសិនការចំណាយមានការប្រុងប្រយ័ត្នទៅលើគំរោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងដោយមានការប្រើពេលដ៏ខ្លី នោះវានឹងទទួលបាននូវកំណើនសេដ្ឋកិច្ចយ៉ាងលឿននៅប្រទេសកម្ពុជា ។

កិច្ចប្រជុំស្តីពីការងារចំណូល វានឹងតំរូវអោយមានការអនុវត្តន៍ការវាស់វែងសារពើពន្ធ និងការកែលំអអភិបាលកិច្ច ដែលយើងធ្វើការពិភាក្សានៅក្នុងផ្នែកទី៥ ។ ការវាស់វែងចំណូលទាំងនេះ មានទាំងដាក់បញ្ចូលនូវការពង្រីកបន្ថែមពន្ធលើតំលៃបន្ថែម VAT. បង្កើនការប្រមូលពន្ធ ដូចជា ពន្ធអាករ. ពន្ធលើប្រាក់ចំណេញ. ពន្ធលើបៀវត្ស និងពន្ធលើការនាំចូល និងធ្វើការពង្រឹងរចនាសម្ព័ន្ធពន្ធ និងរដ្ឋបាលគយរដ្ឋាករ ។ រដ្ឋបាលពន្ធអាចធ្វើ ទៅបានដោយតាមរយៈការពង្រឹងសមត្ថភាពត្រួតពិនិត្យពន្ធ និងកែលំអការរៀបចំស្ថាប័ន ដូចជាបង្កើនការងារនៃ អង្គភាពបង់ពន្ធធំ (LTU) ។

ការកែទំរង់ពន្ធគយ និងមានភាពទំនើប គឺជាតំរូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រមូលចំណូល និងរក្សាដែនកំណត់របស់វា ហើយទាំងអស់នេះវាក៏ជាតំរូវការរបស់ផ្នែកឯកជនផងដែរសំរាប់ការរីកចំរើន និងមានភាពងាយស្រួលដល់ពាណិជ្ជកម្ម

អន្តរជាតិ ។ រដ្ឋធម្មនុញ្ញដើម្បីប្រយុទ្ធប្រឆាំងនឹងការគេចពន្ធ គឺជាអាទិភាពខ្ពស់ របស់រដ្ឋាភិបាលក្នុងការបង្កើនការប្រមូលចំណូល ។ សកម្មភាពអនុវត្តន៏ នឹងធ្វើការចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធពត៌មានវិទ្យាសំរាប់ពន្ធគយ និងនាយកដ្ឋានរដ្ឋាករ ដើម្បីកែលំអប្រកបដោយប្រសិទ្ធភាព ។

យើងនឹងលើកយកកត្តាពីរដើម្បីដាក់បញ្ចូលទៅក្នុងរយៈពេលចំណាយរបស់ យជកភ ។ ការបង្កើនការចំណាយលើសេវាកម្មបៀវត្សស៊ីវិល និងការពារជាតិ/សន្តិសុខសង្គម នឹងស្រូបយកសមាមាត្រយ៉ាងច្រើននៃតំលៃបច្ចុប្បន្នរបស់បណ្តាក្រសួងដ៏ទៃ ។ ការបង្កើនប្រាក់បៀវត្ស វានឹងលើកទឹកចិត្តសេវាកម្មសាធារណៈក្នុងការបង្កើនសេវាសាធារណៈនៅតំបន់ជនបទដែលប្រជាជនក្រីក្ររស់នៅច្រើន ។ ផ្ទុយទៅវិញវានឹងមានការប៉ះពាល់ខ្លះដល់ការចំណាយ ។

ដូចកាលពីចាប់ផ្តើមដំបូងក្នុងការវិភាគបំណុល គឺចំណុលសំខាន់នៃបំណុលវាមានភាពធ្ងន់ធ្ងរណាស់ ដែលបរិមាណបំណុលលើសពី ១៥ ដល់ទៅ ២០% នៃចំណូលក្នុងរយៈពេល១០ឆ្នាំខាងមុខ ។ បំណុលបន្ថែមនឹង មានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ថវិកាជាតិ និងគោលដៅកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះរដ្ឋាភិបាលគួរយកចិត្តទុកដាក់អោយបានខ្លាំង និងប្រុងប្រយ័ត្នដល់ការគ្រប់គ្រងគោលនយោបាយបំណុលក្រៅប្រទេស និងមានភាពហ្មត់ចត់ ដើម្បីជៀសវាងការផ្តល់ហិរញ្ញប្បទានពុំមែនសម្បទាន ។

## ការរួមចំណែកនៃផ្នែកហិរញ្ញវត្ថុចំពោះកំណើនសេដ្ឋកិច្ច

ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងសមរម្យ គឺមានសារៈសំខាន់សំរាប់សំរេចនូវកំនើនសេដ្ឋកិច្ច និងគោលដៅសេដ្ឋកិច្ចសង្គមរួមទាំងការកាត់បន្ថយភាពក្រីក្រ ។ ប្រព័ន្ធហិរញ្ញវត្ថុដែលមានមុខនាទីល្អ គឺជាគន្លឹះជួយធានាដល់លំនឹងម៉ាក្រូសេដ្ឋកិច្ច ការប្រមូលប្រាក់សច្ច័យ ការបែងចែកធនធានសំរាប់ជំរុញការអភិវឌ្ឍន៏ផ្នែកឯកជន និងឱកាសបង្កើតការងារធ្វើ និងកាត់បន្ថយភាពក្រីក្រ។ ប្រព័ន្ធហិរញ្ញវត្ថុជនបទប្រកបដោយប្រសិទ្ធភាពដែលការពារជនក្រីក្រ មានសារៈសំខាន់សំរាប់ ការផ្តល់សេវាហិរញ្ញវត្ថុដែលអាចអោយជនក្រីក្របង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រដែលចំនុចទាំងនេះនឹងលើកយកមកបរិយាយនៅក្នុងផ្នែក ៤.២.៥ ។ ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយតំលាភាព គឺមានសារៈសំខាន់ផងដែរសំរាប់ទាក់ទាញកំណើន សេដ្ឋកិច្ចនៅកម្ពុជា។ រាជរដ្ឋាភិបាលបានទទួលស្គាល់ថាការកែទំរង់ធនាគានាអនាគត គឺក្នុងគោលបំណងការពារដល់ជនក្រីក្រ។

បច្ចុប្បន្ននេះ មានការជួបការលំបាកជាច្រើនដល់ផ្នែកហិរញ្ញវត្ថុក្នុងការបំពេញតួនាទីរបស់ខ្លួន ក្នុងនោះគឺ ក្របខ័ណ្ឌច្បាប់នៅខ្វះចន្លោះ ខ្វះខាតបុគ្គលិកជំនាញ ប្រាក់ចំណូលទាប និងបរិដ្ឋានប្រកបដោយហានីរភ័យខ្ពស់។

រាជរដ្ឋាភិបាលមានការបារម្ភណ៏ថា ការចរាចរប្រាក់ដុល្លារខ្ពស់នៅលើទីផ្សារ វាបានក៏រិតនូវលទ្ធភាពរបស់ធនាគារជាតិក្នុងការអនុវត្តន៏ឧបករណ៏នយោបាយរូបិយវត្ថុតាមបែបចាស់អោយមានប្រសិទ្ធភាព។ ការត្រួតពិនិត្យលើសាច់ប្រាក់របស់ធនាគារនៅមានក៏រិត។ ធនាគារពាណិជ្ជកម្មមិនបានប្រើប្រាស់នូវកិច្ចការផ្នែកហិរញ្ញប្បទានឡើងវិញ និងការចុះតំលៃជាថ្មីនៅឡើយ។ ការផ្តល់រូបិយវត្ថុ គឺស្ថិតនៅលើការសំរេចចិត្តនៃឥរិយាបទរបស់អ្នកកាន់កាប់ទ្រព្យសម្បត្តិ (រួមទាំងសាច់ប្រាក់ផង) ដែលប្រើឈ្មោះជនបរទេស។ ការប្រើប្រាស់ឧបករណ៏នយោបាយរូបិយវត្ថុប្រយោល ដូចជាការត្រួតពិនិត្យសាច់ប្រាក់ និងតំរូវការមូលនិធិបំរុងនៅមានក៏រិត។ លើសពីនេះទៀតដោយហេតុថា NBC មិនផ្តល់ហិរញ្ញប្បទានឡើងវិញដល់បណ្តាធនាគារដ៏ទៃទៀតនោះ NBC ពុំមានតួនាទីប្រើប្រាស់អត្រាកាប្រាក់អោយមានប្រសិទ្ធភាពសំរាប់គោលដៅនយោបាយ។ ការប្រកាសបំណុលលើរាជរដ្ឋាភិបាល

ត្រូវបានគេប្រើសំរាប់ជាសូចនាករចង្អុលបង្ហាញពីលំនឹងរូបិយវត្ថុ ព្រោះការប្រកាសនេះបង្ហាញពីស្ថានភាពរបស់ធនាគារកណ្តាលក្នុងការផ្តល់ហិរញ្ញប្បទាននៃឱនភាពថវិកា។ ក្នុងកាលៈទេសៈនេះ ក្រសួងសេដ្ឋកិច្ចបានអនុមតិគោលនយោបាយសំរាប់ការជៀសវាងអោយធនាគារផ្តល់ហិរញ្ញប្បទានឱនភាពថវិកាដែលអាចជះឥទ្ធិពលភ្លាមៗលើអត្រាប្តូរប្រាក់ថ្លៃ និងអតិផរណា។ អតិផរណាមានបច្ច័យជាវិសមាមាត្រលើអ្នកក្រីក្រ និងធ្វើអោយពួកគេស្ថិតក្នុងស្ថានភាពលំបាកឡើង។

ការខំប្រឹងប្រែងរបស់ធនាគារដើម្បីពង្រឹងផ្នែកធនាគារ នឹងចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈយន្តការដូចខាងក្រោម និងដូចដែលបានដាក់ចេញនៅក្នុងផែនការផ្នែកហិរញ្ញវត្ថុ:

សំរាលភាពមិនទៀងទាត់ និងហានីភ័យដែលបណ្តាលមកពីខ្វះហេដ្ឋារចនាសម្ព័ន្ធខាងផ្លូវច្បាប់ និងហិរញ្ញវត្ថុ ដើម្បីបង្កើនឥណទានទំនេរ។ ដោយហេតុថាធនាគារមានបំណងផ្តល់ឥណទានកម្ចី នោះចលនទ្រព្យដែលលើសហួសពីសេចក្តីត្រូវការនៃធនាគារនឹងត្រូវថយចុះ រីឯអន្តរការីកម្មធនាគារនឹងត្រូវបានលើកស្ទួយ។ ជាលទ្ធផលមូលនិធិលើសរបស់ធនាគារ នឹងផ្ទេរទៅផ្នែកដែលខ្វះទុនដើម្បីធ្វើការខ្ចីសំរាប់វិនិយោគ។

ការកាត់បន្ថយចំណាយជាប្រចាំរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ នឹងឈានទៅធ្វើអោយសេវាកម្មធនាគារចុះថោកសំរាប់សេដ្ឋកិច្ច។ ដោយមានអត្រាការប្រាក់អោយខ្ចីទាប ប្រជាជននៅតាមជនបទមួយចំនួនធំអាចខ្ចីប្រាក់ពីធនាគារ។

លើកកំពស់ជំនឿទុកចិត្តជាសាធារណៈចំពោះប្រព័ន្ធធនាគារតាមរយៈ កម្មវិធីប្រកួតប្រជែង កែទំរង់ដែលមានជោគជ័យពង្រឹងការគោរពបទបញ្ញត្តិប្រុងប្រយ័ត្នសមត្ថភាពគ្រប់គ្រងលើប្រព័ន្ធទូទាត់ជាដើម។ អាស្រ័យដោយមូលនិធិដែលអាចរកបានច្រើនសំរាប់អោយខ្ចី និងអត្រាអោយខ្ចីទាប ធនាគារអាចបង្កើនការប្រមែប្រមូលទុនច្រើន។

អភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងតម្លាភាពរួមជាមួយ មធ្យោបាយដែលគួរអោយទុកចិត្តបានសំរាប់ដំណើរការកិច្ចការហិរញ្ញវត្ថុ ដើម្បីសំរួលវិនិយោគពីក្រៅប្រទេស និងក្នុងស្រុកដែលជាកំលាំងជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងប្រព័ន្ធគណនេយ្យដែលធានាដោយច្បាប់កិច្ចការហិរញ្ញវត្ថុ និងពាណិជ្ជកម្ម និងគាំទ្រអភិបាលកិច្ចល្អ ដោយជំរុញតម្លាភាពនៃការទទួលខុសត្រូវ ការព្យាករណ៍ (សូមអានផ្នែក ៤-៤) ។
បណ្តាគោលនយោបាយ និងផែនការសកម្មភាពជំរុញមីក្រូហិរញ្ញវត្ថុមានបរិយាយក្នុងផ្នែក ៤-២-៥ ខាងក្រោម។

## ៤.១.២ ការកែលំអជីវភាពរស់នៅតាមជនបទ

ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចមានស្ថេរភាព និងគោលនយោបាយផ្នែកហិរញ្ញវត្ថុគួរជាទីសង្ឃឹមគឺមានសារៈសំខាន់ណាស់ ក៏ប៉ុន្តែនេះមិនធានាដល់ការធ្វើអោយប្រសើរឡើងនូវក្នុងការរស់នៅតាមតំបន់ជនបទដែលជាកន្លែង ដែលប្រជាជនក្រីក្រកម្ពុជាភាគច្រើនរស់នៅនោះទេ។ ដូចបានបង្ហាញក្នុងជំពូកទី៣ មានប្រភេទ និងឫសគល់ជាច្រើននាំអោយមានភាពក្រីក្រនៅទីជនបទ។ សំរាប់ហេតុផលគោលនយោបាយ និងកម្មវិធីមួយដែលចាំបាច់សំរាប់ដោះស្រាយភាពក្រីក្រ គឺក៏មានតួនាទីសំខាន់ផងដែរ។ ផ្នែកនេះបានដាក់ចេញនូវកំរិត និងរបៀបវារៈនៃគោលនយោបាយដែលមានស្រាប់ក្នុងបញ្ហាគន្លឹះជាច្រើន រួមជាមួយគោលដៅជាទូទៅនៃការបង្កើតប្រាក់ចំនូលសំរាប់ប្រជាជនរស់នៅតាមតំបន់ជនបទទាំងនោះរួមមាន ដី ទឹក កសិកម្ម ព្រៃឈើ ការនេសាទ និងការដឹកជញ្ជូន។ គេរំពឹងថាការកែលំអក្នុងវិស័យទាំងនេះនឹងរួមចំណែកដល់ការធ្វើអោយប្រសើរឡើងដល់ផ្នែកផ្សេងៗនៃភាពក្រីក្រ

ឧទាហរណ៍ ដូចជាតាមរយៈការទទួលបាននូវសេវាជាមូលដ្ឋានល្អជាងមុន ហើយក៏មានទំនាក់ទំនងរវាងសកម្មភាពក្នុងវិស័យផ្សេងទៀតដូចជាការធ្វើវិមជ្ឈការនិងការរស់នៅតាមតំបន់ជនបទ។

ការធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅតាមជនបទត្រូវពឹងផ្អែកលើការកាត់បន្ថយភាពក្រីក្រលើវិស័យផ្សេងទៀត ។ ភាពទន់ខ្សោយលើផ្នែកសុខភាពការអប់រំ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធកសិកម្មនិងផលិតភាពមានកំរិតទាប ជាហេតុនាំអោយអ្នករស់នៅជនបទឈានទៅរកភាពក្រីក្រ។ ការថែរក្សាសុខភាពបឋម គឺមានសារៈសំខាន់ណាស់សំរាប់ប្រជាជនរស់នៅជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទកំពុងធ្វើការជំរុញការអប់រំសុខភាពនៅតាមជនបទដោយធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយក្រសួងសុខាភិបាល។ យោងទៅលើរបាយកាណណ៍អភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ ១៩៩៧ ប្រជាជនកម្ពុជាភាគច្រើន មិនបានទទួលប្រពន្ធ័ការពារសុខភាព និងអត្រានៃការប្រើប្រាស់សេវាសុខភាពគឺស្ថិតក្នុងចំណោមការប្រើប្រាស់មានកំរិតទាបនៅក្នុងពិភពលោក។ នាពេលបច្ចុប្បន្ន មានប្រមាណ ៤៧%នៃប្រជាជនទាំងមូលពុំបានទទួលសេវាថែរក្សាសុខភាពបានគ្រប់គ្រាន់ទេ។ ជំរឿនឆ្នាំ ១៩៩៨ បានរកឃើញថាមានតែ ៨,៦% នៃអ្នករស់នៅជនបទមានលទ្ធភាពក្នុងការកែលំអប្រព័ន្ធបង្គន់អនាម័យ បើប្រៀបធៀបទៅនឹង ៤៩% នៃអ្នករស់នៅតាមជាយក្រុង។ រីឯវិស័យ ផ្សេងទៀត គឺត្រូវបានបង្ហាញតាមរយៈគោលនយោបាយជាច្រើនដែលមាននៅក្នុងផ្នែក៤.២ និង ៤.៣ ។

## កែលំអការកាន់កាប់ដីធ្លី

ដី និងទឹក គឺជាធនធានធម្មជាតិសំខាន់ពីរជាមូលដ្ឋានដែលអាចយកមកប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទដែលប្រជាពលរដ្ឋរស់នៅដោយពឹងផ្អែកលើដីទាំងនោះសំរាប់ធ្វើកសិកម្ម ។ របបខ្មែរក្រហម ប្រព័ន្ធកសិកម្មជាសមូហភាព ការអូសបន្លាយនៃសង្គ្រាមស៊ីវិល រួមទាំងការរំលោភយកដី និងវិវាទដីធ្លី គឺជាបញ្ហាចំបង ជាពិសេសសំរាប់ប្រជាពលរដ្ឋក្រីក្រ ។ គ្រួសារកសិករជាង១៥% មិនមានដីសំរាប់ធ្វើកសិកម្ម ក្នុងនោះភាគច្រើនមេគ្រួសារជាស្ត្រី ។ ដូច្នេះសុវត្ថិភាពនៃលទ្ធភាពទទួលបានដីរបស់ពលរដ្ឋក្រីក្រនៅតំបន់ជនបទនៃប្រទេសកម្ពុជា នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងធានាឱ្យមានការលូតលាស់ផ្នែកសេដ្ឋកិច្ចដោយសមធម៌ ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហានៃការប្រើប្រាស់ដី និងការរៀបចំដែនដី។

គោលដៅនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចដោយចីរភាព ធ្វើវិមជ្ឈការការរៀបចំដែនដី និងធ្វើការកាត់បន្ថយភាពក្រីក្រ ។ នៅពេលដែលបានបញ្ចូលជាមួយនឹងយុទ្ធសាស្ត្រនៃផ្នែកដទៃទៀត ទស្សនវិស័យនៃគោលនយោបាយដីធ្លី ដូចមានចែងក្នុងឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី នឹងជួយផ្តល់នូវឱកាសសេដ្ឋកិច្ចប្រសើរឡើងសំរាប់ពលរដ្ឋក្រីក្រ និងកាត់បន្ថយនូវភាពងាយរងគ្រោះ ។ ទស្សនវិស័យនៃគោលនយោបាយនេះមានទិដ្ឋភាពបី រួមមាន (១)- ដីត្រូវបានគ្រប់គ្រងតាមវិធីដែលធ្វើឱ្យសិទ្ធិកម្មសិទ្ធិលើទ្រព្យមានភាពច្បាស់លាស់ និងមានសុវត្ថិភាព (២)-សម្បទានដីសង្គមកិច្ច គឺការបែងចែកដីឯកជនរបស់រដ្ឋដែលទំនេរដល់គ្រួសារក្រីក្រ ដែលត្រូវការដី និង (៣)- ដីនឹងត្រូវបានរៀបចំតាមវិធីមួយ ដែលធ្វើឱ្យការប្រើប្រាស់បានល្អ ប្រកបដោយចីរភាព និងត្រឹមត្រូវតាមបែបបទបរិស្ថាន ហើយនឹងផ្តល់សុវត្ថិភាពឱ្យប្រជាពលរដ្ឋក្រីក្រនូវឱកាស និងលទ្ធភាពដែលអាចអាស្រ័យផលបាន ពីធនធានធម្មជាតិ (ពិសេសដីធ្លី)

សុវត្ថិភាពនៃលទ្ធភាពតាំងទីលំនៅ លទ្ធភាពរកឥណទានបាន និងលទ្ធភាពរកការងារធ្វើបាន និងសុវត្ថិភាពនៃលទ្ធភាពធ្វើការវិនិយោគ ។

ចំណុចសំខាន់ៗនៃឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី ដែលនឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ត្រូវបានប្រមូលផ្តុំនៅក្នុងទិដ្ឋភាពសំខាន់ទាំងបីនៃគោលនយោបាយដីធ្លីនេះ ។ ទំនាក់ទំនងតាមលំដាប់លំដោយ ក៏ដូចជាការផ្តល់អាទិភាពដល់កម្មវិធី និងសកម្មភាពនៃរដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី ត្រូវបានកំណត់ឡើងដោយយោងទៅតាមតំរូវការនៃការស្នើសុំតាមតំបន់នីមួយៗ ដែលនឹងកំណត់តាមរយៈការអង្កេតស្រាវជ្រាវ និងការធ្វើវិភាគ ។ ឧទាហរណ៍ : នៅក្នុងតំបន់ដែលដីមិនទាន់បានបែងចែក ការបែងចែកដីនឹងត្រូវបានផ្តល់អាទិភាពដល់អ្នករដ្ឋបាល ។ នៅកន្លែងដែលក្បាលដីត្រូវបានចុះបញ្ជីរួចហើយ ហើយការកាន់កាប់ដីនោះមិនមានជម្លោះ ការងាររដ្ឋបាលដីធ្លី និងការរៀបចំដែនដីនឹងត្រូវធ្វើមុនពេលការបែងចែកដី ។ ទិដ្ឋភាពទាំងនេះ ត្រូវបានពិភាក្សាលើកឡើងដូចតទៅ :

**រដ្ឋបាលដីធ្លី:**

ការងាររដ្ឋបាលដីធ្លី នឹងផ្តល់ឱកាសសេដ្ឋកិច្ចប្រសើរឡើង និងកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រ ដោយបង្កើតអោយមានសុវត្ថិភាពលើសិទ្ធិកម្មសិទ្ធិ ។ សុវត្ថិភាពលើសិទ្ធិកម្មសិទ្ធិនោះ គឺ (១)-ការពារប្រជាពលរដ្ឋក្រីក្រពីការរំលោភយកដី និងជួយដោះស្រាយវិវាទដីធ្លី (២)- ធ្វើឱ្យប្រសើរឡើងនូវការលើកទឹកចិត្តដល់ការវិនិយោគលើដីធ្លីសំរាប់ វិស័យកសិកម្ម ឬសំរាប់គោលដៅនៃការផលិតផ្សេងទៀត និង (៣)-ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ប្រជាពលរដ្ឋក្រីក្រនៅក្នុងការប្រើប្រាស់ដីរបស់ពួកគេ ដូចជា ការដាក់បញ្ចាំដីធ្លី ហើយការដាក់បញ្ចាំនោះបានសមស្របទៅនឹងតម្លៃនៃទីផ្សារដីជាដើម ។ ការធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលដីធ្លី គឺជាសមាសធាតុមួយ រួមចំណែកធ្វើឱ្យគោលដៅក្នុងវិស័យកសិកម្មសំរាប់គ្រួសារក្រីក្របានប្រសើរឡើង ហើយនិងជាសមាសធាតុសំរាប់ការអភិវឌ្ឍន៍ផ្នែកនគរូបនីយកម្ម និងឧស្សាហកម្ម ផងដែរ ។

គោលបំណងជាទូទៅនៃគោលនយោបាយរដ្ឋបាលដីធ្លី គឺធ្វើឱ្យមានភាពច្បាស់លាស់ និងកត់ត្រានូវកម្មសិទ្ធិ និងសិទ្ធិកម្មសិទ្ធិផ្សេងទៀតលើអចលនទ្រព្យទាំងអស់ (ទ្រព្យសាធារណៈ និងទ្រព្យឯកជន) ដោយអនុលោមតាមច្បាប់ភូមិបាល ។ គោលដៅជាក់លាក់នៃគោលនយោបាយរដ្ឋបាលដីធ្លី គឺធ្វើការកំណត់ប្រភេទនៃកម្មសិទ្ធិ និងសិទ្ធិលើដី របៀបទទួលបានសិទ្ធិ និងដើម្បីអនុវត្តប្រព័ន្ធចុះបញ្ជីដីទូទាំងប្រទេសឱ្យមានតម្លាភាព សមធម៌ និងគណនេយ្យភាព ។ សមាសធាតុផ្សេងៗទៀតនៃប្រព័ន្ធរដ្ឋបាលដីធ្លីនេះ គឺការផ្សារភ្ជាប់ការចុះបញ្ជីដីធ្លីទៅនឹងការដោះស្រាយវិវាទដីធ្លី ការកំណត់ព្រំប្រទល់រដ្ឋបាល ការរៀបចំបទប្បញ្ញត្តិសំរាប់ទីផ្សារដី និងការដាក់ឱ្យដំណើរការក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីជំរុញ និងតាមដានការអនុវត្តន៍គោលនយោបាយដីធ្លីតាមការតម្រង់ទិសរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**ការបែងចែកដីធ្លី:**

គោលដៅរបស់រដ្ឋ គឺធ្វើឱ្យមានការបែងចែកដីធ្លីដោយសមធម៌ ។ ដើម្បីសំរេចបានកិច្ចការនេះ អនុក្រឹត្យមួយស្តីពីសម្បទានដីសង្គមកិច្ចកំពុងត្រូវបានរៀបចំ ។ ការអនុវត្តន៍ រួមទាំងគំរោងសាកល្បងសំរាប់អនុវត្តអនុក្រឹត្យនេះគ្រោងនឹងចាប់ផ្តើមនៅឆ្នាំ ២០០៣ ។

កម្មវិធីបែងចែកដី នឹងត្រូវធ្វើការបែងចែកដីឯកជនរបស់រដ្ឋដែលទំនេរ ឱ្យទៅក្រុមគ្រួសារដែលនឹងត្រូវបានកំណត់ជាអាទិភាពសំរាប់ការទទួលបានដីសម្បទានសង្គមកិច្ចនេះ ។ កម្មវិធីសម្បទានដីសង្គមកិច្ច នឹងត្រូវបានរៀបចំឡើងដោយរួមបញ្ចូលនូវគំរោងកម្មវិធីដែលបានផ្តួចផ្តើមឡើងដោយថ្នាក់ទាំងពីរ គឺថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។ កម្មវិធីនេះនឹងឆ្លើយតបទៅនឹងតំរូវការដីសំរាប់គ្រួសារក្រីក្រដែលគ្មានដី គ្មានទីជំរក និងគ្រួសារដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិ ឬដោយប្រការផ្សេងៗទៀត ។

**ការរៀបចំដែនដី :**

វិធានការណ៍នៃការរៀបចំដែនដី គឺមានបំណងដើម្បីការពារប្រជាពលរដ្ឋក្រីក្រនូវលទ្ធភាពអាចប្រើប្រាស់ធនធានធម្មជាតិបាន និងកាត់បន្ថយភាពងាយរងគ្រោះ ហើយគាំទ្រដល់លទ្ធភាពនៃការតាំងទីលំនៅ និងឱកាសសេដ្ឋកិច្ចនៅក្នុងតំបន់ទីប្រជុំជន ។ គោលដៅនៃនយោបាយរៀបចំដែនដី គឺធ្វើឱ្យប្រាកដថា ដី និងធនធានធម្មជាតិត្រូវបានប្រើប្រាស់នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដោយប្រសិទ្ធភាព ចិរភាព និងសមធម៌ ។ បណ្តាវិធានការណ៍ដែលនឹងត្រូវបានដាក់ចេញ គឺសំដៅការពារដីការពារ ធនធានធម្មជាតិ និងដោះស្រាយជំរកដល់ពលរដ្ឋដែលត្រូវផ្លាស់ចេញពីកន្លែងយ៉ាប់យ៉ឺន ឬកន្លែងមិនគួរឱ្យប្រើប្រាស់ និងគាំទ្រដល់ការធ្វើវិមជ្ឈការ ប្រសិទ្ធភាព និងគណនេយ្យភាពនៃអភិបាលកិច្ចនៅក្នុងផែនការប្រើប្រាស់ដីធ្លី ។

សមាសភាគជាក់លាក់នៃការរៀបចំដែនដី ដែលនឹងត្រូវបានដាក់ឱ្យអនុវត្តដើម្បីសំរេចឱ្យបាននូវគោលដៅទាំងនេះរួមមាន: ការសំរបសំរួលរវាងផែនការប្រើប្រាស់ដីជាមួយនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ ការធ្វើវិមជ្ឈការការរៀបចំដែនដីនឹងអាជ្ញាធរផែនការកម្ម អភិវឌ្ឍន៍ផែនការប្រើប្រាស់ដីសំរាប់តំបន់អាទិភាពអនុវត្តន៍នីតិវិធីសំរាប់ការរៀបចំដែនដីទីប្រជុំជន ការបង្កើតគោលនយោបាយលំនៅឋានការរៀបចំឱ្យប្រសើរឡើងនូវការតាំងទីលំនៅបណ្តោះអាសន្ន និងការអនុមតិគោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មី ។

## ការអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងបុព្វបទនៃការកាត់បន្ថយភាពក្រីក្រ

គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំរេចអោយបានជោគជ័យនូវការអភិវឌ្ឍន៍ដោយសមធម៌ និងភាព-យុត្តិធម៌ក្នុងសង្គមតាមរយ:ការអភិវឌ្ឍន៍ធនធានមនុស្ស និងនិរន្តរភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ។ ភាពចាំបាច់នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដើម្បីជំរុញដោះស្រាយកំរិតជីវភាពដ៏ក្រីក្ររបស់ប្រជាជនដែលរស់នៅទីជនបទ ប្រជាជនកម្ពុជាភាគច្រើនរហូតចំនួន ៨៥ ភាគរយ ជាកសិករដែលប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេបានពឹងផ្អែកទាំងស្រុងលើការធ្វើកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិជាពិសេសព្រៃឈើ និងនេសាទ ។

វិស័យកសិកម្មបានដើរតួនាទីជាអាទិភាពនៃរាជរដ្ឋាភិបាលកម្ពុជា។ នៅចន្លោះឆ្នាំ ១៩៩៣-២០០១ វិស័យកសិកម្មជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចជាតិដែលបានចូលរួមចំណែករហូត ៤៦,៤ ភាគរយ នៃផលទុនជាតិសរុប។ ក្នុងនោះផលិតផលដំណាំកសិកម្មមានចំនួន ៤៥ ភាគរយ ផលិតកម្មបសុសត្វ ១៤ភាគរយ ផលិតផលនេសាទ ៣០ ភាគរយ និង ១០ ភាគរយបានមកពីផ្នែកព្រៃឈើ។

ផែនការយុទ្ធសាស្ត្រចាំបាច់ក្នុងការកាត់បន្ថយភាពក្រីក្រចំពោះមុខវិស័យកសិកម្មគឺ ការប្រឹងប្រែងរកដំណោះស្រាយដើម្បីបង្កើននូវសក្តានុពលភាព និងការធ្វើភាវូបនីយកម្មកសិកម្មដោយជំរុញបង្កើននិយោជក បង្កើនប្រាក់ចំណូលគ្រួសារនិងបង្កើនស្បៀងអាហារអោយបានគ្រប់គ្រាន់ ។ ការធ្វើភាវូបនីយកម្មកសិកម្មតំរូវអោយទាមទារការគាំទ្រដល់កសិករក្នុងការធ្វើកសិកម្មទ្រង់ទ្រាយតូចតាមបែបនៃការប្រើប្រាស់បច្ចេកទេសសមស្រប ដែលកសិករអាចត្រួតពិនិត្យបាននូវផលិតភាពលក្ខខណ្ឌបរិស្ថានធម្មជាតិ ។ នៅក្នុងដំណោះស្រាយនេះរួមមានៈ ការបញ្ចូលនូវប្រព័ន្ធគាំទ្រផ្នែកម៉ាក្រូសេដ្ឋកិច្ច និងទំរង់គោលនយោបាយកសិកម្មដែលអាចសំរួលនូវលក្ខខណ្ឌបរិស្ថាន ការងារសមស្របឆ្ពោះទៅបង្កការចូលរួមពីផ្នែកឯកជនលើការអភិវឌ្ឍន៏វិស័យកសិកម្ម ។ ទន្ទឹម នោះក៏គួរមានការលើកទឹកចិត្តដល់ការវិនិយោគសាធារណៈ និងឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗកិច្ចសន្យានៃ ការផ្លាស់ប្តូរទំនិញសាធារណៈនិងការអភិវឌ្ឍន៏ធនធានមនុស្ស ។ ចំនុចដូចបានលើកមកនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពបំផុតដើម្បីជំរុញអោយបានឆាប់រហ័ស និងមាននិរន្តរភាពនៃការកើនឡើងនូវផលិតភាពកសិកម្ម ដែលផ្តល់ផលសមស្រប និងតំលៃនៃប្រសិទ្ធភាពបច្ចេកទេសដូចជាៈ លទ្ធភាពត្រួតពិនិត្យបានរបស់កសិករលើកសិដ្ឋានទ្រង់ទ្រាយតូច សំភារៈចែកចាយទឹកឯកជន ការធ្វើពហុវប្បកម្មនិងប្រពលវប្បកម្មនៃដំណាំ ។

ម៉្យាងវិញទៀត ការអភិវឌ្ឍន៏លើវិស័យកសិកម្មក៏បានផ្តោតការយកចិត្តទុកដាក់ទៅលើអំណាចរបស់កសិករក្រីក្រនៅទីជនបទ ពួកអ្នកងាយទទួលរងនូវការឈឺចាប់ដើម្បីបង្កើនលទ្ធភាពអោយពួកគេអាចចូលរួមក្នុងដំណើរការអភិវឌ្ឍនេះផងដែរ ។ ការប្រឹងប្រែងនោះគឺគួរផ្តើមឡើងពីការជំរុញអោយពួកគាត់មានដីធ្លី ទឹកប្រើប្រាស់ និងបណ្តាផលិតភាពផ្សេងៗទៀត ដើម្បីសុវត្ថិភាពក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ស្បៀងអាហារ និងការអភិវឌ្ឍន៏សង្គម ។

ស្ថាប័នរាជរដ្ឋាភិបាលជាច្រើនដែលមានការពាក់ព័ន្ធនឹងបានកំពុងចូលរួមក្នុងការអភិវឌ្ឍន៏វិស័យកសិកម្ម រួមមានៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងអភិវឌ្ឍន៏ជនបទ និងក្រសួងគ្រប់គ្រងដែនដី និងនគររូនីយកម្ម។

ការផ្តល់អាទិភាពដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនោះគឺភាពគ្រប់គ្រាន់នៃស្បៀងអាហារភាពស្រស់ត្រកាលនៃបរិស្ថានធម្មជាតិ និងនិរន្តរភាពនៃការលូតលាស់ដោយឈរលើគោលការណ៏ប្រកួតប្រជែងជាសាកល និងគោលការណ៏អភិវឌ្ឍន៏ស្មើភាពគ្នាគួរតែកំនត់អោយបានច្បាស់លាស់ក្នុងរង្វង់ៈ (១) រៀបចំទំរង់ការសមស្របនៃម៉ាក្រូសេដ្ឋកិច្ច តំរូវតាមគោលនយោបាយ និងបរិស្ថានស្ថាប័ន (២) បង្កើនល្បឿនអភិវឌ្ឍន៏ប្រព័ន្ធស្រោចស្រពដោយនិរន្តភាព (៣) បង្កើតកម្មវិធីសំរាប់ផ្តល់កម្មសិទ្ធ និងការបែងចែកដីកសិកម្ម (៤) អភិវឌ្ឍន៏ទីផ្សារនាំចេញស្រូវនិងផលិតផលផ្សេងៗទៀត ទន្ទឹមនោះការកែច្នៃ និងការត្រួតពិនិត្យគុណភាពផលិតផល (៥) ការពង្រឹងសេវាកម្មសំខាន់ៗ គាំទ្រដល់កសិកម្មនិង មុខងាររួមមានៈ ការងារផ្សព្វផ្សាយការស្រាវជ្រាវ និងអភិវឌ្ឍន៏ទីផ្សារឥណទាន និងការបែងចែកសំភារៈ (៦) ពង្រីកផលិតកម្មបសុសត្វជាមួយនិងការខិតខំប្រឹងប្រែងលើសេវាសុខភាពសត្វចំនីអាហារ ការគ្រប់គ្រង និងបង្កើននូវផែនការកែច្នៃ (៧) ជំរុញការគ្រប់គ្រងនិង ផ្តើមនូវបច្ចេកទេសសមស្របដូចជាកសិដ្ឋានចំរុះ ស្រូវ ត្រី និងការធ្វើវារីវប្បកម្ម (៨) ជំរុញការបង្កើតសហគមព្រៃឈើនិងសហគមនេសាទ (៩) ជំរុញពង្រឹងសមត្ថភាពគ្រប់ក៏រិតទាំងអស់នៃស្ថាប័នរដ្ឋាភិបាលដូចជាៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧត្តុនិយម ។ល ។

សេចក្តីពេញចិត្តនៃលក្ខខណ្ឌគោលនយោបាយគួរតែស្ថិតក្នុងចំណោមការការពារនិងភាពឯករាជ្យ និងបរិស្ថានទីផ្សារក្នុងការធ្វើពាណិជ្ជកម្ម ការនាំចេញនូវផលិតផលកសិកម្ម ការអភិវឌ្ឍន៍ស្តង់ដារគុណភាពផលិតផលដោយ ធ្វើយ៉ាងណាលើកទឹកចិត្តដល់ការធ្វើវិនិយោគឯកជនក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធសមស្រប និងសំភារៈក្នុងការ ប្រមូលផលចូលឃ្លាំង ការកែច្នៃ កសាងច្បាប់ និងជំរុញការអនុវត្តន៍ច្បាប់សេដ្ឋកិច្ចសមស្រប និងកិច្ចសំរបសំរួលរវាងស្ថាប័នផ្សេងៗដើម្បីជំរុញដល់ការទទួលផល និងប្រសិទ្ធភាពក្នុងការដោះស្រាយភាពមន្ទិលសង្ស័យដើម្បីបង្កអោយកាន់តែប្រសើរឡើងនូវតំម្លាភាព និងភាពអាចទទួលយកបាន និងកាត់បន្ថយនូវការរាំងស្ទះ ។

## ការល្បងយុទ្ធសាស្រ្ត

១- តើកសិកម្មអាចបង្កើនផលិតភាពកសិកម្មក៏រិតណា? ដែលអាចមានស្បៀងអាហារគ្រប់គ្រាន់សំរាប់ការរស់នៅរបស់គ្រួសារកសិករជនបទ?

២- តើធនធានធម្មជាតិអាចគ្រប់គ្រាន់យ៉ាងណា? ដើម្បីអោយមាននិរន្តរភាពពេលតំរូវការកើនឡើង ។

៣- តើអ្វីដែលអាចភ្ជាប់ទំនាក់ទំនងនៅក្នុងកសិកម្ម?

៤- តើអ្វីគាំទ្រដល់ការចាំបាច់ខាងលើដើម្បីឈានទៅសំរេចផល?

## ដំណោះស្រាយ និងលក្ខណៈសម្បត្តិនៃកម្មវិធីយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ

*លើកស្ទួយវិស័យកសិកម្មដើម្បីជំរុញបង្កើនស្បៀងអាហារ និងមុខរបរដល់កសិករនៅជនបទ ។*

ទិសដៅនៃកម្មវិធីយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រគឺ ជំរុញអោយមានការកើនឡើងជាអតិបរមានូវស្បៀងអាហារនៃប្រជាកសិករ ជនបទតាមរយៈការបង្កើនផលិតភាពកសិកម្ម និងការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានធម្មជាតិ និងការអភិរក្សដើម្បីបង្កើនស្បៀងអាហារ និងប្រាក់ចំណូល ។

## គោលបំណង:

ដើម្បីសំរេចអោយបានជោគជ័យនូវទិសដៅខាងលើគោលបំណងសំខាន់ នៃកម្មវិធីយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រលើវិស័យកសិកម្មគឺ: (១)មានទំរង់ការច្បាប់មួយគ្រប់គ្រាន់គួបផ្សំនឹងភាពអំណោយផលនៃបរិស្ថានស្ថាប័ន (២)កសាងសមត្ថភាព/បង្កើនប្រព័ន្ធចំណេះដឹងដល់មន្រ្តីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត (៣)ធ្វើប្រពលវប្បកម្ម និងសន្តិសុខនៃផលិតកម្ម (៤)ការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានធម្មជាតិ និងការអភិរក្ស (៥)ជំរុញផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្មទៅក្នុងប្រព័ន្ធទីផ្សារ ។

រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តកម្មវិធីយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្ពោះទៅធានាបានទាំងស្រុងនូវសន្តិសុខស្បៀងដែលកម្មវិធីនេះនិងឈានទៅកាត់បន្ថយបាននូវភាពទ័លច្រកករបស់ប្រជាជនកម្ពុជា ។ យុទ្ធសាស្រ្តបានកំណត់ច្បាស់លាស់ទៅលើរង្វង់នៃអ្នកក្រីក្រសំដៅកន្លែងដែលខ្វះខាតស្បៀងអាហារខ្លាំង ។ ផែនទីនៃការវាស់ស្ទង់លើភាពក្រីក្ររបស់អង្គការស្បៀងអាហារពិភពលោកនឹងត្រូវយកមកប្រើប្រាស់ដើម្បីជំនួយដល់កម្មវិធីយុទ្ធសាស្រ្តនេះ ។ គោលបំណងនៃផែន

ការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រគឺការផ្តោតទៅលើភាពក្រីក្រ ដែលនឹងធ្វើអោយមានការកើនឡើងនូវដំណាំពហុវប្បកម្មតាមបែបប្រពលវប្បកម្មនៃកសិដ្ឋាន និងសុវត្ថិភាពនៃផលិតកម្មកសិកម្ម ។ ទោះយ៉ាងណាដើម្បីជំរុញអោយបានជោគជ័យនូវគោលបំណងនៃយុទ្ធសាស្ត្រខាងលើកត្តាសំខាន់ ផ្សេងៗទៀតក៏គួរចាប់អារម្មណ៍និងចាត់ទុកសកម្មភាពយុទ្ធសាស្ត្រដូចជា: ការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានធម្មជាតិ ការកសាងសមត្ថភាពនៃអ្នកពាក់ព័ន្ធ កសាងនឹងពង្រឹងច្បាប់ និងលក្ខខណ្ឌបរិស្ថានស្ថាប័នសមស្របដល់ការអនុវត្តន៏ការងារ ។ លើសពីនេះទៅទៀត គួរត្រូវបានបង្កើនឡើងនូវផលិតផលកសិកម្ម និងកសិឧស្សាហកម្មឯកជននឹងជំរុញផលិតផលទាំងនោះអោយចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយទីផ្សារនិងមានលទ្ធភាពទៅក្នុងទីផ្សារ ។

## វិធីសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រលើវិស័យកសិកម្ម

### ការកសាងសម្ថភាព

***កសាងសម្ថភាពនិងការងារផ្សព្វផ្សាយ:*** ជំរុញអ្នកពាក់ព័ន្ធលើយុទ្ធសាស្ត្រនេះអោយមានចំណេះដឹង នឹងភាពជំនាញគ្រប់គ្រាន់ដើម្បីឈានទៅជំរុញ ផលិតភាពកសិកម្ម ។

ទិដ្ឋភាពសំខាន់ៗគួរត្រូវបានដោះស្រាយដូចជា: ការជំរុញប្រព័ន្ធកសិដ្ឋាន គុណភាពពូជ ជីនិងវិធីសាស្ត្រ នៃការប្រើជីដើម្បីជំរុញការបង្កើនផលិតផលកសិកម្មដល់កំរិតអតិបរមា ឆ្ពោះទៅជំរុញស្បៀងអាហារដល់កសិករ។ ដើម្បីអោយទទួលបានជោគជ័យនូវទិដ្ឋភាពទាំងនោះកម្មវិធីជាតិ (SPFS) ការកសាងសមត្ថភាព គឺមិនគ្រាន់តែយោងទៅលើប្រព័ន្ធចំនេះដឹងនឹងភាពជំនាញនៃអ្នកផ្តល់សេវាកម្មនឹងអ្នករួមចំណែកប៉ុណ្ណោះទេប៉ុន្តែការពង្រឹងបានយកចិត្តទុកដាក់លើសហករជនបទ ជាឧទាហរណ៍: សហករណ៏កសិកម្ម និងស្ថាប័នសេវាកម្មផ្សព្វផ្សាយដោយរួមបញ្ចូលនូវការស្រាវជ្រាវ និងមជ្ឈមណ្ឌលកណ្តាលសំរាប់កសិកររៀនសូត្រជាដើម ។ ការគាំទ្រសេវាកម្មផ្សេងៗទៀតរួមមាន: ពតិមានទីផ្សារ អាកាសធាតុក៏ជាកត្តាសំខាន់ជួយជំរុញដល់ការទទួលជោគជ័យនៃផែនការយុទ្ធសាស្ត្រនេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជំរុញការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយតាមរយ:ការចូលរួមធ្វើផែនការធ្វើវិមជ្ឈការនិងតម្លាភាពនៃការអនុវត្តន៏ផែនការ ។ ដើម្បីជំរុញការងារនេះកាន់តែស្រួចស្រាវទិដ្ឋភាព មួយចំនួនដូចជា: ការអភិវឌ្ឍន៏គោលការណែនាំវិធីសាស្ត្រផ្សព្វផ្សាយសមស្របដើម្បីជាតំរូវការចាំបាច់របស់ប្រជាជនក្នុងស្រុក និងទីផ្សារបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃដែលអាចអនុញ្ញាតអោយវាស់ស្ទង់បាននូវលទ្ធផលនៃសកម្មភាព ផ្តល់អត្តសញ្ញាណកម្មមនុស្សដែលមានសមត្ថភាព និងមានបទពិសោធន៏ ហើយលើកទឹកចិត្តដល់ពួកគេ ផ្តល់អត្តសញ្ញាណកម្មវិធីសាស្ត្រផ្សព្វផ្សាយដែលមានប្រសិទ្ធភាពបំផុតដើម្បីផ្ទេរបច្ចេកទេសទៅកសិករជាមួយការទទួលយកកំរិតខ្ពស់ជាមួយការសាយភាយឆាប់រហ័ស និងការធ្វើរបាយការណ៏ជាទៀងទាត់ពង្រឹងនិងភ្ជាប់ទំនាក់ទំនងជាតិ និងស្ថាប័នអន្តរជាតិជំរុញអោយកាន់តែកើនឡើងនូវការសហប្រតិបត្តិការទំនាក់ទំនងនឹងអ្នករួមចំណែកផ្សេងៗ ដើម្បីរកមើលឱកាសនិងគាំទ្រដល់ប្រភពបច្ចេកទេសនិងតំរូវការពតិមានផ្សេងទៀតសំរាប់កាងារផ្សព្វផ្សាយការអភិវឌ្ឍន៏ធនធានមនុស្សនិង កសាងសមត្ថភាពរបស់ពួកគេអំពីវិធីសាស្ត្រផ្សព្វផ្សាយបច្ចេកទេស និងសេដ្ឋកិច្ចទីផ្សារដើម្បីអោយគេអាចក្លាយជាអ្នកដឹកនាំគ្រប់គ្រងសកម្មភាពរបស់ខ្លួនក៏ដូចជាជំរុញអោយមានជំនាញច្បាស់លាស់ ។ កសាងនឹងពង្រីកសមត្ថភាពមន្ត្រីរដ្ឋាភិបាលនិងភាពជាដៃគូរដូចជា: ស្ថាប័នឯកជន អង្គការក្រៅរដ្ឋាភិបាល។ ល ។ នៅគ្រប់កំរិតដើម្បីអនុវត្តន៏ការងារផ្សព្វផ្សាយ

និងការគាំទ្រដល់កសិករក្នុងការប្រើប្រាស់ផលិតផលដោយប្រសិទ្ធភាពការកែច្នៃ និងការផ្សព្វផ្សាយលើទីផ្សារនៃផលិតផលកសិកម្ម ។

***ការស្រាយជ្រាវនិង ការផ្សព្វផ្សាយកសិកម្ម:*** រាជរដ្ឋាភិបាលកម្ពុជា និងធ្វើអោយមានភាពជាក់ច្បាស់ថា: មជ្ឈមណ្ឌលស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និងតំរង់ឆ្ពោះទៅកសិករទីទ័លក្រដើម្បីពង្រីកធនធានដែលមានរបស់គាត់ មជ្ឈមណ្ឌលស្រាវជ្រាវនឹងរៀបចំឡើងអាស្រ័យលើអាកាសធាតុនៃតំបន់និមួយៗដូចជា: ភ្លៀងនៅតំបន់ទំនាប តំបន់ខ្ពង់រាបនិង ទឹកជំនន់ប្រចាំឆ្នាំ ។ ការស្រាវជ្រាវនឹងភ្ជាប់ទំនាក់ទំនងជាមួយក្រុមអ្នកផ្សព្វផ្សាយវិមជ្ឈការដោយផ្អែកលើប្រជាជនក្នុងតំបន់ ។ ការស្រាវជ្រាវនិងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយពិតជាកើនឡើងបន្ទាប់ពីជំរុញការប្រើប្រាស់ជីគីមី ការផលិតពូជ និងការខិតខំប្រឹងប្រែងដើម្បីបង្កើនការប្រើប្រាស់ប្រកបដោយរូបភាពច្បាស់លាស់ និងអនុវត្តន៏ការគ្រប់គ្រងជាក់លាក់ (ឧទាហរណ៏: រុក្ខជាតិ ទឹក ដី និងការគ្រប់គ្រងសារធាតុរបស់ដី) ។ ដូច្នេះអាទិភាពគួរតែត្រូវបានផ្តល់ទៅលើប្រព្រឹត្តកម្មដំណាំច្រើនមុខ និងនិរន្តរភាពប្រពលវប្បកម្មនៃផលិតផលកសិកម្ម រួមជាមួយសកម្មភាពខាង ក្រៅមួយចំនួនទៀតដូចជា អនុវត្តន៏ការគ្រប់គ្រងដើម្បីប្រសិទ្ធិភាពតំលៃ ។

***គុណភាពសម្ភារៈកសិកម្ម:*** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានឆ្ពោះការយកចិត្តទុកដាក់ទៅលើការងារស្រាវជ្រាវដើម្បីផលិតនូវពូជដែលមានគុណភាពល្អ និងការត្រួតពិនិត្យនូវគុណភាពពូជ ដើម្បីអោយជាក់ច្បាស់ថាកសិករទទួលបាននូវសំភារៈកសិកម្មទាំងនោះ។ ច្បាប់មួយចំនួនគួរតែអភិវឌ្ឍន៏និងពង្រឹងអោយបានល្អ ច្បាប់ទាំងនេះគួរតែលើកទឹកចិត្តដោយបង្ហាញនូវហេតុផលដើ្បីអោយមានការចូលរួមវិនិយោគពីឯកជនលើសំភារៈកសិកម្មនេះ។ សំភារៈកសិកម្មគួរត្រូវបានបង្ហាញជាមួយនឹងកំណើននៃការលូតលាស់បច្ចេកទេសសមស្រប ។

រាជរដ្ឋាភិបាលកម្ពុជាក៏មានការព្រួយបារម្ភណ៏ផងដែរចំពោះការប្រើប្រាស់ដ៏ទូលំទូលាយនៃក្សេត្យគីមី ដែលអាចបង្កើនផលិតផល។ ប៉ុន្តែទន្ទឹមនោះតំលៃនៃការនាំចូលខ្ពស់ជាពិសេសជី និងថ្នាំសំលាប់សត្វល្អិត ។ ការប្រើប្រាស់ដ៏ទូលំទូលាយ និងការជះឥទ្ធិពលនៃការប្រើប្រាស់ គួរតែធ្វើការសិក្សាវាយតំលៃអំពីអត្ថប្រយោជន៏នៃការប្រើប្រាស់នេះ។ ការប្រើប្រាស់គួរចង្អុលបង្ហាញកន្លែងដែលសមស្របតាមតំបន់ និងមានលក្ខណៈសេដ្ឋកិច្ច ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជួយបង្កើននូវវិធីសាស្រ្តដូចជា ប្រព័ន្ធនៃការធ្វើប្រពលវប្បកម្មស្រូវដែលជំរុញដល់ការបង្កើនផលិតផលដោយកាត់បន្ថយនូវការប្រើប្រាស់ជីគីមី ។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ផងដែរ ចំពោះគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតដែលកំពុងប្រើក្នុងប្រទេសកម្ពុជា។ កសិករនៅបន្តប្រើប្រាស់យ៉ាងពេញទំហឹងនូវថ្នាំសំលាប់សត្វល្អិតរួមទាំងប្រភេទថ្នាំ DDT ផង ។ ទន្ទឹមនឹងនោះការជំរុញអនុវត្តអនុក្រឹតស្តីអំពី"ស្តង់ដារសំភារៈកសិកម្ម" ដែលកិច្ចការនេះចាំបាច់ត្រូវមានកម្មវិធីអប់រំចំណេះដឹងសាធារណៈ (ឧទាហរណ៏: កម្មវិធី IP) ដើម្បីអនុវត្តន៏ការប្រើប្រាស់មួយជាក់ច្បាស់ថា: កសិករ និងអ្នកប្រើប្រាស់ គឺអាចជៀសវាងបាននូវការប្រើប្រាស់ដ៏សែនគ្រោះថ្នាក់នៃប្រភេទជីគីមី និងថ្នាំសំលាប់សត្វល្អិតនេះ។

### កាត់បន្ថយការពឹងផ្អែកលើលក្ខខណ្ឌធម្មជាតិ

***ពង្រឹងការត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធទឹក :*** ផលិតផលកសិកម្មគឺពឹងផ្អែកទាំងស្រុងលើរបបទឹកភ្លៀងដើម្បីស្រោចស្រពភាពសង្វេគនេះកើតមានឡើងដោយសារតែកំរិតនៃប្រព័ន្ធស្រោចស្រពនៅកម្ពុជាមានកំរិតទាប ។ ប្រព័ន្ធស្រោចស្រពមានតែ ១២,៤

ភាគរយ នៃ២,០៦ លានហិចតានៃផ្ទៃដីស្រូវរដូវវស្សា និងជាងពាក់កណ្ដាល (៥៥.២១ ភាគរយ) នៃផ្ទៃដីស្រូវរដូវប្រាំង ២៥៩.៩១៩ ហិចតា ដែលគួរតែទទួលបាននូវប្រព័ន្ធទឹកស្រោចស្រព (ADB ២០០០) ។ ផលិតផលកសិកម្ម គឺទទួលរងគ្រោះដោយធម្មជាតិដូចជាភាពរាំងស្ងួត និងទឹកជំនន់ដែលបណ្ដាលអោយរងការខាតបង់រាប់ពាន់ហិចតានៃដំណាំស្រូវ និងដំណាំផ្សេងៗទៀត ។ គ្រោះធម្មជាតិគឺមានជារៀងរាល់ឆ្នាំដែលធ្វើ អោយមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជន និងបណ្ដាលអោយមានឱនភាពផ្នែកស្បៀងអាហារ និងជួបនូវគ្រោះអត់ឃ្លាន។ ដើម្បីកាត់បន្ថយនូវគ្រោះធម្មជាតិនេះសកម្មភាពជាអាទិភាពគួរតែរាប់បញ្ចូលនូវការពង្រឹងការត្រួតពិនិត្យ គ្រប់គ្រងតាមរយៈនៃការជួសជុល និងពង្រីកប្រព័ន្ធប្រលាយដើម្បីស្រោចស្រព ។ ការព្យាយាមប្រឹងប្រែងនេះគួរផ្ដល់អាទិភាពផងដែរលើការប្រើប្រាស់ម៉ាស៊ីនបូមទឹកតូចៗ ដែលមានសមត្ថភាពស្រោចស្រពលើផ្ទៃដីទំហំប្រមាណ ១០ ហិចតា ដែលកសិករអាចទទួលនូវអត្ថប្រយោជន៍ក្នុងការទទួលខុសត្រូវ និងគ្រប់គ្រងដំណើរការនឹងតំលៃ ។

***គាំទ្រដល់ការធ្វើប្រភេទវប្បកម្ម និងពហុវប្បកម្ម:*** ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ស្រូវមួយមុខគឺមិនអាចឈានទៅសំរេចនូវគោលបំណងដ៏សំខាន់នេះបានទេ ។ កត្តាសំខាន់គឺត្រូវគាំទ្រដល់ការធ្វើពហុវប្បកម្ម ដំណាំឆ្លាស់និងដំណាំឧស្សាហកម្មចាំបាច់ត្រូវអភិវឌ្ឍន៍ឧស្សាហកម្មក្នុងស្រុក និងការនាំចេញផលិតផលដោយបង្កើនតំលៃបន្ថែម ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ ។ ក្នុងចំណោមផលិតផលទាំងនោះកៅស៊ូគឺជាមុខព្រួញដ៏សំខាន់មួយដែលទាមទារនូវការអភិវឌ្ឍន៍បន្ថែម ទៀតជាពិសេសការដាំកៅស៊ូទ្រង់ទ្រាយតូច ផលិតផលបន្លែក៏ត្រូវធ្វើអោយមានការកើនឡើងក្នុងកំរិតមួយដើម្បីធានាបាននូវការប្រើប្រាស់ក្នុងស្រុក ។ ក្ដីសង្ឃឹមត្រូវបានចាប់ផ្ដើមផងដែរលើការការអភិវឌ្ឍន៍ផ្នែកកសិ-ឧស្សាហកម្មដែលនឹងផ្ដល់ឱកាសការងារច្រើនដល់ប្រជាជននៅតំបន់ជនបទ និងប្រាក់ចំណូល។ កិច្ចការនេះនឹងត្រូវចាប់ផ្ដើមពីបច្ចេកទេសប្រមូលផល និងការកែច្នៃកសិផលនៃផលិតផលកសិកម្មតាមរដូវដោយផ្អែកលើការកសាងសមត្ថភាពនៃស្ថាប័នទទួលខុសត្រូវ និងប្រជាកសិករនៅទីជនបទ។ ការកំណត់តំបន់ដីសំរាប់ដំណាំកសិកម្មគឺដើម្បីភាពងាយស្រួលដល់កម្មវិធីអភិវឌ្ឍន៍ និងគោលនយោបាយសមស្រប និងជាសេចក្ដីត្រូវការចាំបាច់ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម។

***ការអភិវឌ្ឍន៍ផលិតកម្ម និង បសុព្យាបាល:*** ផលិតផលពីប្រភេទសត្វគឺមានសារៈសំខាន់មិនត្រឹមតែជាប្រភពនៃប្រូតេអ៊ីនប៉ុណ្ណោះទេ តែក៏ជាប្រភពចំណូលថវិការបស់ប្រជាកសិករនៅទីជនបទ។ គោ ក្របីបានដើរតួនាទីសំខាន់នៅក្នុងការភ្ជួរាស់ ប្រព័ន្ធកសិដ្ឋានចំរុះ និងការកែលំអដី ផលិតកម្មបសុសត្វគឺមានន័យថាជាប្រភពនៃប្រាក់សន្សំ។ បច្ចុប្បន្នផលិតកម្មបសុសត្វបានទទួលរងគ្រោះថ្នាក់ដោយទឹកជំនន់ដែលបណ្ដាលអោយសត្វមានជំងឺ និងស្លាប់ជាច្រើន ។ ម្យ៉ាងវិញទៀតទីផ្សារ និងការប្រកួតប្រជែងក្នុងការធ្វើអាជីវកម្ម គឺជាចំណុចគន្លឹះជំរុញដល់ការអភិវឌ្ឍន៍ផលិតកម្មបសុសត្វ។ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ផ្នែកនេះ រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពលើអនុក្រឹត្យស្ដីពី "ការបង្កើត និងគ្រប់គ្រងពេទ្យ សត្វភូមិ" ដែលអនុញ្ញាតអោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពង្រីកការគាំទ្រទូទាំងប្រទេសដល់គ្រួសារកសិករក្រីក្រ។ ដើម្បីអភិវឌ្ឍន៍គោលនយោបាយរបស់ រាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលបានកំណត់ច្បាស់នូវកត្តាគន្លឹះមួយចំនួនដូចជាៈ (១)កាត់បន្ថយអត្រាមរណៈ និងជំងឺនៃបសុសត្វតាមរយៈការអនុវត្តទូទាំងប្រទេសនូវកម្មវិធីបសុព្យាបាលភូមិ (២)កសាងមជ្ឈមណ្ឌលស្រាវជ្រាវជាតិបសុសត្វ និងតំបន់ រីការរៀនសូត្រការចញ្ចឹមសត្វ

ក្នុងកសិដ្ឋានតាមខេត្តសំរាប់កសិករដែលអាចជំរុញដល់ការអភិវឌ្ឍន៍នូវច្ចេកទេសសមស្របអំពីការថែបំប៉នសត្វ ការផ្តល់ចំណី និង (៣) ត្រួតពិនិត្យចរាចរសត្វ។

***ការអភិវឌ្ឍន៍វារីវប្បកម្មៈ*** ការផ្គត់ផ្គង់ផលនេសាទពីដែនធម្មជាតិគឺមិនអាចគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រជាជននោះទេជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលពីប្រភពទឹកធម្មជាតិអាស្រ័យដោយកំណើនប្រជាជនបានកើនឡើងយ៉ាងឆាប់រហ័ស និងទន្ទឹមនឹងការប្រែប្រួលបរិស្ថានធម្មជាតិ។ ដើម្បីបំពេញសេចក្តីត្រូវការនេះ នាយកដ្ឋានជលផលបានផ្តល់អត្តសញ្ញាណកម្មអំពីលទ្ធភាពនៃការអភិវឌ្ឍន៍វារីវប្បកម្មទ្រង់ទ្រាយតូចនៅតំបន់ទីជនបទ តាមរយៈការសំរបសំរួលគាំទ្រថវិការពី FAO និងអង្គការក្រៅរដ្ឋាភិបាលរួមមាន AIT MRC DANIDA PADEK and SAO ។ នាយកដ្ឋានជលផលបានផ្តល់ការគាំទ្រលើសេវាកម្មផ្សព្វផ្សាយវគ្គបំពាក់បំប៉នដល់កសិករ អំពីការចិញ្ចឹមត្រីក្នុងស្រះ ការចិញ្ចឹមត្រីជាមួយស្រូវ ក្នុងខេត្តមួយចំនួនដូចជាៈ ខេត្តកណ្តាល ព្រៃវែង ស្វាយរៀង និងតាកែវ ។ នាយកដ្ឋានជលផលដោយមានជំនួយការឧបត្ថមពីកម្មវិធី ស្បៀងអាហារពិភពលោកក្នុងការផ្តល់អង្ករពលកម្មទៅកសិករដើម្បីលើកទឹកចិត្តអោយពួកគាត់ជីកស្រះសំរាប់ធ្វើវារីវប្បកម្មទ្រង់ទ្រាយតូច។ ជាងនេះទៀតនាយកដ្ឋានជលផលនិងជំរុញបង្កើនការធ្វើវារីវប្បកម្មទ្រង់ទ្រាយតូចនៅតាមបណ្តាខេត្តផ្សេងៗ ទៀត ។ ការចិញ្ចឹមត្រីក្នុងស្រះ និងក្នុងស្រែ មានតួនាទីសំខាន់បំផុតក្នុងការផ្តល់សន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូល ដើម្បីទ្រទ្រង់ការរស់នៅរបស់ប្រជាកសិករតាមជនបទ។

## ការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានធម្មជាតិ និងការអភិរក្ស

ការគ្រប់គ្រងដោយនិរន្តរភាពនូវប្រភពធនធានធម្មជាតិ និងការអភិរក្សបានក្លាយជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដើម្បីនិរន្តរភាពនៃការរីកចំរើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថានិរន្តរភាពនៃការរីកចំរើន និងការអភិវឌ្ឍន៍ គឺមិនអាចសំរេចបានដោយគ្មានការគ្រប់គ្រងប្រកបដោយគតិបណ្ឌិត និងការអភិរក្សនៃធនធានធម្មជាតិ នានាដែលជិតបាត់បង់ និងមិនទាន់បាត់បង់។ ក្នុងចំណោមសម្បត្តិធម្មជាតិដ៏ទៃទៀត ការតាំងចិត្តនឹងត្រូវបានគេចំណាយដើម្បីធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រង និងការអភិរក្សធនធានព្រៃឈើ និងធនធានជលផល ហើយផលប៉ះពាល់នេះជះឥទ្ធិពលយ៉ាងសំខាន់ទៅលើជនក្រីក្រ ។

***ការគ្រប់គ្រងធនធានជលផល និង ការបង្កើនជីវភាព*** ៖ ត្រីគឺជារបបអាហារដ៏សំខាន់បំផុតទីពីរបន្ទាប់ពីស្រូវរបស់ប្រជាជនកម្ពុជាក្នុងការធានារ៉ាប់រងនូវស្បៀងអាហារ។ វិស័យជលផលបានចូលរួមចំណែកក្នុងផលទុនជាតិយ៉ាងខ្ពស់ចន្លោះពី ៨ ទៅ ១០ភាគរយ។ ប្រជាជនកម្ពុជាបរិភោគត្រីជារៀងរាល់ថ្ងៃ ពិសេសប្រជាជនដែលរស់នៅទីជនបទបានពឹងផ្អែកសំខាន់លើផលរបរនេសាទ សំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ ទន្ទឹមគ្នានេះត្រីបានផ្តល់ក៏វិតប្រូតេអ៊ីនពី ៤០ ទៅ ៦០ភាគរយ នៃប្រជាជននៅទីជនបទ បើទោះបីជាការរស់នៅឆ្ងាយពីតំបន់ទឹកក៏ដោយ ។ ចំពោះតំបន់ដែលស្ថិតនៅជាប់នឹងដងទន្លេ តំបន់បឹងទន្លេសាប និងតំបន់ ព្រៃលិចទឹកត្រីផ្តល់ប្រូតេអ៊ីនរហូត៧០ ទៅ ៧៥ភាគរយ ។

សេចក្តីត្រូវការម្ហូបអាហារបានកើនឡើងជាលំដាប់ជាពិសេសត្រីសំរាប់សង្គមខ្មែរ ការផ្លាស់ប្តូរបរិស្ថានធម្មជាតិនិងកំនើនប្រជាជនបានកើនឡើងយ៉ាងឆាប់រហ័ស ការផ្គត់ផ្គង់ពីធម្មជាតិគឺមិនគ្រប់គ្រាន់ទៅតាមសេចក្តីត្រូវការចាំបាច់របស់មនុស្សទេ។ ជាលទ្ធផលបានបង្ហាញអោយឃើញថាៈ ពីមួយថ្ងៃទៅមួយថ្ងៃធនធានធម្មជាតិ ត្រូវបានទទ្រានយ៉ាងធ្ងន់ធ្ងរ ហើយការកើនឡើងនូវ

ទំនាស់មានស្ទើរគ្រប់ទីកន្លែងដើម្បីផលប្រយោជន៍ជាញឹកញាប់ ទំនាស់បានកើតក្នុងចំនោមអ្នកប្រើប្រាស់ធនធានធម្មជាតិ។ ធនធានធម្មជាតិត្រូវបានបន្តបំផ្លិចបំផ្លាញហើយប្រជាជននៅតែក្រីក្រដដែល។ ដើម្បីទទួលបានជោគជ័យដូចគោលដៅដែលបានលើក និងជៀសវាងបាននូវភាពអវិជ្ជមានទាំងឡាយនោះនាយកដ្ឋានជលផលបានកំនត់យ៉ាងច្បាស់ទៅនូវយុទ្ធសាស្រ្តដូចខាងក្រោមៈ

***សហគមន៍នេសាទ:*** ការមិនទទួលបានជោគជ័យនៃការប្រើប្រាស់វិធីសាស្រ្តតែមួយលើទំរង់ការច្បាប់របស់រដ្ឋ ដើម្បីរក្សានូវធនធានធម្មជាតិបានឈានទៅដល់ការកើនឡើងនូវបញ្ហាស្មុគស្មាញយ៉ាងច្រើនដូចជា ទំនាស់រវាងប្រជានេសាទ និងម្ចាស់ឡូតិ៍នេសាទករណី ទំនាស់កើតមានផងដែរក្នុងចំណោមប្រជានេសាទពួកគាត់លើការទាញយកផលពីធនធានធម្មជាតិ ។ លទ្ធផលបានបង្ហាញអោយឃើញថាៈ ប្រជានេសាទក្រីក្រគ្មានលទ្ធផលគ្រប់គ្រាន់ដើម្បីរករបរចិញ្ចឹមជីវិតរបស់ខ្លួន ដែលឈានទៅដល់ការប្រើប្រាស់សកម្មភាពនេសាទខុសច្បាប់បណ្តាលអោយធនធានធម្មជាតិមានការថយចុះនិងខូចខាតគួរកត់សំគាល់។ ផ្ទៃឡូត៍នេសាទចំនួន ៥៦ ភាគរយនៃផ្ទៃឡូត៍សរុបទូទាំងប្រទេសបានចែកជូនអ្នកនេសាទសំរាប់សហគមន៍នេសាទធ្វើនេសាទជាលក្ខណៈគ្រួសារ ។ ការកែទំរង់វិស័យនេសាទមានគោលបំណងធ្វើអោយប្រាដកនូវការប្រើប្រាស់ដោយនិរន្តរភាពនៃធនធានធម្មជាតិ និងបង្កើនកំរិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ។

នាយកដ្ឋានជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំដែននេសាទដែលបានកាត់ជូនប្រជាជននោះដើម្បីកសាងជាសហគមន៍នេសាទ ។ ប្រព័ន្ធគ្រប់គ្រងនេសាទត្រូវបានផ្លាស់ប្តូរពីការគ្រប់គ្រងដោយ រដ្ឋតែឯងមកជាសហគ្រប់គ្រង ។ បែបផែននៃការគ្រប់គ្រងថ្មីនេះ គឺបានផ្តល់សិទ្ធអំណាចដល់ប្រជាជន និងលើកទឹកចិត្តដល់ពួកគាត់អោយចូលរួមក្នុងសកម្មភាពគ្រប់គ្រង និងអភិរក្សដើម្បីអោយមានភាពទុកចិត្តបាននៃការប្រើប្រាស់ធនធានធម្មជាតិបានកាន់តែប្រសើរឡើង ។ ការកែប្រែនេះនឹងផ្តល់ឱកាសដ៏ល្អដល់ប្រជាជនក្នុងការប្រកបមុខរបរ និងរកប្រាក់ចំណូល ។ ជាងនេះទៅទៀតរាជរដ្ឋាភិបាលបានបញ្ឈប់ការប្រមូលថ្លៃឈ្នួលលើឧបករណ៍នេសាទសិប្បកម្ម ហេតុដូច្នេះប្រជានេសាទគឺមានលទ្ធភាពទូលំទូលាយក្នុងការរកចំណូលរបស់ពួកគាត់ ។ ទោះជាយ៉ាងណាការគ្រប់គ្រង និងអភិបាលកិច្ចល្អនៅក្នុងវិស័យនេសាទ គឺទាមទារនូវការពង្រឹងសមត្ថភាព ។ ការពង្រឹងសមត្ថភាពផ្នែកនេសាទគួរតែត្រូវបានកសាងមិនត្រឹមតែតាមរយៈវគ្គសិក្សានោះទេ ប៉ុន្តែក៏ត្រូវបង្ហាញអោយឃើញពីបទពិសោធន៍នៃការទទួលបានជោគជ័យក្នុងបណ្តាប្រទេសផ្សេងៗ និងការលើកទឹកចិត្តពួកគាត់អោយខិតខំរៀនសូត្របទពិសោធន៍ពីសហគមន៍ផ្សេងៗ។ យន្តការនៃការចូលរួមក្នុងការតាមដាន និងសមធមិនៃការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពក៏នឹងបង្កើតឡើងផងដែរ ។

សកម្មភាពជាច្រើនដើម្បីត្រួតពិនិត្យដល់ការរាំងស្ទះនៃការអនុវត្តន៍ និងអភូតហេតុផ្សេងៗគួរតែត្រូវបានទទួលយកមកដោះស្រាយប្រកបដោយគត្តិយុទ្ធ។ ការប្រព្រឹត្តមិនសមស្របមួយចំនួនរួមមានៈ ការនេសាទខុសច្បាប់ ការបំផ្លិចបំផ្លាញ វិធីសាស្រ្ត និង ឧបករណ៍នេសាទមិនសមស្របតាមការកំនត់របស់ច្បាប់ និងការប្រើប្រាស់នូវ ថ្នាំបំពុលសត្វល្អិតកំរិតខ្ពស់ ។

ការត្រួតពិនិត្យជិតដល់ទៅលើការធ្វើពាណិជ្ជកម្ម នៃផលនេសាទនឹងត្រូវទទួលយកនូវការប្រតិបត្តិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គោលនយោបាយគួរតែបង្កើតដែលថាតុល្យភាពនៃប្រាក់ចំណូលនៃអ្នកនេសាទត្រូវតែមាននិរន្តរភាពទៅលំនឹងនៃធនធាន និងសេចក្តីត្រូវការស្បៀងក្នុងស្រុក ។

***ជំរុញការគ្រប់គ្រងព្រៃឈើ:*** ចំណូលនៃផលទុនជាតិលើវិស័យព្រៃឈើបានចូលរួមប្រហែលជា ៥ភាគរយ ។ ការកែទំរង់វិស័យព្រៃឈើបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការចាំបាច់នៃការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានព្រៃឈើ ។ អនុក្រឹត្យសហគមន៍ព្រៃឈើបានអភិវឌ្ឍន៍ដោយឆ្លងកាត់ការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយក្នុងក៏រិតជាតិ។ សកម្មភាពទាំងនោះបានជំរុញអោយមានការចូលរួមពីសហគមន៍ក្នុងការធ្វើសេចក្តីសំរេចចិត្តដើម្បីសំរបសំរួលគ្រប់គ្រងព្រៃឈើតំណាក់ការដំបូងៗ ការអភិវឌ្ឍន៍សេចក្តីថ្លែងការគោលនយោបាយព្រៃឈើ និងការរៀបចំឡើងវិញនៃរដ្ឋបាលព្រៃឈើត្រូវបានទទួលយកដោយនាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិដោយយោងទៅលើគំរោងស្នើសុំរបស់ក្រុមអន្តររដ្ឋាភិបាល នៃវិស័យព្រៃឈើ និងការជួបប្រជុំអន្តរជាតិនៃវិស័យព្រៃឈើ។ បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាកំពុងអភិវឌ្ឍន៍ច្បាប់ព្រៃឈើរួមមានៈ ការកំណត់ព្រំប្រទល់ព្រៃឈើ បញ្ឈប់ការកាប់ព្រៃឈើខុសច្បាប់ ជំរុញពង្រីកការអភិរក្សតំបន់ព្រៃធម្មជាតិដើម្បីបង្កើតជាកន្លែងទេសចរណ៍ ។ សកម្មភាពទាំងអស់នេះនឹងធ្វើអោយមានលំនឹងភាពក្នុងការទទួលចំណូលពីព្រៃឈើដោយរដ្ឋាភិបាលក្នុងក៏រិតប្រកួតប្រជែងជាមួយនឹងការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានព្រៃឈើ ។

រាជរដ្ឋាភិបាលកម្ពុជាមានការរីកចំរើនគួរជាទីមោទនៈលើការគ្រប់គ្រងព្រៃឈើសម្បទាន កិច្ចការនេះបានបង្ហាញពីដំណើរឆ្ពោះទៅរកភាពទុកចិត្តបានលើការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានធម្មជាតិ ។ ទោះជាយ៉ាងណាការរីកចំរើនទទួលបានមកនេះក៏នៅទាមទារការប្រឹងប្រែងបន្ថែមទៀត ។ ដើម្បីអោយទៅដល់ការគ្រប់គ្រងមួយមានក៏រិតអន្តរជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាបានឈានមកដល់ដំនាក់កាលមួយដ៏មមាញឹក ដើម្បីធ្វើអោយមានការកើនឡើង នៃការអភិរក្សរួមមានការព្យួរទុកនូវសកម្មភាពអាជីវកម្មព្រៃឈើ ។ ដំណាក់កាលបន្តទៀតគឺទាមទារការធ្វើផែនការជាក់លាក់មួយ ដើម្បីជំរុញការអនុវត្តអោយបានប្រសើរនូវអភិបាលកិច្ចល្អ និងមានតម្លាភាពនៅក្នុងវិស័យព្រៃឈើ ។ រដ្ឋាភិបាលកម្ពុជាថ្មីៗនេះកំពុងពិនិត្យឡើងវិញលើស្ថានការណ៍ និងប្រព័ន្ធនៃការគ្រប់គ្រងព្រៃសម្បទាន និងបាននាំយករួចមកហើយនូវសកម្មភាពសំខាន់ៗ។ កិច្ចការនេះគឺនៅបន្តទៅមុខជានិច្ចដោយភ្ជាប់ទំនាក់ទំនងរវាងរដ្ឋាភិបាលក្នុងស្រុកជាមួយស្ថាប័នអង្គការក្រៅរដ្ឋាភិបាល ដើម្បីពិនិត្យអោយបានជាក់លាន់នូវចំណុចសំខាន់ៗទាំងឡាយត្រូវបានដោះស្រាយដោយឆ្លើយតបទៅតាមគោលនយោបាយព្រៃឈើ ផលប្រយោជន៍សហគមន៍ និងប្រជាជនក្រីក្រ ។ សហគមន៍ក្នុងស្រុកបានធ្វើនិងការជំរុញសិទ្ធអោយគ្រប់ភាគគីអាចចូលរួមនៅក្នុងកម្មវិធីសហគមព្រៃឈើ គោលនយោបាយ ជាពិសេសត្រូវតែគាំទ្រដល់ការគ្រប់គ្រងសហគមន៍ព្រៃឈើ និងត្រូវកសាងឡើងនៅគ្រប់តំបន់ព្រៃទាំងអស់ ។ អ្នកចូលរួមក្នុងស្រុកទាំងអស់អាចបំរើជាអ្នកតាមដានឯករាជនៅក្នុងកិច្ចការព្រៃឈើនេះ ។ ការគ្រប់គ្រងនិរន្តរភាពនៃព្រៃឈើ និងការងារនូវការធ្វើចំណាត់ថ្នាក់ដោយប្រុងប្រយ័ត្ន ដើម្បីទុកជំរើសផ្សេងទៀតដល់អ្នកប្រើប្រាស់ដូចជាផលិតផលព្រៃគុប និងផលិតផលដែលមាននៅក្នុងតំបន់នោះ ។ ជំរុញការធ្វើនូវប្រព័ន្ធព្រៃសម្បទាន ការអភិវឌ្ឍន៍ផែនការគ្រប់គ្រងដោយនិរន្តរភាព រួមបញ្ចូលនូវការវាយតំលៃផលប៉ះពាល់បរិស្ថានសង្គមគួរត្រូវបានធ្វើអោយមានតម្លាភាពនៅក្នុងនោះនិងចាំបាច់ ត្រូវមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដើម្បីបង្កើនការងារនេះកាន់តែប្រសើរឡើង។ ច្បាប់ព្រៃឈើត្រូវបានពិនិត្យលើការប្រជុំគ្នាអំពីពត៌មាននៃប្រសិទ្ធិភាព និងការអនុវត្តន៍។ ប្រព័ន្ធនៃការប្រមូលថ្លៃឈ្នួល និងលិខិតអនុញ្ញាតលើការប្រមូលផល-អនុផលនៃព្រៃឈើ និងត្រូវពិនិត្យផងដែរក្នុងការប្រឹក្សាយោបល់ជាមួយអ្នកប្រើប្រាស់ក្នុងស្រុក ។ ជាងនេះទៅទៀតការប្រឹងប្រែងគួរ ធ្វើផងដែរទៅលើការជំរះឧបសគ្គ ដើម្បី

ធ្វើការផ្សព្វផ្សាយទីផ្សារអំពីផល-អនុផលនៃព្រៃឈើ (ជាពិសេសការយកជ័រ) ពីព្រោះផល-អនុផលនៃ ព្រៃឈើអាចប្រមូលផល ដោយគ្មានផលប៉ះពាល់ជាអវិជ្ជមានលើព្រៃឈើ និងកាន់តែប្រសើរថែមទៀតដល់ការ ជំរុញសេដ្ឋកិច្ចគ្រួសារនៅតាមជនបទបាន មួយកំរិតទៀត ។

## សមាសភាពសកម្មភាព

ដើម្បីសំរេចអោយបាន និងសំរបសំរួលការអនុវត្តន៍យុទ្ធសាស្ត្រដែលបានចែងខាងលើនោះ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្របានស្នើឡើងនូវកម្មវិធីសកម្មភាពចំនួន ១៦ ដែលមានទំនាក់ទំនងដោយផ្ទាល់សំរាប់វិស័យកសិកម្មដូចខាងក្រោម: (១)-ដើម្បីផ្លាស់ប្តូរទៅលើច្បាប់ដែលបានចែង តំរូវទៅលើភាពចាំបាច់បន្ទាន់នៃស្ថានភាពការងារ បច្ចុប្បន្នក្នុងនោះរួមបញ្ចូលនូវៈ ការកសាងសន្និបង្ខិលនិង ធនាគារពូជស្រូវ និងការធានាគុណភាពសំភារៈកសិកម្ម (២)-ដើម្បីពង្រឹង និងភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ច នៃការធ្វើពាណិជ្ជកម្ម និងវិនិយោគនៃគ្រប់សកម្មភាពម៉ាក្រូសេដ្ឋកិច្ចរួម ទំនិញកសិកម្មផលិតផលកែច្នៃ (៣)-ដើម្បីចងក្រងច្បាប់កសិកម្ម គោលនយោបាយ និងអភិវឌ្ឍន៍ផែនការសកម្មភាពដែលផ្តល់អត្ថប្រយោជន៍ដល់កសិករជនបទ (៤)-ការកសាង និងពង្រឹងស្ថាប័ន (៥)-ដើម្បីកំណត់អោយបានច្បាស់ និងកម្មវិធីកសាងសមត្ថភាពតាមរយៈការធ្វើវិភាគវគ្គសិក្សាចាំបាច់នៃអ្នករួមចំណែក និងកម្មវិធីសិក្សា (៦)-សកម្មភាពផ្សព្វផ្សាយកសិកម្ម (៧)-អភិវឌ្ឍន៍ប្រព័ន្ធអប់រំនៅជនបទអំពីកសិកម្មដល់ប្រជាជនកម្ពុជា ជាពិសេសយុវជនដោយរួមបញ្ចូលកម្មវិធីឥណទាន ដើម្បីអោយពួកគេអាចចាប់ផ្តើមសិប្បកម្មទ្រង់ទ្រាយតូច (៨)-ពង្រឹងការត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធទឹកដើម្បីកាត់បន្ថយភាពពឹងផ្អែកទាំងស្រុងលើលក្ខខ័ណ្ឌធម្មជាតិ (៩)-គាំទ្រដល់ការធ្វើប្រពលវប្បកម្ម និងពហុវប្បកម្មៈ កសាងកម្មវិធីសន្តិសុខស្បៀងជាលក្ខណជាតិ និងកម្មវិធីតាមខេត្ត ដើម្បីជំរុញប្រពលវប្បកម្ម និងពហុវប្បកម្មកសិដ្ឋាន និងសន្តិសុខស្បៀង (១០)-គាំទ្រដល់ផលិតកម្មបសុសត្វ (១១)-លើកទឹកចិត្តដល់ការអភិវឌ្ឍន៍ការធ្វើវារីវប្បកម្មទ្រង់ទ្រាយតូចរួមមានៈ គាំទ្រការអភិវឌ្ឍន៍ វារីវប្បកម្ម គាំទ្រការចិញ្ចឹមត្រីក្នុងស្រែ និងគាំទ្រការចិញ្ចឹមត្រីក្នុងបែ (១២)-កសាងនិងពង្រឹងសហគមន៍ព្រៃឈើ (១៣)-និរន្តរភាពសហគមន៍នេសាទអាស្រ័យការគ្រប់គ្រងធនធានជលផលនៅក្នុងអាងទន្លេមេគង្គផ្នែកខាងក្រោម និងបណ្តាខេត្តតាមតំបន់ឆ្នេរនៃប្រទេសកម្ពុជា (១៤)-ការគ្រប់គ្រងតំបន់ការពារទឹកសាប និងទឹកប្រៃនៃអាងទន្លេមេគង្គខាងក្រោម និងបណ្តាខេត្តតាមតំបន់ឆ្នេរនៃកម្ពុជា (១៥)-ប្រព័ន្ធវិភាគ និងការបង្កើនបច្ចេកទេស (១៦)-គាំទ្រដល់ផលិតផលកសិកម្មទៅក្នុងទីផ្សារ និងប្រព័ន្ធផ្សព្វផ្សាយទីផ្សារដែលផ្តល់អត្ថប្រយោជន៍ដល់កសិករ និងអ្នកផលិតនៅជនបទ ។

## ជំរុញចលនាភូមិមួយ ផលិតផលមួយ

ចលនាភូមិមួយ ផលិតផលមួយ បានកើតមាននៅកម្ពុជាតាមបណ្តាខេត្ត ស្រុកនានា ដែលសុទ្ធតែមានផលិតផលពិសេសដោយឡែករបស់ខ្លួន ក៏ប៉ុន្តែរាជរដ្ឋាភិបាលនៅពុំទាន់បានពិចារណាក្នុងការជំរុញចលនានេះអោយទៅជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍នៅឡើយ ។ សំរាប់ប្រទេសកម្ពុជា ចលនានេះអាចរៀបចំជាដំបូងនៅកំរិតថ្នាក់ខេត្តដែលហៅថា “ភូមិមួយ ផលិតផលមួយ “ មុននឹងអាចពង្រីកដល់ថ្នាក់ស្រុក និង ឃុំ ។ គន្លឹះសំខាន់នៃការអភិវឌ្ឍន៍នេះគឺ ជាការជ្រើសរើសយកផលិតផលពិសេសមួយពីរ រឺបីដែលជាផលិតផលសក្តានុពលប្រចាំខេត្ត ហើយត្រូវផ្សារភ្ជាប់នឹងលទ្ធភាពនៃហិរញ្ញវត្ថុ ការផ្ទេរនូវបច្ចេកវិទ្យា ចំណេះដឹង-ចំណេះធ្វើ ការបណ្តុះបណ្តាលធនធានមនុស្ស សំរាប់អនុវត្តន៍គំរោងការរៀបចំគុណភាពផលិតផល និងការស្វែងរកទីផ្សារសំរាប់លក់ផលិតផល

ដែលតំរូវអោយមានការលើកទឹកចិត្ត និងការចូលរួមរបស់វិស័យឯកជន តាមរយៈការទទួលបាននូវឥណទាន និងការពង្រឹងសមត្ថ-ភាពរបស់ក្រុមហ៊ុនធុនតូច និងមធ្យម ។

## ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព និងការដោះទឹក

ភាពចាំបាច់នៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និងការធ្វើអាជីវកម្មឱ្យមាននិរន្តរភាពលើធនធានទឹកជាតិជាមធ្យោបាយមួយដ៏មានសារៈសំខាន់មួយក្នុងការកាត់បន្ថយភាពក្រីក្រ ដែលកំពុងត្រូវបានគេទទួលយកយ៉ាងទូលំទូលាយ។ ការទទួលស្គាល់នូវភាពចាំបាច់របស់ធនធានទឹកនេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបង្កើតក្រសួងធនធានទឹក និងឧតុនិយមឡើងក្នុងឆ្នាំ ១៩៩៩ ដែលជាភ្នាក់ងារដឹកនាំការគ្រប់គ្រងធនធានទឹក ។ ដើម្បីគ្រប់គ្រងធនធានទឹកឱ្យបានកាន់តែល្អប្រសើរ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើការសម្របសម្រួលការវិនិយោគ (ឬការអភិវឌ្ឍន៍) នៅក្នុងវិស័យទឹកនេះ ដើម្បីធានានូវសមភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ ជៀសវាងបាននូវការប្រើប្រាស់ដោយគ្មាននិរន្តរភាព និងមិនបង្កឱ្យមានផលប៉ះពាល់នានាទៅលើធនធានទាំងអស់នេះ ដែលជាមូលហេតុបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍន៍ប្រទេសជាតិនាពេលខាងមុខ ។ បញ្ហាទាំងអស់នេះសុទ្ធតែបានលើកឡើងនៅក្នុងផែនការជាយុទ្ធសាស្ត្រ ២០០១-២០០៥ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

មានផ្ទៃដីកសិកម្មសរុបប្រមាណ ៧៥.៦ ភាគរយ គឺពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ក៏ប៉ុន្តែការប្រែប្រួលនៃរបបទឹកភ្លៀងម្តងម្កាលធ្វើឱ្យផលិតកម្មដំណាំជារឿយៗត្រូវបានទទួលការគំរាមកំហែងដោយភាពរាំងស្ងួតដោយហេតុនេះ ហើយបានជាដំណាំដាំដុះផ្សេងទៀតបន្ថែមមិនអាចធ្វើទៅរួច ។ ទោះបីជាប្រទេសកម្ពុជាមានលទ្ធភាពអាចផ្គត់ផ្គង់អាហារ បានដោយខ្លួនឯងក៏ដោយក៏សន្តិសុខស្បៀងនៅតែជាទិសដៅមួយដែលត្រូវសំរេចឱ្យបាន ។ ការស្រោចស្រពមានតួនាទី សំខាន់ណាស់នៅក្នុងការធ្វើឱ្យទិសដៅនេះអាចសំរេចបាន ដែលជាផ្នែកមួយនៃទិសដៅរួមរបស់ជាតិក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចសង្គម ។

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលសំបូរប្រភពទឹកដោយមានទន្លេមេគង្គ បឹងធំៗ និងប្រព័ន្ធផ្លូវទឹកផ្សេងៗ ទៀត ។ ទោះជាយ៉ាងនេះក៏ដោយផ្ទៃដីកសិកម្មដែលទទួលបាននូវការស្រោចស្រពនៅមានកំរិតនៅឡើយ ហើយទឹកជំនន់ដែលកើតមានប្រហែលពីរ បីឆ្នាំមុននេះបានបណ្តាលឱ្យមានការខូចខាតយ៉ាងខ្លាំងដល់សេដ្ឋកិច្ចជាតិ ។ បញ្ហាទឹកជំនន់ និងការគ្រប់គ្រងទឹកជំនន់មានការពន្យល់បន្ថែមក្នុងផ្នែក ៤.៥.៤ ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ ។

ផ្ទៃដីដែលគេទទួលស្គាល់ថាបានទទួលការស្រោចស្រពត្រូវបានគេប៉ាន់ប្រមាណថាមានតែប្រមាណ ១៩.៥ ភាគរយប៉ុណ្ណោះនៃផ្ទៃដីដាំដុះស្រូវសរុប ។ នេះគឺជាផ្ទៃដីដែលទទួលការស្រោចស្រពតាមលំនាំប្រព័ន្ធប្រឡាយតាមរយៈការបង្ហូរទឹកដោយផ្ទាល់ពីប្រភពទឹកទៅកាន់ដីស្រែតែម្តង ។ គេបានធ្វើការប៉ាន់ប្រមាណថា សក្តានុពលផ្នែករូបវ័ន្តអាចបង្កើន លទ្ធភាពនៃការស្រោចស្រពទ្វេរដង ។ ការស្រោចស្រពអាចត្រូវបានគេចាត់ថ្នាក់ជា៣ប្រភេទៈ (១) ការស្រោចស្រព បន្ថែមសំរាប់ស្រូវនៅវាលទំនាបនៅរដូវវស្សា (១២,៥%) (២) ការស្រោចស្រពបន្ថែមនៅរដូវប្រាំងដល់ស្រូវប្រដេញទឹក (៥,៨%) និង (៣) ការស្រោចស្រពនៅរដូវប្រាំងដល់ស្រូវនៅវាលទំនាប (១,២%)។

បច្ចុប្បន្ននេះផ្ទៃដីស្រោចស្រព ១៩,៥% ផលិតស្រូវបានប្រហែល ៣១,៤ % នៃផលិតកម្មស្រូវសរុបនៅកម្ពុជា ។ នេះបង្ហាញពីសារៈសំខាន់នៃការស្រោចស្រព និងផលប៉ះពាល់ទៅលើសន្តិសុខស្បៀងដែលគេសង្កេតឃើញថាមានលក្ខណៈល្អប្រសើរនៅកន្លែងណាដែលមានទឹកធ្វើស្រែ ចំការ ។ ផ្ទៃដីដាំស្រូវដែលទទួលបានការស្រោចស្រពនៅទាប ក្នុងខណៈដែលអាងមានក៏រិតនៅឡើយ ការស្រោចស្រពភាគច្រើនដំណើរការនៅរដូវវស្សាសំរាប់ផ្គត់ផ្គង់ទឹក ឬកំឡុងពេលរាំងស្ងួតនៅដើម និងនៅចុងរដូវវស្សា ។

ការស្រោចស្រពបន្ថែមគឺមានសារៈសំខាន់ជាទីបំផុតក្នុងការធ្វើឱ្យដំណាំលូតលាស់បានត្រូវពេលវេលា និងធ្វើឱ្យដំណាំឆ្លងផុតពីគ្រោះរាំងស្ងួតដែលកើតឡើងចំពេលដំណាំកំពុងលូតលាស់ ។ លើសពីនេះទៅទៀតកសិករត្រូវការឱ្យមានការកែលំអបន្ថែមដល់ការដោះទឹកជំនន់ និងទាញទឹកបញ្ចូលក្នុងស្រែចំការរបស់ពួកគេផងដែរ ។ ទាំងនេះផ្តល់ដល់កសិករ ធានាការដាំដុះដំណាំផង និងកាត់បន្ថយបាននៃការចំណាយហានិភ័យ ដែលនាំឱ្យមានការបង្កើនភាពជឿជាក់ និងទិន្នផល ។

មិនទាន់មានធារាសាស្ត្រខ្នាតធំណាមួយត្រូវបានចាប់ផ្តើមសាងសង់នៅឡើយទេ ចាប់តាំងពីគំរោងព្រែកត្នោតត្រូវបានបោះបង់នៅឆ្នាំ ១៩៧៤ ។ មានគំរោងខ្នាតមធ្យមមួយចំនួនត្រូវបានបរាជ័យចាប់តាំងពីរបបខ្មែរក្រហមត្រូវបានបញ្ចប់ ។ ភាគច្រើននៃគំរោងនេះគឺការស្តារឡើងវិញនូវគំរោងដែលបានដំណើរការនៅក្រោមរបបប៉ុលពត ដែលមិនបានរៀបចំឱ្យបានត្រឹមត្រូវនៅដំណាក់កាលទីមួយ ។ ផ្ទៃដីដ៏ធំធេងត្រូវបានទទួលរងផលប៉ះពាល់ដោយសារសមិទ្ធិផលដែលបានធ្វើក្នុង របបប៉ុលពតបានបណ្តាលឱ្យមានការកើនឡើងនូវទឹកជំនន់ និងការដោះទឹកដែលមិនត្រូតត្រាយសភាពការណ៍បាន ។

ប្រភេទគំរោងនេះ និងគំរោងចាស់ៗមួយចំនួនទៀតដែលដំណើរការពីដំបូង ប៉ុន្តែត្រូវបានខូចខាត ឬមានការខ្វះខាតមិនបានថែទាំឥឡូវនេះតំរូវឱ្យមានការស្តារសំណង់ធារាសាស្ត្រ និងការងារដីឡើងវិញ ដើម្បីបំរើឱ្យដល់ការកែលំអ ការដោះទឹក និងការពារ ទឹកជំនន់ ឬផ្គត់ផ្គង់ទឹកដល់ការស្រោចស្រពបន្ថែម ។ យោងតាមលក្ខខណ្ឌភូមិសាស្ត្រ ស្ថានភាពដី ធនធានធម្មជាតិ និងហិរញ្ញវត្ថុ ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព កម្ពុជាត្រូវបានចាត់ថ្នាក់ជាច្រើនប្រភេទដែលត្រូវបានសំរបសំរួលជាមួយតំបន់ធំៗ៣ គឺតំបន់លិច ទឹក តំបន់វាលទំនាប និងតំបន់ខ្ពង់រាប ។

**តំបន់លិចទឹក:** ចិតនៅក្នុងតំបន់ដែលងាយជន់លិចដោយទឹកទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ហើយជាទូទៅលិចលង់នៅរដូវវស្សា ។ នៅពេលដែលទឹកស្រកចុះ កសិករនាំគ្នាដាំដំណាំចំរុះ ដោយដាំតាមវិធីសាស្ត្រសាមញ្ញ ( ភាគច្រើនគឺមានទ្រង់ទ្រាយតូច) និងមធ្យោបាយងាយស្រួលដើម្បីគ្រប់គ្រងទឹក ដូចជា ប្រឡាយនាំដីល្បាប់ ប្រឡាយ ដែលនាំទឹកពីទន្លេដោយប្រើប្រាស់ម៉ាស៊ីនបូមទឹក អាងស្តុកទឹកមានទំហំតូច និងមធ្យមសំរាប់ការស្រោចស្រពបន្ថែម ជាពិសេសសំរាប់ដំណាំស្រូវប្រដេញទឹក ។ ទោះជាយ៉ាងនេះក៏ដោយ កសិករភាគច្រើនអាចប្រើប្រាស់ម៉ាស៊ីនបូមទឹកផ្ទាល់ខ្លួនដែលចិតនៅលើតំបន់នេះ ព្រោះវាអាចផ្តល់ទិន្នផលខ្ពស់ដោយដីមានជីជាតិ ។

ស្រូវឡើងទឹកក៏ដាំនៅលើតំបន់ដីលិចទឹកផងដែរ ជាពិសេសនៅជុំវិញបឹងទន្លេសាប ប៉ុន្តែស្រូវឡើងទឹកនេះប៉ះពាល់ដល់ព្រៃលិចទឹកដោយការពង្រីកផ្ទៃដីដាំដុះ ។ យោងតាមស្ថិតិកសិកម្ម ក្នុងកំឡុងពេល៧ឆ្នាំ ផ្ទៃដីដាំដុះស្រូវបណ្តែញទឹកត្រូវបានពង្រីករហូតដល់ ១៥០ ០០០ ហិកតា ( ១០០ ០០០ ហិកតា ក្នុងឆ្នាំ១៩៩៤ និង ២៥០ ០០០ ហិកតា ក្នុងឆ្នាំ ២០០១ ) ។

**តំបន់វាលទំនាប:** គឺក្លាយជាប្រធានបទសំខាន់មួយ នៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលមធ្យម និងរយៈពេលវែងរបស់រដ្ឋាភិបាល ។ ផ្ទៃដីដ៏ធំនៃដីកសិកម្មនេះ មានទីតាំងឋិតនៅចន្លោះតំបន់លិចទឹក និងតំបន់ខ្ពង់រាប តំបន់វាលទំនាបនេះមានការអភិវឌ្ឍទ្រង់ទ្រាយតូចប៉ុណ្ណោះ ពីព្រោះវាទទួលរងការខ្វះខាតធនធានទឹកនៅរដូវប្រាំង ។ បើតាមលទ្ធផលនៃការសិក្សាមុនៗរបស់គណកម្មាធិការទន្លេមេគង្គ ដែនទន្លេទាំងអស់ទាំងនៅក្នុងនិងក្រៅអាងទន្លេមេគង្គ អាចផ្តល់លទ្ធភាពស្រោចស្រពធំធេង (ច្រើនជាង ១,៥ លានហិកតា) បូករួមទាំងការបង្កើតអាងស្តុកទឹក សំរាប់ការអភិវឌ្ឍន៍វារីអគ្គិសនី ។

ផ្ទៃដីនេះមានសក្តានុពលខ្ពស់បំផុតក្នុងការឆ្លើយតបទៅនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល ការសន្យាចំពោះទីផ្សារ និងការថែរក្សាធនធានធម្មជាតិ (ការការពារផ្ទៃរងទឹកភ្លៀងទល់នឹងការបំផ្លាញព្រៃឈើនិងការហូរច្រោះដី) ។

**តំបន់ខ្ពង់រាប:** ភាគច្រើនស្ថិតនៅប៉ែកខាងជើង និងឦសាននៃប្រទេស ជាទីដែលការគ្រប់គ្រងធនធានទឹកពឹងផ្អែកភាគច្រើនលើអាកាសធាតុ ឬទឹកភ្លៀង ប៉ុន្តែទីនោះក៏មានលទ្ធភាពសាងសង់ប្រព័ន្ធស្រោចស្រពមានទ្រង់ទ្រាយតូចដែរ ដោយបង្កើតអាងស្តុកទឹកតូចៗ ដើម្បីចែកចាយការស្រោចស្រពបន្ថែមជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សា ធនធានធម្មជាតិ និងការពារការហូរច្រោះ ។

## គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព

គោលនយោបាយធនធានទឹកជាតិ គឺជាផ្នែកមួយនៃគំរោងទូលំទូលាយមួយ ដែលផ្តល់ជាមូលដ្ឋានដល់ការការពារការគ្រប់គ្រង និងការប្រើប្រាស់ទឹកសាប ទឹកប្រៃ និងធនធានទឹកសមុទ្រ ឱ្យមានលក្ខណៈនិរន្តរភាពស្មើភាព និងបំរើផលប្រយោជន៍សាធារណៈឱ្យមានប្រសិទ្ធិភាព ។ ទិសដៅរបស់គោលនយោបាយនេះគឺប្រមើលមើលជាមុន និងដោះស្រាយនូវរាល់បញ្ហាដែលស្ថាប័នបំពេញការងារក្នុងវិស័យទឹកប្រឈមមុខក្នុងកំឡុងពេល ២០ឆ្នាំខាងមុខ ហើយជួយវិស័យនេះឱ្យប្រកាន់យកនូវវិធានការសមស្របដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ។ គោលនយោបាយនេះធ្វើឡើងបន្ថែមពីលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្តីពីការការពារបរិដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិ ព្រមទាំងច្បាប់នានា និងអនុក្រឹត្យមួយចំនួន ។ វាផ្តល់ឱ្យនូវបរិបទបញ្ហាមួយរួមជាមួយនឹងយុទ្ធសាស្ត្រគ្រប់គ្រងធនធាន ទឹកជាតិដែលនឹងត្រូវបានអនុវត្ត ព្រមជាមួយនេះគោលនយោបាយតាមអនុវិស័យ និងយុទ្ធសាស្ត្រក៏ត្រូវបានរៀបចំផងដែរ។ វាច្បាស់ណាស់ថា គោលនយោបាយជាតិនេះហើយដែលនឹងដឹកនាំសកម្មភាពរបស់ក្រសួង និងភ្នាក់ងាររបស់ រដ្ឋាភិបាល ខេត្តក្រុង ផ្នែកឯកជន និងសង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍ ប្រើប្រាស់ និងគ្រប់គ្រងធនធានទឹក ដើម្បីធ្វើឱ្យសំរេចគោលដៅជាតិក្នុងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយស្ថេរភាព ។

រាជរដ្ឋាភិបាលបានបង្ហាញពីគោលដៅសំរាប់រយៈពេលវែងរបស់ខ្លួន ក្នុងការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធិភាព និងស្ថេរភាពនៅក្នុង " ចក្ខុវិស័យអំពីទឹក " នៅក្នុងប្រទេសកម្ពុជា: (១)-ការផ្តល់ឱ្យពលរដ្ឋគ្រប់រូបនូវទឹកដែលមាន សុវត្ថិភាព អាចរកបាន និងប្រកបដោយអនាម័យ (២)-ផ្តល់នូវសេរីភាពដល់ពលរដ្ឋគ្រប់រូបដោយបញ្ចៀសនូវ ការគំរាមកំហែងបាត់បង់ជីវិត និងលក្ខខណ្ឌជីវិតដែលបណ្តាលមកពីភាពចៃដន្យដែលទាក់ទងនឹងទឹក (៣)-ផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវការ ដើម្បីធានាបាននូវសន្តិសុខស្បៀង ការរស់នៅរបស់ប្រជាជន និងសកម្មភាពសេដ្ឋកិច្ច (៤)-បរិស្ថានទឹកដែលគ្មានជាតិពុល និងការទ្រទ្រង់ជីវិតនៃមច្ឆា និងប្រព័ន្ធអេកូឡូស៊ីដែលរស់នៅក្នុងទឹក ។

វិស័យទឹកនឹងរួមចំណែកធ្វើឱ្យសំរេចទិសដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលកែលំអការប្រើប្រាស់ និងការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តភាព ការការពារធនធានទឹក និងការកាត់បន្ថយ ឥទ្ធិពលនៃស្ថានភាពគ្រោះថ្នាក់ផ្សេងៗដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ។

ចាប់តាំងពីមានតួនាទីសំខាន់នៅគ្រប់វិស័យជាច្រើនរបស់សេដ្ឋកិច្ចជាតិមក វាមានការលំបាកក្នុងការផ្តល់តែមួយតំរូវទៅលើគ្រប់បញ្ហាដែលអាចកើតឡើងទទ្ទឹមនឹងនេះ វាក៏មានការលំបាកផងដែរក្នុងការកំណត់យុទ្ធសាស្ត្រតែមួយលើយុទ្ធសាស្ត្រទូទៅ ។ ដូច្នេះយុទ្ធសាស្ត្រទាំងនោះគឺ :

- ការពារជំលោះជុំវិញការប្រើប្រាស់ទឹក សំរាប់គោលបំណងច្រើនដែលនៅក្នុងតំបន់ខុសគ្នា និងបង្កើតបរិស្ថានមួយដែលឆ្លើយតបបានទៅនឹងការពេញចិត្តនៃសេចក្តីត្រូវការបច្ចុប្បន្ន និងអនាគតស្របជាមួយនឹងការការពារបរិស្ថានរួម ជាមួយនឹងការប្រើប្រាស់ និងការអភិវឌ្ឍធនធានទឹកដែលបានគ្រោងទុកក្នុងគោលបំណងផ្សេងៗ គ្នាទៅតាមចំណាត់ថ្នាក់អាទិភាពតាមរយៈផ្តល់អាជ្ញាប័ណ្ណដល់ការប្រើប្រាស់ជាមួយគូភាគីផ្សេងៗទៀត ស្របកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ១៩៩៥ ក្នុងការអនុវត្តលក្ខខណ្ឌផ្សេងៗ
- ពង្រីកដីស្រោចស្រព ពង្រីកផ្ទៃដីស្រោចស្រពដើម្បីផ្តល់ការងារ និងបង្កើនចំនួលរបស់ប្រជាជនជនបទតាមរយៈការកែលំអប្រព័ន្ធស្រោចស្រព និងកាត់បន្ថយផលប៉ះពាល់ដោយទឹកជំនន់ និងមហន្តរាយផ្សេងទៀត។ ការអភិវឌ្ឍន៍រយៈពេលខ្លី និងមធ្យមនៃការស្តារឡើងវិញនូវគំរោងស្រោចស្រពជាពិសេសនៅក្នុងតំបន់លិចទឹក និងការស្តារអាងស្តុកទឹកជាអាទិភាពមួយចំនួនដែលចិតនៅតំបន់វាលទំនាបជាមួយគ្នានេះការកសាងសមត្ថភាពនៃការធ្វើផែនការការសាងសង់ប្រតិបត្តិការ និងថែរក្សារបស់ប្រព័ន្ធ ក៏ត្រូវបានកែលំអ ។
- ប្រើប្រាស់ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលភាពរបស់ប្រទេសដែលមាន ដើម្បីបង្កើនកំរិតជីវភាពរបស់ប្រជាជនការប្រើប្រាស់ប្រាស់វត្ថុធាតុដើមកសិកម្មនៅក្នុងកសិ-ឧស្សាហកម្ម ឬឧស្សាហកម្មជាមួយនឹងការកាត់បន្ថយតំលៃចំណាយលើថាមពលអគ្គិសនីបច្ចុប្បន្ន ដែលប្រការនេះស្របទៅនឹងភាពចាំបាច់នៃការការពារបរិស្ថាន ។

គំរោងអភិវឌ្ឍន៍រយៈពេលខ្លី និងមធ្យម រួមមានការពិនិត្យឡើងវិញនូវទិន្នន័យ និងពតិមានលើការអភិវឌ្ឍន៍ធនធានទឹកនិងការវិនិយោគលើសក្តានុពលភាពក្នុងស្រុក ដើម្បីសំរេចឱ្យបាននូវការអភិវឌ្ឍទំនប់ទឹកសំរាប់ប្រើប្រាស់ក្នុងគោលបំណងច្រើនជាមួយនឹងការកំណត់វិស័យអាទិភាព ។ គំរោងអភិវឌ្ឍន៍សំរាប់រយៈពេលមធ្យម និងវែង គឺធ្វើផែនការអភិវឌ្ឍន៍ធនធានទឹកនៅក្នុងក្របខ័ណ្ឌផែនការធនធានទឹករួម ផែនការទាំនោះរួមមាន:

- ធានាស្ថេរភាពហិរញ្ញវត្ថុរបស់រចនាសម្ព័ន្ធធារាសាស្ត្រ រួមទាំងការដាក់ចេញនូវគំនិតយកថ្លៃពីអ្នកប្រើប្រាស់ទឹក ដើម្បីរ៉ាប់រងតំលៃផ្តល់សេវាថ្លៃប្រតិបត្តិការ និងថែរក្សាដោយជំរុញឱ្យមានការចូលរួមពីវិស័យឯកជនចូលរួមក្នុងការកសាងរចនាសម្ព័ន្ធធារាសាស្ត្រសំរាប់រយៈពេលខ្លី និងមធ្យម ។
- បង្កើនគុណភាពទឹក រួមទាំងទឹកនៅលើ និងនៅក្រោមដី ដើម្បីអាចបំពេញសេចក្តីត្រូវការនៅពេលបច្ចុប្បន្ន និងអនាគតនិងធានាបានថាទឹកអាចថែរក្សាជីវិតសត្វមានជីវិតរស់ក្នុងទឹក និងមច្ឆា និងការពារបាននូវសុខភាពរបស់មនុស្ស សត្វ ក្នុងរយៈពេលខ្លី និងមធ្យម ។

- បង្កើតបរិស្ថានមួយដើម្បីបញ្ចូលការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានទឹករួមទាំងការបង្កើត និងការអនុម័តក្របខ័ណ្ឌច្បាប់មួយមានលក្ខណៈតភ្ជាប់ និងគ្រប់ជ្រុងជ្រោយសំរាប់វិស័យទឹក ការសំរបសំរួលស្ថាប័នការពង្រឹងក្រសួងធនធានទឹកនិងឧតុនិយមលើមូលដ្ឋានទិន្នន័យ និងប្រព័ន្ធពតិមានដើម្បីសំរួលដល់ការគ្រប់គ្រងបរិមាណនិងគុណភាពទឹក និងពង្រឹងសមត្ថភាពរបស់ក្រសួងធនធានទឹក និងឧតុនិយមលើការគ្រប់គ្រងពតិមានធនធានទឹក ការធ្វើផែនការគំរោងប្លង់ ការប្រតិបត្តិ និងថែរក្សា និងការត្រួតពិនិត្យ ។

យោងតាមបទពិសោធន៍ពីអតីតកាលការប្រើប្រាស់គំរោងស្រោចស្រពហាក់ដូចជាមានរយៈពេលខ្លីដោយសារ តែមានការកិរិតថវិកាលើការវិនិយោគពីសំណាក់អ្នកផ្តល់ជំនួយទាំងក្នុង និងក្រៅស្រុក ដោយហេតុថាមានតែប្រព័ន្ធមេ ឬអាងស្តុកទឹកតែប៉ុណ្ណោះ (ប្រព័ន្ធមិនទាន់ពេញលេញ) ដែលត្រូវបានគេពិចារណា ចំណែកឯគំរោងតភ្ជាប់សំរាប់ធ្វើការស្រោចស្រពដទៃទៀតត្រូវបានប្រគល់ឱ្យសហគមន៍កសិករ ។ ដើម្បីធានាការប្រើប្រាស់ប្រព័ន្ធស្រោចស្រពឱ្យកាន់តែមានប្រសិទ្ធិភាពយូរត្រូវទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសលើបួនចំណុចខាងក្រោម :

**ការធ្វើឱ្យប្រសើរឡើងនូវផែនការ ការសិក្សាគ្រោងប្លង់ និងគុណភាពគ្រប់គ្រងការសាងសង់:** ចំពោះប្រព័ន្ធស្រោចស្រព មានស្រាប់ភាគច្រើន ជាពិសេសចំពោះប្រព័ន្ធដែលបានសាងសង់ក្នុងរបប ប៉ុល ពត មានឯកសារមួយចំនួនប៉ុណ្ណោះទាក់ទងទៅនឹងគំរោងផែនការស្រោចស្រព និងគំរោងប្លង់នៅមានមកទល់បច្ចុប្បន្នហើយដែលអាចយកជាការបានផងដែរ ។ ហេតុដូចនេះវាជាការពិបាកច្រើននឹងយល់បានពីផែនការដើម និងការសិក្សាគ្រោងប្លង់រៀបចំប្រព័ន្ធដែលមានស្រាប់ ។ ចំពោះការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធស្រោចស្រពដែលមានស្រាប់វាចាំបាច់ត្រូវយល់នូវលក្ខណៈភិនភាគប្រព័ន្ធនៅពេលចាប់ផ្តើមការងារ ។ ការដាក់ចេញនូវគំរោងផែនការដើម បទដ្ឋានសិក្សាគ្រោងប្លង់ និងមូលដ្ឋានពតិមានសំរាប់ការ សិក្សាបញ្ជាក់បន្ថែមណាមួយត្រូវស្វែងយល់ស្រាវជ្រាវឬសាកសួរពតិមានក្នុងទំនាក់ទំនងទៅនឹងការប្រើប្រាស់ពីមុននៃមធ្យោបាយទាំងនោះ ។ ក្នុងការតភ្ជាប់រៀបចំបង្កើតមូលដ្ឋានបទដ្ឋាន គឺជាបញ្ហាគន្លឹះមួយផ្សេងទៀតសំរាប់អនុម័ត ។ យើងមាន ២ ចំណុចដែលធានាយ៉ាងប្រាកដក្នុងការគ្រប់គ្រងសំណង់ ។ ទីមួយ គឺកសាងសមត្ថភាពនៃវិស្វករក្នុងការត្រួតពិនិត្យ និងតាមដានគុណភាព ។ មួយផ្សេងទៀត គឺការផ្លាស់ប្តូរប្រព័ន្ធតម្លៃគំរោងប៉ាន់ស្មាន ។ ឧទាហរណ៍ តម្លៃចាំបាច់ សំរាប់ការសាងសង់សំណង់ (ការគិតដល់ផលកំរៃអ្នកម៉ៅការ ) និងថ្លៃវិស្វករត្រួតពិនិត្យក្នុងគំរោង ។

**ការជំរុញ និងលើកទឹកចិត្តសហគមន៍មូលដ្ឋានឱ្យចូលរួមក្នុងការប្រតិបត្តិ និងថែទាំ:** ក្រសួងធនធានទឹក និងឧតុនិយមទទួលស្គាល់ហើយថាសារៈសំខាន់នៃបញ្ហា និងការដាក់ចេញសារាចរលេខ ០១ របស់រាជរដ្ឋាភិបាល ក្នុងការជំរុញ និងធ្វើឱ្យមាននិរន្តភាពសហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះទាមទារនូវពេលវេលាមួយដែលនឹងជួយបំប៉នដល់សតិអារម្មណ៍របស់កសិករ ហើយវាក៏មិនអាចដំណើរទៅបានទាំងអស់ក្នុងការរៀបចំបង្កើត ស.ក.ប.ទ ដោយគ្មានការអនុវត្តគំរោងពិតនិងប្រព័ន្ធពេញលេញឡើយ ។ ដូច្នេះដើម្បីធ្វើឱ្យប្រាកដប្រជានូវការប្រតិបត្តិ និងថែទាំ ក្រោយពីគំរោងបញ្ចប់ ស.ក.ប.ទ. នឹងត្រូវបង្កើតមុនការអនុវត្តគំរោងតាមសារាចរលេខ ០១ ឬយ៉ាងហោចក៏ត្រូវមានការប្តេជ្ញាចិត្តរៀបចំបង្កើត ស.ក.ប.ទ. ក្នុងជួរអ្នកដឹកនាំកសិករ និង/ឬមេឃុំជាមួយនឹងលក្ខខណ្ឌនៃការអនុវត្តន៍គំរោងផង ។

**ការជំរុញ និងការតាមដានត្រួតពិនិត្យសារពើភ័ណ្ឌ និងការអនុវត្តន៏ផែនការៈ** ដូចបានរៀបរាប់ខាងលើថវិកាមានកំណត់ដូចនេះវាមានសារៈសំខាន់ណាស់ក្នុងការជ្រើសរើសប្រសិទ្ធិភាពតម្លៃគំរោង ។ ការជ្រើសគំរោងវាមានចាំបាច់ត្រូវមានមូលដ្ឋានពតិមានរាល់ប្រព័ន្ធស្រោចស្រព ។ តាមសំណើនេះការកែលំអ និងការធ្វើឱ្យប្រសើរឡើងវិញនូវសារពើភ័ណ្ឌជាតិនៃប្រព័ន្ធស្រោចស្រពជាតម្រូវការចាំបាច់បន្ទាន់ ។

ម៉្យាងវិញទៀតដើម្បីអនុវត្តគំរោងស្រោចស្រពឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាពនោះតំរូវឱ្យមានទីប្រឹក្សាផ្តល់យោបល់ជាច្រើនទៀតពីអ្នកផ្តល់ជំនួយ និងស្នើបញ្ចូលយុទ្ធសាស្ត្ររបស់ក្រសួងធនធានទឹក និងឧតុនិយមទៅក្នុង SEDP2 (2001-2005) វាជាការសារៈសំខាន់ណាស់ក្នុងការអនុវត្តន៏ផែនការតាមគោលនយោបាយគ្រឹះ ដូចបានរៀបរាប់ខាងលើ ។ ការអនុវត្តន៏ផែនការនៅផ្សាភ្ជាប់យ៉ាងច្រើនជាងផែនការវិនិយោគសាធារណៈជាការចាំបាច់ (PIP) និងរួមបញ្ចូលទាំងឈ្មោះគំរោងទំហំតម្លៃគំរោង ការសិក្សា និងកម្មវិធីអនុវត្តន៏ ។ល។

**ការធ្វើឱ្យប្រសើរឡើងវិញនូវការសំរបសំរួលស្ថាប័នៈ** ការធ្វើឱ្យស៊ីគ្នានូវធនធានមនុស្ស និងធនធានរូបវ័ន្តចំពោះការទទួលខុសត្រូវរបស់ក្រសួងធនធានទឹក និងឧតុនិយមនោះ ក្រសួងនឹងប្រឹងប្រែងអភិវឌ្ឍន៏សមត្ថភាព ដូចជាធនធានមនុស្ស ឧបករណ៏សំភារៈជារូបវ័ន្ត និងថវិកាសំរាប់ចំណាយទៅលើការងារជាប្រចាំដែលតំរូវការអនុវត្តនូវការទទួលខុសត្រូវរបស់ខ្លួន ។ វានឹងប្រមើមើលនូវការនិយមដែលអាចកើតមានទៅអនាគត ជាពិសេសអត្រាទំនោរនៃជំនួយមូលនិធិ និងការបង្កើនឱ្យមានការចូលរួមពីសហគ្រាសឯកជន និងអ្នកទទួលផលក្នុងការប្រើប្រាស់ទឹក ព្រមទាំងការគ្រប់គ្រងសំរាប់បង្កើនសមត្ថភាពដែលនឹងតំរូវការ និងនិរន្តរភាពទៅអនាគត ។

កម្មវិធីអភិវឌ្ឍន៏មន្ត្រីនឹងត្រូវរៀបចំឡើងវិញ ដោយផ្តល់ទៅតាមជំនាញនៃការរីកចំរើននៃវិស័យផ្សេងៗ ដូចជាផែនការស្រោចស្រព និងដោះទឹកការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចការរដ្ឋបាលនៃការប្រើប្រាស់ទឹក អាជ្ញាប័ណ្ណផ្សេងៗទៀត ការប្រតិបត្តិច្បាប់ និងការផ្តល់កិច្ចគាំទ្រសហគមន៏ ។ ការអភិវឌ្ឍន៏មន្ត្រីត្រូវផ្អែកលើមូលដ្ឋានពីការវាយតម្លៃដ៏ត្រឹមត្រូវនៃតម្រូវការសមត្ថកិច្ច និងការបណ្តុះបណ្តាលដោយស៊ីគ្នាទៅនឹងសមត្ថភាពនៃនិយោជិកដែលពួកគេធ្វើកិច្ចការនោះ ។

ក្រសួងធនធានទឹក និងឧតុនិយមនឹងរិះរក និងជំរុញយន្តការផ្សេងៗ ដែលនឹងឈានដល់ការលប់បំបាត់របាំងឧបសគ្គផ្សេងៗ ដើម្បីឈានដល់ការយោគយល់គ្នា ការទំនាក់ទំនងនិងសហការគ្នាក្នុងចំណោមស្ថាប័ននានា ជាមួយនឹងការទទួលខុសត្រូវពាក់ព័ន្ធនឹងទឹក ។

ដើម្បីនឹងជួយឱ្យការប្រើប្រាស់ធនធានទឹក ការស្រោចស្រព និងការដោះទឹក ប្រកបដោយមាននិរន្តភាពយុទ្ធសាស្ត្រទូលំទូលាយមួយ សំរាប់ការចូលរួមគ្រប់គ្រងការស្រោចស្រព និងការដោះទឹករួមចូលជាមួយការប្រើនូវវិធីសាស្ត្រមួយចំនួន ដើម្បីឈានដល់ការសំរេចឱ្យបានប្រកបដោយប្រសិទ្ធិភាពខ្ពស់នូវគោលបំណងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ បញ្ហាដែលគេត្រូវនឹងបានដោះស្រាយឱ្យមានផលប្រយោជន៏ដល់អ្នកក្រីក្រ អន្តរសម្ព័ន្ធភាពរួមមានៈ

- មធ្យោបាយធានារ៉ាប់រងការគ្រប់គ្រងដែលប្រកបដោយសមត្ថភាព និងមាននិរន្តភាពលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសរយៈពេលវែងនៃព្រព័ន្ធទៅក្នុងកម្មសិទ្ធិសាធារណៈ ឧទាហរណ៏ៈ ការចូលរួមប្រតិបត្តិរបស់អ្នកពាក់ព័ន្ធក្នុងគ្រប់រូបភាពនៃការអនុវត្តន៏ប្រព័ន្ធស្រោចស្រព និងដោះទឹក ទាំងផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្តផ្សេងៗទៀត ។ល។
- ការត្រៀមជាស្រេចនូវប្រព័ន្ធដែលត្រូវផ្ទេរឱ្យសហគមន៏កសិករប្រើប្រាស់ទឹកសំរាប់កិច្ចដំណើរការ និងថែទាំ ។

- ឱ្យមានការចូលរួមពីផ្នែកឯកជនក្នុងការគាំទ្រ និងគ្រប់គ្រងប្រព័ន្ធស្រោចស្រពនិងដោះទឹកព្រមទាំងសេវាកម្មពាក់ព័ន្ធ ផ្សេង ៗ ទៀត ។

- យកចិត្តទុកដាក់ក្នុងការអនុវត្តន៍ទស្សនទានប្រកបដោយនិរន្តរភាពធារាសាស្ត្រកសិកម្មនៅកម្ពុជា ។

- ការធានានូវច្បាប់ទ្រព្យសម្បត្តិដីធ្លី និងទឹក នោះជាការលើកទឹកចិត្តដល់ការវិនិយោគបុគ្គល ។

- ការព្យាករណ៍ទុក និងការកាត់បន្ថយផលប៉ះពាល់ពីការរៀបចំប្រព័ន្ធធារាសាស្ត្រ ( ជាពិសេស ផលប៉ះពាល់ដែលត្រួតគ្នាច្រើនក្នុងប្រព័ន្ធ ) ស្តីពីធនធានទឹក និងប្រព័ន្ធអេកូឡូស៊ីទឹកសាប ។

- ផ្អែកតាមសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ការរៀបចំជាក់ស្តែងដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ទឹក ជាពិសេសចំពោះអ្នកប្រើប្រាស់ទឹកដែលមានបរិមាណតិច ដែលមានចំនួនច្រើន ។

ម៉្យាងវិញទៀតក្រសួងធនធានទឹក និងឧតុនិយមត្រូវការមានផែនការ និងស្វែងរកការវិនិយោគមូលនិធិសំរាប់ប្រព័ន្ធធារាសាស្ត្រអាទិភាពមួយចំនួន និងធ្វើការរៀបចំយ៉ាងសមរម្យដើម្បីសិក្សាគ្រោងប្លង់សាងសង់ដោយមានលក្ខណៈគ្រប់គ្រាន់ការអនុវត្តថែទាំ និងការគ្រប់គ្រង ។

គោលបំណងរបស់ក្រសួងធនធានទឹក និងឧតុនិយម មានចែងក្នុងកិច្ចព្រមព្រៀងដៃគូកាត់បន្ថយភាពក្រីក្រជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីសំដៅបង្កើនផ្ទៃដីស្រោចស្រព ពី ២០ ទៅ ២៤% នៃផ្ទៃដីដាំដុះ ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៧ ។ ផ្អែកលើមូលដ្ឋានផ្ទៃដីស្រោចស្រពបច្ចុប្បន្នមានចំនួន ៤០០.០០០ ហ.ត ចំពោះមុខដែលត្រូវពង្រីកផ្ទៃដីស្រោចស្រព និងដោះទឹកប្រមាណ ៣០០.០០០ ហ.តក្នុងមួយឆ្នាំ ។ ការប៉ាន់ស្មានតំរូវការវិនិយោគប្រមាណជា ៨៨០ ដុល្លារ/ហត សំរាប់ការស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រពរួមមានៈ ហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំសហគមន៍កសិករ ។ ការិនិយោគសរុបត្រូវការប្រមាណ ៥២ លាន ដុល្លារ ក្នុងមួយឆ្នាំ (រួមមានៈ ប្រព័ន្ធស្រោចស្រព ការដោះទឹក និងការការពារទឹកជំនន់ ) ។

កញ្ចប់ថវិកានៃគំរោងធារាសាស្ត្របច្ចុប្បន្ន សរុបប្រមាណ ៧៥ លានដុល្លារ សំរាប់ការវិនិយោគរយៈពេលខ្លីទៅ មធ្យម (រហូតដល់ឆ្នាំ២០០៦) ក្នុងនោះចំណែកហិរញ្ញវត្ថុរយៈពេលខ្លីដែលត្រូវបំពេញមានចំនួន ៨១ លានដុល្លារ។ ផែនការសកម្មភាពផ្តោតទៅលើមធ្យោបាយចាំបាច់គិតដល់គោលបំណងប្រកបដោយនិរន្តភាព ។ ជាការមិនគប្បីបន្ថយល្បឿននៃការអនុវត្តគំរោងថ្មីៗ ទន្ទឹមនឹងសមត្ថភាពស្ថាប័ន និងបច្ចេកទេសពុំបានពង្រឹងឱ្យល្មមគ្រប់គ្រាន់នៅក្នុងក្រសួងធនធានទឹក និងឧតុនិយមនោះ ។

## ផ្លូវថ្នល់ និងការដឹកជញ្ជូន

វិស័យដឹកជញ្ជូន នៅកម្ពុជា ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចផ្សេងៗទៀត បានទទួលរងការខូចខាតយ៉ាងដំណំនាសម័យសង្គ្រាម ។ ចាប់ពីឆ្នាំ ១៩៩០ រហូតដល់បច្ចុប្បន្ន រដ្ឋាភិបាលរួមជាមួយសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិបានធ្វើការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ជាមូលដ្ឋានរបស់ប្រទេសជាតិ ជាពិសេសនៅក្នុងវិស័យដឹកជញ្ជូន។ មានគំរោងជាច្រើនតាមផ្នែកដែលបានបញ្ចប់ និងក៏នៅមានការងារ និងគំរោងជាច្រើនទៀតដែលពុំទាន់បានអនុវត្តន៏។

វិស័យដឹកជញ្ជូននៅកម្ពុជា រាប់បញ្ចូលទាំងការដឹកជញ្ជូនតាមផ្លូវគោក (ផ្លូវថ្នល់) ផ្លូវដែក ផ្លូវទន្លេ កំពង់ផែ និងនាវាសមុទ្រ (ភាគច្រើននៅក្រោមការទទួលខុសត្រូវរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ហើយក្រសួងអភិវឌ្ឍន៏ជនបទ ទទួលខុស

ត្រូវលើផ្លូវជនបទ) ការដឹកជញ្ជូនផ្លូវអាកាស (នៅក្រោមការទទួលខុសត្រូវរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល) ។ ការដឹកជញ្ជូនផ្លូវគោក គឺជាប្រភេទដឹកជញ្ជូនចំបង ដែលគ្របដណ្តប់ប្រមាណជា ៦៥% នៃការដឹកជញ្ជូនអ្នកដំណើរ និងប្រមាណជា៧០% នៃការដឹកជញ្ជូនទំនិញទូទាំងប្រទេស។ សេវាកម្ម-អាជីវកម្មដឹកជញ្ជូនផ្លូវគោកភាគច្រើនអនុវត្តន៍ដោយផ្នែកឯកជន។

បណ្តាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅកម្ពុជាមាន ផ្លូវប្រភេទចំបង (ផ្លូវហាយវេតំបន់ ឬផ្លូវជាតិ) ផ្លូវប្រភេទទី២ (ផ្លូវខេត្ត) ផ្លូវប្រភេទទ៣ (ផ្លូវជនបទ ឬផ្លូវមូលដ្ឋាន) និងផ្លូវក្នុងក្រុង-ទីប្រជុំជន។ ក្រៅពីផ្លូវប្រភេទជាតិចំបងដែលបានស្តាររួចហើយ ផ្លូវថ្នល់ភាគច្រើន និងផ្លូវថ្នល់ក្នុងក្រុងមួយចំនួនមានស្ថានភាពលំបាក និងអាក្រក់បំផុតដែលមានផ្នែកខ្លះមិនអាចធ្វើចរាចរបាន។

**ការដឹកជញ្ជូនជនបទ:** បច្ចុប្បន្នប្រជាពលរដ្ឋនៅជនបទជួបប្រទះនូវការលំបាកយ៉ាងខ្លាំង ដោយពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសេវាដឹកជញ្ជូនឱ្យបានប្រសើរនៅឡើយ។ ផ្លូវថ្នល់គឺជាមធ្យោបាយសំរាប់ជួយទ្រទ្រង់ដល់ការអភិវឌ្ឍន៏តំបន់ជនបទជួយសំរួលការធ្វើដំណើររបស់ប្រជាពលរដ្ឋទៅកាន់ទីផ្សារ កន្លែងប្រកបការងារ សាលារៀន ឬមជ្ឈមណ្ឌលអប់រំ មន្ទីរពេទ្យ ឬមណ្ឌលសុខភាព ជាពិសេសក្នុងករណីសង្គ្រោះបន្ទាន់ដែលផ្សារភ្ជាប់ទៅលើអាទិភាព និងការចំណាយសមល្មមទៅលើការដឹកជញ្ជូនដែលតភ្ជាប់ទៅនឹងទីប្រជុំជន ទីក្រុងតូចៗ។ល។ ថ្មីៗ នេះតាមរយៈការសិក្សាស្តីអំពីវិស័យសេដ្ឋកិច្ច សង្គមកិច្ច ដែលធ្វើឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ ឃើញថាបន្ទាប់ពីផ្លូវជនបទបានស្តារឡើងវិញរួចរាល់ និងមានការថែទាំសមរម្យ មានកត្តាចំរើនមួយចំនួនកើតឡើងដូចខាងក្រោម:

- បរិមាណចរាចរកើនឡើងទ្វេដង លើផ្លូវជនបទ (បរិមាណយានយន្តកើនឡើង ១០% )
- បរិមាណនៃការធ្វើដំណើរពីតំបន់ជនបទ ទៅតំបន់ទីប្រជុំជន កើនឡើង ២០%
- ការចំណាយពេលវេលាក្នុងការធ្វើដំណើរត្រូវថយចុះ ៤៣ % (ចុះពីរយ:ពេល ១ ម៉ោង ទៅ ២៥នាទី )
- សោហ៊ុយចំណាយក្នុងការធ្វើដំណើរត្រូវថយចុះ ៣៨% (ពី ១០០០រៀល ចុះទៅ ៦២០រៀល)
- មានការកើនឡើងបរិមាណដឹកជញ្ជូនទំនិញនៅតាមផ្លូវជនបទ
- សកម្មភាពជំនួញ ឬពាណិជ្ជកម្ម នៅទីផ្សារជនបទកើនឡើង ៦០០% ។

ការអភិវឌ្ឍន៍ និងការថែទាំ ការដឹកជញ្ជូនជនបទ មានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជានៅជនបទ។ តែទោះជាយ៉ាងណាក៏ដោយបណ្តាញដឹកជញ្ជូនជនបទ នៅពុំទាន់គ្រប់គ្រាន់នៅឡើយ។ បច្ចុប្បន្ននេះ បណ្តាញផ្លូវជនបទមានប្រវែងប្រមាណជា ២៨ ០០០គម ដែលក្នុងនោះមានតែផ្លូវជនបទ ប្រមាណតែ ១១ ០០០គម ប៉ុណ្ណោះដែលបានស្តារ និងសាងសង់ឡើងវិញរួចហើយ (ដោយក្រាលដីធម្មតា ឬដីគ្រួសក្រហម ) ។ នៅក្នុងបណ្តាញផ្លូវ ជនបទនេះមានផ្លូវប្រមាណតែ ០.៥គម ប៉ុណ្ណោះដែលទ្រទ្រង់ សំរាប់ផ្ទៃដី ១០ គីឡូម៉ែត្រក្រឡា (១ ០០០ហិកតា) ។ ផ្លូវជនបទភាគច្រើននៅមិនអាច ធ្វើចរាចរបាននៅឡើយពិសេសនៅរដូវវស្សា។

## ការដឹកជញ្ជូនក្នុងទីក្រុង_ទីប្រជុំជន

ក្រៅពីបរិមាណប្រជាពលរដ្ឋនៅជនបទប្រមាណជា ៨០% នៃចំនួនពលរដ្ឋសរុបនៅទូទាំងប្រទេសនោះ មានការកើនឡើងប្រជាពលរដ្ឋរស់នៅតាមតំបន់ទីក្រុង-ទីប្រជុំជនធំៗ ដូចជាភ្នំពេញ បាត់ដំបង សៀមរាប និងក្រុងព្រះស៊ីហនុ ដែលមានប្រមាណ

លើសពីចំនួនពាក់កណ្តាលនៃកំណើនប្រជាពលរដ្ឋនៅទូទាំងប្រទេស។ នៅទីក្រុងភ្នំពេញ ផ្លូវថ្នល់ប្រមាណជា ៥៩% មានស្ថានភាពលំបាក និងអាក្រក់ជាខ្លាំង។ ស្ថានភាពផ្លូវដែលលំបាកនេះ ជាហេតុបណ្តាលឱ្យមានការចំណាយពេលវេលាវែងក្នុងការធ្វើដំណើរ ចំនាយលើការដឹកជញ្ជូនខ្ពស់ និងកើនឡើងគ្រោះថ្នាក់ដែលប៉ះពាល់ដោយផ្ទាល់ទៅលើពលរដ្ឋក្រីក្រ ច្រើនជាងក្រុមពលរដ្ឋផ្សេងៗទៀតនៅក្នុងសង្គម។

ផ្លូវថ្នល់ក្នុងក្រុង-ទីប្រជុំជនដែលមានស្ថានភាពលំបាកស្រាប់ទៅហើយ ត្រូវរងគ្រោះបន្ថែមទៀតពីការលិចលង់ជំនន់ទឹកភ្លៀងនៅរដូវវស្សាព្រមទាំងពុំមានសេវាកម្មដឹកជញ្ជូនគ្រប់គ្រាន់ និងមិនច្បាស់លាស់ ។ សេវាដឹកជញ្ជូនសាធារណៈភាគច្រើនដំណើរការដោយម៉ូតូឌុប ឬតាក់ស៊ី ដែលបណ្តាលឱ្យមានបញ្ហាកកស្ទះចរាចរ ការកើនឡើងអាត្រាគ្រោះថ្នាក់ចរាចរ និងការបំពុលបរិយាកាស។ ទីក្រុងធំ និងទីប្រចុំជនមួយចំនួននៅកម្ពុជានឹងប្រឈមមុខទៅនឹងបញ្ហាធំៗ ខាងចរាចរ និងការដឹកជញ្ជូនដែលពាក់ព័ន្ធ នៅក្នុងឆ្នាំខាងមុខជិតៗ ប្រសិនបើរការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាំងអស់មិនបានស្របទៅនឹងកំណើនប្រជាពលរដ្ឋ។

## ការដឹកជញ្ជូនរវាងទីក្រុង ទីប្រជុំជន និងការតភ្ជាប់នៅក្នុងតំបន់

ការចំណាយក្នុងការដឹកជញ្ជូនមានតំលៃខ្ពស់ជាងការចាំបាច់ដោយសារតែទំនិញ និងពលរដ្ឋមិនត្រូវបានដឹកជញ្ជូនដោយប្រភេទដឹកជញ្ជូន ដែលមានប្រសទ្ធិភាពខ្ពស់ខាងសេដ្ឋកិច្ច។ ការដឹកជញ្ជូនពលរដ្ឋ និងទំនិញរវាង និងក្នុងរង្វង់ខេត្ត-ក្រុង ភាគច្រើនដំណើរការដោយផ្អែកឯកជនតាមរយៈការធ្វើជីវកម្មលើរថយន្តដឹកទំនិញតូចៗ មីនីស រថយន្តភីកអ័ប រថយន្តទេសចរ និងរ៉ឺម៉កម៉ូតូ ។ ការខ្វះខាតលើការប្រកួតប្រជែងរវាងអនុវិស័យផ្សេងៗគ្នា គឺជាបញ្ហាទូទៅមួយក៏ដូចជាកង្វះខាតមន្ត្រីដែលមានការបណ្តុះបណ្តាលមន្ត្រីមានសមត្ថភាព ដើម្បីរៀបចំ និងអនុវត្តគោលនយោបាយ ដែលជាលទ្ធផលធ្វើឱ្យមានការពន្យារពេល និងលំបាកក្នុងការសំរេចចិត្ត ។ ឧបសគ្គមួយទៀត គឺការធ្វើពាណិជ្ជកម្មតំបន់រាប់ទាំងការបង់ថ្លៃក្រៅផ្លូវការ និងការចំណាយខ្ពស់ក្នុងការលើកដាក់ និងការដឹកជញ្ជូន ។

## ផ្លូវដែក

បណ្តាញផ្លូវដែកកម្ពុជា មាន២ខ្សែ ខ្សែទី១ តភ្ជាប់ភ្នំពេញ ទៅព្រំដែនកម្ពុជា-ថៃ ហើយមួយខ្សែទៀតទៅភាគខាងត្បូងភ្នំពេញទៅកាន់ក្រុងព្រះសីហនុ ។ ស្ថានភាពផ្លូវដែកមានសភាពលំបាកមធ្យោបាយ និងក្បាលម៉ាស៊ីនមានសភាពទ្រុឌទ្រោម។ ជារឿយៗ មានគ្រោះថ្នាក់ដោយមានក្បាល និងទូររថភ្លើងធ្លាក់ចេញពីផ្លូវដែក។ ជាមួយគ្នានេះសកម្មភាពសេវាកម្ម-អាជីវកម្ម នៅមានកំរិតទាបនៅឡើយ ។ បច្ចុប្បន្ននៅលេផ្លូវដែកទាំង២ខ្សែមានខ្សែរថភ្លើងត្រឹមតែ ៧ ខ្សែប៉ុណ្ណោះ ដែលដំណើរការជារៀងរាល់ថ្ងៃ។ ទោះបីជាបរិមាណទំនិញមានការកើនឡើងខ្លះៗក៏ដោយក៏បរិមាណអ្នកដំណើរត្រូវថយចុះដោយសារដំណើរការអាជីវកម្មមិនបានល្អប្រសើរ។

## កំពង់ផែ នាវាសមុទ្រ និងការដឹកជញ្ជូនផ្លូវទន្លេ

ប្រទេសកម្ពុជាមានកំពង់ផែសមុទ្រអន្តរជាតចំនួន 0២ (កំពង់ផែក្រុងព្រះស៊ីហនុ និងកំពង់ផែភ្នំពេញ) និងកំពង់ផែកោះកុង។ កំពង់ផែក្រុងព្រះស៊ីហនុបំរើឱ្យនាវាសមុទ្រធំៗ និងជាកំពង់ផែដ៏សំខាន់របស់ប្រទេស ដែលស្ថិតនៅមិនឆ្ងាយពីកំពង់ផែប្រេង

មួយ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយ បរិមាណទំនិញនាំចូលមានអត្រាកើនឡើង២ដង។ បច្ចុប្បន្នកំពង់ផែក្រុងព្រះសីហនុកំពុងពង្រីក និងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់កំពង់ផែ។

ចរាចរទំនិញនៅកំពង់ផែភ្នំពេញមានការថយចុះគួរឱ្យកត់សំគាល់។ ដើម្បីជំរុញដំណើរការអាជីវកម្មរបស់កំពង់ផែភ្នំពេញ ត្រូវទាមទារឱ្យមានការបូមស្ពារប្រឡាយនាវា ក៏ដូចជាការជំរុញឱ្យមានការចរចា និងការព្រមព្រៀងជាមួយវៀតណាមពាក់ព័ន្ធទៅលើការបង់ថ្លៃការដឹកជញ្ជូនឆ្លងកាត់។ ការចំណាយក្រៅផ្លូវការ នៅកំពង់ផែ គឺជាឧបសគ្គក្នុងការបង្កើនការប្រកួតប្រជែងការនាំចេញ និងពាណិជ្ជកម្ម (សូមអានផ្នែកពាណិជ្ជកម្មខាងក្រោម)។

ការដឹកជញ្ជូនតាមផ្លូវទន្លេធ្លាប់ជាការដឹកជញ្ជូនជាប្រពៃណាមួយក្នុងចំណោមប្រភេទដឹកជញ្ជូនសំខាន់ៗ នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែបច្ចុប្បន្នពុំមានស្ថិតិច្បាស់លាស់ណាមួយអំពីចរាចរតាមផ្លូវទន្លេ ក្រៅអំពីតួលេខកំពង់ចំលងមួយចំនួនប៉ុណ្ណោះ។ ប្រព័ន្ធផ្លូវទន្លេមានបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ដែលមានប្រវែងសរុបប្រមាណ ១៧៥០គម ។ ជំរៅទឹកមានសភាពខុសគ្នាតាមរដូវ (រដូវប្រាំង និងរដូវវស្សា)។ ការបូមស្ពារប្រឡាយនាវាគឺជាតំរូវការមួយចាំបាច់ ដើម្បីរក្សាជំរៅទឹកសំរាប់នាវាចរនៅរដូវប្រាំង។ ឧបសគ្គផ្សេងៗ ទៀតសំរាប់ការដឹកជញ្ជូនផ្លូវទន្លេមានកង្វះខាតហេដ្ឋារចនាសម្ព័ន្ធរបស់កំពង់ផែ និង និងមធ្យោបាយលើកដាក់នៅកំពង់ផែនៅទូទាំង ប្រទេសកង្វះខាតឃ្លាំង និងការចំនាយខ្ពស់ក្នុងការដឹកជញ្ជូន។

ដោយមានជំនួយពីក្រៅប្រទេសដូចជា ADB, Japan, UNDP, World Bank និងភ្នាក់ងារផ្តល់ជំនួយជាទ្វេភាគីផ្សេងទៀត និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ និងស្តារឡើងវិញបណ្តាញផ្លូវថ្នល់សំខាន់ៗ ព្រមទាំងស្ពាន និងសាឡាងចំលង ដើម្បីសំរួលការដឹកជញ្ជូនទំនិញ និងសមាហរណកម្មទីផ្សារ ។ មានទីភ្នាក់ងារផ្តល់ជំនួយមួយចំនួនបានផ្តល់ជំនួយក្នុងការស្តារឡើងវិញផ្លូវថ្នល់ក៏រិតទាប ផ្លូវជនបទ (ជាផ្លូវថ្នល់ប្រភេទទី៣ ឬក្រោមប្រភេទទី៣) ដោយបានទុកចោលឱ្យនៅចន្លោះ ក្នុងការស្តារឡើងវិញផ្លូវថ្នល់ប្រភេទទី២ ដូចជាផ្លូវខេត្តជាដើម។ ដោយសារក៏រិតតិចតួចនៃថវិកាជាតិ សំរាប់ការថែទាំផ្លូវដែលបានស្តាររួចមកហើយ ក្នុងការការពារទុកជាមុននូវការខូចខាតផ្លូវថ្នល់ គឺជាការប្រឈមមុខជាមូលដ្ឋានរបស់វិស័យដឹកជញ្ជូន។

## គោលនយោបាយ និងយុទ្ធសាស្ត្រផ្លូវថ្នល់ និងការដឹកជញ្ជូន

ទិសដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាលនៅលើវិស័យដឹកជញ្ជូន គឺផ្តល់សុវត្ថិភាព និងប្រសិទ្ធភាពលើការដឹកជញ្ជូនដោយសោហ៊ុយចំណាយទាបសមរម្យ នៅក្នុងទីក្រុងធំៗ ក៏ដូចជាក្នុងទីប្រជុំជន និងសហគមន៍ជនបទ ដែលអាទិភាពត្រូវបានផ្តល់ឱ្យទៅការដឹកជញ្ជូនប្រជាពលរដ្ឋ ច្រើនជាងការបង្កើនបរិមាណយានយន្ត។ តែទោះជាយ៉ាងណាក៏ដោយកម្ពុជានៅពុំទាន់មានរៀបចំ និងអនុម័តគោលនយោបាយផ្លូវថ្នល់ និងការដឹកជញ្ជូននៅឡើយ។

ក្រសួងស្ថាប័នខាងដឹកជញ្ជូនត្រូវមានយុទ្ធសាស្ត្ររបស់ខ្លួនមួយ ជាពិសេសសំរាប់ការវិនិយោគលើផ្លូវថ្នល់។ ប៉ុន្តែកង្វះខាតទិសដៅ ជាគោលនយោបាយច្បាស់លាស់មួយបានធ្វើឱ្យមិនមានការយកចិត្តទុកដាក់ទៅលើការថែទាំ និងការផ្តល់ថវិកាមិនមានប្រសិទ្ធភាពសំរាប់វិស័យដឹកជញ្ជូន (ទាំងថវិកាជាតិ និងទាំងជំនួយបរទេស)។ បញ្ហាសំខាន់សំរាប់វិស័យដឹកជញ្ជូន គឺកង្វះខាតយន្តការការគ្រប់គ្រង និងហិរញ្ញប្បទានដ៏ពិតប្រាកដមួយសំរាប់ការថែទាំផ្លូវថ្នល់ ការប្រមែប្រមូលការចំណាយសាធារណៈនៅក្នុង

វិស័យដឹកជញ្ជូន ការបង្កើនឡើងនូវតំលាភាព ទំនាក់ទំនងនិងការបែងចែកតួនាទីច្បាស់លាស់រវាងស្ថាប័នក្នុងការគ្រប់គ្រងថវិកាថែទាំផ្លូវថ្នល់ និងការចូលរួមរបស់ផ្នែកឯកជន។

នាពេលបច្ចុប្បន្ន ការសំរេចចិត្តលើការវិនិយោគធ្វើឡើង និងផ្តល់របៀបជាកិច្ចសន្យាដោយអាជ្ញាធរផ្សេងពីក្រសួងស្ថាប័នដែលទទួលខុសត្រូវការដឹកជញ្ជូន ដែលទទួលបានត្រឹមតែចំណែកជាតួលេខ អំពីបែងចែកថវិកាជាផ្លូវការរបស់ខ្លួនតែប៉ុណ្ណោះ។ ស្ថាប័នដែលទទួលខុសត្រូវក្នុងការដឹកជញ្ជូនមិនអាចរៀបចំផែនការ និងគ្រប់គ្រងទ្រព្យសម្បត្តិជាតិខាងផ្លូវថ្នល់បានទេ។

យុទ្ធសាស្ត្រនៃការដឹកជញ្ជូនជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ មានគោលបំណងបង្កើនការធ្វើដំណើរនៅជនបទដោយផ្តល់អាទិភាពទៅលើការថែទាំ តាមតំលៃដែលមានប្រសិទ្ធភាព និងការស្តារឡើងវិញផ្លូវជនបទ និងការលើកទឹកចិត្តក្នុងការប្រើប្រាស់បច្ចេកវិជ្ជាពលករជាមូលដ្ឋានដ៏សមរម្យដោយមានការចូលរួមពីផ្នែកឯកជនក្នុងមូលដ្ឋាន (អ្នកម៉ៅការតូច និងមធ្យម) ក្នុងការប្រតិបត្តិការងារនេះ។

យុទ្ធសាស្ត្រនៃការស្តារឡើងវិញផ្លូវថ្នល់របស់ក្រសួងសាធារណការ និងដឹកជញ្ជូនគឺស្វែងរកការពង្រឹងការតភ្ជាប់រវាងតំបន់ធំៗចំនួន ០៣ ដែលបែងចែកប្រទេសជាតំបន់ ឬត្រីកោណសំរាប់បំរើឱ្យដំណើរការដឹកជញ្ជូនៈ (១) តំបន់ទេសចរណ៍ ដែលកំណត់ដោយត្រីកោណសៀមរាប-ព្រះវិហារ និងកំពង់ធំ (២) តំបន់ឧស្សាហកម្មដែលកំណត់ដោយតំបន់ឆ្នេរសមុទ្រភាគខាងត្បូងប្រទេសទាំងមូល និង (៣) តំបន់កសិ-ឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិ គ្របដណ្តប់តំបន់ខាងកើតទន្លេមេគង្គ រាប់ទាំងរតនគិរី និងមណ្ឌលគិរី។

## សកម្មភាពសាធារណៈខាងអាទិភាព

អាទិភាពទី១ នៃវិស័យដឹកជញ្ជូនគឺថែទាំ និងអភិវឌ្ឍន៍អនុវិស័យផ្លូវថ្នល់ ដែលជាប្រភេទនាំមុខគេក្នុងការដឹកជញ្ជូននៅកម្ពុជា និងជាប្រភេទនៃការដឹកជញ្ជូនមួយដែលមានចំណងទាក់ទងដោយផ្ទាល់ទៅលើជនក្រីក្រ។ ប៉ុន្តែវាទាមទារសកម្មភាពដើម្បីធានាថាវិស័យដឹកជញ្ជូនចូលរួមចំណែកប្រកបដោយប្រសិទ្ធភាព ទៅលើកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រដោយផ្តល់អាទិភាពទៅលើការចំណាយការងារស៊ីវិល។ សកម្មភាពជាតំរូវការចាំបាច់មួយចំនួនមានដូចខាងក្រោមៈ

- ធនធានគ្រប់គ្រាន់ មិនប្រែប្រួល និងច្បាស់លាស់នូវមូលនិធិសំរាប់ការថែទាំផ្លូវថ្នល់ (ផ្លូវថ្នល់ទាំងអស់ដែលស្ថិតនៅក្នុងស្ថានភាពត្រូវការ ការថែទាំ គឺជាទ្រព្យសម្បត្តិសាធារណៈ)
- ការគ្រប់គ្រងដោយតំលាភាព នូវរាល់មូលនិធិសាធារណៈ សំរាប់វិស័យដឹកជញ្ជូន
- ការធ្វើឱ្យប្រសើរឡើង និងជួសជុលផ្លូវជនបទ ផ្លូវខេត្ត និងផ្លូវជាតិ
- ការប្រកួតប្រជែងក្នុងការដេញថ្លៃ សំរាប់រាល់បញ្ហាកិច្ចសន្យាសាងសង់ ដែលប្រើប្រាស់ថវិកាជាតិ និងជំនួយបរទេសដោយភ្ជាប់ផ្នែកសាធារណៈ ជាមួយផ្នែកឯកជន មូលដ្ឋាន និងសង្គមស៊ីវិល។
- កម្មវិធីមួយសំរាប់ពង្រឹងស្ថាប័ន និងការកសាងសមត្ថភាព នៅគ្រប់កំរិតនៅក្នុងស្ថាប័នដឹកជញ្ជូនសាធារណៈ
- អនុម័តនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់តាមផ្នែក ក្នុងការគាំទ្រយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

- ការជំរុញសេវាដឹកជញ្ជូនសាធារណៈ ដោយប្រើប្រាស់ចំណាយទាប និងរៀបចំឱ្យមាន "សេវានីសាន់ រឺ សេវាហ្សិប" (ឡាំប្រីតា) ដោយផ្នែកឯកជន ។
- ការអភិវឌ្ឍន៍ និងពង្រឹងការតភ្ជាប់ក្នុងតំបន់ (ASEAN ឬ Asia ) ក្នុងការសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនជាមួយវៀតណាម និងថៃឡង់
- បង្កើនការចូលរួមរបស់ផ្នែកឯកជន ក្នុងវិស័យកំពង់ផែ និងការគ្រប់គ្រងផ្លូវដែក និងតំលាភាពនៅក្នុងការគ្រប់គ្រងកំពង់ផែ និងសម្បទានហេដ្ឋារចនាសម្ព័ន្ធ ។
- សំរួលការដឹកជញ្ជូនខាងក្នុងប្រទេស តាមរយៈការសាងសង់ជាអប្បរមា មធ្យោបាយផែ និងសំរួលការចូលចតនៅកំពង់ផែ ។

## ៤.២ ការពង្រីកកាលានុវត្តភាពការងារ

ប្រហែលបីភាគបួននៃការងារនៅកម្ពុជា ស្ថិតក្នុងសកម្មភាពជាច្រើនដែលទាក់ទង នឹងវិស័យវិស័យកសិកម្ម ។ ទន្ទឹមពេលគ្នានេះដែរ កសិកម្មមានសារៈសំខាន់សំរាប់រាជរដ្ឋាភិបាលកម្ពុជាទ្រទ្រង់ការអភិវឌ្ឍន៍វិស័យកសិកម្មពីខាងក្រៅ, ដើម្បីអាចធ្វើទៅបាននូវចំណូលផ្សេងៗគ្នា និងចំណូលនានាប្រសើរឡើងចំពោះការងារ ។ ក្នុងតំបន់ជនបទ និងទីក្រុង ជនក្រីក្រភាគច្រើនកំពុងធ្វើការដោយចំណាយពេលច្រើនម៉ោងហើយទទួលបានចំណូលទាប, លទ្ធភាពផលិតកម្មនៅទាប និងសុវត្ថិភាពមានកំណត់ ។ ដូចអង្គការពលកម្មអន្តរជាតិបានបញ្ជាក់ក្នុងការផ្តល់យោបល់ជាច្រើនរបស់គេ, ការបង្កើនប្រាក់ចំណូលពីការងារ និងការកែលំអលក្ខខណ្ឌការងារគឺជាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ ។

### ៤.២.១ ការអភិវឌ្ឍន៍ផ្នែកឯកជន

ផ្នែកឯកជនក្នុងប្រទេសកម្ពុជាត្រូវបានគេពិពណ៌នាដូចជាយន្តការនៃការរីកចំរើន ។ ផ្នែកឯកជនផ្តល់ការងារច្រើនជាងគេបំផុត និងការបែងចែកផ្លែផ្ការយៈពេលវែងដើម្បីអភិវឌ្ឍប្រទេសកម្ពុជា ។ ឧបសគ្គចំពោះផ្នែកឯកជនមាន តែភាគច្រើននៃឧបសគ្គទាំងនេះវាបានធ្វើអោយរាំងស្ទះផ្នែកផ្សេងៗ ទៀតក្នុងយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ ដោយនាំទៅរកការកាត់បន្ថយការវិនិយោគទុន និងការងារកាន់តែតិចទៅៗ ។ ផ្នែកនេះត្រូវធ្វើការពិនិត្យពិច្ច័យអោយបានត្រឹមត្រូវនូវឧបសគ្គជាទូទៅដែលរារាំងសកម្មភាពផ្នែកឯកជន ហើយដាក់ចេញផងដែរនូវការរៀបចំគោលនយោបាយឧស្សាហកម្មរបស់រដ្ឋាភិបាល ដើម្បីជួយទ្រទ្រង់អ្នកក្រ អោយមានជីវៈភាពរស់នៅសមរម្យឡើង ។

ផ្នែកឯកជនមានមូលដ្ឋាននូវសហគ្រិនសំខាន់ៗ ក្រៅផ្លូវការ សហគ្រាសធុនមធ្យម និងតូចជាច្រើន ដូចគ្នាដែលក៏មានក្រុមហ៊ុនអន្តរជាតិមួយចំនួន កំពុងធ្វើមានសកម្មភាពពាណិជ្ជកម្មយ៉ាងសកម្មក្នុងកម្ពុជា ។ តាំងពីឆ្នាំ ១៩៩១ ការកើនឡើងសកម្មភាពរកស៊ីបានផ្តល់នូវភស្តុតាងយ៉ាងច្បាស់លាស់ថាសង្គមកម្ពុជាកំពុងផ្លាស់ប្តូរទិសដៅ ដោយចេញពីការវិលចុះឡើងនៃសង្គ្រាមបំផ្លាញហិនហោច ។ វត្តមាននៃឧស្សាហកម្មវាយនភ័ណ្ឌពាក់កណ្តាលទស្សវត្ស ឆ្នាំ ១៩៩០ និងការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃវិស័យឧស្សហកម្មទេសចរណ៍ (ផ្នែក ៤.៣.៣ ) បានផ្តល់នូវចំណូលកើនឡើង (ផ្នែក ៤.១.១ ) ដែលនូវការងារធ្វើជាច្រើនអោយជនកម្ពុជារាប់ពាន់នាក់ ។

ការសិក្សាលើគំរោងវិនិយោគមួយចំនួន បានទទួលស្គាល់ថាមានឧបសគ្គច្រើនចំពោះការអភិវឌ្ឍន៏វិស័យឯកជនអោយរីកចំរើនដូចជា ហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្តនៅខ្សោយ ការចំណាយដឹកជញ្ជូនខ្ពស់ ចំណាយអគ្គីសនីនិងទូរគមនាគមន៏នៅខ្ពស់ សុវត្ថិភាព និងការគោរពកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ធនធានមនុស្សនៅមានកំរិត ការកើនឡើងតំលៃពលកម្ម ការចំណាយចាត់ចែងកិច្ចការខ្ពស់ និងពុំទាន់មានប្រព័ន្ធច្បាប់និងតុលាការសមស្រប ។

ការលើកទឹកចិត្តយ៉ាងពិសេសអោយមានការអភិវឌ្ឍន៏សហគ្រាសតូច និងមធ្យមច្រើនក្នុងកន្លែងដែលមានមនុស្សណែនណាន់តាន់តាប់មាន ទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ សៀមរាប និងបាត់ដំបង ដោយស្នើអោយម្ចាស់សហគ្រាសក្នុងតំបន់ទាំងនេះមានឆន្ទះហ៊ានទទួលយកគ្រោះប្រថុយប្រថាននានា ដោយមានការជួយឧបត្ថម្ភមូលនិធិពីអ្នកផ្តល់ជំនួយ ។ ដូច្នេះក្រុមហ៊ុនទាំងនេះធ្វើប្រតិបត្តិការក្នុងបរិស្ថាននៃការអភិវឌ្ឍន៏មានស្ថេរភាពកំណត់មួយ និងមានការចាត់ថ្នាក់ ឬពុំមានគ្រឿងជួយដោះស្រាយពីតុលាការ ។ ហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ ទឹក និងអគ្គីសនីនៅថ្លៃ ហើយការថែរក្សាក៏នៅខ្សោយ ។ សិទ្ធិដើម្បីទទួលឥណទាននៅមានកំណត់ដោយអត្រាការប្រាក់ខ្ពស់ពីវិទ្យាស្ថានផ្លូវការនានា ឬការខ្ចីធនធានពីបងប្អូន និងមិត្តភក្តិនៅមានកំណត់ ។ ការពុំមានកំណែទំរង់ដីធ្លី និងការចាត់ថ្នាក់ដីធ្លីអោយបានច្បាស់លាស់ ក៏បានកំណត់ការរីកចំរើនក្នុងផ្នែកនេះផងដែរ ។

## នយោបាយ និងយុទ្ធសាស្ត្រដើម្បីជំរុញការអភិវឌ្ឍន៍ផ្នែកឯកជន

ទោះបីអ្នកវិនិយោគបទេសបានត្រូវគេស្វាគមន៏ក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ក្នុងបរិស្ថាននៃការធ្វើជំនួញអន្តរជាតិដែលមានការប្រកួតប្រជែងកើនឡើង ធ្វើអោយជំនួញមកពីបរទេសហូរចូលមានចលនាយឺត។ ដោយសារតែមូលហេតុផ្សេង។ ។ ការប្រកួតប្រជែងនៃបណ្តាប្រទេសជិតខាង ក្នុងពាក្យពេចន៏នៃកំណែទំរង់ច្បាប់ តុលាការគួរអោយជឿជាក់បាន និងប្រើប្រាស់ចំណាយធ្លាក់ចុះមានន័យថាកម្ពុជាត្រូវតែខិតខំធ្វើការទ្វេឡើងចំពោះការចាប់ផ្តើមបង្កើត និងការអនុវត្តន៏កំណែទំរង់ច្បាប់ក្នុងវិស័យនេះ ។ ការចំណាយនៃការចុះបញ្ជីធ្វើជំនួញថ្មី។ ដោយស្របច្បាប់ក៏នៅតែជាកត្តារុញច្រានសំរាប់អ្នកវិនិយោគទុនផងដែរ ។

ការកំណែទំរង់ច្បាប់និងតុលាការដែលទាក់ទងនឹងផ្នែកឯកជន ត្រូវបានគេធ្វើឡើងអោយទាក់ទងផ្នែកខាងក្នុងទៅនឹងការវិនិយោគទុន ។ ការគ្មានឧបករណ៏ជំនួយដើម្បីអាចអនុវត្តច្បាប់ ធ្វើអោយក្រុមហ៊ុនបរទេសប្រឈមមុខនឹងភាពប្រថុយប្រថានយ៉ាងធំធេងនៅលាយលំជាមួយការវិនិយោគ ។ ចំពោះក្រុមហ៊ុនក្នុងស្រុកជាច្រើន ការធ្វើវិនិយោគក្នុងកម្ពុជាមានន័យថា ពួកគេយល់ព្រមទទួលការខូចខាតនឹងអំពើពុករលួយ ពីសំណាក់អ្នកប្រកួតប្រជែងនានា និងពីមន្ត្រីរដ្ឋាភិបាល ។ ក្របខ័ណ្ឌការងារច្បាប់រឹងមាំមួយ និងតុលាការមួយ (ផ្នែក ៤.៤ ) ដែលនឹងផ្តល់យុត្តិធមិ និងការសំរេចចិត្តដោយស្មើភាព លើបញ្ហាទាក់ទងនឹងជំលោះការធ្វើជំនួញនិងការធ្វើជំនួញ និងជំលោះរវាងរដ្ឋាភិបាលនឹងការធ្វើជំនួញ នឹងជំរុញផ្នែកឯកជនអោយមានជំនឿជឿជាក់ ។

ការចំណាយនៃការធ្វើក្នុងប្រទេសកម្ពុជាទាក់ទងមិនត្រឹមតែចំពោះឧបករណ៏ប្រើប្រាស់ផ្សេង។ ប៉ុណ្ណោះទេ ប៉ុន្តែចំណាយលើការចាត់ចែងកិច្ចការក្រៅផ្លូវការផងដែរ ។ ចំណាយអាថិកំបាំងនៅឯកំពុងផែមានន័យថា ចំណាយការនាំចូលទំនិញមួយកុងតឺន័រ មកពីអឺរុបទៅ ក្រុងព្រះសីហនុ មានតំលៃទឹកប្រាក់ដូចគ្នានិងការដឹកទំនិញមួយកុងតឺន័រ ពីក្រុងព្រះសីហនុ ទៅភ្នំពេញតាមផ្លូវជាតិលេខ៤ ។

ចំណូលពីការប្រមូលពន្ធកំពុងត្រូវបានគេធ្វើមានការខាតបង់ច្រើន ដោយរោងចក្រ សហគ្រាសមួយចំនួនធំ រាប់បញ្ចូលទាំងការរត់ពន្ធ ឆ្លងព្រំដែន ហើយមូលដ្ឋានពន្ធអាករប្រែជារូមតូច ។ មូលដ្ឋានពន្ធអាករប្រែជារួមតូចបានបញ្ជាក់ដោយបណ្តា

ក្រុមហ៊ុនដែលមិនបានចុះបញ្ជី កំពុងតែចំណាយក្រៅផ្លូវការសំរាប់មន្ត្រីរដ្ឋាភិបាល ។ គ្រប់ក្រុមហ៊ុនដែលមិនបានចុះបញ្ជីជាញឹកញាប់កំពុងទូទាត់ថ្លៃពន្ធអាករនានាលើមូលដ្ឋានក្រៅផ្លូវការ ។ ការធ្វើអោយទូលំទូលាយនៃមូលដ្ឋានអាករ និងធ្វើការផ្តាច់ចេញពីកងចក្រនៃប្រព័ន្ធពន្ធអាករពីរផ្នែកមួយផ្លូវការ ឬក្រៅផ្លូវការនឹងប្រព្រឹត្តទៅលើចំងាយផ្លូវដ៏វែងឆ្ងាយមួយ សំដៅទៅរកការទ្រទ្រង់ការអភិវឌ្ឍន៏ផ្នែកឯកជនក្នុងកម្ពុជា ។

រចនាសម្ព័ន្ធពន្ធអាករតាមខ្សែបណ្តោយមានស្រាប់ក្នុងកម្ពុជា ជាទីកន្លែងចំនួននៃការធ្វើជំនួញដែលបាន ចុះបញ្ជីបច្ចុប្បន្នមិនបានឆ្លុះបញ្ចាំងអោយឃើញនូវចំនួននៃការធ្វើជំនួញទេ ។ ដើម្បីទ្រទ្រង់ដល់រចនាសម្ព័ន្ធស៊ីវិល និងបំណុលរបស់រដ្ឋាភិបាលពឹងផ្អែកលើការធ្វើពាណិជកម្មចំនួនច្រើនដូចគ្នានេះដែរ ។ ទាំងពីរនេះគ្មានទាំងនិរន្តភាព និងគ្មានទាំងតួនាទីតួជាទីពេញចិត្តចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាអ្នកកំពុងតែខាតបង់ចំណូល មូលដ្ឋានពន្ធអាករដែលបានចុះបញ្ជីត្រឹមត្រូវមិនមានតួនាទីតាមក៏រិតមួយនៅនឹងកន្លែង ឬពាណិជ្ជកម្មដែលមិនបានចុះបញ្ជីកំពុងតែចំណាយពន្ធអាករក្រៅផ្លូវការ គឺមិនមានផលប្រយោជន៏មកពីសមាជិករបស់សហគមន៏ពាណិជកម្មដែលបានទទួលស្គាល់រួចហើយ ។ ការប្រព្រឹត្តទៅតាមរចនាសម្ព័ន្ធដែលបានគ្រោងទុកត្រូវបានគេអនុវត្តអោយជិតស្និទ្ធរវាងគំលាតចំណូល និងការប្រកួតប្រជែង ដែលមានស្រាប់នៅក្នុងរចនាសម្ព័ន្ធការចំណាយពន្ធអាករក្នុងកម្ពុជា កំណែទំរង់នានានៅក្នុងវិស័យនេះត្រូវបានគេបង្ហាញក្នុងជំពូកទី ៥ ។

## ៤.២.២ ការអភិវឌ្ឍន៍ពាណិជ្ជកម្ម

រាជរដ្ឋាភិបាលបានបញ្ជាក់ថាពាណិជ្ជកម្ម គឺជាធាតុផ្សំដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយមានការយល់ព្រមពីគណរដ្ឋមន្ត្រីនូវវិធីសាស្ត្រអភិវឌ្ឍន៏ពាណិជ្ជកម្មដល់អ្នកក្រីក្រនៅខែកុម្ភៈ ឆ្នាំ ២០០១ ហើយបានបង្ហាញដល់សហគមន៏អ្នកផ្តល់ជំនួយនៅទីក្រុងតូក្យូ ខែមិថុនាឆ្នាំនេះដែរ។ ក្រសួងពាណិជ្ជកម្មមានអនុក្រិត្យ ដើម្បីកំណត់គោលដៅវិធីសាស្ត្រដោយធ្វើការឆ្លងកាត់ថ្នាក់ដឹកនាំគណកម្មាធិការអន្តរក្រសួង។

វិធីសាស្ត្រអភិវឌ្ឍន៏ពាណិជ្ជកម្ម ដល់អ្នកក្រីក្រចាំបាច់ត្រូវរួមបញ្ចូលទាំងអស់ និងបង្កើនឡើងការបើកចំហរ ប្រព័ន្ធពាណិជ្ជកម្មពិភពលោក និងដំណើរការចូលអង្គការពាណិជ្ជកម្មពិភពលោក គឺជាការជឿនលឿនល្អបំផុត ។ ទោះយ៉ាងណាក៏ដោយការយល់ព្រមចូលអង្គការពាណិជ្ជកម្មពិភពលោកតំរូវអោយមានតំរូវការយ៉ាងច្រើន សំរាប់ប្រទេសតូចដែលកំពុងអភិវឌ្ឍន៏ ដូចជាប្រទេសកម្ពុជា ហើយត្រូវការយ៉ាងច្រើន អ្នកជំនួយការបច្ចេកទេសនៅគ្រប់តំបន់ដូចជា គំរោងច្បាប់និតិបញ្ញត្តិ, នីតិវិធីប៉ាន់តំលៃ, វិធីសាស្ត្រប៉ាន់តំលៃពាណិជ្ជកម្ម និងរបាយការណ៏ ដែលប៉ាន់ប្រមាណនូវផលប៉ះពាល់ ដល់ការការពារពាណិជ្ជកម្ម។

ការគាំទ្រក៏ត្រូវការផងដែរនូវការធ្វើអោយប្រសើរឡើងការប្រកួតប្រជែងឧស្សាហកម្មកម្ពុជាក្នុងពិភពទីផ្សារ។ ជំនួយការ ដល់អ្នកផ្តល់ជំនួយនៃក្រុមគំរោងរួមបញ្ចូលគ្នាគឺ (IMF, ITC, UNCTAD, UNDP, World Bank, &WTO) និងដៃគូអភិវឌ្ឍន៏ផ្សេងទៀត រាជរដ្ឋាភិបាលបានបញ្ជាក់ និងផ្សព្វផ្សាយការសិក្សាវិនិច្ឆ័យ ពីការប្រកួត ប្រជែងពាណិជ្ជកម្មកម្ពុជាដោយផ្អែកលើការអភិវឌ្ឍន៏ក្នុងគោលនយោបាយពាណិជ្ជកម្ម (របាំងពាណិជ្ជកម្ម សមាជិកអាស៊ាន ភាពក្រីក្រ និងឥទ្ធិពលផ្សេងទៀតនៃពន្ធនាំចេញនាំចូល និងការចូលអង្គការពាណិជ្ជកម្មពិភពលោក) និងការប្រមូលផ្តែកសិក្សា (ការផលិតស្រូវ ទីផ្សារកសិកម្មផ្សេងទៀត និងដំណើកេ្សត្រវិទ្យា សិប្បកម្ម ទឹកស្អាត នេសាទ រោងចក្រ ទេសចរណ៏ និងសេវាពលកម្ម)។ គោលដៅអ្នកជំនួយការបច្ចេកទេស តំរូវអោយអនុភាពពាណិជ្ជកម្ម អ្នកក្រីក្រគឺបានអភិវឌ្ឍន៏ដែល នៅជួរបន្ទាត់គោលនយោបាយ

កម្មវិធី និងសមត្ថភាពសាងសង់ដំបូង និងតំរូវការប្រភពរបស់ពួកគេ។ របាយការណ៍អាចរកបាននៅក្រសួងពាណិជ្ជកម្ម website at (www.moc.gov.kh)

នៅទសវត្សមុន ពាណិជ្ជកម្មកម្ពុជានិងការនាំចេញមានការកើនឡើងគួរអោយកត់សំគាល់ ទាំងផលិតផល (ជលផល, ឈើហ៊ុប, កៅស៊ូ, សេវាពលកម្ម) និងកាត់ដេរ និងទេសចរណ៍ ឧទាហរណ៍ ការនាំចេញក្នុងស្រុកនៅឆ្នាំ ២០០១ ចំនួន ១.១៩៨,៨ លានដុល្លា ហើយកើនឡើង ១០ ភាគរយនៅឆ្នាំ ២០០០។ គន្លឹះដើម្បីអោយកើនឡើង គឺបង្កើន ១៣ភាគរយ នៃការនាំចេញដោយធ្វើតាមប្រព័ន្ធទូទៅមួយ។ រក្សាការកើន ការនាំចូលអោយនៅត្រឹម ៥,២ ភាគរយក្នុងឆ្នាំ ២០០១។

ការបង្អាប់បញ្ហាជាច្រើនដើម្បីអោយពាណិជ្ជកម្មរីកចំរើនរួមមាន បញ្ហាម៉ាក្រូនៃប្រពន្ធពាណិជ្ជកម្មទូទៅ, ច្បាប់នៅកម្ពុជាខ្សោយ, ប្រព័ន្ធយុត្តិធម៌ និងរដ្ឋបាល, ខ្វះហេដ្ឋារចនាសម្ព័ន្ធ ខ្វះអ្នកបច្ចេកទេស និងសមត្ថភាពហិរញ្ញវត្ថុ និងខ្វះសមត្ថភាពអភិវឌ្ឍន៍ធនធានមនុស្ស ពិសេសស្ថាប័នឯកជន និងកម្មករជំនាញ។

រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមកម្មវិធីយ៉ាងទូលាយមួយនៃការកែទំរង់គោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។ វិស័យសំខាន់ៗ រួមមានការកែទំរង់នៃសារពើពន្ធ ដូចជាការកែប្រែរចនាសម្ព័ន្ធផ្នែកធនាគារ ការកែទំរង់សេវាកម្មស៊ីវិល និងធ្វើឱ្យប្រសើរឡើងនូវការងារអភិបាលកិច្ច។ មានការងារជាច្រើនដែលបានសំរេច ក៏ប៉ុន្តែក៏នៅមានការងារជាច្រើន ទៀតដែលត្រូវធ្វើ។ ការដាក់កំរិតបរិមាណទាំងឡាយលើពាណិជ្ជកម្មត្រូវបានលប់បំបាត់នៅក្នុងឆ្នាំ ១៩៩៤។ របបពន្ធគយ បានកែទំរង់ម្តងទៀតកាលពីខែ មេសា ឆ្នាំ ២០០១។ អត្រាខ្ពស់ត្រូវបានបញ្ចុះពី ១២០ ភាគរយទៅ ៣៥ភាគរយ ។ ជាបន្ថែមប្រព័ន្ធនេះត្រូវបានធ្វើឱ្យងាយស្រួលដោយចំនួននៃក្រុមខ្លះត្រូវបានកាត់បន្ថយពី ១២ មកត្រឹម ៤ ភាគរយ ស្របគ្នានេះ ដែរពន្ធពិសេសត្រូវបានដាក់តំឡើងលើផលិតផលពិសេសៗ។ នេះមានន័យថា ចំណូលនានា គួរតែរក្សាដោយគ្មានការផ្តល់ការយកចិត្តទុកដាក់ការពារខ្ពស់ដល់ផលិតផលទាំងអស់នេះទេ ។ បើប្រៀបធៀបជាមួយបណ្តាប្រទេសក្នុងតំបន់ការនាំចេញរបស់ប្រទេសកម្ពុជា មានរបបពាណិជ្ជកម្មជាចំហ។

ការគ្រប់គ្រងរបស់គយនិងរដ្ឋាករ បានកែលំអយ៉ាងច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗ នេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ការបង្កើតឱ្យមានថ្លៃទាបមួយ នៃប្រព័ន្ធពាណិជ្ជកម្មងាយស្រួលជាផ្លូវការតែងតែជួបប្រទះការលំបាកជាច្រើន។ កិច្ចការ រដ្ឋបាល (គ្រប់គ្រង) កំពង់ធ្វើឱ្យរុញរាជារើយៗដោយមានការជ្រៀតចេញតាមព្រំដែន ជាមួយប្រទេសជិតខាងទាំង៣ និងតាមបណ្តោយឆ្នេរ ។ ក្របខ័ណ្ឌស្ថាប័នសំរាប់ការត្រួតពិនិត្យតាមព្រំដែន គឺមានភាពស្មុគ្រស្មាញ ដោយមានអំណាច មិនច្បាស់លាស់ក្នុងចំណោមស្ថាប័ន (ភ្នាក់ងារ)ផ្សេងៗ។ ការរៀបចំពាណិជ្ជកម្មនានា (ច្បាប់នៃតំរូវការប្រភពដើម, ការរៀបចំពាណិជ្ជកម្មជាក់ស្តែង) មានការលំបាកចំពោះកិច្ចការនេះ ។ ការកំណត់ប្រភពធនធានវាកំហិតដល់សមត្ថភាព នៃទីចាត់ការគយក្នុងការអនុវត្តន៍ តួនាទីនានារបស់គេ។ ប្រាក់បៀវត្សមន្ត្រីរាជការមានកំរិតទាបសំភារៈគាំទ្រផ្តល់ជារូបវន្ត័មិនគ្រប់គ្រាន់ ហើយគ្រប់គ្រងប្រព័ន្ធពិតមានមានភាពទន់ខ្សោយ ។ ការលំបាកទាំងនេះឆ្លុះបញ្ចាំង នូវការទូទាត់ក្រៅផ្លូវការខ្ពស់ មានការរត់ពន្ធទ្រង់ទ្រាយធំ គ្មានការបញ្ជាក់ អាចទុកចិត្តបាននិងពេលវេលាកែច្នៃ និងការប្រមូលពន្ធគយ គឺថាមានកំរិតទាបជាងគួឱ្យកត់សំគាល់ទៅនឹងពន្ធគយជាផ្លូវការ។ ការកែទំរង់គយរដ្ឋាករកំពង់តែដំណើរការ ដោយមានការគាំទ្រពីមូលនិធិរូបិយវត្ថុអន្តរជាតិ។

ក្រៅពីការលំបាកដែលទាក់ទងជាមួយភាពងាយស្រួលពាណិជ្ជកម្មអន្តរជាតិ (ពីក្រោយព្រំដែន) ដែលកំហិត គឺមានភាពរុញរាខ្លាំងផងដែរចំពោះការនាំចេញ។ ថ្លៃដឹកជញ្ជូននៅកម្ពុជាខ្ពស់ជាងគេនៅក្នុងតំបន់ ហើយបើប្រៀបធៀប ថ្លៃដឹកជញ្ជូន

ជាមួយប្រទេសថៃគឺថ្លៃជាង៤ដងឯណោះ។ ថ្លៃដឹកជញ្ជូនផ្ទៃក្នុងខ្ពស់អាស្រ័យដោយសារគុណភាពហេដ្ឋារចនាសម្ព័ន្ធអន់ថយ (មិនល្អ) និងការចំណាយក្រៅផ្លូវការក្នុងអ្នកប្រើប្រាស់ផ្លូវ (រហូតដល់ ១៧ភាគរយ នៃថ្លៃដឹក ជញ្ជូនសរុប)។ តួនាទីនៃភ្នាក់ងាររដ្ឋាភិបាលដែលទាក់ទងដល់ពាណិជ្ជកម្មជាញឹកញាប់តែងតែជាន់គ្នា។

ការវិភាគដំបូងត្រូវបានអនុវត្តន៍ទៅលើវិស័យមួយចំនួន ដែលប្រទេសកម្ពុជាមានឱកាសដើម្បីលើកកំពស់ពាណិជ្ជកម្មទាំងក្នុងស្រុក និងអន្តរជាតិហើយដែលបានបង្ហាញយ៉ាងលំអិតនៅក្នុងរបាយការណ៍ IF បញ្ជាក់ពីខាងលើនោះ។ ប្រទេសកម្ពុជាមានកំលាំងពលកម្មខ្ពស់នៅក្នុងឧស្សាហកម្មសំលៀកបំពាក់ និងវាយនភ័ណ្ឌដែលបានផ្តល់ឱកាសការងារយ៉ាងសំខាន់ជាពិសេសសំរាប់កម្មការិពីតំបន់ជនបទ។ ដោយសារទីផ្សារក្នុងស្រុកកម្ពុជាមានទំហំតូច នោះការនាំចេញ បានជំរុញដល់ការប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីបង្កើតការងារបន្ថែមទៀត។ អនុវិស័យសំលៀកបំពាក់ និងវាយនភ័ណ្ឌបានបង្ហាញកំណើន ជាភាគរយនៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) ជាបន្តបន្ទាប់ពី ១,១ភាគរយក្នុងឆ្នាំ ១៩៩៣ ដល់ ១១,៩ភាគរយក្នុងឆ្នាំ ២000។ បច្ចុប្បន្នវិស័យនេះគឺជាចលករដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ដែលមានអត្រាកំណើនប្រចាំឆ្នាំដល់ ៦៥ ភាគរយ សំរាប់ឆ្នាំ ១៩៩៥ ដល់ ២00២។ សព្វថ្ងៃមានក្រុមហ៊ុនជិត ២00 ទទួលកម្មករបំរើការដល់ទៅ ២00.000នាក់ ដែលផលិតបានជាចំណូលដល់ទៅ ១,២ កោដិដុល្លា គិតជាប្រាក់ខែ សរុបក្នុងមួយខែៗប្រហែល ១២ លានដុល្លាអាមេរិក។

កំណើននៃការនាំចេញដ៏លើសលុប ឆ្លុះបញ្ចាំងនូវការបញ្ចូលគ្នានៃច្រកចូលកំណត់ទៅកាន់ទីផ្សារ US & EU ដោយលក្ខខណ្ឌយ៉ាងតឹងរឹងនាពេលបច្ចុប្បន្ន (ផុតកំណត់នៅឆ្នាំ ២00៥) បរិយាកាសនយោបាយដែលទទួលស្វាគមន៍យ៉ាងរាក់ទាក់ និងថ្លៃផលិតកម្មប្រកួតប្រជែង។ ក្នុងករណីច្រកចូលជាក់លាក់មានន័យថាកម្ពុជាមានច្រកចូលខ្លះទៅកាន់ទីផ្សារដោយលក្ខខណ្ឌតឹងរឹង។ នៅខណៈដែលកម្ពុជាមានច្រកចូលទីផ្សារ សហរដ្ឋអាមេរិកសំរាប់បរិមាណយ៉ាងធំនៃទំនិញរួចពន្ធ (អនុគ្រោះពន្ធ) និងក្រោមកូតា GSP សំរាប់ទំនិញនាំចេញមានសំលៀកបំពាក់, ចំពោះរបស់របរជាផលិតផលសំលៀកបំពាក់ការដាក់ពាក្យសុំអត្រាអនុគ្រោះពន្ធ (MFN) សំលៀកបំពាក់ដែលកម្ពុជាបានបង្ហាញដោយខ្លួនឯង ដើម្បីទទួលបានការកើតចំនួនប្រកួតប្រជែងយ៉ាងពិសេសតាមការដាក់ពាក្យសុំ ។ ចំពោះសហគមន៍ អឺរុប ការរៀបចំប្រព័ន្ធអនុគ្រោះពន្ធ គឺថាកម្ពុជាអាចនាំចេញដោយគ្មានពន្ធ និងការកំណត់បរិមាណ អោយតែច្បាប់នៃសេចក្តីត្រូវការដើមត្រូវបានគេសន្យា ។ សេចក្តីត្រូវការទាំងនេះ គឺស្ថិតក្នុងករណីជាច្រើន មិនត្រឹមតែបានសន្យាផ្តល់អោយនូវការអភិវឌ្ឍន៍មានកំណត់ផ្នែកវាយណភ័ណ្ឌរបស់កម្ពុជាឡើង ។ ដូច្នេះ ផលិតផលសំខាន់មកពីកម្ពុជា គឺមានការប្រកួតប្រជែងយ៉ាងគ្រប់គ្រាន់ ដើម្បីអាចលក់នៅលើទីផ្សារ អង់គ្លេស ដោយគ្មានការសម្បទាន ។

ផលិតករក្នុងស្រុកនៅតែនិយាយថាការចំណាយនៃការធ្វើជំនួញនៅកម្ពុជាមានតម្លៃខ្ពស់ ។ ច្បាប់ការងារកម្ពុជាតំរូវអោយបណ្តាក្រុមហ៊ុនចំណាយចំពោះកម្មករថែមម៉ោង ឬតម្លៃពលកម្មធ្វើ សំរាប់ការធ្វើការ ក្នុងកំឡុងពេលល្ងាច និងយប់ បណ្តាក្រុមហ៊ុននៅកម្ពុជាត្រូវតែចំណាយទាក់ទងនឹងតម្លៃពលកម្មខ្ពស់តិចបំផុត ការចំណាយដឹកជញ្ជូននៅខ្ពស់ណាស់ ចំណាយបន្ទាប់បន្សំ និងអំពើពុករលួយនៅតែបន្តរាលដាល ។

### *នយោបាយ និងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ពាណិជ្ជកម្មដែលអាចជួយអ្នកក្រ*

វិស័យកសិកម្ម មានសារៈសំខាន់ក្នុងចំណោម បណ្តាឱកាសជាច្រើនរបស់កម្ពុជាសំរាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈកម្មករដែលបានកើនឡើងមកពីការផលិតផលនាំទៅរកការនាំចេញ។ ការផ្លាស់ប្តូរមួយកំពុងកើតឡើងពីផលិតស្រូវសំរាប់

សន្តិសុខស្បៀងទៅជាការ ផលិតអង្ករសំរាប់ការធ្វើពាណិជ្ជកម្ម និងបង្កើនប្រាក់ចំណូល ។ ពាណិជ្ជកម្ម អង្ករទាំងក្នុងប្រទេស និងឆ្លងកាត់ព្រំដែនបានបង្កើតបញ្ហាក្នុងពេលថ្មីៗ ដោយការប្រមូលផលថយចុះ និងហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនទន់ខ្សោយហើយ សិទ្ធិទទួលឥណទានពាណិជ្ជកម្ម ។ ដំណើរការនាំចេញ និង "ថ្លៃឈ្នួលសំរួលកិច្ចការ " ចោទជាបញ្ហាពន្ធអាករ ដែលសំខាន់លើការនាំចេញអង្ករ ការប្រែប្រួលតំលៃអង្ករបានជះឥទ្ធិពលអវិជ្ជមានលើជនក្រីក្រកម្ពុជា ពេលខ្លះមានការប្រឈមមុខដោយផ្ទាល់ ។ ការវាស់វែងដើម្បីកាត់បន្ថយការប្រែប្រួលតំលៃអង្ករ ឬដើម្បីការពារអ្នកផលិតដែលក្រីក្រ (ឬអតិថិជនក្រីក្រ) ដោយសារផលប៉ះពាល់នៃការប្រែប្រួលតំលៃអង្ករ សេចក្តីត្រូវការត្រូវបានគេពិចារណា ។ ឧទាហរណ៍ៈ ការកាត់បន្ថយ នៃចរាចរជាជំហានៗ យ៉ាងប្រុងប្រយ័ត្នការទំនុកបំរុង និងការវាស់វែងដោយពេលលេញ ។

កសិកម្មកម្ពុជាបច្ចុប្បន្នកំពុងប្តូរទិសដៅពីអង្ករផ្គត់ផ្គង់ជីវិតរស់នៅ ឆ្ពោះទៅរកភាពទូលំទូលាយនៅកន្លែងណាមួយ និងអនុសញ្ញាសំខាន់សំរាប់ទីផ្សារ ហើយនិន្នាការនេះ គឺជាឱកាសដែលសំខាន់នៅក្នុងយុទ្ធសាស្រ្តអភិវឌ្ឍពាណិជ្ជកម្មសំរាប់អ្នកក្រីក្រ ។ កម្ពុជាអាចចំណេញពីការកើនឡើងតំរូវការពិភពលោកចំពោះផលិតផលកសិកម្ម ដែលមាននៅនឹងកន្លែងដូចជា ថ្នាំរុក្ខជាតិ ផ្លែឈើពិសេសតំបន់ត្រូពិច ពិសេស និងផលិតផល "ពិណបៃតង" ឬធម្មជាតិ ។ ការលើកតំកើនការអភិវឌ្ឍន៍កសិកម្មជាមធ្យោបាយមួយកែលំអជីវិតរស់នៅតាមជនបទត្រូវតែរាប់បញ្ចូលការ វិនិយោគសហគ្រាសធុនតូច និងមធ្យម ជាមួយសមត្ថភាព ដំណើរការដែលមានតម្លៃបន្ថែម ដូច្នេះផលិតផលកសិកម្មអាចមានសិទ្ធចូលទីផ្សារជាតិ និងទីផ្សារនាំចេញ ហើយប្រជាជននៅជនបទអាចមានការងារធ្វើច្រើន ។ ការចាត់ចែង និងសិទ្ធិរបស់កសិករ ដើម្បីទទួលឥណទាន និងជំនាញផ្សេងៗ ដើម្បីអភិវឌ្ឍន៍មុខជំនួញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ត្រូវបានកែលំអ ហើយមានសិទ្ធិប្រើប្រាស់ពិតមានទីផ្សារ គឺជាសេចក្តីត្រូវការចំបាច់ផងដែរ ។ ការយល់ឃើញ និងការបង្កើនល្បឿនក្នុងជួរតំលៃចំពោះផលិតផលកសិកម្ម គឺជាតំរូវការចាំបាច់ ដើម្បីជួយកសិករផលិត ផលិតផលស្របច្បាប់ដោយមានគុណភាព ប្រសើរសំរាប់ទីផ្សារក្នុងស្រុកនិងអន្តរជាតិ ។ ការវិភាគ និងសកម្មភាពតំរូវការក្នុងស្រុកតាមបណ្តាខេត្ត និងថ្នាក់ជាតិ ។ យុទ្ធសាស្រ្ត គឺស៊ីសង្វាក់ជាមួយការគាំទ្រ ដោយផ្តោតទៅលើក្រសួងកសិកម្ម អំពីការលើកតំកើងឧស្សាហកម្មកសិកម្មឯកជន ។

ផលិតផលធ្វើដោយដៃត្រូវបានគេការពារមិនដោយបាត់បង់ជំនាញ ប្រពៃណី និងគំនូរក្នុងកំឡុងឆ្នាំ ដែលមានសង្គ្រាម ។ ប្រជាជនដែលធ្វើដោយដៃ ពុំមានពិតមានច្បាស់លាស់អំពីតំរូវការទីផ្សារ ស្តង់ដារគុណភាព និងនិន្នាការទីផ្សារ ។ ការទ្រទ្រង់គឺជាតំរូវការក្នុងវិធីដូចគ្នាជាពង្រឹងសម្ថភាពកសិកម្មដោយបណ្តោះបណ្តាលពីការធ្វើជំនួញ និងបច្ចេកទេសឥណទាន ការចាត់ចែង និងសិទ្ធិទទួលពិតមាន ។

ការអភិវឌ្ឍន៏វិស័យជលផល ត្រូវបានគេរាំងដោយអន្តរាគម៏មិនសមរម្យរបស់ភ្នាក់ងាររដ្ឋាភិបាល ក្នុងស្ទើតែគ្រប់រូបភាពនៃកិច្ចការលក់ដូរនៅទីផ្សារ និងដោយការប្រព័ន្ធការលក់ដូរគ្មានប្រសិទ្ធិភាព ជាពិសេសនៅតាមព្រំដែនថៃ ។ ការបង្កើតការប្រកួតប្រជែង និងទីផ្សារឆ្លើយតបនឹងវិស័យជលផល នឹងទាមទារអោយ មានការផ្លាស់ប្តូរក្នុងវប្បធម៌ ប្រតិបត្តិការក្នុងវិស័យនេះ សំរាប់កិច្ចការជំនួញដែលមានមូលដ្ឋានផ្អែកលើធម្មជាតិ ។ ភាពទៀងទាត់នៃរបបគ្រប់គ្រង់ ដើម្បីត្រូវពិនិត្យលើការនេសាទ គឺជាសេចក្តីត្រូវការចាំបាច់ផងដែរ ។

អង្គការពាណិជ្ជកម្មពិភពលោក (WTO) ត្រូវបានគេសំលឹងឃើញជាវេទិការ ដ៏មានតំលៃបំផុតសំរាប់ការអភិវឌ្ឍន៍នូវរបបពាណិជ្ជកម្មពិភពលោកដោយឈរលើមូលដ្ឋានច្បាប់ ។ សិទ្ធិចំពោះការចូលអង្គការពាណិជ្ជកម្មពិភពលោកត្រូវបានគេបំពេញបន្ថែមដោយការចងភ្ជាប់គ្នា ការធ្វើពាណិជកម្មភាគខាងត្បូង និងក្នុងតំបន់កើនឡើង ។ ដូច្នោះវាប្រាកដថាកម្ពុជាកំពុងបន្តធ្វើអោយមានសន្តិភាព ភាពចំបាច់នូវអធិតេយ្យភាពជាតិ ដើម្បីរៀបចំគោលនយោបាយ សេដ្ឋកិច្ចក្នុងស្រុក និងអន្តរជាតិ មានមូលដ្ឋានឈរលើការចាប់អារម្មណ៍ និងសេចក្តីត្រូវការនានាដ៏ធំធេងរបស់ប្រជាជន ។ វាពិតផងដែរថាកម្ពុជាអាចទទួលបានផលចំណេញពីការផ្តល់អោយផ្សេងៗ ទៀតក្នុងក្របខ័ណ្ឌការងារអង្គការពាណិជ្ជកម្មពិភពលោក ភាពសមរម្យចំពោះស្ថានភាពរបស់វាដូចជា LDC មួយ ។ តួនាទីនៃការនាំចេញផលិតផលកសិកម្មកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ គឺមានអត្ថន័យយ៉ាងពិសេសក្នុងភាពសមរម្យ ។

ដៃគូយុទ្ធសាស្រ្តពាណិជ្ជកម្មក្នុងសិទ្ធិសំរាប់អ្នកក្រចំពោះលទ្ធផលការងារ និងផលប្រយោជន៍ចំណូល ជាពិសេសមិនគិតរួមបញ្ចូលក្នុងតំបន់ជនបទ និងតំបន់ជាយក្រុងដែលមានមនុស្សច្រើនលើសលប់នៅភ្នំពេញ ។ ការប្រើប្រាស់ដោយសមស្របនូវប្រភពធនធានធម្មជាតិ និងលក្ខខណ្ឌការងារដែលបានកែលំអចំពោះកម្មករ (ភាពស្មើភាពគ្នានៃភេទ សុខភាព សុវត្ថិភាព និងកំរិតថ្លៃពលកម្មសមរម្យ) គឺជាកម្មវត្ថុគន្លឹះផងដែរ ។ ការវិភាគអំពីភាពក្រីក្រពីអតីត និងផលប៉ះពាល់សង្គមនឹងត្រូវបានគេអនុវត្តក្នុងទិសដៅ ដើម្បីព្យាករណ៏អោយប្រសើរឡើងទាំងផលវិបាកវិជ្ជមាន និងអវិជ្ជមាន អំពីយុទ្ធសាស្រ្តពាណិជកម្មល្អដូចដែលធានាថាផលប្រយោជន៍នានា ត្រូវគេកែតំរូវសំរាប់ជនក្រីក្របំផុត ហើយរដ្ឋាភិបាលកម្ពុជានឹងត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ននូវផលប៉ះពាល់នានាលើក្រុមដែលងាយរងគ្រោះ ។

តាមពិត ការវិនិយោគដោយផ្ទាល់ពីបរទេស និងសកម្មភាពនាំចេញ នឹងមិនមែនសុទ្ធតែផ្តល់ឱកាសសំរាប់ការកាត់បន្ថយភាពក្រីក្រទេ ប្រសិនបើការព្រួយបារម្ភអំពីប្រភេទ និងលក្ខខណ្ឌវិនិយោគ ភាពជាកម្មសិទ្ធិ ស្តង់ដារកម្មករ និងស្ថេភាពនៃបរិស្ថាន និងគ្រឿងចក្រដែលអាចទទួលខុសត្រូវបានមិនបានបញ្ជាក់អោយសមស្រប ។ ឧទាហរណ៏ការ ផ្តោតការយកចិត្តទុកដាក់របស់បណ្តាសហគ្រាសដែលមានទិសដៅសំរាប់តែនាំចេញ ក្នុងតំបន់សេរីសំរាប់ដំណើរការនាំចេញ ( EPZs ) នឹងផ្តល់នូវបរិស្ថាន ឧបករណ៏រីកដុះដាលមុខជំនួញក្នុងគោលគំនិតអ្វីមួយ និងបទពិសោធន៍ជាច្រើនអាចផ្លាស់ប្តូរគ្នា នឹងអនុញ្ញាត្តអោយត្រួតពិនិត្យអោយល្អឡើងផងដែរនូវផលប៉ះពាល់បរិស្ថានទាំងឡាយនៃបណ្តាសកម្មភាពសេដ្ឋកិច្ចដោយចំពោះ ។ ដូច្នេះ តំបន់សេរីសំរាប់តែការនាំចេញ (EPZs) ទទួលគ្រោះថ្នាក់គ្រប់ការនាំចេញ ការចំណេញស្របតាមផលិតផល ហើយប្រសិនពួកធ្វើមិនមែនសុទ្ធតែធានាទំនាក់ទំនងមិនអោយដើរថយក្រោយ និងបង្ហាញពីលទ្ធភាពការធ្វើអោយរឹតតែខ្លាំងឡើងនូវវិសមភាពប្រាក់ចំណូល រវាងតំបន់ទីក្រុង និងជនបទ បានធ្វើអោយកើនឡើងអន្តោប្រវេសន៏ពីជនបទទៅទីក្រុង ហើយបង្កើតអោយមានអ្នកក្រីក្រច្រើននៅទីក្រុង និងជុំវិញទីក្រុង ។

ដើម្បីអោយពាណិជ្ជកម្មមានការរីកដុះដាលប្រកបដោយជោគជ័យនៅតែបន្តគុណភាពផលិតផលគឺជាគន្លឹះ ។ ការជំរុញនូវការផ្ទេរបច្ចេកវិទ្យា ការធ្វើអោយប្រសើរឡើងនូវផលិតផល នឹងតំរូវអោយមានប្រព័ន្ធត្រួតពិនិត្យសំរាប់ផលិតនាំចេញដោយបង្កើតអោយមានស្តង់ដារដែលអន្តរជាតិអាចទទួលយកបាន ។ បន្ថែមលើសនេះ ការផ្ទេរបច្ចេកវិទ្យា នឹងជាតំរូវការចាំបាច់សំរាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍក្នុងក្របខ័ណ្ឌការងារបទបញ្ញត្តិច្បាប់ ដោយគ្របដណ្តប់លើសិទ្ធិជាកម្មសិទ្ធិ និងផ្លាកសញ្ញាពាណិជ្ជកម្ម ។

សកម្មភាពបច្ចុប្បន្នក្នុងការអភិវឌ្ឍន៍យុទ្ធសាស្ត្រពាណិជ្ជកម្មរាប់បញ្ចូលៈ (១)ភាពទូលំទូលាយ និងការទ្រទ្រង់ដោយម្ចាស់ជំនួយជាច្រើន ដើម្បីពង្រឹកសមត្ថភាពក្រសួងពាណិជ្ជកម្ម ក៏ដូចជាស្ថាប័នដែលជាប់ពាក់ព័ន្ធដែលបានដាក់ ទិសដៅដើម្បីដឹកនាំ រៀបចំរូបមន្ត និងអនុវត្តនូវយុទ្ធសាស្ត្រសំរាប់អ្នកក្រីក្រ និងការចូលរួមជាមួយអង្គការពាណិជ្ជកម្ម ពិភពលោក (WTO) (២)ការអភិវឌ្ឍន៍នូវសូចនាករ និងការព្យាករណ៍ ចំពោះផលប៉ះពាល់ភាពក្រីក្រនៃនយោបាយពាណិជ្ជកម្ម និងមធ្យោ-បាយដើម្បីធានានូវការត្រួតពិនិត្យ និងវាយតម្លៃដោយផ្ទាល់នូវគោលដៅការកាត់បន្ថយភាពក្រីក្រ (៣)ការទំនាក់ទំនងជាមួយផ្នែកឯកជន ដើម្បីលើកតំកើងនិងឆ្លើយតបដែលទ្រទ្រង់ភាគីខាងអ្នកផ្គត់ផ្គង់ និងការកើនឡើងផលិតកម្ម (៤)ផែនការសកម្មភាពអនុវត្តច្បាប់ជាតិដើម្បីជួបប្រជុំតំរូវការចាំបាច់ការចូលអង្គការពាណិជកម្មពិភពលោករាប់បញ្ចូលទាំងច្បាប់ជាង ៤០ ប្រភេទថ្មីៗនេះផងដែរបានអនុម័តរួច ឬស្ថិតក្រោមការពិភាក្សា ។

តារាងនៃការវាស់វែងដែលសកម្មនានា សំរាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្មចំពោះអ្នកក្រ គឺត្រូវគេផ្តល់អោយក្រោមចំណែកនៃម៉ាទ្រីសផែនការសកម្មភាពដែលបានរួមបញ្ចូលគ្នាក្នុងតារាង ។ ភាគច្រើននៃម៉ាទ្រីសទាំងនេះ ត្រូវបានគេបំពេញរួចហើយក្នុងពេលថ្មីៗ នេះហើយមានការពិភាក្សាជាមួយភ្នាក់ងារដៃគូផ្សេងៗ ទៀត ។ គោលដៅចំពោះ និងការចាយវាយចំណាយសំរាប់ការចាប់ផ្តើមជាង ៥០ ប្រភេទខុសគ្នាក្នុងកម្មវិធី គឺជាការពិបាក ដើម្បីធ្វើអោយជាក់លាក់អោយពុំនាំទៅរកការខុសឆ្គង ។ តារាងមានតាមផ្នែក និងសកម្មភាពដែលជាតំណាងរបស់ភ្នាងារច្រើនជាងមួយ ដោយក្រសួងពាណិជ្ជកម្មជាអ្នកអនុវត្តដោយផ្ទាល់ ។ ដូច្នេះ ឋានៈរបស់ភាគីនានា គឺមានភាពទូលំទូលាយណាស់ ។ កិច្ចចរចាជាមួយប្រទេសថៃ អំពីតំបន់ដែលដំណើរ ការនាំចេញកំពុងពិចារណាយ៉ាងល្អិតល្អន់ពីការវិនិយោគ លើទឹកប្រាក់ជាង ២០០ លានដុល្លាអាមេរិក ។ ធនាគារ ADB បច្ចុប្បន្នកំពុងបន្តទ្រទ្រង់ ចំពោះការអភិវឌ្ឍន៍ ច្បាប់កិច្ចការជំនួញដ៏រឹងមាំមួយ មានទឹកប្រាក់ជាង ៦០០.០០០ ដុល្លាអាមេរិក ។ ធាតុផ្សំដែលកសាងសមត្ថភាពក្រសួងពាណិជ្ជកម្មរបស់រដ្ឋាភិបាលជប៉ុន បានផ្តល់មូលនិធិដោយគំរោងក្របខ័ណ្ឌការងារ ដែលរួមបញ្ចូលគ្នា (IF) គឺតិចជាង ២០០.០០០ ដុល្លាអាមេរិក ហើយមានចំនួនចាប់ផ្តើមដំបូងដែលនៅតែតូចជាង ប៉ុន្តែនៅតែមានសារៈសំខាន់ណាស់ ។

## ៤.២.៣ ការអភិវឌ្ឍន៍ទេសចរណ៍

វិស័យទេសចរណ៍នៃប្រទេសកម្ពុជាបានដើរតួនាទីដ៏សំខាន់ និងជាគន្លឹះក្នុងការអភិវឌ្ឍន៍ប្រទេស ។ វិស័យនេះបានបង្កើតចំណូលប្រហែល ២០០ លានដុល្លាក្នុងមួយឆ្នាំៗ និងបង្កើត ១០០ ០០០ការងារ ។ ដូច្នេះ ហើយវិស័យនេះបានចូលរួមយ៉ាងសំខាន់ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស និងការកាត់បន្ថយភាពក្រីក្រ ។ តាមការសន្និដ្ឋានបានអោយដឹងថាភ្ញៀវទេសចរណ៍ម្នាក់បានចំណាយយ៉ាងហោចណាស់ ៥០០ដុល្លា ហើយវាអាចចិញ្ចឹមប្រជាជនបានពីរនាក់ក្នុងមួយឆ្នាំ ។

ដើម្បីប៉ាន់ប្រមាណពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងវិស័យនេះ ដូចដែលការមកដល់របស់ភ្ញៀវទេសចរណ៍មកកាន់កម្ពុជាបានកើនឡើងជាបន្តបន្ទាប់ ប្រហែល ៣០% ក្នុងឆ្នាំ២០០១ ។ ការកើនឡើងនេះ ត្រូវបានគេគិតថាជាលទ្ធផលនៃការធ្វើអោយប្រសើរឡើងវិញនូវស្ថេរភាព សុវត្ថិភាព និងសន្តិសុខនៅក្នុងប្រទេស ក៏ដូចជាគោលនយោបាយ "បើកចំហរជើងមេឃ" ក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសចាប់តាំងពី ឆ្នាំ១៩៩៨ ។ សកម្មភាពទេសចរណ៍បានកើនឡើង ៣០% ក្នុងឆ្នាំ ១៩៩៤-១៩៩៥ ។

នាទសវត្សរកន្លងមក ការអភិវឌ្ឍន៍ក្នុងឧស្សាហកម្មទេសចរណ៍បានរួមចំណែកយ៉ាងសំខាន់ក្នុងការកើនឡើងនៃសេដ្ឋកិច្ចដោយការទាក់ទាញការវិនិយោគបរទេស ការបង្កើតការងារ និងការបង្កើតប្រាក់ចំណូលសំរាប់ប្រជាជនក្នុងមូលដ្ឋាន ។

ដោយសារតែកេរ្តិ៍តំណែលវប្បធម៌ និងធម្មជាតិដ៏សំបើម ។ គោលនយោបាយទេសចរណ៍នឹងត្រូវបាន គេផ្តោតអារម្មណ៍ទៅរកទេសចរណ៍វប្បធម៌ និងធម្មជាតិ ។ វានឹងធានាបាននូវការអភិវឌ្ឍន៍បរិស្ថានធម្មជាតិ និងវប្បធម៌ប្រកបដោយនិរន្តរភាព ក៏ដូចជាការការពារបរិស្ថានដោយមិនប្រែក្លាយទៅជាឧបសគ្គក្នុងការអភិវឌ្ឍន៍ឡើយ ។ បញ្ហាសំខាន់នេះគឺធ្វើយ៉ាងណាអោយមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រង និងធ្វើអោយមានតុល្យភាពរវាងការការពារនិងការអភិវឌ្ឍន៍ និងបង្កើតនូវផែនការបែងចែកតំបន់មួយ សំរាប់ការអភិវឌ្ឍន៍ទេសចរណ៍ ដើម្បីធានានូវការគ្រប់គ្រងវិស័យនេះអោយបានត្រឹមត្រូវ ។

ទោះបីជាយ៉ាងណាក៏ដោយនៅបច្ចុប្បន្ន វិស័យនេះបានបន្ថែមនូវសារប្រយោជន៍ដ៏តិចតួចណាស់ ។ ការប៉ាន់ប្រមាណបានបង្ហាញថា ទេសចរម្នាក់ៗបានចំណាយ ០,៧៥ ដុល្លា ទៅអោយប្រទេសថៃដោយការនាំចូលនូវបន្លែស្រស់ៗ ផ្លែឈើ ផ្កា សិប្បកម្ម និងគ្រឿងសង្ហារឹម ។

**គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ទេសចរណ៍ដែលជួយដល់ជនក្រីក្រ**

ប្រទេសកម្ពុជាមានរមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រជាច្រើន ។ ប្រាសាទអង្គរ គឺជាបេតិកភ័ណ្ឌដែលមិនអាចកាត់ថ្លៃបាន និងជាកម្មសិទ្ធិរបស់មនុស្សគ្រប់រូប ។ វាតំរូវអោយបង្កើតផែនការមេត្រឹមត្រូវមួយសំរាប់ការជួសជុលកែលំអឡើងវិញ ការអភិវឌ្ឍន៍ និងការការពារ ។ ការអភិវឌ្ឍន៍តំបន់នេះគឺធ្វើដោយសន្សឹមៗ ប្រកបដោយការពិចារណាខ្ពស់ ។ បច្ចុប្បន្ននេះមានតែផ្លាកសញ្ញាប្រាប់ទិសដៅផ្លូវ បន្ទប់អនាម័យ និងសម្បទាន ផ្សេងៗមួយចំនួនតែប៉ុណ្ណោះ សំរាប់បំរើភ្ញៀវទេសចរ ។ ការធ្វើផែនការមេនេះត្រូវធ្វើកាន់តែឆាប់កាន់តែប្រសើរ ដោយរៀបចំផែនការមួយសំរាប់ការអភិវឌ្ឍន៍ និងធ្វើអោយផែនការនេះអាចប្រើប្រាស់បានសំរាប់វិនិយោគិន ឯកជនក្នុងការចូលរួមរបស់ពួកគេ ។

ក្រៅពីតំបន់ប្រាសាទអង្គរ រាជរដ្ឋាភិបាលបានគិតគូពិចារណាទៅលើប្រភេទផ្សេងៗពីគ្នានៃវិស័យនេះផងដែរ ។ ភាពផ្សេងៗពីគ្នានេះ គឺជាសក្តានុពលដ៏ធំសំបើមដែលចាប់ផ្តើមពីរមណីយដ្ឋានដែលរកឃើញ ថ្មីៗនៅជុំវិញតំបន់អង្គរ ទៅនឹងចំនួនដ៏ច្រើននៃរមណីយដ្ឋានដែលបានរកឃើញថ្មីៗផ្សេងៗទៀតទូទាំងប្រទេសកម្ពុជា ។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍គោលដៅទេសចរណ៍វប្បធម៌ និងអេកូ-ទេសចរណ៍ផ្សេងៗទៀត ដូចជា ភ្នំគូលេន ប្រាសាទកោះកេរ្តិ៍ ប្រាសាទព្រះវិហារ និងផ្ទះតាម៉ុកនៅ អន្លង់វែង ដែលអាចត្រូវបានគេប្រើប្រាស់សំរាប់ជាគោលដៅទេសចរប្រវត្តិសាស្ត្រមួយ ។ តំបន់ទាំងនេះអាចត្រូវបានគេអភិវឌ្ឍន៍ជាតំបន់កំសាន្តដ៏ធំមួយបែបជីវចំរុះប្រវត្តិសាស្ត្រ និងវប្បធម៌ដែលតំបន់ទាំងនេះមិនត្រូវបាន គេចាត់ជាចំណាត់ដល់ក៏រិតតំបន់អង្គរទេ ។ បន្ថែមជាងនេះទៅទៀតបឹងទន្លេសាបមានសក្តានុពលដ៏ធំសំបើម សំរាប់ការអភិវឌ្ឍន៍អេកូ-ទេសចរណ៍ដូចជាតំបន់សត្វស្លាប និងភូមិនេសាទ ។ នៅតំបន់កណ្តាលមាន ប្រាសាទសម្បូរណ៍ព្រៃគុហ៍ដែលផ្លូវទៅកាន់ប្រាសាទត្រូវបានគេអភិវឌ្ឍន៍រួចហើយ ។ ចំណែករមណីយដ្ឋាន ទេសចរផ្សេងៗទៀតរួមមានតំបន់ភ្នំពេញ និងតំបន់ឆ្នេរ ។

គោលនយោបាយរបស់រដ្ឋាភិបាលជំរុញអោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវលើកកំពស់ដល់ វប្បធម៌ជាតិ ក្នុងវិធីមួយដែលជួយដល់ការពង្រីកសេវាកម្ម និងការបង្កើតឱកាសការងារសំរាប់ប្រជាជន និងដោយរួមចំណែកក្នុងគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ ។ ការអភិវឌ្ឍន៍ធនធានវប្បធម៌របស់កម្ពុជា ជាពិសេសរមណីយដ្ឋានតំបន់អង្គរដែលបាននឹង

កំពុងទាក់ទាញចំនួនភ្ញៀវទេសចរណ៍អោយកាន់តែកើនឡើង ហើយវាគឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដែលវាមិនត្រឹមតែជាគោលដៅនៃការអភិវឌ្ឍន៍វប្បធម៌សង្គម មួយប៉ុណ្ណោះទេ ប៉ុន្តែដោយសារតែសក្តានុពលនៃរមណីយដ្ឋានដែលជាប្រវត្តិសាស្ត្រ ទាំងនេះបានបង្កើតនូវប្រាក់ ចំណូល, សេដ្ឋកិច្ច ផងដែរ ។ ការអភិរក្ស និងការអភិវឌ្ឍន៍ធនធានវប្បធម៌ជាតិទាំងអស់ នឹងទាមទារអោយតំបន់ផ្សេងៗទៀតដែលមានប្រាសាទបុរាណស្រាប់ គួរតែត្រូវបានគេជួសជុលឡើងវិញផងដែរ ក្នុងគោលបំណងដើម្បីប្រែក្លាយតំបន់ទាំងនេះអោយទៅជាតំបន់ទេសចរណ៍វប្បធម៌ ។

យុទ្ធសាស្ត្រទាំងនេះកំពុងត្រូវបានដាក់អោយពិចារណា ត្រូវបានគេរៀបចំដើម្បីអោយកម្ពុជា ប្រើប្រាស់នូវវិស័យទេសចរណ៍ជាយុទ្ធសាស្ត្រក្នុងគោលដៅកាត់បន្ថយភាពក្រីក្រជារួម ។ វាមានសារៈសំខាន់ណាស់ថា មន្ត្រីរដ្ឋាភិបាលក៏ដូចជាផ្នែកពាក់ព័ន្ធផ្សេងៗទៀត ត្រូវបណ្តុះបណ្តាលពីតួនាទីសំខាន់នៃទេសចរណ៍ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ វិស័យទេសចរណ៍អាចបង្កើតបាននូវប្រភេទ ប្រាក់ចំណូលផ្សេងៗពីគ្នាដែលបានមក ពីប្រាក់បៀវត្សពីការងារផ្លូវការពលកម្មមិនផ្លូវការ ប្រាក់ចំណូលពីការលក់ទំនិញប្រាក់ចំណេញបានមកពីផលកំរៃដែលទទួលបានពីសហគ្រាសនៅក្នុងមូលដ្ឋាន និងប្រាក់ចំណូលរួម ដែលប្រាក់ចំណូលនេះបានមកពីសហគ្រាសនានាដែលគ្រប់គ្រងដោយសហគមន៍ ប្រាក់ចំណេញបានមកពីភាពជាដៃគូផ្នែកឯកជន និងកំរៃបានមកពីការជួលដីអោយវិនិយោគិន ។

គោលនយោបាយទេសចរណ៍ដែលជួយដល់ជនក្រីក្រ ចង់អោយមានការផ្លាស់ប្តូរក្នុងទិសដៅពីគោលបំណងនានាដែលពាក់ព័ន្ធជាមួយកំណើនប្រាក់ចំណូល និងចំនួនទេសចរណ៍ជារួម ទៅជាគោលបំណងមួយ ដែលមានការសង្កត់ធ្ងន់ទៅលើទំរង់ទេសចរណ៍ដែលអាចផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រ។ ការអនុម័តយក គោលនយោបាយទេសចរណ៍ដែលជួយដល់ជនក្រីក្រតំរូវអោយមានការបញ្ចូលថែមទៀតនូវភាពក្រីក្រ ទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗទៀតរបស់រដ្ឋាភិបាល ។ វាតំរូវអោយមានការផ្លាស់ប្តូរជាមូលដ្ឋានមួយក្នុងការគិតគូរអំពីទំរង់នៃការអភិវឌ្ឍន៍ទេសចរណ៍ ដែលនឹងផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រ ។ រដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ ដើម្បីកាត់បន្ថយការនាំចូលនូវផលិតផលផ្នែកទេសចរណ៍ និងបង្កើននូវទំនាក់ទំនងជាមួយនឹងកសិកម្ម និងឧស្សាហកម្មក្នុងស្រុក ។ ទោះបីជាយ៉ាងណាក៏ដោយជនក្រីក្របានប្រឈមមុខទៅនឹងឧបសគ្គជាច្រើនរួមមានការខ្វះខាតនូវជំនាញដែលពាក់ព័ន្ធ ការខ្វះខាតសិទ្ធិក្នុងការទទួលឥណទាន និងច្បាប់ផ្សេងៗទៀត ( Red tape ) ។

រដ្ឋាភិបាលកំពុងគិតគូពិចារណា ដោយប្រើប្រាស់នូវបច្ចេកវិទ្យាតាមមធ្យោបាយកំលាំងពលកម្មជាមូលដ្ឋាន (ណែនាំដោយ ILO) សំរាប់រមណីយដ្ឋានដែលបានរកឃើញថ្មីៗ និងការថែរក្សាពួកគេដោយបានបង្កើតនូវការងារដ៏មានសារៈសំខាន់សំរាប់ជនក្រីក្រ ។

រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាននៃវិស័យទេសចរណ៍ដែលអាចធ្វើទៅបាន ។ ការអភិវឌ្ឍន៍វិស័យទេសចរណ៍មិនគួរកំនត់តែនៅក្នុងវប្បធម៌សង្គម និងបរិស្ថាននៃតំបន់ទាំងនោះប៉ុណ្ណោះទេ ដែលវានឹងទទួលបាននូវការប្រមូលផ្តុំនូវភ្ញៀវទេសចរជាច្រើន ។ ជាពិសេស យុទ្ធសាស្ត្រនេះនឹងមិនលើកទឹកចិត្តអោយកម្ពុជា ជាគោលដៅមិនត្រឹមត្រូវមួយសំរាប់ទេសចរណ៍ផ្លូវភេទ និងធ្វើអោយប្រទេសកម្ពុជាជាកន្លែងប្រឆាំងទៅនឹងការធ្វើអាជីវកម្មលើផ្លូវភេទកុមារ ។ បន្ថែមជាងនេះទៅទៀតការយកចិត្តទុកដាក់ខ្ពស់លើការជួញដូរគ្រឿងញៀន និងការរត់ពន្ធមនុស្សក៏ដូចជាការលេងល្បែងស៊ីសង ដែលជះឥទ្ធិពលដល់ទេសចរណ៍ក្នុងស្រុក និងទំនាក់ទំនងឆ្លងកាត់ព្រំដែន ។

វិធានការមួយចំនួនត្រូវបានគេស្នើឡើង ដើម្បីធ្វើអោយមានកំរិតអតិបរមានៃផលប្រយោជន៍ផ្នែកវិស័យទេសចរណ៍ទៅអនាគត ដើម្បីកាត់បន្ថយភាពក្រីក្រ ។

ក្នុងគោលបំណងដើម្បីចាប់ផ្តើមស្វែងយល់អំពីតួនាទីយ៉ាងសំខាន់ ដែលវិស័យទេសចរណ៍អាចដើរតួនាទីក្នុងការកាត់បន្ថយភាពក្រីក្រ និងដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍នានាដែលជួយដល់ជនក្រីក្រ វាត្រូវបានគេផ្តល់ជាយោបល់ថា ក្រុមការងារអន្តរក្រសួងមួយគួរត្រូវបានបង្កើតឡើងដោយក្រសួងទេសចរណ៍ ។ ក្រុមការងារនេះនឹងខិតខំសហការជាមួយក្រសួងដទៃទៀត ដែលមានគោលបំណងរួមក្នុងការកាត់បន្ថយភាពក្រីក្រ ។ ក្រុមនេះគួរតែមានទំហំតូចដែលមានការជួយឧបត្ថម្ភគាំទ្រកំរិតខ្ពស់ និងការសិក្សាស្រាវជ្រាវតែភាពចាំបាច់ ព្រមទាំងមានថវិកាសំរាប់បំរុងទុកប្រើប្រាស់ ។ ក្រុមការងារនេះគួរតែត្រូវបានដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូបរបស់ក្រសួង ហើយត្រូវរាយការណ៍ដោយផ្ទាល់ទៅរដ្ឋមន្ត្រី ។ ក្រុមការងារនេះគួរត្រូវបានគេប្រគល់ សេចក្តីទុកចិត្តអោយសម្របសម្រួលរាល់សកម្មភាពនានាដែលទាក់ទងនឹងភាពក្រីក្រ ដើម្បីធានាអោយបាននូវ ដំណោះស្រាយរួមមួយចំពោះការប្រឈមមុខដោះស្រាយបញ្ហាទេសចរណ៍ និងភាពក្រីក្រ ។

តំបន់អភិវឌ្ឍន៍មួយចំនួនសំរាប់ការកាត់បន្ថយភាពក្រីក្រ អាចត្រូវបានគេបង្កើតឡើងដែលមាន ចំនុចលក្ខណៈពិសេសជាច្រើនរួមមាន ភាពក្រីក្រមានកំរិតខ្ពស់ និងទីតាំងមួយដែលទេសចរណ៍អាចរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចមូលដ្ឋាន ទីតាំងមួយដែលរដ្ឋាភិបាលកំពុងខិតខំជំរុញវិស័យទេសចរណ៍សំរាប់ គោលបំណងអភិវឌ្ឍន៍ និងទំនាក់ទំនងសេដ្ឋកិច្ចរួម និងទីតាំងណាមួយដែលមានឱកាសសំរាប់ការបង្កើតឡើង នូវទំរង់ទេសចរណ៍ដែលមានភាពជិតស្និទ្ធទៅនឹងបរិស្ថាន ដែលអាចរួមចំណែកក្នុងការថែរក្សាការពារ ការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានវប្បធម៌ និងធម្មជាតិ ។

ភាពជាដៃគូមួយរវាងផ្នែកសាធារណៈ និងឯកជនគួរជួយគាំទ្រដល់ការបង្កើតសហគ្រាសខ្នាតតូច និងមធ្យមដែលមានទិសដៅខាងវិស័យទេសចរណ៍ ។ វាគួររៀបចំឡើងដើម្បីជួយដល់ជនក្រីក្រក្នុងការ អភិវឌ្ឍន៍សហគ្រាសទាំងឡាយ ឬក្នុងករណីខ្លះគួរគាំទ្រការបង្កើតសហគ្រាសណាមួយដែលផ្តល់ការងារដល់ជនក្រីក្រស្របតាមការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់ខ្លួន ។

រដ្ឋាភិបាលមានការខិតខំ ដើម្បីអនុម័តយកគោលនយោបាយផ្សេងៗនៅក្នុងគំរូនៃគំរោងការ អធិវឌ្ឍន៍ទេសចរណ៍ថ្មីៗ ឬនៅក្នុងការពង្រីកគំរោងបច្ចុប្បន្ននានា ដែលមានយុទ្ធសាស្ត្រច្បាស់លាស់សំរាប់ការវិនិយោគឡើងវិញនូវចំណែកខ្លះនៃប្រាក់ចំណេញរបស់សហគ្រាសអោយដល់សហគមន៍ ។

ដោយសារកង្វះខាតនូវចំណេះដឹងសំរាប់ការអនុវត្តន៍ ដែលមានការសង្ឃឹមយ៉ាងខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈវិស័យទេសចរណ៍ គំរោងការបង្ហាញមួយចំនួនដែលនឹងជួយផ្តល់នូវភស្តុតាងអំពីទំនាក់ទំនងទេសចរណ៍/ទ្រព្យសម្បត្តិ ។ វិធីដែលមានប្រសិទ្ធិភាពបំផុតក្នុងការទទួលបានចំណេះដឹងបន្ថែម ទៀតគឺការរៀនសូត្រតាមការធ្វើ ( Learning by doing ) និងធ្វើការសិក្សាស្រាវជ្រាវទៅលើតំបន់ទាំងនេះ ។

ភ្ញៀវទេសចរណ៍ក្នុងស្រុក គឺជាអតិថិជនយ៉ាងសំខាន់បំផុតសំរាប់អ្នកលក់ដូររបស់របរខ្លួនឯង និងម្ចាស់ជំនួញតូចៗ ។ ភ្ញៀវទេសចរឯករាជ្យ និងចំណាយលុយតិច និងទេសចរសាកាដូក៏ទំនងជានឹងស្នាក់នៅផ្ទះសំណាក់ថោកៗ មានចំនួនច្រើនជាងភ្ញៀវទេសចរថ្នាក់ខ្ពស់ទាំងការស្នាក់នៅតាមផ្ទះ ការដឹកជញ្ជូន និងទាំងសេវាកម្មហូបចុក ដែលបានបំរើដោយប្រជាជនក្នុងមូលដ្ឋាន ។

គោលដៅទេសចរណ៍ត្រូវតែគិតគូរដោយ យកចិត្តទុកដាក់ចំពោះទីផ្សារទេសចរណ៍សាកាដូ ព្រោះពួកគេអាចក្លាយជាប្រភពយ៉ាងសំខាន់ក្នុងការរកប្រាក់ចំណូលដែលសក្តិសមទៅនឹងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងតំបន់ ។

បណ្តាសកម្មភាពដ៏ច្បាស់លាស់ដែលអាចវាស់វែងត្រូវបានអនុវត្តដោយក្រសួងទេសចរណ៍ សំរាប់ជាយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រក្នុងឆ្នាំ ២០០៣-២០០៥ ដូចខាងក្រោម៖

១- បង្កើនបន្ថែមនូវសារសំខាន់នៃទេសចរណ៍ ដោយការបណ្តុះបណ្តាលទាំង ១៣ ខេត្តដែលជាអាទិភាព ។

ក. លើកទឹកចិត្តភ្ញៀវទេសចរអោយប្រើប្រាស់ផលិតផលឧស្សាហកម្ម និងកសិកម្មក្នុងមូលដ្ឋានតាមរយៈសិក្ខាសាលាថ្នាក់តំបន់ និងថ្នាក់ជាតិ និងកម្មវិធីអប់រំទៅដល់១៣ខេត្តដែលបានជ្រើសរើស ។

ខ. បណ្តុះបណ្តាលកសិករអោយយល់ដឹងអំពីស្តង់ដារផលិតផលកសិកម្ម និងធ្វើយ៉ាងណាដើម្បីផលិតផលទាំងនេះដោយសហប្រតិបត្តិការជាមួយក្រសួងកសិកម្ម ។

២- ការបង្កើតការងារតាមរយៈ ការពង្រីកផលិតផលទេសចរណ៍ និងការជំរុញលើកទឹកចិត្តអោយប្រើប្រាស់មធ្យោបាយកំលាំងពលកម្មជាមូលដ្ឋាន ។

ក. សិក្សាស្រាវជ្រាវផលិតផលទេសចរណ៍ទាំង ២៤ ខេត្ត-ក្រុង ។

ខ. ប្រើប្រាស់បច្ចេកវិទ្យាតាមមធ្យោបាយកំលាំងពលកម្មជាមូលដ្ឋាន ដើម្បីថែរក្សាការពារបណ្តារមណីយដ្ឋាននានា ។

៣- ការធ្វើអោយសំបូរបែបនៃទេសចរណ៍ទៅជាអេកូ-ទេសចរណ៍ និងទេសចរណ៍វប្បធម៌ផ្សេងៗទៀត ដូចជា តំបន់ដងទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ តំបន់ដីសើមសំខាន់ៗ តំបន់អភិរក្សបរិស្ថានដ៏មានសារសំខាន់ និងតំបន់ភ្នំ ជាពិសេសខេត្តរតនគីរី មណ្ឌលគីរី និងព្រះវិហារ និងតំបន់ឆ្នេរមាន ខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តកំពត និងក្រុងកែប ។

ក. ការផ្សព្វផ្សាយ និងការលើកទឹកចិត្តវិនិយោគិនឯកជន ជាពិសេសសហគ្រាសខ្នាតតូច និងមធ្យមតាមរយៈ សិក្ខាសាលា សៀវភៅមគ្គុទ្ទេសក៏ ការលើកទឹកចិត្តពិសេសផ្សេងៗទៀតដើម្បីវិនិយោគក្នុងតំបន់ទាំងនេះ ។

ខ. ការត្រួតពិនិត្យ និងការស្រាវជ្រាវទៅលើអេកូ-ទេសចរណ៍នៅតាមរមណីយដ្ឋាន ។

គ. បង្កើតសៀវភៅផ្អត់អំពីអេកូ-ទេសចរណ៍ ។

ឃ. ការផ្សព្វផ្សាយ និងផ្ទាំងផ្សព្វផ្សាយជាលក្ខណៈជាតិ និងអន្តរជាតិ ។

៤- ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធប្រមូលពតិមានភ្ញៀវទេសចរណ៍ ។

ក. អភិវឌ្ឍន៍ប្រព័ន្ធពតិមានភ្ញៀវទេសចរណ៍ ។

ខ. ប្រមូលពតិមាន និងផ្សព្វផ្សាយតាម WEB- SITE ។

## ៤.២.៤ ប្រៃសណីយ៍ និងទូរគមនាគមន៍

សេវាប្រៃសណីយ៍ និងទូរគមនាគមន៍ មានលទ្ធភាពដំណើរការបានតែនៅតាមតំបន់ដែលមាន ក្រុងធំៗ និងប្រជាជនច្រើនរស់នៅតែប៉ុណ្ណោះ ។ ព្រោះបញ្ហាសន្តិសុខ ហេដ្ឋារចនាសម្ព័ន្ធ, និងបញ្ហាតំលៃប្រើប្រាស់ គួបផ្សំនិងការយល់ដឹងបានល្អរបស់ប្រជាជនកម្ពុជាទៅលើភាពចាំបាច់ និងផលប្រយោជន៍ នៃការប្រើប្រាស់សេវាទាំងអស់ខាងលើ ។ ប្រសិនបើការប្រតិបត្តិដំណើរ

ការបានល្អ គួបផ្សំនិងតំលៃសេវាមានកំរិតទាប ធ្វើអោយផ្នែកជំនាញនេះអាចមានលទ្ធភាពដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន ។ វានិងអាចមានលទ្ធភាពផ្តល់នូវការផ្សារភ្ជាប់យ៉ាងល្អប្រសើរចំពោះប្រជាជនតាមជនបទទៅនឹងទីក្រុង និងតាមតំបន់ដែលមានអ្នកមានទ្រព្យសម្បត្តិច្រើន ។ សកម្មភាពនេះកើតឡើង មានន័យថាផ្នែកជំនាញនេះអាចជួយផ្សារភ្ជាប់ និងលើកស្ទួយសេដ្ឋកិច្ចតាមជនបទដែលធ្លាប់តែផ្គត់ផ្គង់បានគ្រប់គ្រាន់តែការចញ្ចឹមជីវិតអោយក្លាយជាសេដ្ឋកិច្ចមួយ មានការរីកចំរើនលូតលាស់ ដូចជាសេដ្ឋកិច្ចតាមទីក្រុង និងសេដ្ឋកិច្ចតាមបណ្តាលផ្សារអន្តរជាតិផងដែរ ។

គោលនយោបាយ និងយុទ្ធសាស្ត្រនៃកិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍ ទិសដៅនិងគោលបំណងរបស់រាជរដ្ឋាភិបាល គឺធ្វើអោយមានប្រសិទ្ធិភាពចំពោះតំលៃសេវាកម្មនៃបញ្ហាទូរគមនាគមន៍អោយមានកំរិតទាប ។ ទិសដៅក្នុងរយៈពេលមធ្យម មធ្យមនោះគឺៈ

- បង្កើតអោយមាននូវបណ្តាញទូរគមនាគមន៍ដែលនៅទីក្រុងភ្នំពេញក្រុងព្រះសីហនុ, និងក្រុងសៀមរាប និងពង្រីកនូវការធ្វើសេវាទៅតាមក្រុង, ទីរួមខេត្តជាច្រើនទៀត
- បង្កើតអោយមានបទដ្ឋានថ្នាក់ជាតិ ក្នុងការរៀបចំគំរោង, ការសាងសង់ និងការប្រតិបត្តិការនូវគ្រប់សេវាគមនាគមន៍ ។
- ពង្រឹងអោយបានរឹងមាំក្នុងការបង្កើត រចនាសម្ព័ន្ធកិច្ចការប្រៃសណីយ៍ ព្រមទាំងសមត្ថភាពនៃស្ថាប័ននោះ ដើម្បីធ្វើអោយសេវាកម្មលើកិច្ចការនេះមានការរីកចំរើនប្រសើរឡើងហើយ
- ពង្រីកនូវបណ្តាញការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ។ ការអភិវឌ្ឍន៍ផ្នែកនេះប្រព្រឹត្តទៅបានវាអាស្រ័យទៅលើការធ្វើអោយកាន់តែប្រសើរឡើងនៃគំរោងដែលត្រឹមត្រូវតាមច្បាប់និងការកំណត់នូវកិច្ចការទូរគមនាគមន៍ ហើយបង្កើតនូវប្រសិទ្ធិភាពប្រើប្រាស់នូវប្រភពនៃការធ្វើសេវាលើផ្នែកពតិមាន និងកិច្ចការប្រៃសណីយថែមទៀត ។ ការពង្រឹងនូវ និងផ្តល់នូវការលើកស្ទួយទៅលើវិនិយោគទុនជាលក្ខណៈឯកជននិងការផ្លាស់ប្តូរនូវបទពិសោធន៍ ជាជំរើសខាងផ្នែកហិរញ្ញវត្ថុ ។

ក្នុងរយៈពេល ៥ឆ្នាំខាងមុខ RGC បានប្តេជ្ញាបង្កើតអោយបានស្តារឡើងវិញ និងពង្រីកបណ្តាញទំនាក់ទំនងទូរសព្ទ័ជាមួយអតិថិជននៅទីក្រុងភ្នំភេញ និងបង្កើតអោយមានការទំនាក់ទំនងតាមរលកធាតុអាកាសកំរិតទាប (Microwave) ឬទំនាក់ទំនងតាម FIO ដោយតភ្ជាប់ជាមួយ (១) កំពង់ចាម-ភ្នំពេញ, តាកែវ-កំពត, ក្រុងព្រះសីហនុ (២)កំពង់ចាម កំពង់ធំ, សៀមរាប, ស៊ីសុផុន, (៣) កំពង់ចាម-ក្រចេះ-ស្ទឹងត្រែង ហើយនិង (៤) មណ្ឌលគីរី ប៉ៃលិន, ព្រះវិហារ, ឧត្តរមានជ័យ ។ ការពង្រីកបណ្តាញ និងត្រូវដាក់ទូរបញ្ញា (ទូរតភ្ជាប់បណ្តាញ) នៅស្នាក់ការកណ្តាល ដែលមានចំណុះ ១៥.000 លេខសំរាប់ក្រុងភ្នំពេញ និងភ្ជាប់បណ្តាញ ទៅប៉ោយប៉ែត បន្ទាយមានជ័យ បាត់បំបង, ពោធិសាត កំពង់ឆ្នាំង អ្នកលឿង, ស្វាយរៀង បាវិត។ គោលដៅដែលត្រូវពង្រីកនេះ គឺធ្វើយ៉ាងណាអោយបានសមល្មមទៅនិងចំនួនប្រជាជន ដោយយ៉ាងហោចណាស់ក្នុងមួយខ្សែបណ្តាញ ប្រើប្រាស់សំរាប់ប្រជាជន ១00នាក់ ដោយអនុវត្តនៅទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងសៀមរាប ព្រមទាំងពង្រីកនូវសេវាកម្មនេះអោយដល់ក្រុង និងទីរួមខេត្តផ្សេងៗទៀត ។

សកម្មភាពផ្សេងៗទៀតដែលត្រូវបំពេញរួមមានៈ ការរៀបចំ និងធ្វើអោយមានគោលការណ៍អនុវត្តន៍ត្រឹមត្រូវចំពោះសកម្មភាពរបស់ទូរគមនាគមន៍ ដើម្បីផ្តល់នូវគំរោងជាផ្លូវការ ចំពោះកិច្ចការដែលបានបង្កើតឡើង, លើកជាមតិចំពោះមូលដ្ឋានទិន្នន័យរបស់ MPTC និងការពង្រីកបណ្តាញទទួលពតិមានគ្រប់ប្រភេទ ដែលទាក់ទងទៅនិងកិច្ចការជាមួយមូលដ្ឋាន

សំរាប់ដំណើរការបញ្ចប់នូវការសិក្សាស្រាវជ្រាវ ដើម្បីធ្វើការអភិវឌ្ឍន៍អោយកាន់តែស៊ីជំរៅលើគំរោងការរយៈពេលវែងសំរាប់ការតភ្ជាប់បណ្តាញនៅតាមបណ្តាទីរួមខេត្តនានា. ការអនុវត្តនៃគំរោងនេះ គឺជាអាទិភាពក្នុងការពង្រីកបណ្តាញ សំរាប់ការអភិវឌ្ឍន៍នៃប្រពន្ធ័តាមខេត្ត ការបញ្ជាក់នូវការសិក្សាស្រាវជ្រាវដោយ CT បានបង្ហាញ និងបញ្ជាក់យ៉ាងពិស្តារពីទីតាំងដែល ត្រូវរៀបចំគំរោងដោយមានការស៊ីសង្វាក់គ្នា ជាមួយការលើកគំរោងរបស់អ្នកជំនាញតាមខេត្តដែលបានលើកឡើង. ការអភិវឌ្ឍន៍ ដែលលើកឡើងដោយ CT បានកំណត់ដល់ស្ថាប័ននូវតំរូវការមួយចំនួនដូចជាគ្រឿងបរិក្ខារ. សំភារៈផ្គត់ផ្គង់ និងសំភារៈផ្សេង ៗ ទៀត និងការអនុវត្តអោយត្រឹមត្រូវលើកិច្ចការគណនេយ្យ និងការត្រួតពិនិត្យដើម្បីស្តារឡើងវិញ និងពង្រីកបណ្តាញថ្មីនៅតាមមូលដ្ឋាន. បង្កើតអោយមានបណ្តាញថ្នាក់ជាតិ និងមានការអនុវត្តន៍ សំរាប់កិច្ចការរៀចំធ្វើគំរោង. ការស្ថាបនា និងការប្រតិបត្តិ ចំពោះគ្រប់សេវាកម្មបំរើ អតិថជន និងគ្រប់ប្រពន្ធ័ ទូរគមនាគមន៍ ។

ក្នុងរយៈពេល ៥ឆ្នាំខាងមុខរាជរដ្ឋាភិបាលនឹងធ្វើការៈ

- ពង្រឹងអោយបានរឹងមាំ នូវការបង្កើតនូវរចនាសម្ព័ន្ធ និងសមត្ថភាពនៃស្ថាប័ននោះដោយកំណត់អោយអនុវត្ត អោយបានប្រាកដប្រជានិងមានប្រសិទ្ធិភាពខ្ពស់ក្នុងការធ្វើសេវាលើកិច្ចការប្រៃសណីយ៍ ។
- យកអស់សមត្ថភាពក្នុងការដោះស្រាយនូវគ្រឿងបរិក្ខារ សំភារៈផ្គត់ផ្គង់ និងសំភារៈផ្សេងទៀត ។
- បង្កើតអោយមាននូវប្រព័ន្ធគណនេយ្យ និងអធិការកិច្ចអោយបានសមស្រប ។
- បង្កើតអោយមានមូលដ្ឋានទិន្នន័យ នៃគ្រប់ទ្រព្យសកម្ម និងហត្ថពលិកដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍន៍ផែនការ. ការបណ្តុះបណ្តាល និង ការត្រៀមសារជាថ្មីនូវការចាត់តាំងកំលាំងតាមស្ថាប័ននីមួយៗ
- លើកគំរោងសិក្សាវាយតំលៃ ប៉ាន់ស្មានក្នុងការធ្វើអោយប្រសើរឡើងលើការពង្រីកបណ្តាញសេវាកម្មផ្នែក ប្រៃសណីយ៍រហូតដល់បណ្តាឃុំនានា ហើយនឹង
- លើកស្ទួយការបង្កើតនូវការទទួល និងបញ្ជូនលិខិតនានាដែលមកពីបណ្តាខេត្ត ។ កិច្ចការនេះរាជរដ្ឋាភិបាល និងធ្វើអោយបានប្រាកដប្រជា នូវចំនួនមូលនិធិនេះ គឺសំរាប់តែធ្វើសេវាកម្ម បំរើនូវរាល់តំរូវការប្រើប្រាស់របស់ការិយាល័យប្រៃសណីយ៍ និងទូរគមនាគមន៍ ប៉ុណ្ណោះ ។

## ៤.២.៥ មីក្រូហិរញ្ញវត្ថុ

ប្រជាជននៅតាមទីជនបទមានលទ្ធភាពតិចតួចបំផុតក្នុងការខ្ចីឥណទានជនបទ ។ ប្រជាជននៅតាមជនបទមានលទ្ធភាពតិចតួចក្នុងការទទួលឥណទានជនបទជាផ្លូវការដែលមានអាត្រាការប្រាក់ទាប ។ ការរីកសាយនៃទីផ្សារឥណទានក្រៅផ្លូវការដែលយកអត្រាការប្រាក់ខ្ពស់ប្រមាណពី ១០ - ១៥ ភាគរយក្នុងមួយខែ បានបង្ហាញនូវសេចក្តីត្រូវការឥណទានជនបទនៅកម្ពុជា ។ គេត្រូវការឥណទានដើម្បីយកទៅជំនួសអោយការ ខ្ចីបុលសំរាប់ប្រើប្រាស់បំពេញការខ្វះខាតស្រូវអង្ករក្នុងគ្រួសារដែលអ្នកអោយខ្ចីកេងប្រវ័ញ្ចខ្លាំងហើយវាចាំបាច់សំរាប់សំរួល និងបង្កើនផលិតកម្មនិងទិន្នផលស្រូវដោយផ្តល់នូវមូលនិធិសំរាប់ទិញជីនិងគ្រាប់ពូជ ។ កំចីទាំងនេះនឹងជួយផ្តល់សន្តិសុខស្បៀងសំរាប់ប្រជាជនក្រីក្រដែលអាចឱ្យពួកគេកាន់តែមានផលិតភាពថែមទៀត និងមានស្ថេរភាពក្នុងការធ្វើស្រែចំការ ។ កំចីក៏ជាតំរូវការផងដែរក្នុងការបែងចែកចំណូលតាមរយៈសកម្មភាព អាជីវកម្ម/សហគ្រាសដែលមានខ្នាតតូច ។

គោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំរេចឱ្យបានទូវការអភិវឌ្ឍន៍ជនបទតាមរយៈការពន្លឿន ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងតាមរយៈការលើកកំពស់ជីវភាពរបស់ប្រជាជននៅតាមទីជនបទ ។ គោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការឆ្ពោះទៅរកឥណទានជនបទគឺជាការគាំទ្រមួយនៅកំរិតមួយដូចគ្នាទៅនឹងការយកចិត្តទុកដាក់ និងការទទួលខុសត្រូវក្នុងការពារនូវភាពត្រឹមត្រូវនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ លើកកំពស់ការជឿជាក់របស់សាធារណជន ការពារអ្នកដាក់ប្រាក់បញ្ញើ បង្ការទល់នឹងការកេងបន្លំ និងជំរុញឱ្យមានការអនុវត្តន៍ ការគ្រប់គ្រងល្អប្រសើរបំផុត ។

ធនាគារិកដែលមានវិជ្ជាជីវៈពុំមានគ្រប់គ្រាន់នៅតាមគ្រឹះស្ថានហិរញ្ញវត្ថុជនបទ ។ ដូច្នេះហើយឧបសគ្គចំបងដែលជួបប្រទះនៅក្នុងឥណទានជនបទ គឺស្ថិតនៅជុំវិញការគ្រប់គ្រងផលប័ត្រឥណទាននិងការវាយតំលៃហានិភ័យ ។ លើសពីនេះទៅទៀតការផ្តល់ឥណទានជនបទបានប្រព្រឹត្តទៅក្នុងបរិបទមួយដែលមានក្របខ័ណ្ឌច្បាប់ពុំគ្រប់គ្រាន់ និងប្រព័ន្ធតុលាការពុំទាន់មានប្រសិទ្ធភាពពេញលេញ ។

ម្យ៉ាងវិញទៀតឱកាសរបស់យើងគឺមានភាពទូលំទូលាយដែលប្រមាណ ៨០ ភាគរយនៃប្រជាជនកម្ពុជាទាំងអស់រស់នៅតាមទីជនបទ ចែកចេញជាប្រមាណ ១,៨៧ លានគ្រួសារ ។ រហូតដល់ខែធ្នូ ឆ្នាំ២០០១ ចំនួនឥណទានសរុបដែលផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ១០,២៧ លានដុល្លារអាមេរិក សំរាប់វិស័យកសិកម្ម ស្មើនឹង ៤,១៩ ភាគរយនៃការផ្តល់ឥណទានសរុបរបស់ធនាគារពាណិជ្ជ ។ ធនាគារពាណិជ្ជភាគច្រើន មិនមានសាខានៅតាមបណ្តាខេត្តទេ ។ ទោះបីជាធនាគារទាំងនោះបានបង្កើតសាខានៅតាមខេត្តខ្លះក៏ដោយ ក៏សាខាទាំងនោះប្រមូលផ្តុំនៅតែតាមទីប្រជុំជនសំខាន់ៗប៉ុណ្ណោះ ហើយពុំមាននៅតាមស្រុក តាមឃុំ តាមភូមិទេ ។ លទ្ធភាពនៃការពង្រីកសេវាកម្មធនាគាររបស់ធនាគារពាណិជ្ជទាំងនោះនៅតាមបណ្តាខេត្ត ស្រុក ឃុំ ឬភូមិនៅមានកំរិតនៅឡើយ ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាល និងធនាគារឯកទេសបានផ្តល់សេវាកម្មឥណទានទៅដល់ប្រជាជននៅតាមទីជនបទដែលមានតំរូវការឥណទានពុំបានជាប់រហូតទេ ។ នាពេលបច្ចុប្បន្ននេះស្ថាប័នទាំង នោះបានផ្តល់កំចីជាមូលនិធិទៅដល់ក្រុមគ្រួសារនៅតាមទីជនបទចំនួន ២៦៤.៤៥២ គ្រួសារ ។ ចំនួនសរុបនៃឥណទានដែលបានផ្តល់អោយនាពេលបច្ចុប្បន្ននេះត្រូវបានប៉ាន់ស្មានមានប្រហែល ៤១ លានដុល្លារអាមេរិក ។ គេបានប៉ាន់ប្រមាណឃើញថា ឥណទានបន្ថែមចំនួនពី ១០ ទៅ ១៥ លានដុល្លារអាមេរិក ត្រូវបានផ្តល់ដោយក្រុមគ្រួសារសាច់ញាតិ មិត្តភ័ក្រ និងអ្នកអោយខ្ចីចងការប្រាក់ ។ ចំពោះឥណទានសរុបសំរាប់ទីជនបទនៃ ស្ថាប័នទាំងនោះសំរាប់រយៈពេល ១០ ឆ្នាំមុន បានកើនឡើងពី ១០០.០០០ ដុល្លារអាមេរិក ដល់ ៤១ លានដុល្លារអាមេរិក និងពី ៤.០០០ ទៅដល់ ២៦៤.៤៥២ កូនបំណុលចុងក្រោយ ។ យ៉ាងណាមិញកង្វះខាតនៃមូលធនឥណទានមានចន្លោះពី ៦០ ទៅ ៩០ លានដុល្លាអាមេរិក ដើម្បីឆ្លើយតបដោយប្រសិទ្ធភាពទៅនឹង ការកើនឡើងតំរូវការទូទាំងប្រទេស ។

គេឃើញថាកំណែនប្រាក់សន្សំនៅក្នុងប្រទេសកម្ពុជានៅតែមានចំនួនតិចតួចដដែល ។ ជាលទ្ធផល គ្រឹះស្ថានហិរញ្ញវត្ថុជនបទភាគច្រើនបានផ្តល់មូលនិធិសំរាប់សកម្មភាពផ្តល់ប្រាក់កំចីរបស់ពួកគេជាមួយនឹង មូលនិធិដែលទទួលបានពីអ្នកផ្តល់ជំនួយ និងពីធនាគារដែលផ្តល់កំចី ។ ធនាគារអភិវឌ្ឍន៍ជនបទ គឺជាប្រភពដ៏សំខាន់មួយក្នុងការផ្តល់ឥណទានទៅដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងអង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីជាប្រតិបត្តិការមីក្រូឥណទាន ។

## ៤.២.៦ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គោលនយោបាយការងារ និងការបណ្តុះបណ្តាលរួមមាន ការផ្តល់ឱកាសផ្លាស់ប្តូរទីកន្លែង ជំនាញថ្មី ដូចជាបច្ចេកវិទ្យាពត៌មាន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានផ្សារភ្ជាប់ទៅនឹងគោលនយោបាយអប់រំដែលមានចែងក្នុងផ្នែក ៤.៣.៣ ។

ការនាំចេញនូវពលកម្មជាជំរើសមួយដ៏សំខាន់ សំរាប់កាត់បន្ថយភាពក្រីក្រក្នុងបណ្តាប្រទេសជិតខាងកម្ពុជានៅទ្វីប អាស៊ី ដូចជា ប្រទេសហ្វីលីពីន ប្រទេសស្រីលង្កា ប្រទេសថៃ និងប្រទេសវៀតណាម ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលគឺលើកទឹកចិត្តការនាំចេញពលកម្មជាផ្លូវការ ដើម្បីបង្កើនសុខុមាលភាព ធ្វើអោយប្រសើរឡើងនូវជំនាញ កាត់បន្ថយភាពគ្មានការងារធ្វើ និងបង្កើនប្រាក់ចំណូលរដ្ឋ ។ ឧបសគ្គដល់ការនាំចេញពលកម្មរបស់ពលកររួមមាន ក៏រិតវប្បធម៌ទាប និងជំនាញភាសាបរទេសនៅមានកំរិត ការប្រកួតប្រជែងទីផ្សារការងារបានកើនឡើងសំរាប់ការនាំចេញពលកម្ម តំរូវការបែបបទរដ្ឋបាល និងនិយតកម្មមានលក្ខណៈស្មុគ្រស្មាញ ។ កសាងគោលនយោបាយ និងបទបញ្ញត្តិ របស់រដ្ឋាភិបាលសមស្រប និងការរៀបចំទ្វេភាគី ដែលពុំបានធ្វើអោយកើនឡើងនូវតំលៃ ដើម្បីការពារផលប្រយោជន៍គ្រប់គ្រាន់សំរាប់ពលករបំរើការងារនៅបរទេស ដែលមានលក្ខណៈប្រកួតប្រជែង ។ ក្នុងផ្នែកនេះត្រូវការចាំបាច់នូវជំនួយបច្ចេកទេស និងត្រូវទាញយកនូវការសំបូរបែបនៃបទពិសោធន៍ក្នុងតំបន់ ក្នុងការកសាងបទបញ្ញត្តិ និងគោលនយោបាយទីផ្សារការងារ ។

### គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់ការងារ និងការបណ្តុះបណ្តាល

ប្រាក់កំរៃទាប និងច្បាប់ការងារ បច្ចេកវិទ្យាពត៌មានមានលទ្ធភាពច្រើនក្នុងការផ្តល់អោយផ្នែកទាំងអស់នេះឆ្ពោះទៅរកប្រព័ន្ធដែលអាចធ្វើអោយមានផលិតផលខ្ពស់ ។ យុវជនកម្ពុជាមួយចំនួនបានកំពុងតែចាប់យកបច្ចេកវិទ្យាពត៌មាន រួចទៅហើយដោយផ្អែកលើសកម្មភាពអនុវត្តរបស់ពួកគេ ។ ក្នុងករណីមួយចំនួនប្រព័ន្ធបច្ចេកវិទ្យាពត៌មានកំពុងត្រូវបានប្រើប្រាស់ដឹកនាំពត៌-មានទីផ្សារ និងធ្វើអោយការជួញដូររបស់សិប្បកម្មផលិតតាមភូមិឆ្ងាយពីទីក្រុងកំពុងមានដំណើរការ ។ ក្នុងករណីខ្លះទៀតប្រជា-ជនកម្ពុជាកំពុងតែតំណើរការទិន្នន័យដែលបានមកពីប្រទេសនានានិងនាំចេញនូវសេវាដំណើរការទិន្នន័យប្រកបដោយប្រសិទ្ធិភាព ។

ដើម្បីទាញយកនូវផលប្រយោជន៍ជាអតិបរិមាពីការផ្លាស់ប្តូរទីផ្សារពិភពលោក ប្រទេសកម្ពុជាត្រូវការចាប់ផ្តើមដោះស្រាយសកម្មភាពពាក់ព័ន្ធផ្ទៃក្នុងទាំង៣កំរិតៈ ការធ្វើអោយប្រសើរឡើងនូវលទ្ធភាពទីផ្សារ ដោយភ្ជាប់ទៅនឹងកម្មវិធីផ្សារភ្ជាប់រវាងជំនួយបច្ចេកទេស និងការកសាងសមត្ថភាព និងផ្អែកលើមូលដ្ឋានការកែតំរូវ និងការកែទំរង់គោលនយោបាយក្នុងស្រុកជាបន្តបន្ទាប់ ។

ប្រជាជនដែលមានជំនាញទាប ជាពិសេសជនងាយរងគ្រោះក្លាយជាអ្នកទទួលយកការងារមិនពេញលេញ (ផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ ឆ្នាំ២០០១) ។ ច្បាប់ការងារដ៏មានប្រសិទ្ធិភាព និងការបង្កើនឱកាសផ្តល់ការបណ្តុះបណ្តាលជំនាញគឺមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហានេះ ។ អគ្គនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារធានាបង្កើនលទ្ធភាពការផ្តល់ឱកាសបង្កើនប្រាក់ចំណូល ធានាបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងទីផ្សារការងារ និងតាមរយៈការអភិវឌ្ឍន៍លក្ខខណ្ឌកិច្ចការពារការងារសំរាប់និយោជក ។

## ៤.២.៧ ការអភិវឌ្ឍន៍ឧស្សាហកម្ម

រាជរដ្ឋាភិបាលបានលើកទិសដៅជំរុញការងអភិវឌ្ឍន៏ផ្នែកឯកជន ដោយបានជ្រើសរើស និងកំណត់គោលនយោបាយដោយម៉ត់ចត់ដែលសរុបរួមមានៈ (១)លើកទឹកចិត្តដល់ការរីកលូតលាស់ផ្នែក SME ជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងវែង (២)ទប់ស្កាត់ការនាំចូលទំនិញដោយសហគ្រាសរដ្ឋ ដោយធ្វើការសហការ ឬធ្វើឯកជនភាវូបនីយកម្ម (៣) ទប់ស្កាត់ការនាំចូលទំនិញដោយខុសច្បាប់ (៤)បន្ថយរបាំងលើការនាំចេញដូចជាពន្ធនាំចេញ និងកាត់បន្ថយបែបបទនាំចេញ (ដូចជាអាជ្ញាប័ណ្ណ) (៥)កាត់បន្ថយរបាំងលើការនាំចូល (៦)ផ្តល់ការគាំពារឧស្សាហកម្មក្មេងខ្ចីមួយចំនួនក្នុងរយៈពេលសមស្រប មួយ (៧)ជំរុញការចងសម្ព័ន្ធរវាង SME និងឧស្សាហកម្មធុនធំ (៨)ជំរុញបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដែលជួយដល់ឧស្សាសហ-កម្មធុនតូច និងមធ្យមដោយការបង្កើនផលិតភាព និងកាត់បន្ថយថ្លៃដើមផលិតកម្ម (៩)បង្កើតវិទ្យាស្ថានស្តង់ដារជាតិ ដែលធ្វើអោយគុណភាពផលិតផលសមស្របទៅនឹងស្តង់ដារតំបន់ និងអន្តរជាតិ (១០)បង្កើតមន្ទីរពិសោធន៏ជាតិផ្នែករូបគីមី មីក្រូជីវៈមេកានិច និងការធ្វើតេស្ត ដែលអាចកំណត់បានលើគុណភាព និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល (១១)បង្កើត ការិយាល័យកម្មសិទ្ធបញ្ញាឧស្សាកម្ម ដែលការពារដល់ការលួចចម្លងដោយខុសច្បាប់ក្នុងការរិះរកបច្ចេកទេសវិទ្យាថ្មី និងផលិតផលថ្មី (១២)ជំរុញដល់ការបណ្តុះបណ្តាលមុខវិជ្ជាជំនាញទាំងនៅក្នុង និងក្រៅប្រទេស (១៣) បង្កើនចលនាចំនួនភូមិមួយ-ផលិតមួយ និង (១៤)ពង្រឹងនូវប្រព័ន្ធច្បាប់ ដោយបង្កើតច្បាប់រោងចក្រ ច្បាប់តំបន់ឧស្សាហកម្ម ច្បាប់ប៉ាតង់ និងតក្កកម្ម ឧស្សាហកម្ម ច្បាប់រង្វាស់រង្វាល់ ច្បាប់សុវត្ថិភាពឧស្សាហកម្ម ។

ផែនការសកម្មភាពអភិវឌ្ឍន៏ឧស្សាហកម្មរបស់រាជរដ្ឋាភិបាល (១៩៩៨-២០០៣) មានគោលដៅធំពីរយ៉ាងគឺ គាំទ្រដល់ការអភិវឌ្ឍន៏ឧស្សាហកម្ម តំរង់ទិសនាំចេញ និងអភិវឌ្ឍន៏ឧស្សាហកម្ម ផលិតទំនិញជំនួសការនាំចូលមួយចំនួន ដែលអាចសំរេចបានដោយជំរុញៈ (១)ឧស្សាហកម្ម ប្រើប្រាស់ពលកម្មច្រើន (២)ឧស្សាហកម្មផ្អែកលើធនធានធម្មជាតិ (៣)ឧស្សាហកម្មតូច និងមធ្យម (៤)កសិ-ឧស្សាហកម្ម (៥)ការផ្ទេរបច្ចេកវិទ្យា និងបង្កើនគុណភាពផលិតផលឧស្សាហកម្ម (៦)បង្កើតតំបន់ឧស្សាហកម្ម (៧)ការអភិវឌ្ឍន៏ឧស្សាហកម្ម ផលិតទំនិញដោយជ្រើសរើសជំនួសការនាំចូល ។

ការជំរុញឧស្សាហកម្ម ប្រើប្រាស់ពលកម្មច្រើន នឹងត្រូវបន្តទៀតដោយផ្តោតទៅលើឧស្សាហកម្មវាយនភ័ណ្ឌ និងផ្នែកកាត់ដេរ ។ ដែលផ្នែកទាំងនេះត្រូវបានផ្តល់ការងារដល់នារី និងប្រកបដោយតម្លៃអាចប្រកួតប្រជែងបាន។ ទោះជាយ៉ាងនេះក្តីរដ្ឋាភិបាលបានទទួលស្គាល់ថា ទីផ្សារនៅដដែល ឬកើនឡើងដោយត្រូវប្រកួតប្រជែងជាអន្តរជាតិ ដែលតំរូវអោយមានការបង្កើនគុណភាពផលិតផលដូចជាត្រូវ បង្កើនផលិតភាពដោយពង្រឹងបច្ចេកវិទ្យា និងការគ្រប់គ្រង។ ការអភិវឌ្ឍន៏នៃការទំនាក់ទំនងវិស័យឧស្សាហកម្មអោយបានប្រសើរឡើងគឺអាស្រ័យទៅលើការពង្រឹងប្រព័ន្ធច្បាប់ ដែលជាការចាំបាច់ ហើយការកើនឡើងនៃផលប៉ះពាល់ដល់វិស័យឧស្សាហកម្មកាត់ដេរ ក៏ជាការចាំបាច់ត្រូវធ្វើការតាមដានសិក្សាដែរ។ បច្ចុប្បន្នវិស័យកាត់ដេរបានដំណើរការតែលើការតាត់ដេរប៉ុណ្ណោះដោយក្រណាត់ និងគ្រឿងបន្ទាប់បន្សំ (ដូចជាខ្សែរូត ឡេវ អំបោះ)ត្រូវបាននាំចូលហើយការផ្គត់ផ្គង់នៅក្នុងប្រទេសមានត្រឹមតែការដឹកជញ្ជូនសេវាកម្មដំណើរ ការរោងចក្រ និងសំណង់អាគាររោងចក្រប៉ុណ្ណោះ។

ដើម្បីអោយមានមូលដ្ឋានផលិតកម្មនាំចេញថ្មីៗទៀត រដ្ឋាភិបាលនឹងលើទឹកចិត្តដល់ផលិតកម្មដែល ផលិតដោយការទិញអាជ្ញាប័ណ្ណផលិត ឬតាមរយៈការវិនិយោគបរទេសដោយផ្ទាល់ ដូចជាផលិតកម្មណាដែលគេរំពឹងគិតថាវាសមស្របទៅនឹងលទ្ធភាពប្រទេសដូចជាកីតជំនាញទាប ឬម្យ៉ាងទៀតដូចជាការជំរុញដល់ការផ្គុំ ឬតម្លើងផលិតផល អេឡិចត្រូនិក ដែលគ្រឿងបំណែកទាំងនោះត្រូវបាននាំចូល ។

ការជំរុញឧស្សាហកម្មដែលផ្អែកលើធម្មជាតិ ផ្តោតទៅលើការកំណត់ និងការធ្វើអាជីវកម្មនៃការកែច្នៃធនធានធម្មជាតិក្នុងនោះធនធានរ៉ែ អលោហៈ ឈើ និងជលផល ។ ការអភិវឌ្ឍន៍នៃការចិញ្ចឹមត្រី និងសត្វ វានឹងអាចផ្តល់ជាវត្ថុធាតុដើមសំរាប់ការកែច្នៃឡើងវិញរបស់រោងចក្រ ។ ទោះយ៉ាងនេះក្តីទស្សនៈជាចំបងនៅក្នុងផ្នែកនេះគឺការផលិតសំភារៈ សំណង់ដែលចេញពីរ៉ែអលោហៈ ។

## ការអភិវឌ្ឍន៍ថាមពល

យុទ្ធសាស្ត្រផ្នែកថាមពលកម្ពុជា (២០០១-២០០៥) បានកំណត់អាទិភាព និងគោលដៅចំបងនូវកម្មវិធីវិនិយោគដើម្បីបញ្ចុះថ្លៃអគ្គិសនី និងការផ្គត់ផ្គង់ដើម្បីធានាបានការទុកចិត្តដល់រាល់អតិថិជន ។ នៅក្នុងកម្មវិធីវិនិយោគរួមមានៈ (១)អភិវឌ្ឍន៍ប្រព័ន្ធផលិតកម្ម និងប្រព័ន្ធបញ្ជូនភ្ជាប់រវាងប្រព័ន្ធផលិតកម្មនៅទីក្រុងភ្នំពេញទៅនឹងបណ្តាទីរួមខេត្ត (២)គំរោងផ្គត់ផ្គង់អគ្គិសនីនៅបណ្តាទីរួមខេត្ត (៣)អភិវឌ្ឍន៍ និងលើកកម្មវិធីអនុវត្តអគ្គិសនីភាវូបនីយកម្មជនបទ ។ ការស្តារ និងពង្រីកប្រព័ន្ធផ្គត់ផ្គង់សមត្ថភាពផលិតកម្មអគ្គិសនីនៅទីក្រុងភ្នំពេញ បាននឹងកំពុងបន្តអនុវត្តន៍តាមរយៈការនាំចូលអគ្គិសនីពីប្រទេសវៀតណាម និងគំរោងការសាងសង់រោងចក្រអគ្គីសនីដោយចំហាយនៅតាមតំបន់មាត់សមុទ្រ ។ ការអនុវត្តន៍នេះនឹងធ្វើឱ្យមានភាពប្រសើរធានាឱ្យជឿជាក់បានក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅតំបន់ភ្នំពេញ ។

កម្មវិធីនៃការបង្កើតប្រព័ន្ធផលិតកម្ម និងបញ្ជូនជាតិបានចាប់ផ្តើមពីឆ្នាំ ២០០០ ។ ជំហានទី១ នៃកម្មវិធីនេះគឺការតភ្ជាប់ខ្សែបញ្ជូនថាមពលពីប្រទេសវៀតណាមមកទីក្រុងភ្នំពេញដោយកាត់តាមខេត្តតាកែវ ។ ជំហានទី២ គឺការតភ្ជាប់ខ្សែបញ្ជូនថាមពលពីក្រុងព្រះសីហនុមកខេត្តកំពត ការបង្កើតប្រព័ន្ធផលិតកម្មថាមពលអគ្គិសនីដោយចំហាយនៅតាមតំបន់ឆ្នេរសមុទ្រ នឹងបង្កើនសន្តិសុខក្នុងការផ្គត់ផ្គង់តាមបណ្តាខេត្តក្រុងដទៃទៀតដែលស្ថិតនៅរវាង ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ វាក៏បានបន្ថយផងដែរនូវការបន្ថយការដឹកនាំប្រេងតាមដងទន្លេមេគង្គ នឹងពុំបង្កផលប៉ះពាល់ដល់បរិស្ថាន ។ ផ្នែកមួយនៃប្រព័ន្ធខ្សែបញ្ជូនថាមពល គឺការតភ្ជាប់រវាងពីព្រំដែនប្រទេសវៀតណាមមកក្រុងភ្នំពេញឆ្លងកាត់តាមខេត្តតាកែវរំពឹងនឹងដាក់ឱ្យដំណើរការក្នុងឆ្នាំ ២០០៥ ខ្សែបញ្ជូននេះបង្កើនការផ្គត់ផ្គង់ដល់ក្រុងភ្នំពេញ និងតំបន់ភាគខាងត្បូងប្រទេស ។

កម្មវិធីអគ្គិសនីភាវូបនីយកម្មជនបទរយៈពេល៥ឆ្នាំ រួមទាំងការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងអនុវត្តតាមកាលបរិច្ឆេទដែលបានគ្រោង ទំហំនៃការវិនិយោគសរុបក្នុងកម្មវិធីនេះរួមទាំងការតភ្ជាប់ខ្សែបញ្ជូនពីប្រទេសវៀតណាមមានតំលៃសរុបប្រមាណ ៨៩ លានដុល្លាអាមេរិក ។ ការតភ្ជាប់ខ្សែបញ្ជូន ១១៥ KW ពីប្រទេសថៃមកផ្គត់ផ្គង់ឱ្យខេត្តចំនួន ៣ៈ បន្ទាយមានជ័យ, បាត់ដំបង, សៀមរាប គ្រោងនឹងចាប់ផ្តើមអនុវត្តក្នុងរយៈពេលដ៏ខ្លីខាងមុខ ។ ក្នុងគំរោងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គីសនីក៏បានបញ្ចូលផងដែរនូវការអភិវឌ្ឍន៍វារីអគ្គិសនីកំចាយ-ស្ទឹងបាត់ដំបង-ស្ទឹងអាតាយ និងស្ទឹងឬស្សីជ្រុំ ។ ពាក់ព័ន្ធទៅនឹងការសាង-

សង់វារីអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា បានភ្ជាប់ទៅនឹងការគិតគូរអំពីលំនឹងរវាងកំណើនសេចក្តីត្រូវការថាមពលបរិស្ថាន និងសង្គម ។ ការខិតខំប្រឹងប្រែងដើម្បីជៀសវាងនូវកំហុស ផ្សេងៗនៃប្រទេសជិតខាងដោយការអភិវឌ្ឍន៍ផ្នែកវារីអគ្គីសនីមិនត្រឹមគិតគូរតែត្រឹមបញ្ហាបរិស្ថានធម្មជាតិ និងសង្គមប៉ុណ្ណោះទេ ប៉ុន្តែក៏គិតគូរផងដែរអំពីបញ្ហាសេដ្ឋកិច្ច ។ ថាមពលនៃអគ្គីសនីភាវូបនីយកម្មជនបទ និងការបង្កើតការងារនៅជនបទ នឹងបង្កើនកំរិតចំណូលដល់ប្រជាជនជនបទ ។

ចំពោះផលិតកម្មឧស្សាហកម្ម និងសិប្បកម្ម រដ្ឋាភិបាលមានទិសដៅផ្តល់អាទិភាពដល់ការជំរុញ សិប្បកម្មប្រពៃណីសំរាប់ទីផ្សារទេសចរណ៏ទាំងនៅក្នុងតំបន់ជនបទ និងទីក្រុង។ ម្យ៉ាងទៀតសក្តានុពលភាពក្នុងការពង្រីកផលិតកម្មថ្នាំជក់ក្នុងទ្រង់ទ្រាយតូចអាចចូលរួមចំណែកក្នុងការផ្តល់វត្ថុធាតុដើមដល់ផលិតកម្មទ្រង់ទ្រាយធំ។ យ៉ាងនេះក្តីដើម្បីអោយបានជោគជ័យសហគ្រាសទាំងនេះចាំបាច់ត្រូវតែរក្សាគុណភាពផលិតផលឱ្យបានជាប្រចាំ។ ជាបន្ថែមទៀតដោយសារតែគេមិនបានទទួលឥណទានមានការប្រាក់ទាបគេបានខ្ចីប្រាក់ដែលមានការប្រាក់ខ្ពស់ ដូច្នេះចាំបាច់ត្រូវតែមានមីក្រូឥណទាន។

យុទ្ធសាស្ត្រសួលសំរាប់ការអភិវឌ្ឍន៍កសិឧស្សាហកម្មគឺការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនទាំងក្នុងស្រុក និងបរទេសសំរាប់រយៈពេលវែង និងលើកទឹកចិត្តដល់ការចូលរួមពីម្ចាស់កម្មសិទ្ធដីតូចៗក្នុងស្រុកតាមរយៈកិច្ច សន្យាជាមួយរោងចក្រកែច្នៃ នៅក្នុងតំបន់។ ការអភិវឌ្ឍន៏កសិឧស្សាហកម្មទាមទារចាំបាច់កិច្ចសហការដ៏ជិតស្និទ្ធរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរដែនដី ដូចជាផ្តល់ជំនួយការបច្ចេកទេស និងការកំណត់ពីសក្តានុពលសំរាប់ការអភិវឌ្ឍន៍។ ការពង្រឹងចំណងសេដ្ឋកិច្ចរវាងកសិកម្មនិងឧស្សាហកម្ម នៅក្នុងបរិបទនៃការគ្រប់គ្រងបរិស្ថានមានសារៈសំខាន់សំរាប់ការបង្កើតប្រាក់ចំណុល និងការងារ។

## ៤.២.៨ ការអភិវឌ្ឍន៍ទីក្រុង

តាមទស្សនៈវិស័យរបស់សាលាក្រុងភ្នំពេញ (ក៏ដូចជានៅតាមបណ្តាទីក្រុងនានានៃបណ្តាប្រទេសអាស៊ី) យល់ឃើញថាការអភិវឌ្ឍន៏ទីក្រុងនិងការអភិវឌ្ឍន៏សង្គមពុំមានការទំនាក់ទំនងនោះហើយ ដែលអនុញ្ញាតិអោយមានការកាត់បន្ថយភាពក្រីក្រ ។ ផ្ទុយទាំងស្រុងទៅនឹងការអភិវឌ្ឍន៏ជនបទ (ដែលមានបំណងយ៉ាងពិតប្រាកដ ដើម្បីផ្តល់ផលប្រយោជន៏ទៅអ្នកក្រីក្រនៅតាមជនបទ) ការអភិវឌ្ឍន៍ទីក្រុងត្រូវបានកត់សំគាល់ជាទំនើបរូបនីយកម្មជាក់ស្តែង និងការរីករាលដាលនៃទីក្រុង តាមរយៈការបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់លំនៅដ្ឋាន អាគារពាណិជ្ជកម្ម សាលារៀន មន្ទីរពេទ្យ ការិយាល័យរដ្ឋាភិបាលគ្រឿងប្រដាប់បរិក្ខាប្រើប្រាស់ផ្សេងៗ និងសេវាកម្មនានា បំរើជាសំខាន់អោយទៅតែផ្នែកនានា សំរាប់អ្នករស់នៅក្នុងទីក្រុង ។ អ្នកក្រីក្រក្នុងទីក្រុងដែលភាគច្រើនជាអ្នកចូលទៅរស់នៅឥតច្បាប់ អ្នករស់នៅតាមចិញ្ចើមថ្នល់ត្រូវបានគេមើលឃើញថា ជាឧបសគ្គមួយសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដោយការកាន់កាប់ដីធ្លីសាធារណៈ និងដោយសាររបៀបរបបរស់នៅរបស់ពួកគេមិនស្របគ្នាទៅនិងរបៀបរស់នៅទំនើបរបស់អ្នកទីក្រុង ។

**អ្នកក្រីក្រក្នុងទីក្រុង និងភាពក្រីក្រក្នុងទីក្រុង**

ភាពក្រីក្របានបង្ខំអោយអ្នកក្រីក្រក្នុងទីក្រុងរស់នៅតាមទីកន្លែងអនាធិបតេយ្យដែលជាទីកន្លែងខុសច្បាប់ ដែលពួកគេគ្មានសិទ្ធិកាន់កាប់ដីធ្លី និងលទ្ធភាពទទួលបាននូវសេវាកម្មនានា ។ ទីតាំងអនាធិបតេយ្យមានការរស់នៅប្រមូលផ្តុំយ៉ាងណែនតាន់តាប់គ្មានសណ្តាប់ធ្នាប់នៅតាមបណ្តាបឹងប្រឡាយ ផ្លូវរថភ្លើង និងផ្លូវថ្នល់នានា ។ ទាំងរដ្ឋអំណាចមូលដ្ឋាន និងអ្នកមានរស់ក្នុងទីក្រុងស្តីបន្ទោសទៅអ្នកក្រីក្រចំពោះលក្ខខណ្ឌក្រីក្ររបស់ពួកគេ ហើយនិយាយមិនល្អចំពោះអ្នកក្រីក្រថា ជាអ្នកសង្គមមិនត្រូវការអ្នកបង្កើតឧក្រិដ្ឋកម្ម និងអ្នកមិនដឹងខុសត្រូវ ។ ប្រជាជនថ្នាក់កណ្តាល និងមន្ត្រីមួយចំនួនបានឆ្លើយតបថាអ្នកក្រីក្រទាំងនោះគួរតែបញ្ជូនទៅកន្លែងដើមរបស់ពួកគេវិញ ។ អ្នកក្រីក្រនៅតាមជនបទ ដែលជាតំណាងច្រើនលើស លុបនៃប្រជាជនក្រីក្រនៅកម្ពុជា ត្រូវបានចាត់ទុកថាជាអ្នករងគ្រោះស្លូតបូតនៃការរៀបចំរដ្ឋបាលមិនល្អ និងស្ថិតនៅក្រោមការអភិវឌ្ឍន៍ (ខ្វះហេដ្ឋារចនា-សម្ព័ន្ធ និងសេវាកម្មសំខាន់ៗ) ។ អ្នកក្រីក្រទីក្រុងថា ជាអ្នកទទួលខុសត្រូវចំពោះស្ថានការណ៍ ដ៏លំបាករបស់ខ្លួន ។ ពួកគេទទួលបាននូវអាទិភាពនៃការជួយតិចជាងអ្នកក្រីក្រនៅតាមជនបទគ្រប់យ៉ាងពីព្រោះនៅក្នុងឯកសារគេបាននិយាយថា ពួកគេធូរធារជាងអ្នកជនបទដូចជាប្រាក់ចំណូលអាហាររូបត្ថម្ភ និងទទួលបាននូវសេវាកម្មសំខាន់ៗ ដូចជា វិស័យអប់រំ និងសុខាភិបាល ។ ថ្វីបើមានការផ្តល់ពតិមាន ដ៏ល្អក៏ដោយបុគ្គលិកភ្នាក់ងារផ្តល់ជំនួយបន្ថយចុះនូវកង្វះភាពសុខដុមនៃជីវិតរបស់អ្នកក្រីក្រក្នុងទីក្រុងដោយប្រើការប្រៀបធៀបជាមួយអ្នកក្រីក្រតាមជនបទ ដើម្បីផ្តល់ហេតុផលត្រឹមត្រូវប្រឆាំងនឹងការផ្តល់ជំនួយដល់អ្នកក្រីក្រទីក្រុង និងគោលនយោបាយអោយខ្ចីថវិកា ។ តាមការធ្វើបែបនេះសហគមន៍ ម្ចាស់ជំនួយពង្រឹងយកឈ្នះលើការច្រឡំក្នុងមូលដ្ឋាន ហើយធ្វើអោយលំអៀងប្រឆាំងនឹងអ្នកក្រីក្រទីក្រុង ។

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (UPRS) នៅឆ្នាំ ១៩៩៩ របស់សាលាក្រុងភ្នំពេញបានទទួលស្គាល់ថា ភាពក្រីក្រក្នុងទីក្រុង គឺមានច្រើនជាងបញ្ហាសេដ្ឋកិច្ចទៅទៀតដែលទទួលបានមកពីប្រាក់ចំណូលទាប ឬទិន្នផល ។ សាលាក្រុងបានរកឃើញនូវដើមហេតុនៃភាពក្រីក្របី គឺ :

ក- សេដ្ឋកិច្ច ពោលគឺ ប្រាក់ចំណូលទាប ឬកង្វះមធ្យោបាយចិញ្ចឹមជីវិតគ្រប់គ្រាន់ ។

ខ- សង្គម ពោលគឺ កង្វះខាតលក្ខខណ្ឌលំនៅដ្ឋានគ្រប់គ្រាន់ និងបរិស្ថានរស់នៅ រួមបញ្ចូលទាំងកង្វះខាតផ្លូវចូលទៅសេវាកម្មសំខាន់ៗ ។

គ- នយោបាយពោលគឺ ប្រជាពលរដ្ឋខ្លះពុំមានសំលេងក្នុងការធ្វើការសំរេចចិត្តអ្វីមួយ ឬមិនបានគេទទួលស្គាល់ថាមាន សិទ្ធិស្មើគ្នានឹង អ្នកដ៏ទៃ ។

តាមការមើលឃើញជាក់ស្តែងនិយមន័យនេះមិនទាន់ត្រូវបានយល់ ឬទទួលយកពីថ្នាក់ជាតិនិងសាលាក្រុងនៅឡើយទេ ។ វាមានតែនៅលើឯកសារដែលមន្ត្រីសាលាក្រុងភាគច្រើនមិនបានដឹង ។ មន្ត្រីក្រុងភាគច្រើនបានចាត់ទុកថាភាព ក្រីក្ររបស់ក្រុងត្រូវទទួលខុសត្រូវតាមស្ថានភាពរបស់ខ្លួន ។ ពួកគេនិយាយថា "ដោយការសំរេចចិត្ត" រស់នៅក្នុងតំបន់អានាធិបតេយ្យពួកគេបាន" បង្កើត" លក្ខខណ្ឌរស់នៅផ្ទាល់ខ្លួន និងគួរត្រលប់ទៅខេត្តរបស់ពួកគេវិញ "។

## ការកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង

រហូតដល់ឆ្នាំ ១៩៩៨-១៩៩៩ សាលាក្រុងភ្នំពេញបានរក្សាគោលនយោបាយរឹងមាំមួយដោយមិនទទួលស្គាល់អ្នកមករស់មិនស្របច្បាប់ថាជាអ្នករស់នៅស្របច្បាប់របស់ក្រុងទេ ហើយក្រុងមិនគាំទ្រសកម្មភាពអភិវឌ្ឍន៍ទាំងឡាយ ដើម្បីឈានទៅដល់អ្នករស់នៅក្នុងតំបន់អនាធិបតេយ្យទេ ។ តែសាលាក្រុងបណ្តេញអ្នកចូលមករស់ឥតច្បាប់ដ៏ឃោរឃៅ ដោយមិនធ្វើការសង ឬគាំទ្រចំពោះអ្នកដែលត្រូវផ្លាស់ប្តូរចេញទៅកន្លែងថ្មីទេ ។

ជំហានសំខាន់ទី មួយឆ្ពោះទៅរកគន្លឹះកាត់បន្ថយភាពក្រីក្រទីក្រុងដោយផ្អែកលើមូលដ្ឋានសហគមន៍ពីឆ្នាំ ១៩៩៥ ទៅ ១៩៩៩ គឺការអភិវឌ្ឍន៍ហេតុផលសំខាន់ៗនៃការរៀបចំសហគមន៍តាមរយៈការធ្វើយោធូបនីយកម្មសន្សំប្រាក់ និងការបង្កើតរចនាសម្ព័ន្ធនៅក្នុងការរៀបចំសហគមន៍ទាំងនោះ ។ ជំហានទីពីរគឺការអនុវត្តការធ្វើអោយប្រសើរឡើង ជាលក្ខណៈតូចតាចនៅនឹងកន្លែង និងការរៀបចំកម្មវិធីនៃការបំលាស់ប្តូរទីលំនៅទៅកន្លែងថ្មីដោយស្ម័គ្រចិត្តនៅក្រៅទីក្រុងខ្លះ ។ សំខាន់ៗ ពីរក្នុងការរៀបចំអ្នកក្រីក្រក្នុងទីក្រុង ( ក្នុងចំណោម ១២ ឬ NGO តូចៗ) គឺសហព័ន្ធសាមគ្គីភាព អ្នកក្រីក្រទីក្រុង (SUPF) និងក្រុម ផ្អែកទីក្រុង (USG) បានរៀបចំកន្លែងតាំងទីលំនៅសំរាប់អ្នករស់នៅឥតច្បាប់ប្រហែល ១៨០ ដោយបង្កើតសម្ព័ន្ធភាពជាមួយសហគមន៍ និងផ្តល់ការគាំទ្រដល់ពួកគេនៅក្នុងដំណើរការនោះ ។ សហគមន៍ដែលមានស្ថេរភាពភាគច្រើន បានរៀនសូត្រអំពីសំណើសំរាប់រៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន, ស្វែងរកមូលនិធិសហគមន៍ និងម្ចាស់ជំនួយខាងក្រៅដើម្បីអនុវត្តគំរោងរបស់គេ ។ ការបណ្តុះបណ្តាលអ្នកដឹកនាំដោយក្រុមអ្នកគាំទ្រស្តីពីសិទ្ធិមនុស្សច្បាប់ស៊ីវិល និងច្បាប់ព្រហ្មទណ្ឌបានធ្វើអោយសហគមន៍អាចចរចាជាមួយសាលាក្រុងភ្នំពេញ និងដើម្បីអោយប្រតិបត្តិតាមនូវច្បាប់ដូចគ្នានៅកន្លែងតាំងលំនៅដែលមានឧក្រិដ្ឋកម្ម និងអសន្តិសុខកើតមានពីមុនជាបន្តបន្ទាប់ ។

ចាប់តាំងពីឆ្នាំ ១៩៩៦ មកមន្ត្រីជាន់ខ្ពស់ក្រុងមួយចំនួនបានសហការជាមួយគំរោងលំនៅដ្ឋាន UN (UN-Habitat Project) និង CBO និង NGO ផ្សេងៗទៀតដើម្បីបង្កើតលក្ខខណ្ឌរស់នៅរបស់អ្នកក្រីក្រក្នុងទីក្រុងតាមរយៈគំរោងធ្វើអោយប្រសើរឡើងដោយផ្អែកលើសហគមន៍ ។ តាមរយៈនៃការធ្វើបែបនេះពួកគេបានចាប់ផ្តើម ទទួលស្គាល់សក្តានុពលភាពរបស់សហគមន៍ក្រីក្រជាច្រើនដើម្បីជួយដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់គេដូចជាប្រាក់ចំណូលទាប និងលក្ខខណ្ឌរស់នៅក្រោមស្តង់ដារ ។

បន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងច្រើនជាមួយសហគមន៍ដែលបានរៀបចំរួច NGOs និង CBOs រួចមកសាលាក្រុងភ្នំពេញ និងគំរោងលំនៅដ្ឋាន UN-Habitat រួមគ្នាបានបង្កើតយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រក្នុងក្រុង (UPRS) នៅឆ្នាំ ១៩៩៩ ។ ដោយផ្អែកលើការសិក្សាដែលបានមកពីការសហការខាងលើយុទ្ធសាស្ត្រនេះមានគោលបំណង:

ក-បង្កើនផ្លូវចូលទៅរកសេវាកម្មសំខាន់ៗសំរាប់អ្នកក្រីក្រក្នុងទីក្រុង ដោយធានាដល់ការលៃលកទិញដីអាចផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធរូបសាស្ត្រ ( ការផ្គត់ផ្គង់ទឹក ប្រព័ន្ធបង្ហូរ ផ្លូវថ្នល់ អនាម័យ អគ្គិសនី ការដឹកជញ្ជូន ការប្រមូលកាកសំណល់) និងការអនុវត្តន៍ការគ្រប់គ្រងគ្រោះមហន្តរាយ ( ប្រឆាំងនឹងអគ្គិភ័យ និងទឹកជំនន់ ) ។

ខ- បង្កើនសក្តានុពលភាពសេដ្ឋកិច្ចមូលដ្ឋាន ( ជាពិសេសសំរាប់ស្ត្រី) ដោយផ្តល់ការអប់រំជំនាញខាងមុខរបរ និងជំនួញឥណទាន និងការសន្សំប្រាក់ ការផ្តល់ការងារឧស្សាហកម្ម ពតិមានពីទីផ្សារ និងទីកន្លែងសំរាប់ធ្វើជំនួញតូចតាច ។ ពង្រឹងយន្តការអភិបាលកិច្ចក្រុងដោយមានការចូលរួមដោយសំរបសំរួលការរៀបចំ និងដឹកនាំសហគមន៍បង្កើតគណៈកម្មការគ្រប់គ្រងការ

អភិវឌ្ឍន៍សហគមន៍ បង្កើតគោលនយោបាយដីធ្លី និងលំនៅដ្ឋានសំរាប់អ្នកក្រីក្រក្នុងទីក្រុងធ្វើអោយទំរង់ការមានភាពងាយស្រួលសំរាប់សេវាកម្មរដ្ឋលុបបំបាត់ចោលអំពើពុករលួយ និងធានាសិទ្ធិកាន់កាប់ដីធ្លី ។

ការអនុវត្ត UPRS គឺផ្អែកលើការសំរេចចិត្តបែបវិមជ្ឈការពីសាលាក្រុងភ្នំពេញទៅថ្នាក់ខ័ណ្ឌ សង្កាត់ និងសហគមន៍ ។ ការអនុវត្តន៍នេះអាចសំរេចបានតាមរយៈគណៈកម្មការគ្រប់គ្រងការអភិវឌ្ឍន៍សហគមន៍ (CDMC) ដែលបានបង្កើតឡើងនៅថ្នាក់ខ័ណ្ឌ ហើយមានតំណាងមកពីសហគមន៍អ្នកក្រីក្រទីក្រុង NGO$_s$ សង្កាត់ សាលាក្រុងភ្នំពេញ និងផ្នែកឯកជន ។ CDMC មានបំណងគាំទ្រការអភិវឌ្ឍន៍ និងអនុវត្តផែនការសកម្មភាពកាត់បន្ថយភាពក្រីក្រនៅថ្នាក់ សហគមន៍តាមរយៈផែនការសកម្មភាពសហគមន៍ (CAP) ។ លទ្ធផលទីមួយនៃដំណើរការ CAP នៅក្នុងសហគមន៍និមួយៗ គឺការបោះឆ្នោតគណៈកម្មការអភិវឌ្ឍន៍សហគមន៍ (CDC) ។ CAP ទទួលមូលនិធិសំខាន់មកពី DFID /UNDP គំរោងកាត់បន្ថយភាពក្រីក្រក្រុងភ្នំពេញ UN Habitat ។ សហគមន៍ខ្លួន ឯងផ្ទាល់ដោយមានការគាំទ្រពី NGO និង CBO ក៏បានអនុវត្តផែនការសកម្មភាពរបស់ខ្លួន ។ តាមរយៈយុទ្ធវិធីរបស់សាលាក្រុងធ្វើអោយសហគមន៍ក្រីក្រអាចអនុវត្តគំរោងដែលគេបានធ្វើផែនការហើយដែលលក្ខខណ្ឌ ផែនការរបស់គេនេះត្រូវគ្នានឹងមគ្គុទេសក៏របស់សាលាក្រុង ។

ទោះជាយ៉ាងណាក៏ដោយការប្រឹងប្រែងអនុវត្ត UPRS អស់រយៈពេល ៣ឆ្នាំ កន្លងមកត្រូវបានរារាំងដោយគុណវិបត្តិពីរភាគីទាំងពីរ ។ តែសាលាក្រុងភ្នំពេញបានបង្កើតផ្នែកកាត់បន្ថយភាពក្រីក្រទីក្រុង (UPRU) និងគំរោងសុខភាពក្រុង (បច្ចុប្បន្នគេហៅថា សេវាកម្មសុខភាពសំរាប់គំរោងអ្នកក្រីក្រទីក្រុង) ដើម្បីធ្វើការសំរាប់អ្នកក្រីក្រ និងជាមួយអ្នកក្រីក្រ នៅមានតំរូវការចាំបាច់សំរាប់ការផ្លាស់ប្តូរមូលដ្ឋានគ្រឹះនៅក្នុងអាកប្បកិរិយាជាផ្លូវការឆ្ពោះទៅរកអ្នកក្រីក្រ ។ ជាពិសេសមានតំរូវការជាបន្ទាន់មួយសំរាប់ទប់នឹងអំពើពុករលួយទូទៅដែលញាំញីគំរោងជាមួយអ្នកក្រុងក្រីក្រ និងការពារការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងមគ្គុទេសក៍ ។ ការកំណត់មួយទៀតរបស់ UPPU គឺខ្វះខាតសមត្ថភាព ដើម្បីផ្តល់យោបល់ដែលមានសារៈសំខាន់ទៅសាលាក្រុងភ្នំពេញ និងដើម្បីជួយផ្តល់ពត៌មានពីគោលនយោបាយ និងសំរបសំរួលសកម្មភាពនៃមន្ទីរជំនាញផ្សេងៗ របស់រដ្ឋបាលមូលដ្ឋាន និងថ្នាក់ជាតិក៏ដូចជាអ្នកធ្វើការងារទាក់ទងនឹងការអភិវឌ្ឍន៍នៅក្នុងក្រុងដែរ ។

នៅខាងសហគមន៍ និងសង្គមស៊ីវិលវិញគេឃើញមានការកំណត់មួយចំពោះក្រុមដែលមិនបានរៀបចំសំរាប់អ្នកក្រីក្រដែលសំរេចបានតាមរយៈសកម្មភាពរបស់ NGO និង CBO ។ មានភស្តុតាងមួយបញ្ជាក់ថាកំរិត និងផលប៉ះពាល់ នៃឥណទាន និងកម្មវិធីសន្សំប្រាក់ប្រហែលជាមានការបំផ្លើស ។ បុព្វហេតុមួយទៀតនៃកង្វល់ គឺភាពងាយបាក់បែកនៃការរៀបចំសហគមន៍ជាច្រើនក្នុងការធានាកម្មសិទ្ធិសហគមន៍នៃគំរោងរបស់គេ និងការប្រព្រឹត្តិចំពោះការប្រតិបត្តិ និងថែរក្សារបស់ពួកគេ ។ ទោះបីជាគេមានជោគជ័យក៏ដោយការរៀបចំមូលដ្ឋានបានប្រឈមមុខនឹងការកំណត់មុតមាំដើម្បីឈានទៅដល់ទីដៅ និងតំណាងអោយអ្នកក្រីក្រទីក្រុងក្នុងទីក្រុង ។ ជាញឹកញាប់បទអន្តរាគមន៍របស់ពួកគេបានពង្រឹងភាពមិនស្មើគ្នានៃសង្គម និងនយោបាយពីព្រោះពួកគេបានរៀបចំលំនៅដ្ឋានទៅជាសហគមន៍ដោយគាំទ្ររចនាសម្ព័ន្ធ អំណាចដែលមានស្រាប់របស់អតិថិជននិយម ។ នៅពេលខ្លះអ្នកដឹកនាំបានគាំទ្រតែសាខាសមាជិកសហគមន៍ជារបៀបនយោបាយកំណត់ច្រកចូល ទៅរកផលប្រយោជន៍ពីគំរោងគេគិតពី

មិត្តភក្តិ និងគ្រួសារគេតែប៉ុណ្ណោះ ។ គំរោងមានគោលបំណងផ្តល់ប្រយោជន៏ទៅតែផ្នែកដែលមានស្ថេរភាពនៃអ្នកតាំងទីលំនៅក្រីក្រប៉ុណ្ណោះ គឺមិនបានពិចារណាពីតំរូវការសមត្ថភាព និងផលវិបាកនៃគ្រួសារដែលគេរាប់ចេញ និងទទួលរងនូវការខូចខាតទេ ។

អវត្តមានដែលលេចចេញនៅក្នុងការអនុវត្តន៏ UPRS មកទល់ពេលនេះគឺជាការទទួលស្គាល់ថាការបំលាស់ទីលំនៅពីជនបទមកក្រុង នឹងបន្តមានរាប់ទស្សវត្សទៀត ។ ដូច្នេះការប្រឹងប្រែងរបស់សាលាក្រុងបានយកចិត្តទុកដាក់យ៉ាងច្រើនទៅលើការបំលាស់ប្តូរលំនៅដោយស្ម័គ្រចិត្តរបស់អ្នកមករស់នៅឥតច្បាប់ទៅទីតាំងថ្មី ដែលសាលាក្រុងផ្តល់អោយ ហើយដែលជាបរិមណ្ឌលរបស់ក្រុង ។ ឥឡូវនេះការវាយតំលៃ និងតាមដានដោយមានការចូលរួមលើផលប៉ះពាល់នៃការបំលាស់ប្តូរលំនៅ នេះបានសអោយឃើញថា វាទំនងជាធ្វើអោយកាន់តែធ្ងន់ធ្ងរឡើងលើជីវភាព និងលក្ខខណ្ឌរស់នៅរបស់ប្រជាជនក្រីក្រ ដូចនេះត្រូវមានតំរូវការយ៉ាងច្បាស់លាស់មួយ ដើម្បីអនុវត្តន៏កម្មវិធីធ្វើអោយប្រសើរឡើង ចំពោះអ្នកមករស់នៅឥតច្បាប់ ។ ការធ្វើអោយតំបន់អនាធិបតេយ្យប្រសើរឡើង គឺមិនគ្រាន់តែការពារផលប្រយោជន៏សេដ្ឋកិច្ច និងជីវភាពរបស់អ្នកក្រីក្រប៉ុណ្ណោះទេ គឺវាក៏ជាវិធីកាត់បន្ថយភាពក្រីក្រមួយសំរាប់ប្រាក់ចំណូលដ៏ទន់ខ្សោយរបស់សាលាក្រុងដែរ ។ នៅពេលជាមួយគ្នានោះដែរ ត្រូវមានតំរូវការជាបន្ទាន់ដើម្បីបង្កើតកម្មវិធីរៀបចំដីធ្លី (Land banking) ទីតាំង និងសេវាកម្មសំរាប់អ្នកបំលាស់ ប្តូរទីលំនៅនៅពេលអនាគតធ្វើដូច្នេះគឺពួកគេពុំមានការបង្ខំអោយរស់នៅរបៀបអនាធិបតេយ្យ និងបង្កើតបញ្ហាថ្មីៗ ទៀតសំរាប់សាលាក្រុងទៀតឡើយ ។ ផ្នែកនៃយុទ្ធសាស្រ្តដែលយើងមើលទៅថ្ងៃខាងមុខ គឺត្រូវសហការយ៉ាងជិតស្និទ្ធជាមួយ ក្រុងដ៏ទៃទៀតលើវិធី និងមធ្យោបាយផ្សេងៗដើម្បីជំរុញការអភិវឌ្ឍន៏ ។ តាមរយៈការអភិវឌ្ឍន៏បែបនេះទីក្រុងតូចៗ អាចជួយជួបនូវតំរូវការដែលចៀសមិនរួចសំរាប់ការផ្តល់ឱកាសការងារដីធ្លី និងលំនៅដ្ឋានសំរាប់ប្រជាជន មកពីជនបទនៅទស្សវត្សក្រោយៗ ។ បើគ្មានការសហការបែបនេះទេសាលាក្រុងភ្នំពេញនឹងត្រូវបន្តទទួលការបំលាស់ប្តូរទីលំនៅយ៉ាងច្រើន ដែលជាផលវិបាកដល់សាលាក្រុងខ្លួនឯងផង និងទីក្រុងដ៏ទៃទៀតផង ។

## គោលដៅកាត់បន្ថយភាពក្រីក្រនៅភ្នំពេញ (២០០៣-២០០៥)

### ការប៉ាន់ប្រមាណបច្ចុប្បន្ននៃអ្នកក្រុងក្រីក្រនៅភ្នំពេញ

នៅឆ្នាំ ២០០២ ប្រជាជនប្រមាណ ២២៨.៤០០ នាក់ ទៅ ២៤១.៦០០ នាក់ រស់នៅក្នុងសហគមន៏ដែលមានប្រាក់ចំណូលទាប។ គ្រួសារភាគច្រើនត្រូវគេចាត់ទុកជាអ្នកមករស់នៅឥតច្បាប់ ដែលក្រុមអ្នកក្រីក្រមួយចំនួនតូចរស់នៅក្នុងលក្ខខណ្ឌបែបអនាធិបតេយ្យ ប៉ុន្តែគេតវ៉ារកសិទ្ធិកាន់កាប់ ។ ពួកគេរស់នៅលើដីលិចទឹកជាបន្ទាប់បន្សំតាមរដូវ ឬអចិន្រ្តៃយ៏ ឬរស់នៅតាមអាគារទ្រុឌទ្រោមនានានៅក្នុងទីក្រុង ។ អ្នកចូលមករស់នៅឥតច្បាប់ និងអ្នកក្រីក្រក្នុងទីក្រុងនេះមានប្រហែល ២០% នៃប្រជាជននៅក្នុងទីក្រុងទាំងមូល ។

## តារាង ៤.៤ ការប្រមាណចំនួនប្រជាជនរបស់ក្រុងភ្នំពេញរាប់បញ្ចូលទាំងអ្នកក្រុងក្រីក្រ

| | 1998 | 1999 | | 2002 ( ប៉ាន់ស្មាន) | | |
|---|---|---|---|---|---|---|
| | សរុប | សរុប ( ប៉ាន់ស្មាន) | អ្នកក្រុងក្រីក្រ | សរុប | អ្នកក្រុងក្រីក្រ | ភាពក្រីក្រក្រុង |
| កំនើន ៨៥ ក្នុងមួយឆ្នាំ | 999.800 | 1.049.790 | 207.150 | 1.157.400 | 228.400 | 19.75 |
| កំនើន ៨៥ ក្នុងមួយឆ្នាំ | 999.800 | 1.049.790 | 207.150 | 1.224.480 | 241.600 | 19.75 |

- ចំនួនគ្រួសារប្រជាជនក្នុងទិសដៅ 2003-2005
- បង្កើតលក្ខខ័ណ្ឌលំនៅដ្ឋាន និង ជីវភាពរស់នៅ
- បង្កើតឱកាសសេដ្ឋកិច្ច

**លក្ខខណ្ឌលំនៅដ្ឋាន និងជីវភាពរស់នៅគ្រប់គ្រាន់សំរាប់អ្នកក្រុងក្រីក្រ**

- បង្កើតការផ្គត់ផ្គង់ដីធ្លីសមស្របសំរាប់គ្រួសារមានប្រាក់ចំណូលទាបនៅក្នុងទីតាំងសមរម្យ ។
- ជំរុញការបង្កើតលំនៅដ្ឋានសមស្របនៅលើទីតាំងទាំងនេះ ។
- បង្កើនច្រកចូលទៅសេវាកម្ម និងប្រយោជន៍សំរាប់លំនៅដ្ឋានមានលក្ខណៈប្រសើរនិងតំបន់ថ្មីដែលមានប្រាក់ចំណូលទាប
- ផ្តល់សិទ្ធប្រើប្រាស់ទឹក អគ្គិសនី និងសេវាប្រមូលកាកសំណល់រឹងទុកនៅកន្លែងណាមួយនៅទីតាំងថ្មីៗ
- ផ្តល់នូវប្រព័ន្ធបង្ហូរទឹកសមរម្យក្នុងទីកន្លែងកំណត់មួយនៅទីតាំងថ្មី
- ផ្តល់នូវអនាម័យគ្រប់គ្រាន់ក្នុងកន្លែងដែលមានទីលំនៅថ្មី

**ឱកាសសេដ្ឋកិច្ចគ្រប់គ្រាន់ក្នុងការរកប្រាក់ចូល ( ជាពិសេសសំរាប់ស្ត្រី)**

- ជំរុញការអប់រំក្រៅប្រព័ន្ធ និង វគ្គបំពាក់បំប៉ន មុខរបរដល់អ្នកក្រីក្រ ( ជាពិសេសស្ត្រី) ។
- ជំរុញ និងគាំទ្រការសន្សំប្រាក់ និងឥណទានក្នុងមីក្រូហិរញ្ញវត្ថុដល់អ្នកក្រីក្រ ។
- បង្កើនការយល់ដឹងពីផ្នែកក្រៅប្រព័ន្ធដែលបង្ហាញវិធានការពីរដើម្បីធ្វើអោយប្រសើរឡើង និងត្រឹមត្រូវឡើង ។
- រកការងារសំរាប់ស្ត្រី និងបុរសក្រីក្រនៅទីក្រុងរួមមានសហគមន៍ និងគ្រួសារនានាដោយមានការសហការយ៉ាងជិតស្និទ្ធ ជាមួយក្រសួងឧស្សាហកម្ម សហគមន៍ និងសហជីពអ្នកផ្តល់ការងារ ។
- ពិនិត្យឡើងវិញនូវគោលនយោបាយ និងការអនុវត្តនៅតាមទីផ្សារទីក្រុងនិងផ្លូវនានានៅក្នុងក្រុង ដើម្បីធានាកន្លែងសមស្រប សំរាប់អ្នកលក់ដូរក្រីក្រៈ បង្កើតបទបញ្ជា និងការផាកពិន័យអោយអ្នកក្រីក្របានស្គាល់ហើយតាមដាន ការអនុវត្តរបស់គេ ។
- ជំរុញ SME រកផលិតផលសំភារៈសំណង់សំរាប់សិប្បករក្រីក្រ និងមានជំនាញ ។
- បង្ហាញពីវិធីលើកទឹកចិត្តតាមរយៈពលកម្មនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់និងប្រព័ន្ធបង្ហូរ ។
- បើកការប្រើប្រាស់សហគមន៍ក្នុងសហគ្រាស CBO សំរាប់ការផ្តល់ទំនិញ និងសេវាកម្ម ( ឧទាហរណ៍. គ្រឿងសង្ហារឹមសំរាប់សាលារៀនសេវាកម្មដឹកជញ្ជូនសាធារណៈការប្រមូលសំរាម និងការសំអាតផ្លូវថ្នល់) សំរាប់សាលាក្រុងភ្នំពេញក៏ ដូចជាការិយាល័យរដ្ឋាភិបាល និងនាយកដ្ឋាននានាដែរ ។

- ដោយមានការសហការយ៉ាងជិតស្និទ្ធិជាមួយក្រសួងទេសចរណ៍ សាលាក្រុងក៏បានរកឃើញនូវ សក្តានុពលភាពនៃឱកាសធ្វើជំនួញសំរាប់អ្នកក្រុងក្រីក្រ និងធ្វើគំរោងសាកល្បងលើឱកាសទាំងនោះនៅក្នុង ផ្នែកផ្សេងៗ គ្នាដូចជា គមនាគមន៍ សិប្បកម្ម អាហារតាមថ្នល់ និងការកំសាន្ត ។ល។

**បង្កើនអភិបាលកិច្ចមូលដ្ឋាន**

- ជំរុញការរៀបចំសហគមន៍ត្រឹមត្រូវ ហើយផ្តល់អំណាចទៅពួកគេដើម្បីផ្តល់ប្រយោជន៍ទៅសមាជិករបស់គេ ។
- ទទួលស្គាល់តួនាទីរបស់ NGO និង បង្កើតភាពជាដៃគូស្ថាប័នជាមួយពួកគេ ។
- ធ្វើការជាមួយ MLMUPC សង្គមស៊ីវិល និងក្រុមសហគមន៍ ដើម្បីបង្កើតគោលនយោបាយគាំទ្រ ដីអ្នកក្រីក្រ និងលំនៅដ្ឋាន និងការយល់ដឹងសាធារណៈ (ជាពិសេសសំរាប់ក្រុមអ្នកមានប្រាក់ចំណូលទាប) នៃគោលនយោបាយដីធ្លី និងលំនៅដ្ឋាន និងច្បាប់ដីធ្លី ។
- ផ្តល់អាទិភាពកំណែទំរង់រដ្ឋបាលនៅក្នុងកម្មវិធី និងគំរោងកាត់បន្ថយភាពក្រីក្រៈភ្ជាប់ទៅទីក្រុងដ៏ទៃ ទៀតតាមរយៈការបង្កើតសហគមន៍ទីក្រុងសំរាប់ការផ្លាស់ប្តូរបទពិសោធន៍ ស្តីពីកំណែទំរង់រដ្ឋបាល និងការកាត់បន្ថយភាពក្រីក្រ ។
- ធ្វើទំរង់ការអោយងាយស្រួលសំរាប់ការទទួលសេវាកម្ម និងការអនុញ្ញាត្តិ ពីរដ្ឋាភិបាល ។
- ផ្តើមបញ្ហាដោយផ្អែកលើការពិគ្រោះយោបល់ដើម្បីបង្កើតគ្រោងការ និងយន្តការស្ថាប័នសំរាប់ភាពជាដៃគូរវាងអ្នកដើរតួផ្សេងៗគ្នា ទៅលើការកាត់បន្ថយភាពក្រីក្រ ។
- ដាក់ទិសដៅលើឱកាសពង្រឹងសមត្ថភាពចំពោះកិរិតសមស្រប និងតំណាងសាលាក្រុងភាគច្រើន NGOs និងសហគមន៍ៈចែករំលែកឱកាសជាមួយក្រុងដ៏ទៃទៀត ហើយប្រៀបធៀបផលប៉ះពាល់តាមរយៈសហគមន៍ទីក្រុងកម្ពុជាដែលបានបង្កើតថ្មី ។
- បង្កើតការតាមដាន និងការវាយតំលៃដោយមានការចូលរួមលើផ្នែកទាំងមូលនៃវិធានការកាត់បន្ថយភាពក្រីក្រថាតើវាជាច្បាប់ គោលនយោបាយការពង្រឹងសមត្ថភាព ឬកម្មវិធី ឬគំរោងពិត ។
- បង្កើតបណ្តាញគមនាគមន៍ និងសេវាកម្មដល់ប្រជាជនមានប្រាក់ចំណូលទាប ។
- អភិវឌ្ឍកម្មវិធីការពារ និងបន្ធូបន្ថយគ្រោះមហន្តរាយចំពោះទីលំនៅដែលមានស្រាប់ (តើត្រូវកែលំអ ឬមិនកែលំអ) និងទីតាំងថ្មី

## ៤.៣ លើកកំពស់សមត្ថភាព

នៅក្នុងផ្នែកទី ៣ បានលើកឡើងពីផលប៉ះពាល់ដែលបណ្តាលមកពីភាពក្រីក្រមកលើប្រជាជនកម្ពុជា ដូចជា វិស័យអប់រំ, សុខាភិបាល និងអាហារូបត្ថម្ភ ។ ទាំងអស់នេះគឺជាបញ្ហាចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការជួយជ្រោមជ្រែងពីភ្នាក់ងារអភិវឌ្ឍន៍នានាដើម្បីធ្វើការអភិវឌ្ឍន៍បញ្ហាទាំងអស់នោះ តាមរយៈផែនការសកម្មភាពជាអាទិភាពលើវិស័យ អប់រំ, សុខាភិបាល អាហារូបត្ថម្ភ, ទឹកស្អាត និងការថែទាំអនាម័យ ។ អាស្រ័យហេតុនេះ ម៉ាទ្រីសនៃផែនការសកម្មភាពមិនគ្របដណ្តប់លើកិច្ចការគ្រប់យ៉ាងទាំងអស់ ដែលបានរៀបរាប់នៅក្នុងអត្ថបទ ក្នុងជំពូកនេះឡើយ ។

## ៤.៣.១ សុខាភិបាល

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី ២ ទទួលស្គាល់ថា សមាមាត្រនៃការចំណាយដោយប្រជាជនក្រីក្រទៅលើសេវាសុខាភិបាលសាធារណៈមានកំរិតទាប ដោយការខំប្រឹងប្រែងរហូតដល់បច្ចុប្បន្ននេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមធម៌ នៃវិស័យសុខាភិបាល មិនទាន់មានប្រសិទ្ធិភាពនៅឡើយ ដោយសារអ្នកក្រប្រើប្រាស់សេវាសាធារណៈតិចជាងអ្នកមិនក្រ ។

បញ្ហានេះបានបញ្ជាក់ដោយការវិភាគអំពីផលប៉ះពាល់នៃសង្គម និងភាពក្រីក្រនៅក្នុងការពិនិត្យឡើងវិញនៃការចំណាយសាធារណៈបច្ចុប្បន្ន ដូចដែលមានការបង្ហាញក្នុងរូបភាពទី ៤.១ ។ រូបភាពនេះបង្ហាញថា ទទួលបានផលចំណេញតែ ២/៣ ប៉ុណ្ណោះ ចំណែកអ្នកមានបំផុតទទួលបានផលចំណេញទ្វេរមួយជាពីរ ។

ការទប់ស្កាត់ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ អាស្រ័យលើកំណែទំរង់យ៉ាងសំខាន់នៃប្រព័ន្ធលើកលែងការបង់ថ្លៃសេវា ហើយអាចឱ្យអ្នកក្រទទួលយកបានសេវាថែទាំប្រកបដោយគុណភាព ។

### រូបភាព ១ ក្រុមដែលទទួលអាំងស៊ីដង់ផលចំណេញ

(ការចំណាយរបស់រាជរដ្ឋាភិបាល)




សំគាល់: ទីម អិនស៊ (២០០២): ពង្រាងការចំណាយលើវិស័យសុខាភិបាលនៅប្រទេសកម្ពុជា

ការវិភាគបង្ហាញថាក្រុមដែលមានចំណូលទាបបំផុត (២០%) ប្រើប្រាស់១៣% នៃធនធាន ក្រុមដែលមានចំណូលខ្ពស់បំផុតប្រើប្រាស់ស្ទើរតែ ៤០%នៃធនធាន ។ ភាពខុសគ្នានេះកាន់តែធំលើតំរូវការសុខភាពរបស់អ្នកក្រកាន់តែធំជាងអ្នកមាន ។

វិសមភាពក្នុងការបែងចែកធនធាន គឺកាន់តែច្បាស់លាស់ណាស់សំរាប់មូលដ្ឋានសុខាភិបាលថ្នាក់ជាតិ ដែលអ្នកមានមធ្យមនៅទីក្រុងបានប្រើប្រាស់សេវាទាំងនេះ ។ ផ្ទុយទៅវិញមន្ទីរពេទ្យស្រុកផ្តល់នូវផលចំណេញយ៉ាងធំធេងដល់ក្រុមអ្នកក្រីក្រ ។ ដោយយល់ដឹងអំពីការបែងចែកនេះ ទាមទារឱ្យមានការវិភាគនូវពហុកត្តាកំណត់នានា នៃការប្រើប្រាស់វិស័យសុខាភិបាល ។

ការអង្កេតពិនិត្យជំហានដំបូងផ្នែកទិន្នន័យឆ្នាំ ១៩៩៩ សំណួមពរថា ទីតាំងមូលដ្ឋានសុខាភិបាលសំខាន់ណាស់ ទាំងការកំណត់រយៈពេលដែលប្រជាជនរង់ចាំមុនពេលពិគ្រោះជាមួយគ្រូពេទ្យនៅពេលមានជំងឺ និងការជ្រើសរើសមូលដ្ឋានសុខាភិបាលដើម្បីធ្វើការព្យាបាល ។ ហេតុដូច្នេះហើយវាហាក់ដូចជាការជ្រើសរើសមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ត្រូវបានកំណត់ដោយកន្លែងដែលមានប្រជាជនប្រមូលផ្តុំច្រើន ។ ហើយវាជាករណីដែលមានជំងឺអ្នកក្រត្រូវរង់ចាំយូរ មុនពេលស្វែងរកការព្យាបាលដែលប្រហែលជាអាចធ្វើឱ្យសភាព ជំងឺកាន់តែធ្ងន់ធ្ងរ ហើយដែលត្រូវព្យាបាលមូលដ្ឋានសុខាភិបាលក៏រិតខ្ពស់ជាចាំបាច់ ។ ធនធាននៃផ្នែកសាធារណៈសំរាប់ផ្តល់សេវានៅមានក៏រិត ហើយដែលអាចស្ថិតនៅដូច្នេះក្នុងរយៈពេលយូរឆ្នាំទៀត ។ ក្នុងខណៈដែលតួលេខមិនច្បាស់លាស់ ការចូលរួមរបស់រដ្ឋាភិបាលក្នុងការចំណាយលើសុខាភិបាលសរុបត្រូវបានប៉ាន់ស្មានថា ប្រហែល ១០% ប៉ុណ្ណោះ ម្ចាស់ជំនួយ ២០% ហើយគ្រួសារបានចូលរួមក្នុងចំណាយយ៉ាងច្រើន លើការថែទាំសុខភាព (PER 2002) ។

ចំនួនបុគ្គលិកនៃក្រសួងសុខាភិបាល គឺសមស្របហើយ ( មានជំនាញចំរុះ តែមិនទាន់មានគុណភាព ) ទៅនឹងតំរូវការក្នុងនាមជាអ្នកផ្តល់ផ្ទាល់នូវសេវាសុខាភិបាលគ្រប់ជ្រុងជ្រោយ ។ តែទោះជាយ៉ាងណាក៏ដោយ ក្រសួងមិនទាន់មានបុគ្គលិកគ្រប់គ្រាន់នៅក្នុងផ្នែកដែលមិនផ្តល់សេវា ។ គំនិតផ្តួចផ្តើមនានា អំពីការគ្រប់គ្រង និងការធ្វើហិរញ្ញប្បទានកំពុងដំណើរការ ។ បន្ថែមនៅលើការសាកល្បងនៃកិច្ចសន្យាក្នុង (CI) និងកិច្ចសន្យា (CO) គំនិតផ្តួចផ្តើមនានានៃការបង្កើតឡើងការគ្រប់គ្រង និងកំណែទំរង់ហិរញ្ញប្បទាន រួមមាន " កិច្ចសន្យាថ្មី (New Deal) ដែលបានអនុវត្តនៅស្រុកសូត្រនិគមន៍ ខេត្តសៀមរាប នៅខេត្តតាកែវ ស្វាយរៀង និងនៅមន្ទីរពេទ្យ ខេត្តពោធិសាត់ ។

ជាលទ្ធផលនៃការសាកល្បងទាំងរហូតមកដល់បច្ចុប្បន្ន មានលក្ខណៈល្អប្រសើរ ។ គោលនយោបាយ និងយុទ្ធសាស្ត្រនេះកំពុងបន្តអនុវត្តដោយផ្តោតជាសំខាន់ទៅលើការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពតំលៃ និងសមធមិជន សេវាសុខាភិបាលសាធារណៈ ។

## គោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាល

នៅឆ្នាំ ២០០២ ក្រសួងសុខាភិបាលបានបង្កើតផែនការយុទ្ធសាស្ត្រវិស័យបើកទូលាយសំរាប់ ឆ្នាំ ២០០៣-២០០៧ ដែលបានគូសបញ្ជាក់ពីទិសដៅគោលនយោបាយថា រួមនូវរាល់ធនធានទាំងអស់នៅក្នុងវិស័យសុខាភិបាល ទាំងក្នុងស្រុក, ជំនួយអន្តរជាតិ និងពីផ្នែកឯកជន ។ ផែនការបានសង្កត់ធ្ងន់នៅលើលទ្ធផលប្រយោលនៃសុខភាព ហើយផ្តល់អាទិភាព ក្នុងការលើកកំពស់ស្ថានភាពសុខភាពប្រជាជនក្រីក្រ និងប្រជាជនកម្ពុជាដែលមានការលំបាកក្នុងសង្គម ។ ផែនការយុទ្ធសាស្ត្រដែលបានគាំទ្រដោយរាជរដ្ឋាភិបាល គឺថាមូលដ្ឋាន ដើម្បីលើកកំពស់សមត្ថភាពគ្រប់គ្រងវិស័យបើកទូលាយរបស់ក្រសួងសុខាភិបាល ហើយផ្តល់នូវគំរោងការងារក្រោមឆ័ត្រនៃសកម្មភាពវិស័យសុខាភិបាលតាមរយៈយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ ។

គោលនយោបាយសុខាភិបាល ២០០៣-២០០៧ ស្វែងរកនូវគុណភាពខ្ពស់, សេវាសុខាភិបាលដែលផ្អែកលើភស្តុតាងជាមូលដ្ឋាន, សមធមិ ហើយគ្មានការរើសអើងភេទ អាយុ ទីកន្លែងរស់នៅ ឬលទ្ធភាពបង់ថ្លៃ ដែលជាគោលនយោបាយទ្រទ្រង់អ្នកក្រីក្រ ហើយដែលផ្អែកលើទំនុកចិត្តរវាងអ្នកផ្តល់ និងអ្នកប្រើសេវា ។

គោលការណ៍ធានានៃការងាររួមមាន ធានានូវការការពារសង្គមចំពោះក្រុមមនុស្សងាយរងគ្រោះស្តាប់នូវអ្វីដែលប្រជាជនចង់បាននូវតំលៃសមស្របមាននិរន្តរភាព ផ្តោតលើការផ្តល់សេវានៅជនបទ ដោយចូលរួមក្នុងការកសាងសមត្ថភាព

និងអភិវឌ្ឍធនធានមនុស្ស និងភាពជាដៃគូ ។ តំរូវការចាំបាច់ដែលបានលើកឡើងដោយរដ្ឋាភិបាល គឺត្រូវបង្កើតការគាំទ្រជាសាធារណៈសំរាប់ការថែទាំសុខភាព ។ ការចូលរួមនៃថវិកាបច្ចុប្បន្នសំរាប់សុខាភិបាលត្រូវបានធ្វើចំណោលថានឹងកើនឡើងពី ៩,៥% នៅឆ្នាំ ២០០១ ដល់ ១៣% នៅ ២០០៥ ការកើនឡើងជាង ៣០% រួមជាមួយការគ្រប់គ្រងសាធារណៈប្រសើរឡើង (មើលជំពូក ៥) ។

ក្រសួងសុខាភិបាលបានកំណត់គោលដៅជាចំណុច ដើម្បីសំរេចបាន ផ្អែកលើគោលបំណងការអភិវឌ្ឍន៍នៃសហស្សវត្ស ។ ទាំងនោះ គឺថាសូចនាករលទ្ធផលប្រយោលដែលមាននៅក្នុងឧបសម្ព័ន្ធគំរោងការងារត្រួតពិនិត្យតាមដាន និងវាយតំលៃនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (មានក្នុងតារាង ៦.១) ។ ដើម្បីសំរេចបានគោលដៅចំណុចនេះ ក្រសួងកំពុងតែផ្តោតការផ្តល់សេវាដល់ប្រជាជនក្រីក្ររួមមានការបែងចែកធនធាន ឱ្យបានសមស្របនៅតាមភូមិសាស្ត្រដែលមានអ្នកក្រីក្រច្រើន ។ គោលបំណងយុទ្ធសាស្ត្រគន្លឹះគឺ: (១) លើកកំពស់ការគ្របដណ្តប់ និងការប្រើប្រាស់សេវាសុខភាព (២) បង្កើនការទទួលយកបាននៃសេវាសារវន្តសំខាន់ៗ (៣) និងផ្តល់ពតិមាន ធ្វើឱ្យប្រសើរឡើងនូវការចូលរួម និងផ្តល់សិទ្ធិដល់អ្នកក្រីក្រក្នុងការជ្រើសរើស ។

ដើម្បីលើកកំពស់ការគ្របដណ្តប់ ក្រសួងនឹងពង្រឹងយុទ្ធសាស្ត្រផ្តល់សេវាបច្ចុប្បន្ន ឬប្រើយុទ្ធសាស្ត្រផ្សេងទៀត ដែលនឹងអាចពង្រីកសេវាអាទិភាពដល់អ្នកក្រ និងអ្នកដែលងាយរងគ្រោះដោយផ្តោតទៅលើការការពារ និងការកំណត់លក្ខខណ្ឌធ្ងន់ធ្ងរចំពោះស្ត្រី និងកុមារ ។ ផ្នែកជា អាទិភាពមាន: (១) ទីតាំងមូលដ្ឋានសុខាភិបាល ត្រូវរៀបចំឱ្យមានប្រសិទ្ធិភាពទៅដល់អ្នកក្រ និងនៅតំបន់ជនបទដាច់ស្រយាល (២) សេវាសុខភាពកុមាររួមមាន ការផ្តល់ថ្នាំបង្ការ ការគ្រប់គ្រង និងការការពារជំងឺ ដែលអាចការពារបានដូចជា ជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវ, ជំងឺរាក, គ្រុនឈាម នឹងត្រូវបានពង្រឹង និងពង្រីកតាមរយៈសមាហរណកម្មគ្រប់គ្រងជំងឺកុមារ (៣) ការបំប៉ៅដោះ ការអនុវត្តន៍ផ្តល់អាហារត្រឹមត្រូវ និងការការពារកង្វះមីក្រូអាហារូបត្ថម្ភ នឹងត្រូវជំរុញថែមទៀត (៤) សេវាសុខភាពមាតារួមមាន ការពន្យាកំណើត ការពិនិត្យផ្ទៃពោះ មុននិងក្រោយសំរាលកូនសុវត្ថិភាព ការថែទាំសម្ភពជាបន្ទាន់ សុវត្ថិភាពរំលូតកូន និងការផ្តល់យោបល់ក្រោយរំលូតកូន ការការពារ និងទប់ស្កាត់ជំងឺកាមរោគ ដែលត្រូវបានលើកកំពស់តាមរយៈការផ្តល់សេវាគ្រប់គ្រាន់នៅមូលដ្ឋានសុខាភិបាល និងសហគមន៍ ហើយនិងអាចឱ្យមានការប្រតិបត្តិត្រឹមត្រូវ និងផ្សារភ្ជាប់ជាមួយសហគមន៍ (៥) ការគ្រប់គ្រង ការការពារ និងការត្រួតពិនិត្យជំងឺឆ្លង និងជំងឺសំខាន់ៗ នៃភាពក្រីក្រ គឺជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម នឹងត្រូវបានពង្រឹងតាមរយៈការពង្រីកយុទ្ធសាស្ត្រផ្តល់សេវា រួមមានការថែទាំសុខភាពតាមផ្ទះ និងនៅតាមមណ្ឌលសុខភាព ការចែកចាយថ្នាំ សំភារៈជាសកម្ម ដូចជា មុង គំរបពាង ថ្នាំអាបែត ស្រោមអនាម័យ ។ល។ សេវាទាំងនេះត្រូវបានផ្តល់តាមរយៈសកម្មភាពចុះមូលដ្ឋាន នៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ដែលជាផ្នែកមួយនៃសំណុំសកម្មភាពអតិប្បបរិមា និងអប្បបរិមា ការចុះទៅដល់សហគមន៍ផ្អែកទៅលើវិធានការន៍កាត់បន្ថយការមានកូនដោយចៃដន្យដោយផ្អែកលើការផ្សព្វផ្សាយការពន្យារកំណើតដល់ស្ត្រីក្រីក្រ ដើម្បីអោយគេមានសមត្ថភាពទ្រទ្រង់ជីវភាពរបស់គេប្រកបដោយជីវជាតិគ្រប់គ្រាន់ ។ ការចុះមូលដ្ឋានជាវិធានការណ៍ដ៏សំខាន់ដើម្បីធ្វើអោយប្រសើរដល់ការផ្សព្វផ្សាយ និងការការពារសុខភាពកុមារ ។

ក្រុមសកម្មភាពនានាទៀត ដែលទាក់ទងនឹងការបង្កើនទទួលយកបាននូវសេវាដែលមានតំលៃថោកតាមរយៈយន្តការផ្សេងៗ។ យុទ្ធសាស្ត្រនានា ដូចខាងក្រោមនេះ មានបំណងបន្ថយរបាំងហិរញ្ញវត្ថុ ដើម្បីទទួលយកសេវារបស់អ្នកក្រ ហើយធ្វើឱ្យ

ប្រសើរឡើងសមត្ថភាពគ្រប់គ្រងនៅក្នុងផ្នែកសាធារណដូចជា: (១) យន្តការទៀងទាត់សំរាប់ត្រួតពិនិត្យតំលៃតាមរយៈការបង់ថ្លៃជាផ្លូវការដោយមានការចូលរួមពីសហគមន៍ក្នុងការកំណត់តំលៃ កំណត់អ្នកក្រីក្រ និងពិនិត្យតាមដានគុណភាព (២) មូលនិធិសមធម៌នឹងត្រូវបានបង្កើត ហើយអនុវត្តដើម្បីលើកកំពស់ការទទួលយកសេវាអាទិភាពក៏ដូចជាការការពារការចំណាយខ្ពស់ហួសពិសេសនៅមន្ទីរពេទ្យបង្អែក ។ យន្តការបែបនេះ នឹងធានាបាននូវគុណភាព និងលើកកំពស់សេវាថែទាំបឋម តំលៃថោកដែលអាចការពារ ឬទប់ស្កាត់ផលប៉ះពាល់នូវការចំណាយគ្រួសារទៅលើជំងឺធ្ងន់ធ្ងរ (៣) អង្គការក្រៅរដ្ឋាភិបាល នឹងទទួលធ្វើកិច្ចសន្យាដើម្បីផ្តល់សេវាបឋម និងមធ្យម (CPA/MPA) សំរាប់ប្រជាជនក្រីក្រ និងនៅតំបន់ដាច់ស្រយាល ។ គំនិតផ្តួចផ្តើមនេះកំពុងដំណើរការ ហើយនិងពង្រីកបន្ថែមទៀត ដើម្បីគ្របដណ្តប់ស្រុកទាំង ១២ នៅក្នុង ខេត្តតាកែវ កំពង់ចាម ព្រៃវែង មណ្ឌលគីរី រតនគីរី ព្រះវិហារ និងកោះកុង (៤) ការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល នឹងត្រូវប្រមូលផ្តុំសំរាប់តំបន់មិនទាន់មានកិច្ចសន្យាដើម្បីពង្រីកសេវា MPA & CPA ដល់ប្រជាជនក្រីក្រ និងសហគមន៍ (៥) ការលើកទឹកចិត្តដល់បុគ្គលិកធ្វើការនៅតំបន់ដាច់ស្រយាល និងមានប្រសិទ្ធិភាពតាមរយៈផែនការផ្អែកលើការបំពេញការងារ ។

បន្ថែមពីនេះទៀតដើម្បីការក្រុមដែលងាយរងគ្រោះថ្នាក់ នឹងមានចំណូលទាបធ្លាក់ចូលទៅក្នុងភាពក្រីក្រដោយសារតែតំលៃព្យាបាលខ្ពស់ ក្រសួងសុខាភិបាល នឹងស្រាវជ្រាវមើលលទ្ធភាពអាចធ្វើបាននៃការសាកល្បងការធានារ៉ាប់រងសុខភាពនៅសហគមន៍ និងជំងឺបង់ថ្លៃជាមុនដោយមានភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ។ ចុងបញ្ចប់សកម្មភាពទី៣ នៃវិស័យសុខាភិបាល នឹងផ្តោតលើការប្រមូលធនធានដែលមានស្រាប់ក្នុងចំណោមអ្នកក្រីក្រ ដើម្បីអាចឱ្យមានការជ្រើសរើស ក្នុងការថែទាំសុខភាព និងសុខាមាលភាពរបស់ពួកគាត់ឱ្យសមស្រប និងលើកកំពស់ ក្នុងការចូលរួមរបស់ពួកគាត់ក្នុងការសំរេចចិត្តអំពីសុខភាព និងសេវាដែលទាក់ទងនឹងសុខភាព ។ លើសពីនេះទៀត យុទ្ធសាស្ត្រនានាចូលរួមចំណែក ដើម្បីសំរេចបានគោលដៅនៃវិស័យសុខាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ នឹងត្រូវអនុវត្តន៍តាមរយៈ (១) បង្កើតក្រុមទ្រទ្រង់សុខភាព ឬសហគមន៍ ដើម្បីសំរេចឱ្យមានមគ្គុទ្ទេសក៍ដឹកនាំនៅថ្នាក់សហគមន៍ ភូមិ ក្នុងការសំរេចចិត្ត និងធ្វើសកម្មភាពដើម្បីឱ្យប្រសើរឡើងនូវដំណើរការមណ្ឌលសុខភាពហើយនឹងផ្តល់ពត៌មានត្រឡប់ និងយោបល់នានាទាក់ទងនឹងសេវាគុណភាព និងតំលៃក្នុងចំណោមប្រជាជនក្រីក្រ (២) ផ្តល់ពត៌មានគ្រប់គ្រាន់តាមរយៈយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដែលអាចឱ្យអតិថិជនជ្រើសរើសសមស្រប និងប្រកាន់យកការប្រព្រឹត្តិដែលនាំមកនូវសុខភាពល្អ ដូចជាការបំបៅដោះសុទ្ធ ការទទួលថ្នាំបង្ការ ការទទួលទានដែលមានជាតិមីក្រូអាហារូបត្ថម្ភថាមពល និងអាហារដែលមានវីតាមីនច្រើន ហើយស្វែងរកដំបូន្មាន និងការ ព្យាបាលពីអ្នកផ្តល់សេវា ដែលបានបណ្តុះបណ្តាលហើយនិងគ្រប់គ្រងរោគសញ្ញាគ្រោះថ្នាក់នៃការមានផ្ទៃពោះ និងជំងឺកុមារ (៣) លើកកំពស់ការប្រើប្រាស់សេវាសុខភាពសាធារណៈតាមរយៈបណ្តាញសហគមន៍ អ្នកផ្តល់សេវានៅមូលដ្ឋាន និងបណ្តាញផ្សេងៗ ទៀតរួមមាន ពត៌មានពីកន្លែង និងពីអ្នកដែលត្រូវទៅពិគ្រោះ និងឱ្យដំបូន្មានចំពោះបញ្ហាសុខភាពណាមួយ (៤) ប្រមែប្រមូលធនធានសុខាភិបាល និងធ្វើសកម្មភាពតាមរយៈវិធានការនានា ដើម្បីលើកកំពស់ការចូលរួមខាង នយោបាយក្នុងចំណោមប្រជាជនក្រីក្រ ដោយផ្សារភ្ជាប់ទៅនឹងក្រុមប្រឹក្សាឃុំ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។ល។ និង (៥) លើកកំពស់ការស្រាវជ្រាវដោយមានការចូលរួម និងវាយតំលៃនៅក្នុងសហគមន៍ ដើម្បីរៀបចំដំណើរការ ដែលអាចឱ្យមានការលើកឡើងជាយោបល់ផ្សេងៗ និងការយល់ដឹងរបស់ប្រជាជនក្រីក្រ ។ បញ្ហាពាក់ពន្ធ័នានានៅក្នុងយុទ្ធសាស្ត្រសុខាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រ រួមបញ្ចូលនូវសក្តានុពលនៃផ្នែកឯកជនក្នុងការ

ពង្រីកសេវានានា ដូចជា ការពន្យារកំណើត ការប្រើប្រាស់ទឹកអូរ៉ាលីត ការបែងចែកអំបិលអ៊ីយ៉ូដ និងការផ្តល់ថ្នាំបង្ការ និយតកម្មនៃការធ្វើពាណិជ្ជកម្មរបស់អ្នកផ្តល់សេវា ជាពិសេសពួកអ្នកដែលគ្មានក្របខណ្ឌច្បាស់លាស់ គឺសំខាន់ណាស់ដោយហេតុថា ពួកគេអាចបន្តអូសទាញអ្នកក្រីក្រថែមទៀត ។ ដើម្បីផ្សារភ្ជាប់ក្រសួងសុខាភិបាលគួរតែពង្រីកភាពជាដៃគូជា មួយផ្នែកមិនយក ផលចំណេញដើម្បីពង្រីកការគ្របដណ្តប់ការទទួលយកសេវា និងការប្រាស្រ័យទាក់ទងផ្លាស់ប្តូរ អាកប្បកិរិយា ដើម្បីផ្តល់សេវាដល់ អ្នកក្រីក្រ និងអ្នកដែលពិបាកទៅដល់ ។ ទោះជាយ៉ាងណាក៏ដោយការខំប្រឹងប្រែងនៃវិស័យសុខាភិបាល ដើម្បីទ្រទ្រង់អ្នកក្រីក្រ ត្រូវផ្សារភ្ជាប់ជាមួយគំនិតផ្តួចផ្តើមអន្តរក្រសួង ដើម្បីបំបែកវដ្តនៃភាពក្រីក្រ ដែលបណ្តាលឱ្យមានជំងឺ ហើយដែលធ្វើឱ្យបាត់បង់ ការផលិត និងចំណូលជួយគ្រួសារ ។ នៅទីកន្លែងណាដែលធ្វើទៅបានយុទ្ធសាស្ត្រសុខាភិបាលគួរតែផ្សារភ្ជាប់ជាមួយរបៀប ចិញ្ចឹមជីវិត អ្នកនៅជនបទ និងទីប្រជុំជន និងកម្មវិធីលើកកំពស់ជំនាញមីក្រូឥណទាន គំនិតផ្តួចផ្តើមវិស័យអប់រំ និងវិធានការណ៍ ពង្រីកសេវាមូលដ្ឋានរួមមានជំនួយអាហារ ទឹកស្អាត ផ្ទះសំបែង និងសេវាអនាម័យទូទៅ ។

យុទ្ធសាស្ត្រទាំងនេះ ទាមទារនូវភាពត្រឹមត្រូវ និងលំអិតតាមរយៈការវិនិច្ឆ័យ ដើម្បីកំណត់នូវផលប៉ះពាល់នៃផែនការ ផ្តល់សេវាសុខភាពបច្ចុប្បន្ន ដោយបំបែកតាមប្រាក់ចំណូល និងក្រុមសេដ្ឋកិច្ចសង្គម ។ វាមានសារៈសំខាន់ណាស់ ដើម្បីបន្ត ធ្វើការស្រាវជ្រាវប្រព័ន្ធសុខាភិបាល ដែលវិភាគលើទ្រព្យសម្បត្តិនៃទិន្នន័យរបស់អង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ ២០០០ និងអង្កេតសេដ្ឋកិច្ចសង្គម ឆ្នាំ ១៩៩៩ ។ ការស្រាវជ្រាវវាយតំលៃទៅលើការសាកល្បងនៃមូលនិធិសមធម៌ ការបង់ថ្លៃសេវា ការផ្តល់សេវា និងយុទ្ធសាស្ត្រផ្លាស់ប្តូរអាកប្បកិរិយា និងចូលរួមធ្វើឱ្យប្រសើរឡើងនៃយុទ្ធសាស្ត្រ សុខាភិបាលទ្រទ្រង់អ្នកក្រីក្រ សំរាប់ឆ្នាំ ២០០៣-២០០៥ ។ ការងារ និងបន្តលើការគណនាតំលៃនៃការធ្វើអន្តរាគមន៍ ទ្រទ្រង់អ្នកក្រីក្ររួមមាន ការវិភាគប្រសិទ្ធិភាពតំលៃនៃយុទ្ធសាស្ត្រផ្តល់សេវា ។

សមាសភាពសុខាភិបាលនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ នឹងទទួលបាននូវផលប្រយោជន៍ពីទិសដៅបន្ថែមទៀត និងការ សង្កេតពិនិត្យមើលពីគណៈកម្មការជាតិ អំពីម៉ាក្រូសេដ្ឋកិច្ច និងសុខភាពដែលជាគំនិតផ្តួចផ្តើមរួមគ្នារវាងក្រសួង សុខាភិបាល និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ។ គណៈកម្មការ នឹងត្រូវបានបង្កើតនៅឆ្នាំ ២០០៣ ហើយនិងផ្តោតទៅលើការវិនិយោគ ក្នុងវិស័យសុខាភិបាល ។ អនុប្រធានបទនឹងត្រូវបានធ្វើការព្យាករណ៍ រួមមាន ការវិភាគគោលនយោបាយសាធារណៈ ដែលប៉ះពាល់ ដល់ភាពក្រីក្រ និងសុខភាព ហើយនិងផលប៉ះពាល់នៃកំណែទំរង់បែបទូលាយរបស់រដ្ឋាភិបាល និងហិរញ្ញវត្ថុសាធារណៈលើការ អនុវត្តន៍នៃវិស័យសុខាភិបាល ។ គណៈកម្មការជាតិ នឹងដឹកនាំការគាំទ្រលើការបង្កើនអាទិភាព និងការវិនិយោគលើសុខភាព ដែលជាដំណាក់កាលសំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ។

## ៤.៣.២ អាហារូបត្ថម្ភ

ជំពូក ៣ បានគូសបញ្ជាក់នូវភាពធ្ងន់ធ្ងរនៃបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា ។ នៅក្នុងចំណោមប្រជាជន ពិសេសកុមារ និងស្ត្រី មូលហេតុសំខាន់បំផុតនៃកង្វះអាហារូបត្ថម្ភ មិនមែនទាក់ទងជាសំខាន់បំផុតទៅនឹងលទ្ធភាពអាហារនោះទេ ប៉ុន្តែវា ទាក់ទងទៅនឹងការអនុវត្តន៍នៃការផ្តល់អាហារ និងការពង្រីកសេវាសុខាភិបាលមានកំរិតទាបរួមនឹងបញ្ហាអានាម័យបរិដ្ឋានទូទៅ ។

ហេតុដូច្នេះហើយស្ត្រី គឺជាគោលដៅចំណុចសំខាន់សំរាប់កម្មវិធីអាហារូបត្ថម្ភ ។ កង្វះវីតាមីនអា គឺជាមូលហេតុចំបងនៃជំងឺខ្វាក់ភ្នែកលើកុមារ ដែលអាចការពារបាន ហើយកង្វះវីតាមីនអា នេះក៏ប៉ះពាល់ដោយប្រយោលនៃជំងឺកុមារ និងមរណភាព និងការចំណាយខ្ពស់ ។ កង្វះជាតិអ៊ីយ៉ូដ អាចបន្ថយប្រាជ្ញាស្មារតីរហូតដល់ ១៣-២១ IQ ។ កុមារដែលមានភាពស្លេក ស្លាំងរៀនខ្សោយនៅក្នុងសាលា ហើយប្រាជ្ញាស្មារតីរបស់ពួកគេត្រូវបានបន្ថយរហូតដល់ ៥-១០ IQពិន្ទុ ។ កង្វះជាតិប្រូតេអ៊ីន និងថាមពលច្រើនរួមផ្សំជាមួយកង្វះមីក្រូសារជាតិបញ្ជាក់ពីផលិតកម្មទាប និងបន្ថយសមត្ថភាពរកចំណូលក្នុងគ្រួសារ ។

បទពិសោធន៍អំពីកម្មវិធី សិទ្ធិកុមារនៅក្នុងសហគមន៍ បានបង្ហាញថា តំលៃនៃការកាត់បន្ថយកង្វះអាហារូបត្ថម្ភនៅកម្ពុជាអាចទាបនៅត្រឹមតែ ១,៧៨ ដុល្លា ក្នុងកុមារម្នាក់ (CNIP ២០០៣-២០០៧) ។ ដោយប្រើសមាហរណកម្ម ផែនការកម្មអន្តរផ្នែកនៃអាហារូបត្ថម្ភ និងបែបបទប្រមែប្រមូលសហគមន៍ វាអាចបង្កើនការប្រើប្រាស់ធនធាន ដើម្បីទទួលបាននូវលទ្ធផលប្រយោលជាវិជ្ជមាន ។ វិនិយោគនៅក្នុងអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជាទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ចខ្ពស់ ។ វាស្សូផលចំណេញនៃតំលៃត្រូវបានប៉ាន់ស្មានប្រហែលជា ១,៨ រាល់ប្រាក់ដុល្លារ ដែលចំណាយលើការធ្វើឱ្យប្រសើរឡើងនៃអាហារូបត្ថម្ភ ។ ដោយវាផ្តល់នូវផលចំណេញមកវិញ ៨ ដុល្លារអាមេរិក ។ ដោយលើកឡើងនូវបញ្ហាកង្វះអាហារូបត្ថម្ភនេះអាចធ្វើឱ្យមានការចូលរួមដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ដើម្បីដោះស្រាយមូលហេតុនៃកង្វះអាហារូបត្ថម្ភ គឺចាំបាច់សហគមន៍ត្រូវវាយតំលៃខ្លួនឯង និងវិភាគបញ្ហានានា ដែលគេជួបប្រទះមុនពេលរាល់សកម្មភាពសមស្របនានាត្រូវបានអនុវត្តនៅគ្រប់ថ្នាក់ ។ សហគមន៍ត្រូវតែជាអ្នកចូលរួម យ៉ាងសកម្មក្នុងការលុបបំបាត់ភាពក្រីក្រ ហើយមិនមែនជាអ្នកទទួលអកម្មនូវសេវា និងសំភារៈផ្សេងៗ ឡើយ ។ កម្មវិធី ដែលមាននៅក្រសួងនានា និងការគាំទ្រការខំប្រឹងប្រែងរបស់សហគមន៍ក្នុងទិសដៅរួមមួយ ។

ការផ្តោតលើការការពារនៃកង្វះអាហារូបត្ថម្ភ នៅឆ្នាំដំបូងនៃជីវិតដោយមានការធ្វើអន្តរាគមន៍ ចាប់ផ្តើមពីពេលមុនកំណើត ហើយផ្តោតលើ ២ឆ្នាំ ដំបូងនៃជីវិតនៅពេលដែលកុមារប្រមាណ ៥០% មានកង្វះអាហារូបត្ថម្ភ ។ វាក៏ចាំបាច់ដែរក្នុងការធ្វើឱ្យប្រសើរឡើងសមត្ថភាពអាហារូបត្ថម្ភ ស្ត្រីនៅក្នុងវ័យបន្តពូជ និងស្ត្រីមានផ្ទៃពោះ សំរាប់សុខភាពរបស់ពួកគេ ហើយនិងការពារ ការលូតលាស់យឺតយ៉ាវនៃទារកក្នុងផ្ទៃ ។

គោលនយោបាយឆ្លើយតបទៅនឹងកង្វះខាតអាហារូបត្ថម្ភដែលប្រឹងប្រែងអនុវត្តន៍ដោយក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការក្រៅរដ្ឋាភិបាល អង្គការសហប្រជាជាតិ ដូចជា កម្មវិធីស្បៀងអាហារពិភពលោក និងអង្គការយូនីសេហ្វ រួមមានដូចខាងក្រោម:

- ពង្រីកកម្មវិធីចែកចាយបន្ថែមនូវមីក្រូសារជាតិ ដូចជាវីតាមីនអា ជាតិដែក អាស៊ីដហ្វូលិក ដល់ចំណុចពិសេសស្ត្រី និងកុមារ ។
- បង្កើនផលិតកម្មអំបិលអ៊ីយ៉ូដ ដើម្បីសំរេចបាន អំបិលអ៊ីយ៉ូដភាវូនីយកម្មសកល (ឧទាហរណ៍ រាល់ការប្រើប្រាស់ អំបិលសំរាប់មនុស្ស និងសត្វត្រូវតែមានជាតិអ៊ីយ៉ូដ) ហើយលើកកំពស់ការប្រើអំបិលអ៊ីយ៉ូដដល់គ្រួសារទាំងអស់ ។ នៅកន្លែងមានអត្រាប្រេវ៉ាឡង់ ជំងឺពកកខ្ពស់ ត្រូវផ្តល់ថ្នាំកាប់ស៊ូល ដែលមានជាតិអ៊ីយ៉ូដ ។
- សកម្មភាពចុះមូលដ្ឋាននៅតំបន់ក្រីក្រ និងរួមបញ្ចូលការតាមដានការលូតលាស់ជាទៀងទាត់របស់កុមារអាយុក្រោម ២ ឆ្នាំ បញ្ចុះព្រូនជាទៀងទាត់ ហើយធ្វើការផ្សព្វផ្សាយអប់រំ និងពិគ្រោះពិភាក្សាអំពី ការផ្តល់អាហាឱ្យបានសមស្របដល់កុមារ ។

- ធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយា និងការប្រព្រឹត្តរបស់ក្រុមគ្រួសារក្នុងការស្វែងរកការថែទាំចំពោះកុមារ និងស្ត្រីមានផ្ទៃពោះ
- ការបន្ថែមអាហារនៅតែជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភ នៅក្នុងចំណោមប្រជាជនក្រីក្រ ។ ក្រុមប្រជាជន គឺកុមារអាយុ ៦-៥៩ខែ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅកូនដោយទឹកដោះផ្ទាល់ ។ ការបន្ថែមអាហារត្រូវធ្វើរាល់ខែជាមូលដ្ឋាន ដោយមានការអប់រំអំពីអាហារូបត្ថម្ភ និងការតាមដានការលូតលាស់របស់កុមារ ។
- និងស្រាវជ្រាវរកមើលលទ្ធភាពនៃការពង្រឹងអាហារមីក្រូសារជាតិ ដែលជាយុទ្ធសាស្ត្រសំរាប់លុបបំបាត់ចោលនូវ កង្វះមីក្រូអាហាររូបត្ថម្ភ ។

## ៤.៣.៣ អប់រំ

លក្ខណៈសំខាន់ៗនៃប្រព័ន្ធអប់រំកម្ពុជានៅក្នុងទសវត្សឆ្នាំ១៩៩០ គឺ (១)ចំនួនសិស្សមកពីគ្រួសារក្រីក្រ ជាពិសេសកុមារី និងក្រុមជនជួបការលំបាក ដូចជាកុមារជាជនជាតិភាគតិចនិងកុមារពិការដែលបានចូលរៀនមានចំនួនតិចតួចប៉ុណ្ណោះ នៅគ្រប់កំរិតសិក្សា ជាពិសេសនៅកំរិតមធ្យមសិក្សា និងកំរិតក្រោយមធ្យមសិក្សា (២)ប្រសិទ្ធភាពផ្ទៃក្នុងនៅមានកំរិត ដោយអត្រាសិស្សត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាខ្ពស់នៅកំរិតបឋមសិក្សា ឯការដាក់ពង្រាយបុគ្គលិកនៅមធ្យមសិក្សា ក៏ដូចជានៅក្រោយមធ្យមសិក្សាពុំទាន់មានប្រសិទ្ធភាពល្អ (៣)គុណភាពនៃសេវាអប់រំមិនទាន់មានលក្ខណៈច្បាស់លាស់ រួមទាំងលទ្ធភាពផ្តល់សៀវភៅសិក្សាមិនទាន់សមស្រប ហើយការបណ្តុះបណ្តាល និងការលើកទឹកចិត្តគ្រូបង្រៀនក៏នៅមានកំរិត (៤)លទ្ធភាពធនធានសំរាប់វិស័យអប់រំមានតិចតួច ។ កង្វះខាតធនធានសាធារណៈសំរាប់ប្រព័ន្ធអប់រំនាំអោយ ការចំណាយសំរាប់ការចូលរៀនមានកំរិតខ្ពស់ បញ្ហានេះគឺជាឧបសគ្គចំពោះលទ្ធភាពចូលរៀន ជាពិសេសកុមារមកពីក្រុមគ្រួសារក្រីក្រ ហើយការផ្តល់ប្រាក់បៀវត្សរ៍សំរាប់គ្រូបង្រៀនក៏មានកំរិតទាប។ លើសពីនេះទៀតការអប់រំក្រោយមូលដ្ឋាន ដែលមិនសូវទាក់ទងទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមក៏ជាហេតុធ្វើអោយប៉ះពាល់ដល់ការចូលរួមវិភាគទានរបស់វិស័យអប់រំទៅក្នុងការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចផងដែរ។

ភាពក្រីក្រ បានបង្កអោយមានភាពឯកោនិងភាពដាច់ឆ្ងាយពីសង្គម របស់ក្រុមប្រជាជនមួយចំនួនដែលមិនទាន់ទទួលបានសេវាបំរើផ្សេងៗព្រោះតែលក្ខណៈភូមិសាស្ត្រពិបាកនិងដាច់ស្រយាលពេក។ ដោយឡែកទៀតតំបន់ជនបទក្រីក្រ និងតំបន់ជនជាតិភាគតិច ក៏ទទួលរងគ្រោះដោយសារមិនមានសាលារៀនមិនគ្រប់គ្រាន់ ចំងាយផ្លូវពីផ្ទះទៅកាន់សាលារៀនឆ្ងាយពេក និងលក្ខខណ្ឌបន្ទប់រៀនមិនសមស្រប ព្រមទាំងសាលារៀនមិនគ្រប់កំរិតថ្នាក់សំរាប់កំរិតអប់រំមូលដ្ឋាន។ កត្តាទាំងអស់នេះគួបផ្សំជាមួយប្រាក់បៀវត្សដែលមិនមានលក្ខណៈជួយលើកទឹកចិត្តផងនោះធ្វើអោយគុណភាពអប់រំនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលទាំងអស់មានភាពមិនច្បាស់លាស់ ហើយថែមទាំងជួបការលំបាកក្នុងការទាក់ទាញគ្រូបង្រៀនអោយទៅបំរើការងារនៅតំបន់ទាំងនោះផងដែរ។ ម្យ៉ាងទៀតស្ថានភាពនេះ ក៏ជះឥទ្ធិពលមកពីពុំបានផ្តល់ឱកាសអោយបានគ្រប់គ្រាន់សំរាប់ចូលរៀនក្នុងប្រព័ន្ធឡើងវិញ ហើយនិងកង្វះខាតកម្មវិធីអក្ខរកម្មនៅតាមតំបន់ដែលការបោះបង់ការសិក្សារបស់សិស្សមានកំរិតខ្ពស់ ។

វត្ថុបំនងគោលនយោបាយនៃវិស័យអប់រំសំខាន់ៗមានបីគឺ: (១)សំរេចអោយបានការអប់រំសំរាប់ទាំងអស់គ្នា ដោយកុមារទាំងអស់បានបញ្ចប់ការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ តាមរយៈផ្តោតការដោះស្រាយលើបញ្ហានៃការផ្គត់ផ្គង់តំរូវការ និងគុណភាព និងប្រសិទ្ធភាព ជាពិសេសផ្តោតការយកចិត្តទុកដាក់លើក្រុមគ្រួសារក្រីក្របំផុត និងក្រុមងាយរងគ្រោះ (២)រួមចំនែកដល់កំនើន

សេដ្ឋកិច្ច តាមរយៈការបង្កើនសមធមិនៃការចូលរៀនប្រកបដោយគុណភាព និងបង្កើនការអប់រំក្រោយកំរិតអប់រំមូលដ្ឋានអោយឆ្លើយតបទៅនឹងតំរូវការជាក់ស្តែង (៣)ចីរភាពនៃការអភិវឌ្ឍន៍ស្ថាប័ន ដោយឆ្ពោះទៅរកការគ្រប់គ្រង និងការកសាងផែនការជួយដល់អ្នកក្រីក្រ។

ដើម្បីដោះស្រាយនូវបញ្ហាដែលបានលើកឡើងខាងលើ និងដើម្បីសំរេចបានវត្ថុបំណងរបស់វិស័យកម្មវិធីគាំទ្រវិស័យអប់រំ (ESSP) សំរាប់ឆ្នាំ២០០១-២០០៥ បានកំនត់យ៉ាងច្បាស់ពីគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីអប់រំ ហើយកម្មវិធី ESSP បានឯកភាពរួមគ្នាជាមួយអ្នកផ្តល់ជំនួយ/អង្គការក្រៅរដ្ឋាភិបាល កាលពីពាក់កណ្តាលឆ្នាំ២០០១ កន្លងមកនេះ។ ការរៀបចំកម្មវិធី ESSP ផ្អែកលើគោលវិធីរំកិល ដោយធ្វើការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំ រវាងរាជរដ្ឋាភិបាល និងដៃគូរបស់ខ្លួន។ កម្មវិធីនេះត្រូវបានរៀបចំកែតំរូវជារៀងរាល់ឆ្នាំ ដោយផ្អែកលើអានុសាសន៍នៃការពិនិត្យឡើងវិញលើ ESSP និងចំនែកថវិកាដែលបានគ្រោងនៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF)។ ESSP បានរៀបចំដោយឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ តាមរយៈការបញ្ចូលគ្នានៃកំណែទំរង់អោយមានលក្ខណៈជាប្រព័ន្ធ ដើម្បីធានាថាធនធានសាធារណៈត្រូវបានប្រើប្រាស់ជាចំបងសំរាប់កម្មវិធីនានាដែលផ្តល់ប្រយោជន៍ដល់អ្នកក្រីក្រច្រើនជាងអ្នកដែលធូធា។ កិច្ចអន្តរាគមន៍នានា គឺផ្តោតចំពោះក្រុមមុខសញ្ញាដែលងាយរង គ្រោះ និងក្រុមដែលជួបការលំបាកបំផុត ហើយវិធានការផ្សេងទៀត គឺបង្កើនភាពទាក់ទងនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលទៅនឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដើម្បីជួយជំរុញកំនើនសេដ្ឋកិច្ចជាតិ។ គោលដៅរយៈពេលវែងគឺ ត្រូវសំរេចអោយបានការអប់រំសំរាប់ទាំងអស់គ្នា (EFA) នៅឆ្នាំ២០១៥ ។ ចំណែកឯគោលដៅរយៈពេលមធ្យមគឺផ្តល់ការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំប្រកបដោយគុណភាព នៅឆ្នាំ២០១០ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងវិស័យ និងពង្រឹងការអភិវឌ្ឍន៍គោលនយោបាយឆ្ពោះទៅរកអ្នកក្រីក្រ ហើយនិងកែលំអការអប់រំក្រោយមូលដ្ឋានអោយទាក់ទងទៅនឹងស្ថានភាពជាក់ស្តែង។

រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការគោលនយោបាយនានា ដើម្បីអនុវត្តន៍កំណែទម្រង់អប់រំដើម្បីជួយដល់ជនក្រីក្រ ។ ការលុបបំបាត់ការបង់វិភាគទានពីមាតាបិតាសិស្សនៅដើមឆ្នាំសិក្សាក្នុងកំរិតអប់រំមូលដ្ឋាន (ថ្នាក់ទី១-៩) ដែលបានអនុវត្តន៍ក្នុងឆ្នាំសិក្សា២០០០/០១ កន្លងមកនេះ បង្ហាញអោយឃើញថាចំនួនសិស្សចុះឈ្មោះចូលរៀននៅទូទាំងប្រទេសបានកើនឡើង ១៨% ហើយកំនើននេះកាន់តែខ្ពស់នៅតំបន់ដាច់ស្រយាល។ នៅក្នុងរយៈពេល ២ឆ្នាំកន្លងមកនេះចំណែកថវិកាចំណាយចរន្តសំរាប់វិស័យអប់រំបានកើនឡើងពី ១៥,៧% ទៅ ១៨,២% ហើយអាចផ្តល់ជាថវិកាសំរាប់ដំណើរការសាលារៀនបឋមសិក្សា និងមធ្យមសិក្សា បានប្រហែល ៦.០០០ សាលារៀន ។

គោលដៅសំរាប់ការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ គឺសំរេចអោយបានអត្រាពិតនៃការសិក្សា ១០០% ប្រកបដោយគុណភាពនៅក្នុងរយៈពេល ៨ឆ្នាំខាងមុខ តាមរយៈការបង្កើនចំនួនសិស្សចូលរៀនពីគ្រួសារក្រីក្រ កុមារី និងក្រុមជួបការលំបាកដូចជាកុមារជនជាតិភាគតិចនិងកុមារពិការ។ ជាមួយនោះដែរគោលដៅសំរាប់ការអប់រំក្រោយមូលដ្ឋាន គឺត្រូវពង្រីកឱកាសអប់រំនៅមធ្យមសិក្សាទុតិយភូមិ និងនៅកំរិតអប់រំក្រោយមធ្យមសិក្សាបន្ថែមទៀតតាមរយៈការពង្រីកការផ្តល់សេវាកម្មអប់រំពីផ្នែកសាធារណៈ និងផ្នែកឯកជន ហើយត្រូវបង្កើនការចូលរៀនរបស់អ្នកក្រីក្រ និងនារីភេទ ។ គោលដៅដ៏មានសារៈសំខាន់មួយទៀតគឺសំរេចអត្រាឡើងថ្នាក់ និងអត្រាឆ្លងភូមិសិក្សាអោយបានយ៉ាងហោចណាស់ ៩៥%នៅគ្រប់កំរិតសិក្សា ក្នុងអំឡុងពេលពីឆ្នាំ ២០០៥ ដល់ឆ្នាំ២០១០ និងកាត់បន្ថយអត្រាត្រួតថ្នាក់អោយមកនៅក្រោម៥% នៅកំរិតបឋមសិក្សា និងមធ្យមសិក្សា ។ គោលដៅដែល

ប្រកបដោយប្រសិទ្ធភាពមួយផ្សេងទៀត គឺកាត់បន្ថយសមាមាត្រ បុគ្គលិកមិនបង្រៀនអោយនៅប្រហែល ១៥% និងបង្កើនផលធៀបសិស្ស/គ្រូ ៣៥:១ នៅមធ្យមសិក្សា និង ២៥:១ នៅកំរិតអប់រំក្រោយមធ្យមសិក្សា ។

ដើម្បីអនុវត្តន៏គោលនយោបាយទាំងនេះជាទិសដៅ គឺត្រូវបន្តបង្កើនចំណែកថវិកាចំណាយចរន្តរបស់រាជរដ្ឋាភិបាលអោយបានយ៉ាងតិច ២០%នៅត្រឹមឆ្នាំ២០០៥ ហើយក្នុងនេះថវិកាប្រហែល ៧០% គឺសំរាប់ការអប់រំមូលដ្ឋាន។ ម្យ៉ាងទៀត ដើម្បីបង្កើននិងរក្សាអោយបាននូវគុណភាពអប់រំ គឺត្រូវរក្សាចំណែកថវិកាមិនមែនបៀវត្សអោយបានពី ៤០%-៤៥% ក្នុងរយៈពេល៥ឆ្នាំខាងមុខ ហើយតាមរយៈយន្តការនៃការពិនិត្យឡើងវិញជាទៀងទាត់នូវនិន្នាការនៃហិរញ្ញប្បទានទូលំទូលាយរបស់វិស័យយន្តការនេះនឹងធានាផងដែរនូវកំនើនប្រាក់បៀវត្សរបស់បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន អោយបានស្របតាមគោលការណ៏ណែនាំស្តីពីមន្ត្រីរាជការស៊ីវិល។

ការបង្កើនចំណែកថវិកាសំរាប់វិស័យអប់រំត្រូវបានគ្រោងឡើងសំរាប់ផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ផែនការនេះកសាងឡើងដោយផ្អែកលើនិន្នាការពីរឆ្នាំកន្លងមកនេះ។ នៅក្នុងជំពូកទី ៥ បានបង្ហាញជូនពីចំណោលនៃការចំនាយដែលត្រូវបានបង្កើនជាលំដាប់ពី ១៦.២%នៃចំណាយចរន្តនៅឆ្នាំ ២០០១ ឡើងដល់ ១៨.៥%នៅឆ្នាំ ២០០៣ និង ២០%នៅឆ្នាំ ២០០៥។ កម្មវិធី ESSP ផ្តល់នូវក្របខ័ណ្ឌការងារមួយសំរាប់ការបែងចែកធនធានទាំងនេះ ក៏ដូចជាធនធានដែលឧបត្ថម្ភដោយអ្នកផ្តល់ជំនួយ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ការកែលំអការគ្រប់គ្រងការចំណាយសាធារណៈ ក៏ជាចំនុចគន្លឹះមួយផងដែរ (សូមមើលជំពូកទី៥)។ ស្របគ្នាទៅនឹងវិធានការណ៏នានាដែលបានគ្រោងនៅក្នុង ESSP ចីរភាពនៃការរីកចំរើននៅក្នុងកំណែទំរង់ប្រាក់បៀវត្សសំរាប់មន្ត្រីរាជការស៊ីវិល គឺជាចំណុចសំខាន់បំផុត ដើម្បីជួយដោះស្រាយនូវឧបសគ្គចំពោះការបំពេញការងាររបស់គ្រូជាពិសេសគ្រូបង្រៀន ដែលនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល។

បង្កើនការចូលរៀនដោយកាត់បន្ថយនូវការចំណាយចំពោះសិស្សក្រីក្រ ហើយនិងកាត់បន្ថយចំណាយមិនផ្លូវការរបស់មាតាបិតាសិស្ស តាមរយៈការផ្តល់ថវិកាសំរាប់ដំណើរការសាលារៀន/គ្រឹះស្ថានសិក្សា។ យុទ្ធសាស្ត្រអប់រំជាមូលដ្ឋានមួយទៀត គឺផ្តល់សំភារៈរូបវ័ន្តបន្ថែមទៀត ដល់តំបន់ដែលពុំទាន់មានការផ្គត់ផ្គង់បានគ្រប់គ្រាន់ ហើយនិងការផ្តល់រង្វាន់លើកទឹកចិត្ត/ អាហារូបករណ៏ដល់តំបន់ដែលមានសន្ទស្សន៏ភាពក្រីក្រ សំរាប់សិស្សនៅបឋមសិក្សានិងមធ្យមសិក្សា ដែលវិធានការនេះនឹងជួយដោះស្រាយបញ្ហាលទ្ធភាពចូលរៀន និងភាពគង់វង្សនៃការសិក្សារបស់សិស្ស។ យុទ្ធសាស្ត្រមួយទៀតគឺកែលំអភាពសក្តិសិទ្ធនៃការផ្តល់សេវាតាមរយៈការធានាដល់ការបណ្តុះបណ្តាល និងការលើកទឹកចិត្តគ្រូបង្រៀន និងសមធម៌នៃការផ្តល់សៀវភៅសិក្សាគោលដៅទូទាំងប្រទេស ជាពិសេសនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ យុទ្ធសាស្ត្រជួយសំរួលដល់ការចូលរៀន និងការចូលរៀនជាថ្មីនៅក្នុងប្រព័ន្ធអប់រំផ្លូវការ (កម្មវិធីអភិវឌ្ឍន៏និងគាំពារកុមារតូច និងកម្មវិធីចូលរៀនជាថ្មី) នឹងត្រូវបានបំពេញបន្ថែមតាមរយៈវិធានការមួយចំនួនទៀត ដូចជាការផ្តល់ឱកាសសំរាប់ការអប់រំក្រៅប្រព័ន្ធ កម្មវិធីអក្ខរកម្ម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់យុវជននិងជនពេញវ័យនៅក្រៅសាលា។ លើសពីនេះទៀត សកម្មភាពមួយចំនួនត្រូវអនុវត្តន៏ដើម្បីធានាថា កុមារីចូលរៀនទៅតាមអាយុកំនត់ហើយបានបញ្ចប់ការអប់រំមូលដ្ឋាន ហើយដែលសកម្មភាពនេះឈានទៅកាត់បន្ថយបានជាបណ្តើរៗនូវអនក្ខរភាពដ៏ខ្ពស់ក្នុងជួរកុមារី និងស្ត្រីភេទ។

យុទ្ធសាស្ត្រសំរាប់ការអប់រំក្រោយមូលដ្ឋាន គឺលើកកំពស់ការចូលរួមពីផ្នែកឯកជន ព្រមទាំងការបង់ថ្លៃពីសិស្ស និងនិស្សិត នៅក្នុងខណៈដែលអនុវត្តន៍កម្មវិធីផ្តល់អាហារូបករណ៍ផ្អែកលើតំរូវការនិងការបំពេញការងារ និងសំភារៈរូបវ័ន្ត ផ្សេងៗទៀត (ឧទាហរណ៍ៈ អន្តេវាសិកដ្ឋាន) ដោយធានាថាសិស្សក្រីក្រ សិស្សស្រី និងក្រុមជួបការលំបាកដូចជា ជនជាតិភាគតិចមានលទ្ធភាព ចូលរៀនកាន់តែច្រើននៅក្នុងកំរិតនេះ។ ការប្រលងបញ្ចប់ថ្នាក់ទី ១២ នាពេលថ្មីៗនេះជាមូលដ្ឋានដើម្បីបង្កើតប្រព័ន្ធមួយមាន តម្លាភាពនិងយុត្តិធម៌ ដល់ការចូលរៀននៅសកលវិទ្យាល័យ ហើយលុបបំបាត់នូវឧបសគ្គនៃការបង់ថ្លៃមិនផ្លូវការសំរាប់ការចូល រៀន ដែលនេះជាឧបសគ្គចំពោះសិស្ស/និស្សិតមកពីក្រុមគ្រួសារក្រីក្រ។ រៀបចំបង្កើតប្រព័ន្ធនានាសំរាប់ការកំណត់ស្តង់ដារ និងធានា គុណភាពដែលប្រព័ន្ធនេះធានាបានថាកម្មវិធីសិក្សារបស់កម្មវិធីអប់រំក្រោយមូលដ្ឋានបានរៀបចំជាបណ្តើរៗ ទាក់ទិនទៅ នឹងតំរូវការជាក់ស្តែងរបស់ទីផ្សារ។

ការអនុវត្តន៍កម្មវិធីនេះផ្អែកលើ ការបន្តប្រើប្រាស់យន្តការរបស់កម្មវិធីសកម្មភាពជាអាទិភាព នៃថវិកាចំណាយចរន្ត ជំពូក១៣ ដោយពង្រីកការកសាងសមត្ថភាពគ្រប់គ្រង និងពិនិត្យតាមដានការងារបច្ចេកទេស និងហិរញ្ញវត្ថុ ទាំងនៅថ្នាក់កណ្តាល ថ្នាក់មន្ទីរអប់រំខេត្ត/ក្រុង ថ្នាក់ការិយាល័យអប់រំស្រុក/ខ័ណ្ឌ និងថ្នាក់សាលារៀន ។ គោលដៅជាយុទ្ធសាស្ត្រ ដែលបានកំណត់នេះ នឹងរួមបញ្ចូលកម្មវិធីបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ទៅដល់គ្រូឧទ្ទេសនាម អធិការកិច្ចអប់រំ មន្ត្រីអប់រំក្រៅប្រព័ន្ធ និងអ្នកដឹក នាំសហគមន៍អំពីការងារគ្រប់គ្រងកម្មវិធីអប់រំ ដើម្បីធ្វើយ៉ាងណាអាចជួយដល់ក្រុមជនក្រីក្របាន ។ យុទ្ធសាស្ត្រសំខាន់មួយទៀតគឺ ខិតខំស្រូបយកជំនួយបរទេសអោយជួយគាំទ្រថវិការួមគ្នា វិនិយោគលើផ្នែកសំភារៈរូបវ័ន្ត និងការកសាងសមត្ថភាព ហើយនិងការ ផ្តល់ជំនួយបច្ចេកទេសជាដើម ។

កម្មវិធីសកម្មភាពជាអាទិភាពត្រូវបានពង្រីកសំរាប់ៈ (១)កម្មវិធីគុណភាពនិងប្រសិទ្ធភាពផ្តោតលើការផ្តល់ថវិកាដំណើរ ការសាលារៀន និងសកម្មភាពមួយចំនួនផ្សេងទៀតទាំងក្នុងសាលារៀនបឋមសិក្សា និងមធ្យមសិក្សា សាលាបណ្តុះបណ្តាល វិជ្ជាជីវៈ សាលាគរុកោសល្យ និងគ្រឹះស្ថានឧត្តមសិក្សា ហើយនិងពង្រីកការអភិវឌ្ឍន៍គ្រូបង្រៀន ព្រមទាំងការផ្គត់ផ្គង់ សៀវភៅសិក្សាទៀតផង (២)កម្មវិធីបង្កើនការចូលរៀនរបស់សិស្សរួមមាន ការបង្រៀនសិស្សខ្សោយជាបន្តទៀត ការពង្រីក ការអប់រំក្រៅប្រព័ន្ធ និងការបង្កើនការយល់ដឹងអំពីជំងឺហ៊ីវ/អេដស៍ ព្រមទាំងការផ្តល់រង្វាន់លើកទឹកចិត្ត និងអាហារូបករណ៍ សំរាប់សិស្សក្រីក្រ សិស្សស្រី និងក្រុមជនជាតិភាគតិច ។

លើសពីនេះទៀតក៏មានការពង្រីកកម្មវិធីសំភារៈរូបវ័ន្តសាលារៀនផងដែរ ជាពិសេសផ្តោតលើការផ្តល់បន្ថែមនូវចំនួន សាលាបឋមសិក្សា និងមធ្យមសិក្សា ហើយនិងបង្កើនចំនួនបន្ទប់រៀនបន្ថែមទៀតនៅក្នុងឃុំ ស្រុកដែលពុំមានការផ្គត់ផ្គង់គ្រប់គ្រាន់ លក្ខណៈវិនិច្ឆ័យសំរាប់ការពង្រីករួមមានៈ (១)ភូមិ ឃុំដែលពុំទាន់មានសាលារៀន (២)សាលាបឋមសិក្សា និងមធ្យមសិក្សា ដែលមិនទាន់មានគ្រប់កំរិតថ្នាក់ (៣)សាលារៀនដែលមានសិស្សច្រើនលើសលុប។ សំរាប់កម្មវិធីសំភារៈរូបវ័ន្តមានការផ្តល់ បន្ថែមនូវសំភារៈរូបវ័ន្តដល់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលស្ថិតក្នុងតំបន់ដែលគ្មានការផ្គត់ផ្គង់គ្រប់គ្រាន់ ការផ្តល់បន្ទប់ រៀនថ្មីដែលអាចប្រើបានច្រើនមុខនៅក្នុងសាលាមធ្យមសិក្សា និងការកែលំអផ្សេងៗទៀតនៅគ្រឹះស្ថានសិក្សាសំរាប់ការអប់រំ ក្រោយមូលដ្ឋានដែលចាំបាច់ត្រូវលើកកំពស់ផលសំរេចនៃការអប់រំ (ឧទាហរណ៍ៈ បន្ទប់ពិសោធន៍ និងបណ្ណាល័យ) ការផ្តល់អន្តេវា-

សិកដ្ឋាននៅក្នុងសាលាមធ្យមសិក្សាជ្រើសរើសមួយចំនួន ក្នុងសាលាគរុកោសល្យ និងក្នុងគ្រឹះស្ថានឧត្តមសិក្សាព្រមទាំងការផ្តល់កន្លែងស្នាក់នៅរបស់គ្រូបង្រៀនក្នុងតំបន់ដាច់ស្រយាលផងដែរ ។

កម្មវិធីកសាងសមត្ថភាព នឹងជួយពង្រឹងដំណើរការគ្រប់គ្រងកម្មវិធី និងការគ្រប់គ្រងទូទាំងវិស័យទាំងនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត/ក្រុង ថ្នាក់ស្រុក/ខ័ណ្ឌ ។ អាទិភាពមួយនៃកម្មវិធីនេះ គឺត្រូវធានាបាននូវសមត្ថភាព ក្នុងការរៀបចំផែនការ ការពិនិត្យតាមដានបច្ចេកទេស និងហិរញ្ញប្បទាន និង ការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព។ អាទិភាពមួយទៀតនោះគឺពង្រឹងក្របខ័ណ្ឌអភិបាលកិច្ចវិស័យអប់រំនៅគ្រប់លំដាប់ថ្នាក់រួមទាំងយន្តការសំរាប់សាលារៀនក្នុងការទទួលខុសត្រូវចំពោះសហគមន៍។

## ៤.៣.៤ ទឹកស្អាត និងអនាម័យ

ដូចបានចង្អុលបង្ហាញនៅជំពូក ៣ ខាងលើប្រជាជននៅជនបទនៅតែមានការលំបាកក្នុងការទទួលបានការផ្គត់ផ្គង់ទឹកនិងអនាម័យ។ ទោះបីប្រភពទឹកក្រោមដីមានលក្ខណៈសំបូរយ៉ាងណាក៏ដោយក៏ទឹកស្អាត ដែលបានផ្គត់ផ្គង់ជូនប្រជាពលរដ្ឋនៅមានកំរិត។ តាមទិន្នន័យនានា ឆ្នាំ ២000 នៃ DHS បានបង្ហាញថា ៥៤ភាគរយនៃគ្រួសារក្រីក្រនៅជនបទបានប្រើប្រាស់អណ្តូងស្នប់ រឺអណ្តូងជីក ក្នុងនោះគ្រួសារអ្នកធូរធានៅជនបទមាន ១៥ ភាគរយ និង អ្នកនៅទីក្រុង ៦ ភាគរយ។ ជំរឿននៅឆ្នាំ ១៩៩៨ បានអោយដឹងថាមាន ២៣ភាគរយ នៃគ្រួសារនៅជនបទអាចមានលទ្ធភាពប្រើប្រាស់ទឹកស្អាតសំរាប់ផឹក ចំនែកគ្រួសារអ្នកនៅទីក្រុងអាចមានទឹកស្អាតសំរាប់ផឹករហូតដល់ ៦០ភាគរយ ។ តាមតួលេខ ក៏មានបញ្ជាក់ផងដែរ ២០ភាគរយនៃប្រជាជនក្រីក្របំផុតនៅជនបទមានការប្រើប្រាស់ទឹកស្អាតសំរាប់ផឹកបានត្រឹមតែ ៤ ភាគរយប៉ុណ្ណោះ ។ តាមការអង្កេតអត្រាមរណនៃកុមារបានកើនឡើងពី ៨៨/១000 ទៅដល់ ៩៥/១000 នៅក្នុងឆ្នាំ ១៩៩០ ដល់ ១៩៩៧ ដែលស្ថានភាពនេះពាក់ពន្ធ័យ៉ាងច្បាស់ទៅនឹងកំរិតដ៏ទាបនៃលទ្ធភាពផ្គត់ផ្គង់ទឹកនៅជនបទ ។

ការផ្គត់ផ្គង់ទឹកគឺជាចំនុចគន្លឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលបានធ្វើការវិនិយោគលើសំណង់ធារាសាស្ត្រខ្នាតតូចសំរាប់ការធ្វើស្រែ និងចំការ ក៏ដូចជាការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតាមជនបទ ។ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយជាយុទ្ធសាស្ត្រក្នុងការផ្គត់ផ្គង់ទឹកនិងអនាម័យដោយយកចិត្តទុកដាក់ដល់ការធ្វើស្វ័យាភិបាលសេដ្ឋកិច្ច, ការកំរិតតំលៃ, ការចូលរួមរបស់ផ្នែកឯកជន, ការសំរបសំរួលរបស់អ្នកផ្តល់ជំនួយ, ការចែកចាយប្រភពទឹក និងការទទួលខុសត្រូវច្បាស់លាស់ ។

រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់ការ អភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកដោយប្រើជាមធ្យោបាយបង្កើនសុខភាពប្រជាជន និងការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។ ការយកចិត្តទុកដាក់ដោយប្រុងប្រយត្ន័ត្រូវបានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់អោយបានល្អប្រសើរនូវប្រភពទឹកដែលមានស្រាប់ទៅលើការពង្រឹងសមត្ថភាពស្ថាប័ន ការបង្កើនកំរិតផលិតកម្មនៃអង្គភាពផ្គត់ផ្គង់ទឹកដែលមានស្រាប់ ដោយធ្វើអោយប្រសើរឡើងថែមទៀតនូវការអនុវត្តន៏របស់ពួកគេ នឹងការពង្រីកបណ្តាញផ្គត់ផ្គង់ទឹកដល់អ្នកប្រើប្រាស់ ។ ការស្វ័យគ្រប់គ្រង និងម្ចាស់ការហិរញ្ញវត្ថុឈានទៅអោយអ្នកផ្គត់ផ្គង់ទឹកមានលទ្ធភាពម្ចាស់ការក្នុងការថែទាំ និង វិនិយោគ ។ អណ្តូងជនបទ និងត្រូវពង្រីកតាមរយៈការបង្កើនការបែងចែកថវិការបស់រាជរដ្ឋាភិបាល និងការគាំទ្ររបស់អ្នកផ្តល់ជំនួយដោយយកចិត្តទុកដាក់លើការចូលរួមយ៉ាងសកម្មនៃអ្នកទទួលផលនៅមូលដ្ឋានក្នុងដំណើរការប្រើប្រាស់ និងការថែទាំ ជាពិសេសចំពោះស្ត្រីដែលជាអ្នកប្រមូល និងប្រើប្រាស់ទឹកមុនគេ ។ ការថែទាំសុខភាពនឹងត្រូវយកចិត្តទុកដាក់ដោយក្រសួង

អភិវឌ្ឍន៍ជនបទដើម្បីធានាថាកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនៅជនបទដែលជាគន្លឹះសំខាន់ដល់អ្នកប្រើប្រាស់ ហើយគ្របដណ្តប់លើអត្រាអ្នកក្រីក្រដែលជួបបញ្ហាស្ថានភាពបរិស្ថាន យេនឌ័រ និងភូមិសាស្ត្រ ។

## ៤.៤ ពង្រឹងសមត្ថភាពស្ថាប័ន និងកែលំអអភិបាលកិច្ច

បញ្ហាអស្ថិរភាព និងវិបត្តិនយោបាយអស់រយៈពេលជិត ២៥ ឆ្នាំ បាននាំឱ្យស្ថាប័នរបស់រដ្ឋ និងប្រព័ន្ធរដ្ឋបាលរបស់ប្រទេសមិនមានដំណើរការល្អ និងស្ទើរតែដួលរលំទាំងស្រុង ។ ហេតុនេះហើយបានជាក្រោយពេលបញ្ចប់សង្គ្រាម រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការអនុវត្តន៍គោលការណ៍ប្រជាធិបតេយ្យសេរី ការគោរពសិទ្ធិមនុស្ស ការអភិវឌ្ឍន៍សហគ្រាសឯកជន និងសេដ្ឋកិច្ចទីផ្សារ ហើយនិងការធ្វើសមាហរណកម្មប្រទេសទៅក្នុងតំបន់ និងពិភពលោក ។ ការងារទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច យុត្តិធម៌សង្គម និងការកាត់បន្ថយភាពក្រីក្រ ។ ការពង្រឹងនិតិរដ្ឋ និងការប្រតិបត្តិតាមគោលការណ៍អភិបាលកិច្ចដូចជាតម្លាភាព ភាពអាចប្រមាណទុកជាមុនបាន ការទទួលខុសត្រូវខ្ពស់ និងការចូលរួម គឺជាតម្រូវការដ៏សំខាន់ដែលមិនអាចខ្វះបាន ដើម្បីសំរេចឱ្យបានជោគជ័យតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

ព្រះរាជាណាចក្រកម្ពុជាក្នុងទសវត្សថ្មីនេះ គឺជាប្រទេសមួយដែលបានអនុវត្តលទ្ធិប្រជាធិបតេយ្យនៅទូទាំងប្រទេស សេដ្ឋកិច្ចទីផ្សារ និងធានាបានទាំងស្រុងនូវសន្តិភាព និងសុវត្ថិភាពសង្គម ហើយទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននឹងកំពុងកែលំអស្ថាប័នរដ្ឋនានាមួយដំណាក់កាលម្តងៗ ទៅតាមបែបបទ និងបរិយាកាសសង្គម ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាកំពុងស្ថិតនៅលើចំណុចចាប់ផ្តើមនៃការធ្វើដំណើរលើដងផ្លូវដ៏វែងឆ្ងាយមួយប្រកបដោយក្តីសង្ឃឹមយ៉ាងមុតមាំ ជាមួយនឹងធនធានដ៏មានកំរិត ។ កម្មវិធីកំណែទំរង់ដែលបានដាក់បញ្ចូលក្នុងឯកសារផ្លូវការនានា ដូចជាៈ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ និងឯកសារជាតិស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ គឺជាតម្រូវការដ៏ចាំបាច់ ។ ជោគជ័យនឹងអាស្រ័យទៅលើការពង្រីក និងពង្រឹងការអនុវត្តន៍គោលការណ៍អភិបាលកិច្ចល្អ ។ រាជរដ្ឋាភិបាលបានពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយដៃគូរពាក់ព័ន្ធទាំងអស់មុននឹងអនុម័តលើផែនការសកម្មភាពអភិបាលកិច្ចកាលពីខែមីនា ឆ្នាំ ២០០១ ។

ផែនការសកម្មភាពអភិបាលកិច្ច គឺជាកំរងឯកសារផែនការយុទ្ធសាស្ត្រដែលមានលក្ខណៈរំកិល និងបង្កើតបានជាយុទ្ធ-សាស្ត្រមួយប្រកបដោយតម្លាភាព និងនិរន្តរភាពដើម្បីសម្របសម្រួលការអនុវត្តន៍ការងារឱ្យបានល្អប្រសើរលើវិស័យអាទិភាពទាំង ៨ៈ កំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ, កំណែទំរង់រដ្ឋបាល និងវិសហមជ្ឈការ, វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន, ហិរញ្ញវត្ថុសាធារណៈ, ការប្រឆាំងអំពើពុករលួយ, សមភាពបុរស និងស្ត្រី, ការរំសាយកងទ័ព និងកំណែទំរង់កងយោធពលខេមរៈភូមិន្ទ ហើយនិងការគ្រប់គ្រងធនធានធម្មជាតិ (ដីធ្លី ព្រៃឈើ និងជលផល) ។ គំរោងសកម្មភាពការងារភាគច្រើនសំរាប់រយៈពេលខ្លីត្រូវអនុវត្តបានសំរេច ហើយគំរោងសកម្មភាពសំរាប់រយៈពេលមធ្យមកំពុងដាក់ឱ្យដំណើរការបានយ៉ាងល្អ ។ ផែនការសកម្មភាពអភិបាលកិច្ចទី២ កំពុងត្រូវបានតាក់តែងរៀបចំឡើងដោយដាក់បញ្ចូលនូវគំរោងសកម្មភាពការងារជាអាទិភាពថ្មីៗ សំរាប់រយៈពេល ៣ ឆ្នាំ ខាងមុខដោយផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍន៍សង្គមកិច្ចឱ្យបានល្អប្រសើរ ។

សមត្ថភាពធនធានមនុស្សក្នុងស្រុកពុំសូវមានសមត្ថភាពសំបូរបែប ហើយក្នុងក្របខ័ណ្ឌនៃច្បាប់ហិរញ្ញវត្ថុ ថវិកាសំរាប់បៀវត្សត្រូវបានកំរិតដោយត្បិតត្បៀត និងថវិកាសំរាប់ប្រតិបត្តិការការងារ មិនត្រូវបានបើកផ្តល់ទៅឱ្យបានគ្រប់គ្រាន់ដែលជា

ហេតុនាំឱ្យគ្មានឱកាស និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីឈានឆ្ពោះទៅរកការផ្លាស់ប្តូរ និងបង្កើនទិន្នផលការងារ ។ ដូចនេះហើយបានជារាជរដ្ឋាភិបាលចាំបាច់ត្រូវតែពង្រឹងឡើងវិញនូវសមត្ថភាពជំនាញមន្ត្រីរាជការ និងការគ្រប់គ្រង រួមទាំងបង្កើនបរិយាកាសកន្លែងធ្វើការឱ្យបានល្អប្រសើរ ។ ការប្រមើលមើលសំរាប់អនាគតរាជរដ្ឋាភិបាលនឹងបន្តការងាររបស់ខ្លួន ដោយមានជំនួយឧបត្ថម្ភពីខាងក្រៅលើកលែងតែការវិនិយោគជាបឋមសំខាន់ៗដែលត្រូវបានដាក់ឱ្យដំណើរការ ហើយបែបផែននៃការផ្តល់ជំនួយនឹងត្រូវពិនិត្យមើល ឬធ្វើការកែតម្រូវបើចាំបាច់ដើម្បីឆ្ពោះទៅការពង្រឹងភាពម្ចាស់ការ និងការធ្វើឱ្យមានឧត្តមភាពលើការផ្ទេរចំណេះដឹងនិងសមត្ថភាពជំនាញ ។ ប៉ុន្តែអ្វីដែលជាអាទិភាពបំផុតនោះ គឺការបង្កើតមូលដ្ឋានគ្រឹះនៃការឯកភាពគ្នាជាឯកឆន្ទៈស្តីពីអ្វីដែលត្រូវអនុវត្តឱ្យបានសំរេច ។ បញ្ហាដែលចោទឡើង គឺមានការពាក់ព័ន្ធទៅនឹងមធ្យោបាយ និងការរក្សាឱ្យបាននិរន្តរភាព ។ ជាពិសេសនោះគឺថា តើធនធានដែលត្រូវការចាំបាច់នោះត្រូវបានផ្តល់ឱ្យទាន់ពេលវេលាដែរ ឬអត់ ?

ជំពូកស្តីពីការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ និងលើកកម្ពស់អភិបាលកិច្ចនៃឯកសារយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រនេះ គឺនិយាយអំពីអន្តរវិស័យ៤ ផ្នែកសំខាន់ៗដើម្បីពង្រឹងស្ថាប័ន និងអភិបាលកិច្ចក្នុងទិសដៅដើម្បីជួយគាំទ្រការកាត់បន្ថយភាពក្រីក្រៈ ប្រព័ន្ធយុត្តិធម៌មួយដែលគាំទ្រដល់ការអភិវឌ្ឍន៍ និងការការពារសិទ្ធិសេរីភាព ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានដែលចែករំលែកអំណាចទៅអោយប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានរដ្ឋបាលសាធារណៈមួយដែលជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព និងជាដៃគូដ៏មានសមត្ថភាពក្នុងការអភិវឌ្ឍន៍ ហើយនិងបរិយាកាសមួយដែលគ្មានអំពើពុករលួយរាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍន៍ និងយុត្តិធម៌សង្គម ។ ជារួមគោលដៅនៃអន្តរវិស័យទាំង៤ នេះ គឺជាបេសកកម្មដ៏ឧត្តុងឧត្តមដើម្បីឆ្ពោះទៅរកអភិបាលកិច្ចល្អដែលត្រូវបានចាត់ទុកជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍ប្រទេស និងការកាត់បន្ថយភាពក្រីក្រ ហើយនិងដើម្បីឈានទៅសំរេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍន៍នាសហសវត្សថ្មី ។

ក្រៅពីនេះគោលដៅដទៃទៀតនៃកំណែទម្រង់អភិបាលកិច្ចលើការងារសារពើពន្ធ ថវិកា និងហិរញ្ញវត្ថុ ហើយនិងការគ្រប់គ្រងធនធានធម្មជាតិ គឺជាបញ្ហាដ៏សំខាន់ដោយឡែកផងដែរដែលត្រូវបានដាក់បញ្ចូលក្នុងជំពូកផ្សេងៗទៀតនៃឯកសារយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រនេះ ។ សកម្មភាពជាក់ស្តែងសំរាប់រយៈពេលមធ្យមមិនទាន់បានកំណត់ឱ្យបានលំអិតលើវិស័យនីមួយៗ ។ ការងារជាច្រើនដែលកំពុងដំណើរការគឺជាការរក្សា និងពង្រឹងសមិទ្ធផលដែលសំរេចបាន ហើយនឹងការបំពេញបន្ថែមនូវចំណេះដឹងសំរាប់បន្តនិរន្តរភាពការងារ ដូចជាៈ (១)ផ្តល់នូវយុត្តិធម៌សំរាប់ប្រជាពលរដ្ឋទូទៅ (២) ចែករំលែកអំណាចទៅឱ្យសហគមន៍មូលដ្ឋាន (៣) កំណែទំរង់បៀវត្ស និងនិយោជន៍ក្នុងមុខងារសាធារណៈ និង (៤) ការគាស់រំលើង និងលុបបំបាត់បុព្វហេតុ និងឱកាសនៃការប្រព្រឹត្តអំពើពុករលួយក្នុងស្ថាប័នសាធារណៈ ។ ការងារទាំងអស់នេះមានគោលដៅដ៏ប្រទាក់ក្រឡាគ្នាបំផុត ។

ការងារកំណែទំរង់ទាំងនេះ គឺត្រូវប្រើប្រាស់ពេលវេលាយូរដើម្បីធ្វើឱ្យការខិតខំប្រឹងប្រែង និងសមិទ្ធផលកើតចេញជារូបរាងជាក់ស្តែង។ ដូច្នេះយុទ្ធសាស្ត្រជាទូទៅ គឺត្រូវបង្កើតឱ្យបានឆាប់រហ័សនូវមូលដ្ឋានគ្រឹះសំរាប់ធានាឱ្យមានចីរភាព និងដោះស្រាយបញ្ហាបន្ទាន់ៗជាច្រើនដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។

## ៤.៤.១ កំណែទំរង់វិស័យតុលាការ

ក្នុងរបបខ្មែរក្រហម ប្រព័ន្ធច្បាប់ និងតុលាការបានដំណើរការដោយមានលក្ខណៈឃោរឃៅ និងយង់ឃ្នងរួមផ្សំជាមួយ

នឹងអ្នកអនុវត្តដែលគ្មានធមិមេត្តា ។ ក្នុងបរិបទមួយដែលប្រទេសមានសន្តិភាព សន្តិសុខ និងស្ថិរភាពនយោបាយកំណែទំរង់ច្បាប់ និងតុលាការត្រូវបានចាត់ទុកជាចំណុចស្នូលដ៏សំខាន់នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ គោលដៅជាចំបង គឺផ្តល់នូវលក្ខខណ្ឌដ៏ចាំបាច់ និងសមស្របដើម្បីជំរុញការគោរពសិទ្ធិមនុស្ស និងសិទ្ធិលើកម្មសិទ្ធិ ហើយនិងការអភិវឌ្ឍន៍វិស័យឯកជនឱ្យមានលក្ខណៈរឹងមាំដែលអាចចាត់ទុកជាភ្នាក់ងារមួយនៃការអភិវឌ្ឍន៍ ។ កំណែទំរង់ប្រព័ន្ធយុត្តិធម៌ គឺជាដំណើរការមួយដែលត្រូវអនុវត្តដោយមានលក្ខណៈវឌ្ឍនៈភាព និងចីរភាព ។ ដូច្នេះកំណែទំរង់នេះត្រូវតែអនុវត្តឱ្យបានសមស្របទៅនឹងតំលៃ និងគោលការណ៍សំខាន់ៗមួយចំនួន ដូចជាៈ លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាច នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ។

រាជរដ្ឋាភិបាលបានធ្វើនូវអ្វីៗដើម្បីប្រែក្លាយដំណើរការនៃការចូលរួមយ៉ាងទូលំទូលាយ ឱ្យក្លាយទៅជាការផ្តួចផ្តើមគំនិតជាអាទិភាព និងការគៀងគរធនធានសំខាន់ៗ ។ វិស័យតុលាការនិយាយជារួម គឺផ្តោតជាសំខាន់ទៅលើអត្ថបទច្បាប់ ស្ថាប័នមនុស្ស និងដំណើរការ ដោយធ្វើយ៉ាងណារក្សាឱ្យបានតំលៃ និងគុណសម្បត្តិខាងលើ ដូច្នេះវិស័យតុលាការត្រូវគ្របដណ្តប់តាំងពីការប្រតិបត្តិ និងដំណើរការនៃការតាក់តែងច្បាប់ និងបទបញ្ញត្តិរហូតដល់ការអនុវត្តន៍ដោយមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដទៃទៀតក្នុងសង្គម ។ ការសិក្សាជាច្រើនត្រូវបានបញ្ចប់ និងធនធានសំខាន់ៗកំពុងត្រូវបានគៀងគរ ។ យន្តការនៃការគ្រប់គ្រង និងសំរបសំរួលកំពុងត្រូវបានពង្រឹង ។

នៅពេលបញ្ចប់កិច្ចប្រជុំពិគ្រោះយោបល់ខាងមុខ រាជរដ្ឋាភិបាលនឹងប្តេជ្ញាបន្តការអនុវត្តន៍យុទ្ធសាស្ត្រ និងកម្មវិធីដើម្បីជំរុញការកែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ ។ រាជរដ្ឋាភិបាលនឹងបង្កើតឱ្យមានទស្សនៈវិស័យមួយច្បាស់លាស់ប្រកបដោយគុណសម្បត្តិ និងអាទិភាពហើយនិងវិធីសាស្ត្រដើម្បីគាំទ្រអោយបានល្អប្រសើរដល់ដំណើរការកំណែទំរង់ និងត្រួតពិនិត្យអំពីវឌ្ឍនៈភាពនៃការអនុវត្តន៍ ។ កំណែទំរង់ក្នុងវិស័យនេះមានដៃគូជាច្រើនមកហើយដែលបានចូលរួម ហើយអ្នកពាក់ព័ន្ធដទៃទៀតកំពុងតែអំពាវនាវ និងស្វះស្វែងរកបន្ថែមទៀត ។

## ស្ថានភាពបច្ចុប្បន្ន

មានមូលហេតុផ្សេងៗគ្នាជាច្រើននិយាយអំពីកំណែទំរង់ច្បាប់ និងតុលាការថាមិនមានការរីកចំរើនជាទីពេញចិត្តសោះ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ជាមួយធនធានដ៏មានកំរិត ក៏មានការរីកចំរើនគួរឱ្យចាប់អារម្មណ៍ខ្លះដែរ ។

ផ្នែកច្បាប់ៈ ច្បាប់សំខាន់ៗ ជាច្រើនត្រូវបានអនុម័តឱ្យប្រើប្រាស់តាំងពីច្បាប់ថវិការហូតដល់ច្បាប់ពាក់ព័ន្ធនឹងការវិនិយោគ អាជីវកម្ម និងពាណិជ្ជកម្ម រហូតដល់ច្បាប់ភូមិបាល និងច្បាប់ស្តីពីសិទ្ធិជាមូលដ្ឋាន ។ ព្រះរាជក្រឹត្យ និងអនុក្រឹត្យមួយចំនួនត្រូវបានប្រកាសឱ្យប្រើដើម្បីគាំទ្រដល់ដំណើរការអនុវត្តន៍ឱ្យមានប្រសិទ្ធិភាព ។ ច្បាប់ភូមិបាល គឺជាសមិទ្ធផលដ៏សំខាន់ដែលបង្ហាញឱ្យឃើញពីការចូលរួមតាមលទ្ធិប្រជាធិបតេយ្យក្នុងការដោះស្រាយមូលហេតុចំបងនៃភាពក្រីក្រៈ ភាពគ្មានដីធ្លី។ ច្បាប់ពាក់ព័ន្ធទៅនឹងវិស័យសង្គម ការជួញដូរមនុស្ស និងអំពើហឹង្សាក្នុងគ្រួសារ នឹងត្រូវបានអនុម័តនៅពេលដ៏ខ្លីខាងមុខ ។ ក្រមនិងនីតិវិធីព្រហ្មទណ្ឌកំពុងត្រូវបានរៀបចំដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត និងរដ្ឋសភានៅឆ្នាំ ២០០៣ រួមជាមួយនឹងក្រម និងនីតិវិធីរដ្ឋប្បវេណីក្នុងខែបន្ទាប់ ។ ដំណើរការ និងបែបបទនៃការអនុវត្តន៍ក្នុងការតាក់តែងអត្ថបទ ច្បាប់កំពុងត្រូវបានកែសំរួលដើម្បីផ្តល់ឱកាសឱ្យមានការចូលរួម ។ ស្ថាប័នរដ្ឋរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា តុលាការ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ទាំងអស់ នឹងតម្រូវឱ្យធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធដើម្បីជំរុញឱ្យមានដំណើរការវិវឌ្ឍន៍ ។

ផ្នែកតុលាការៈ មានការរីកចំរើនសំខាន់ៗផងដែរក្នុងវិស័យកំណែទំរង់តុលាការ ។ ជាបឋមច្បាប់ស្តីពីលក្ខន្តិកៈ នៃអង្គចៅក្រមកំពុងឈានចូលដល់ដំណាក់កាលចុងក្រោយនៃការអនុម័តប្រៀវត្សរ៍សំរាប់មន្ត្រីតុលាការសំខាន់ៗ ត្រូវបានបង្កើនឱ្យស្មើនឹងកំរិតប្រៀវត្សរបស់ឧត្តមមន្ត្រីក្នុងមុខងារសាធារណៈ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកំពុងត្រូវបានពង្រឹងសមត្ថភាព ឥរិយាបទ វិន័យ និងកែលំអដំណើរការការងារ ។ សាលាភូមិន្ទចៅក្រមត្រូវបានបង្កើតឡើងដើម្បីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកក្នុងវិស័យតុលាការ ។ មេធាវី និងមន្ត្រីពង្រឹងការអនុវត្តន៍ច្បាប់កំពុងត្រូវបានបណ្តុះបណ្តាល នៅវិទ្យាស្ថានបណ្តុះបណ្តាលមេធាវី ។ ថវិកាសំរាប់តុលាការកំពុងត្រូវបានពិនិត្យឡើងវិញ ហើយនឹងផ្តាច់ចេញពីកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ នៅឆ្នាំ ២០០៣ ។ មធ្យោបាយ និងធនធានដើម្បីបង្កើនការប្រើប្រាស់សេវាសាធារណៈក្នុងវិស័យតុលាការ និងគំរោងបង្កើតតុលាការគំរូកំពុងស្ថិតក្នុងការសិក្សាអង្កេតស្រាវជ្រាវ ។ ធនធានសំខាន់ៗកំពុងត្រូវបានគៀងគរដើម្បីដាក់ឱ្យដំណើរការគំរោងពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិកក្នុងទស្សនៈជំរុញដំណើរការវិវឌ្ឍន៍ ។

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងតុលាការត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យដើម្បីដឹកនាំ និងសម្របសម្រួលការងារកំណែទំរង់វិស័យតុលាការ ។ ដូច្នេះក្រុមប្រឹក្សានេះនឹងដំណើរការដោយមានកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញរវាងអំណាចទាំង ៣ របស់រដ្ឋ និងដៃគូអភិវឌ្ឍន៍ ។

## យុទ្ធសាស្ត្រ

ក្នុងគោលបំណងនៃផែនការសកម្មភាពអភិបាលកិច្ច កំណែទំរង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានបង្កើតឡើងដើម្បីអនុវត្តឱ្យបានសំរេចនូវការងារ ២ផ្នែកសំខាន់ៗៈ (១) បញ្ចប់ឱ្យបានសព្វគ្រប់នូវការតាក់តែងច្បាប់ដើម្បីធានាដល់ការអភិវឌ្ឍន៍ដែលមានសន្ទុះយ៉ាងលឿន និងជំរុញការការពារសិទ្ធិសេរីភាព និង (២) ពង្រឹងសមត្ថភាពតុលាការដើម្បីធានាឱ្យមានតម្លាភាព និងយុត្តិធម៌សង្គមសម្រាប់មនុស្សគ្រប់រូប ។ គោលនយោបាយជាអាទិភាព និងបន្ទាន់បំផុតគឺតម្រង់ទិសដៅវិស័យតុលាការឱ្យឆ្ពោះទៅរកកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និងបញ្ចប់ការងារតាក់តែងក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ហើយនិងសម្របសម្រួលការធ្វើសមាហរណកម្មកម្ពុជាទៅកាន់សេដ្ឋកិច្ចពិភពលោក ។ ប្រតិបត្តិការជាអាទិភាព និងបន្ទាន់បំផុត គឺពង្រឹងសមត្ថភាពដើម្បីគ្រប់គ្រងការងារកំណែទំរង់ ស្វះស្វែងរកដៃគូសំខាន់ៗ និងធានាឱ្យបាននូវហិរញ្ញប្បទានដែលត្រូវការ ។

យុទ្ធសាស្ត្រ និងកម្មវិធីដែលកំពុងបង្កើតឡើង គឺត្រូវអនុវត្តឱ្យស្របទៅនឹងគោលការណ៍ដ៏មានតម្លៃដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនេះ គឺផ្តោតទៅលើគោលដៅជាបឋមចំនួន ៧ ដូចខាងក្រោមៈ

- ជំរុញកំណែទំរង់យុត្តិធម៌
- ពង្រឹងការការពារសិទ្ធិជាសារវន្តរបស់ប្រជាពលរដ្ឋកម្ពុជា
- កែលំអក្របខ័ណ្ឌច្បាប់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ
- បង្កើនការផ្សព្វផ្សាយឱ្យបានយល់ជ្រួតជ្រាប និងផ្តល់ពត៌មានឱ្យបានល្អប្រសើរ ស្តីពីច្បាប់ និងតុលាការ
- បង្កើនគុណភាពសេវាកម្មច្បាប់ និងតុលាការ
- បង្ហាញនូវជំរើស ស្តីពីយន្តការដោះស្រាយជំលោះ

- ផ្តល់ឱ្យនូវលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីធ្វើឱ្យវិស័យគតិយុត្តិ មានប្រសិទ្ធិភាព

យុទ្ធសាស្ត្រ គឺត្រូវបង្កើតឡើងដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានការចូលរួម ។ កំណែទំរង់នេះត្រូវប្រើប្រាស់រយៈពេលយូរ ប៉ុន្តែផែនការសកម្មភាពដែលកំពុងរៀបចំគឺសំរាប់អនុវត្តក្នុងរយៈពេល ៣ ឆ្នាំដំបូង រហូតដល់ឆ្នាំ ២០០៥។ ផ្នែកកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការដែលមាននៅក្នុងផែនការសកម្មភាពអភិបាលកិច្ច ដែលឥឡូវនេះកំពុងតែត្រូវបានធ្វើនឹងផ្តល់មកឱ្យនូវក្របខ័ណ្ឌការងារទិសដៅ និងសកម្មភាពដែលត្រូវអនុវត្តជាក់ស្តែង ។ ដំណាក់កាលបន្ទាប់គឺត្រូវពង្រឹងសមត្ថភាពដើម្បីធ្វើផែនការ និងគ្រប់គ្រងការងារកំណែទំរង់ហើយនិងរៀបចំការប្រជុំពិគ្រោះយោបល់ឱ្យបានទូលំទូលាយមុននឹង អនុម័តឯកសារយុទ្ធសាស្ត្រផែនការការងារ និងធានាឱ្យបាននូវហិរញ្ញប្បទានដែលត្រូវការ ។

ដូចទៅនឹងការងារកំណែទំរង់ដទៃទៀតការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច មិនទាន់អាចមានលទ្ធភាពកំណត់ឱ្យបានច្បាស់លាស់អំពីលទ្ធផលរំពឹងទុកពេលវេលា និងបរិមាណនៃការចំណាយនៅឡើយទេ គឺវាពឹងផ្អែកភាគច្រើនទៅលើដៃគូនីមួយៗ ដែលត្រូវសហការអនុវត្តការងារជាមួយគ្នា ។

គំរោងការងារ ដែលត្រូវអនុវត្តសំរាប់រយៈពេលខ្លីគេនោះ គឺៈ

- អនុវត្តកម្មវិធី និងយុទ្ធសាស្ត្រកំណែទំរង់ ដោយពិគ្រោះយោបល់ឱ្យបានទូលំទូលាយ ជាមួយដៃគូ
- ពង្រឹងស្ថាប័នសំខាន់ៗដូចជា : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ រួមទាំងការអនុម័តទៅលើលក្ខន្តិកៈនៃអង្គចៅក្រម និងក្រមសីលធម៌
- ពង្រឹងសមត្ថភាពស្ថាប័នគាំទ្រការអនុវត្តន៍ ដូចជា អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធ តុលាការ
- កំណត់បែបបទឱ្យបានច្បាស់លាស់នៃដំណើរការតាក់តែងច្បាប់ដោយមានការចូលរួម ការប្រមាណទុកជាមុន និងប្រកបដោយប្រសិទ្ធិភាព
- បញ្ចប់ការតាក់តែងច្បាប់សំខាន់ៗ និងចាំបាច់ដើម្បីបំពេញឱ្យបានសព្វគ្រប់ទៅនឹងក្របខ័ណ្ឌគតិយុត្តិ ដូចជា ក្រមនិងច្បាប់រដ្ឋប្បវេណី ច្បាប់ និងក្រមព្រហ្មទណ្ឌ ហើយនិងច្បាប់ និងបទប្បញ្ញត្តិទាក់ទងដល់ការវិនិយោគ ពាណិជ្ជ កម្ម និងជំនួញ
- ពង្រឹងយន្តការ ដើម្បីបង្កើនការប្រើប្រាស់ និងយល់ដឹងអំពីពតិមានពាក់ព័ន្ធនឹងច្បាប់ និងតុលាការ
- ពង្រឹងសមត្ថភាពអង្គតុលាការ ( ការអភិវឌ្ឍន៍ធនធានមនុស្ស ការលើកទឹកចិត្ត និងការគោរពវិន័យ)
- អនុវត្តកម្មវិធី ដែលមានការចូលរួមក្នុងទិសដៅគាំទ្រការគោរពសិទ្ធិមនុស្ស

**សកម្មភាពរយៈពេលមធ្យម នឹងត្រូវផ្តោតការយកចិត្តទុកដាក់អនុវត្តទៅលើសកម្មភាពមួយចំនួនដូចជាៈ**

- ធានាឱ្យបាននូវក្របខ័ណ្ឌគតិយុត្តិ និងយន្តការដោះស្រាយជំលោះ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ និងគោរពទៅតាមបទដ្ឋានអន្តរជាតិឱ្យបានត្រឹមត្រូវ ដូចជាអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន
- អនុវត្តក្រម និងនីតិវិធីរដ្ឋប្បវេណី ច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ
- ពង្រឹងវិស័យតុលាការ តាមរយៈការបង្កើនជំនឿទុកចិត្តពីសាធារណៈជន និងការបង្កើតឱ្យមានជំរើស ស្តីពីយន្តការដោះ

ស្រាយជំលោះ ដូចជាការិយាល័យបណ្តឹងសាធារណៈ (Ombudsman Office)

- បង្កើតតុលាការជំនាញ សំរាប់វិស័យនីមួយៗ ដូចជាៈ តុលាការពាណិជ្ជកម្ម និងតុលាការរដ្ឋបាលដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងពង្រឹងយន្តការដោះស្រាយជំលោះ
- បោះពុម្ព " សៀវភៅកំរងឯកសារច្បាប់ សំរាប់ចៅក្រម " (Bench Book) ដើម្បីធានាអំពីឱ្យមានការឯកភាពគ្នាជាទូទៅ លើការអនុវត្តន៍ច្បាប់ និងនីតិវិធី រួមទាំងការដាក់បញ្ចូលអត្ថបទច្បាប់ និងសេចក្តីសំរេចចិត្តរបស់តុលាការទៅក្នុងមូលដ្ឋានទិន្នន័យពតិមានវិទ្យា
- ធានាឱ្យមានការផ្សព្វផ្សាយ និងយល់ដឹងឱ្យបានទូលំទូលាយអំពីអត្ថបទច្បាប់ និងបទបញ្ញត្តិនានា រួមទាំងការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលចំណេះដឹងផ្នែកតុលាការ (Justice Knowledge Center)
- ពង្រឹងសមត្ថភាពនគរបាលយុត្តិធម៌
- ពង្រឹងការគ្រប់គ្រង និងធានាឯករាជ្យភាពរបស់តុលាការរួមទាំងការផ្តល់មធ្យោបាយ និងធនធានឱ្យបានគ្រប់គ្រាន់។

## ៤.៤.២ កំណែទំរង់រដ្ឋបាល និងមុខងារសាធារណៈ

លក្ខខណ្ឌដ៏ចាំបាច់ និងសំខាន់មួយទៀតដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយចីរភាព យុត្តិធម៌សង្គម និងការកាត់បន្ថយភាពក្រីក្រគឺត្រូវមានរដ្ឋបាល និងមុខងារសាធារណៈមួយមានលក្ខណៈអព្យាក្រឹត្យ តម្លាភាព ឆ្លើយតបទៅនឹងតម្រូវការទាន់ពេលវេលា មានសមត្ថភាព និងទទួលខុសត្រូវខ្ពស់ ។ កម្មវិធីជាតិកំណែទំរង់រដ្ឋបាល (NPAR) ត្រូវបានបង្កើតឡើងដើម្បីប្រែក្លាយរដ្ឋបាល និងមុខងារសាធារណៈឱ្យក្លាយទៅជាដៃគូដ៏មានអានុភាពក្នុងការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។ កម្មវិធីជាតិកំណែទំរង់រដ្ឋបាល គឺជាកម្មវិធីដែលត្រូវអនុវត្តរយៈពេលវែងក្នុងការកែទំរង់រដ្ឋបាលសាធារណៈ ស្របទៅនឹងតម្រូវការ និងធនធានរបស់ប្រទេស ។ កម្មវិធីនេះត្រូវបានបង្កើតឡើងជា ៣ ដំណាក់កាលៈ ការកសាងមូលដ្ឋានគ្រឹះ ការកែសំរួលដំណើរការការងារ និងការពង្រាយមន្ត្រីរាជការ ពង្រឹងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ គំរោងការងារទាំងនេះត្រូវអនុវត្ត ជា៤អ័ក្សៈ ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌគតិយុត្តិ អភិបាលកិច្ចល្អ និងការផ្តល់សេវា ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងបង្កើនសមត្ថភាពគ្រប់គ្រងការផ្លាស់ប្តូរ ។

ដំណាក់កាលទី១ នៃកម្មវិធីត្រូវបានបញ្ចប់តាមគោលដៅនៃការអនុវត្តន៍ ហើយសំរេចបានលទ្ធផលជាមូលដ្ឋានគ្រឹះ ៥ យ៉ាងសំខាន់ៗគឺ : រៀបចំឯកសារ និងត្រួតពិនិត្យទំហំ និងចំនួនក្របខ័ណ្ឌមន្ត្រីរាជការបង្កើតឧបករណ៍សំខាន់ៗសំរាប់គ្រប់គ្រង និងលើកទឹកចិត្តមន្ត្រីរាជការ វាយតម្លៃអំពីសេចក្តីត្រូវការរបស់ក្រសួងស្ថាប័នពាក់ព័ន្ធទៅនឹងសេវាកម្មផ្នែកទ្រទ្រង់ បញ្ចប់ការរៀបចំការងារ និងឯកសារដើម្បីបង្វិតរដ្ឋបាលសាធារណៈឱ្យទៅជិតនឹងប្រជាពលរដ្ឋ និង ពង្រឹងសមត្ថភាពក្នុងការធ្វើផែនការ និងគ្រប់គ្រងការងារកំណែទំរង់ ។

នាពេលបច្ចុប្បន្ននេះមូលដ្ឋានគ្រឹះទាំងនេះត្រូវបានបង្កើតឡើង ហើយដល់ពេលវេលាដែលត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការប្រែក្លាយរដ្ឋបាល និងមុខងារសាធារណៈឱ្យមានលក្ខណៈសមស្របទៅនឹងតម្រូវការ និងធនធានរបស់ប្រទេស។ តម្រូវការគឺមានពិតប្រាកដជាក់ច្បាស់ ដូចជាៈ ទីកន្លែង និងពេលវេលានៃការផ្តល់សេវាប្រកបដោយគុណភាព និងប្រសិទ្ធិភាពនៃ

ការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិដែលជាមូលដ្ឋានគ្រឹះនៃការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សង្គម ។ មធ្យោបាយក៏មានពិតប្រាកដជាក់ស្តែងដែរដោយរូមានរដ្ឋបាលសាធារណៈដែលនៅជិតនឹងប្រជាពលរដ្ឋ និងមានប្រសិទ្ធភាពទទួលខុសត្រូវខ្ពស់ប្រកបដោយតម្លាភាព ។

លើសពីនេះទៅទៀតរដ្ឋបាល និងមុខងារសាធារណៈ គឺត្រូវមានមន្ត្រីរាជការ ស្ថាប័ន ដែលមានសមត្ថភាព និងយល់ដឹងពីគោលបំណងច្បាស់ពីសម្ភារៈ ឧបករណ៍ និងធនធានគ្រប់គ្រាន់សំរាប់អនុវត្តការងាររបស់ខ្លួន និងជាពិសេសប្រតិបត្តិ ការងារក្នុងបរិយាកាសមួយដែលអាចនាំឆ្ពោះទៅរកការបង្កើនផលិតភាព និងវិជ្ជាជីវៈដោយគោរពតាមគោលការណ៍អភិបាលកិច្ចល្អ ។ គោលដៅចម្បងគឺត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើគុណភាព ទីកន្លែង និងពេលវេលាកំណត់ក្នុងការផ្តល់សេវាសាធារណៈតាមតម្រូវការរបស់ប្រជាពលរដ្ឋ ហើយនិងពង្រឹងការដំណើរការការងារជាប្រក្រតីរបស់ស្ថាប័ន និងបង្កើនសមត្ថភាពមន្ត្រីរាជការតាមរយៈកំណែទំរង់បៀវត្ស និងនិយោជន៍ ។ ដើម្បីសំរេចឱ្យបាននូវគោលដៅកំណែទំរង់ខាងលើចាំបាច់ត្រូវមានការប្រើប្រាស់ឧបករណ៍ប្រកបដោយប្រសិទ្ធិភាព និងបែបបទនៃការអនុវត្តន៍ដ៏ប្រពៃដើម្បីធានាអំពីភាពម្ចាស់ការ និងនិរន្តរភាព ។ កម្មវិធីបច្ចេកវិទ្យាពត៌-មានដើម្បីសំរួលការផ្តល់សេវាសាធារណៈ នីតិវិធី និងដំណើរការរដ្ឋបាល ហើយនិងពង្រឹងការទំនាក់ទំនងសមត្ថភាព គឺជាកម្មវិធីមួយដ៏សំខាន់ត្រូវបំពេញបន្ថែមទៅលើគំរោងវិភាគមុខងារ និងប្រតិបត្តិការដែលគំរោងនេះ គឺជាចំណុចគន្លឹះសំរាប់ជំរុញការងារកំណែទំរង់បៀវត្ស និងនិយោជន៍ ។

កំណែទំរង់រដ្ឋបាល និងមុខងារសាធារណៈ បាននឹងកំពុងជួបប្រទះបញ្ហាប្រឈមជាច្រើនគួរឱ្យព្រួយបារម្ភដោយហេតុថាមុខងារសាធារណៈបច្ចុប្បន្នគឺជាលទ្ធផលដែលកើតចេញមកពីការធ្វើសមាហរណកម្មពីគ្រប់កំលាំងភាគីនយោបាយ ហើយកំពុងតែជួបប្រទះនូវកង្វះខាតមធ្យោបាយ ធនធាន និងសមត្ថភាព ។ តាមគំរោងចំណាយសំរាប់រយៈពេលមធ្យម និងច្បាប់សារពើពន្ធគឺមិនបានផ្តល់ឱកាស និងលទ្ធភាពឱ្យបានទូលំទូលាយសំរាប់ធានានូវនិរន្តរភាពការងារ ប្រសិនបើគ្មានជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ចាប់តាំងពីគ្រាដំបូងមក ។ ការងារកំណែទំរង់ដែលបានគ្រោងឡើងនេះ នឹងត្រូវការនូវពតិមានសំខាន់ៗចាំបាច់ដើម្បីធ្វើការសំរេចចិត្តផ្នែកនយោបាយដ៏ប្រសើបក្នុងការជ្រើសរើសយកយុទ្ធសាស្ត្រណាមួយមកអនុវត្ត ។ សមត្ថភាពមន្ត្រីរាជការចាំបាច់ត្រូវតែពង្រឹង ហើយការអភិវឌ្ឍន៍ធនធានមនុស្សត្រូវដាក់ឱ្យដំណើរការជាបន្ទាន់ ។ ការអនុវត្តន៍កម្មវិធីការងារនឹងជួបប្រទះបញ្ហាជាច្រើនជាឧទាហរណ៍ៈ ដើម្បីរក្សាឱ្យបាននូវចំនួនមន្ត្រីរាជការក្នុងមុខងារសាធារណៈ ឱ្យនៅកំរិតដដែល គឺត្រូវការនូវការផ្តល់ថវិកា ធនធានដ៏ច្រើនសន្ធឹកសន្ធាប់ទៅឱ្យវិស័យអប់រំ និងសុខាភិបាល និងពីរដ្ឋបាលកណ្តាលទៅថ្នាក់មូលដ្ឋាន ។

ជាពិសេសបញ្ហាប្រឈមដ៏ពិបាក គឺកើតមាននៅពេលតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការឱ្យដល់កំរិតមួយដែលមានលក្ខណៈលើកទឹកចិត្ត និងអាចផ្គត់ផ្គង់ជីវភាពរស់នៅបាន ។ ផ្អែកតាមតារាងសន្ទស្សន៍បៀវត្សបច្ចុប្បន្ន（Simulation）បង្ហាញឱ្យឃើញថាដើម្បីតម្លើងប្រាក់បៀវត្សកំរិតអប្បរមាក្នុងមុខងារសាធារណៈឱ្យស្មើនឹងកំរិតនៃផ្នែកឯកជន ឧទាហរណ៍ រោងចក្រកាត់ដេរគឺតម្រូវឱ្យផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជា（Cambodia's GDP）ចាំបាច់ត្រូវមានកំណើនមួយយ៉ាងខ្ពស់បំផុតតាមរយៈជំរើសតែមួយគត់ក្នុងការធ្វើហិរញ្ញប្បទានទៅលើថវិការដ្ឋ ។ ផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជាទៀតសោធក៏មានកំរិតផងដែរ និងត្រូវការនូវជំនួយឧបត្ថម្ភពីដៃគូសំរាប់រយៈពេលវែង និងការប្តេជ្ញាចិត្តដ៏មុតមាំក្នុងការផ្តល់ធនធានឱ្យបានច្រើនលើសពីកំរិតនៃច្បាប់សារពើពន្ធទៅទៀត ។ ទោះបីជាក្នុងតារាងសន្ទស្សន៍បៀវត្សបានសន្និដ្ឋានជាដំបូងថាកំណើន

នៃផ.ស.ស របស់ប្រទេសកម្ពុជានឹងកើនឡើងត្រឹមតែ ៦%ប៉ុណ្ណោះ ក្នុងមួយឆ្នាំរហូតដល់ឆ្នាំ ២០០៦ ។ តាមតារាងសន្ទស្សន៍បៀវត្សនេះចំនួនភាគច្រើននៃមន្ត្រីរាជការនៅតាមខេត្ត និងជនបទនឹងត្រូវទទួលបានកំរិតបៀវត្សមួយសមស្របសំរាប់ជីវភាពរបស់ខ្លួន ។ មន្ត្រីថ្នាក់គ្រប់គ្រងនៅតាមក្រសួង ខេត្ត ស្រុក មន្ត្រីជំនាញកន្សោមអាទិភាព គ្រូបង្រៀន មន្ត្រីសុខាភិបាលនឹងទទួលបានបៀវត្សមួយសមរម្យ ហើយប្រាក់បំណាច់ផ្សេងៗ នឹងផ្តល់ជូនមន្ត្រីរាជការដែលធ្វើការងារនៅតំបន់ដាច់ស្រយាល និងបំពេញការងារលំបាក ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលមានឆន្ទៈយ៉ាងមោះមុតក្នុងការធ្វើអ្វីៗទាំងអស់ដែលអាចធ្វើទៅបានដើម្បីធានាឱ្យបាននូវនិរន្តរភាពក្នុងការជំរុញកំណែទំរង់បៀវត្ស និងនិយោជន៏ ។

ការងារទាំងនេះអាចដំណើរការទៅបានលុះត្រាតែមានកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធរវាងក្រសួង និងដៃគូខាងក្រៅ ក្រសួងសំខាន់ៗមួយចំនួនបាននឹងកំពុងដំណើរការកំណែទំរង់របស់ខ្លួន ទាំងក្នុងស្ថាប័ន និងការផ្តល់សេវា ។ ដោយផ្អែកទៅលើវិឌ្ឍនៈភាពនៃការងារ និងការប្រមូលផ្តុំកំលាំងសរុបរួម អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលកំពុងតែបញ្ចប់ឯកសារស្តីពីការសំរបសំរួលភាពជាដៃគូ ដែលនឹងបង្កើតចេញជាសកម្មភាពជាក់ស្តែង និងយន្តការនៃការផ្តល់ជំនួយ ។

## ស្ថានភាពបច្ចុប្បន្ន

កំណែទំរង់រដ្ឋបាលកំពុងតែទទួលបានជោគជ័យយ៉ាងធំធេងក្នុងកំឡុងពេល ២ ឆ្នាំចុងក្រោយនេះ លើការបញ្ចប់ដំណាក់កាលទី១នៃកម្មវិធីជាតិកំណែទំរង់រដ្ឋបាល ។ សមាសភាព និងចំនួនមន្ត្រីរាជការត្រូវក្តាប់បាន និងស្ថិតនៅក្រោមការត្រួតពិនិត្យ ។ មន្ត្រីរាជការមិនប្រក្រតីចំនួន ៩០០០ នាក់ ត្រូវបានលុបឈ្មោះចេញពីតារាងបៀវត្ស ។ យន្តការសំរាប់ត្រួតពិនិត្យមន្ត្រីរាជការត្រូវបានដាក់ឱ្យដំណើរការ ។ រាជរដ្ឋាភិបាលបានអនុម័តទៅលើឯកសារស្តីពីយុទ្ធសាស្ត្រសនិទានកម្ម មុខងារសាធារណៈ ហើយនិងការអនុវត្តន៏ជាដំបូងគេនូវគំរោង ៣ សំខាន់ៗ ។ បែបបទសំខាន់ៗ នៃប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមពតិមានវិទ្យាដូចជាការត្រួតពិនិត្យ និងការបើកបៀវត្ស ត្រូវបានដាក់ឱ្យដំណើរការ ។ ប្រព័ន្ធចំណាត់ថ្នាក់ និងប្រព័ន្ធលាភការថ្មី ដែលមានលក្ខណៈលើកទឹកចិត្ត និងបង្កើនវិជ្ជាជីវៈ ត្រូវបានដាក់ឱ្យដំណើរការ ។ កម្មវិធីកន្សោមអាទិភាពកំពុងតែអនុវត្តដោយប្រុងប្រយ័ត្នបំផុតដើម្បីគាំទ្រដល់ដំណើរកំណែទំរង់ និងការបង្កើនការផ្តល់សេវាសាធារណៈ ។ គំរោងសំរាប់ពង្រឹងសមត្ថភាពគ្រប់គ្រងមុខងារសាធារណៈ និងមុខងារសំខាន់ៗជាយុទ្ធសាស្ត្រត្រូវបានរៀបចំរួចជាស្រេចត្រៀមសំរាប់ដាក់ឱ្យអនុវត្ត ។ ការសិក្សាមួយចំនួនបាននឹងកំពុងចាប់ផ្តើមអនុវត្តន៏ដើម្បីបំពេញបន្ថែមលើការបង្កើតគំរោងការងារកំណែទំរង់សំរាប់ដំណាក់កាលបន្ទាប់ និងត្រៀមរៀបចំសំរាប់អនុវត្ត (ជាពិសេស គឺកំណែទំរង់បៀវត្ស និយោជន៏ និងការពង្រឹងសមត្ថភាព) ។

**សមិទ្ធផលសំខាន់ៗ ដែលសំរេចបានមានដូចខាងក្រោមៈ**

- ប្រព័ន្ធចំណាត់ថ្នាក់ថ្មីគឺត្រូវបានដាក់ឱ្យដំណើរការទាំងស្រុង ។ លក្ខន្តិកៈដោយឡែកសំរាប់ក្រសួងស្ថាប័នទាំងអស់បានរៀបចំរួចហើយ និងបានដាក់ឱ្យអនុវត្តនូវអនុក្រឹត្យស្តីពីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងស្ថាប័ន។ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងសៀវភៅស្តីពីកាតព្វកិច្ចមន្ត្រីរាជការបានបង្កើតជាក្របខ័ណ្ឌគតិយុត្តិមួយសមស្រប ។ ក្នុងផែនការសកម្មភាពអភិបាលកិច្ច ក្រមសីលធមិ ត្រូវបានចាត់ទុកជាគំរោងសកម្មភាពដែលត្រូវអនុវត្តក្នុងរយៈពេលខ្លី ។

- ចាប់តាំងពីឆ្នាំ ២០០២ ប្រាក់បៀវត្សជាមធ្យមបានកើនឡើងជាង ៤៤% ហើយសំរាប់មុខតំណែងមួយចំនួនត្រូវបានកើនឡើងទ្វេរដងទៀតផង ។ ការតម្លើងប្រាក់បៀវត្សនេះ ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃច្បាប់ថវិកាជាតិ និងកំពុងត្រូវបានធ្វើហិរញ្ញប្បទានដោយថវិកាដែលសន្សំបានមកពីការពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកញ្ចប់ថវិកាជំពូក ១០ ។ រាជរដ្ឋាភិបាលកំពុងចាប់ផ្តើមអនុវត្តនូវចំណុចគន្លឹះសំខាន់ៗ ដើម្បីជំរុញការប្រតិបត្តិការងារហើយនឹងត្រូវបង្កើនប្រសិទ្ធភាពឱ្យខ្លាំងថែមទៀតនៅពេលខាងមុខ។ បៀវត្សមូលដ្ឋានដែលផ្អែកលើគោលការណ៍ក្របខ័ណ្ឌកំពុងត្រូវបានបំពេញបន្ថែមដោយប្រាក់បំណាច់មុខងារផ្សេងៗដូចជា ប្រាក់ តំបន់ ប្រាក់ហានិភ័យ និងប្រាក់សុខាភាព ។ ប្រាក់បំណាច់មុខងារពិសេសត្រូវបានផ្តល់ជូនបុគ្គលិកសិក្សា សុខាភិបាល និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់រហូតដល់អភិបាលស្រុក-ខ័ណ្ឌ ។
- កម្មវិធីកន្សោមអាទិភាពត្រូវបានរៀបចំរួចហើយត្រៀមសំរាប់ដាក់ឱ្យដំណើរការនៅដើមឆ្នាំ ២០០៣ ខាងមុខនេះតាមរយៈអនុក្រឹត្យលេខ ៨៣ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ។ យន្តការសំរាប់គ្រប់គ្រងដំណើរការ និងហិរញ្ញវត្ថុកំពុងរៀបចំដាក់ឱ្យដំណើរការដោយមានកិច្ចសហការពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួង និងក្រុមប្រឹក្សាពាក់ព័ន្ធ ។ កន្សោមអាទិភាពដំបូងគេ នឹងផ្តល់ទៅឱ្យមន្ត្រីរាជការដែលកំពុងបំពេញការងារកំណែទំរង់ ។
- ការកសាង និងដំណើរការប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធពតិមានវិទ្យាកំពុងមានការវិវឌ្ឍទៅមុខយ៉ាងល្អដូចជា: ការបើកបៀវត្សតាមប្រព័ន្ធពតិមានវិទ្យាត្រូវបានអនុវត្តទូទាំងប្រទេស, ការកំណត់មុខតំណែង (ពីអគ្គនាយករហូតដល់ការិយាល័យ) ឋានន្តរស័ក្តិ និងកាំប្រាក់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត, តារាងបៀវត្ស ត្រូវបានបោះពុម្ពផ្សាយជាស្វ័យប្រវត្តិ, កំពុងបន្តការពិភាក្សាជាមួយផ្នែកអប់រំ និងសុខាភិបាលដើម្បីបង្កើតមូលដ្ឋានទិន្នន័យមួយដែលមានអត្ថប្រយោជន៍ និងងាយស្រួលប្រើប្រាស់សំរាប់វិស័យទាំង ២នេះ, បានបញ្ចប់ការផ្លាស់ប្តូរពីប្រព័ន្ធចាស់មកប្រព័ន្ធថ្មី (Migration to a Window-based platform) ហើយនិងបន្តការកែលំអបន្តិចម្តងៗទៅតាមលទ្ធភាព ។ ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធពតិមានវិទ្យានេះសង្ឃឹមថានឹងផ្តល់ ទៅឱ្យក្រសួងប្រើប្រាស់នៅក្នុងឆ្នាំ ២០០៤ ខាងមុខ ខណៈពេលដែលក្រសួង និងស្ថាប័នទាំងនោះមានសមត្ថភាពគ្រប់ គ្រាន់ក្នុងការប្រើប្រាស់ប្រព័ន្ធនេះបាន ។ ការងារជាអាទិភាពរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល គឺត្រូវបង្កើតគំរោង ជាក់ស្តែងមួយដើម្បីដឹកនាំ និងគ្រប់គ្រងការងារទាំងនេះក្នុងទិសដៅគាំទ្រដល់កំណែទំរង់បៀវត្ស និងនិយោជន៍ ។
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងដៃគូររបស់ខ្លួនបាននឹងកំពុងរៀបចំកម្មវិធីសិក្សា ដែលនឹងត្រូវបញ្ចប់នៅ ខែសីហា ឆ្នាំ ២០០៣ ខាងមុខនេះដើម្បីការអង្កេតស្រាវជ្រាវអំពីធនធាន និងមធ្យោបាយដែលមានក្នុងការជំរុញកំណែទំរង់បៀវត្ស និងនិយោជន៍ ។ ការងារវិសហមជ្ឈការ និងដំណើរការនៃការផ្តល់សេវាកំពុងត្រូវបានដំណើរការ ។ ការពិនិត្យអំពីប្រតិបត្តិការរបស់អង្គភាពទ្រទ្រង់ និងអង្គភាពឈានមុខកំពុងត្រូវបានបញ្ចប់ និងត្រៀមសំរាប់ដាក់ឱ្យដំណើរការ ។ វិធីសាស្រ្តសំរាប់បង្កើនដំណើរការផលិតកម្មកំពុងត្រូវបានរៀបចំបញ្ចប់ ដើម្បីបំពេញបន្ថែមទៅលើការវិភាគមុខងារ ។ ការពិគ្រោះយោបល់កំពុងតែប្រព្រឹត្តទៅជាមួយក្រសួងអាទិភាពសំខាន់ៗ (ដូចជា: អប់រំ

សុខាភិបាល និងយុត្តិធម៌) ។

- ជាឧទាហរណ៍ ការសិក្សាមួយចំនួនកំពុងតែដំណើរការ ឬក៏រៀបចំដាក់ឱ្យដំណើរការជាបន្ទាន់ដូចជា ការសិក្សាស្តីពីកម្មវិធី និងគោលនយោបាយក្នុងការផ្តល់សេវា, កម្មវិធី និងគោលនយោបាយស្តីពីប្រព័ន្ធលាភការ, ស្តីពីការវិភាគលើដំណើរការការងារ, ស្តីពីយន្តការពង្រាយមន្ត្រីរាជការ និងការពង្រឹងសមត្ថភាព ។ ការវិភាគលើដំណើរការការងារទាំងនេះកំពុងតែអនុវត្តដើម្បីទាញយកផលប្រយោជន៍ នៃលទ្ធផលនេះទៅជួយបំពេញបន្ថែមជាជំហានដំបូងលើការងារដែលកំពុងតែដំណើរការក្នុងក្រសួងសុខាភិបាល អប់រំ និងយុត្តិធម៌ ។ ទោះបីយ៉ាងណាក៏ដោយ ជំនួយឧបត្ថម្ភគឺជាតម្រូវការដ៏សំខាន់ និងបន្ទាន់សំរាប់ជួយដល់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់ឱ្យបំពេញ ការងាររបស់ខ្លួនទាន់ពេលវេលាកំណត់ពាក់កណ្តាលឆ្នាំ ២០០៣ ។

## យុទ្ធសាស្ត្រ

ចាប់តាំងពីឆ្នាំ ១៩៩៨ មករាជរដ្ឋាភិបាលបានធ្វើការប្តេជ្ញាចិត្តក្នុងការជំរុញវិស័យឯកជន ឱ្យក្លាយជាក្បាលម៉ាស៊ីននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយសហការជាមួយស្ថាប័នសាធារណៈរបស់រដ្ឋដែលជាយុទ្ធសាស្ត្រវិទូជាដៃគូ និងជាអ្នកសម្របសម្រួល ។ រាជរដ្ឋាភិបាលកម្ពុជាបានបើកចំហរទ្វារឆ្ពោះទៅកាន់សេដ្ឋកិច្ចក្នុងតំបន់អាស៊ីអាគ្នេយ៍ និងពិភពលោក។ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់លើការលើកកំពស់កំរិតជីវភាពរបស់ប្រជាជនតាមរយៈការផ្តល់ឱ្យនូវសេវាជាមូលដ្ឋាននានាដូចជាក្នុងវិស័យៈ សុខាភិបាល អប់រំ កសិកម្ម និងលើសពីនេះទៀតគឺការអភិវឌ្ឍន៍ជនបទ ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្តារឡើងវិញឱ្យបានល្អប្រសើរនូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធ ពង្រឹងស្ថាប័នសាធារណៈ និងការអនុវត្តន៍តាមគោលការណ៍អភិបាលកិច្ចល្អ ។

កំណែទំរង់រដ្ឋបាលបានធ្វើឱ្យវិស័យទាំងនេះមានការរីកចំរើន និងផ្លាស់ប្តូរមុខមាត់ថ្មី ប៉ុន្តែកំណែទំរង់របៀបនេះគឺត្រូវប្រើប្រាស់រយៈពេលយូរ និងត្រូវបន្តដំណើរការអនុវត្តន៍ជាប់ជានិច្ចទោះបីស្ថិតក្នុងកាលទេសៈអំណោយផលយ៉ាងណាក៏ដោយ ។ កាលពីកិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅទីក្រុងភ្នំពេញ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានចែកផ្សាយនូវឯកសារស្តីពីលទ្ធផលរំពឹងទុកក្នុងការអនុវត្តន៍យុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈ (២០០២-២០០៦) ហើយឥឡូវនេះកំពុងត្រូវបានកែលំអ ។ លើសពីនេះទៅទៀតដើម្បីបញ្ចប់ការងារដែលកំពុងដំណើរការផែនការការងាររបស់អគ្គលេខាធិការដ្ឋាន ផ្តោតជាសំខាន់ទៅលើការកសាងនិងអនុវត្តគំរោងការងារនៅដំណាក់ទី ២ និងទី៣ របស់ខ្លួន ។ គោលនយោបាយ និងកម្មវិធីដែលនឹងត្រូវបង្កើតក្នុងប៉ុន្មានខែខាងមុខនេះ នឹងគ្របដណ្តប់លើគំរោងការងារមួយចំនួន ដូចជាកំណែទំរង់បៀវត្ស, វិសហមជ្ឈការសេវាសាធារណៈ, ការអភិវឌ្ឍន៍ធនធានមនុស្ស, ការបង្កើនប្រសិទ្ធភាពដំណើរការការងារក្នុងវិស័យរដ្ឋបាល និងបង្កើតយន្តការ ដើម្បីសម្របសម្រួល និងកែតំរូវការផ្លាស់ប្តូរផ្សេងៗ ។ គំរោងដើម្បីពង្រឹងសមត្ថភាពមុខងារសាធារណៈលើការគ្រប់គ្រង និងផែនការកម្មនឹងចាប់ផ្តើមដំណើរការក្នុងប៉ុន្មានខែខាងមុខ ។ លេខកូដសំរាប់អក្សរខ្មែរកំពុងបង្កើតចេញជាស្តង់ដារដើម្បីពង្រីកលទ្ធភាពលើការប្រើប្រាស់ប្រព័ន្ធតភ្ជាប់ជាមួយគ្នា និងមូលដ្ឋានទិន្នន័យ ។

**កំណែទម្រង់បៀវត្ស**

កំណែទម្រង់បៀវត្សជាចំណុចស្នូលក្នុងយុទ្ធសាស្ត្រសន្និទាននកម្មមុខងារសាធារណៈ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល កាលពីខែ តុលា ឆ្នាំ ២០០១ ក្រោយពេលបញ្ចប់ការពិគ្រោះយោបល់ ។ រាជរដ្ឋាភិបាលបានចាត់ទុកថា កំណែទម្រង់បៀវត្ស និងនយោជន៍ គឺជាការងារអាទិភាពបំផុតក្នុងកំណែទម្រង់រដ្ឋបាល ។ សកម្មភាពដំបូងគេត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយរាជរដ្ឋាភិបាលដើម្បីបង្កើតបរិយាកាសមួយអំណោយផលដល់ការបង្កើនផលិតភាព និងការបំពេញការងារជាក់ស្តែង ដូចជាការតម្លើងប្រាក់បៀវត្ស មិនត្រឹមតែប្រើឱ្យអស់លទ្ធភាពនូវធនធានដែលមានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានតំរង់ទិសទៅរកការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់មន្ត្រីថ្នាក់គ្រប់គ្រងមន្ត្រីបំពេញបេសកកម្មការងារជាយុទ្ធសាស្ត្រ បុគ្គលិកសិក្សាសុខាភិបាល និងមន្ត្រីរាជការជាច្រើនដែលកំពុងបំពេញការងារនៅតាមជនបទ និងតំបន់ទីដាច់ស្រយាល ។ គោលនយោបាយទូទៅរបស់រាជរដ្ឋាភិបាលលើការងារកំណែទម្រង់បៀវត្ស គឺត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃច្បាប់សារពើពន្ធ ដែលជាមធ្យមសេដ្ឋកិច្ចជាតិមានកំណើន ៦% ក្នុងមួយឆ្នាំហើយកញ្ចប់ថវិកាសំរាប់បៀវត្សក្នុងជំពូក ១០ គឺមិនលើសពី ៤០ % នៃចំណាយចរន្ត ។ ទាំងនេះគឺជាព្រំដែនកំណត់នៃធនធានដែលមានក្នុងប្រទេសកម្ពុជា ។ តាមយុទ្ធសាស្ត្រនេះប្រាក់បៀវត្ស នឹងត្រូវកើន ឡើងជាមធ្យមដល់កំរិត ៥១.៥ ដុល្លាក្នុងមួយខែក្នុងឆ្នាំ ២០០៦ ប្រសិនបើថវិកាជាតិអាចទ្រទ្រង់បាន ។ ការពិតបៀវត្សជាមធ្យមរបស់មន្ត្រីរាជការបានកើនឡើងរួចទៅហើយពី ១៩.៥ ដុល្លា ក្នុងមួយខែ ក្នុងខែ តុលា ឆ្នាំ ២០០១ ទៅដល់ ២៦.៩ ដុល្លា ក្នុងមួយខែ ក្នុងខែ មករា ឆ្នាំ ២០០២ (បានកើនឡើងកំរិត ៣៧.៩%) និងទៅដល់ ២៨.១ ដុល្លាក្នុងមួយខែ ក្នុងខែ ឧសភា ឆ្នាំ ២០០២ (បានកើនឡើងកំរិត ៤៤.៣% ប្រៀបធៀបនឹងខែ តុលា ឆ្នាំ ២០០១) ។ ដូច្នេះ ការកើនឡើងនេះ គឺវាឆ្លើយតបទៅនឹងគោលដៅនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាល បានពុះពារក្នុងការធ្វើអ្វីៗដែលអាចមានលទ្ធភាពធ្វើទៅបានក្នុងកញ្ចប់ថវិកាមួយដ៏មានកំរិតបំផុត ។ ប៉ុន្តែរាជរដ្ឋាភិបាល បានទទួលស្គាល់ថាការតម្លើងបៀវត្សឱ្យដល់កំរិតមួយសមស្របគឺជាគោលដៅចុងក្រោយបំផុតនៃកំណែទម្រង់រដ្ឋបាលនាពេលអនាគតដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឱ្យក្លាយជាអ្នកផ្តល់សេវាមួយប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងជាដៃគូនៃការអភិវឌ្ឍន៍ដ៏គួរឱ្យជឿទុកចិត្តបាន ។ រាជរដ្ឋាភិបាលកំពុងតែធ្វើការស៊ើបអង្កេតអំពីមធ្យោបាយ និងធនធាន ដើម្បីជំរុញការងារកំណែទម្រង់បៀវត្សក្នុងក្របខ័ណ្ឌនៃការធានាស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងសារពើពន្ធឱ្យបានល្អ និង ប្រកបដោយចីរភាព ។ តម្រូវការដើម្បីធានាការដំណើរការ និងការទំនាក់ទំនងរវាងស្ថាប័នរដ្ឋទាំងអស់គឺជាបញ្ហាដ៏ចំបងមួយក្នុងការតម្លើងបៀវត្សក្នុងមុខងារសាធារណៈ ដូច្នេះ គឺតម្រូវឱ្យមានការធ្វើ ការសំរេចចិត្តមួយដ៏លំបាកមួយក្នុងការ ជ្រើសរើសយកជំរើសណាមួយមកអនុវត្ត ។

មជ្ឈដ្ឋានទូទៅបានយល់ឃើញថាបៀវត្សសមស្រប និងមានការលើកទឹកចិត្ត គឺជាលក្ខខណ្ឌដ៏ចាំបាច់មួយ ដើម្បីធ្វើឱ្យរដ្ឋបាលសាធារណៈក្លាយជាដៃគូដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងការផ្តល់សេវាសាធារណៈ ។ ទស្សនៈដែលបានលើកឡើងនេះក៏នៅតែមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ គឺចាំបាច់ត្រូវតែមានការអនុវត្តន៍ជាបណ្តើរៗថែមទៀតដោយប្រុងប្រយ័ត្នបំផុតជាមួយនឹងវិធានការជំរុញការអនុវត្តន៍ការងារ ឧទាហរណ៍ដូចជាការបើកបៀវត្សឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។ ក្តីសង្ឃឹមនឹងអាចក្លាយជាលទ្ធផលជាក់ស្តែងបាន លុះត្រាតែមានការគ្រប់គ្រងពេលវេលាឱ្យបានច្បាស់លាស់ និងដោយយកចិត្តទុកដាក់បំផុត ។ ជារួមរាជរដ្ឋាភិបាលមិនចង់បន្សល់ទុកនូវមរតកប្រកបដោយការទទួលខុសត្រូវ យ៉ាងធ្ងន់ធ្ងរទៅដល់ប្រជាពលរដ្ឋជំនាន់ក្រោយហើយក៏តែមិនចង់ប្រឈមនឹងភាពប្រថុយប្រថាននៃទង្វើដែលអាចនាំឱ្យមាន អស្ថិរភាពក្នុងសង្គមថែមទៀតទេ ។

បើផ្អែកលើគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងសេដ្ឋកិច្ចទីផ្សារ រាជរដ្ឋាភិបាល មិនអាចកំណត់យកគោលនយោបាយនៃកំណែប្រែវត្សសំរាប់តែកែលំអដំណើរការការងាររដ្ឋបាល ដូចមតិរបស់ដៃគូខាងក្រៅបានលើកឡើងក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ប៉ុណ្ណោះទេ បទវិន័យនៅលើទីផ្សារ គឺជាកត្តាមួយផ្សេងទៀតនៃការសំរេចជោគជ័យរបស់ខ្លួន ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលកំពុងអនុញ្ញាតឱ្យមានការសិក្សា អំពីតម្រូវការកំលាំងពលកម្មនៅលើទីផ្សាររៀបចំឯកសារស្តីពីតម្រូវការ និងចំនួនមន្ត្រីរាជការ ឯកសារសំរាប់ប្រតិបត្តិ និងវិធានការកែតំរូវ ។ ការសិក្សានេះនឹងរួមចំណែកជាមួយការសិក្សាដទៃទៀត ដើម្បីកំណត់ពីជំរើសក្នុងការបង្កើនល្បឿនកំណែទំរង់ប្រែវត្ស និងនិយោជន៍ ។

## យុទ្ធសាស្ត្រ

ស្ថិតក្រោមយុត្តាធិការរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ដែលដឹកនាំដោយសម្តេច នាយករដ្ឋមន្ត្រី ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានដឹកនាំ និងឈានមុខគេលើការងារកំណែទំរង់រដ្ឋបាល ។ បេសកកម្មស្នូលរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល គឺធ្វើជាកាតាលីករ អ្នករៀបចំ និងសម្របសម្រួល ។ ក្រុមប្រឹក្សានេះ មានអគ្គលេខាធិការដ្ឋានមួយធ្វើជាសេនាធិការដែលត្រូវបានជួយបំពេញការងារដោយក្រុមការងារអន្តរក្រសួងទទួលខុសត្រូវលើការអនុវត្តន៏គំរោងនានាដើម្បីពង្រឹងភាពម្ចាស់ការ និងផ្តោតការយកចិត្តទុកដាក់លើការសម្របសម្រួលឱ្យបានល្អប្រសើរ ។

យុទ្ធសាស្ត្រសទិទានកម្មមុខងារសាធារណៈគ្របដណ្តប់លើការងារមួយចំនួនដូចជាចំនួន សមាសភាព ការពង្រាយ និងប្រាក់បំណាច់របស់មន្ត្រីរាជការ ។ ទំហំការងារទាំងនេះនឹងអាចកំណត់បាននៅពេលដែលការសិក្សាត្រូវបានបញ្ចប់ ។ ការសិក្សាស្តីពីពលកម្មការងារទីផ្សារ និងការផ្តល់សេវា (រួមទាំងកម្មវិធីវិសហមជ្ឈការ និងការប្រើប្រាស់ក្នុងផ្តល់សេវា) គឺជាតម្រូវការដំបូងគេបំផុតមិនអាចខ្វះបាន សំរាប់ចាប់ផ្តើមធ្វើសិក្សាវិភាគអំពីដំណើរការការងាររបស់ក្រសួង ស្ថាប័ន និងបង្កើតគោលនយោបាយមួយសំរាប់ប្រាក់ប្រែវត្សដែលមានលក្ខណៈចិរភាព ។ ការងារសំខាន់ៗដទៃទៀត គឺមានការពាក់ព័ន្ធនឹងការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធីដើម្បីពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស ។

សកម្មភាពរយៈពេលខ្លី រាជរដ្ឋាភិបាល នឹងផ្តោតទិសដៅទៅលើៈ

- ថែរក្សាសមិទ្ធផលដែលសំរេចបានក្នុងការបង្កើតជាមូលដ្ឋានគ្រឹះសំរាប់កំណែទំរង់រដ្ឋបាល ជាពិសេសឧបករណ៍សំរាប់គ្រប់គ្រង និងត្រួតពិនិត្យមន្ត្រីរាជការ (HRMIS) និងយន្តការបង្កើនការលើកទឹកចិត្ត ដូចជាកំណែទំរង់ប្រែវត្ស និងនិយោជន៍
- ដាក់ឱ្យដំណើរការកន្សោមអាទិភាព ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងដៃគូខាងក្រៅ
- បង្កើតគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈដោយកំណត់អំពីបែបបទ និងតម្លៃនៃការផ្តល់សេវាដោយរដ្ឋបាលសាធារណៈ ដើម្បីបំពេញបន្ថែមទៅនឹងកម្មវិធីវិសហមជ្ឈការ និងគំរោងការងារដែលត្រូវអនុវត្តនាពេលដ៏ខ្លីខាងមុខ ។
- បញ្ចប់យុទ្ធសាស្ត្រស្តីពីការពង្រឹងសមត្ថភាព និងចាប់ផ្តើមអនុវត្តគំរោងពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធា-រណៈ
- បញ្ចប់ការសិក្សាវិភាគស្រាវជ្រាវ ដើម្បីកែលំអការរៀបចំ និងការប្រព្រឹត្តទៅនៃដំណើរការការងារ ក្នុងទិសដៅជួយ

ជំរុញការផ្តល់សេវាសាធារណៈ ជាពិសេសនៅតាមខេត្ត និងជនបទហើយនិងដើម្បីបង្កើនល្បឿនកំណែទំរង់បៀវត្ស និងនិយោជន៍

- កសាងយុទ្ធសាស្ត្របច្ចេកវិទ្យាពត៌មានមួយឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹងតម្លាភាពលើការផ្តល់សេវាលិខិតបទដ្ឋានគតិយុត្តិ ស្តីពីដំណើរការការងារ និងបង្កើនផលិតភាពជាទូទៅ (E-Government)
- បង្កើតកម្មវិធី និងគំរោងការងារឱ្យមានភាពរលូន ដើម្បីអនុវត្តឱ្យបានសំរេចជោគជ័យនៅដំណាក់កាលទី២ និងទី៣ នៃកម្មវិធីជាតិកំណែទំរង់រដ្ឋបាល
- បង្កើនការទំនាក់ទំនងល្អជាមួយដៃគូពាក់ព័ន្ធ ក្នុងទិសដៅដើម្បីពង្រឹងការចូលរួម និងភាពម្ចាស់ការ
- បន្តពង្រឹងការគ្រប់គ្រងការងារកំណែទំរង់

សំរាប់សកម្មភាពរយៈពេលមធ្យម រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគំរោងការងារដែលបានដាក់ឱ្យដំណើរការ និងអនុវត្តកម្មវិធីរួមមួយដើម្បីបង្កើនល្បឿនកំណែទំរង់បៀវត្ស និងនិយោជន៍ក្នុងទិសដៅសំរាប់ជំរុញ និងគាំទ្រការផ្តល់សេវាសាធារណៈដែលកម្មវិធីរួមនេះមានគំរោងសំខាន់ៗមួយចំនួនដូចជាៈ

- កម្មវិធី និងគោលនយោបាយប្រព័ន្ធលាភការព្រមទាំងតម្រូវឱ្យមានយន្តការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុមួយប្រកបដោយចីរភាព
- កម្មវិធី និងគោលនយោបាយកន្សោមអាទិភាព ដោយមានការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍន៍
- កម្មវិធី និងគោលនយោបាយក្នុងការផ្តល់សេវាសាធារណៈរួមទាំងកម្មវិធីវិសហមជ្ឈការ និងយន្តការនៃការផ្តល់សេវាតាមជំរើស
- កម្មវិធី និងគោលនយោបាយដើម្បីកែលំអធ្វើឱ្យមានការផ្លាស់ប្តូររូបរាងថ្មីក្នុងរដ្ឋបាលសាធារណៈ រួមទាំងយន្តការសំរបសំរួល
- កម្មវិធី និងគោលនយោបាយដើម្បីពង្រឹងសមត្ថភាពរួមទាំងការដាក់ឱ្យដំណើរការគំរោងពង្រឹងសមត្ថភាពមន្ត្រីរាជការផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ
- កម្មវិធី និងយុទ្ធសាស្ត្របច្ចេកវិទ្យាពត៌មានវិទ្យា ក្នុងទិសដៅសំរបសំរួលកិច្ចការ និងពង្រឹងការទំនាក់ទំនង និងតម្លាភាព
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលចំណេះដឹងកម្ពុជា ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋកម្ពុជា មន្ត្រីរាជការបានក្រេបជញ្ជក់នូវចំណេះដឹងពីពិភពលោក
- ធានាឱ្យបាននូវចីរភាពនៃការកែទំរង់ រួមទាំងពង្រឹងសមត្ថភាពគ្រប់គ្រង ។

ផែនការសកម្មភាពលំអិតលទ្ធផលរំពឹង និងពេលវេលាត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងផែនកាសកម្មភាពអភិបាលកិច្ច និងឯកសារជំនួយស្មារតីស្តីពីកំណែទំរង់រដ្ឋបាលដែលឯកសារទាំងនេះនឹងត្រូវចែកផ្សាយដល់ដៃគូពាក់ព័ន្ធទាំងអស់នៅខែ មករា ឆ្នាំ២០០៣ ខាងមុខដើម្បីឱ្យបានយល់ដឹងជ្រួតជ្រាប និងងាយស្រួលធ្វើការសម្របសម្រួលការងារនៃកម្មវិធីជាតិកំណែទំរង់រដ្ឋបាល ។

## ៤.៤.៣ កម្មវិធីវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន

តាមប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាបានដឹកនាំ និងគ្រប់គ្រងប្រទេសភាគច្រើនអនុវត្តតាមប្រព័ន្ធវិមជ្ឈការ ។ តាមនិន្នាការនៃចរន្តសកលភាវូបណីយកម្មនាសហវត្សថ្មីនេះបានតម្រូវឱ្យរាជរដ្ឋាភិបាលទទួលស្គាល់អំពីសារៈប្រយោជន៍ និងប្តេជ្ញាចិត្តយ៉ាងអង់អាចក្នុងការដាក់ឱ្យការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការជាលើកដំបូងនៅក្នុងប្រទេសកម្ពុជាតាមរយៈការបោះឆ្នោត រៀបចំជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅទូទាំងប្រទេស ដែលសំរេចបានជោគជ័យជាប្រវត្តិសាស្ត្រ កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០២ ។ ដូច្នេះដើម្បីគាំទ្រ និងពង្រឹងដំណើការនៃការអនុវត្តន៍ប្រពន្ធ័វិមជ្ឈការឱ្យសំរេចបានជោគជ័យថែមទៀត រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងខ្លាំងក្លាដោយយកចិត្តទុកដាក់បំផុត ។

ការរំលែកអំណាចតាមរយៈការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ នឹងក្លាយជាគោលដៅមួយដ៏សំខាន់ក្នុងការបង្វែរទិសដៅនៃការអភិវឌ្ឍន៍ទៅឱ្យប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាអ្នកទទួលខុសត្រូវក្នុងទស្សនៈ ដើម្បីធ្វើការស្តារហេដ្ឋារចនាសម្ព័ន្ធពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។ ការចែករំលែកធនធាន និងអំណាចពីរដ្ឋបាលកណ្តាលទៅមូលដ្ឋានតាមរយៈប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការបានក្លាយទៅជាការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងជាសក្តានុពលដើម្បីពង្រឹងប្រសិទ្ធិភាពក្នុងការផ្តល់សេវាសាធារណៈនៅតាមមូលដ្ឋាន ។

### គោលនយោបាយ និង យុទ្ធសាស្ត្រ នៃកម្មវិធីវិមជ្ឈការ

ការអនុវត្តន៍កម្មវិធីវិមជ្ឈការ នៅកម្ពុជា មានគោលដៅ ៣ យ៉ាងសំខាន់ៗ គឺ:

- បង្កើនការចូលរួមតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនៅតាមមូលដ្ឋាន (រួមទាំងអភិបាលកិច្ចល្អ និងប្រជាធិបតេយ្យមូលដ្ឋាន) តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលផ្តល់ស្វ័យភាព និងអំណាចទៅឱ្យឃុំ-សង្កាត់ជាអ្នកទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋដែលបោះឆ្នោតឱ្យខ្លួន ការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងធ្វើការសំរេចចិត្តលើការផ្តល់សេវាសាធារណៈ និងផលិតកម្មផ្សេងៗ ។
- បង្កើតវប្បធមិឱ្យមានការចូលរួមអភិវឌ្ឍន៍ (ផែនការកម្ម ការគ្រប់គ្រង ការគៀងគរធនធាន) នៅតាមមូលដ្ឋានតាមរយៈក្រុមប្រឹក្សាឃុំ ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច
- ចូលរួមកាត់បន្ថយភាពក្រីក្រនៅទូទាំងប្រទេស ដោយកែលំអលក្ខខណ្ឌផ្តល់ឱកាស និងភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ផ្តល់សេវា ។

រាជរដ្ឋាភិបាល ក៏បានទទួលស្គាល់ផងដែរថាសហសម្ព័ន្ធរវាងការកាត់បន្ថយភាពក្រីក្រ និងវិមជ្ឈការ គឺមិនជាប់ពាក់ព័ន្ធជាមួយគ្នាដោយស្វ័យប្រវត្តិទាំងស្រុងនោះទេ ដោយហេតុថាគោលដៅនៃការធ្វើវិមជ្ឈការគឺដើម្បីពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋឱ្យចេះការពារប្រយោជន៍របស់ខ្លួន ហើយសហសម្ព័ន្ធនេះអាចកើតមានបានលុះត្រាតែ លក្ខខណ្ឌសំខាន់ៗមួយចំនួនត្រូវបង្កើតឱ្យចេញជាលទ្ធផលជាក់ស្តែង ។ តាមបទពិសោធន៍ និងមេរៀនអន្តរជាតិបង្ហាញឱ្យឃើញថា ការអនុវត្តន៍វិមជ្ឈការ ដើម្បីជួយគាំពារ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្រីក្រ អាចសំរេចបានលុះត្រាតែអនុវត្តទៅតាមគោលការណ៍ ចំបងៗ មួយចំនួនដូចជា: (១) ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទមានសមត្ថភាពគ្រប់គ្រាន់អាចការពារផលប្រយោជន៍របស់ខ្លួនឯងបាន (២) ភ្នាក់ងារ

អភិវឌ្ឍន៍ជនបទរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមិនត្រូវមានសមត្ថកិច្ច និងមានទ្រង់ទ្រាយធំពេកទេជាងឃុំ-សង្កាត់ (៣) បង្កើតកម្មវិធីដោយផ្ដោតតែទៅលើក្រុមអ្នកក្រីក្រ និង កម្មវិធីបណ្ដុះបណ្ដាលដើម្បីអភិវឌ្ឍន៍ជនបទ (៤) គំរោងបណ្ដុះបណ្ដាលផងធ្វើការផង និង (៥) តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល ត្រូវកំណត់ឱ្យបានច្បាស់លាស់ ។

រាជរដ្ឋាភិបាលយល់ឃើញថា នយោបាយវិមជ្ឈការអាចនាំឱ្យមានការកើនឡើងនូវការចូលរួមរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានក្នុងបញ្ហានយោបាយ និង ការសំរេចចិត្តលើការអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្រ ។ ការអនុវត្តន៏វិមជ្ឈការចាំបាច់ត្រូវតែមានធានធានគ្រប់គ្រាន់ មានភ្នាក់ងារប្រកបដោយការទទួលខុសត្រូវខ្ពស់លើការផ្ដល់សេវា បង្កើនគុណភាពនៃសេវា និងការអភិវឌ្ឍន៏ធនធានមនុស្ស ។ លើសពីនេះទៅទៀតទាំងប្រព័ន្ធ និងដំណើរការអនុវត្ត គឺត្រូវតែធានាឱ្យមានការចូលរួម និងមានសំឡេងរបស់ប្រជាពលរដ្ឋក្រីក្រ ។

កម្មវិធីអភិវឌ្ឍន៏មូលដ្ឋានគួរតែមានទិសដៅដើម្បីពង្រឹងភាពម្ចាស់ការនៅតាមមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៏ប្រទេស និងពង្រឹងចំណងសាមគ្គីរវាងរដ្ឋ និងសង្គមស៊ីវិល ។ ការអនុវត្តន៏វិមជ្ឈការ គឺមានអត្ថន័យនិងសារៈប្រយោជន៏យ៉ាងជ្រាលជ្រៅដើម្បីបង្កើនសមត្ថភាពរបស់មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យចេះធ្វើការសំរេចលើការអភិវឌ្ឍន៏ប្រទេស ។ នៅពេលអាជ្ញាធរមូលដ្ឋាន មានសមត្ថភាពខ្លាំងក្លាហើយរាជរដ្ឋាភិបាលអាចចែករំលែកអំណាចទៅឱ្យប្រជាពលរដ្ឋដើម្បីមានលទ្ធភាពចូលរួមក្នុងសកម្មភាពនៃដំណើរការអភិវឌ្ឍន៏ ប៉ុន្តែប្រសិនបើអាជ្ញាធរមូលដ្ឋានមិនទាន់មានសមត្ថភាពខ្លាំងក្លានៅឡើយ រាជរដ្ឋាភិបាលនឹងនៅតែបន្តជួយពង្រឹងសមត្ថភាពរហូតតាមរយៈការបណ្ដុះបណ្ដាល និងការបញ្ជូនមន្ត្រីរាជការពីរដ្ឋបាលកណ្ដាលឱ្យទៅជួយពួកគេលើការអនុវត្តន៏ការងារឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធិភាព ។

រាជរដ្ឋាភិបាលសង្ឃឹមថា នឹងពង្រឹងសមត្ថភាពអាជ្ញាធរមូលដ្ឋានលើការធ្វើផែនការដើម្បីដាក់បញ្ចូលសូចនាករមួយចំនួនដែលមានការពាក់ព័ន្ធទៅនឹងការកាត់បន្ថយភាពក្រីក្រ ការបែងចែកធនធានប្រកបដោយសមភាពបញ្ហាយេនឌ័រ កុមារជនជាតិភាគតិច និងជនពិការទៅក្នុងផែនការ និងកម្មវិធីអភិវឌ្ឍន៏ឃុំ-សង្កាត់ ។ សូចនាករទាំងនេះត្រូវតែធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់ហើយលទ្ធផល នឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៏ប្រចាំឆ្នាំ ។

ដ្យាក្រាមខាងក្រោមនេះ គឺជាតារាងសង្ខេបអំពីរចនាសម្ព័ន្ធថ្មីរបស់វិមជ្ឈការៈ

## ដ្យាក្រាម

យុទ្ធសាស្ត្រវិមជ្ឈការរបស់រាជរដ្ឋាភិបាល គឺផ្អែកលើគោលការណ៍ពីមូលដ្ឋានមកមជ្ឈឹម (Bottom-Up) ការប្រមូលផ្ដុំការចូលរួម និងការអភិវឌ្ឍន៏ជនបទតាមប្រព័ន្ធវិមជ្ឈការ ។ ដ្យាក្រាមនេះត្រូវដាក់បញ្ចូលបន្ថែមនូវចំនួនគណកម្មាការអភិវឌ្ឍន៏ភូមិ (Village Development Committes-VDCs) ដែលជាអង្គភាពកើតចេញពីការបោះឆ្នោតមានតួនាទីជាអ្នកតំណាងឱ្យប្រជាពលរដ្ឋក្នុងភូមិ ចំពោះមុខរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអន្តរជាតិក្នុងការគ្រប់គ្រងគំរោងអភិវឌ្ឍន៏ជនបទ ។ រាជរដ្ឋាភិបាលមានបំណងពង្រីកកម្មវិធីសីលាឱ្យបានចំនួន ១.២១៦ ភូមិក្នុង ១៧ ខេត្តនៅឆ្នាំ ២០០៥ ខាងមុខដែលស្មើនឹង ៨០% នៃចំនួនភូមិទាំងអស់នៅទូទាំងប្រទេស ។ ការងារទាំងនេះ នឹងនាំឱ្យមានការចូលរួមយ៉ាងសកម្មពីសហគមន៏មូលដ្ឋានពង្រឹងភាពម្ចាស់ការលើការបង្កើតគំរោង និងរំកិលការធ្វើសេចក្ដីសំរេចចិត្ត និងការទទួលខុសត្រូវឱ្យទៅជិតនឹងប្រជាពលរដ្ឋគ្រប់រូប មេគ្រួសារ និងសហគមន៏ ។

គោលនយោបាយ និងកំណែទំរង់ស្ថាប័នកំពុងត្រូវបានគាំទ្រដោយយុទ្ធសាស្ត្រវិនិយោគសាធារណៈរួមទាំងការផ្គត់ផ្គង់ទឹកស្អាតក្នុងភូមិ និងផ្លូវលំជនបទដើម្បីគាំទ្រដល់ការស្តារឡើងវិញ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងបង្កើនការងារនៅតាមជនបទ ។

## ប្រអប់ទី ៨: គណៈកម្មការអភិវឌ្ឍន៏ភូមិ និងការចែករំលែកអំណាចទៅឱ្យរដ្ឋបាលមូលដ្ឋាន

សហគមន៏ជនបទ ជាពិសេសកម្មាការអភិវឌ្ឍភូមិ (គអភ) ដើរតួនាទីដ៏សំខាន់ជាស្ថាប័នមូលដ្ឋាន ដើម្បីធានាការអភិវឌ្ឍន៏ជនបទប្រកបដោយចីរភាព ។ គអភ គឺជាស្ថាប័នអភិវឌ្ឍន៏មូលដ្ឋានឯករាជ្យដែលមានភារកិច្ចជាអ្នកដឹកនាំ គ្រប់គ្រង និងចាត់ចែងសកម្មភាពការងារអភិវឌ្ឍន៏ភូមិ ។ គអភ នីមួយៗ ត្រូវបានបង្កើតឡើងតាមរយៈបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋក្នុងភូមិ តាមលទ្ធិប្រជាធិបតេយ្យសេរី និងសម្ងាត់ ។ គអភ គឺជាភ្នាក់ងារដ៏ចំបងរបស់ក្រុមប្រឹក្សាឃុំ នៅ ថ្នាក់ភូមិ ។ គអភ ក៏មានតំណាងរបស់ខ្លួនចំនួន ២ រូប (ដោយក្នុងនោះមានស្ត្រី១រូប) ក្នុងគណៈកម្មាការផែនការ និងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ ។

ក្នុងរចនាសម្ព័ន្ធនេះ គអភ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ លើការបង្កើត និងអនុវត្តគំរោងតូចៗមួយចំនួននៅថ្នាក់ភូមិ ។ គអភ ជាអ្នកស្វះស្វែងជំរុញការអភិវឌ្ឍន៏ជនបទ ប្រកបដោយចីរភាព តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋលើការវាយតម្លៃពីសេចក្តីត្រូវការផែនការកម្ម ការបង្កើតអនុវត្តន៏ ត្រួតពិនិត្យ និងវាយតម្លៃ ហើយនិងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៏សហគមន៏នៅក្នុងភូមិ ។ ការចូលរួមរបស់ គអភ លើការថែរក្សាផ្លូវលំ អណ្តូង ប្រព័ន្ធធារាសាស្ត្រ និងសាលារៀន គឺដើម្បីរួមចំណែកដល់ការបង្កើតគំរោង និងកម្មវិធីអភិវឌ្ឍន៏ជនបទ ។

នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មាន គអភ ចំនួន ៨.000 ក្នុងចំណោមភូមិចំនួន ១៣.៦៩៤ ភូមិ ។ បើតាមតួលេខនៃការស្ទាបស្ទង់ ដែលបានធ្វើឡើងដោយក្រសួងអភិវឌ្ឍន៏ជនបទក្នុងឆ្នាំ ១៩៩៩ គអភ ទាំងនោះនៅមានការខ្វះខាតធនធានមនុស្សផ្នែកគ្រប់គ្រង និងហិរញ្ញវត្ថុ សំរាប់អភិវឌ្ឍន៏ភូមិ ។ ដូច្នេះគោលដៅជាសំខាន់របស់យើង គឺត្រូវបណ្តុះបណ្តាលបន្ថែមដល់សមាជិក គអភ អំពីមុខជំនាញ មគ្គុទ្ទេសក៏ភាព និងការគ្រប់គ្រងសហគមន៏ កំណែនប្រជាពលរដ្ឋ និងអំពីតួនាទី និងការទទួលខុសត្រូវរបស់ គអភ ហើយក៏ត្រូវមានការបណ្តុះបណ្តាលផងដែរដល់អ្នកសម្របសម្រួល ។

លើសពីនេះទៅទៀត ការសំរបសំរួលរវាងការអនុវត្តន៏នយោបាយវិមជ្ឈការ (ឧទាហរណ៏: អភិបាលកិច្ចមូលដ្ឋានត្រូវបានបង្កើតឡើងដោយការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ: ក្រុមប្រឹក្សាឃុំ-សង្កាត់ ) និងកម្មវិធីវិសហមជ្ឈការ (ការចែករំលែកការទទួលខុសត្រូវ និងអំណាចពីរដ្ឋបាលកណ្តាលទៅឱ្យរដ្ឋបាលមូលដ្ឋាន) គឺជាការចាំបាច់បំផុត ។ ការបង្វែរថវិកាទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ដើម្បីដំណើរការការងារ គឺត្រូវតែធ្វើឡើងដោយមានការសហការ និងស្របពេលជាមួយគ្នាទៅនឹងការបង្កើតគោលនយោបាយស្តីពីការបែងចែកការទទួលខុសត្រូវលើការសំរេចចិត្តនៅគ្រប់ថ្នាក់រដ្ឋបាលទាំងអស់ ។

នៅពេលដែលដំណើរការវិមជ្ឈការមានការរីកចំរើនកាន់តែខ្លាំងឡើង ចាំបាច់ត្រូវតែកំណត់អំពីនិយមន័យឱ្យបានច្បាស់លាស់ស្តីពីតួនាទី និងភារកិច្ចរបស់ស្ថាប័នគ្រប់ថ្នាក់រដ្ឋបាលទាំងអស់ (ថ្នាក់ជាតិ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងឃុំ-សង្កាត់) ដើម្បីងាយស្រួលដល់ការចែករំលែកអំណាច និងសមត្ថកិច្ច ។

ដើម្បីអនុវត្តឱ្យសំរេចបានជោគជ័យតាមគោលដៅខាងលើ លុះត្រាតែគ្រប់ស្ថាប័ននៃថ្នាក់រដ្ឋបាលទាំងអស់មានការពង្រឹងសមត្ថភាពបន្ថែមទៀត ។ ដូច្នេះហើយបានជារាជរដ្ឋាភិបាលបានចែករំលែកចំណេះដឹង បទពិសោធន៏ ជំនាញ ធនធានក្នុងការ

អនុវត្តន៍ និងគ្រប់គ្រងតាមប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំង ១,៦២១ ។ មន្ត្រីរាជការដែលទទួលបន្ទុកសម្របសម្រួលការអនុវត្តន៍វិមជ្ឈការ បានចុះទៅជួយពង្រឹងសមត្ថភាពថ្នាក់រដ្ឋបាលមូលដ្ឋានលើដំណើរការនៃការសំរេចចិត្ត និងការយល់ដឹងអំពីអំណាចវិមជ្ឈការ ។ មិនតែប៉ុណ្ណោះក៏ត្រូវមានការបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាព ផងដែរដល់មន្ត្រីរាជការនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដូចជាពង្រឹងសមត្ថភាពការិយាល័យរដ្ឋបាលមូលដ្ឋានខេត្ត (POLAs) និងមន្ទីរជំនាញដទៃទៀតដែលមានការពាក់ព័ន្ធនឹងកម្មវិធីវិមជ្ឈការជាពិសេសមន្ទីរផែនការ ។ ពង្រឹងសមត្ថភាពមន្ត្រីរាជការ នៅថ្នាក់ស្រុកដែលមានការពាក់ព័ន្ធដល់ការអនុវត្តន៍វិមជ្ឈការ ហើយនិងប្រធានក្រុមប្រឹក្សាឃុំ លើការអភិវឌ្ឍន៍ឃុំ ព្រមទាំងពង្រឹងសមត្ថភាពអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅតាមមូលដ្ឋាន ។ ការបណ្ដុះបណ្ដាលទាំងនេះ គឺមិនត្រឹមតែដើម្បីបង្កើនចំណេះដឹង និងជំនាញប៉ុណ្ណោះទេ តែចាំបាច់ក៏ត្រូវធ្វើឱ្យមានការផ្លាស់ប្ដូរនូវអកប្បកិរិយា និងសីលធម៌រស់នៅផងដែរ ។

ការចូលរួមយ៉ាងសកម្ម និងការពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិលនៅតាមមូលដ្ឋាន គឺមានអត្ថប្រយោជន៍យ៉ាងសំខាន់ផងដែរដោយហេតុថាសង្គមស៊ីវិលនៅកម្ពុជាមានបទពិសោធន៍តិចតួចក្នុងជួយឧបត្ថម្ភ និងត្រួតពិនិត្យគ្នាទៅវិញទៅមកជាមួយអាជ្ញាធរមូលដ្ឋាន ។ ប្រជាពលរដ្ឋទាំងអស់ត្រូវតែយល់ដឹងអំពីសិទ្ធិសេរីភាពរបស់ខ្លួន មធ្យោបាយក្នុងការអនុវត្តន៍ សិទ្ធិសេរីភាព ហើយនិងរបៀបក្នុងការបញ្ចេញមតិឆ្លើយតបទៅនឹងរដ្ឋាភិបាល ។ ប្រជាពលរដ្ឋក៏ត្រូវមានការយល់ដឹងផងដែរ អំពីអំណាច និងតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីអង្កេតមើល និងតាមដានអំពីការបំពេញការងាររបស់តំណាងរបស់ខ្លួន។

ធនធានហិរញ្ញវត្ថុ និងកម្មវិធីៈ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវការជាចាំបាច់នូវធនធានឱ្យបានគ្រប់គ្រាន់ដើម្បីប្រតិបត្តិការងារស្របច្បាប់របស់ខ្លួននៅតាមមូលដ្ឋានហើយធនធានហិរញ្ញវត្ថុរបស់ឃុំ ត្រូវប្រព្រឹត្តទៅតាមដំណើរការមួយប្រកបដោយតម្លាភាព ។ តាមពិសោធន៍ បានបង្ហាញឱ្យឃើញថាមិនមានយុទ្ធសាស្ត្រគាំពារអ្នកក្រណាមួយត្រូវបានអនុវត្តបានសំរេចប្រសិនបើគ្មានការអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមគោលការណ៍អភិបាលកិច្ចល្អ នៅតាមស្ថាប័នគ្រប់ថ្នាក់រដ្ឋបាលទាំងអស់ ។

រាជរដ្ឋាភិបាលបានលើកឡើងនូវយុទ្ធសាស្ត្រផ្សេងៗគ្នាជាច្រើនដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តន៍កម្មវិធីវិមជ្ឈការដើម្បីកាត់បន្ថយភាពក្រីក្រ ដូចជាៈ

- បង្កើនការចូលរួម ការទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាពរបស់រាជរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានៈ ក្នុងទិសដៅនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែផ្ដល់ពត៌មានអំពីការសំរេចចិត្ត និងធនធានរបស់ខ្លួនទៅដល់ប្រជាពលរដ្ឋ និងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការពង្រឹងសមត្ថភាពសហគមន៍ ។ ការអនុវត្តន៍របៀបនេះប្រជាពលរដ្ឋក្រីក្រនឹងបានដឹងឮដោយផ្ទាល់អំពីការសំរេចចិត្ត ធនធាន និងសេវាដែលផ្ដល់ដោយឃុំ-សង្កាត់ ។
- ផលប្រយោជន៍នៃជំនួយអភិវឌ្ឍន៍សំរាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន និងការផ្ដល់សេវាៈ អំណាចវិមជ្ឈការត្រូវតែអនុវត្តឱ្យស្របទៅនឹងធនធានដែលមានរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការ ដោះស្រាយបញ្ហានៃការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ ។ រាជរដ្ឋាភិបាលបានលើកឡើងនូវសំណើដើម្បីផ្ដល់ ជំនួយឧបត្ថម្ភផ្នែករដ្ឋបាល និងការអភិវឌ្ឍន៍ទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ជំនួយឧបត្ថម្ភនេះគឺមានការផ្ដល់ ហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងតម្រូវការសេវាសំខាន់ៗចាប់តាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរហូតដល់កម្មវិធីដើម្បីកាត់បន្ថយ

ភាពក្រីក្រ ។ រាជរដ្ឋាភិបាល បានលើកឡើងនូវគោលការណ៍ដើម្បីធ្វើការចែករំលែកចំណូលថវិកាជាតិមួយចំនួនដាក់បញ្ចូលទៅក្នុងជំនួយឧបត្ថម្ភនេះហើយប្រគល់ទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ នៅឆ្នាំក្រោយ ។ ដូច្នេះនៅពេលដែលអាជ្ញាធរមូលដ្ឋានធ្វើការសំរេចចិត្តលើការប្រើប្រាស់ធនធាន និងសេវាសំរាប់បំរើប្រជាពលរដ្ឋ រាជរដ្ឋាភិបាលមានជំនឿថាមានការកើនឡើងជាទូទៅនូវការទទួលខុសត្រូវខ្ពស់ចំពោះតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ ។

- ដំណើរការនៃការចូលរួម និងការធ្វើផែនការមានទិសដៅពីមូលដ្ឋានមកមជ្ឈិមៈ ដើម្បីធានានូវការឆ្លើយតបទៅនឹងតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋក្រីក្រ និងក្រុមមនុស្សដែលងាយរងគ្រោះ ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋានចាំបាច់ត្រូវតែមានការចូលរួម និងពិភាក្សាឱ្យបានល្អិតល្អន់ពីសំណាក់ប្រជាពលរដ្ឋទាំងនោះ ។ ដំណើរការនេះត្រូវប្រព្រឹត្តទៅជា៥ ដំណាក់កាល និង១១ ជំហ៊ាននៃការធ្វើផែនការ ដោយចាប់ផ្តើមពីការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងភូមិ ក្នុងការកំណត់អំពីតម្រូវការ និងការងារជាអាទិភាពក្នុងមូលដ្ឋាន ហើយដាក់ឆ្លងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាបន្តបន្ទាប់មុនពេលដែលផែនការទាំងនេះត្រូវបានអនុម័ត និងអនុវត្តជាផ្លូវការដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ដំណើរការនៃការធ្វើផែនការ គឺមិនត្រឹមតែធានា ឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្រីក្រក្នុងការកំណត់អំពីតម្រូវការចាំបាច់របស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានការខ្នះខ្នែង និងព្យាយាមឆ្លើយតបទៅនឹងតម្រូវការដែលបានលើកឡើង ។ ធនធានដែលបានគ្រោងទុកសំរាប់ផ្ទេរទៅឱ្យឃុំ-សង្កាត់ក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវបានកំណត់ក្នុងតារាងលេខ ៤។

### តារាង ៤.៥ សំណើរបស់រាជរដ្ឋាភិបាល ដើម្បីផ្ទេរទៅឱ្យឃុំ-សង្កាត់ ឆ្នាំ ២០០១-២០០៥

| | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|
| | ការពិត | ថវិកា | គំរោង | | |
| គិតជាកោដរៀល | 0 | ២០.000 | ៤០.៦៩៣ | ៥៧.១៤៨ | ៦៣.៦៨៤ |
| ១ ភាគនៃចំណូលចរន្ត | 0 | ១,១១ | ២,0 | ២,៥ | ២,៥ |

ប្រភព : គំរោងចំណាយរយៈពេលមធ្យម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បង្កើនសមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់ និងសហគមន៍ៈ ដោយមានការគាំទ្រពីគណៈកម្មការជាតិគាំទ្រឃុំ-សង្កាត់ និងការគៀងគរជំនួយពីក្រសួងជំនាញ និងដៃគូខាងក្រៅរាជរដ្ឋាភិបាល បានលើកឡើងនូវសំណើដើម្បីជួយឧបត្ថម្ភយ៉ាងទៀងទាត់ដល់ក្រុមប្រឹក្សាឃុំ និងសហគមន៍លើការធ្វើផែនការ និងចាត់ចែងការងារឱ្យមានប្រសិទ្ធិភាព ។ រាជរដ្ឋាភិបាលជឿជាក់ថាការបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសហគមន៍ គឺជាចំណុចគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។
- បង្កើនភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការក្រៅរដ្ឋាភិបាល/សង្គមស៊ីវិល និងផ្នែកឯកជនក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រៈ រាជរដ្ឋាភិបាលបានទទួលស្គាល់ និងលើកទឹកចិត្តដល់ការអភិវឌ្ឍន៍អង្គការក្រៅរដ្ឋាភិបាល/សង្គមស៊ីវិល និងផ្នែកឯកជនដោយចាត់ទុកជាដៃគូដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ក្នុងបរិបទ

វិមជ្ឈការ រដ្ឋាភិបាលជំរុញឱ្យមានភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជនលើការធ្វើផែនការគ្រោងគរធនធាន ការពង្រឹងសមត្ថភាព ការវិនិយោគ និងការផ្តល់សេវាសាធារណៈ ។

- បង្កើនការទំនាក់ទំនង និងសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្ថាប័នដទៃទៀតក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ដើម្បីភ្ជាប់ការអភិវឌ្ឍន៍ធនធានមនុស្សទៅនឹងការកាត់បន្ថយភាពក្រីក្រ គឺចាំបាច់ត្រូវតែបង្កើតចំណងទំនាក់ទំនងមួយប្រកបដោយប្រសិទ្ធិភាពរវាងសហគមន៍ ក្រុមប្រឹក្សាឃុំ និងអង្គភាព និងការិយាល័យដទៃទៀតរបស់ក្រសួងដែលពាក់ព័ន្ធនឹងការផ្តល់សេវា ។ ដូច្នេះ រាជរដ្ឋាភិបាលអាចដាក់បញ្ចូលគ្នានូវផែនការការងារផ្សេងៗទៅនឹងដំណើរការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ និងភ្នាក់ងារជំនាញតាមផ្នែករបស់រដ្ឋាភិបាល ។
- ចែករំលែកមុខងារជាភ្នាក់ងាររដ្ឋទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់រួមជាមួយនឹងធនធាន និងយន្តការគាំទ្ររាជរដ្ឋាភិបាលបានលើកឡើងនូវសំណើសំរាប់ប្រគល់សមត្ថកិច្ចក្នុងនាមជាភ្នាក់ងាររដ្ឋទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីបង្កើនប្រសិទ្ធិភាព ផលិតភាព និងតម្លាភាព ។ ក្នុងទស្សនៈនេះ រាជរដ្ឋាភិបាលជឿជាក់ថាតួនាទីជាភ្នាក់ងារត្រូវតែអនុវត្តដោយមាន ធនធាន និងយន្តការគាំទ្រមួយប្រាកដប្រជា ។ ភាគច្រើននៃតួនាទីជាភ្នាក់ងាររដ្ឋ គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការប្រើប្រាស់សេវាជាមូលដ្ឋានរបស់ប្រជាពលរដ្ឋគ្រប់រូប ។ នៅពេលអនុវត្តន៍តាមគោលការណ៍នេះឱ្យបានពេញលេញ និងយូរអង្វែរ រាជរដ្ឋាភិបាលមានក្តីសង្ឃឹមថា ក្រុមប្រឹក្សាឃុំ-សង្កាត់ នឹងចូលរួមជានិច្ចនិរន្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់លើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

### ៤.៤.៤ ការប្រឆាំងអំពើពុករលួយ

ការប្រឆាំងអំពើពុករលួយគឺជាផ្នែកទី ៤ នៃបញ្ហាអន្តរវិស័យដែលជាចំណុចគន្លឹះជាយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ។ ប្រទេសកម្ពុជាបាននឹងកំពុងប្រឈមមុខនឹងបញ្ហាដ៏លំបាកក្នុងការសំរេចឱ្យបានជោគជ័យលើការប្រឆាំងអំពើពុករលួយ ។ ការវិនិយោគមានលក្ខណៈប្រកួតប្រជែងគ្នាយ៉ាងខ្លាំងក្លា និងស្រួចស្រាវបំផុតក្នុងចំណោមប្រទេស និងឧស្សាហកម្មធំៗលើពិភពលោក ប៉ុន្តែដោយថាហេតុប្រទេសកម្ពុជាអាចគ្រប់គ្រងបានតែចំណុចប៉ារ៉ាម៉ែត្រមួយចំនួនតូចប៉ុណ្ណោះដើម្បីសំរេចឱ្យបានជោគជ័យលើការប្រកួតប្រជែងរបៀបនេះ ។ ចំណុចប៉ារ៉ាម៉ែត្រតែមួយប៉ុណ្ណោះដែលអាចធ្វើឱ្យមានការកក្រើករញ្ជួយដល់ការកាត់បន្ថយភាពក្រីក្រ គឺមានតែការអនុវត្តន៍តាមអភិបាលកិច្ចល្អ ការប្រឆាំងអំពើពុករលួយនិងតម្លៃសម្របសម្រួល ។

ក្រោយកិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅទីក្រុងតូក្យូ ឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលបានអនុញ្ញាត និងសម្រួលឱ្យមានការសិក្សាស្ទាបស្ទង់មតិស្តីពីស្ថានភាពអភិបាលកិច្ចនៅក្នុងស្ថាប័នរបស់រដ្ឋ និងលើកឡើងពីដំណោះស្រាយដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តន៍អភិបាលកិច្ចល្អ ។ ការសិក្សាមួយស្តីអំពីអភិបាលកិច្ច និងអំពើពុករលួយត្រូវបានរៀបចំធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់មួយ (Lidee Khmer) ក្រោមជំនួយឧបត្ថម្ភធនាគារពិភពលោក ហើយការសិក្សាមួយទៀតស្តីអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពត្រូវបានរៀបចំធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CDRI ) ដោយមានជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី ។ ការសិក្សាទាំង ២ នេះបានរួមចំណែកជាមួយនឹងរបាយការណ៍ជាច្រើនទៀតរបស់អ្នកជំនាញការស្តីអំពីបញ្ហាដែលទាក់ទងនឹងអភិបាលកិច្ចស្ទើរតែគ្រប់វិស័យទាំងអស់ នៃសកម្មភាពរបស់រាជ-

រដ្ឋាភិបាល ។

ប្រសិនបើអនុវត្តតាមអភិបាលកិច្ចល្អនោះអំពើពុករលួយនឹងមានកើតឡើងដោយងាយៗនោះទេ ។ ទស្សនៈទូទៅបានយល់ឃើញថាអំពើពុករលួយគឺមិនគ្រាន់តែគំរាមកំហែងដល់ស្ថាប័នប្រជាធិបតេយ្យ និងការគោរពសិទ្ធិជាសារវ័ន្ត និងសេរីភាពប៉ុណ្ណោះទេប៉ុន្តែថែមទាំងបង្កឱ្យមានភាពអន្តរាយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងធ្វើឱ្យប្រជាជនរាប់លាននាក់នៅលើពិភពលោកកាន់តែក្រទៅៗ ។ អំពើពុករលួយអាចនាំឱ្យមានការសំរេចចិត្តមិនសមហេតុផល និងរាំងស្ទះដល់ការអភិវឌ្ឍន៍ផ្នែកឯកជន និងមិនអំណោយផលដល់បរិយាកាសសង្គមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ បញ្ហាដែលសំខាន់បំផុតនោះ គឺមិនត្រឹមតែស្វែងរកឱ្យឃើញនូវការប្រព្រឹត្តអំពើពុករលួយប៉ុណ្ណោះទេប៉ុន្តែថែមទាំងកំណត់ឱ្យបានច្បាស់លាស់អំពីវិធីសាស្ត្រ និងមធ្យោបាយក្នុងការអនុវត្តន៍ ។

រាជរដ្ឋាភិបាលបានជ្រើសរើសយកនូវយុទ្ធសាស្ត្រដើម្បីប្រឆាំងអំពើពុករលួយដោយដាក់ចេញនូវវិធានការជាក់ស្តែង ដែលអាចលុបបំបាត់នូវឫសគល់នៃអំពើពុករលួយ ។ យុទ្ធសាស្ត្រនេះត្រូវបានដាក់ឱ្យអនុវត្តដោយមានទាំងមធ្យោបាយ និងធនធានគ្រប់គ្រាន់ដើម្បីទប់ស្កាត់ និងបង្ក្រាបជាអតិបរមាដល់អ្នកប្រព្រឹត្តអំពើពុករលួយ ពីព្រោះបើមានតែច្បាប់ បទបញ្ញត្តិ និងក្រមសីលធម៌មួយមុខប៉ុណ្ណោះ គឺមិនអាចសំរេចបានជោគជ័យទេ ហើយចាំបាច់ត្រូវតែមានយន្តការពង្រឹងការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធិភាពមួយថែមទៀត ។ រាជរដ្ឋាភិបាលកំពុងអនុវត្តន៍យ៉ាងសកម្មលើការពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងការរៀបចំ និងតាក់តែងលិខិតបទដ្ឋានគតិយុត្តិឱ្យបានគ្រប់គ្រាន់ និងអាចអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

ផែនការសកម្មភាពអភិបាលកិច្ចត្រូវបានបង្កើតឡើងដើម្បីបោសសំអាត និងលុបបំបាត់នូវមូលហេតុនៃការប្រព្រឹត្តអំពើពុករលួយដែលបានកំណត់ក្នុងឯកសារសិក្សាស្រាវជ្រាវ និងឯកសារដទៃផ្សេងទៀត ។ ផែនការសកម្មភាពអភិបាលកិច្ច គឺជាកម្មវិធីមួយដែលមានលក្ខណៈមហិច្ឆតា និងគ្រប់ជ្រុងជ្រោយក្នុងការប្រឆាំងអំពើពុករលួយជាក់ស្តែងដូចជា គំរោងការងារជាច្រើនត្រូវអនុវត្តន៍បានសំរេចក្នុងទិដ្ឋភាពនៃការប្រឆាំងអំពើពុករលួយ ហើយកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យការប្រឆាំងទាំងនេះមានលក្ខណៈចីរភាព និងប្រក្រតីភាព គឺជាបញ្ហាដ៏លំបាកបំផុត ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងតែរៀបចំយុទ្ធសាស្ត្រមួយប្រឆាំងអំពើពុករលួយដោយផ្តោតការយកចិត្តទុកដាក់ដ៏ខ្លាំងក្លាទៅលើឯកសារសំខាន់ៗមួយចំនួនដូចជា ឯកសារយុទ្ធសាស្ត្រជាតិស្តីពីការកាត់បន្ថយភាពក្រីក្រដែលត្រូវបានបង្កើតឡើងផ្អែកលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ ។ ការពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធទាំងអស់ នឹងត្រូវរៀបចំធ្វើឡើងមុនពេលបញ្ចប់ និងអនុម័តយុទ្ធសាស្ត្រនេះ ។

ទោះបីយ៉ាងណាក៏ដោយការប្រឆាំងអំពើពុករលួយក្នុងរដ្ឋបាលសាធារណៈគ្រាន់តែជាវិធានការមួយប៉ុណ្ណោះ ហើយចាំបាច់ត្រូវធានាការចូលរួមពីដៃគូពាក់ព័ន្ធដូចជា វិស័យឯកជន និងសង្គមស៊ីវិលដែលចាំបាច់ត្រូវតែមានការដាក់ទណ្ឌកម្ម និងគោរពវិន័យរបស់ខ្លួន ពីព្រោះអំពើពុករលួយ គឺវាកើតឡើងដោយចរន្តនៃសកម្មភាពពីរបញ្ចូលគ្នារវាងអ្នកសូក និងអ្នកទទួលសំណូក ។

## ស្ថានភាពបច្ចុប្បន្ន

រាជរដ្ឋាភិបាល បាននឹងកំពុងខិតខំប្រឹងប្រែងបោសសំអាតការប្រព្រឹត្តអំពើពុករលួយ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយបើតាមបទពិសោធន៍នៅទូទាំងពិភពលោកបង្ហាញឱ្យឃើញថាការត្រួតពិនិត្យ និងលុបបំបាត់អំពើពុករលួយ គឺត្រូវការពេលវេលាយូរ

និងជាការងារមួយដ៏លំបាក ។ ការបង្កើនភាពហានិភ័យដល់អ្នកប្រព្រឹត្តអំពើពុករលួយគ្រាន់តែជាធាតុមួយប៉ុណ្ណោះ ហើយចំណែកឯការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិ គឺជាយន្តការមួយដ៏សំខាន់នៃយុទ្ធសាស្ត្រនេះ ។

សមិទ្ធផលជាច្រើនត្រូវសំរេចបាន ប៉ុន្តែក៏នៅតែមិនទាន់គ្រប់គ្រាន់ទៅតាមការសង្ឃឹមទុកនៅឡើយ ជាក់ស្តែងដូចជាក្នុងវិស័យព្រៃឈើ ជលផល និងការគ្រប់គ្រងដីធ្លី វិស័យអប់រំ និងសុខាភិបាល ។ បៀវត្ស និងនិយោជន៍ កំពុងត្រូវបានកែសំរួលទៅតាមសេចក្តីត្រូវការរបស់សង្គម ។ ប្រាក់បំណាច់ កំពុងត្រូវបានតម្លើងឱ្យបានលឿនតាមលទ្ធភាពថវិកាដែលមាន ប៉ុន្តែបើពឹងផ្អែកទាំងស្រុងទៅលើធនធានដែលមាន នោះវាមិនអាចបង្កើនឱ្យបានគ្រប់គ្រាន់ទេ ហើយក៏នៅមានលក្ខ័ណ្ឌជាបឋមមួយចំនួនទៀតនៃកាលានុវត្តភាព ។ គំរោងការងារជាច្រើន ដែលមានការពាក់ព័ន្ធនឹងការកែលំអតវិយាបទ និងការបង្កើនហានិភ័យដល់អ្នកប្រព្រឹត្តអំពើពុករលួយនោះគឺ:

- ច្បាប់ប្រឆាំងនឹងអំពើពុករលួយកំពុងត្រូវបានតាក់តែងសំរាប់ដាក់ឱ្យធ្វើការពិគ្រោះយោបល់មុនពេលទទួលការ អនុម័តពីគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិបញ្ញត្តិ ។ ដែនកំណត់ និងខ្លឹមសារនៃច្បាប់គឺជាប្រធានបទនៃការពិគ្រោះយោបល់ដោយតានតឹង និងយកចិត្តទុកដាក់ក្នុងកិច្ចប្រជុំអន្តរក្រសួង ហើយបែបបទនៃការអនុវត្តន៍ គឺចាំបាច់ត្រូវតែមានការឯកភាពគ្នាឱ្យបានទូលំទូលាយ និងត្រូវមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធានាដល់ការអនុវត្តន៍ឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។
- លក្ខ័ណ្ឌជាបឋម គឺត្រូវពង្រឹងការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តិ និងក្រមសីលធម៌ឱ្យមានប្រសិទ្ធិភាព ។ ការតាក់តែងច្បាប់ បទបញ្ញត្តិ និងក្រម គឺមានលក្ខណៈងាយស្រួលជាងការអនុវត្តន៍ច្រើនណាស់ ។
- ការគ្រប់គ្រងមូលនិធិសាធារណៈ កំពុងបង្កើនតម្លាភាព និងប្រសិទ្ធិភាព ជាពិសេសវិស័យសំខាន់ៗដែលមានការពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ ។ គំរោងការងារមួយចំនួនកំពុងបានដាក់ឱ្យដំណើរការ ដូចជាវិស័យ: ការធ្វើផែនការ និងត្រួតពិនិត្យថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ។
- កំពុងពង្រឹងការអនុវត្តន៍អនុក្រឹត្យស្តីពី ការធ្វើលទ្ធកម្មសាធារណៈដោយចាប់អនុវត្តក្នុងក្រសួងដែលមានកម្មវិធីសកម្មភាពជាអាទិភាព ។
- យន្តការត្រួតពិនិត្យ និងតុល្យភាព (Check and Balance) ដូចជា អាជ្ញាធរជាតិសវនកម្ម និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កំពុងត្រូវបានពង្រឹងសមត្ថភាព និងប្រតិបត្តិការ ។ អាជ្ញាធរជាតិសវនកម្ម កំពុងត្រូវបានដាក់ឱ្យដំណើរការ និងគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកមួយ ដើម្បីធានាឱ្យមានឯករាជ្យភាព និងប្រសិទ្ធិភាព ហើយកម្មវិធីដើម្បីពង្រឹងសមត្ថភាពស្ថាប័នទាំងនេះកំពុងតែអនុវត្តជាជំហានៗ ។
- ក្រមសីលធម៌របស់មន្ត្រីរាជការ និងចៅក្រម កំពុងតែរៀបចំធ្វើសេចក្តីព្រាង ហើយនិងដាក់ឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ ។
- ផែនការសកម្មភាព និងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយកំពុងតែព្រាង និងរៀបចំដាក់ឱ្យពិគ្រោះយោបល់ ។

គំរោងការងារជាច្រើន នៃកម្មវិធីកំណែទំរង់រដ្ឋបាល ដែលជួយបំពេញបន្ថែមដល់សកម្មភាពទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីជួយគាំទ្រដល់ដំណើរការសកម្មភាពនៃការប្រឆាំងអំពើពុករលួយ ជាពិសេសកំណែទំរង់បៀវត្ស និងនិយោជន៍ ហើយនិងកំណែ

ទំរង់ក្នុងការផ្តល់សេវាសាធារណៈ ។

## យុទ្ធសាស្រ្ត

អំពើពុករលួយ គឺជាបញ្ហាដែលកើតឡើងនៅតាមតំបន់ផ្សេងៗទូទាំងពិភពលោក ប៉ុន្តែអាចកាត់បន្ថយបានតាមរយៈកិច្ចសហប្រតិបត្តិការ ឱ្យបានជិតស្និទរវាងប្រទេស និងប្រទេស ។ សកម្មភាពនៃអំពើពុករលួយ គឺជាលទ្ធផលនៃកាលានុវត្តភាព ឥរិយាបទ និងហានិភ័យ ។ ដំណោះស្រាយនៃបញ្ហានេះ គឺត្រូវបង្កើតនូវយុទ្ធសាស្ត្រដែលមានលក្ខណៈប្រាកដនិយម ការចូលរួម និងត្រូវអនុវត្តមួយជំណាក់កាលម្តងៗ ប្រកបដោយចីរភាព ។

ការប្រឆាំងអំពើពុករលួយ នឹងត្រូវប្រើប្រាស់ពេលវេលាយូរប្រកបដោយក្តីលំបាកក្រៃលែង ។ គោលដៅនៃគំរោងការងារដែលត្រូវដាក់ឱ្យដំណើរការ ឬកំពុងតែរៀបចំបង្កើត មានដូចតទៅ: (១)ក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធី ត្រូវបង្កើតឡើងដោយគោរពតាមគោលការណ៍អភិបាលកិច្ចល្អ ជាពិសេសក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីទាំងឡាយណាដែលមានការពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមូលនិធិសាធារណៈ និងការផ្តល់សេវាសាធារណៈ (២)-សាធារណៈជនទូទៅ និងអ្នកប្រើប្រាស់សេវាសាធារណៈ គឺត្រូវតែយល់ដឹងអំពីក្របខ័ណ្ឌគតិយុត្តិនីតិវិធី និងសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន (៣)-មន្ត្រីរាជការក៏ត្រូវតែមានការយល់ដឹងអំពីបទប្បញ្ញត្តិទាំងនោះ និងមានសមត្ថភាពជំនាញ និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធិភាព (៤)-យន្តការត្រួតពិនិត្យត្រូវដាក់ឱ្យដំណើរការ ហើយស្ថាប័នសំរាប់ត្រួតពិនិត្យ និងតាមដានការអនុវត្តន៏ ក៏ត្រូវមានអំណាច និងប្រតិបត្តិការងាររបស់ខ្លួនឱ្យបានពេញលេញ (៥)-ត្រូវមានយន្តការមួយប្រកបដោយសច្ចធម៌ ភាពអាចប្រមាណទុកជាមុនបាន និងប្រសិទ្ធិភាព ដើម្បីផ្តន្ទាទោស និងដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តល្មើស (៦)-ត្រូវដាក់ឱ្យដំណើរការ និងផ្តល់ឱ្យបានទាន់ពេលវេលានូវថវិកាសំរាប់ប្រតិបត្តិការ និងសំភារៈឧបករណ៍ ដែលទ្រទ្រង់ដល់ការប្រតិបត្តិការងារ និង (៧)-កម្ពុជាបានទទួលនូវអត្ថប្រយោជន៏ជាច្រើន នៃកិច្ចខិតខំប្រឹងប្រែងលើឆាកអន្តរជាតិ ដូចជាអត្ថប្រយោជន៏ នៃការចូលជាសមាជិកអាស៊ាន ។

ជាក់ស្តែង ផលប្រយោជន៏នៃការចូលជាសមាជិកនេះ បាននាំឱ្យមានការយល់ដឹងអំពីបុព្វហេតុ កលល្បិច និងការជំរុញទឹកចិត្តឱ្យមានការប្រព្រឹត្តអំពើពុករលួយ ។ យុទ្ធសាស្ត្រដើម្បីប្រឆាំងអំពើពុករលួយ គឺមិនត្រឹមតែជំរុញការអនុវត្តន៏ច្បាប់ និងផ្តន្ទាទោសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកផែនការបង្ការទប់ស្កាត់ និងអប់រំដល់សង្គម។ ប្រសិនបើផ្តោតការយកចិត្តទុកដាក់តែមួយមុខទៅលើការអនុវត្តន៏ច្បាប់ នោះនឹងនាំឱ្យមានការបរាជ័យយ៉ាងពិតប្រាកដ ។ កម្មវិធី និងនីតិវិធីត្រូវតែអនុវត្តប្រកបដោយភាពងាយស្រួល និងប្រសិទ្ធិភាព ដើម្បីលុបបំបាត់របាំងនានា និងកាត់បន្ថយអំណាចឆន្ទានុសិទ្ធិ ។ ការអនុវត្តន៏ត្រូវតែគោរពទៅតាមនីតិវិធី និងគោលការណ៍សំខាន់ៗមួយចំនួនដូចជា ការអនុវត្តន៏តាមដោយស្ម័គ្រចិត្ត និងសច្ចធានិរទោស (Presumption of innocence) ។

កិច្ចសហប្រតិបត្តិការឱ្យបានទូលំទូលាយពីអ្នកពាក់ព័ន្ធទាំងអស់ គឺជាចំណុចគន្លឹះដ៏សំខាន់ដើម្បីសំរេចជោគជ័យ ហើយក៏រឹតគុណភាពនៃធនធាន នឹងកំណត់អំពីល្បឿននៃដំណើរការការងារ ។

### សកម្មភាពសំរាប់រយៈពេលខ្លីរួមមាន:

- ការបញ្ចប់នូវការតាក់តែងផែនការសកម្មភាពអភិបាលកិច្ចទី២ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយ

ដៃគូពាក់ព័ន្ធ

- បង្កើតយុទ្ធសាស្ត្ររួមសំរាប់ប្រឆាំងអំពើពុករលួយដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
- អនុម័ត និងអនុវត្តលិខិតបទដ្ឋានសំខាន់ៗ រួមទាំងការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ និងក្រមសីលធម៌
- បង្កើតការិយាល័យបណ្តឹងសាធារណៈ (Ombudsman Office) ដើម្បីការពារផលប្រយោជន៍ និងសិទ្ធិអ្នកប្រើប្រាស់សេវាសាធារណៈដែលតម្រូវឱ្យមានការចូលរួមពីដៃគូពាក់ព័ន្ធ
- ផ្តល់ភាពងាយស្រួល និងដំណើរការការផ្តល់សេវាតាមរយៈប្រព័ន្ធពតិមានវិទ្យា ដើម្បីបង្កើនតម្លាភាព ការឆ្លើយតបទាន់ពេលវេលា និងការទទួលខុសត្រូវខ្ពស់ ហើយនិងកាត់បន្ថយឱកាសក្នុងការប្រព្រឹត្តអំពើពុករលួយ
- ពង្រឹងការគ្រប់គ្រងចំណាយ និងដំណើរការលទ្ធកម្មសាធារណៈ ដោយអនុវត្តឱ្យបានទូលំទូលាយនូវគោលការណ៍តម្លាភាព តម្លៃនៃសាច់ប្រាក់ និងភាពត្រឹមត្រូវ ហើយនិងការអនុវត្តន៍ឱ្យបានគត់មត់ ជាពិសេសក្នុងក្រសួងដែលអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព
- បន្តការឃោសនាផ្សព្វផ្សាយអំពីពតិមាននៃការប្រព្រឹត្តអំពើពុករលួយ និងផលប៉ះពាល់
- សកម្មភាពរយៈពេលមធ្យម នឹងត្រូវផ្តោតទៅលើគំរោងការងារមួយចំនួនដូចជាៈ អនុវត្តកម្មវិធីពង្រឹងសមត្ថភាពដើម្បីធានានូវនិរន្តរភាពនៃការខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយក្នុងរដ្ឋបាលសាធារណៈ, បន្តការអភិវឌ្ឍន៍ និងពង្រឹងអំណាចតាមប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពក្នុងការប្រឆាំងអំពើពុករលួយជាពិសេស ពង្រឹងសមត្ថភាពអាជ្ញាធរសវនកម្មជាតិ
- ចូលរួមឱ្យបានពេញលេញក្នុងវេទិកាអន្តរជាតិ ស្តីពីការប្រឆាំងអំពើពុករលួយ
- អនុវត្តកម្មវិធីពង្រឹងការតាក់តែងច្បាប់ និងលិខិតបទដ្ឋាន និងការអនុវត្តន៍
- សម្របសម្រួលការអនុម័តក្រមប្រឆាំងអំពើពុករលួយជាមួយដៃគូពាក់ព័ន្ធខាងក្រៅ ។

## ៤.៥ ការកាត់បន្ថយភាពងាយរងគ្រោះ និងការពង្រឹងការចូលក្នុងសង្គម

ការកាត់បន្ថយភាពងាយទទួលរងគ្រោះនៃជនក្រីក្រ គឺទាក់ទងទៅនឹងទិដ្ឋភាពដោយឡែកៗពីគ្នា ។ ការកើនឡើងនូវការគ្រប់គ្រងបរិស្ថាន និងការកែលំអធនធានធម្មជាតិគឺជាទំហំគន្លឹះមួយ ។ ការគ្រប់គ្រងគ្រោះមហន្តរាយ ជាពិសេសការប្រឈមមុខគ្រោះទឹកជំនន់ជារឿងសំខាន់របស់អ្នកក្រីក្រនៅជនបទ ។ នៅប្រទេសកម្ពុជាការបោសសំអាតមីនដោយសារសង្គ្រាមស៊ីវិលជាច្រើនឆ្នាំក៏ជាកត្តាចាំបាច់ដែរ ។ ជាពិសេសក្រុមអ្នកងាយរងគ្រោះ ហើយដែលក្នុងនោះមានជនពិការផង ក្រុមអ្នកងាយរងគ្រោះទាំងនេះមាន កុមារកំព្រា ក្មេងអនាថា កុមារដែលត្រូវគេបោះបង់ចោល និងជនអនាថាបានទទួលផលប៉ះពាល់ដោយមេរោគអេដស៍ ។ កម្មវិធីសុវត្ថិភាពសង្គមត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងបញ្ហានេះ ក៏ប៉ុន្តែវាអាស្រ័យលើថវិកា និងសមត្ថភាពការងារ ។ ហើយសន្តិសុខស្បៀងអាហារ ក៏ជាបញ្ហាដ៏សំខាន់ដែរដែលរាជរដ្ឋាភិបាលបានគិតគូរបំផុត ។ នៅក្នុងផ្នែកនេះមានបង្ហាញពីគោលនយោបាយ, យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពដែលនឹងធ្វើការដោះស្រាយរាល់បញ្ហាពាក់ព័ន្ធទាំងនោះ ។

### ៤.៥.១ សន្តិសុខស្បៀង

សន្តិសុខស្បៀងកើតមាននៅពេលដែលមនុស្សទាំងអស់ មានទូវសំភារៈជារូបវន្តផ្នែកសង្គម និងសេដ្ឋកិច្ច គ្រប់ពេលវេលា ដើម្បីទទួលបានស្បៀងអាហារដែលមានជីវជាតិនិងសុវត្ថិភាពគ្រប់គ្រាន់តាមសេចក្តីត្រូវការនៃការហូបចុក និងអាហារតាមចំណង់ ចំនូលចិត្តសំរាប់ការរស់នៅនៃជីវភាពសុខសាន្តប្រកបដោយសុខភាពមាំទាំ ។

កម្ពុជា គឺជាប្រទេសមួយដែលពឹងផ្អែកលើសលប់ទៅលើកសិកម្ម ដែលមាន ៩៥%នៃប្រជាជនក្រីក្ររស់នៅតាមជនបទ។ ដូច្នេះ សន្តិសុខស្បៀង និងភាពក្រីក្រមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធដូចបានលើកឡើងនៅ ក្នុងការចូលរួមវាយតំលៃភាពក្រីក្រ (PPA) ដឹកនាំដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលកំណត់ថាជាកង្វះខាតអាហាររូបត្ថម្ភជាលក្ខណៈចំបងរបស់កសិករជនបទ របស់ជនក្រីក្រ (សូមមើលជំពូកទី៣)។ អ្នកចូលរួមការវាយតំលៃលើភាពក្រីក្រនៅគ្រប់ទីកន្លែងបានអោយនិយមន័យយ៉ាងច្បាស់ ថា ភាពក្រីក្រ គឺការអត់ឃ្លានមានជាប្រចាំដែលអ្នកក្រមិនអាចគេចផុត លើកលែងតែពេលខ្លះប៉ុណ្ណោះ។ ដោយសារតែសេចក្តី ស្រេកឃ្លាននេះ ពួកគេមិនអាចបំពេញបាននូវសេចក្តីត្រូវការចាំបាច់ផ្សេងទៀតរបស់ពួកគេ ដូចជាការបញ្ជូនកូនអោយចូលរៀន ការចំណាយលើការថែរក្សាសុខភាព និងការបំពេញកាតព្វកិច្ចវប្បធម៌។

### លទ្ធភាពស្បៀងអាហារ

ស្រូវអង្ករ គឺជាកត្តាគន្លឹះមួយសំរាប់សន្តិសុខស្បៀងនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាមានការខ្វះខាតផលិតកម្មស្រូវ ដ៏ធ្ងន់ធ្ងរនៅទសវត្សឆ្នាំ ១៩៨០ និង ដើមទស្សវត្សឆ្នាំ១៩៩០ ក៏ដោយក៏ផលិតកម្មនេះត្រូវបានកែលំអជាបន្តបន្ទាប់ ហើយយើង អាចរក្សាបានអតិរេកភាពចាប់តាំងពីឆ្នាំ១៩៩៥-៩៦ ដែលផលិតកម្មស្រូវបានកើនឡើងគួរអោយកត់សំគាល់ដែលបានរួមចំណែក ដល់ការកើនឡើងយ៉ាងលឿននៃទិន្នផល។ ទោះបីជាកម្ពុជាបានទទួលរងគ្រោះធម្មជាតិដ៏ធ្ងន់ធ្ងរនៅក្នុងកំឡុងពេល ៦-៧ ឆ្នាំកន្លង ទៅនេះ ក៏ផលិតផលស្រូវប្រចាំឆ្នាំបានកើនឡើងពី ៣.៥ ទៅ ៤លានតោន ដែលផ្តល់អតិរេកភាពពី ៣០.០០០ លានតោន នៅក្នុងឆ្នាំ ១៩៨៨-៨៩ ដល់ទៅ ២៦០.៧០០ លានតោន ក្នុងឆ្នាំ ១៩៩៩-២០០០ ។ នេះបង្ហាញថាសន្តិសុខស្បៀងកម្ពុជា ក្នុងកំរិតជាតិសរុបអាចផ្គត់ផ្គង់បានយ៉ាងហោចណាស់ក៏ក្នុងរយះពេលមធ្យមដែរ។

ក៏ប៉ុន្តែដូចបានចង្អុលបង្ហាញខាងលើ សន្តិសុខស្បៀងទាក់ទងទៅនឹងអន្តរកម្មដ៏ស្មុគស្មាញមួយនៃកត្តាជាច្រើន ហើយ ឆ្ងាយហួសពី ត្រឹមតែផលិតកម្មកសិកម្ម។ ការមានស្រូវគ្រប់គ្រាន់នៅកំរិតថ្នាក់ជាតិ គឺមិនមែនមានន័យថាប្រជាជនកម្ពុជាគ្រប់រូប មានស្រូវគ្រប់គ្រាន់សំរាប់បរិភោគនោះឡើយ ជាពិសេសអ្នកក្រីក្របំផុតនិងក្រុមងាយទទួលរងគ្រោះនៅតាមតំបន់ជនបទ ។ ខណៈពេលដែលកសិករនៅក្នុងតំបន់មួយចំនួនផលិតស្រូវបានលើសពីសេចក្តីត្រូវការឯអ្នកខ្លះទៀតទទួល រងនូវកង្វះខាតស្បៀង យ៉ាងធ្ងន់ធ្ងរ ។ ការសិក្សាថ្មីៗនេះមួយបង្ហាញថា នៅក្នុងខេត្តផលិតស្រូវធំៗ ៣០% នៃឃុំទាំងអស់ប្រឈមមុខនឹងកង្វះខាត ស្បៀងអាហារជាប្រចាំ ។ ផលិតផលកសិកម្មដែលកំនត់លទ្ធភាពទទួលស្បៀងអាហារនោះក៏ត្រូវបានរារាំងផងដែរដោយសារកង្វះ ប្រពន្ធ័ធារាសាស្ត្រ ការកាន់កាប់ដីធ្លីមានទំហំតូច ដីគ្មានជីជាតិ សេវានៃការផ្សព្វផ្សាយវិស័យកសិកម្មនៅមានកំរិត និងផលិតផល កសិកម្មមានកំរិតទាប។

## ការទទួលបានស្បៀងអាហារ

សំរាប់អ្នករស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ ចំណាយរបស់ពួកគេមិនគ្រប់គ្រាន់សំរាប់ការទទួលបានស្បៀងអាហារ ដែលមាន ២១០០ កាឡូរី សំរាប់មនុស្ស១នាក់ ដែលត្រូវបានទទួលស្គាល់ជាបទដ្ឋានអន្តរជាតិ និងកំនត់ដោយអង្គការសុខភាព ពិភពលោក (WHO)។ ពួកគេពុំមានលទ្ធភាពទិញស្បៀង ហើយជារឿយៗមានបំណុលច្រើន និងខ្វះការទទួលបាននូវឥណទាន គ្រប់គ្រាន់ ដូច្នេះហើយ ទោះជាស្បៀងអាហារអាចរកបានក៏ដោយ ក៏អ្នកក្រីក្រមិនអាចមានមធ្យោបាយ ដើម្បីទទួលបាននូវស្បៀង ទាំងនោះទេ។ ការទទួលបានស្បៀងអាហារ ក៏ត្រូវបានរាំងដោយសារប្រពន្ធ័ទីផ្សារខ្សោយ អស្ថិរភាពតំលៃទីផ្សារ ហេដ្ឋារចនា សម្ពន្ធ័គមនាគមន៍ និងគមនាគមន៍នៅទន់ខ្សោយ ឱកាសទទួលបានការងារធ្វើស្រែចំការមានកំរិត និងការវិនិយោគទុនទាប។ ស្ថានភាពដ៏អាក្រក់ទាំងនោះ បានធ្វើអោយគ្រួសារកសិករក្រីក្រជាច្រើនកាន់តែមានភាពដុនដាបថែមទៀត ដែលពួកគេបាន ទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារទឹកជំនន់ក្នុងឆ្នាំ ២០០០ និងទទួលរងគ្រោះរាំងស្ងួត និងទឹកជំនន់ក្នុងឆ្នាំ ២០០១ ហើយបន្ត ទទួលរងគ្រោះធម្មជាតិក្នុងឆ្នាំ ២០០២ ទៀត។ ជាងនេះទៀត សមាជិកគ្រួសារដែលកំពុងតែកើនឡើងវាជាប្រភពនៃការកើនឡើង នូវអសន្តិសុខស្បៀង ដែលនឹងធ្វើអោយហិនហោចដល់ផលនេសាទ និងព្រៃឈើទៀតផង។

## ការប្រើប្រាស់ស្បៀងអាហារ

ស្បៀងអាហារជាមូលដ្ឋានរបស់ប្រជាជនកម្ពុជាគឺ បានមកពីស្រូវអង្ករដែលផ្តល់ ៦៨% នៃតំរូវការកាឡូរីប្រចាំថ្ងៃ ហើយចំណែកនៅសល់ គឺទទួលបានពីត្រី សាច់ មើម បន្លែ ផ្លែឈើ និងម្ហូបដ៏ទៃទៀត។ កង្វះរបបស្បៀងអាហារ គឺជាកត្តាមួយ ក្នុងចំណោមកត្តាជាច្រើន ដែលរួមចំណែកអោយមានកើនឡើងកំរិតខ្ពស់នូវការកង្វះអាហារូបត្ថម្ភ និងមីក្រូសារជាតិនៅក្នុង ប្រទេស (សូមមើលអាហារូបត្ថម្ភផ្នែក 4.3.2)។ កត្តារួមចំណែកផ្សេងទៀតរួមមានកំរិតការអប់រំទាប (ជាពិសេសសំរាប់ស្ត្រី និង ក្មេងស្រី) មានចំណេះដឹងតិចតួច ភាពទន់ខ្សោយក្នុងការអនុវត្តន៍ធ្វើអោយមានសុខភាព និងអាហាររូបត្ថម្ភល្អ ការថែទាំកូនមិន ដិតដល់ និងការឈប់បំបៅដោះកូនក្នុងរយៈពេលមិនសមស្រប លទ្ធភាពចំលងរោគមានអត្រាខ្ពស់ និងកង្វះខាតនៃការលទ្ធភាព ទទួលបាននូវហេដ្ឋារចនាសម្ពន្ធ័ និងសេវាថែរក្សាសុខភាពសាធារណៈជាមូលដ្ឋាន (DHS 2000)។ កង្វះខាតអាហាររូបត្ថម្ភ និងការអប់រំសុខភាព ជាពិសេសវាជាឧបសគ្គដ៏ធំបងដែលជះឥទ្ធិពលទៅលើស្ថានភាពអាហាររូបត្ថម្ភខ្សត់ខ្សោយរបស់ក្រុមដែល ងាយរងគ្រោះ។

## គោលនយោបាយ និង យុទ្ធសាស្ត្រដើម្បីធានាសន្តិសុខស្បៀង

រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវជំរុញសន្តិសុខស្បៀងសំរាប់ប្រជាជនកម្ពុជាគ្រប់រូបនៅគ្រប់កំរិត (ថ្នាក់ជាតិ សហគមន៍ និងគ្រួសារ) និងកាត់បន្ថយភាពស្គមស្គាំងក្នុងចំណោមស្ត្រី និងកុមារ ដូច្នេះយុទ្ធសាស្ត្រទាំងអស់ ដើម្បីអោយមានប្រសិទ្ធិភាពដល់ បញ្ហាសន្តិសុខស្បៀងសំរាប់អ្នកក្របំផុត ត្រូវតែយកចិត្តទុកដាក់ទៅលើកិច្ចខំប្រឹងប្រែងសំរបសំរួល និងរួបរួមគ្នា (សហការណ៏គ្នា) ដើម្បីរកមូលហេតុនៃភាពងាយទទួលរងគ្រោះ និងធ្វើការកែលំអអោយមានស្បៀងអាហារ ការទទួលបានស្បៀងអាហារ និងការប្រើប្រាស់អាហារគ្រប់គ្រាន់។

នៅក្នុងន័យនេះជំនួយស្បៀងអាហារដើរតួនាទីយ៉ាងសំខាន់ ដែលវាអាចជួយបំពេញសេចក្តីត្រូវការម្ហូបអាហារជាមធ្យម របស់ក្រុមដែលងាយរងគ្រោះបំផុតបានទាន់ពេលវេលា ដែលក្នុងខណៈនេះដើម្បីអោយពួកគេអាចចូលរួមក្នុងសកម្មភាពជាច្រើន ដែលនឹងជួយកែលំអសមត្ថភាពស្បៀងសំរាប់រយៈពេលវែង។ ឧទាហរណ៍ នេះមានន័យថាការវិនិយោគលើផ្នែកធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបំពាក់បំប៉ន់ការអប់រំ ឬការបង្កើតអោយមានទ្រព្យសម្បត្តិសហគមន៍ តាមរយៈស្បៀង ពលកម្មដើម្បីគាំទ្រសកម្មភាពជាច្រើនដូចជា ការកសាង និងស្តារឡើងវិញនូវផ្លូវថ្នល់ ស្រះទឹក ប្រឡាយទឹក សាលារៀន ឬ ក៏មជ្ឈមណ្ឌលសុខភាព។ ដើម្បីធានាបានសន្តិសុខស្បៀងគ្រួសារ ត្រូវធ្វើការពិនិត្យអោយបានច្បាស់លាស់ចំពោះស្ត្រីបានចូលរួម យ៉ាងសកម្ម និងទទួលបាននូវផលប្រយោជន៍ ដែលធានាបានតំរូវការសន្តិសុខស្បៀង ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ដែលជាក្រុមងាយទទួលរងគ្រោះគឺត្រូវបានផ្តល់ការយកចិត្តទុកដាក់ជាអាទិភាព (ឧទាហរណ៍ តាមរយៈកម្មវិធីជាគោលដៅ ដូចជាកម្មវិធីពិសេសស្តីអំពីសន្តិសុខស្បៀង)។

ការធ្វើអោយប្រសើរឡើងនូវសន្តិសុខស្បៀង រាជរដ្ឋាភិបាលកម្ពុជាបានកំនត់យុទ្ធសាស្រ្ត ដូចខាងក្រោម៖

- **បង្កើនលទ្ធភាពស្បៀងអាហារ** (ក្រសួងកសិកម្ម ,ធនធានទឹក , កិច្ចការនារីៈ សូមមើលផ្នែក ៤.១.២ និង ៤.៥.៤)។
- **កែលំអការទទួលបានស្បៀងអាហារ** (ក្រសួងកសិកម្ម ,អភិវឌ្ឍន៍ជនបទ, ដែនដីនគរូបនីយកម្ម, ពាណិជ្ជកម្ម និង កិច្ចការនារីៈ សូមមើលផ្នែក ៤.១.២, ៤.២ និង ៤.៣)។
- **ការប្រើប្រាស់ស្បៀងអាហារប្រសើរជាងមុន** (ក្រសួងអប់រំ ,សុខាភិបាល, អភិវឌ្ឍន៍ជនបទ និងកិច្ចការនារីៈ សូមមើលផ្នែក ៤.១, ៤.២, ៤.៣, ៤.៥ និង ៤.៦ )។

## ៤.៥.២ កិច្ចការពារសង្គម និងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស

បច្ចុប្បន្ន អំពើហិង្សាក្នុងគ្រួសារនៅតែបន្តកើតឡើង ដែលជាការគំរាមកំហែងមួយចំពោះស្ត្រីកម្ពុជា ។ តាមការស្រាវជ្រាវឆ្នាំ ១៩៩៦ បានបង្ហាញថាអំពើហិង្សាទៅលើស្ត្រីក្នុងគ្រួសារជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ដែលស្ត្រីមួយចំនួនធ្លាប់ទទួលរង។ ពេលដែលជួបការលំបាកក្នុងការកំនត់គ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ កត្តាចង្អុលបង្ហាញមួយចំនួនបញ្ជាក់ថាករណីមួយចំនួនកំពុងតែកើនឡើង ។ បញ្ហានេះក៏កាត់បន្ថយផងដែរនូវសុខុមាលភាព និងផលិតភាពរបស់គ្រួសារ ។ អ្នកស្រាវជ្រាវវិទ្យាសាស្រ្តសង្គមជឿថា លទ្ធភាពមិនបានទទួលស្មើគ្នាចំពោះសុខភាព និងទំនិញ ការធ្វើមិនអោយសំរេចបានដោយសារការប្រកួតប្រជែកផ្នែកសេដ្ឋកិច្ច បានបង្ខំអោយស្វែងរកប្រាក់ចំណូលខ្ពស់ និន្នាការផ្លាស់ប្តូរកន្លែងធ្វើការងារ និងធ្វើអោយការប្រើប្រាស់សារធាតុញៀនកើនឡើង ដែលជាកត្តាជំរុញអោយមានអំពើហិង្សាក្នុងគ្រួសារ ។ ភាពក្រីក្រ ប្រាក់កាស ការងារសមស្របមានកំរិត និងការកើនឡើងនៃតំលៃទំនិញមូលដ្ឋាន និងសេវាកម្មនានា វាជាបន្ទុកបន្ថែមទៀតទៅលើរចនាសម្ព័ន្ធគ្រួសារ និងសង្គមដែលកំពុងតែមានលក្ខណៈយ៉ាប់យឺនស្រាប់ទៅហើយ ។

ការចាប់រំលោភលើស្ត្រីភេទគឺជាអំពើរំលោភលើសិទ្ធិរបស់ពួកគេ ដែលបណ្តាលអោយមានស្លាកស្នាមឈឺចាប់ផ្លូវចិត្ត និងជំរុញអោយពួកគេប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ ។ អំពើហិង្សាក្នុងគ្រួសារ និងការគំរាមកំហែងពីដៃគូរួមភេទ ធ្វើអោយអន្តរាយដល់ស្ថានភាពស្ត្រី និងធ្វើអោយពួកគេបាត់បង់លទ្ធភាពក្នុងការជជែក ដើម្បីអោយប្រើប្រាស់ស្រោមអនាម័យ ។ អំពើហិង្សាក្នុងគ្រួសារធ្វើអោយមានការចំណាយខ្ពស់សំរាប់គ្រួសារ សហគមន៏ និងរដ្ឋ និងជាឧបសគ្គដ៏ធ្ងន់ធ្ងរដល់កិច្ចអភិវឌ្ឍន៏ ។ ការងារស្ត្រីគឺជាការងារមួយដ៏សំខាន់ចំពោះការរស់រាននៃគ្រួសារកម្ពុជា ប្រាក់ចំណូលគ្រួសារជួបការលំបាកនៅពេលដែលស្ត្រីគ្មានសមត្ថភាព ។ ការអប់រំសំរាប់កូនជួបការលំបាក ដោយសារមានប្រាក់បន្តិចបន្តួចសំរាប់ចំណាយលើសាលារៀន រឺក៏ដោយសារកូនទាំងនោះរ៉ាប់រងបន្ទុកការងាររបស់ម្តាយ ។ ជាងនេះទៅទៀត អំពើហិង្សាក្នុងជំនាន់មួយនឹងតែងតែបន្តទៅជំនាន់ក្រោយៗទៀត ។

ការជួញដូរមនុស្សគឺជាកត្តាដ៏សំខាន់មួយទៀត ដែលធ្វើអោយមានភាពងាយរងគ្រោះ ។ ប្រទេសកម្ពុជាជាប្រទេសមួយដែលសំរាប់បញ្ជូនទទួល និងសំចតបណ្តោះអាសន្នសំរាប់ការជួញដូរស្ត្រី និងកុមារ ។ តាមការប៉ាន់ស្មានមានស្ត្រីកម្ពុជាចំនួន ៨៨,000នាក់ ត្រូវគេជួញដូរក្នុងប្រទេសថៃ និងចន្លោះពី៤0 ទៅ៦0ភាគរយនៃអ្នករកស៊ីផ្លូវភេទ (១៤,000នាក់)ក្នុងប្រទេសកម្ពុជាបាននិយាយថា ពួកគេត្រូវបានបង្ខិតបង្ខំ រឺបោកប្រាស់ក្នុងមុខជំនួញ ។ មានកុមារីក្មេងៗផ្សេងទៀតក៏ធ្លាក់ខ្លួនក្នុងឧស្សាហកម្មផ្លូវភេទ ដោយពួកគេគ្មានផ្លូវជ្រើសរើស ។ ភាពក្រីក្រ ចលនានៃសង្គម ហេដ្ឋារចនាសម្ព័ន្ធស្របច្បាប់មិនទាន់អភិវឌ្ឍន៏ និងការអនុវត្តច្បាប់នៅខ្សោយគឺជាបច្ច័យអាក្រក់ដល់ការរីកដុះដាលយ៉ាងលឿននៃឧស្សាហកម្មផ្លូវភេទ និងការជួញដូរស្ត្រី និងកុមារ ។ យេនឌ័រប៉ះពាល់យ៉ាងខ្លាំងដល់កំរិតគ្រោះថ្នាក់ និងប្រឈមមុខនឹងជំងឺអេដស៏ ដូចជាស្ត្រីដែលត្រូវគេជួញដូរត្រូវបានគេបោកបញ្ឆោត រឺបង្ខំអោយធ្លាក់ក្នុងស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទ ។

## គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់កិច្ចការពារសង្គម និងការប្រយុទ្ធនឹងការជួញដូរមនុស្ស

យុទ្ធសាស្ត្រដោះស្រាយការជួញដូរត្រូវការការប្រឈមមុខយ៉ាងច្រើន ទាក់ទងទៅនឹងកត្តា "រុញ " និង "ទាញ" ។ ច្បាប់នឹងត្រូវបានពង្រឹង និងបង្ខំអោយមានប្រសិទ្ធិភាព ។ កិច្ចព្រមព្រៀងមួយនឹងត្រូវបានបង្កើតឡើងជាមួយប្រទេសវៀតណាមប្រហាក់ប្រហែលនឹងកិច្ចព្រមព្រៀងជាមួយប្រទេសថៃដែរ ដើម្បីសំរេចបាននូវវិធីសាស្ត្រទូទៅមួយចំពោះបញ្ហាជួញដូរឆ្លងកាត់ទល់ដែន ។ អាជ្ញាធរមានសមត្ថកិច្ចនឹងត្រូវបានអប់រំទាំងច្បាប់ និងភាពម៉ឺងម៉ាត់/លទ្ធភាពជំរុញ និងក្នុងករណីមានជនរងគ្រោះត្រូវអនុវត្តតាមលក្ខណៈសមស្រប ។ ស្ត្រី និងកុមារីនឹងមិនត្រូវរងគ្រោះទ្វេឡើង ។ យុទ្ធនាការបង្កើនការយល់ដឹងដឹកនាំដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សហការជាមួយអង្គការ IOM នឹងត្រូវបានពង្រីក ។ តួនាទីរបស់នគរបាលក្នុងការតាមដានបទឧក្រិដ្ឋ គ្រប់គ្រងការជួញដូរ ដោយរួមមានប្រតិបត្តិការឆ្លងដែនរបស់ពួកគេនឹងត្រូវបានពង្រឹង ។ ជាចុងក្រោយយ៉ាងណាក៏ដោយការចូលរួមចំណែកយ៉ាងសំខាន់បំផុត នឹងត្រូវបានបង្កើតឡើងដោយដោះស្រាយភាពក្រីក្រ ដែលជាគោលការណ៏កត្តា " រុញ " ខាងក្រោយការជួញដូរ ។

## ៤.៥.៣ ជំងឺហ៊ីវ/អេដស៍

ភាពក្រីក្រជាប់ទាក់ទិនយ៉ាងជិតស្និទ្ធទៅនឹងមេរោគ/ជំងឺអេដស៍ទៅតាមរបៀបពីរយ៉ាង ។ ជនដែលក្រីក្រ ងាយទទួលរងគ្រោះនូវការឆ្លង ចំពោះសកម្មភាពប្រឈមមុខ ។ គេហាក់ដូចជាទទួលបានតិចតួចនូវការផ្សព្វផ្សាយពីរបៀបដែលត្រូវការពារខ្លួន និងមានឱកាសតិចតួចក្នុងការប្រើប្រាស់សេវាសុខភាព និងសេវា ប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ ។ ក្នុងពេលជាមួយគ្នានេះ មេរោគ/ជំងឺអេដស៍កំពុងតែមានឥទ្ធិពល ទៅលើការរីកលូតលាស់នៃសេដ្ឋកិច្ចរបស់ប្រទេស បណ្តាលឱ្យមានការបាត់បង់ផលលិតកម្ម និងការបងខាត់ ។ អ្នករស់នៅតាមជនបទ ក្រីក្រជាងអ្នករស់នៅតាមទីក្រុង និងទទួលផលប៉ះពាល់ច្រើនជាងដោយកង្វះខាត នូវឱកាសប្រើប្រាស់សេវាសុខភាព និងការធ្វើវិមជ្ឈការមិនគ្រប់គ្រាន់នៃសេវានិងការធ្វើវិមជ្ឈការមិនគ្រប់គ្រាន់របស់រដ្ឋាភិបាល ។

ជាពិសេសស្ត្រីងាយទទួលរងការឆ្លងមេរោគអេដស៍នៅពេលដែលទំនាក់ទំនងនៃយេនឌ័រ បង្កើតជាចំណែកទំនាក់ទំនងដ៏ទូលំទូលាយក្នុងសង្គម ដែលជាទំនាក់ទំនងដ៏មានសារៈសំខាន់នៃអំណាចរវាងបុរសនិងស្ត្រី ។ ជាទូទៅ វិសមភាពយេនឌ័រជំរុញឱ្យមានការរាតត្បាតនៃមេរោគអេដស៍នៅកម្ពុជា ។ ចំពោះស្ត្រីការប្រឈម មុខនិងភាពងាយរងគ្រោះនៃការឆ្លងមេរោគអេដស៍បានកើនឡើងទៅតាមបទដ្ឋានមិនសមស្របសំរាប់ស្ត្រីស្តីពីការរួមភេទឬការស្នើសុំប្រើប្រាស់ស្រោមអនាម័យ ។ ចាប់តាំងពីមានមួយករណីនៅឆ្នាំ ១៩៩២ គេបានប្រមាណនៅក្នុងចំណោមប្រជាជន១១លាននាក់ ប្រទេសកម្ពុជាឥឡូវនេះមានអ្នកផ្ទុកមេរោគអេដស៍ ចំនួន១៦៩.០០០នាក់ ។ នៅក្នុងចំណោមប្រជាជនពេញវ័យ ១៥-៤៩ឆ្នាំអត្រាប្រេវ៉ាឡង់ដែលបានប៉ាន់ប្រមាណបានបង្ហាញឱ្យឃើញថាមានការថយចុះចាប់ពី៣.៩% នៅឆ្នាំ ១៩៩៧ដល់២.៦%នៅឆ្នាំ២០០២ ។ ការឆ្លើយតបទៅនឹងមេរោគ/ជំងឺអេដស៍នៅកម្ពុជាបានពឹងផ្អែកទៅលើការយល់ដឹងដ៏ប្រសើរនៃការរាតត្បាតនិងការស្គាល់កាន់តែកើនឡើង នៃផលប៉ះពាល់ទៅលើសន្តិសុខអភិវឌ្ឍន៍សេដ្ឋកិច្ចនិងស្ថេរភាពជាតិ ។ មេរោគ/ជំងឺអេដស៍កំពុងតែទទួលបាននូវការយកចិត្តទុកដាក់ជាអាទិភាពពីរដ្ឋាភិបាល អង្គការមិនរដ្ឋាភិបាល ដៃគូដែលនៅខាងក្រៅ ។ អត្រាខ្ពស់នៃការរីកលូតលាស់នៃមេរោគ/ជំងឺអេដស៍ ជាការបារម្ភយ៉ាងខ្លាំង ។ ចាប់តាំងពីឆ្នាំ១៩៩៨ ២.៤% នៃស្ត្រីមានផ្ទៃពោះ ៤២.៦%នៃស្ត្រីរកស៊ីផ្លូវភេទ និង១៩.១%នៃស្ត្រីរកស៊ីផ្លូវភេទប្រយោលបានឆ្លងមេរោគអេដស៍ ។ ស្ត្រីជាអ្នកទទួលខុសត្រូវទី១ក្នុងការថែទាំសមាជិកគ្រួសារដែលមានផ្ទុក/កើតជំងឺអេដស៍ក៏ដូចគ្នា ដែរចំពោះអ្នករងគ្រោះដោយសារមីន ពិការភាពនិងជំងឺដ៏ទៃទៀត ។ ភាពងាយរងគ្រោះនៃការឆ្លងមេរោគអេដស៍ជាពិសេស ចំពោះស្ត្រី កើតចេញពីឥទ្ធិពលនៃកត្តាសង្គមវប្បធម៌ សេដ្ឋកិច្ច និងនយោបាយ ។កត្តាទាំងអស់នេះ រួមបញ្ចូលទាំងការរើសអើង ការស្អប់ខ្ពើមក្រុមប្រជាជនខ្លះ ដូចជាស្រីរកស៊ីផ្លូវភេទ អ្នកផ្ទុកមេរោគអេដស៍ អនក្ខរជន អ្នកកង្វះនិងអ្នកគ្មានការអប់រំស្តីពីជំងឺកាមរោគ /ជំងឺអេដស៍ ។ ចាប់តាំងពីសង្គ្រាមស៊ីវិលមក មានការបែកបាក់នៅក្នុងសង្គមការឃ្លាតឆ្ងាយពីគ្នានៅក្នុងគ្រួសារ បុរសចាំបាច់ត្រូវតែស្វែងរកការងារបន្ថែម ឬការងារបណ្តោះអាសន្ន ។ នៅក្នុងការផ្លាស់ប្តូរយ៉ាងឆាប់ រហ័សពីសេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារសេរី ប្រជាជនជាច្រើនកំពុងតែផ្លាស់ប្តូរទីនៅក្នុងប្រទេសនិងឆ្លងកាត់ព្រំដែនដើម្បីស្វែងរកការងារដែលល្អប្រសើរ ។

## គោលនយោបាយនិងយុទ្ធសាស្ត្រដើម្បីការពារនិងលប់បំបាត់មេរោគនិងជំងឺអេដស៍

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានតួនាទីរៀបចំគោលនយោបាយ ពង្រឹងទំនាក់ទំនងរវាងដៃគូរ សំរបសំរួលការឆ្លើយតបជាពហុវិស័យ ចលនាប្រភពធនធានចាប់តាំងពីស្ថាប័នជាតិអន្តរជាតិ ស្វែងរកការគាំទ្រ ផ្លូវច្បាប់និងស្រាវជ្រាវនូវផលប៉ះពាល់ទៅលើសង្គមសេដ្ឋកិច្ចនៃមេរោគនិងជំងឺអេដស៍ សំរបសំរួល នូវរបៀប វិរៈនៃការស្រាវជ្រាវ ពិនិត្យឡើងវិញនិងផ្តល់នូវសច្ចានុម័តទៅលើកម្មវិធីផ្សព្វផ្សាយ(IEC )ពីគ្រប់ស្ថាប័នបន្ថយនូវភាពងាយទទួលរងគ្រោះថ្នាក់នៃការឆ្លង មេរោគ/ជំងឺអេដស៍នៃស្ត្រីនិងក្មេងស្រីនិងលើកស្ទួយនូវស្ថានភាពរបស់គេ ដោយខិតខំបន្ទូរបន្ថយនូវអត្តចារិករើសអើងមានប្រៀបលើនៅក្នុងសង្គមជាពិសេសនៅ ក្នុងចំណោមបុរស។ ដើម្បីការពារមេរោគ/ជំងឺអេដស៍ គេត្រូវតែយល់ថា ការអប់រំនិងពិតមានជាសាធារណៈមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើចំណេះដឹងស្តីអំពីមេរោគ/ជំងឺអេដស៍នៅក្នុងចំណោមប្រជាជនកម្ពុជា ។ ប្រជាជនកាន់តែច្រើនឡើងមានការយល់ដឹងអំពីមេរោគ/ជំងឺអេដស៍ ប៉ុន្តែការផ្លាស់ប្តូរនូវការប្រព្រឹត្តិនៅក្នុងចំណោមប្រជាជនខ្លះនៅតែមានកំរិត។ បញ្ហានេះឋិតនៅលើ កម្មវិធីដែលមានលក្ខណៈពិសេសសំរាប់ក្រុមប្រជាជននិមួយៗទាំងនោះដូច្នេះវិធីសាស្ត្រសមស្របនឹងត្រូវបានគេយកមកប្រើសំរប់ប្រជាជនគោលដៅផ្សេងៗគ្នានេះ។ ការអប់រំសុខភាពត្រូវតែធ្វើទៅតាមកំរិតចំណេះដឹងទូទៅរាប់បញ្ចូលទាំងការផ្សព្វផ្សាយតាមប្រព័ន្ធ ចំណែកឯយុទ្ធសាស្ត្រដែលទាក់ទងទៅនឹងការផ្លាស់ប្តូរការប្រព្រឹត្តិគួរតែផ្តោតទៅលើជនណា ដែលកំពុងតែមានការប្រព្រឹត្តិប្រឈមមុខនិងនៅពេលជាមួយគ្នាដែលមានការចំលងទៅប្រជាជនទូទៅ ។ ជោគជ័យនៃបទអន្តរាគមន៍ទាំងអស់នេះពឹងផ្អែកទៅលើការចូលរួមរបស់សហគមន៍ ចំណែកឯសកម្មភាពទីផ្សារសង្គមនៃការប្រើប្រាស់ស្រោមអនាម័យនិងការបង្កឱ្យមាន បរិយាកាសល្អផ្តល់នូវលទ្ធផលស្របគ្នាទៅលើការផ្លាស់ប្តូរការប្រព្រឹត្ត។ ដោយសារតែអត្រាឆ្លងនៃស្ត្រីមានផ្ទៃពោះកើនឡើង ជាការចាំបាច់ត្រូវតែបញ្ចូលកម្មវិធីការពារការចំលងពីម្តាយទៅកូន។ នៅមានការចូលរួមចំណែកជាវិជ្ជមាននៃកម្មវិធីដ៏ទៃទៀតដូចជា មិត្តអប់រំមិត្ត សុវត្ថិភាពឈាម និងការប្រុងប្រយ័ត្នជាសាកល។ ចំពោះការថែទាំអ្នកផ្ទុកមេរោគអេដស៍ការថែទាំនៅតាមផ្ទះនិងតាមសហគមន៍ជាវិធីសាស្ត្រដែលមានទំនាក់ទំនងច្រើនជាងគេបង្អស់ រដ្ឋាភិបាលទទួល ស្គាល់ថានេះជាបន្ទុកមួយបន្ថែមទៀតមកលើស្ត្រីនិងសេចក្តីត្រូវការជាចាំបាច់សំរាប់សេវាគាំទ្រនៅតាមសហគមន៍។ ចាប់តាំងតែពីចំនួនអ្នកជំងឺអេដស៍បានកើនឡើងយ៉ាងឆាប់រហ័ស ក៏មានសេចក្តីត្រូវការជាចាំបាច់នូវសម្ភារៈបរិក្ខាមួយចំនួនដើម្បីផ្គត់ផ្គង់ដល់អ្នក ជំងឺអេដស៍។ យើងគួរធ្វើយុទ្ធនាការផ្សព្វផ្សាយដល់ប្រជាជនឱ្យចូលរួមថែទាំនិងផ្តល់ការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍។ ក្នុងន័យនៃការខ្វះខាតនូវឱកាសប្រើប្រាស់នូវសេវាសុខភាព ការបង់ខាតនៃជំងឺដែលគំរាមគំហែងដល់ជីវិត រ៉ាំរ៉ៃរួមទាំងមេរោគអេដស៍ ទំនងជាបន្ទុកមួយយ៉ាងធ្ងន់ធ្ងរណាស់ចំពោះគ្រួសារអ្នកក្រីក្រ ជាពិសេសចំពោះ ស្ត្រីដែលជាអ្នកថែទាំទី១។ អាទិភាពនៃការកាត់បន្ថយភាពក្រីក្របន្តការថែទាំបានជួយឱ្យដល់អ្នកផ្ទុកមេរោគអេដស៍ ដែលក្រីក្រជាងគេបង្អស់ ឱ្យមានឱកាសទទួលបាននូវការថែទាំគាំទ្រដែលមានតម្លៃទាប សមស្រប និងអាចទទួលបាន។

អាទិភាពនៃការបន្ថយភាពក្រីក្រទាក់ទងទៅនឹងៈ

- កម្មវិធីការពាររបស់សហគមន៍ចំពោះកម្មករចល័តដែលជាអ្នកក្រ
- សេចក្តីប្តេជ្ញាចិត្តផ្នែកនយោបាយមានសារៈសំខាន់ចំពោះការការពារនិងថែទាំអ្នកផ្ទុក/អ្នកជំងឺអេដស៍

• យុទ្ធសាស្ត្រវិមជ្ឈការថវិកាមួយនិងរចនាសម្ព័ន្ធខេត្តដែលមាន គណកម្មាធិការអេដស៍ខេត្ត លេខាធិការដ្ឋានអេដស៍ខេត្ត និង គណៈកម្មធិការអេដស៍ស្រុក។

ផែនការយុទ្ធសាស្ត្រជាតិដែលបង្កើតឱ្យមានសកម្មភាពនៅក្នុងកម្មវិធីជាតិ ដែលជាមូលដ្ឋានក្នុងការវាយតំលៃនៃការឆ្លើយតបជាតិ។ គេរំពឹងថាក្រសួងនិមួយរបស់អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍នឹងបង្កើននិងធ្វើការវាយតំលៃនៃការឆ្លើយតបដោយខ្លួនឯងផ្ទាល់ ហើយនិងអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូរដ៏ទៃទៀត ក៏ពង្រីកនិងវាយតំលៃនៃប្រសិទ្ធិភាពនៃការខិតខំប្រឹងប្រែង។

## ៤.៥.៤ ការគ្រប់គ្រងគ្រោះមហន្តរាយ

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះគ្រោះរាំងស្ងួត និងទឹកជំនន់ដែលជាគ្រោះមហន្តរាយចំបងបង្កដោយធម្មជាតិនៅកម្ពុជាបានបណ្តាលអោយមានការខូចខាតយ៉ាងច្រើនដល់អាយុជីវិត និងសេដ្ឋកិច្ច។ ដូច្នេះគ្រោះមហន្តរាយទាំងនោះទាមទារអោយមានប្រព័ន្ធគ្រប់គ្រង និងប្រាប់អោយដឹងជាមុនមួយសមស្រប។

ការងារការពារទឹកជំនន់នៅមិនទាន់គ្រប់គ្រាន់ និងគ្មានមធ្យោបាយត្រួតពិនិត្យសកម្មភាពរបស់មនុស្សដែលជាប្រភពដែលធ្វើអោយឥទ្ធិពលនៃទឹកជំនន់កាន់តែធ្ងន់ធ្ងរ។ រួមជាមួយនឹងបញ្ហាដ៏ទៃផ្សេងៗ ទៀតបណ្តាសកម្មភាពទាំងនេះមានដូចជាការចាក់ដីបំពេញបឹង, ការសាងសង់អាគារនៅលើច្រាំងទន្លេ និងលើមាត់បឹង, និងការធ្វើអោយរាំងស្ទះចរន្តទឹកតាមស្ទឹង/ទន្លេ, ការកាប់បំផ្លាញព្រៃឈើ ប្រព័ន្ធបង្ហូរទឹកនៅមានភាពខ្សត់ខ្សោយ និងការយកដីខ្សាច់, គ្រួសនិងថ្ម និង សំភារៈដ៏ទៃទៀតចេញពីបាតស្ទឹង-ទន្លេ និង ពីមាត់ច្រាំងផ្លូវទឹក។ អាងទន្លេមេគង្គបានទទួលរងទឹក ជំនន់ចំបងៗជាច្រើននៅក្នុងទស្សវត្សនេះ។

ការខូចខាតនៅកម្ពុជាដែលបង្កដោយទឹកជំនន់ឆ្នាំ ២០០០ មានទំហំធំធេងមនុស្ស ៣៤៧ នាក់បានស្លាប់ហើយប្រជាជនជាង ៣.៥ លាននាក់បានរងគ្រោះដោយទឹកជំនន់នេះ: ក្នុងនោះប្រជាជនជាច្រើននាក់ត្រូវគេជម្លៀសចេញ ពីផ្ទះដែលលិចទឹកអស់រយៈពេលជាច្រើនសប្តាហ៍។ ផលិតផលកសិកម្មនៅក្នុងអាងទន្លេមេគង្គក្រោមត្រូវបានកាត់បន្ថយចុះយ៉ាងធ្ងន់ធ្ងរដោយទឹកជំនន់ហើយផ្លូវជាតិ និង ផ្លូវជនបទរាប់ពាន់គីឡូម៉ែត្រត្រូវបានខូចខាត។ ការខូចខាត សរុបដោយទឹកជំនន់បានកើនដល់ ១៤៥ លានដុល្លាអាមេរិក។ ការខូចខាតផលិតផលកសិកម្មត្រូវបានគេរាយការណ៏ថាមានតំលៃប្រហែល ៦៤លានដុល្លាអាមេរិក។ ម៉្យាងទៀតឥទ្ធិពលនៃទឹកជំនន់មិនមែនមានត្រឹមតែមួយឆ្នាំប៉ុណ្ណោះទេ។ ទឹកជំនន់ធ្វើអោយមានការខូចខាតជាប្រចាំដល់ហេដ្ឋារចនាសម្ពន្ធ័ស្រោចស្រប បំផ្លិចបំផ្លាញទំនប់ការពារទឹកជំនន់ធ្វើអោយរេចរិលទំនប់ ធ្វើអោយបាក់រំហៀវទឹកនិងសំនង់បង្ហូរទឹក ហើយលប់បំបាត់ប្រឡាយ និង សំនង់បង្ហូរទឹកបញ្ចូលស្រែ។

គំរោងស្តារប្រព័ន្ធស្រោចស្រប និងត្រួតពិនិត្យគ្រោះមហន្តរាយដោយទឹកជំនន់ដែលឧបត្ថមដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)និងធនាគារពិភពលោក （WB）ក្នុងគោលបំណងការពារសហគមន៍ទាំងនោះអោយរួចផុតពីឥទ្ធិពល ដ៏ខ្លាំងក្លានៃទឹកជំនន់ដែលបានបណ្តាលអោយខូចខាតដលអាយុជីវិតនិងបង្អាក់ការអភិវឌ្ឍសង្គមស្ទើរតែរៀងរាល់ឆ្នាំ។ ទឹកជំនន់ទន្លេមេគង្គ គឺជាព្រឹត្តិការដែលកើតឡើងផ្ទួនគ្នាដូចដែលយើង បានមើលឃើញតាមរូបភាពទាំងពីរដែលទទួលបានពីផ្កាយរណប នៅខែកញ្ញា ឆ្នាំ ២០០០ និង ២០០១។

វិធីដ៏មានប្រសិទ្ធិភាពមួយសំរាប់ការប្រមើលមើលពីការសង្គ្រោះបន្ទាន់ និងការកាត់បន្ថយការខូតខាតទាមទារអោយមានក្រុមប្រឹក្សាមជ្ឈិមមួយដែលមានជំនាញ និងដំណើរការល្អដើម្បីសំរបសំរួលរវាងក្រសួងទាំងអស់សំដៅ អនុវត្តផែនការសកម្មភាពមួយដែលបានដាក់ចេញ។ ក្រុមប្រឹក្សានេះប្រើប្រាស់ទុកដូចជាវត្ថុដ៏សំខាន់មួយសំរាប់រៃអង្គាសមូលនិធិពីសហគមអន្តរជាតិ និងពីសាធារណជននៅក្នុងប្រទេស។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះរាជរដ្ឋាភិបាលបានបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM), ដែលមានបុគ្គលិកជំនាញ និងមានសមត្ថភាពខ្ពង់ខ្ពស់ដើម្បីទទួលបំពេញការងារនេះ។ ការបង្កើតគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយគឺដោយសារការទទួលស្គាល់ និង ដើម្បីឆ្លើយតបទៅនឹងឥទ្ធិពលនៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិដូចជា ទឹកជំនន់ ឬការថយនៃភោគផលកសិកម្ម ជាពិសេសទៅលើក្រុមដែលងាយរងគ្រោះ។ បន្ថែមពីលើយុទ្ធសាស្ត្រដ៏ច្បាស់លាស់ក្នុងការងារត្រៀមរៀបចំការសង្គ្រោះ, ការកាត់បន្ថយគ្រោះមហន្តរាយ និងការស្តារឡើងវិញរាជរដ្ឋាភិបាលក៏នឹងបង្កើតផងដែរនូវយន្តការដ៏រឹងមាំមួយសំរាប់ធ្វើការសំរបសំរួល, ត្រួតពិនិត្យ, និងស្តារឡើងវិញ ។

ដើម្បីការពារការខូចខាតដែលអាចកើតមានឡើងដោយសារទឹកជំនន់, រាំងស្ងួត, ការធ្វើអោយខូចទីជម្រាល (watershed degradation), ការហូរច្រោះនិងការកកដី, ការធ្វើអោយប្រសើរ និងការអភិវឌ្ឍន៍ទំនប់ត្រួតពិនិត្យទឹកជំនន់សំរាប់តំបន់ក្រីក្រដូចជាតំបន់ក្នុងក្រុង និងតំបន់កសិកម្មរដូវវស្សា និងត្រូវអនុវត្ត ហើយការព្យាករណ៍ អាកាសធាតុ-ឧតុនិយម និងការទប់ស្កាត់ការធ្វើអោយខូចខាតទីជម្រាល ហើយនិងការទប់ស្កាត់ការហូរច្រោះ និង ការកកដី (Sedimentation) ក៏នឹងត្រូវអនុវត្តផងដែរ។ ដោយសហការជាមួយវិទ្យាស្ថានដែលមានការពាក់ពន្ធ័រួម មានបណ្តាប្រទេសក្នុងអាងទន្លេមេគង្គ, ក្រសួងធនធានទឹក និងឧតុនិយម និងកសាងយុទ្ធសាស្ត្រកាត់បន្ថយ និងគ្រប់គ្រងទឹកជំនន់រយះពេលវែងនិងទូលំទូលាយមួយដោយផ្អែកលើការវាយតំលៃដ៏ត្រឹមត្រូវរបស់សហគមន៍និងទ្រព្យសម្បត្តិដែលប្រថុយនឹងគ្រោះថ្នាក់ និងតំលៃពិតប្រាកដនៃការខូចខាតដោយទឹកជំនន់នាពេលអនាគត។ យុទ្ធសាស្ត្រទាំងនេះនិងមានរួមបញ្ចូលវិធានការគ្រប់បែបយ៉ាង (ឧទាហរណ៍ ធាតុអាកាស និងការព្យាករណ៍ធាតុអាកាស, វិធានការសំរាប់ការសាងសង់ដូចជាទំនប់ការពារទឹកជំនន់ និងវិធានការ Non Structural ដូចជាការកំនត់តំបន់វាលលិចទឹក) ដែលអាចនឹងក្លាយជាភាពប្រាកដនិយមសំរាប់ស្ថានភាពនៅកម្ពុជា។ យុទ្ធសាស្ត្រនេះក៏នឹងដោះស្រាយបញ្ហា ដែលមានការពាក់ពន្ធ័ដែរដូចជា ការបង្ហូរទឹក, ការមានច្បាប់ទំលាប់ក្នុងការសាងសង់ និង សកម្មភាពផ្សេងៗទៀតនៅតាមមាត់បឹង/ទន្លេ និងតាមដងទន្លេ និងការធ្វើអោយមានច្បាប់ទំលាប់អំពីការខ្ទប់ ឬចាក់បំពេញផ្លូវទឹក (ឧទាហរណ៍ដូចជាការរុករានដី) ដែលអាចនឹងធ្វើអោយមានទឹកជំនន់នៅចរន្តទឹកខាងលើ (Upstream)។ ក្រសួងធនធានទឹក និងឧតុនិយមនិងវាយតំលៃឥទ្ធិពលដែលអាចនឹងកើតមាននៅពេលអនាគតអំពីការប្រែប្រួលធាតុអាកាស, ជាពិសេសគឺគ្រោះរាំងស្ងួតដោយធ្វើការកត់ត្រាទុកឯកសារធាតុអាកាស និងកំលាំងទឹកហូរក្នុងទន្លេ និងគិតគូរអំពីការផ្លាស់ប្តូរធាតុអាកាសក្នុងពិភពលោក។ ការវាយតំលៃនេះ និងណែនាំការកសាងយុទ្ធសាស្ត្រគ្រប់គ្រងការស្រោច ស្របហើយបើចាំបាច់ត្រូវកសាងយុទ្ធសាស្ត្រ ដ៏ទូលំទូលាយមួយដើម្បីកាត់បន្ថយឥទ្ធិពលនៃ គ្រោះរាំងស្ងួត ការវិនិយោគសំរាប់ការត្រួតពិនិត្យនិងបង្ហូរទឹកជំនន់ប៉ាន់ស្មានតំលៃ ៦៨0ដុល្លាអ៊ុយអេសក្នុងមួយហិចតា នឹងកំនត់យក ១0,000 ហិចតាក្នុងមួយឆ្នាំ។ ដើម្បីជំរុញប្រតិបត្តិការសង្គ្រោះបន្ទាន់ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធីមួយដើម្បីកែលំអភាពត្រឹមត្រូវនៃការព្យាករណ៍ឧតុនិយម ដែលអាចប្រាប់ប្រជាជនឱ្យដឹងមុនអំពីស្ថានភាពទឹកជំនន់ និងរាំងស្ងួត។ ដូច្នេះប្រការសំខាន់គឺក្រសួងធនធានទឹក និងឧតុនិយមត្រូវមានមន្ត្រីជំនាញគ្រប់គ្រាន់ និងត្រូវបំពាក់ដោយ

ឧបករណ៍ព្យាករណ៍អាកាសធាតុដែលប្រើបច្ចេកវិទ្យាខ្ពស់។ ឧបករណ៍នឹងអាចធ្វើអោយស្ថាប័ន នេះទទួលបានការព្យាករណ៍ត្រឹមត្រូវហើយអាចប្រកាសអោយដឹងមួយសប្តាហ៍មុនដើម្បីឱ្យភ្នាក់ងារទទួលខុសត្រូវ ព្រមទាំងប្រជាជនអាចប្រុងប្រៀបបានសំរាប់ប្រតិបត្តិការសង្គ្រោះបន្ទាន់។

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាន់យកវិធានការដែលអាចអនុវត្តបានមួយសំរាប់ប្រតិបត្តិការសង្គ្រោះទឹកជំនន់ ដោយមិនគ្រាន់តែចែកស្បៀងអាហារ និងជំរកប៉ុណ្ណោះទេ គឺថែមទាំងចែកពូជស្រូវស្រាលជូនប្រជាកសិករដាំភ្លាមៗ ក្រោយពេលទឹកស្រកដែរ។ ប្រការនេះបានកាត់បន្ថយទំហំនៃចំការ និងស្រែដែលខូចខាតយ៉ាងមានប្រសិទ្ធិភាព។ ទោះបីជាមានទឹកជំនន់ដ៏ធ្ងន់ធ្ងរដែលប្រទេសកម្ពុជាពុំដែលជួបប្រទះទាល់តែសោះក្នុងរយៈពេលជាង ៧០ឆ្នាំកន្លង មកនេះតែកំណើនសេដ្ឋកិច្ចនៅខ្ពស់នៅឡើយ ៤,៥% សំរាប់ឆ្នាំ ២០០០ ប្រៀបធៀបទៅនឹងព្យាករណ៍ ៥,៥% ដោយសារការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងការគាំទ្ររបស់ដៃគូរអភិវឌ្ឍន៍នៅក្រៅប្រទេសរបស់យើង, អង្គការអន្តរជាតិ, ក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃការថយចុះកសិផល ប្រការសំខាន់គឺត្រូវធ្វើការសិក្សាពីលទ្ធភាពដែលអាចធ្វើបាន និងការស្រាវជ្រាវពីការបង្កើតប្រពន្ធ័ធានារ៉ាប់រងកសិផល ដើម្បីណែនាំអោយស្គាល់ការគ្រប់គ្រងត្រួតពិនិត្យគ្រោះថ្នាក់ជាយថាហេតុដែលកើតមកពីគ្រោះមហន្តរាយដោយធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ អ្នកចូលរួមសំខាន់ៗទាំងអស់ ដូចជាអ្នកផ្តល់អំណោយ, ផ្នែកឯកជន, សង្គមស៊ីវិល, អង្គការមិនមែនរដ្ឋាភិបាល និងកសិករខ្លួនឯងមកចូល រួមជាមួយរដ្ឋាភិបាលក្នុងគំរោងនេះដើម្បីជំរុញយន្តការរបស់ខ្លួននិងភាពម្ចាស់ការអោយរីកចំរើនសំដៅធានានិរន្តភាពនៃគំរោង។ ក៏ប៉ុន្តែដើម្បីបញ្ចប់គំរោងក្នុងរយៈពេលខ្លី ហើយឈានទៅរកគំរោងរយៈពេលមធ្យមរដ្ឋាភិបាលត្រូវទុកថវិកាដោយឡែកក្នុងមូលនិធិបំរុងសំរាប់គ្រោះមហន្តរាយដែលកើតឡើង ជាយថាហេតុដោយធម្មជាតិ ។ ម៉្យាងទៀតឥទ្ធិពលនៃទឹកជំនន់មិនមែនមានត្រឹមតែមួយឆ្នាំប៉ុណ្ណោះទេ។ ទឹកជំនន់ធ្វើអោយមានការខូចខាតជាប្រចាំ ដល់ហេដ្ឋារចនាសម្ពន្ធ័ស្រោចស្រព បំផ្លិចបំផ្លាញទំនប់ការពារទឹកជំនន់ ធ្វើអោយរិចរិលទំនប់ធ្វើអោយបាក់រំហៀវទឹក, សំនង់បង្ហូរទឹក និងលប់បំបាត់ប្រឡាយ និងសំនង់បង្ហូរទឹកបញ្ចូលស្រែ។ ការស្តារ និងការអភិវឌ្ឍន៍គំរោងត្រួតពិនិត្យទឹកជំនន់មានតួនាទីសំខាន់ណាស់ដើម្បីជួយក្នុងការកាត់បន្ថយភាពក្រី ក្រទាំងនៅសហគមន៍នៅជនបទ និងនៅសហគមន៍នៅទីក្រុងឧបករណ៍ការពារទឹកជំនន់បានការពារជីវភាពរស់នៅ នៅជនបទ និងហេដ្ឋារចនាសម្ពន្ធ័នៅទីក្រុងឱ្យរួចផុតពីព្រឹត្តិការដែលប្រកបដោយគ្រោះមហន្តរាយ។

### ៤.៥.៥ សកម្មភាពកំចាត់មីនៈ សកម្មភាពដែលប្រឆាំងទៅនឹងគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

យោងតាមកេរ្តិ៍តំណែលនៃជំលោះជាងបីទសវត្សកន្លងមកកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេស ដែលទទួលរងនូវផលប៉ះពាល់ដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះច្រើនជាងគេបំផុតនៅលើពិភពលោក និងជាប្រទេសដែលមានអត្រារងគ្រោះជនស៊ីវិលខ្ពស់ជាងគេបំផុត ។ ដូចនេះសកម្មភាពមីន ត្រូវបានរាប់បញ្ចូលជាអាទិភាពខ្ពស់បំផុតមួយនៅក្នុងការងារស្តារ និងការអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ជាពិសេសនៅក្នុងការឈានទៅសំរេចបាននូវការកាត់បន្ថយភាពក្រីក្រនៅទីជនបទ ។ ដោយមានការទទួលស្គាល់ពីសារៈសំខាន់នៃវិស័យនេះ កាលពីឆ្នាំ ១៩៩៧ កម្ពុជាបានក្លាយជាភាគីហត្ថលេខីនៃអនុសញ្ញាអូតាវ៉ា

ស្តីពីការហាមប្រាមការប្រើប្រាស់ រក្សាទុកផលិត និង ការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញគ្រាប់មីនគ្រប់ប្រភេទទាំងនោះចោល ។ ផ្ទៃដីដ៏ច្រើនសន្ធឹកសន្ធាប់ដែលប៉ះពាល់ដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គឺជាឧបសគ្គយ៉ាងធំមួយរារាំងដល់កិច្ចអភិវឌ្ឍន៏សង្គម និងសេដ្ឋកិច្ចនិងវិស័យដទៃទៀត ។

ចលនាសកម្មភាពកំចាត់មីននៅកម្ពុជា បានចាប់ផ្តើមដំណើរការតាំងពីសម័យ UNTAC ឆ្នាំ ១៩៩២ដោយមានជំនួយទាំងបច្ចេកទេស និងហិរញ្ញវត្ថុពីសហគមន៍អន្តរជាតិ ។ រហូតមកទល់ពេលនេះ មានអង្គការប្រតិបត្តិករដោះមីន សំខាន់ៗចំនួនបួនធ្វើសកម្មភាពនៅព្រះរាជាណាចក្រកម្ពុជា: មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) កងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ អង្គការ MAG និងអង្គការ HALO Trust ដែលរហូតមកដល់ពេលនេះបានសំអាត មីនសរុបលើផ្ទៃដីចំនួនប្រមាណ ១៨.៥០០ហ.ត ដោះគ្រាប់មីនបានចំនួន ៣៥០.០០០គ្រាប់ និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ៨០០.០០០ គ្រាប់ ។

តាមការប៉ាន់ប្រមាណនាពេលថ្មីៗនេះ ការចំណាយរួមសំរាប់កិច្ចប្រតិបត្តិការដោះមីន មានចំនួនប្រហាក់ប្រហែលប្រមាណជា ៣០លានដុល្លាអាមេរិកក្នុងមួយឆ្នាំៗ ដោយតួលេខនេះបានរាប់បញ្ចូលផងដែរនូវជំនួយជាបច្ចេកទេស និងសំភារៈ ហើយដែលបានចេញជាលទ្ធផលក្នុងការបោសសំអាតចំការមីនប្រមាណជា ៣០ លានម៉ែតក្រឡាក្នុងមួយឆ្នាំគឺឆ្នាំ ២០០២ នេះ (តាមការប៉ាន់ស្មាន) ។

បើទោះបីកិច្ចប្រតិបត្តិការបោសសំអាតមីនហាក់ដូចជាមានទំហំធំធេងយ៉ាងនេះក្តី កំរិតផ្ទៃដីដែលទទួលរងនូវផលប៉ះពាល់ និងចំនួនអ្នករងគ្រោះដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតែមានចំនួនខ្ពស់ជាងគេបំផុតនៅលើពិភពលោក ដែលជាការបង្ហាញអោយឃើញថា ផលប៉ះពាល់ទូទាំងប្រទេសនេះមានកំរិតខ្ពស់ណាស់ដែលជាលទ្ធផលបន្សល់ទុកមកដោយសារជំលោះនាប៉ុន្មានទសវត្សកន្លងមកនេះ ។ ការធ្វើអង្កេតទូទៅមួយហៅថាការអង្កេតកំរិតមួយ លើផលប៉ះពាល់ដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅទូទាំងប្រទេស បានបញ្ចប់ការងាររបស់ខ្លួនកាលពីខែឧសភាឆ្នាំ ២០០២ កន្លងទៅនេះ ។ លើសពីនេះមានការសិក្សាអង្កេតពេញលេញមួយទៀតដែលបានបញ្ចប់កាលពីខែកក្កដាឆ្នាំ ២០០២នេះផងដែរទៅលើទិន្នន័យនៃការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកលើទឹកដីកម្ពុជា ចាប់តាំងពីសង្គ្រាមឆ្នាំ ១៩៧០ មក ។ ការសិក្សាមានលក្ខណៈទូលាយនេះបានបង្ហាញថាមានចំការមីន/UXOs ប្រមាណ ៣.០០០ចំការ ស្មើនឹង ៤.៤៦៦ គម$^{២}$ ដែលគេសង្ស័យថាមានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ តួលេខនេះគឺស្មើនឹង ២.៥%នៃផ្ទៃដីប្រទេសកម្ពុជាយើងទាំងមូល ។ ម្យ៉ាងទៀត ៦១% នៃផ្ទៃដីដែលសង្ស័យថាមានមីននេះ គឺស្ថិតក្នុងខេត្ត-ក្រុងចំនួនប្រាំ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ និងក្រុងប៉ៃលិន ដែលស្ថិតនៅផ្នែកពាយព្យ និងឧត្តរនៃប្រទេស ។

តាមស្ថិតិគ្រោះថ្នាក់ចន្លោះឆ្នាំ ១៩៧៩ ដល់ឆ្នាំ ២០០២ បង្ហាញថាមានប្រជាជន ៥៤.៤៥៣ នាក់ បានរងគ្រោះ របួសពិការ និងបាត់បង់ជីវិត ។ តួលេខថ្មីៗស្តីពីការគ្រោះថ្នាក់គឺស្ថិតនៅក្នុងកំរិតមួយខ្ពស់នៅឡើយដោយមានការថយ ចុះយ៉ាងតិចតួចបំផុតបើប្រៀបធៀបក្នុងឆ្នាំ ២០០០ និង ២០០១ និងជាមួយអត្រាប្រមាណ ៧៥ ករណីក្នុងមួយខែ គិតពី ខែមករាមកទល់នឹងខែកញ្ញា ឆ្នាំ ២០០២ នេះ ។ និន្នាការគ្រោះថ្នាក់នាពេលថ្មីៗបង្ហាញថា ឧបត្តិហេតុភាគច្រើនគឺកើតមានបណ្តាលមកពីការប៉ះពាល់ទៅលើគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះជាងបណ្តាលមកពីគ្រាប់មីន ។ ក្នុងចំណោមភូមិសរុបចំនួន ១៣.៨៦៨ ភូមិចំនួនប្រហែល ១.៦៤០ ភូមិ ស្មើនឹង ១១.៨% គឺរងនូវផលប៉ះពាល់ខ្ពស់ដោយសារគ្រាប់មីន និង UXOs ហើយច្រើនជាង

៥.៥០០ភូមិ មាន UXOs នៅរាយប៉ាយពាសវាលពាសកាល ។ ហេតុនេះហើយទើបគ្រោះថ្នាក់ជាច្រើនបានកើតមានក្នុងពេលកំពុងប្រកបកិច្ចការចិញ្ចឹមជីវិត ។ នៅឆ្នាំ ២០០០ មានករណីគ្រោះថ្នាក់សរុបចំនួន ៨៣២ ហើយប្រមាណ ៤៧៦ ករណី ស្មើនឹង ៥៧% គឺកើតមាននៅរដូវប្រាំង ។

សកម្មភាពដែលប្រឆាំងនឹងគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ រួមចំណែកជាសំខាន់ និងយ៉ាងជាក់ស្តែងទៅនឹងការកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយ (១)កាត់បន្ថយអត្រាគ្រោះថ្នាក់ដែលបានជះឥទ្ធិពលអវិជ្ជមានជាពិសេសដល់គ្រួសារជនរងគ្រោះ (២) ផ្តល់ដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ខ្លាំង មានលទ្ធភាពប្រើប្រាស់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដូចជាធនធានទឹក សាលារៀន មន្ទីរពេទ្យ និងផ្លូវថ្នល់ (៣)បែងចែកដីធ្លីមានសុវត្ថិភាពសំរាប់ការតាំងទីលំនៅ និងធ្វើស្រែចំការ រួមចំណែកក្នុងការធ្វើសមាហរណកម្មក្នុងវិស័យសេដ្ឋកិច្ចជូនប្រជាជនដែលខ្វះខាតដីធ្លីនៅទីជនបទ (៤) ដាក់ផ្លាកសញ្ញាសំគាល់ដីចំការមីន និងអប់រំលើកកំពស់ការយល់ដឹងពីគ្រោះថ្នាក់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដល់ប្រជាជនដែលរស់នៅក្នុងតំបន់ដែលសង្ស័យថាមានមីន (៥)ធានាក្នុងការកំណត់អាទិភាព និងការត្រួតពិនិត្យការបែងចែក ដីធ្លីដែលដោះមីនហើយដោយមានការចូលរួមចំណែកសមស្របប្រកបដោយសមធម៌ និងមានការគាំទ្រដល់ជនក្រីក្រនៅថ្នាក់ខេត្ត (៦)ផ្តល់ការជួយជ្រោមជ្រែងក្នុងការធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទា ឡើងវិញនៃជនពិការដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសហគមន៍របស់ពួកគាត់ ។

## គោលនយោបាយ និង យុទ្ធសាស្ត្រសកម្មភាពកំចាត់មីន

ដើម្បីធានានៅក្នុងការកសាង និងអនុវត្តគោលនយោបាយជាតិស្តីពីសកម្មភាពកំចាត់មីន ប្រកបដោយប្រសិទ្ធភាព និងការសំរបសំរួលល្អ រាជរដ្ឋាភិបាលបានសំរេចបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ហៅកាត់ថា "អាជ្ញាធរមីន" កាលពី ខែកញ្ញា ឆ្នាំ ២០០០ កន្លងទៅនេះ ។ ការបង្កើតអាជ្ញាធរមីននេះ គឺជាជំហានដ៏មានសារៈសំខាន់ជាចំបងនៃសកម្មភាពកំចាត់មីននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះទៀតអាជ្ញាធរមីនមានភារកិច្ចទទួលខុសត្រូវធានាសំរបសំរួលសកម្មភាពកំចាត់មីនទៅតាមគោលនយោបាយ និងអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។ អាជ្ញាធរមីន កំពុងតែតាក់តែងរៀបចំផែនការយុទ្ធសាស្ត្រសកម្មភាពកំចាត់មីន ៥ឆ្នាំ ដោយគិតពីឆ្នាំ ២០០៣ ទៅ ។ ជាការរួមចំណែកជាមួយយុទ្ធសាស្ត្រកាត់បន្ថយនេះ អាជ្ញាធរមីនមានទិសដៅសំខាន់ៗ របស់ខ្លួនដូចខាងក្រោមៈ

- វត្ថុបំណងជាគោលការណ៍នៃសកម្មភាពកំចាត់មីនដែលគ្រប់គ្រង ចាត់ចែង និងសំរបសំរួលដោយអាជ្ញាធរមីន គឺសំដៅកាត់បន្ថយភាពក្រីក្រដោយការបង្កអោយមានសុវត្ថិភាពក្នុងការប្រើប្រាស់ធនធានសំរាប់ផលិតកម្ម និងសេវាកម្មសង្គមផ្សេងៗទៀត តាមរយៈការបោសសំអាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ផ្សព្វផ្សាយ និង អប់រំ ជាសាធារណៈអំពីគ្រោះថ្នាក់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ គោលបំណងនេះ គឺជាឆ្អឹងខ្នង និងជាសនិទានភាព ផ្នែកសង្គម-សេដ្ឋកិច្ចនៃយុទ្ធសាស្ត្រសកម្មភាពកំចាត់មីនជាតិជាអន្តរវិស័យ ដែលកំពុងត្រូវបានរៀបចំតាក់តែង ដោយអាជ្ញាធរមីនសហការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធទាំងឡាយ ។

- ដើម្បីរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចចីរភាព និងជួយដល់ការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលសំរាប់ជាប្រយោជន៍ ដល់អ្នកទីទ័លក្រតាមរយៈការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានដោយសារគ្រាប់មីន/UXOs អាជ្ញាធរមីននឹងជួយអោយបានសំរេចនូវគោលដៅទាំងឡាយក្នុងវិស័យផ្សេងៗតួយ៉ាងដូចជាទេសចរណ៍ ឬហេដ្ឋារចនាសម្ព័ន្ធ ។
- ទាក់ទងនឹងបញ្ហាសង្គម-សេដ្ឋកិច្ច អាជ្ញាធរមីននឹងបង្កើតអោយមានផ្នែកសំខាន់ដែលយកចិត្តទុកដាក់ជាពិសេស ទៅលើការកាត់បន្ថយភាពក្រីក្រ ។ នៅលំដាប់ថ្នាក់ជាតិ ការជ្រើសរើសអាទិភាពជាតិក្នុងចលនាសកម្មភាពកំចាត់ មីននឹងដំណើរការដោយមានការសំរបសំរួលជាមួយក្រសួងមន្ទីរពាក់ព័ន្ធ អាជ្ញាធរខេត្ត ដើម្បីធានាអោយមានកិច្ច សហការសមស្រប តំរែតំរង់ផែនការសកម្មភាពរបស់អង្គការប្រតិបត្តិករដោះមីនទាំងអស់អោយអនុលោមតាម អាទិភាពទាំងឡាយក្នុងការអភិវឌ្ឍន៍ជាតិ និងតាមគោលនយោបាយគាំទ្រដល់អ្នកក្រីក្រ ក៏ដូចជាការធានាការ ប្រើប្រាស់នូវធនធានដ៏ស្តួចស្តើងអោយមានប្រសិទ្ធភាពខ្ពស់ ។ នៅថ្នាក់ខេត្ត ដើម្បីធានាអោយការបោសសំអាត មីនប្រព្រឹត្តទៅសំរាប់ជាប្រយោជន៍ដល់ប្រជាជនក្រីក្រ អាជ្ញាធរមីននឹងបង្កើតឡើងនូវផ្នែកដោយឡែកមួយចំនួន នៅតាមខេត្តដែលមានបញ្ហាមីន/UXO ដើម្បីជ្រើសរើស កំណត់អាទិភាពការងារ និងការបែងចែកដីធ្លីបោសសំអាតមីនហើយអោយបានសមស្របដល់ដៃអ្នកដែលត្រូវបានទទួលផលប្រយោជន៍នេះ ។ ផ្នែកទាំងនេះត្រូវដឹក នាំរួមគ្នាដោយអាជ្ញាធរមីន និងអភិបាលខេត្ត ដែលជាអ្នកទទួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលទ្ធផលដែលបានសំរេច ។
- ប្រសិទ្ធភាព និងសុក្រឹតភាពនៃសកម្មភាពកំចាត់មីន នឹងត្រូវកែលំអដោយការអនុម័តដាក់ចេញនូវស្តង់ដារថ្មី និងនិយ័តកម្មបច្ចេកទេសដោយអាជ្ញាធរមីន ។ រហូតមកទល់ពេលនេះ គណៈកម្មការបច្ចេកទេសបានរៀបរៀង ពិនិត្យពិច័យលើស្តង់ដារនេះជាភាសាអង់គ្លេសបានចំនួនសរុប ១៦ ជំពូកហើយ ។ ស្តង់ដារជាភាសាអង់គ្លេសទាំង ១៦ជំពូកនេះ មាន ១៥ជំពូកបានបកប្រែជាភាសារខ្មែរហើយ ។ ស្តង់ដារនេះនឹងត្រូវបញ្ចប់នៅចុងឆ្នាំ ២០០២នេះ ហើយគ្រោងនឹងដាក់អោយអនុវត្តន៍សំរាប់ឆ្នាំ ២០០៣ តទៅ ។
- មជ្ឈមណ្ឌលទិន្នន័យជាតិសំរាប់សកម្មភាពកំចាត់មីនរបស់អាជ្ញាធរមីន នឹងត្រូវប្រើប្រាស់ក្នុងការកំណត់អាទិភាពសំរាប់សកម្មភាពបោសសំអាតមីន និង ការរៀបចំផែនការចំពោះចំការមីនទាំងឡាយណាដែលមានអគ្រាគ្រោះ ថ្នាក់ខ្ពស់ជាងគេ និងដោយអនុលោមទៅតាមស្តង់ដារពតិមានសកម្មភាពមីនអន្តរជាតិ ។
- កម្មវិធីអប់រំពីគ្រោះថ្នាក់មីន/UXO នឹងត្រូវបង្កើនឡើងដោយយកចិត្តទុកដាក់នូវចំនួនគ្រោះថ្នាក់ដែលមាន សមាមាត្រកាន់តែកើនឡើងដោយសារការប៉ះពាល់ទៅលើយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ ជាក់ស្តែងតួលេខចន្លោះពីខែមិថុនា ឆ្នាំ ២០០១ ដល់ខែឧសភា ឆ្នាំ ២០០២ បានបង្ហាញថាក្នុងចំណោមជនរងគ្រោះដោយសារ UXO ទាំង ៥៤% មាន ប្រមាណ ៣៣% ដោយសារការប៉ះពាល់ទៅលើគ្រាប់ទាំងនោះ ហើយក្នុងនោះ ៣១% ជាកុមារ ។ ផែនការកម្មវិធីនេះកំពុងតែត្រូវបានរៀបចំឡើងអោយហើយមុនដំណាច់ឆ្នាំនេះ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។
- ដោយហេតុថាជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានចំណែកដ៏ធំផងដែរក្នុងចំណោមជនពិការនៅកម្ពុជា យោងតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល អាជ្ញាធរមីនសំរេចប្រគល់ភារកិច្ចការងារសំរបសំរួលជនពិការនេះទៅក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ

ធ្វើអន្តរាគមន៍ជួយដល់ជនរងគ្រោះ និងសហគមន៍របស់គេ និងបន្តការបង្កើត និងលើកកំពស់ថែមទៀតក្នុងកិច្ចសង្គ្រោះជនពិការនេះ ។

## ៤.៥.៦ ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានដោយនិរន្តរភាព

មានការវិវឌ្ឍន៍រីកចំរើនគួរអោយកត់សំគាល់ក្នុងការគ្រប់គ្រងវិស័យបរិស្ថាន និងការអភិរក្សធនធានធម្មជាតិនាពេលកន្លងទៅនេះ ។ ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យបរិស្ថានគឺ ផ្អែកលើផែនការបរិស្ថានជាតិ (១៩៩៨-២០០២) និងសកម្មភាពផែនការយុទ្ធសាស្ត្រដែលរៀបចំឡើងដោយក្រសួងបរិស្ថាន ។ ផែនការបរិស្ថានជាតិត្រូវបានរៀបចំឡើងដោយមានការចូលរួមពីបណ្តាស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ពន្ធ័ដទៃទៀត ហើយបានកំណត់នូវវិស័យអាទិភាពចំនួន៦ គឺ នយោបាយព្រៃឈើ ជលផល និងកសិកម្មក្នុង តំបន់ទំនាបបឹងទន្លេសាប ការគ្រប់គ្រងជលផលតំបន់ឆ្នេរ ជីវចំរុះ និងតំបន់ការពារធម្មជាតិ ការអភិវឌ្ឍន៍ថាមពល និងបរិស្ថាន និងការគ្រប់គ្រងសំណល់ទីក្រុង។ ការអនុវត្តន៍ផែនការបរិស្ថានជាតិត្រូវបានដំនើរការជាប្រចាំ ហើយយុទ្ធសាស្ត្រ និងអាទិភាពរបស់វាលើវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ក៏ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ។

គោលបំណងរួមរបស់ក្រសួងបរិស្ថានគឺ គ្រប់គ្រង អភិរក្ស ការពារបរិស្ថាន និងធនធានធម្មជាតិរបស់ប្រទេសអោយមាននិរន្តរភាព ហើយអាចជួយកាត់បន្ថយភាពក្រីក្រនៅទូទាំងប្រជាជាតិទាំងមូល ។ ជាមួយគ្នានេះគោលដៅរយ:ពេលមធ្យមរបស់ក្រសួងបរិស្ថានគឺផ្តោតទៅលើ: (១) រៀបចំគ្រងគ្រងតំបន់ឆ្នេរ (២)កាត់បន្ថយការបំពុលដោយឧស្សាហាកម្មនិងការបំពុលនៅទីក្រុង (៣) ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ (៤) ធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងព្រៃសម្បទាន (៥) ធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងប្រពន្ធ័អេកូបឹងទន្លេសាប (៦) កសាងសមត្ថភាពរបស់ស្ថាប័នសំខាន់ឬក្នុងការធ្វើផែនការបរិស្ថាន ។

### ការខិតខំប្រឹងប្រែងរបស់ក្រសួងបរិស្ថានស្ថិតនៅក្រោមគោលការណ៍សំខាន់ៗចំនួន៤ទៀត គឺ

ទី១: ការទទួលស្គាល់នូវទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងបរិស្ថាន ។ ទំនាក់ទំនងនេះមានសារសំខាន់ខ្លាំងណាស់ ។ ការបង្កើតនូវឱកាសសំរាប់អ្នកក្រគឺជា គន្លឹះក្នុងកិច្ចការបរិស្ថាន ហើយធនធានធម្មជាតិត្រូវបានរិចរឹលទៅ ពេលណាដែលអ្នកក្រគ្មានមធ្យោបាយ រឺជំរើសផ្សេងៗ ។ ការខូចខាតធនធានធម្មជាតិគឺ មានមួយផ្នែកដែលកើតឡើង ពីការធ្វើអាជីវកម្មដោយប្រជាជនក្រីក្រនៅតាមទីជនបទ ព្រោះពួកគេក៏ត្រូវការស្វែងរកសេចក្តីត្រូវការជាមូលដ្ឋានរបស់ខ្លួនសំរាប់ការរស់នៅដូចអ្នកដទៃទៀតដែរ។ ការកាត់បន្ថយភាពក្រីក្រនៅជនបទ ជាប្រធានបទដ៏សំខាន់ឆ្ពោះទៅរកការអភិវឌ្ឍន៍ដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា ។ យ៉ាងណាក៏ដោយតំរូវការនៃការពង្រឹងសមត្ថភាព និងការសំរបសំរួលរវាងអន្តរក្រសួងជាការងារសំខាន់បំផុត ។

ទី២: ទទួលស្គាល់នូវសារសំខាន់របស់សហគមន៍ ។ ការធ្វើអន្តរគមន៍ចំពោះសហគមន៍មូលដ្ឋានត្រូវតែផ្តល់ជាចាំបាច់ នូវជំនាញគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋានដែលជីវភាពរស់នៅរបស់ពួកគេពឹងអាស្រ័យលើធនធានទាំងនោះ ហើយម្យ៉ាងទៀតវាក៏ជាមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីឆ្ពោះទៅរកការគ្រប់គ្រងធនធានទាំងនោះដោយនិរន្តរភាពផងដែរ ។

ទី ៣: ការទទួលស្គាល់នូវតំរូវការសំរាប់ការកសាងសមត្ថភាពស្ថាប័ន។ ក្រសួងបរិស្ថាន និងស្ថាប័នរដ្ឋាភិបាលដទៃទៀត បានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងបរិស្ថាន ប៉ុន្តែនៅពេលបច្ចុប្បន្ននេះយើងមានភាពខ្វះខាតនូវជំនាញបច្ចេកទេសសំរាប់កិច្ចការពារ អភិរក្ស និងគ្រប់គ្រងបរិស្ថានរបស់ជាតិយើងអោយមានប្រសិទ្ធភាព ។

ទី ៤: ទទួលស្គាល់នូវសារសំខាន់នៃការបញ្ចូលវិធីសាស្ត្រធ្វើផែនការបរិស្ថាន ។ បញ្ហាបរិស្ថានគឺ ជាបញ្ហាចំរុះ ហើយស្ថាប័នផ្សេង១ក៏មានការទទួលខុសត្រូវ និងធ្វើសកម្មភាពខុស១គ្នាដែរ ។ ក្រសួងបរិស្ថានត្រូវតែខិតខំជំរុញអោយមាន ការធ្វើសមាហរណកម្មវិធីសាស្ត្រគ្រប់គ្រងបរិស្ថានអោយទៅជាគោលការណ៍រួមតែមួយ ។ គោលការណ៍នេះនឹងផ្តល់ក្របខ័ណ្ឌការងារដែលមានប្រយោជន៍ ហើយឆ្លុះបញ្ចាំងនូវអាទិភាពបរិស្ថានទាំងឡាយដែលបានធ្វើអត្តសញ្ញាណដោយក្រសួងបរិស្ថាន ។

កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិអោយមានប្រសិទ្ធិភាពគឺជាកង្វល់រួម ។ សកម្មភាពជាច្រើនរបស់រាជរដ្ឋាភិបាលដើម្បីការពារ និងគ្រប់គ្រងបរិស្ថានគឺ ត្រូវបានរួមបញ្ចូលគ្នាជាមួយនឹងការធ្វើវិនិយោគទុន ព្រមទាំងនយោបាយអាទិភាពនៃវិស័យនានាផង ។ ពេលនេះតំរូវអោយមានការត្រួតពិនិត្យ និងការប្រតិបត្តិដោយខ្ជាប់ខ្ជួននៃគំរោងវិនិយោគសាធារណទាំងអស់ដោយធានាថា ការអនុវត្តន៍ទាំងនេះ បានគិតគូរដល់បរិស្ថានព្រមទាំងពង្រឹងចំណងទាក់ទងរវាងការធ្វើផែនការអភិវឌ្ឍន៍ និងកិច្ចការការពារបរិស្ថាន ។ ទាំងអស់នេះគឺ ជាការទាមទារអោយមាន ការសិក្សាវាយតំលៃ ហេតុប៉ះពាល់បរិស្ថានផង និងការអនុវត្តន៍នីតិវិធីក្នុងរបៀបវិនិច្ឆ័យគំរោងថ្មីផង ។ អាទិភាពដ៏ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាគឺ ពង្រឹងសមត្ថភាពក្រសួងបរិស្ថានក្នុងការរៀបចំផែនការអនុវត្តគោលនយោបាយ អនុវត្តគំរោង ត្រួតពិនិត្យ អនុវត្តវិធានការច្បាប់ និងពង្រឹងការប្រតិបត្តិដោយលើយុត្តាធិការច្បាប់បរិស្ថានដែលមានស្រាប់នាពេលបច្ចុប្បន្ន ។ ក្រសួងបរិស្ថាននឹងជំរុញអោយបានខ្លាំងក្លានូវការចូលរួមពីសាធារណជនក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ហើយពលរដ្ឋគ្រប់រូបអាចផ្តល់ពត៌មាន និងអាចចូលរួមក្នុងដំនើរការធ្វើសេចក្តីសំរេចចិត្ត នានាទាក់ទង នឹងបរិស្ថាន ។

ក្នុងផ្នែកជីវចំរុះដែលជាអាទិភាពមួយក្នុងផែនការបរិស្ថានជាតិ ក្រសួងបរិស្ថានបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើការងារគ្រប់គ្រង ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ធ្វើសេចក្តីព្រាងច្បាប់ និងកំនត់ព្រំប្រទល់ឧទ្យានជាតិ ។ ឧទាហរណ៍២នៃសកម្មភាពនេះគឺ (១) ការគ្រប់គ្រងឧទ្យានជាតិវីរៈជ័យក្នុងខេត្តរតនគីរី ដែលផ្តល់ថវិកាដោយមូលនិធិបរិស្ថានពិភពលោក ធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជា ។ (២)ការរៀបចំផែនការជាតិស្តីពីជីវចំរុះដែលបានផ្តល់ថវិកា ដោយមូលនិធិបរិស្ថានពិភពលោក និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិដែលបានទទួលការអនុម័តដោយគណរដ្ឋមន្ត្រី នាពេលកន្លងទៅថ្មី១នេះ ។ បណ្តាកិច្ចសន្យាព្រៃសម្បទានខ្លះក្នុងតំបន់ភ្នំក្រវាញត្រូវបានបញ្ឈប់ ហើយបង្វែរទៅជាព្រៃបំរុងរបស់រដ្ឋ ។ រាជរដ្ឋាភិបាលបានយកចិត្តដាក់ជាពិសេសដល់ឧទ្យានជាតិ និងដែនជំរកសត្វព្រៃដោយបានផ្តល់នូវសម្ភារៈ មួយចំនួនដូចជា រថយន្តពន្លត់អគ្គិភ័យជាដើម ។ កិច្ចការពារប្រពន្ធ័អេកូបឹងទន្លេសាបគឺជាផ្នែកមួយដែលសំខាន់បំផុតនៃយុទ្ធសាស្ត្រអភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ។ ការបង្កើតឡើងនូវឋានបនីយជីវៈមណ្ឌលដោយផ្តល់ ៥០០.០០០ ហិចតានៃផ្ទៃឡូត៍នេសាទអោយទៅសហគមន៍ គឺជាជំហានដ៏សំខាន់ដែលអនុញ្ញាតិអោយសហគមន៍ បានចូលរួមក្នុងការអភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពជាពិសេសគឺ ធនធានមច្ឆាជាតិ ។ តាមរយៈការគាំទ្ររបស់អង្គការ DANIDA, IMO, IDRC ក្រសួងបរិស្ថានបានធ្វើការយ៉ាងសកម្មក្នុងការអនុវត្តន៍គំរោងជំនួយនានា ក្នុងតំបន់ឆ្នេរបានយ៉ាងល្អប្រសើរ ។

ចំពោះការគ្រប់គ្រងសំណល់ទីក្រុងគឺ បានបំពាក់នូវបរិក្ខារ និងមធ្យោបាយប្រមូលដឹកជញ្ជូនសំណល់រឹងបានល្អជាបណ្តើរៗ ។ រដ្ឋាភិបាលកំពុងព្យាយាមយ៉ាងខ្លាំង បើទោះបីជាជួបប្រទះនូវការលំបាកជាច្រើនក្នុងការកែលំអទីចាក់សំរាមស្ទឹងមានជ័យ ដើម្បីទប់ស្កាត់នូវហេតុប៉ះពាល់ចំពោះសុខមាលភាពប្រជាពលរដ្ឋ និងបរិស្ថានក៏ដោយ ។ ការកសាងទីចាក់សំណល់ឧស្សាហកម្មគឺបានរួចរាល់ជាស្ថាពរ ។ ការគ្រប់គ្រងសំណល់រឹងពីរោងចក្រកាត់ដេរក៏បានរៀបចំល្អប្រសើរផងដែរ។ បណ្តារោងចក្រប្រមាណ ៧០% មានអាងប្រព្រឹត្តកម្មទឹកស្អាតដោយខ្លួនគេផ្ទាល់នាពេលបច្ចុប្បន្ននេះ ។

ការអភិវឌ្ឍន៍ប្រភពថាមពលនានាត្រូវតែធានានូវកិច្ចការពារបរិស្ថាន និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ។ នេះជាយុទ្ធសាស្ត្រដ៏សំខាន់របស់ក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានបានចូលរួមក្នុងការពិនិត្យឡើងវិញលើរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថានពីបណ្តាំរោងផ្សេងៗមួយចំនួន ក្នុងនោះផលប៉ះពាល់ផ្នែករូបសាស្ត្រ ជីវសាស្ត្រ និងសង្គមត្រូវបានទទួលនូវការយកចិត្តដាក់យ៉ាងខ្លាំង ។

ក្រសួងបរិស្ថាននឹងបន្តធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងផ្សេងៗ និងភ្នាក់ងារនានាលើបញ្ហាបរិស្ថានដែលទាក់ទងក្នុងវិស័យកសិកម្ម អភិវឌ្ឍន៍បទ រុក្ខាប្រមាញ់ និងនេសាទ ឧស្សាហកម្ម ពាណិជកម្ម និង វិស័យដទៃទៀត។

ជាឧទាហរណ៍មួយពីការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតក្នុងវិស័យកសិកម្ម កំពុងតែធ្វើអោយមានការព្រួយបារម្ភយ៉ាងខ្លាំងក្លា ។ ហេតុនេះក្រសួងបរិស្ថានត្រូវតែចូលរួមចំនែកក្នុងការងារនេះដោយធ្វើការជំរុញអោយមានការកាត់បន្ថយការប្រើប្រាស់ជីគីមីកសិកម្ម ក៏ដូចជាការបញ្ឈប់ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតដែលមានគ្រោះថ្នាក់ដូចជា DDT ព្រោះវាមានផលប៉ះពាល់យ៉ាងខ្លាំងលើបរិស្ថាន ។ ក្រសួងបរិស្ថាន នឹងចាត់វិធានការមិនត្រឹមតែលើផ្លូវច្បាប់ទេ ថែមទាំងជំរុញនូវការអប់រំសាធារណៈ ដើម្បីធានាអោយបានថា កសិករ និងអ្នកប្រើប្រាស់ទាំងអស់អាចទទួលយកបាននូវពត៌មានទាំងឡាយ ស្តីពីថ្នាំសំលាប់ល្អិត និងសារធាតុបង្កគ្រោះថ្នាក់ដល់គេថែមទៀតផង ។

បើទោះបីជាប្រភពធនធានរបស់ខ្លួនមានកំរិតកំនត់ក៏ដោយ ក៏ក្រសួងបរិស្ថានមានបំណងយ៉ាងធំធេង ហើយយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបំពុលខ្យល់ ការខូចរិចរឹលនៃទីជំរកធម្មជាតិ ការចោលសំណល់រាយប៉ាយជាសាធារណៈ (ដូចជាការចោលស្បោងប្លាស្ទិចពីអ្នករស់នៅលើទូកទៅក្នុងបឹងទន្លេសាប និងការបំផ្លិចបំផ្លាញមច្ឆាជាតិ) ការកាប់ឈើខុសច្បាប់ និស្សារណកម្មធនធាន ហើយការធ្វើសម្បទានដី និងជលផលគឺ ជាការគំរាមយ៉ាងធ្ងន់ធ្ងរលើធនធានធម្មជាតិ ។

## ៤.៥.៧ ជនជាតិភាគតិច

ជនជាតិភាគតិចកំពុងត្រូវការនូវការឧបត្ថម្ភគាំទ្រគ្រប់វិស័យសំរាប់ការអភិវឌ្ឍន៍សហគមន៍ពួកគេ ។ នៅអតីតកាលជនជាតិភាគតិចនៃកម្ពុជាត្រូវបានបំភ្លេចចោល និងចាត់ទុកដូចជាពលរដ្ឋលំដាប់ថ្នាក់ទី ២។ ពួកគេត្រូវបានស្ថិតនៅក្រៅនៃរាល់ការអភិវឌ្ឍន៍និងការធ្វើសេចក្តីសំរេចចិត្តទាំងឡាយដោយមូលហេតុពួកគេមានចំនួនតិច នៅក្នុងសមាសភាពនៃសង្គមទាំងមូលម្យ៉ាងដោយសារជំនើរជីវិត និងប្រពៃណី និងដោយសហគមន៍ពួកគេស្ថិតនៅតំបន់ដាច់ស្រយាល ។ល។ អ្វីៗទាំងអស់នេះត្រូវបានប្តូរផ្លាស់ចាប់ពី ឆ្នាំ ១៩៨០ មក ប៉ុន្តែមិនជាធំដំទេ មកដល់បច្ចុប្បន្ននេះ ។

### គោលនយោបាយនិងយុទ្ធសាស្ត្រ សំរាប់ជនជាតិភាគតិច

ការអភិវឌ្ឍន៍ជនជាតិភាគតិច ទើបតែមានការរីកចំរើនគួរអោយកត់សំគាល់ តាមរយៈការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដើម្បីអោយការអភិវឌ្ឍន៍នេះកាន់តែមានប្រសិទ្ធិភាព ការស្រាវជ្រាវ និងការសិក្សាបន្តទៀត នឹងត្រូវធ្វើឡើងដើម្បីកំនត់សំគាល់ក្រុមជនជាតិភាគតិចឈានទៅដល់ការយល់ដឹងពី លក្ខខណ្ឌរស់នៅ វប្បធម៌ និងតំរូវការរបស់ពួកគេ ជាពិសេសគឺការបញ្ចប់ការចងក្រងគោលនយោបាយជនជាតិភាគតិចដែលបានរៀបចំកន្លងមក ។

ក្រសួងអភិវឌ្ឍន៍ជនបទ នឹងសហការព្រមទាំងសំរបសំរួលជាមួយស្ថាប័នពាក់ពន្ធ័ និងភ្នាក់ងារអន្តរជាតិនានា ដើម្បីអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ជនជាតិភាគតិចនៅកម្ពុជា ។

## ៤.៦ បង្កើតសមធម៌យេនឌ័រ

### គោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់សមធម៌យេនឌ័រ

ការចូលរួមចំបងរបស់ស្ត្រីក្នុងដំណើរការផលិតកម្មកសិកម្មត្រូវតែទទួលស្គាល់ ដូច្នេះការអន្តរាគមន៍របស់ស្ត្រីជាគោលដៅមួយដ៏សមស្រប ។ ប្រហែល ៦៥ ភាគរយនៃកំលាំងពលកម្មកសិកម្ម និង៧៥ ភាគរយនៃផលិតកម្មជលផលគឺអនុវត្តន៍ដោយស្ត្រី ដូច្នេះភាពក្រីក្រមិនអាចបានកាត់បន្ថយបានឡើយបើមិនដំណោះស្រាយពីគោលនយោបាយ និងយុទ្ធសាស្ត្រសំរាប់សមធម៌ស្ត្រីកម្ពុជា ។ នេះគឺជាបញ្ហាយេនឌ័រ។ ក្នុងផ្នែកទី ៣ បានដាក់ចេញនូវទំហំយេនឌ័រនៃភាពក្រីក្រនៅកម្ពុជា។ ការយកចិត្តទុកដាក់ជាពិសេសត្រូវតែបានផ្តល់ផងដែរដល់ស្ត្រីដែលងាយរងគ្រោះបំផុត និងស្ត្រីដែលបាត់បង់កាយសម្បទា និងស្ត្រីផ្ទុកមេរោគអេដស៍ដូចជាយកចិត្តដាក់ថែររក្សាស្ត្រីដែលឆ្លងមេរោគអេដស៍ជាដើម ។

អាទិភាពសមធម៌យេនឌ័រ បានស្នើអោយអន្តរាគមន៍ពីផ្នែកដែលពាក់ព័ន្ធ។ វាមានសារៈសំខាន់ណាស់ដែលយល់យ៉ាងច្បាស់ពីភាពអសមភាពនៃយេនឌ័រ និងជះឥទ្ធិពលត្រឡប់វិញនូវរាល់ទិដ្ឋភាពនៃការអភិវឌ្ឍន៍ផែនការ និងគោលនយោបាយកម្ពុជា។ សារៈប្រយោជន៍មួយទៀតការអន្តរាគមន៍ត្រូវតែបង្ហាញពីរបាំងនៃឱកាសចូលរួមរបស់ស្ត្រី ដូចច្នេះពួកគេអាចចូលរួមក្នុងផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍។ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនមានសកម្មភាពគាំទ្រដល់សមភាព និងសមធម៌ដែលឆ្លងកាត់ឥរិយាបទយេនឌ័រដែលត្រូវទទួលខុសត្រូវចំពោះក្រសួងដែលពាក់ព័ន្ធ។ ម្យ៉ាងទៀតត្រូវបានទទួលស្គាល់ថាឥរិយាបទយេនឌ័រដែលគ្មានឥទ្ធិពលដល់យុទ្ធសាស្ត្រ ប្រសិនបើមិនគាំទ្រដោយផ្តល់ថវិកាសំរាប់អន្តរាគមន៍ដោះស្រាយអសមភាពយេនឌ័រ។

រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំក្រសួងកិច្ចការនារី និងអតីតយុទ្ធជនសំដៅកាត់បន្ថយអសមភាពយេនឌ័រជាមូលដ្ឋាន និងធ្វើឱ្យប្រសើរឡើងនូវសមធម៌យេនឌ័រនៅក្នុងផ្នែកសុខាភិបាល អប់រំ និងត្រួតពីនិត្យទៅលើប្រភពធនធានកសិកម្ម ការការពារច្បាប់ និងការផ្តល់អំណាចដល់អ្នកនយោបាយក្នុងផ្នែសេដ្ឋកិច្ច សង្គមកិច្ច។ ទាំងនេះធានាថាស្ត្រី និងនារីភេទទទួលបានពេញលេញនូវការការពារផ្នែកច្បាប់ដូចជាច្បាប់អប់រំ ដែលទាក់ទងទៅនឹងសិទ្ធិ និងអត្ថប្រយោជន៍របស់ពួកគេ ដូចជាលទ្ធភាពទទួលបានកម្មសិទ្ធដីធ្លី និងធនធានធម្មជាតិ។ យុទ្ធសាស្ត្រដ៏ចំបងនេះត្រូវបានអនុម័តដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជនដើម្បីកាត់បន្ថយភាពក្រីក្ររួមមានវិធានការទូទៅដូចជាការជំរុញឥរិយាបទយេនឌ័រនៅក្នុងស្ថាប័នរដ្ឋាភិបាលទាំងអស់ និងវិធានការពិសេសជាច្រើនដូចជាការសហការជាមួយក្រសួងសុខាភិបាលសំរាប់ផ្នែកសុខភាព ជាមួយក្រសួងអប់រំ យុវជន និងកីឡាសំរាប់ផ្នែកអប់រំ និងក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៏ជនបទសំរាប់វិស័យកសិកម្ម នឹងបង្កើតឱ្យមានចំណូលនៅជនបទ។ របាំងច្បាប់ពីសិទ្ធិស្មើភាពគ្នានៃស្ត្រីត្រូវបានធ្វើ និងកំពុងធ្វើដើម្បីឈានទៅរកដំណោះស្រាយ។ ការអប់រំនិងការយល់ដឹងពីយេនឌ័រនឹងត្រូវបានបញ្ចូលជាគន្លឹះសំខាន់ៗគ្រប់ក៏រិតក្នុងរាជរដ្ឋាភិបាលកម្ពុជា។

ការបដិសេធន៏ស្ត្រីពីការចូលរួមពិគ្រោះយោបល់ក្នុងវិស័យផ្សេងៗនៅថ្នាក់ ឃុំ និងថ្នាក់ជាតិ មានន័យថាតំរូវការរបស់ស្ត្រី គឺមិនត្រូវបានលើកយកមកពិចារណា និងដោះស្រាយហើយមានន័យទៀតថាគោលនយោបាយនិងកម្មវិធី តាមវិស័យគឺមិនទាន់បានបំពេញសព្វគ្រប់នៅឡើយទេ។ ការយល់ដឹងពីអសមធមិយេនឌ័រដែលកើតមានឡើងរវាងបុរស និងស្ត្រី ដែលនៅមានក៏រិត និងមិនទាន់បានដោះស្រាយចេញនៅឡើយ "ឧទាហរណ៏ ស្ត្រីធ្វើការតែក្នុងផ្ទះក្នុងខណ:ពេលដែលបុរសចាកចេញទៅធ្វើការងារ ផ្សេងៗដូចជានៅក្នុងរោងចក្រ និងការិយាល័យនេះអាចជាដំណោះស្រាយមួយសមស្រប ប៉ុន្តែវាមិនមែនជាការងារពិតប្រាកដនោះទេ។ កន្លែងដែលពិតប្រាកដហើយត្រូវបានទទួលស្គាល់នោះគឺវាបានពិចារណាលើអ្វីៗដែលឆ្ពោះទៅរកភាពល្អប្រសើរ។

ការចូលរួមបង្ហាញទាំងនេះពេលខ្លះបង្ហាញពីស្មារតីក្នុងការសន្មត់ពីអ្វីដែលស្ត្រីអាចឬគួរតែអាចធ្វើបាន។ តែពេលខ្លះមិនបានបង្ហាញឡើយ។ ដូច្នេះពួកគេត្រូវបានគេលើកយកមកបង្ហាញតិចតួចណាស់ ក្នុងមុខងារធ្វើសេចក្តីសំរេចចិត្តនៅគ្រប់ថ្នាក់ក្នុងរដ្ឋាភិបាល។ និយាយរួមមានន័យថាទស្សនវិស័យរបស់ស្ត្រីគឺមិនបានចូលរួមចំណែកក្នុងកិច្ចការនយោបាយការអនុវត្តន៏កម្មវិធី និងការត្រួត ពិនិត្យ និងការវាយតំលៃនៅឡើយទេ។អភិបាលកិច្ចល្អ គឺផ្អែកទៅលើស្ត្រីភាគច្រើនដែលត្រូវបានលើកយកមកបង្ហាញនៅគ្រប់ថ្នាក់ក្នុងរដ្ឋាភិបាលវាក៏ផ្អែកលើការរាប់បញ្ចូលស្ត្រីក្នុងគ្រប់វេទិការពិគ្រោះយោបល់ ជួនកាលវាអាចបញ្ជាក់ថាជាការប្រជុំដោយឡែកពីគ្នានៃបុរស និងស្ត្រីរហូតដល់ស្ត្រីមាននូវការអប់រំ និងក្លាហានអាចចូលរួមក្នុងការពិភាក្សាជាសាធារណ:។

# ជំពូក ៥: គំរូការ និង ការគ្រប់គ្រងធនធានសាធារណៈ

ចំនុចសំខាន់នៃការរៀបចំ និងការអនុវត្តន៏នៃ យជកភ គឺជាប់ទាក់ទងទៅនឹងថវិការជាតិ។ ការបែងចែកថវិកាទាមទារធ្វើអោយស្របទៅនឹង យជកភ និង ជាសំខាន់គឺការអនុវត្តន៏ និងការគ្រប់គ្រងថវិកាត្រូវតែអនុលោមតាមគម្រោងការដែលបានគ្រោងទុក។

រាជរដ្ឋាភិបាលទទួលស្គាល់ថា កិច្ចការអនុវត្តន៏កន្លងមកនៅមានកំរិតនៅឡើយ។ ចំនូលជាតិក្នុងម្នាក់ៗ នៅមានចំនួនទាប ហើយទោះបីជាមានការកើនឡើងជារៀងរាល់ពេលក្តី ក៏បរិមាណភាគនៃចំណូលក្នុងស្រុកនៅក្នុង ផ.ស.ស ក៏នៅមានចំនួនទាបដែរ បើគិតតាមខ្នាតស្តង់ដារអន្តរជាតិ ។ នេះមានន័យថា ថវិកានៅមាន ឧបមាកំរិតកំណត់ជាអតិបរមា ដែលដាក់កំរិតដល់ការអនុវត្តន៏បណ្តាសកម្មភាពទាំងឡាយ។ ជំនួយឧបត្ថម្ភនៃដៃគូ ពីខាងក្រៅក៏បានជួយមួយផ្នែកដល់សកម្មភាពទាំងនេះដែរ។ បទពិសោធរបស់កម្ពុជាក៏បង្ហាញផងដែរថា ការគ្រប់គ្រងចំណាយសាធារណៈមានភាពទន់ខ្សោយជាខ្លាំងទោះបីជាមានការយកចិត្តទុដាក់គ្រប់ពេលយ៉ាងណាក៏ដោយ ។ ធនធានសាធារណៈត្រូវបានគៀងគរតាមរយៈថវិកាជាតិ ។ ជាឧបករណ៏នយោបាយម៉ាក្រូសេដ្ឋកិច្ច ថវិកា និងនយោបាយសារពើពន្ធ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដែលចាំបាច់ធានាដល់និរន្តរភាពនៃការអនុវត្តន៏សេដ្ឋកិច្ចអោយបានល្អ និងសំរេចបាននូវការអភិវឌ្ឍន៏សេដ្ឋកិច្ចប្រកបដោយចីរភាព ។

ជំពូកនេះ បង្ហាញនូវការប៉ាន់ស្មានគំរូវការ និងគំរោងបែងចែកថវិកាសំរាប់ការអនុវត្តន៏នៃ យជកភ និង ពិនិត្យអំពីបណ្តាវិធានការអនុវត្តន៏លើចំណូល ដើម្បីបង្កើនធនធាន និងដាក់ចេញនូវទំនាក់ទំនងស្អិតរមួតជាមួយថវិកា។ វិធានការដើម្បីលើកកំពស់ការគ្រប់គ្រងថវិកា ជាពិសេសលើការអនុវត្តន៏ចំណាយថវិកា នឹងត្រូវបានលើកយកមកពិនិត្យខាងក្រោម។

## ៥.១ ការគៀងគរចំណូល

ការខំប្រឹងប្រែងប្រមូលចំណូលនាពេលថ្មីៗនៅមានកំរិតទាប ដែលឆ្លុះបញ្ចាំងពីភាពទន់ខ្សោយក្នុងការគ្រប់គ្រងផ្នែករដ្ឋបាលពន្ធគយ មូលដ្ឋានពន្ធមានលក្ខណៈចង្អៀត ចំណូលមិនមែនសារពើពន្ធមិនគ្រប់គ្រាន់ និងទំលាប់អាក្រក់មិនប្រព្រឹត្តតាមច្បាប់ទំលាប់។ ដូច្នេះ ការគៀងគរចំណូល គឺជាកត្តាសំខាន់នៃនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តការកែទំរង់សំដៅសំរេចនូវការបង្កើនការប្រមូលចំណូលអោយបានពី ៩ ភាគរយនៃ ផ.ស.ស នៅឆ្នាំ ១៩៩៨ ដល់ ១៤ ភាគរយ នៅឆ្នាំ២០០៥។

ជាធម្មតាមូលដ្ឋានពន្ធដារដែលមានលក្ខណៈទូលំទូលាយរំពឹងថានឹងបច្ច័យនៃការបែងចែកជាអវិជ្ជមាន។ សំរេចបានការប្រមូលចំណូលតាមផែនការអោយបាន ១៤ ភាគរយ នៃ ផ.ស.ស នៅឆ្នាំ ២០០៥ គឺជាការសំខាន់សំរាប់ការអនុវត្តន៏កម្មវិធីកាត់បន្ថយភាពក្រីក្រ។ ក្នុងរយៈពេលបីឆ្នាំខាងមុខ កម្ពុជាមានបំណងនឹងបង្កើនចំណូលអោយបាន ២ភាគរយ នៃ ផសស ដើម្បីកំណើនចំណាយផ្នែកសង្គម និងទូទាត់សេវាបំណុល។ នេះតម្រូវអោយប្រកាន់យកនូវវិធានការអនុវត្តនយោបាយសារពើពន្ធដោយឥតងាករេ (ទាំងពន្ធដារ និង មិនមែនពន្ធដារ) និង លើកកំពស់អភិបាលកិច្ច។

វិធានការរកចំណូលទាំងនេះ រួមមានៈ (១)ពង្រីក VAT (២) ធ្វើអោយប្រសើរឡើងនូវការប្រមូលពន្ធ ដែលមានរួច ដូចជា ពន្ធរដ្ឋាករ ពន្ធលើប្រាក់ចំណេញ ពន្ធលើបៀវត្ស និងពន្ធលើប្រាក់ចំណូលនិង (៣)ពង្រឹងការគ្រប់គ្រងផ្នែករដ្ឋបាលនៃពន្ធដារ និងគយ។ គម្រោងការពង្រីកប្រពន្ធ័ប្រមូលពន្ធតាមរបបពិត ដែលជាផ្នែកមួយនៃវិធានការពង្រីកមូលដ្ឋានពន្ធ នឹងត្រូវធ្វើឡើង ចំពោះខេត្តប្រាំទៀត ដែលជាការបន្ថែមលើខេត្តទាំងប្រាំដែល បានអនុវត្តរួចហើយគឺ ក្រុងព្រះសីហនុ ខេត្តបាត់ដំបង សៀមរាប កំពង់ចាម និងកោះកុង។

រាជរដ្ឋាភិបាលកម្ពុជាយល់ដឹងថា VAT មានការប៉ះទង្គិចដល់ថ្លៃសំភារៈឧបករណ៍បំរើអោយកសិកម្ម ដែលជាហេតុប៉ះពាល់ដល់ប្រជាជនក្រីក្រ។ ក្នុងន័យនេះ បានជាកាលពីឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចផ្តល់ការលើកលែង VAT ចំពោះការនាំចូលសំភារៈបរិក្ខារ និងគ្រឿងម៉ាស៊ីនបំរើអោយកសិកម្ម។ ចាប់តាំងពីដើមឆ្នាំ ១៩៩០ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបោះឆ្នោតបដិសេដការដាក់អោយមានពន្ធលើដីធ្លី ដែលពន្ធនេះ នឹងប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនក្រីក្រដែលរស់នៅតាមជនបទ។ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថា វាមិនជាការងាយស្រួលទេ ចំពោះការអះអាងពីភាពប៉ះទង្គិចរបស់ពន្ធដារ និងពិចារណាថា ជាការចាំបាច់ត្រូវធ្វើការសិក្សាអំពីបច្ច័យនៃនយោបាយពន្ធចំពោះប្រជាជនក្រីក្រ។ ជាការអកុសល តួលេខដែលរកបាន មិនអាចយកទៅវិភាគបញ្ហាទាំងនេះបានទាន់ពេល។ ទៅអនាគត រាជរដ្ឋាភិបាលកម្ពុជាគ្រោងនឹងធ្វើការវិភាគនៃភាពក្រីក្រ និងបច្ច័យនៃវិធានការប្រមូលចំណូលយថាប្រភេទចំពោះសង្គម និង ឬក៏គាំទ្រដល់ដៃគូរទាំងឡាយ និងភាគីដទៃទៀតក្នុងការ ធ្វើវិភាគ ដើម្បីផ្តល់ជាពត៌មានបន្ថែមសំរាប់ធ្វើការសំរេចចិត្ត។

ការគ្រប់គ្រងផ្នែករដ្ឋបាលពន្ធដារ អាចនឹងត្រូវពង្រឹងតាមរយៈការបង្កើនចំនួនសវនករដែលមានគុណភាព និងចំនួនក្រុមហ៊ុន ដែលតម្រូវអោយដាក់ក្រោមសវនៈកម្ម។ ដោយមានការសង្ឃឹមទុកជាមុននៃការពង្រីករបបពិត នាយកដ្ឋានពន្ធដារបានប្រកាន់យក នូវវិធានការជាជំហាន១ ដើម្បីលើកកំពស់ផ្នែកគ្រប់គ្រងរដ្ឋាបាលនៃរបបពិត តាមរយៈការរៀបចំឡើងវិញអង្គភាពរបបពិតអោយ ទៅជាស្ថាប័នពីរដាច់ពីគ្នាៈ (១)អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ១ ដែលមានតួនាទីត្រួតពិនិត្យសាជីវកម្មធំ១ និងសំដៅលើកកំពស់ ប្រតិបត្តការសវនៈកម្ម ពង្រឹងប្រតិបត្តិការប្រមូលចំណូល និងលើកកំពស់ការគោរពតាមច្បាប់ បទបញ្ជា និង (២)អង្គភាពគ្រប់ គ្រងអ្នកជាប់ពន្ធ មធ្យម ដែលមានតួនាទីត្រួតពិនិត្យអាជីវកម្មប្រភេទមធ្យម។

ការកែទំរង និងការធ្វើទំនើបកម្មផ្នែកគយ គឺជាការចាំបាច់បំពេញសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាល សំរាប់ការគៀងគរ ចំណូល និងសំរាប់ការការពារសីម៉ារដ្ឋបេស់រដ្ឋ និងបំពេញសេចក្តីត្រូវការរបស់ផ្នែកឯកជន សំរាប់ការធ្វើពាណិជ្ជកម្មបានឆាប់ មិនស្មុគស្មាញ និងមានលក្ខណៈជាអន្តរជាតិ។ ដើម្បីពង្រឹងរដ្ឋបាលគយ គណៈកម្មាធិការដឹកនាំសំរាប់អធិការកិច្ចមុនដឹកជញ្ជូន (PSI) ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យ និងពង្រឹង យន្តការ PSI បច្ចុប្បន្ន។ ខាងក្រោមនេះ គឺជាកញ្ចប់នៃការកែទំរង់ សំដៅពង្រឹងរដ្ឋបាលគយ និង សំរួលដល់កិច្ចការពាណិជ្ជកម្ម។

**ច្បាប់កែសំរួលពន្ធគយៈ** ការអនុវត្តន៍ និងការអភិវឌ្ឍន៍ច្បាប់កែសំរួលស្តីពីគយដើម្បីជាមូលដ្ឋានច្បាប់ សំរាប់ការកែទំរង់ និង បំពេញនូវការប្តេជ្ញាចិត្តចូលជាទៅក្នុងសមាជិក WTO និងមានស្តង់ដារ។

**និតិវិធីធ្វើវូបនីយកម្ម និងបែបបទគយ:** ដាក់អោយប្រើនូវនិតិវិធីរធ្វើបែបបទគយដែលមាន លក្ខណៈសាមញ្ញ ដែលជួយសម្រួលផ្នែកពាណិជ្ជកម្ម និង លើកកំពស់ប្រសិទ្ធភាពនៃប្រតិបត្តិការ តាមរយៈការអនុវត្តន៍ការនៃបច្ចេកទេសគ្រប់គ្រងហានីភ័យ។
**ការបញ្ចូលនៃកិច្ចព្រមព្រៀងវាយតំលៃ WTO:** ការកែប្រែច្បាប់ដើម្បីកំណត់ពីវិធីសាស្ត្រវាយតំលៃ ទំនិញនាំចូលសំរាប់គយ ដោយប្តូរទៅជាការប៉ាន់តំលៃនៃការធ្វើអាជីវកម្ម ឬថ្លៃត្រូវបង់សំរាប់ទំនិញ ដែលតម្រូវអោយបង់ក្រោមកិច្ចព្រមព្រៀង ការវាយតំលៃរបស់ WTO ។ ការបង្កើតសវនកម្មក្រោយការរត់បែបបទ នឹងជាផ្នែកមួយយ៉ាងសំខាន់នៃការផ្តើមអនុវត្តកិច្ច ព្រមព្រៀងនេះ។
**ពង្រឹងការអនុវត្តន៍ច្បាប់:** ការអនុវត្តន៍ និងការអភិវឌ្ឍន៍កម្មវិធី និងយុទ្ធសាស្ត្រអនុវត្តន៍ច្បាប់ ឈរលើគោលការណ៍ ការគ្រប់គ្រងហានីភ័យ ដើម្បីកាត់បន្ថយការរត់គេចពន្ធ និងសកម្មភាពបទល្មើសដទៃទៀត នៅតាមព្រំដែន។
**ប្រើនិតិវិធី និងប្រពន្ធ័ដែលមានលក្ខណៈជាស្វ័យប្រវត្តិ:** ប្រើប្រាស់បច្ចេកវិជ្ជាពតិមាន ដើម្បីលើកស្ទួយប្រពន្ធ័អាជីវកម្ម ប្រសិទ្ធភាពនៃសេវា និងប្រត្តិបត្តិកាដល់អតិថិជន។ គោលដៅយូរអង្វែងគឺ ធ្វើអោយមានប្រពន្ធ័ស្វ័យប្រវត្តិ ដល់គ្រប់ដំណើរការអាជីវកម្មរបស់អតិថិជន។
**ការទទួលផលជាអតិបរិមាពីប្រតិបត្តការនៃ PSI :** ការដាក់អោយអនុវត្តឡើងវិញនូវ PSI គឺសំដៅ កាត់បន្ថយឱកាសនាំអោយមានកំហុសឆ្គង និងការរំលោភផ្នែកសារពើពន្ធ អាស្រ័យដោយអ្នកនាំចូលទំនិញមានការខុសឆ្គងភ្លេចរាយមុខទំនិញ ការបែងចែកខុសប្រភេទទំនិញ និងការវាយតំលៃទំនិញពុំបានជិតដល់ និងដើម្បីសំរួលដល់ការធ្វើពាណិជ្ជកម្ម។ ត្រូវមានការយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលខាងបច្ចេកទេសគយ និងមុខជំនាញគ្រប់គ្រងព្រមទាំងការអភិវឌ្ឍន៍ប្រពន្ធ័ធ្វើបែបបទ គយមានលក្ខណៈជាស្វ័យប្រវត្តិ។

ចំណូលមិនមែនសារពើពន្ធ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រឹងប្រែងគៀងគរចំណូល។ ដើម្បីបង្កើនការប្រមូលចំណូលមិនមែនសារពើពន្ធ បណ្តាសកម្មភាពទាំងឡាយ ត្រូវបានដាក់អោយអនុវត្តតាមរយៈការបិតភ្ជាប់ ទិដ្ឋាការ ពិនិត្យឡើងវិញនូវកិច្ចសន្យាបង់ចំណូលចូលទស្សនាអង្គរវត្ត ត្រួតពិនិត្យកិច្ចសន្យាជួលទ្រព្យសម្បត្តរដ្ឋ និងបង្កើនការប្រឹងប្រែងប្រមូល ទូទាត់ចំណូលត្រូវបង់លើការជួលទ្រព្យរដ្ឋ និងទូទាត់ប្រមូលចំណូលត្រូវបង់ពី គមនាគមន៍ និងប្រមូលអោយបានរួសរាន់នូវចំណូលពីកាស៊ីណូ។

ប្រមាណជា ៣០ ភាគរយនៃថវិកាជាតិ ឬ ៦ ភាគរយនៃ ផសស ទទួលហិរញ្ញប្បទានពីជំនួយក្រៅប្រទេស ក្នុងរូបភាពជាថវិការទ្រទ្រង់កម្ចីមានលក្ខណៈសម្បទាន និងអំណោយ។ កម្ចីតាមរយៈគម្រោង មានចំនួន ២,៦ ភាគរយនៃ ផសស រីឯអំណោយមានចំនួន ២,៨ ភាគរយនៃ ផសស ។ ចំនួនដែលនៅសល់ គឺជាកម្ចី និងជាអំណោយផ្តល់ដោយអ្នកផ្តល់ជំនួយពីខាងក្រៅ។ ដូច្នេះបំណុល និងអំណោយក្រៅប្រទេសរំពឹងថា នឹងមានការជាប់ទាក់ទងនឹងការគ្រប់គ្រងចំណាយថវិកាជាតិ និងការកាត់បន្ថយភាពក្រីក្រដែលនឹងលើកយកមក ពិភាក្សានាពេលក្រោយក្នុង យជកភ ខាងមុខ។

## ៥.២ គំរូវការចាន់ស្មាន និងគម្រោងបែងចែកថវិកា

ចំណែកឯផ្នែកចំណាយថវិការវិញ ចាប់តាំងពីឆ្នាំ ១៩៩៩ មកផែនការសកម្មភាពមួយចំនួនត្រូវបានយកមកអនុវត្ត ដើម្បីលើកកំពស់ចំណាយសាធារណៈ ដោយផ្តោតទៅលើភាពក្រីក្រ រួមមានការចំណាយសមស្របលើផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច

និងកាត់បន្ថយចំណាយសន្តិសុខ និងការពារ អនុវត្តកម្មវិធីសកម្មភាព ជាអាទិភាព (PAP) ដើម្បីបង្កើនការផ្តល់ថវិកាដល់ផ្នែកអាទិភាព និងលុបឈ្មោះបុគ្គលិកខ្មោច និងទាហានខ្មោច ពីបញ្ជីបៀវត្សសេវាសាធារណៈ។ ទោះបីមានការរីកចំរើនក្នុងការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលចេញពី ផ្នែកសន្តិសុខ និងការពារក៏ដោយ ក៏ចំណាយផ្នែកសង្គម នៅមិនទាន់បានអនុវត្តទាំងស្រុង ដែលបង្ហាញអោយឃើញជាអាទិ៍ នូវការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយអសមត្ថភាពនៃបណ្តាក្រសួងពាក់ព័ន្ធគ្រប់ខេត្តក្រុង ។ លើសពីនេះទៀត ចំណាយសំរាប់ជួយសង្គ្រោះទឹកជំនន់ និងការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់បានបង្កការលំបាកបន្ថែមទៀតដល់ការអនុវត្តន៍ថវិកាឆ្នាំ ២០០១ ។

ដើម្បីកែប្រែការដកប្រាក់ពីរតនាគារអោយមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវៈ (១) បង្កើននូវភាពជាក់ច្បាស់ និងរបាយការណ៍ដែលមានគុណភាពដែលរដ្ឋាភិបាលធ្វើការផ្ទេរហិរញ្ញប្បទានដោយពន្យល់ពីការគណនានៃប្រតិបត្តិការរតនាគារ, (២) អនុវត្តន៍ដោយមានគំនូរក្រាហ្វិកបង្ហាញប្រកបដោយភាពងាយស្រួលភ្ជាប់នឹងលេខកូដគណនេយ្យថវិកាជាមួយ នឹងកូដគណនេយ្យរបស់រតនាគារដើម្បីជួយសំរួលដល់ការប្រតិបត្តិរបាយការណ៍ថវិកា និងតុល្យបញ្ជីហិរញ្ញវត្ថុពីប្រភពទិន្នន័យតែមួយ និង (៣) ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរតនាគារនូវការអនុវត្តន៍គ្រប់គ្រងហិរញ្ញវត្ថុថ្មី ។

ដូចបានបញ្ជាក់ជូនរួចមកហើយ យជកភ មានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយគម្រោងចំណាយ រយៈពេលមធ្យម (MTEF) ដែលបានបង្កើតនូវការបែងចែកចំណាយថវិកាសំរាប់រយៈពេលមធ្យម។ ចំពោះ យជកភ គឺពុំមានលទ្ធភាពគិតគូរគ្រោងចំណាយទាំងស្រុងក្នុងគ្រប់សកម្មភាពបាននោះទេ បើទោះបីការប៉ាន់ស្មានត្រូវបានធ្វើសំរាប់ផ្នែកសុខាភិបាល អប់រំ និងផ្នែកដ៏ទៃមួយចំនួនទៀត ។ ប្រអប់ទី៨ បង្ហាញការជាប់ទាក់ទងរវាង បណ្តាសកម្មភាពដែលបានគ្រោងនៅក្នុង យជកភ និងថវិកា និង MTEF ក្នុងករណីផ្នែកអប់រំ ដែលជាផ្នែកអាទិភាពជាគន្លឹះមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងករណីនេះការទាក់ ទងដ៏រឹងមាំគឺការប្រកាន់ខ្ជាប់ខ្ជួននូវការងារធ្វើជាបន្ត និងអោយបានល្អជាមុន លើយុទ្ធសាស្ត្រតាមផ្នែក

**ប្រអប់ទី៩: ការទាក់ទងរវាងយុទ្ធសាស្ត្រតាមផ្នែកជាមួយថវិកា និង MTEF: ករណីផ្នែកអប់រំ**

ដូចដែលបានពន្យល់ក្នុងជំពូកមុន១ របៀបដោះស្រាយផ្នែកអប់រំមាននៅ ក្នុងយុទ្ធសាស្ត្រ តាមផ្នែក (ESSP) ។ គំរោងហិរញ្ញប្បទានរបស់អស់ ESSP ត្រូវបានបង្កើតឡើង ដើម្បីនឹងទាក់ទងការចំណាយដែលហុចជាលទ្ធិផលតាមរយៈកម្មវិធីជាអាទិភាពឈរលើ លទ្ធផលជាធំនិងត្រូវបានយល់ព្រមនិងត្រួតពិនិត្យប្រចាំឆ្នាំ។ កិច្ចព្រមព្រៀងរួមមួយត្រូវបានចុះ ហត្ថលេខាដោយ MOEYS និង MEF ស្តីអំពីសូចនាករអនុវត្តន៍តាមផ្នែកជាគន្លឹះ រួមទាំង ទិសដៅផ្តល់ហិរញ្ញប្បទានដោយថវិការជាតិដល់ ESSP ។ ចំណាយសំរាប់កម្មវិធីត្រូវបានគ្រោងឡើងតាមរបៀបគ្រោងពីក្រោមឡើងលើ ផែនការឈរលើមូលដ្ឋាន "តំរូវការ" និងដាក់អោយប្រើពីលើចុះក្រោម ផ្នែកតាមធនធានថវិកាដែលមាន។ ជាឧទាហរណ៍ កិច្ចសន្យា គឺកាត់ចំណាយចំពោះឪពុកម្តាយ ហើយផ្តល់ថវិការចំណាយជាប្រចាំដល់សាលារៀន គឺជាចំណាយប្រើប្រាស់សំរាប់ប៉ាន់ស្មានឯកតាចំណាយអប់រំមូលដ្ឋាន និងបញ្ញាសវិញសំរាប់រយៈពេលប្រាំឆ្នាំ និងអនុបាតរវាងហិញ្ញវត្ថុសាធាណៈ និងឯកជន។ ធ្វើដូចនេះ គឺសំរួលដល់ (១)កំណត់អោយបានជាមុនពីការបង្កើតធនធានសំរាប់រយៈពេលមធ្យមពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់ផ្នែកអប់រំ នៅក្នុងឯកសារដូចជា IPRSP លើកកំពស់ពតិមានស្តីពីជំនួយរបស់អ្នកផ្តល់ជំនួយ។ ដូចដែលបានពន្យល់ក្នុងជំពូកមុន១ របៀបដោះស្រាយផ្នែក អប់រំមាននៅក្នុងយុទ្ធសាស្ត្រតាមផ្នែក (ESSP) ។ គំរោងហិរញ្ញប្បទានរបស់អស់ ESSP ត្រូវបានបង្កើតឡើង ដើម្បីនឹងទាក់ទងការចំណាយដែលហុចជាលទ្ធផល តាមរយៈកម្មវិធីជាអាទិភាពឈរលើ លទ្ធផលជាធំនិងត្រូវបានយល់ព្រមនិងត្រួតពិនិត្យប្រចាំឆ្នាំ។ កិច្ចព្រមព្រៀងរួមមួយត្រូវបានចុះ

ហត្ថលេខាដោយ MOEYS និង MEF ស្តីអំពីសូចនាករអនុវត្តន៍តាមផ្នែកជាគន្លឹះ រួមទាំង ទិសដៅផ្តល់ហិរញ្ញប្បទានដោយថវិការជាតិដល់ ESSP ។ ចំណាយសំរាប់កម្មវិធីត្រូវបាន គ្រោងឡើងតាមរបៀបគ្រោងពីក្រោមឡើងលើ ផែនការឈរលើមូលដ្ឋាន "តំរូវការ" និងដាក់អោយ ប្រើពីលើចុះក្រោម ផ្អែកតាមធនធានថវិកាដែលមាន។ ជាឧទាហរណ៍ កិច្ចសន្យា គឺកាត់ចំណាយ ចំពោះឪពុកម្តាយ ហើយផ្តល់ថវិកា ចំណាយជាប្រចាំដល់សាលារៀន គឺជាចំណាយប្រើប្រាស់សំរាប់ប៉ាន់ស្មានឯកតាចំណាយ អប់រំមូលដ្ឋាន និងបញ្ច្រាសវិញសំរាប់រយៈពេលប្រាំឆ្នាំ និង អនុបាតរវាងហិរញ្ញវត្ថុសាធារណៈ និងឯកជន។ ធ្វើដូចនេះ គឺសំរួលដល់ (១) កំណត់អោយបានជាមុនពីការបង្កើតធនធានសំរាប់រយៈពេលមធ្យមពី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសំរាប់ផ្នែកអប់រំ នៅក្នុងឯកសារ ដូចជា PRSP លើកកំពស់ពតិមានស្តីពីជំនួយរបស់អ្នកផ្តល់ជំនួយ ។

គម្រោងហិរញ្ញប្បទាន ESSP គឺទាក់ទងជិតស្និទ្ធជាមួយថវិការដ្ឋាភិបាល។ កម្មវិធីជាអាទិភាពមួយចំនួនធំត្រូវបានអនុវត្តតាមរយៈ PAP ក្រោមគំរោងចំណាយជាប្រចាំនៃ MOEYS ។ គេរំពឹងថា ទំនាក់ទំនងនេះនឹងត្រូវបន្តលើកកំពស់អភិវឌ្ឍន៍បន្ថែមទៀតនៃ MTEF ដោយ MEF និងធ្វើសមាហរណកម្មហិរញ្ញប្បទានពីខាងក្រៅអោយបានប្រសើរឡើងក្នុងថវិការដ្ឋាភិបាល ឬ MTEF ដែលជាគំរូអនុវត្តជ្រើសដោយ ភ្នាក់ងារផ្តល់ជំនួយ។ បច្ចុប្បន្ន ក្នុងផ្នែកអប់រំ ហិរញ្ញប្បទានពីខាងក្រៅ គឺផ្តល់អោយតាមរយៈថវិកាទ្រទ្រង់ គំរោងជួយសំរាប់វិនិយោគមូលធន គំរោងជួយសំរាប់កសាងសម្ថភាព និងគំរោងទ្រទ្រង់ដល់កម្មវិធីជាអាទិភាពជាប្រចាំខ្លះ។

មានភាពខុសគ្នាខ្លះរវាងតំរូវការប៉ាន់ស្មានសំរាប់ ESSP និង MTEF ។ ភាពខុសគ្នាទាំងនេះនឹង ត្រូវយកមកពិភាក្សាជាបន្ថែម ទៀតដើម្បីធានាអោយស៊ីសង្វាក់គ្នាគ្រប់ពេល។ ភាពខុសគ្នាទាំងនោះរួមមាន ការផ្លាស់ប្តូរប្រែប្រួលចំណាយថវិកា លើប្រាក់បៀវត្សបុគ្គលិក និងការលំបាកក្នុងការដាក់បញ្ចូលគំរោងនានានៃ MTEF ទៅក្នុងកម្មវិធីជាប្រចាំ។ ខាងក្រោមនេះ ជាការសរុបសកម្មភាពចំណាយនៃ យជកភ ក្នុងផ្នែកអប់រំ:

- ចំណាយមួយចំនួនធំសំរាប់ផែនការសកម្មភាពដែលមានក្នុងតារាងម៉ាត្រិច(ឧបសម្ពន្ធ៍3) អាចធ្វើទៅ បាន និងបញ្ជាក់ថា ថវិការដ្ឋាភិបាលសំរាប់ឆ្នាំ ២00៣-២00៤ និង ២00៥ ត្រូវបានបែង ចែកស្របជាមួយការប៉ាន់ស្មានទុក ជាមុនកាល ពីខែកញ្ញា ២00២។
- ទោះបីយ៉ាងណាក៏ដោយ ក៏មានគំលាតហិរញ្ញប្បទានយ៉ាងខ្លាំង ដែលទាក់ទងនឹងការផ្តល់ថវិកាសំរាប់ ហេត្ថារចនា សម្ព័ន្ធអាទិភាព។ ក្នុងខណៈដែលក្រសួងកំពុងតែលើកកំពស់ការវាយតំលៃនៃតម្រូវការ ជាអតិភាព និងកំណត់ធន ធានដែលមាន និងដែលអាចយកមកប្រើប្រាស់បាន ការប៉ាន់ស្មានគំលាត នៅឆ្នាំ ២00២ មានចំនួនយ៉ាងហោចណាស់ ៣៧ លាន ដុល្លារសំរាប់រយៈពេលពីឆ្នាំ ២00៣ ដល់ ២00៥ ។
- ដូចបានបញ្ជាក់ដោយ MEF នៅឯសិក្ខាសិលា NPRS លើកទីបី ភាពទន់ខ្សោយមួយ ចំនួនក្នុងថវិកា និង MTEF នឹងត្រូវយកមកដោះស្រាយ។ ឧទាហរណ៏ក្នុងផ្នែកអប់រំ ពុំទាន់មានលទ្ធភាពដាក់ បញ្ចូលរាល់ចំណាយក្នុងផ្នែកអប់រំ MTEF ឆ្នាំ ២00៣-២00៥ ទៅក្នុងកម្មវិធីជាប្រចាំនៃ ហិរញ្ញប្បទានដោយគំរោងនានា។ ជាផលវិបាក រាល់ការគ្រោងចំណាយ គឺមិនបានបញ្ចូលទៅក្នុង ផែនការសកម្មភាពចំណាយអប់រំក្នុងម៉ាត្រិច។ ផែនការការងារ ESSP សំរាប់ឆ្នាំខាងមុខមានបណ្តិវិធានការសំដៅដោះស្រាយបញ្ហារួមគ្នាជាមួយ MEFនិងដៃគូរផ្តល់ជំនួយរបស់MOEYS ។

សរុបមក យជកភ គំរោពិចារណាអំពីការបង្ហាញការកាត់បន្ថយភាពក្រីក្រចិត អប់រំនៃ ESSP ។ គំរោងហិរញ្ញប្បទាន យជកភ ក្នុងករណីអប់រំគឺមានភាពស្របគ្នាទៅនឹងថវិការដ្ឋាភិបាលនិង MTEF ។ មានបន្ថយការដើម្បីកែសំរួលផ្នែក អទិភាពរបស់ ESSP ប្រចាំឆ្នាំដោយមានការពិគ្រោះយោបល់ទូលំទូលាយ និងផ្តេកលើការត្រួតពិនិត្យដ៏ហ្មត់ចត់ នៃការរីកចំរើន ជាមួយនឹងសូចនាករអនុវត្តន៏ ដែលបានកំនត់រួចក្រសួងអប់រំមានជំនឿថា សារៈប្រយោជន៏នៃរបៀបដោះស្រាយនេះ និងមានផល ប្រយោជន៏ពេញលេញក្នុងបរិបទ នៃការអនុវត្តន៏នៃ យជកភ ។

គោលនយោបាយសារពើពន្ធប្រកបដោយចីរភាព គឺមានសារៈសំខាន់សំរាប់ការកាត់បន្ថយភាពក្រីក្រ។ ឱនភាពសារពើពន្ធដ៏ធំសម្បើមនឹងប៉ះប៉ាល់ដល់ប្រជាជនក្រីក្រ ព្រោះវាធ្វើអោយមានការរីកចំរើនយឺត និងការចំណាយ ពុំមានប្រសិទ្ធភាព។

ក្រៅពីមានមុខនាទីក្នុងការគៀងគរ និងបែងចែកធនធាន យុទ្ធសាស្រ្ត និងទិសដៅនៃគោលនយោបាយសារពើពន្ធក៏អនុញ្ញាតិអោយថវិកាបំពេញនូវមុខនាទីបែងចែកឡើងវិញដោយប្រសិទ្ធភាព និងចូលរួមចំណែកយ៉ាងប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ។ លទ្ធផលទាំងនេះនឹងមានភាពមិនទៀងទាត់ ប្រសិនបើថវិកាមិនត្រូវបានអនុវត្តតាមវិន័យសារពើពន្ធដ៏តឹងរឹង និងការគ្រប់គ្រងដោយហ្មត់ចត់។

ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងធ្វើអោយសមហេតុផលជាបន្ថែមទៀតនូវ ការចំណាយជាអាទិភាព ដើម្បីអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចនិងសង្គម ជាពិសេសលើផ្នែកអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ដែលជាគោលដៅសំខាន់នៃការកាត់បន្ថយភាពក្រីក្រ។

ចំណាយសាធារណៈត្រូវបានប្រើសំរាប់ការធ្វើអន្តរាគមន៍របស់រដ្ឋាភិបាល និងជា ***ឧបករណ៏នយោ បាយម៉ាក្រូសេដ្ឋកិច្ច*** មួយ សំរាប់បំពេញអោយការបរាជ័យនៃទីផ្សារប្រកួតប្រជែង និងធានាសមភាពក្នុង ការបែងចែកធនធាន។ ***អាស្រ័យដោយកំរិត និងសមភាគចំណាយសាធារណៈអាចមានបច្ច័យដល់ កំណើនសេដ្ឋកិច្ច អតិផរណា និងជញ្ជីងទូទាត់*** រដ្ឋាភិបាលនឹងសំរេចធ្វើអោយដើរស្របគ្នានៃនយោបាយស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយកែទំរង់មីក្រូសេដ្ឋកិច្ច ធានាការគ្រប់គ្រងសេដ្ឋកិច្ចឱ្យបានល្អ។ រដ្ឋាភិបាល ធានាកំរិតចំណាយស្របជាមួយស្ថេរភាពផ្នែកម៉ាក្រូសេដ្ឋកិច្ច និងបន្ទាប់មកកែទំរង់ផ្នែកចំណាយដែលជាផ្នែកមួយនៃផែនការកែទំរង់មានប្រព័ន្ធសំដៅជំរុញសញ្ជ័យវិនិយោគក្នុងស្រុកដែលផ្តល់ផលល្អ និងការបែងចែកធនធានអោយមានប្រសិទ្ធភាព។ កិច្ចការនេះអាចធ្វើទៅបានតាមរយៈបន្តការកែទំរង់អនុវត្តនយោបាយសារពើពន្ធដ៏ហ្មត់ចត់ ផ្តោតលើការគៀងគរចំណូល និងភាពសមហេតុផលនៃចំណាយ។ មូលដ្ឋាននៃគោលនយោបាយនេះគឺធានាសមធម៌ និងប្រសិទ្ធភាព ក្នុងការចំណាយតាមរយៈការបែងចែកធនធានអោយបានច្រើនទៅផ្នែកសេដ្ឋកិច្ច និងសង្គម និងទីបញ្ចប់ ពង្រឹងមូលដ្ឋានសំរាប់ការ អនុវត្តន៍ថវិកានៅតាមក្រសួងអាទិភាព។

ដូចនេះ កម្ពុជាបានប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ហ្មត់ចត់នូវសនិទានកម្មនៃចំណាយ។ មូលដ្ឋាននៃគោលនយោបាយនេះគឺអនុវត្ត <<**កម្មវិធីនយោបាយសង្គមថ្មី**>> មួយសំរាប់កម្ពុជា។ មូលដ្ឋានគ្រឹះនៃនយោបាយសង្គម គឺថាកំណើនត្រូវតែប្រកាន់នូវគន្លងការការពារប្រជាជនក្រីក្រ។ ដោយបានអនុវត្តនូវ <<**កម្មវិធីនយោបាយសង្គមថ្មី**>> នេះសំរាប់កម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការបែងចែកថវិកាសំរាប់ផ្នែកអាទិភាព ដូចជាអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ដែលជាមូលដ្ឋាននៃការរីកចំរើនសមធម៌ និងអភិវឌ្ឍន៍ជាអនាគត។ រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តន៍ការកែទំរង់ក្នុងប្រព័ន្ធអប់រំ និងលើកកំពស់សមត្ថភាពធនធានមនុស្ស ដើម្បីអោយកម្ពុជាឈានទៅប្រកួតប្រជែង និងបង្កើនផលប្រសើរឡើងនៅក្នុងសេដ្ឋកិច្ចពិភពលោក។ <<**កម្មវិធីនយោបាយសង្គមថ្មី**>> ប្រមើលអំពីការបង្កើតសង្គម ដែលមានទំនាក់ទំនងសង្គមល្អ សារៈប្រយោជន៏ខាងអប់រំ មាននិប្បធម៌រស់រវើកនៅកម្ពុជា។ នេះតំរូវអោយមានការយកចិត្តទុកដាក់ដល់បញ្ហាភាព ក្រីក្រ គ្រោះអវិជ្ជា និងជំងឺរាតត្បាត។

បន្ទាប់ពីពីរទសវត្សនៃទំនាស់ផ្ទៃក្នុងនយោបាយនៅកម្ពុជា កម្ពុជាកំពុងកាត់បន្ថយចំណាយផ្នែក សន្តិសុខ និងការពារ។ ជាផ្នែកមួយនៃការប្តូរទិសចំណាយទៅផ្នែកអាទិភាពនោះ ការចំណាយសន្តិសុខ និងការពារ ត្រូវបានកាត់បន្ថយពី ៦ ភាគរយនៃ ផសស នៅឆ្នាំ ១៩៩៤ មកនៅត្រឹម ២,៦ ភាគរយនៃ ផសស នៅឆ្នាំ ២០០៣ ។ ជាមួយគ្នានេះ ក៏មានការបង្កើន មូលនិធិដល់ផ្នែកសង្គម។ ផ្នែកអប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ថាជាផ្នែក អាទិភាព។ ចំណាយសង្គមនឹងបន្តកើនឡើងគួរជាទីមោទនៈ។ ភាគចំណែកនៃកំណើនដ៏ធំនេះនឹងត្រូវប្រើដើម្បីបង្កើនការចំណាយ ផ្នែកសុខាភិបាល និងអប់រំ។

គោលដៅសំខាន់នៃ MTEF ២០០៣-២០០៥ គឺរក្សាទ្រទ្រង់ដល់ការប្តូរផ្លាស់ការបែងចែកធនធានពី ផ្នែកការពារ និងសន្តិសុខទៅក្រសួងអាទិភាព ជាពិសេសអប់រំ និងសុខាភិបាល។ គំរូនេះស្តែងឡើងតាម មធ្យោបាយជាច្រើនដោយបង្កើន បរិមាណភាគទៅក្រសួងអាទិភាព ឬ និយាយអោយចំទៅ គឺបមាណភាគនៃថវិកា និងបមាណភាគនៃ ផសស ដែលមាន បង្ហាញក្នុងតារាង ៥-១។ គួរកត់សំគាល់ដែរថា ផែនការទាំងនេះអាចធ្វើទៅបានគឺ អាស្រ័យមួយចំណែកធំលើលទ្ធភាព នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលចំណូលគ្រប់ផែនការ (សូមអានផ្នែក៥-១) ព្រមជាមួយការលើកកំពស់ការគ្រប់គ្រង ចំណាយសាធារណៈ (សូមអានផ្នែក៥-៤)។

### តារាង ៥.១ កំណើនមាណភាគ នៃក្រសួងអាទិភាព ដែលមានការធ្លាក់ចុះផ្នែកការពារ និងសន្តិសុខ

(គិតជាភាគរយនៃចំណាយជាប្រចាំ)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| | ជាក់ស្តែង | ជាក់ស្តែង | ថវិកា | | គ្រោង | |
| សុខាភិបាល | 8.4 | 9.5 | 10.9 | 12.0 | 12.5 | 12.9 |
| អប់រំ | 14.0 | 16.2 | 18.2 | 18.5 | 19.5 | 20.0 |
| សន្តិសុខ និងការពារ | 37.1 | 30.1 | 24.7 | 22.0 | 20.8 | 19.4 |
| អប់រំ និងសុខាភិបាល | 22.4 | 25.7 | 29.1 | 30.5 | 32.0 | 32.9 |
| អប់រំ និងសុខាភិបាល កសិកម្មអភិវឌ្ឍន៍ជនបទ ចំណាំ | 25.3 | 30.3 | 32.9 | 33.9 | 35.8 | 37.3 |
| ចំណាយជាប្រចាំគិតជាលានរៀល | 1,228,540 | 1,389,128 | 1,595,847 | 1,784,100 | 2,033,353 | 2,276,032 |

ប្រភព : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ស្របតាមក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលបានកំណត់ក្នុង យជកភ ថវិកាឆ្នាំ ២០០៣ និងផ្តល់ការលើកកំពស់ បន្ថែមទៀតក្នុងចំណាយផ្នែកសង្គម និងលើកកំពស់ការគៀងគរធនធាន។ ថវិកាឆ្នាំ ២០០៣ ឈរលើការបង្កើនចំណូល ក្នុងស្រុកដល់ទៅ ១២,៧ ភាគរយនៃ ផសស រួមមានចំណាយជាប្រចាំ ១១,៤ ភាគរយ និងរក្សាអតិរេកចរន្តចំនួន ១,១ ភាគរយនៃ ផសស។ ឱនភាពថវិការួមនឹងត្រូវក៏រិតចំពោះជំនួយសម្បទាន និងដោយគ្មានហិរញ្ញប្បទានថវិកាក្នុងស្រុក។ ការរក្សា អតិរេកថវិកាជាប្រចាំ និងជាការសំខាន់ ដើម្បីធានាបន្តការអនុវត្តន៍សេដ្ឋកិច្ចអោយបានល្អ។ ការកែទំរង់រចនាសម្ពន្ធ័ និងសារពើ

ពន្ធដូចដែលបានរៀបរាប់ខាងលើ នឹងបង្កើនសក្តានុពលភាពកំណើននៃចំណូល។ មួយផ្នែកនៃចំណូលដែលបានមកពីការលើកកំពស់សារពើពន្ធ អាចត្រូវបានប្រើប្រាស់សំរាប់បង្កើនការចំណាយសេដ្ឋកិច្ចសង្គម និងសំរាប់មុខចំណាយថ្មីៗ ព្រមជាមួយនោះនៅតែរក្សាស្ថានភាពថវិកាអោយបានល្អ (តារាង ៥.២)។

**តារាង ៥.២ ចំណាយថវិកាតាមក្រសួង ឆ្នាំ ១៩៩៩-២០០៣**

| *ឯកតា: លានរៀល* | **១៩៩៩** | ២០០០ | ២០០១ | ២០០២ | ២០០៣ |
|---|---|---|---|---|---|
| **ចំណាយចរន្ត** | **១.០៩៥.៨៩៩** | **១.២១៩.៤៧៧** | **១.៤១៥.៦៣៤** | **១.៥៧៥.៤០០** | **១.៧៤៥.០០០** |
| **រដ្ឋបាលទូទៅ** | **១៨១.៩៩២** | **២២៩.៣៩៥** | **៣២៩.៧៩៣** | **២២៨.៩៦៥** | **២៨៥.៦៩៥** |
| - ព្រះបរមរាជវាំង | ២០.៤៤២ | ១៩.៧៧៥ | ១៩.០១៤ | ២១.២០០ | ២២.៧៤០ |
| - សភាជាតិ | ១៣.១៥៨ | ២០.៦៥០ | ៣១.៦៦៥ | ៣៣.១៦០ | ៣៥.១៥០ |
| - ព្រឹទ្ធសភា | ៦.៣៩៤ | ១០.១៤០ | ១៤.៩៣២ | ១៦.៦០០ | ១៨.០៥០ |
| - ក្រុមប្រឹក្សាធម្មនុញ្ញ | ១.៦៧៣ | ២.១៦៥ | ២.៧៨២ | ៣.០៥០ | ៣.៣០០ |
| - ទីស្តីការគណៈរដ្ឋមន្ត្រី | ៤៣.៤៣៤ | ៧៥.២៧៥ | ៩៩.៦៨៣ | ៤៧.២៥០ | ៥៧.៧៥០ |
| - លេខាធិការដ្ឋានមុខងារសាធារណៈ | ៤០០ | ៦១៣ | ៧០៤ | ១.០៤០ | ១.២៥០ |
| - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១.១២៧ | ២.០៣០ | ២.៤០៨ | ៣.១០០ | ៣.៩៨០ |
| រដ្ឋបាលទូទៅ | ៦.៨៧៥ | ៨.៥៧៤ | ២២.២៤១ | ១២.៩៥០ | ១៦.៤០០ |
| - ទំនាក់ទំនងសភា | ៤៧៣ | ៩៣៩ | ១.០៣៧ | ១.៤៨០ | ២.៦៦០ |
| - ការបរទេស និង សហប្រតិបត្តិការ | | | | | |
| អន្តរជាតិ | ៣៦.៤៧២ | ៣៦.១៩៩ | ៤១.២៨៦ | ៤៨.១៤៥ | ៥២.០០០ |
| - សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ៤២.៧០៦ | ៤១.៥១៥ | ៣៩.៩១៣ | ២២.៩០០ | ៥០.៩៣០ |
| - ផែនការ | ២.២០២ | ៣.២៤៧ | ៣.៧១៤ | ៤.២៨៥ | ៥.៣៧៥ |
| - យុត្តិធម៌ | ៤.៤៥៤ | ៥.៧៨៤ | ៦.៣៧៧ | ៨.៣១៥ | ៩.៦៥០ |
| - គណៈកម្មការជាតិបោះឆ្នោត | ២.១៨១ | ២.៤៩០ | ៣៦.៨៩៧ | ២.៨០០ | ៣.២៣៥ |
| - NAA | | | | ២.៦៥០ | ៤.៥៨៥ |
| **ការពារជាតិ និង សន្តិសុខជាតិ** | **៤៦៨.០៦១** | **៤៥០.៧២៤** | **៤០៦.៥៥៦** | **៣៩០.០០០** | **៤១៤.៥០០** |
| - ការពារជាតិ | ៣៣៥.៧៤៤ | ៣០៨.៥៦០ | ២៦៧.៨៥៦ | ២៥៥.០០០ | ២៦៨.៣០០ |
| - មហាផ្ទៃ និង សន្តិសុខសាធារណៈ | ១៣២.៣១៧ | ១៤២.១៦៥ | ១៣៨.៧០០ | ១៣៥.០០០ | ១៤៥.២០០ |
| **រដ្ឋបាលសង្គមកិច្ច** | **៣០០.៩៥៥** | **៣៦៨.៨០៣** | **៤៥៥.៩៣៨** | **៥៨២.៧៣៥** | **៦៦៤.១៥០** |
| - ក្រសួងពត៌មាន | ៤.៦៩៣ | ៨.៩៤៣ | ៨.២១៥ | ៨.៤០០ | ១២.៦១៥ |
| - ក្រសួងសុខាភិបាល | ៧៥.៣៦៦ | ១០១.៨០៨ | ១៣០.២៩៤ | ១៧១.៧០០ | ២០២.០០០ |
| - ក្រសួងអប់រំយុវជន និងកីឡា | ១៤៩.៧៨១ | ១៦៥.៨១៦ | ២១២.៣០៦ | ២៨៦.២០០ | ៣២៣.០០០ |

| | | | | | |
|---|---|---|---|---|---|
| - ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ៥.១៣៦ | ៧.០៥២ | ៨.២៤៦ | ១១.១១៥ | ១៤.៦៤០ |
| - ក្រសួងបរិស្ថាន | ២.១៩០ | ៣.៨៥២ | ៤.៤៩៩ | ៦.៩៨០ | ៨.៦៧៥ |
| - ក្រសួងសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និង និតិសម្បទា | ១៨.៨៧០ | ២៦.៤៥២ | ២៩.៦០៥ | ៣២.៩២០ | ៣៣.៦៣០ |
| - ធម្មការ និង សាសនា | ១.៤៤០ | ១.៨៦០ | ២.៣៤២ | ២.៩៣៥ | ៣.៦១៥ |
| - កិច្ចការនារី និង អតីតយុទ្ធជន | ៤៣.១៥៥ | ៥២.៩៨០ | ៦០.០៣៣ | ៦២.៤៨៥ | ៦៥.៩៧៥ |
| **រដ្ឋបាលសេដ្ឋកិច្ច** | **៩៣.៧៦៤** | **១១២.៥១២** | **១៥០.៦៥២** | **១៧៣.៣០០** | **១៩០.១៥៥** |
| - អាកាសចរណ៍ស៊ីវិល | ៣.៣៤០ | ៣.៨២៦ | ៥.១៤៩ | ៥.៣០០ | ៧.៣០០ |
| - ឧស្សាហកម្ម រ៉ែ និងថាមពល | ៤.១៣៧ | ៥.៤៨៧ | ៦.០៤៥ | ៧.០៥៥ | ៨.១៥៥ |
| - ពាណិជ្ជកម្ម | ៣.៨៩៦ | ៦.២៣៩ | ១១.៨៧៧ | ១៣.៩៦០ | ១៨.០០០ |
| - កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២១.១៧៨ | ២៣.៤១៤ | ៣១.៣៨៧ | ៤០.០០០ | ៤៣.៣៤០ |
| - អភិវឌ្ឍន៍ជនបទ | ៣.២៥៦ | ៧.៥៥៨ | ១២.៥១៣ | ២០.០០០ | ២១.០០០ |
| - ប្រៃសណីយ និង ទូរគមនាគមន៍ | ៣៧.៩៥៨ | ២៨.៧៦៦ | ៣៩.៩៤៥ | ៣៨.៦៤០ | ៤២.៧៥០ |
| - សាធារណៈការ និងដឹកជញ្ជូន | ៩.៣២២ | ២០.៣១៧ | ២១.៤៥៦ | ២២.៩៤០ | ១៥.០៣០ |
| - ទេសចរណ៍ | ៥.១០៦ | ៦.៣៩៦ | ៨.៧១៨ | ៩.៨៤០ | ១២.១៤០ |
| - រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ២.៣៥៤ | ៤.៣១១ | ៤.៧៤៣ | ៥.៦១០ | ៨.០០៥ |
| - ធនធានទឹក និង ឧតុនិយម | ៣.១៧៦ | ៦.១៩៩ | ៨.៨១៩ | ៩.៩៥៥ | ១៤.៤៣៥ |

ប្រភព: ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ជាផ្នែកមួយនៃគោលនយោបាយចំណាយនេះ ថវិកាឆ្នាំ២០០៣ មានគោលដៅកាត់បន្ថយការចំណាយក្នុងវិស័យការពារ និងសន្តិសុខជាតិ ពី ៣,០៣ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០០១ មកនៅត្រឹម ២,៦៤ ភាគរយនៃ ផសស ក្នុងឆ្នាំ ២០០៣ ។ ការចំណាយក្នុវិស័យសង្គមកិច្ចនឹងបន្តកើនឡើងយ៉ាងច្រើនសន្ធឹកសន្ធាប់ (តារាង ៥.២) ។ ចំណែកមួយភាគធំនៃកំនើននេះនឹងត្រូវប្រើប្រាស់ដើម្បីបង្កើនថវិកានៃកម្មវិធី PAP សំរាប់ក្រសួងអាទិភាពនានា ។ ដើម្បីគាំទ្រគោលនយោបាយវិស័យសង្គមកិច្ចដែលបានលើកឡើងមុននេះ ថវិកា ២០០២ សំរាប់វិស័យអប់រំត្រូវបានបង្កើនដល់ ១៨,៣ ភាគរយនៃថវិកាចរន្ត និងសំរាប់វិស័យសុខាភិបាល កើនដល់ ១១,៤ ភាគរយនៃថវិកាចរន្ត ។

តួលេខប៉ាន់ស្មាននៃការចំណាយសំរាប់កម្មវិធីនានា ស្ថិតក្រោមយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ត្រូវបានរៀបចំឡើងដោយសាម៉ីក្រសួងនានា ។ នៅក្នុងករណីវិស័យអប់រំ និងសុខាភិបាល តួលេខប៉ាន់ស្មាននេះរៀបចំឡើង ជាផ្នែកមួយនៃយុទ្ធសាស្ត្រតាមវិស័យ ដែលបច្ចុប្បន្នយុទ្ធសាស្ត្រទាំងនេះគាំទ្រដល់គោលនយោបាយនានានៅក្នុងវិស័យទាំងអស់នោះ ។ ដូចដែលបានកត់សំគាល់ពីខាងដើម កម្មវិធីមួយចំនួនកំពុងអនុវត្តន៍ ខ្លះទៀតកំពុងត្រូវបានពង្រីក និងមួយចំនួនទៀត គឺជាគំនិតផ្តួចផ្តើមថ្មី ។ តំលៃ

ប៉ាន់ស្មានទាំងនេះ នៅជាកម្មវត្ថុនៃការវិភាគជាបន្ត និងគប្បីចាត់ទុកជាតួលេខបឋមសិន ។ ទិន្នន័យលំអិតជាងនេះអំពីការចំណាយលើកម្មវិធីនានា មានបង្ហាញជូននៅក្នុងម៉ាទ្រីសនៃផែនការសកម្មភាពក្នុងឧបសម្ព័ន្ធ ៣ ។ តារាង ៥.៣ ផ្តល់ជូននូវតួលេខចំណាយសង្ខេបនៃកម្មវិធីនានាទៅតាមផ្នែកសំខាន់ៗនៃសកម្មភាពគោលនយោបាយដែលត្រូវប្រកាន់យក ។

លើផ្នែកចំណាយ វាមានសារៈសំខាន់ណាស់ក្នុងការធានាអោយសមាសភាគនានានៃការចំណាយ រួមចំណែកដល់កំនើនសេដ្ឋកិច្ចលើមូលដ្ឋានទូលំទូលាយមួយ និងការពារផលប្រយោជន៍ជនងាយរងគ្រោះ ។ គេអាចវាយតំលៃបានថ្វីត្បិតជារឿយៗវាមានការលំបាក នូវប្រសិទ្ធិភាព និងសមភាពនៃការចំណាយរបស់រដ្ឋាភិបាល ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ការយកកំរៃដើម្បីរាប់ការចំណាយអាចជួយលើកកំពស់ប្រសិទ្ធិភាព និងភាពខ្ជះខ្ជាយក្នុងការប្រើប្រាស់ប៉ុន្តែអាចនឹងរារាំងជន ក្រីក្រក្នុងការប្រើប្រាស់សេវាសាធារណៈនេះ ។ ដោយមូលហេតុនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវការលើកលែងមិនយកកំរៃសំរាប់ជនក្រីក្រ ដើម្បីអោយពួកគេមានលទ្ធិភាពប្រើប្រាស់សេវាក្នុងវិស័យសុខាភិបាល និងអប់រំ តែចាំបាច់ត្រូវមានការវាយតំលៃឯករាជ្យនូវស្ថានភាពជនទាំងនោះ ដើម្បីកំនត់អ្នកណាអាចបង់បាន និងអ្នកគ្មានលទ្ធភាពបង់ ។

ជាចុងក្រោយ រាជរដ្ឋាភិបាលមានបំណងចង់លើកឡើងនូវបញ្ហាស្ត្រី គឺមិនត្រឹមតែនៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងសកម្មភាពនោះទេ តែគឺនៅក្នុងការបែងចែកថវិកាផ្ទាល់ ។ ប្រការនេះមានន័យថាមិនគ្រាន់តែផ្តល់ថវិកាចំណាយសំរាប់សកម្មភាពស្ត្រីនោះទេ ប៉ុន្តែជាការចាំបាច់ត្រូវធ្វើការវិភាគលើគោលនយោបាយពាក់ព័ន្ធនឹងផលប៉ះពាល់ទៅលើកុមារា កុមារី ស្ត្រី និងបុរសដោយលើកឡើងនូវដំណោះស្រាយចំពោះបញ្ហាវិសមភាព កើតមានការឆ្លុះបញ្ចាំងនៅក្នុងមុខចំនាយនានានៃថវិកា ។ វិស័យនេះត្រូវការបន្តវិភាគ និងចាំបាច់ត្រូវឆ្លុះបញ្ចាំងនៅក្នុងការធ្វើវិភាជន៍ថវិកានាពេលអនាគត ។

ដើម្បីសំរេចបាននូវសមភាព និងប្រសិទ្ធិភាពនៅក្នុងការចំណាយគេចាំបាច់ត្រូវបែងចែកថវិកាអោយបានច្រើនថែមទៀតទៅដល់វិស័យសង្គមកិច្ច និងកសិកម្ម ។ ក្រៅពីនេះថវិកាផ្អែកលើមូលដ្ឋាននៃការអនុវត្តន៍ (Performance-based Budget) នឹងត្រូវដាក់អោយអនុវត្តនៅតាមបណ្តាក្រសួងអាទិភាពនានា ។ រាល់គំនិតផ្តួចផ្តើមទាំងអស់នេះនឹងត្រូវអនុវត្តប្រកបដោយតម្លាភាព ការទទួលខុសត្រូវ និងមានសន្ទុះលឿនទៅមុខនៅក្នុងគ្រប់វិស័យទាំងអស់នៃសកម្មភាពរបស់រាជរដ្ឋាភិបាល ។ ចំណាត់ការ និងវិធីសាស្ត្រទាំងអស់នេះមានសង្គតភាពជាមួយនឹងកិច្ចខិតខំទប់ស្កាត់នូវអំពើពុករលួយដែលរដ្ឋាភិបាលមានឆន្ទៈនឹងជីករំលើងឬសគល់របស់វានៅក្រោមផែនការសកម្មភាពអភិបាលកិច្ច (GAP) ។

# តារាង ៥.៣ តំលៃ យជកភ នៃផែនការសកម្មភាពឆ្នាំ ២០០៣-២០០៥

(ឯកតាដុល្លាសហរដ្ឋអាមេរិក)

| | | |
|---|---|---:|
| ១ | **បង្កើនកាលានុវត្តភាពរកចំណូល** | **២១៦.000.000** |
| ១.១ | រក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច | ២.000.000 |
| ១.២ | បង្កើនជីវភាពរស់ដល់អ្នកក្រីក្រនៅតាមជនបទ | |
| ១.២.១ | បង្កើនការកាន់កាប់ដី | ១២.000.000 |
| ១.២.២ | បង្កើនការអភិវឌ្ឍន៏វិស័យកសិកម្ម | ២៧.000.000 |
| ១.២.៣ | អភិវឌ្ឍន៍ការគ្រប់គ្រងប្រភពទឹក និងប្រព័ន្ធស្រោចស្រព | ១៥.000.000 |
| ១.២.៤ | អភិវឌ្ឍន៍ផ្លូវគមនាគមន៍ និងការដឹកជញ្ជូន | ១៦០.000.000 |
| ២ | **ពង្រីកកាលានុវត្តភាពការងារ** | **៥៧០.000.000** |
| ២.១ | អភិវឌ្ឍន៏វិស័យឯកជន | ៤.000.000 |
| ២.២ | អភិវឌ្ឍន៍ពាណិជ្ជកម្ម | ៤.000.000 |
| ២.៣ | បង្កើនវិស័យទេសចរណ៍ | ១០.000.000 |
| ២.៤ | មីក្រូហិរញ្ញវត្ថុ | ១០.000.000 |
| ២.៥ | បង្កើនជំនាញការងារ | ២៦.000.000 |
| ២.៦ | កែលំអលទ្ធភាពថាមពលអគ្គិសនី | ៥០០.000.000 |
| ២.៧ | អភិវឌ្ឍន៍ទីក្រុង | ១៦.000.000 |
| ៣ | **បង្កើនសមត្ថភាព** | **៥០៩.000.000** |
| ៣.១ | សុខភាពប្រសើរជាងមុន | ១២៩.000.000 |
| ៣.២ | អាហារូបត្ថម្ភ | ៤២.000.000 |
| ៣.៣ | សិក្សាអប់រំ | ៣៣៨.000.000 |
| ៤ | ពង្រឹងស្ថាប័ន និង | ១០២.000.000 |
| ៤.១ | បង្កើនអភិបាលកិច្ច | ១០.000.000 |
| ៤.២ | កែទំរង់វិស័យយុត្តិធម៌ | ៤០.000.000 |
| ៤.៣ | កែទំរង់រដ្ឋបាល និងសេវាកម្មស៊ីវិល | ៥០.000.000 |
| ៤.៤ | វិមជ្ឈការ និងបង្កើនអភិបាលកិច្ចមូលដ្ឋាន និងប្រឆាំងអំពើពុករលួយ | ២.000.000 |
| ៥ | **កាត់បន្ថយភាពងាយរងគ្រោះ** | **១៧៤.000.000** |
| ៥.១ | បង្កើនសន្តិសុខស្បៀង | ៨.000.000 |
| ៥.២ | រក្សាសន្តិសុខសង្គម និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស | |
| ៥.២.១ | ថែរក្សាសន្តិសុខសង្គម | ១៤.000.000 |
| ៥.២.២ | កម្មវិធីសុវត្ថិភាពសង្គម | ២.000.000 |

| | | |
|---|---|---|
| ៥.២.៣ | ប្រយុទ្ធប្រឆាំងការប្រើប្រាស់កុមារ, ការជួញដូរ និងថែរក្សាកុមារ | ២៦.000.000 |
| ៥.៣ | ហ៊ីវ/ អេដស៍ | ៤0.000.000 |
| ៥.៤ | គ្រប់គ្រងគ្រោះមហន្តរាយ | ៤២.000.000 |
| ៥.៥ | សកម្មភាពមីន | ៣0.000.000 |
| ៥.៦ | បង្កើនការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ | ១0.000.000 |
| ៥.៧ | អភិវឌ្ឍន៍ជនជាតិភាគតិច | ២.000.000 |
| ៦ | **បង្កើនសមភាពយេនឌ័រ** | **៧.000.000** |
| ៧ | **កំរូវការប្រភពធនធានសាធារណៈ និងការគ្រប់គ្រង** | **៦.000.000** |
| | **សរុប** | **១.៥៨៤.000.000** |
| | **ហិរញ្ញប្បទាន** | |
| | **ថវិការដ្ឋ** | **២៣0.000.000** |
| | **ចំណាយទុន** | **១៩៥.000.000** |
| | **វិនិយោគផ្ទាល់ពីបរទេស** | **២៥0.000.000** |
| | **ជំនួយអភិវឌ្ឍន៍ផ្លូវការ** | **១.0៨៤.000.000** |
| | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **៦៦៥.000.000** |

ប្រភព: ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការបង្វែរការចំណាយលើវិស័យការពារជាតិ និងសន្តិសុខសង្គម គឺជាចំណុចគន្លឹះដើម្បីបង្កើនការចំណាយលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ដែលរួមចំណែកការកាត់បន្ថយភាពក្រីក្រ ។ ជាមួយនេះដែរ យជកភ គឺមានទំនាក់ទំនងជាមួយថវិកាជាតិមិនអាចខ្វះបានដើម្បីការផ្តល់ហិរញ្ញប្បទាន ។ តំលៃប៉ាន់ស្មានរបស់ផែនការសកម្មភាពក្នុងកំឡុងពេលបីឆ្នាំខាងមុខ ២00៣-២00៥ គឺ ១,៥ ពាន់លានដុល្លាអាមេរិក (មើលតារាង ៥.៣) មានន័យថារដ្ឋាភិបាលត្រូវចំណាយជាអប្បរមា ៥00 លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ ផែនការចំណាយទាំងនេះ នឹងត្រូវផ្តល់ហិរញ្ញវត្ថុដោយប្រភពទុនរបស់រដ្ឋាភិបាល (២៣0 លានដុល្លាអាមេរិក), វិនិយោគផ្ទាល់ពីបរទេស (២៥0 លានដុល្លាអាមេរិក) និងជំនួយអភិវឌ្ឍន៍ពីបរទេស (១,0៨ ពាន់លានដុល្លាអាមេរិក) ។

រដ្ឋាភិបាលគ្រោងចំណាយលើសពី ១ពាន់លានដុល្លាអាមេរិក ក្នុងរយៈពេល ៣ឆ្នាំខាងមុខនេះ ដើម្បីពង្រីកកាលានុវត្តភាពការងារ និងពង្រឹងសមត្ថភាពដល់អ្នកក្រីក្រ ដោយធ្វើការផ្តោតទៅលើសុខភាព និងការអប់រំ ។ ការបង្កើនកាលានុវត្តភាពការងារ យជកភ បានលើកឡើងថា ត្រូវមានការវិនិយោគច្រើនទៅលើផ្នែកថាមពល ដែលជាផ្នែកមួយអាចទទួលហិរញ្ញវត្ថុពីវិស័យឯកជនតាមរយៈគំរោង BOT ។ យជកភ បានលើកឡើងពីការចំណាយ ២១៦ លានដុល្លាអាមេរិក ដើម្បីបង្កើនកាលានុវត្តភាពចំណូលជាពិសេសលើគំរោងផ្លូវគមនាគមន៍ និងការដឹកជញ្ជូន ។ លើសពីនេះទៀតរដ្ឋាភិបាល គ្រោងចំណាយ ១0២ លានដុល្លាអាមេរិក និង ១៧៤ លានដុល្លាអាមេរិក លើការពង្រឹងស្ថាប័ន, អភិបាលកិច្ច និងកាត់បន្ថយភាពងាយរងគ្រោះ ។ តំលៃសំណើរបស់ យជកភ មានទំនាក់ទំនងជាមួយថវិកា ដែលនឹងធ្វើការពិភាក្សាដូចខាងក្រោម ។

អភិបាលកិច្ចល្អ គឺជាស្នូលនៃកម្មវិធីកំណែទំរង់របស់រាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលបានអនុម័តកាលពី ខែមិនា ឆ្នាំ ២០០១ នូវផែនការសកម្មភាពអភិបាលកិច្ច ដើម្បីប្រមូលផ្ដុំគំនិតផ្ដួចផ្ដើមទាំងអស់ដែលពាក់ព័ន្ធដល់បញ្ហាអភិបាលកិច្ចមកនៅក្នុងក្របខ័ណ្ឌរួមមួយ ដើម្បីធានានូវការអនុវត្តន៍អោយបានរលូន និងស៊ីសង្វាក់គ្នា ។ ប្រការនេះតំរូវអោយមានប្រព័ន្ធច្បាប់មួយដែលអាចនិទស្សន៍ដឹងមុន និងអនុវត្តបានដែលមានប្រយោជន៍ដល់ការទាក់ទាញវិនិយោគបរទេស និងជួយការពារនូវសេរីភាពបុគ្គលព្រមទាំងសិទ្ធិរបស់ពលករ ។ អភិបាលកិច្ចល្អអាចជួយលើកកំពស់នូវគុណភាពនៃសេវាសាធារណ និងជាយន្តការមួយជួយអោយមានការទទួលខុសត្រូវ និងតម្លាភាពច្រើនឡើងនៅក្នុងសង្គម និងជាសង្គ្រាមគ្មានទីបញ្ចប់ប្រឆាំងនឹងអំពើពុករលួយ ។

បច្ចុប្បន្នដោយកង្វះខាតទិន្នន័យ និងសមត្ថភាពជំនាញយើងមិនអាចមានលទ្ធភាពធ្វើការវាយតំលៃការចំណាយសំរាប់គ្រប់សកម្មភាពដែលបានកំណត់នៅក្នុង យជកភ នេះអោយបានពេញលេញនៅឡើយទេ ។ ទោះបីយ៉ាងនេះក្ដី រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតឡើងនូវផែនការសារពើពន្ធរួមមួយសំរាប់រយៈពេលមធ្យមដែលត្រូវបានបែងចែកទៅតាមវិស័យជាច្រើនយ៉ាងទូលំទូលាយ (កថាខ័ណ្ឌ ៥.៤) ។ គេអាចធ្វើការវាយតំលៃការចំនាយ លើគំរោងសំខាន់ៗមួយចំនួន ជាពិសេសនៅក្នុងវិស័យអប់រំ និងសុខាភិបាល ។

## ៥.៣ វិធានការកែលំអការគ្រប់គ្រងថវិកា (ការអនុវត្តន៍ និងការបើកផ្ដល់ថវិកា)

ប្រព័ន្ធអនុវត្តន៍ថវិកានៅកម្ពុជា មានលក្ខណៈប្រមូលផ្ដុំខ្ពស់ ។ ប្រព័ន្ធអនុវត្តន៍ថវិការបែបនេះ ធានាបាននូវវិន័យក្នុងការចំណាយថវិកាល្អប្រសើរជាខ្លាំង ។ ក៏ប៉ុន្តែការត្រួតពិនិត្យតឹងតែងបែបនេះធ្វើអោយសាម៉ីក្រសួងមានការលំបាកក្នុងការគ្រប់គ្រងកម្មវិធីរបស់ខ្លួនប្រកបដោយគំនិតផ្ដួចផ្ដើម និងកាត់បន្ថយប្រសិទ្ធិភាពផ្នែកបច្ចេកទេសនៃដំណើរការអនុវត្តន៍ថវិកា ព្រោះប្រព័ន្ធវិមជ្ឈការខ្ពស់រមែងក៏រិតភាពទន់ភ្លន់របស់ថវិកា និងចំណាយការប្រឹងប្រែងខ្លាំងទៅលើការងារក្រដាសស្នាម ឬឯកសារ។ លើសពីនោះការអនុវត្តន៍ថវិការមែងពើបប្រទះនូវបញ្ហានានា ដូចជាការចំនាយច្រើនយឺតយ៉ាវអូសបន្លាយទៅចុងឆ្នាំសារពើពន្ធ និងបញ្ហាខ្វះការសម្របសម្រួលរវាងថវិកាមូលធន និងថវិកាចរន្ត ។

ចំណែកមួយនៃ "ការយឺតយ៉ាវ" (Back-loading) បង្ហាញអោយឃើញនូវបញ្ហាកំនត់ពេលវេលានៃការធ្វើលទ្ធកម្ម និងការចំណាយដែលប្រែប្រួលរដូវកាល ដូចជាសម័យប្រឡងនានា ។ បញ្ហាយឺតយ៉ាវ (Back-loading) នៃការអនុវត្តចំណាយនេះបង្កើតឡើងនូវភាពមិនច្បាស់លាស់មិនអាចដឹងមុនបាននៅក្នុងការអនុវត្តន៍ថវិកា ដែលមានផលប៉ះពាល់ជាអវិជ្ជមានទៅលើគុណភាពនៃសេវា ។ ភាពមិនច្បាស់លាស់នៃពេលវេលាបើកផ្ដល់ថវិកាពីរតនាគាររួមផ្សំនឹងភាពយឺតយ៉ាវក្នុងការទូទាត់នេះនៅក្នុងឆ្នាំថវិកានិមួយៗ ធ្វើអោយមានការយោគយល់ ឬភាពសម្របសម្រួលយ៉ាងធ្ងន់ធ្ងរចំពោះប្រសិទ្ធិភាពនៃការចំណាយថវិកាលើសេវាសំខាន់ៗមួយចំនួនដែលបំរើអោយជនក្រីក្រ ។ អាស្រ័យហេតុនេះ ការកែតំរូវពេលវេលានៃការបើកផ្ដល់ថវិកា គឺប្រហែលជាវិធាន-ការណ៏កំណែទំរង់មួយបន្ទាន់បំផុតនៅក្នុងការអនុវត្តន៍ថវិកា ដើម្បីទទួលបាននូវតំលៃសមស្របពីប្រាក់ដែលបានចំណាយនៅក្នុងវិស័យសង្គមកិច្ច ។

ភាពយឺតយ៉ាវ （Back-laoding） នេះ គឺទាក់ទងនឹងការគ្រប់គ្រងសាច់ប្រាក់មិនបានល្អគ្មានប្រសិទ្ធិភាព ។ ប្រការនេះ គឺហាក់ដូចជាចំនុចសំខាន់ដែលត្រូវជំរុញអោយមានការជឿនលឿន ដើម្បីលើកកំពស់ស្ថានភាពនៃជំរើសដែលប្រកាន់យកការគ្រប់គ្រងម៉ាក្រូអោយបានល្អជំនួសប្រសិទ្ធិភាពបច្ចេកទេស និងវិភាជន៏ថវិកា ។ ដើម្បីដោះស្រាយបញ្ហានេះចាំបាច់ត្រូវលើកកំពស់ការគ្រប់គ្រងសាច់ប្រាក់ និងប្រព័ន្ធពតិមានវិទ្យាសំរាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ។

បញ្ហាមួយទៀតដែលប៉ះពាល់ដល់ការអនុវត្តន៏ថវិកា គឺបញ្ហាអវត្តមាននៃការសម្របសម្រួលរវាងថវិកាចរន្ត និងថវិកាមូលធន ។ ប្រការនេះ នាំអោយគ្មានការស៊ីសង្វាក់គ្នារវាងបណ្តាអាទិភាពនានានៅក្នុងថវិកាវិនិយោគរបស់ក្រសួងមួយ និងថវិកាប្រចាំឆ្នាំដែលក្រសួងនោះស្នើឡើងបណ្តាលអោយបរាជ័យក្នុងផ្តល់ធនធានថវិកាចរន្តសមស្រមសំរាប់ហេដ្ឋារចនាសម្ព័ន្ធថ្មីនោះ និងមានការចំនាយទាបសំរាប់ដំណើរការ និងការថែទាំ ។

រាជរដ្ឋាភិបាលបានចាត់វិធានការណ៏ដំបូងមួយចំនួន ដែលចាំបាច់ដើម្បីធ្វើអោយការអនុវត្តន៏ថវិកានៅកម្ពុជា មានតម្លា-ភាព មានភាពទន់ភ្លន់ និងឆ្លើយតបនឹងការកាត់បន្ថយភាពក្រីក្រ ។ ការដាក់អោយអនុវត្តនូវកម្មវិធីពន្លឿនការ អភិវឌ្ឍន៏ថ្នាក់ស្រុក （ADD） នៅក្នុងឆ្នាំ ១៩៩៦ និងផែនការសកម្មភាពអាទិភាព （PAP） ក្នុងឆ្នាំ ២000 ដែលអនុញ្ញាតិអោយមានការកើនឡើងនូវចំណាយក្នុងវិស័យសង្គមកិច្ចនៅតាមបណ្តាខេត្តដាច់ស្រយាល និងលើកកំពស់ដំណើការរបស់មន្ទីរពេទ្យបង្អែកមណ្ឌលសុខភាព និងសាលារៀននៅទូទាំងប្រទេស ( ប្រអប់ ៩) ។ យន្តការ PAP អនុញ្ញាតិអោយគ្រូបង្រៀនអាចផ្តល់ថ្នាក់បន្ថែមច្រើនឡើង ជាពិសេសដល់សិស្សក្រីក្រនាំអោយអត្រាបោះបង់ការសិក្សា និងរៀនត្រួតថ្នាក់មានការធ្លាក់ចុះ ។

### ប្រអប់ទី១០: កម្មវិធីពន្លឿនការអភិវឌ្ឍន៏ថ្នាក់ស្រុក និងផែនការសកម្មភាពអាទិភាព

ជាផ្នែកមួយនៃយុទ្ធនាការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាបានផ្តើមធ្វើកំណែទំរង់ ដើម្បីលើកកំពស់ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំ និងអនុវត្តន៏ថវិកា និងប្រព័ន្ធលទ្ធកម្មសាធារណៈ ដើម្បីធានានូវតម្លាភាព និងការទទួលខុសត្រូវក្នុងការចំណាយថវិការដ្ឋ ។ កំណែទំរង់នេះរួមមានវិធានការណ៏ជាច្រើនត្រូវអនុវត្ត ។ រាជរដ្ឋាភិបាលមានគោលបំណងធ្វើការសិក្សាស្រាវជ្រាវដើម្បីពិនិត្យមើលតើធនធានមានកំរិតណាដែលបានទៅដល់ថ្នាក់មូលដ្ឋាន ដូចជាសាលារៀន និងមន្ទីរពេទ្យ ឬមណ្ឌលសុខភាពដើម្បីចាត់វិធានការណ៏កែតំរូវ ។

ដើម្បីលើកកំពស់ការអនុវត្តន៏ និងបើកផ្តល់ថវិកា រាជរដ្ឋាភិបាលមានគោលដៅចាត់វិធានការណ៏ដើម្បីបន្តពង្រឹងយន្តការ PAP ដោយធ្វើការពង្រឹងសមត្ថភាពតាមបណ្តាក្រសួងក្នុងការរៀបចំកម្មវិធីនានាមុនឆ្នាំអនុវត្តថវិកា និងអនុញ្ញាតិអោយមានការ បើកផ្តល់ថវិកាជាស្វ័យប្រវត្តិនៅក្នុងឆ្នាំ ។ ការបើកផ្តល់លើកទីបីនៃថវិកា PAP នឹងជាលក្ខខណ្ឌសំរាប់ការទូទាត់ចំណាយនៅក្នុងការបើកផ្តល់លើកទីមួយធ្វើដូចនេះអាចអនុញ្ញាតិអោយសាម៉ីក្រសួងមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើរបាយការណ៏ ។

រាជរដ្ឋាភិបាល បានលើកឡើងនូវវិធានការណ៏ដោះស្រាយជាក់ស្តែងមួយចំនួនសំរាប់បញ្ហាខាងលើ （PAP and ADD） នៅក្នុងដំណើរការអនុវត្តកម្មវិធីទាំងពីរនេះ ។ យន្តការពីរនេះបង្កើតឡើងដើម្បីបង្ហូរថវិកាចំណាយអោយទៅវិស័យសុខាភិបាល និងអប់រំដោយជៀសវាងនូវឧបសគ្គនៃភាពរឹតត្បិត ការអូសបន្លាយពេលវេលា និងការបាត់បង់ថវិកាដោយប្រកាណាមួយនៅក្នុងដំណើការ និងបរិបទនៃការអនុវត្តន៏ថវិកាធម្មតា ។

***កម្មវិធីពន្លឿនការអភិវឌ្ឍន៏ថ្នាក់ស្រុក ( ADD )***

កម្មវិធី ADD អនុញ្ញាតិអោយបណ្តាស្រុកដែលចូលរួមនៅក្នុងកម្មវិធីនេះ ដកយកថវិកាផ្ទាល់ពីក្រសួងសុខាភិបាលនៅភ្នំពេញ ដោយមិនបាច់ឆ្លងកាត់អភិបាលខេត្ត-ក្រុង និងរតនាគារខេត្ត-ក្រុង ។ ថវិកាដំណើរការ (លើកលែងប្រាក់បៀវត្ស និងចំណាយថ្នាំពេទ្យ) ត្រូវបានផ្តល់ជាកញ្ចប់ថវិការួម និងអាចចំណាយបានតាមតំរូវការរបស់ស្រុក ។

ទោះបី ADD មានភាពស្រដៀងគ្នានឹងចំនាយរដ្ឋទេយ្យបុរេប្រទាន កម្មវិធីនេះបានផ្តល់នូវសំណុំគោលការណ៍មួយជាលើកដំបូងក្នុងការអនុវត្តន៍ថវិកាទំនើប ដែលរួមមានការធ្វើសវនកម្មក្រោយការអនុវត្តន៍ចំណាយជំនួសអោយការត្រួតពិនិត្យមុនដោយក្រសួងហិរញ្ញវត្ថុ ព្រមទាំងការបង្កើតឡើងនូវមជ្ឈមណ្ឌលអនុវត្តន៍ថវិកា នៅថ្នាក់ការិយាល័យ សុខាភិបាលស្រុក ដោយមានសិទ្ធិសំរេចលើការបែងចែកថវិការបស់ខ្លួន (រវាងថវិកាបៀវត្ស និងមិនមែនបៀវត្ស) ។

***ផែនការសកម្មភាពអាទិភាព ( PAP )***

កម្មវិធី ADD អាចអនុវត្តចំពោះតែការចំណាយតូចតាច ។ មានការប្រឹងប្រែង ក្នុងទិសដៅស្របគ្នាតែក្នុង ទ្រង់ទ្រាយធំជាង ដើម្បីផ្តល់ថវិកាទៅអោយវិស័យសុខាភិបាល និងអប់រំ តាមរយៈប្រព័ន្ធនៃការអនុវត្តន៍ថវិកាមួយ សំរាប់ជំនះឧបសគ្គនោះគឺកម្មវិធី PAP ។ កម្មវិធី PAP មានគោលបំណងធានាអោយសកម្មភាពជាក់លាក់មួយចំនួនទទួលបានថវិការបស់ខ្លួនពេញលេញតាមការកំនត់នៅក្នុងផែនការ ថវិកាដោយញែកចេញការបើកផ្តល់ ឬផ្តល់ហិរញ្ញ-ប្បទានសំរាប់ PAP ដាច់ពីប្រព័ន្ធឆន្ទានុសិទ្ធិនៃការបែងចែកសាច់ប្រាក់ (ខុសគ្នាពី ADD ដែលថវិកាទទួលបានជាស្វ័យប្រវត្តិជាប្រចាំត្រីមាសនិមួយៗ) ដោយបង្កើតឡើងនូវមជ្ឈមណ្ឌលគ្រប់គ្រងថវិកានៅតាមបណ្តាស្ថាប័នទទួលបន្ទុកចំណាយនិមួយៗ ដែលចាត់ចែងថវិការបស់ខ្លួន ស្របតាមផែនការអនុម័ត និងកំនត់ទុកជាមុនជំនួសការត្រួតពិនិត្យ (pre-audit) មុនដោយការធ្វើសវនកម្មតាមក្រោយ (post-audit ) នៃសកម្មភាពចំណាយ និងបង្កើតនូវគណនីច្បាស់លាស់នៅតាមរតនាគារខេត្ត-ក្រុង ដោយការបើកផ្តល់សាច់ប្រាក់ មិនអាស្រ័យលើឆន្ទានុសិទ្ធិរបស់រតនាគារឡើយ ។

វិសាលភាពនៃកម្មវិធី PAP ត្រូវកំរិតចំពោះមុខចំណាយថវិកានៃកម្មវិធីមួយចំនួនជាក់លាក់ នៅក្នុងវិស័យសុខាភិបាល (នៅក្នុងខេត្តចំនួន ៧ និងមន្ទីរពេទ្យជាតិមួយចំនួន) និងនៅក្នុងវិស័យអប់រំ (គ្រប់សាលារៀនទាំងអស់) ។ គេទទួលបាននូវអត្រាបើកផ្តល់ថវិកាខ្ពស់នៅក្នុងសកម្មភាពដែលទទួលហិរញ្ញប្បទានក្រោមកម្មវិធី PAP ជាងនៅក្នុងផ្នែកផ្សេងដែលស្ថិតក្រោមប្រព័ន្ធថវិកាចាស់ ។ ការសិក្សាមួយអំពីភាពជឿនលឿនតាមសាលារៀនបង្ហាញអោយឃើញថាអត្រាត្រួតថ្នាក់ទាបជាងសំរាប់សិស្សនៅក្នុងខេត្តដែលអនុវត្តកម្មវិធី PAPជាងខេត្តផ្សេងទៀតដែលគ្មាន PAP នៅក្នុងឆ្នាំ ២០០០ ដោយសារមានថវិកាបន្ថែមសំរាប់បង្រៀនថែមម៉ោង ។

ការបង្កើតឡើងនូវកម្មវិធី PAP គឺជាសន្ទុះមួយយ៉ាងខ្លាំង ក្នុងការតំរង់ទិសការអនុវត្តន៍ថវិកានៅកម្ពុជា ។ កម្មវិធីនេះត្រូវបានដាក់អោយប្រើសំរាប់សកម្មភាពជ្រើសរើសមួយចំនួនដែលភាគច្រើនជាសមាសធាតុថវិកាសំរាប់ ការបង្កើតប្រព័ន្ធអនុវត្តន៍ថវិកានៅក្នុងរយៈពេលវែងដែលគេប្រើប្រាស់នៅក្នុងបណ្តាប្រទេសជឿនលឿន - សវនកម្មក្រោយការអនុវត្តន៍ចំណាយប្រសើរជាងការត្រួតពិនិត្យមុន និងជៀសវាងការកែតំរូវថវិកា តាមរយៈកម្មវិធី ឬការសំរេចចិត្ត បែងចែកសាច់ប្រាក់នៅក្នុងពេលអនុវត្តក្នុងឆ្នាំថវិកានិមួយៗ ។

ផ្ទុយទៅវិញ ទោះបីជាមានការកើនឡើងផែនការសកម្មភាពអាទិភាព និងកម្មវិធីពន្លឿនការអភិវឌ្ឍន៍ថ្នាក់ស្រុក ដែលជាតំរូវការសំរាប់ ការពិនិត្យឡើងវិញនូវការប្រើប្រាស់តរិយាបទនៃមជ្ឈមណ្ឌលបញ្ចូលថវិការនិងការពង្រឹងសមត្ថភាពដែលត្រូវការដើម្បីសំរេចធ្វើការផ្ទេរអំណាចនៃការគ្រប់គ្រងហិរញ្ញប្បទានដោយគ្មានការទទួលយកការបាត់បង់ដែលមិនអាចគណនា និងត្រួតពិនិត្យបាន។

នៅក្នុងគំរោងថវិកាមុនៗ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីកំណត់គោលដៅភាពក្រីក្រ (PTP) ដើម្បីដោះស្រាយដោយផ្ទាល់លើតំរូវការរបស់ប្រជាជនក្រីក្រ។ ផែនការនេះត្រូវបានប្រើដូចគ្នានឹងគោលការហិរញ្ញប្បទានដែលបានដាក់ស្នើរទៅលើផែនការសកម្មភាពអទិភាពដោយផ្តល់ព្រៃសម្បទានដល់ប្រជាជនក្រីក្របំផុតតាមបណ្តាខេត្តនានានៃប្រទេសកម្ពុជា ដូចជាខេត្ត ព្រះវិហារ ឧត្តមានជ័យ រតនគីរី និងមណ្ឌលគីរី ដើម្បីដោះស្រាយបញ្ហាខ្វះមីក្រូសារជាតិក្នុងចំណោមប្រទេសទាំងមូល និងធ្វើឱ្យប្រសើរឡើងការដឹកជញ្ជូនសេវាអប់រំក្នុងខេត្តទាំងនោះដោយមានមួយផ្នែកមកពីការផ្តល់អាហារូបត្ថម្ភសំរាប់កុមារ ដែលកើតក្នុងគ្រួសារក្រីក្រ។ ផែនការ PTP នឹងផ្តោតទៅលើការផ្តល់ប្រាក់ឧតបត្ថម្ភដល់គ្រូបង្រៀនដែលនៅតំបន់ដាច់ស្រយាលដោយបង្កើនថវិការសំរាប់កម្មវិធីអភិវឌ្ឍន៍ភាពផុយស្រួយនៃវិស័យអប់រំ និងផ្គត់ផ្គង់លើការចំណាយសំរាប់សាលាដែរតាំងនៅតំបន់ឆ្ងាយៗ ពីគេ ។ PTP បានបង្កើនលទ្ធភាពដល់អ្នកក្រីក្រក្មេងស្រី និងជនជាតិភាគតិចឱ្យបានចូលរៀន។ ក្នុងខេត្តរតនៈគីរី អត្រាអ្នកចូលរៀនបានកើនឡើងច្រើនជាង ៣0 ភាគរយក្នុងឆ្នាំ ២០០១។ ពីផែនការសកម្មភាពទៅមូលដ្ឋាន កំណែទំរង់ថវិកាផែនការសកម្មភាពអាទិភាពគឺជាមុខចុងស្រួចនៃការកែទំរង់ថវិកានៅកម្ពុជា។ វាជាជំហានដ៏សំខាន់ដើម្បីអភិវឌ្ឍន៍ការទទួលខុសត្រូវនូវភ្នាក់ងារចំណាយ។ ទោះបីជាមានការណែនាំរៀបចំឱ្យបានលនូវចំណាយដល់ក្រសួងពីរគឺក្រសួងសុខាភិបាល និងក្រសួងអប់រំយុវជន និងកីឡាក៏ដោយ។ វាមិនគ្រាន់តែប្រមូលដោយប្រុងប្រយ័ត្នទៅតាមផ្នែកប៉ុណ្ណោះទេ តែការប្រមូលដោយប្រុងប្រយ័ត្ន ដើម្បីអង្គភាពចំណាយជាមួយផ្នែកដែលត្រូវបានផ្លាស់ប្តូពីរបបត្រួតពិនិត្យកណ្តាល ទៅដំណើរការប្រតិបត្តិអភិវឌ្ឍន៍ថវិការជាច្រើន។ ផែនការសកម្មភាពអទិភាពគឺជាជំហានមធ្យមក្នុងការបង្កើតឡើងការទទួលខុសត្រូវ គឺត្រូវការឱ្យមាននូវការបង្កើនសមត្ថភាព និងបង្កើនការធានាខុសត្រូវ ។ ឆ្ពោះទៅមុខទៀតពាណិជ្ជកម្មរវាងប្រសិទ្ធភាពម៉ាក្រូនៃថវិកា និងការបែងចែក និងប្រសិទ្ធភាពបច្ចេកទេស គឺនៅតែត្រូវការ។ ជំនួសឱ្យមូលនិធិរដ្ឋបាលគឺអាស្រ័យទៅលើច្បាប់មូលនិធិដែលអាចរៀបចំសំរេចបាននូវគោលដៅ។ ទាំងនេះអាចទាក់ទងដំណើរការសកម្មភាពថវិកា។ គន្លឹះក្នុងការផ្លាស់ប្តូរផែនការសកម្មភាពអាទិភាពគឺណែនាំបន្តិចម្តងៗពីលទ្ធផលនៃការធានាខុសត្រូវ។ នេះគឺជាវិធានការដោយផ្ទាល់សំរាប់ពេលអនាគតដែលចាំបាច់នូវសមត្ថភាព ។ ដើម្បីអោយដំណើរការរលូន និងសំរបសំរួលការចេញសាច់ប្រាក់ត្រូវពិភាក្សារកមធ្យោបាយដើម្បីប្រមូលផ្តុំហិរញ្ញវត្ថុដែលទទួលខុសត្រូវពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅបណ្តាក្រសួងដែលពាក់ព័ន្ធ និងអាជ្ញាធរដែលមានសមត្ថកិច្ចលើផ្នែកនេះត្រួតពិនិត្យហិរញ្ញវត្ថុតាមបណ្តាក្រសួងដែលពាក់ព័ន្ធ។ ជាមួយគ្នានេះដែរការប្រុងប្រយ័ត្នគឺធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសាច់ប្រាក់ និងកាត់បន្ថយនូវការហួសកំណត់ថ្ងៃសងដែលជំរុញដល់ប្រព័ន្ធធនាគា។

ការទទួលបាននូវថវិកាគឺមានសារៈសំខាន់សំរាប់ដំណើរថវិកាសមាមាត្រ នៃចំណាយសាធារណៈនៅគ្រប់កំរិតក្នុងរដ្ឋាភិបាល គឺកើតមាននូវលក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃសកម្មភាពដែលទទួលបានគឺផ្នែកសេដ្ឋកិច្ច ការទិញដោយតំលៃទាបដោយគ្មានការធានាគុណភាព និងដឹកជញ្ជូនមិនទាន់ពេល។ ដើម្បីធ្វើឱ្យប្រសើរឡើងគោលការណ៍នៅដើមឆ្នាំ ២០០២ រដ្ឋាភិបាលបានសំរេចអនុវត្តន៍ យ៉ាងជិតដល់នូវគោលការណ៍ជាសាធារណៈសំរាប់ក្រសួងអាទិភាពចំនួនបួន មានក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការទិញទំនិញសេវាកម្ម និងសំណង់។ លទ្ធផលការប្រកួតប្រជែងដេញថ្លៃគឺគោលបំណងដើម្បីសន្សំថវិកាជាតិដែលអាចប្រើដើម្បីកាត់បន្ថយភាពក្រីក្រ។

## ៥.៤ ចំណងទាក់ទងរវាង យថគត នៅនឹងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយសាធារណៈរយៈពេលមធ្យម

ការធ្វើអោយប្រសើរឡើង ក្នុងការគ្រប់គ្រងចំណាយសាធារណៈជាការចាំបាច់ក្នុងការអនុវត្តន៏យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ ។ ការបំពេញបន្ថែមទៅនិងកំណែទម្រង់ទាំងនេះគឺក្របខ័ណ្ឌចំណាយរយៈពេលមធ្យមគឺជាផែនការអនុវត្តន៏ចំណាយសាធារណៈច្រើនឆ្នាំមួយ ដែលប្រើប្រាស់ក្នុងការកំណត់តំរូវការធនធានទៅអនាគតសំរាប់សេវាដែលមានស្រាប់ដោយផ្អែកទៅលើការប៉ាន់ស្មានទុកសំរាប់កញ្ចប់ធនធានដែលមានជាសរុបរបស់រដ្ឋាភិបាល គឺទាំងធនធានក្នុងស្រុក និងក្រៅស្រុក ។

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមគឺជាដំណើរការនៃការរៀបចំផែនការ និងថវិកាមួយដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាធ្វើការសន្យាដ៏ជឿជាក់មួយទៅលើគោលដៅសារពើពន្ធ និងការប្រមូលធនធានសាធារណៈ ។ ដំណើរការនេះមានគោលបំណងសំរេចអោយបាននូវលទ្ធផលដែលចង់បានចំនួនពាគឺៈ

- បទបញ្ញាត្តិសារពើពន្ធរួមដែលមានន័យថារដ្ឋាភិបាលមិនគួររស់នៅដោយផ្អែកតែទៅលើមធ្យោបាយរបស់ខ្លួននោះទេ ។ ជាការប្រតិបត្តិ បទបញ្ញាត្តិសារពើពន្ធរួមមានន័យថាជាមួយនិងពេលវេលាកំណត់ណាមួយចំណាយរដ្ឋាភិបាល និងត្រូវស្មើចំណូល (រួមបញ្ចូលទាំងជំនួយពីខាងក្រៅ) រួមទាំងកម្ចីប្រកបដោយចីរភាព ។ បទបញ្ញាត្តិសារពើពន្ធទាំងមូលអាចនិងត្រូវបានសំរេចឡើងដោយការកើនឡើងជាប្រចាំនូវការប្រមូលចំណូល និងការរក្សានូវចំណាយចរន្តតាមកំរិតដ៏សមស្របមួយដូចបានគូសបញ្ជាក់ខាងលើ ។
- ប្រសិទ្ធភាពនៃការបែងចែក មានន័យថារដ្ឋាភិបាលគួរតែចំណាយលុយក្នុងផ្លូវត្រូវ ។ ជាគោលការណ៍ ថវិកាគួរតែបែងចែកទៅតាមផលប្រយោជន៏រួមរបស់សង្គមអោយបានស្មើឬក៏ច្រើនជាងផ្លែរួមរបស់សង្គម ។ យុទ្ធសាស្ត្រក្នុងការបែងចែកឡើងវិញនៃធនធានទៅវិស័យជាអាទិភាពជាពិសេសអប់រំ និងសុខាភិបាល និងដោយមិនគិតអំពីការការពារជាតិ និងសន្តិសុខផ្ទៃក្នុងគឺជាផ្អែកនៃក្របខ័ណ្ឌ ចំណាយរយៈពេលមធ្យមដែលបានស្នើឡើង និង
- ប្រសិទ្ធភាពនៃការប្រតិបត្តិ មានន័យថាអ្នកបង់ពន្ធទាំងអស់ទទួលបាននូវតំលៃដ៏ល្អប្រសើរសំរាប់ពន្ធរបស់គេ ។ រដ្ឋាភិបាលបានសំរេចម្តងរួចហើយក្នុងការផ្តល់គុណភាព និងកំរិតជាក់លាក់មួយនៃសេវាសាធារណៈដែលសេវាទាំងនោះគួរតែផ្តល់ក្នុងតំលៃទាប ។

ក្នុងបរិបទនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមបានជួយក្នុងការ បង្កើតចំណងទាក់ទងយ៉ាងជិតស្និតរវាងទិសដៅជាតិរយៈពេលវែង និងមធ្យមដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្រថ្នាក់ជាតិជាមួយ និងដំណើរការថវិកាប្រចាំឆ្នាំ ។

ដូចគ្នានេះដែរ ដោយហេតុថាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិមានសកម្មភាពដែលរៀបចំជាកម្មវិធី នៅក្នុងរយៈពេលមធ្យម រាល់សេចក្តីសំរេចដែលមានការប៉ះពាល់ដល់ថវិការបស់រដ្ឋនិងត្រូវបាន ពិចារណាឡើងវិញពីទស្សនវិស័យច្រើនឆ្នាំ ។ ដូច្នេះថវិកាក្លាយទៅជាយន្តការមួយសំរាប់ធ្វើផែនការទៅថ្ងៃមុខដែលប្រមូលពតិមានពិចារណាលើជំរើសនានា និងជ្រើសរើសក្នុងដំណោះស្រាយផ្សេងៗទៀត ។

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមមានទិសដៅក្នុងការរៀបចំពតិមានដើម្បីសំរេចអោយបាននូវកម្មវិធី នៃការចំណាយ និងធនធានជាមួយគ្នា និងដូចនេះដែរដើម្បីបង្ហាញយ៉ាងច្បាស់ពីការអនុវត្តន៏នៃសេចក្តីសំរេច ឬវិស័យអាទិភាពនានាទៅលើការបែងចែកធនធាន។ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមបែងចែកគ្នារវាងទស្សន ៣ គឺ:

- ក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យម ដែលបង្កើតកញ្ចប់ធនធានដ៏ទូលាយសំរាប់រដ្ឋាភិបាលដោយផ្អែកលើការប៉ាន់ស្មានដ៏ល្អបំផុត។
- ក្របខ័ណ្ឌថវិការយៈពេលមធ្យមដែលបែងចែកធនធានក្នុងរយៈពេលដោយស្របតាមអាទិភាពតាមវិស័យ និងជាតិ និង
- ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលបូកបញ្ចូលទាំងទំហំនៃសកម្មភាព និងទិន្នផលផ្អែកលើ ផែនការនៃតំណើរការ។

ទោះជាយ៉ាងណាក៏ដោយ ការចាប់ផ្តើមទាំងស្រុងនៃដំណើរការក្របខ័ណ្ឌចំណាយរយៈពេលមធ្យមប្រឈម និងការបង្ខំនានា ហើយវាត្រូវការពេលវេលាដើម្បីអនុវត្តន៏។ បទពិសោធន៏ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលកម្ពុជាមាន និងបទពិសោធន៏ជាអន្តរជាតិរហូតមកដល់បច្ចុប្បន្ននេះបង្ហាញនូវបញ្ហាមួយចំនួន ដែលត្រូវការដោះស្រាយបញ្ហាខ្លះទាមទារសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៏។ ក្នុងចំណោមលក្ខខណ្ឌចាំបាច់សំរាប់កិច្ចដំណើរការក្របខ័ណ្ឌចំណាយរយៈពេលមធ្យមមាន:

- គំរូដ៏ទូលំទូលាយនៃថវិកា រួមបញ្ចូលទាំងផ្នែកចំណូល។ ដូចដែលបានបង្ហាញនូវខាងលើសំរាប់ចំណែកធនធាន ដ៏សំខាន់មួយពីដៃគូ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវការដឹងអំពីប្រភេទ និងកំរិតនៃការសន្យាអោយបានច្បាស់ជាមុន ហើយការចំណាយគួរតែអាចគិតទុកជាមុនតាមតែអាចធ្វើទៅបាន។
- ថវិកាចរន្ត និងមូលធនបញ្ចូលជាមួយគ្នា (ករណីនេះមិនទាន់មាននៅកម្ពុជា)។
- ការបែងចែកមុខងារដ៏សមស្រប ការតស៊ូដើម្បីឈានទៅដល់កម្មវិធីដែលផ្អែកទៅលើថវិកានីយកម្ម (ការងារនេះបានកំពុងអនុវត្តន៏សំរាប់អប់រំ និងសុខាភិបាល) និង
- ការអនុវត្តន៏ថវិកាដ៏ត្រឹមត្រូវ។

ចំពោះហេតុផលទាំងនេះ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមកំពុងចាប់ផ្តើមអនុវត្តន៏នៅសុខាភិបាល និងអប់រំតែប៉ុណ្ណោះ។ ផ្អែកទៅលើការសន្និដ្ឋានមួយយ៉ាងតិចក៏៦%នៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរួមបញ្ចូលទាំងកំរិតរួមនៃធនធានសាធារណៈ ចំណូលពន្ធ និងមិនមែនសារពើរពន្ធ និងកំចីដែលអាចត្រូវបានបែងចែកក្នុងចំណោមកម្មវិធីជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលមធ្យម ស៊ីសង្វាក់ជាមួយនិងកំរិតទិសដៅ នៃតុល្យកាសារពើពន្ធទូទៅ (អតិរេក ឬ ឱនភាព)។

## ក្របខ័ណ្ឌថវិការយៈពេលមធ្យម

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុការប្រើប្រាស់ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបំពេញនូវគោល បំណងរបស់ខ្លួនសំរាប់បែងចែកធនធានដែលមានកំណត់របស់ខ្លួនទៅវិស័យអទិភាពជាយុទ្ធសាស្ត្រ។ ជាភាគរយនៃ ចំណាយចរន្ត ការបែងចែក

សំរាប់ក្រសួងអប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ នឹងកើនឡើងពី ៣០.៣% ក្នុងឆ្នាំ ២០០១ ទៅ ៣៧.៣%ក្នុងឆ្នាំ ២០០៥ ដែលការបែងចែកសំរាប់សន្តិសុខ និងការពារជាតិនឹងត្រូវធ្លាក់ចុះពី ៣០.១% ទៅ ១៩.៤% ក្នុងឆ្នាំដូចគ្នានេះ។

ក៏រិតខ្ពស់បំផុតនៃចំណាយជាសរុបដែលផ្អែកទៅលើក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក៏រិតខ្ពស់បំផុតនៃវិភាជន៍ដែលបានគិតទុកនឹងបង្ហាញក្នុងតារាងទី ៥.៤។

**តារាង ៥.៤ ចំណាយសរុប និងក៏រិតអតិបរមានៃវិភាជន៍**

| ការបញ្ជាក់លំអិត | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|
| ផសស នាមករណ៏ (ជាលានរៀល) | ១៩.៦៥០.០០០ | ១៧.០៨៧.០០០ | ១៨.៦៥៦.០០០ |
| ចំណាយសរុប (%នៃផសស) | ១៩.០ | ១៩.១ | ១៩.៤ |
| ចំណាយចរន្ត (%នៃផសស) | ១១.៣ | ១១.៩ | ១២.២ |
| ចំណាយមូលធន (%នៃផសស) | ៧.៣ | ៧.២ | ៧.២ |
| ក៏រិតខ្ពស់បំផុតនៃថវិកាទូទៅ (ជាលានរៀល) | ២.៩៧៣.៥០០ | ៣.២៦៣.៦១៧ | ៣.៦១៩.២៦៤ |
| ចំណាយចរន្ត (ជាលានរៀល) | ១.៧៦៨.៤៥០ | ២.០៣៣.៣៥៣ | ២.២៧៦.០៣២ |
| ចំណាយមូលធន (ជាលានរៀល) | ១.១៤២.៤៥០ | ១.២៣០.២៦៤ | ១.៣៤៣.២៣២ |
| ក៏រិតអតិបរមានៃថវិកាកែតំរូវ (ជាលានរៀល) | ២.៤១០.៥៨២ | ២.៥៦៤.៥០០ | ២.៧៥២.៨២៥ |
| ក៏រិតអតិបរមានៃវិភាជន៍=ចំណាយសរុប-ក៏រិតអតិបរមា មូលដ្ឋានសរុប | ៦៥២.៩១៨ | ៦៩៩.១១៧ | ៨៦៦.៤៣៩ |
| ក៏រិតអតិបរមានៃវិភាជន៍ជាភាគរយនៃផសស | ៣.៦ | ៤.០៩ | ៤.៦៤ |

ក៏រិតអតិបរមានៃចំណាយតាមវិស័យ និងក្រសួងចំណាយនានាដោយផ្អែកលើវិធីសាស្ត្រដែលមានរួចមកហើយ ប៉ុន្តែបានកែតំរូវសំរាប់ការប្តេជ្ញាចិត្តដែលធ្វើឡើងដោយរដ្ឋាភិបាលចំពោះស្ថាប័នអោយខ្ចី និងអ្នកផ្តល់ជំនួយត្រូវបានបង្ហាញក្នុងតារាងទី ៥.៥។

**តារាង ៥.៥ ការបែងចែកតាមវិស័យ និងក្រសួងអាទិភាព**

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|---|
| | ជាភាគរយនៃ ផសស | | | ជាលានរៀល | | |
| រដ្ឋបាលកណ្តាល | ១.៥៤ | ១.៤៤ | ១.៣៥ | ២៤១.០១០ | ២៤៦.០៥២ | ២៥១.៨៥៦ |
| សន្តិសុខ និងការពារ | ២.៥៣ | ២.៤៩ | ២.៤០ | ៣៩៥.៩៤៥ | ៤២៥.៤៦៦ | ៤៤៧.៧៤៤ |
| សេវាសង្គម | ៤.២២ | ៤.៥៥ | ៤.៧៩ | ៦៦០.៤៣០ | ៧៧៧.៤៥៨ | ៨៩៣.៦២២ |
| ក្នុងនោះ: សុខាភិបាល | ១.៣៨ | ១.៤៩ | ១.៥៩ | ២១៩.៩៧០ | ២៥៤.៥៩៦ | ២៩៦.៦៣០ |
| អប់រំ | ២.១៣ | ២.៣៣ | ២.៤៧ | ៣៣៣.៣៤៥ | ៣៩៨.១២៧ | ៤៦០.៨០៣ |

| | | | | | | |
|---|---|---|---|---|---|---|
| វិស័យសេវាសង្គមផ្សេងទៀត | ០,៧១ | ០,៧២ | ០,៧៣ | ១១១.១១៥ | ១២៣.០២៦ | ១៣៦.១៨៨ |
| សេវាសេដ្ឋកិច្ច | ១,១២ | ១,២៤ | ១,៣៦ | ១៧៥.២៨០ | ២១១.៨៧៨ | ២៥៣.៧២១ |
| ក្នុងនោះ:ក.ក រុ.ប្រមាញ់ និងនេសាទ | ០,២៦ | ០,៣០ | ០,៣៥ | ៤០.៦៩០ | ៥១.២៦១ | ៦៥.២៩៦ |
| អភិវឌ្ឍន៏ជនបទ | ០,១៣ | ០,១៥ | ០,២០ | ២០.៣៤៥ | ២៥.៦៣០ | ៣៧.៣១២ |
| វិស័យសេវាសេ.កផ្សេងទៀត | ០,៧៣ | ០,៧៩ | ០,៨១ | ១១៤.២៤៥ | ១៣៤.៩៨៧ | ១៥១.១១៣ |
| ទុនបំរុងជាយថាហេតុ | ២,១៩ | ២,១៨ | ២,៤៩ | ៣៤២.៧៣៥ | ៣៧២.៤៩៦ | ៤៦៤.៣៤៤ |
| ចំណាយមូលធនហិរញ្ញប្បទានក្រៅស្រុក | ៥,៣០ | ៥,២០ | ៥,១០ | ៨២៩.៤៥០ | ៨៨៨.៥២៤ | ៩៥១.៤៥៦ |
| ចំណាយមូលធនហិរញ្ញប្បទានក្នុងស្រុក | ២,០០ | ២,១០ | ២,០០ | ៣១៣.០០០ | ៣៥៨.៨២៧ | ៣៧៣.១២០ |
| ចំណុចកំណត់: | | | | | | |
| ផសសជាលានរៀល | | | | ១៥.៦៥០.០០០ | ១៧.០៨៧.០០០ | ១៨.៦៥៦.០០០ |
| ចំណាយមូលធនហិរញ្ញប្បទានក្រៅស្រុក (ជាលានដុល្លារ) | | | | ២០៧.៤ | ២២១.៨ | ២៣៧.១ |

ដូចដែលបានបញ្ជាក់រួចមកហើយ កម្មវត្ថុមួយផ្នែកធំនៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យមគឺដើម្បីទ្រទ្រង់ ការផ្លាស់ប្តូរក្នុងការបែងចែកថវិកាពីសន្តិសុខ និងការពារទៅក្រសួងអាទិភាព ជាពិសេសសុខាភិបាល និងអប់រំ។ តារាង៥.៦ បង្ហាញថាតើទាំងនេះវានឹងទាក់ទងគ្នានិងករណីជាក់លាក់ណាមួយក្នុងវិស័យអប់រំយ៉ាងដូចម្តេច។ អត្រាកំណើនប្រចាំឆ្នាំនៃការបែងចែកថវិកាមានការកើនឡើងយ៉ាងខ្លាំងប្រមាណ១៥%ក្នុងឆ្នាំ ២០០៥ ដោយប្រៀបធៀប និងឆ្នាំ ២០០៤។

**តារាង ៥.៦ ហិរញ្ញប្បទានរដ្ឋាភិបាលសំរាប់វិស័យអប់រំ ២០០១-២០០៥**

| **ការបញ្ជាក់លំអិត** | **ជាក់ស្តែង ឆ្នាំ២០០១ ឆ្នាំ ១៩៩៩** | **ជាក់ស្តែង ឆ្នាំ២០០២ ឆ្នាំ ២០០០** | **ករិតអតិបរមាជា មូលដ្ឋានឆ្នាំ២០០៣ ឆ្នាំ២០០១** | **ករិតអតិបរមាជា មូលដ្ឋានឆ្នាំ២០០៤ ឆ្នាំ២០០២** | **ករិតអតិបរមាជា មូលដ្ឋានឆ្នាំ២០០៥ ឆ្នាំ២០០៣** |
|---|---|---|---|---|---|
| ហិរញ្ញប្បទានរដ្ឋាភិបាល(ជាលានរៀល) | ២២៩.៦៥៣ | ២៨៦.២០០ | ៣៣៣.៣៤៥ | ៣៩៨.១២៤ | ៤៦០.៨០៣ |
| អត្រាកំណើន ជាភាគរយ | ៣៥,២ | ២៤,៦ | ១៦,៥ | ១៩,៤ | ១៥,៧ |
| ជាភាគរយនៃផសស | ១,៧១ | ១,៩៩ | ២,១៣ | ២,៣៣ | ២,៤៧ |
| ជាភាគរយនៃចំណាយចរន្ត | ១៦,២ | ១៨,២ | ១៨,៨ | ១៩,៦ | ២០,២ |
| ចំណុចកំណត់: | | | | | |

ចំណាយសាធារណៈសរុបសំរាប់អប់រំគឺជាចំនួនទឹកប្រាក់របស់កម្មវិធីអ្នកផ្តល់ជំនួយ និងហិរញ្ញប្បទានរាជរដ្ឋាភិបាល និងគំរោងគាំទ្រ។

ទិសដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺដើម្បីអភិវឌ្ឍន៍សេវាដែលមានគុណភាពខ្ពស់ និងងាយស្រួលប្រើប្រាស់ដែលអាចទទួលយកបានទាំងអស់គ្នា។ ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡារួមមាន ចំណេះដឹងនៃតំរូវការចាំបាច់សំរាប់ប្រព័ន្ធបណ្តុះបណ្តាល និងអប់រំដើម្បីសំរេចអោយបាននូវកំណើនសេដ្ឋកិច្ច ក្តីសង្ឃឹមក្នុងការងារកាន់តែប្រសើរឡើង និងមានកាលានុវត្តន៍ភាពរកចំណូល។

ដូចដែលបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានបំណងបង្កើនលទ្ធផលនៃសកម្មភាពរបស់ខ្លួនជាសំខាន់រួមបញ្ចូលទាំងការចែងចែកថវិកា។ ដើម្បីសំរេចបាននូវគោលបំណងនេះ ដោយផ្អែកទៅលើកំរិតខ្ពស់បំផុតនៃថវិកាឆ្នាំ ២០០៣-២០០៥ នៃក្របខ័ណ្ឌចំណាយរយៈពេលមធ្យមសំរាប់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបានប្តេជ្ញាចិត្តក្នុងការបែងចែកធនធានថវិកាដ៏មានកំរិតរបស់ខ្លួនទៅកម្មវិធីអាទិភាពដែលបានជ្រើសរើសដោយមាន បំណងឈានទៅដល់ទិសដៅរយៈពេលមធ្យមដូចតទៅ:

**តារាង ៥.៧ គោលដៅ និងសន្ទស្សន៍ដែលបានសំរេចដោយជ្រើសរើស ឆ្នាំ ២០០៣-២០០៥**

| **សន្ទស្សន៍** | **២០០៣** | **២០០៤** | **២០០៥** |
|---|---|---|---|
| ១- ឱកាសចូលរៀនតាមសមធម៌ | | | |
| ក- អត្រាចុះឈ្មោះសរុប ថ្នាក់បឋម %ទូទាំងប្រទេស | ៩០ | ៩២ | ៩៥ |
| ខ- អត្រាចុះឈ្មោះសរុប ថ្នាក់បឋម តំបន់ដាច់ស្រយាល ជា% | ៧២ | ៧៦ | ៨០ |
| គ- អត្រាឡើងថ្នាក់ ថ្នាក់ទី ១ ថ្នាក់ទី២ ថ្នាក់ទី៣ ជា% | ៨៤,៨៧,៨៦ | ៨៦,៨៨,៨៧ | ៨៨,៨៩,៨៨ |
| ឃ- អត្រាចុះឈ្មោះសរុប អនុវិទ្យាល័យ តំបន់ដាច់ស្រយាល ជា% | ៦ | ១០ | ១៥ |
| ង- អត្រាចុះឈ្មោះសរុប វិទ្យាល័យ ជា% | ១០ | ១១ | ១៥ |
| ច- ការចុះឈ្មោះ: រដ្ឋ | ៩,៤១០ | ៩,៧១០ | ១០,១១០ |
| **ឯកជន** | ១៥.០០០ | ១៧.០០០ | ១៩.០០០ |
| ២-គុណភាព និងប្រសិទ្ធភាពផ្ទៃក្នុង | | | |
| ក-អត្រាត្រួតថ្នាក់ ថ្នាក់ទី ១ ថ្នាក់ទី២ ថ្នាក់ទី៣ ជា% | ៨,៥,៥ | ៧,៥,៥ | ៦,៥,៥ |
| ខ- អត្រាឡើងថ្នាក់ពីបឋមទៅអនុវិទ្យាល័យ ជា% | ៨៣ | ៨៥ | ៨៧ |
| គ- អត្រាគ្រូបឋម: បឋមសិក្សា | ៥៣ | ៥២ | ៥១ |
| អនុវិទ្យាល័យ | ២០ | ២៣ | ២៦ |
| វិទ្យាល័យ | ២៦ | ២៧ | ២៨ |
| ឃ- បុគ្គលិកមិនបង្រៀនជាចំណែកនៃកំលាំងពលកម្មវិស័យអប់រំសរុប | ១៨ | ១៧ | ១៦ |
| ង- ចំណាយលើអត្ថបទសិក្សាសំរាប់សិស្សម្នាក់ៗជារៀល | ៥.២០០ | ៥.៧០០ | ៥.៨០០ |
| ៣- ធ្វើអោយប្រសើរឡើងវិស័យគ្រប់គ្រង និងវិមជ្ឈការនៃសេវាអប់រំ | | | |
| ក- ចំណែកវិស័យអប់រំរបស់ចំណាយចរន្តរដ្ឋាភិបាលសរុប ជា% | ១៨,៥ | ១៩,៥ | ២០,០ |

តារាង ៥.៨ ង្ហាញនូវការវិភាគបែងចែកយ៉ាងលំអិតស្រដៀងនិងថវិកាសុខាភិបាលរហូតដល់ឆ្នាំ ២០០៥ ។ ទាំងនេះជាការបញ្ជាក់ផងដែរដោយយុទ្ធសាស្ត្រតាមផ្នែកមួយដែលតំរង់ទិសទៅរកគោលដៅជាគន្លឹះ ។

**តារាង ៥.៨ ថវិកាចរន្តរដ្ឋាភិបាលសំរាប់ឆ្នាំសារពើពន្ធ ២០០៣-២០០៥ (សុខាភិបាល)**

| ការបញ្ជាក់លំអិត | ជាក់ស្តែងឆ្នាំ២០០០ ឆ្នាំ ១៩៩៨ | ជាក់ស្តែងឆ្នាំ២០០១ ឆ្នាំ ១៩៩៩ | ជាក់ស្តែងឆ្នាំ២០០២ ឆ្នាំ ២០០០ | កំរិតអតិបរមានៃថវិកាឆ្នាំ ២០០៣ ឆ្នាំ២០០១ | កំរិតអតិបរមា នៃថវិកាឆ្នាំ២០០៤ ឆ្នាំ២០០២ | កំរិតអតិបរមា នៃថវិកាឆ្នាំ២០០៥ ឆ្នាំ២០០៣ |
|---|---|---|---|---|---|---|
| ជាលានរៀល | ១០២.២២៧ | ១៣៤.០៤០ | ១៧១.៧០០ | ២១៥.៩៧០ | ២៥៤.៥៥៦ | ២៩៦.៦៣០ |
| អត្រាកំណើនជា% | ៣៥,១ | ៣១,១ | ២៨,១ | ២៥,៨ | ១៨,០ | ១៦,៥ |
| ជា%នៃផសស | ០,៧៥ | ០,៩៨ | ១,២ | ១,៣៨ | ១,៥ | ១,៦ |
| ជា%នៃចំណាយចរន្ត | ៨,៤ | ៩,៥ | ១០,៩ | ១២,២ | ១២,៥ | ១៣,០ |

មួយផ្នែកធំនៃចំណាយសាធារណៈខាងសុខាភិបាលត្រូវបានហិរញ្ញប្បទានដោយអ្នកផ្តល់ជំនួយ។ កម្មវិធីជាតិ មានត្រឹមតែ ១៤% ប៉ុណ្ណោះដោយរួមបញ្ចូលទាំងធនធានរបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ។ នៅឆ្នាំ ២០០១ ហិរញ្ញប្បទានទ្វេរភាគីមានប្រមាណ ៤៦% នៃជំនួយពីខាងក្រៅខណៈដែលពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល (ហិរញ្ញប្បទានសំខាន់ៗ ប៉ុណ្ណោះ) មានប្រមាណ ៣២ និង ២២%។ ដូចគ្នានេះដែរ ៥៧%នៃ ជំនួយខាងក្រៅដែលផ្តល់ទៅសុខាភិបាលគឺបែងចែកទៅក្នុងកម្មវិធីជាតិ គំរោងនិងការសំរបសំរួល និងក្រសួងសុខាភិបាល។ ផ្នែកដែលនៅសល់ត្រូវបានបែងចែកទៅគំរោងជំនួយតាមខេត្ត និងអង្គការក្រៅរដ្ឋាភិបាលដែលជាអ្នកផ្តល់ផ្សេងៗ។

## ការធ្វើវិមជ្ឈការហិរញ្ញប្បទាន

កម្មវិធីវិមជ្ឈការរបស់រាជរដ្ឋាភិបាលបានលើកឡើងក្នុងវគ្គទី៤ រួមមានការប្តេជ្ញាចិត្តដើម្បីធ្វើវិមជ្ឈការការទទួលខុសត្រូវចំណាយចំពោះឃុំ ។ នៅក្នុងឱកាសនេះ ប្រភពហិរញ្ញវត្ថុសំខាន់សំរាប់ការទទួលខុសត្រូវរបស់ឃុំ-សង្កាត់ គឺមូលនិធិឃុំ (សូមមើលខាងក្រោមនេះ) ។

ចំពោះវិមជ្ឈការសារពើពន្ធដែលមានការជឿជាក់ រដ្ឋាភិបាលមូលដ្ឋានគួរមានការព្យាករណ៍ ប្រភពហិរញ្ញប្បទានគ្រប់គ្រាន់ល្មមដើម្បីអនុវត្តការទទួលខុសត្រូវអាណត្តិរបស់ខ្លួន ។ នៅដំណាក់កាលថ្មីនៃការធ្វើវិមជ្ឈការនេះ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តផ្ទេរប្រភពថវិកាស្មើវត្ថុតាមភាគរយនៃចំណូលក្នុងស្រុកបច្ចុប្បន្ន ។ ដើម្បីធានាការដែលអាចប្រមើលទុកបានអំណោយអន្តររដ្ឋាភិបាលគួតែដាក់នៅក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ។

បន្ទាប់ពីមានការបោះឆ្នោតឃុំនៅខែ កុម្ភៈ ឆ្នាំ ២០០២ និង ការបង្កើតក្រុមប្រឹក្សាឃុំជាបន្តបន្ទាប់ទូទាំងប្រទេសថវិកាឃុំបានបង្កើតអោយឃុំអាចប្រតិបត្តិការងាររបស់ខ្លួនអោយបានពេញលេញ ។ រាជរដ្ឋាភិបាលបានបង្កើតមូលនិធិឃុំ (FC) ដែលមាន

អំណោយមកពីរដ្ឋាភិបាល ចំណូលពន្ធ និងមិនមែនពន្ធដើម្បីកំណត់ចំពោះឃុំដោយសមាជិកសភា និងជំនួយរបស់ម្ចាស់ជំនួយ ។ មូលនិធិឃុំប្រើសំរាប់ផ្តល់ហិរញ្ញប្បទានដូចខាងក្រោមៈ

- កិច្ចការរដ្ឋបាលទូទៅរបស់ឃុំ
- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមរបស់ឃុំ និង
- ការបែងចែកសេវាកម្មសាធារណៈមូលដ្ឋាន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃនឹងធ្វើការពិភាក្សាបន្ថែមទៀតពីរបៀបថាតើមូលនិធិឃុំនេះត្រូវចាត់ចែងរបៀបណា ។ ក្រុមប្រឹក្សាមូលនិធិឃុំអាចត្រូវបង្កើតឡើងនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានតំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងផែនការ លេខាដ្ឋានសីលា និងសហគមន៍មូលដ្ឋានមួយចំនួនទៀត ។ ក្រុមប្រឹក្សាមូលនិធិឃុំធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិ គាំទ្រឃុំ (NCSC) ដើម្បីចាត់ចែងមូលនិធិឃុំនេះ ។ ការបង្កើត និងប្រតិបត្តិការនៅដំណាក់កាលដំបូងរបស់មូលនិធិឃុំនេះគួរផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាល និងក្រុមប្រឹក្សាឃុំដែលទើបបង្កើតឡើងនេះ ដើម្បីបង្កើនសមត្ថភាពយល់ដឹង និងការអនុវត្តអភិបាលកិច្ចមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តំលាភាព និងគណនេយ្យភាពរបស់ពួកគេ ។ នេះទាមទារការបង្កើតសមត្ថភាពយល់ដឹងខ្លាំងក្លានៅថ្នាក់ខេត្តដើម្បីគាំទ្រ និងត្រួតពិនិត្យមើលឃុំទាំងនេះ ។ សមត្ថភាពនេះមានសារៈសំខាន់ចំពោះស្ថាប័នមូលដ្ឋានទាំងអស់នោះ ។ ដូចសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** មានប្រសាសន៍ថា ការបោះឆ្នោតឃុំនឹងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និង កែលំអប្រសិទ្ធភាពសេវាកម្មសាធារណៈ និងកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាន ។ វានឹងប្រគល់អំណាចនៃការទទួលខុសត្រូវពីរដ្ឋាភិបាលកណ្តាលដល់ប្រជាជន ។ ទំរង់នៃ ការផ្តល់អំណាចដល់ប្រជាជនមូលដ្ឋានមាន ឥទ្ធិពលធំធេងនៅពេលអនាគត ។

ការធ្វើកំណែទំរង់ទាំងការធ្វើវិមជ្ឈការ និងការគ្រប់គ្រងចំណាយសាធារណៈត្រូវបានគេប្រមើលទុកជាមុនថា នឹងជួយដោះស្រាយភាពក្រីក្រតាមរយៈការគ្រប់គ្រងកិច្ចការសាធារណៈប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព និងមានសមត្ថភាពថែមទៀត ។ ប្រព័ន្ធវិមជ្ឈការសារពើពន្ធត្រូវបានគេបង្កើតឡើងស្របពេលជាមួយគ្នា និងការកាត់បន្ថយភាពក្រីក្រដែរ ។ វិមជ្ឈការនៅកម្ពុជាកើតមកពីឆន្ទៈនយោបាយរបស់រដ្ឋាភិបាលដើម្បីធ្វើអោយស៊ីជំរៅអភិបាលកិច្ច និងចាក់ឫសកាន់តែខ្លាំងក្លាដល់វប្បធម៌សន្តោសប្រណី និងការយោគយល់គ្នាទៅវិញទៅមកនៅថ្នាក់មូលដ្ឋាន ។ លើសពីនេះទៀតការធ្វើវិមជ្ឈការទាក់ទងដល់ការបង្កើតអង្គការ និងស្ថាប័នរបស់រដ្ឋ ។ អាស្រ័យហេតុនេះរបៀបវារៈវិមជ្ឈការសារពើពន្ធមិនអាចកាត់ផ្តាច់ចេញពីឆន្ទៈនយោបាយ និងការអភិវឌ្ឍន៍បានឡើយ ។

វិមជ្ឈការសារពើពន្ធជាទូទៅ តំរូវអោយមានការផ្ទេរអំណាចនៃការប្រមូលប្រាក់ចំណូលមួយចំនួនពីរដ្ឋាភិបាលកណ្តាលទៅមូលដ្ឋាន និងការផ្ទេរប្រភពថវិកាជាតិបន្ថែមដើម្បីបង្គ្រប់នូវអ្វីដែលរដ្ឋបាលមូលដ្ឋានអាចប្រមូលបានដោយខ្លួនឯង ។ ប្រទេសកម្ពុជាមិនមានករណីលើកលែងចំពោះច្បាប់នេះទេ ។

ក្រុមប្រឹក្សាមូលនិធិឃុំទទួលខុសត្រូវចំពោះការចចារការការសន្យារយៈពេលមធ្យមដូចគ្នានេះ ពីភ្នាក់ងារនៃអ្នកផ្តល់ជំនួយជាច្រើនដែលបានផ្តល់មូលធិនិធិរបស់គេតាមរយៈការផ្តល់ហិរញ្ញវត្ថុដល់ឃុំ-សង្កាត់ដែលគេបានកំណត់ ។ យោងតាមពង្រាងបទបញ្ជា និងច្បាប់មូលនិធិ ក្រុមប្រឹក្សាមានបំណងធ្វើការដូចគ្នាប្រភពធនធានដែលបានផ្តល់ផ្សេងៗគ្នា ប៉ុន្តែក្នុងគោល

បំណងចូលរួមចំណែកដល់ការផ្តល់ហិរញ្ញប្បទានដល់ឃុំ-សង្កាត់ដូចគ្នាដែរ ដោយផ្អែកលើរបៀបនៃការផ្តល់ហិរញ្ញប្បទានត្រូវបានគេកំណត់ ។ នេះអាចគ្របដណ្តប់លើការផ្តល់មូលនិធិសំរាប់ការអភិវឌ្ឍន៍មូនដ្ឋាន ឬជនបទដែលស្ថិតក្រោមដំបូលកម្មវិធីសីលាតាមរយៈក្រសួងនិមួយៗទៀត ។

សមិទ្ធិផលដំបូងក្នុងការប្រមូលធនធានខាងក្រៅសំរាប់មូលនិធិឃុំ សង្កាត់ ជាកិច្ចព្រមព្រៀងត្រីភាគី ( NCSC/Seila Task Force/UNDP) ដែលប្រភពសំខាន់សំរាប់ឃុំសង្កាត់នឹងត្រូវគេផ្តល់តាមរយៈមូលនិធិឃុំ ពីឆ្នាំ ២០០២ តទៅ ។ សំខាន់ជាងនេះទៅទៀត នេះបង្ហាញការផ្លាស់ប្តូរយន្តការនៃការបែងចែកប្រភពធនធានឃុំរបស់សីលាដោយគណកម្មាធិការអភិវឌ្ឍជនបទក៏រិតខេត្តឆ្ពោះទៅប្រព័ន្ធបែងចែកមូលនិធិឃុំ-សង្កាត់ក៏រិតជាតិ ។ វាបង្ហាញការយល់ដឹង ជាមុនដែលថា លក្ខខ័ណ្ឌ និងស្ថានភាពនៃកិច្ចព្រមព្រៀងនឹងត្រូវគេសិក្សាឡើងវិញសំរាប់ឆ្នាំខាងមុខ ។ ដើម្បីពិចារណា ការអភិវឌ្ឍន៍ក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុបន្ថែមទៀត ។ តារាងខាងក្រោមបង្ហាញលក្ខណៈនៃការបែងចែកធនធាន និងមូលធនរបស់មូលនិធិឃុំ-សង្កាត់ ។ សំរាប់ឆ្នាំ ២០០២ គេនឹងផ្តល់ពតិមានអោយបានជាក់លាក់ ។

## រូបភាព ២ ការបែងចែកមូលនិធិរបស់ឃុំសង្កាត់




តារាងលេខ តារាងលេខ ២: ការបែងចែកមូលនិធិរបស់ឃុំសង្កាត់

**ចំណែកនៃការអភិវឌ្ឍន៏មូលដ្ឋាននិងរដ្ឋបាលទូទៅមូលនិធិមានពីចំណែក (ដោយចាត់ទុកថាជាពី "មូលនិធិរងជាក់ស្តែង"**

- រដ្ឋបាលទូទៅ:ចំណែកនៃរដ្ឋបាលទូទៅដែលគ្របដណ្តប់លើប្រាក់ឧបត្ថម្ភចំពោះក្រុមប្រឹក្សាឃុំ ការចំណាយបុគ្គលិក មូលដ្ឋាន ការទិញ ឬជួលការិយាល័យក្រុមប្រឹក្សា សម្ភារីម និងសំភារៈសំរាប់ក្រុមប្រឹក្សា ការជួសជុល និងថែទាំ ថ្លៃការប្រើប្រាស់ទឹកភ្លើង ការទិញ ឬជួលយានយន្ត និងការថែទាំយានយន្ត និង ចំណាយផ្សេងៗទៀតមិនគួរអោយលើស១/៣ នៃកញ្ចប់មូលនិធិទាំងអស់ឡើយ ។

- ចំណែកនៃការអភិវឌ្ឍន៍មូលដ្ឋាន ដែលគ្របដណ្តប់លើការចំណាយចរន្តនិងចំណាយមូលធនសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការបំរើសេវាសាធារណៈសង្គមនិងសេដ្ឋកិច្ចមិនគួរអោយតិចជាង ២/៣ នៃកញ្ចប់មូលនិធិទាំងអស់ឡើយ ។

ក្នុងឆ្នាំ ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តដើម្បីផ្តល់មូលនិធិ ២០ ពាន់លានរៀល ដែលបានមកពីប្រាក់ចំណូលក្នុងស្រុក ។ មូលនិធិនេះត្រូវបានធ្វើការបែងចែកបន្ថែមលើទឹកប្រាក់ ១,៤ លានដុល្លារបស់កម្មវិធីសីលា (SIDA និង DFID) ។

**មូលនិធិនេះផ្តល់ដល់:**

- មូលនិធិសំរាប់រដ្ឋបាលទូទៅ ដែលមានចំនួន ៨,៨ ពាន់លានរៀលបានត្រូវបែងចែកដល់ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១. ៦២១ ដោយមួយក្រុមប្រឹក្សាឃុំទទួលបានជាមធ្យមមានចំនួន ១.៣៦០ ដុល្លា និង
- មូលនិធិសំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន ដែលមានចំនួន ១៦,៨ ពាន់លានរៀល ត្រូវបានបែចែកដល់ក្រុមប្រឹក្សា ចំនួន ៥០៩ ជាឃុំដែលគេចាត់ទុកថាមានសមត្ថភាពគ្រប់គ្រាន់ប្រើប្រាស់មូលនិធិទាំងនេះមានប្រសិទ្ធភាព ដោយឃុំ និមួយៗទទួលបានជាមធ្យមចំនួន ៨.៣០០ ដុល្លា ។

សំរាប់ឆ្នាំ ២០០២ NCSC/Seila Task Force/ UNDO MOU បានស្នើថាប្រភពធនធានរបស់ម្ចាស់ជំនួយត្រូវទុកសំរាប់ការអភិវឌ្ឍន៍មូលដ្ឋានចំពោះភូមិឃុំមួយចំនួន ។ ប្រភពធនធានដែលមានសំរាប់ការអភិវឌ្ឍន៍មូលដ្ឋានបន្ថែមនេះមានឥទ្ធិពលដល់ការសំរេចចិត្តរបស់រដ្ឋាភិបាលនូវសិទ្ធនៃការផ្តល់ជំនួយដល់ ១៥៩ ក្រុមប្រឹក្សាឃុំបន្ថែម និងបន្ថែមរហូតទៅដល់ចំនួន ៣៥០ ក្រុមប្រឹក្សាឃុំ ដែលចាប់ផ្តើមដោយការផ្តល់ទុនពីរដ្ឋាភិបាលចំនួន ២០ ពាន់លាន ។ ចំណែកនៃរដ្ឋបាលទូទៅ គឺត្រូវបែងចែកដោយសមាមាត្រដល់សមាជិកក្រុមប្រឹក្សាឃុំមួយចំនួនក្នុងក្រុមប្រឹក្សានិមួយៗ ។ ធនធាននៃការអភិវឌ្ឍន៍មូលដ្ឋានត្រូវគេបែងចែកតាមរូបមន្តដោយរួមមានកត្តា ៣ គឺ : (១) បរមាណភាពស្មើ (២) ចំនួនប្រជាជន និង (៣) លំដាប់នៃភាពក្រីក្រ ។ ក្នុងឆ្នាំ ២០០២ កត្តាទាំង ៣ នេះ រាប់តាមភាគរយពី ៥០, ៣០, និង ២០ ភាគរយ (មានន័យថា បរមាណភាពស្មើ ចំនួនប្រជាជន និងលំដាប់នៃភាពក្រីក្រ) ។ បើពិចារណាពីកត្តាភាពក្រីក្រ និងចំនួនប្រជាជន រដ្ឋាភិបាលត្រូវមានការប្រុងប្រយ័ត្នចំពោះការគណនាបន្ទុកដែលរាប់ចុះនេះ ព្រោះថាមិនមានពត៌មានពិតប្រាកដអំពីចំនួនប្រជាជន និងភាពក្រីក្រចំពោះឃុំ-សង្កាត់ទាំងអស់នោះទេ ។ ដោយធ្វើអោយបានឆាប់ដែលអាចធ្វើទៅបាន ការបំពេញចន្លោះពត៌មាននេះមានសារៈសំខាន់ណាស់ ។

# ជំពូក ៦: ការតាមដាន និងការវាយតំលៃ

មាន និងការអនុវត្តន៍ យជកភ តែមួយមិនគ្រប់គ្រាន់ទេ បើមិនមានការតាមដាននិងវាយតំលៃ មិនត្រូវបានរួមបញ្ចូលដែល នឹងជួយផ្តល់ពត៌មានអំពីការរីកចំរើនក្នុងការអនុវត្តន៏ឱ្យបានដល់ទិសដៅនិងបញ្ហានានាដែលកើតឡើងពីយុទ្ធសាស្រ្តមិនសមស្របទាំងឡាយ ក៏ដូចជាដំណើរការអនុវត្តន៏ ដើម្បីប្រមូលផ្តុំនូវមេរៀននានា សំរាប់កិច្ចប្រឹងប្រែងនាពេលអនាគត។ ដូច្នេះការតាមដាននិងវាយតំលៃ និងសកម្មភាពកសាងសមត្ថភាពនានា ក្នុងនោះមានការវិភាគផលប៉ះពាល់សង្គមកិច្ច និងភាពក្រីក្រជាសមាសភាគសំខាន់របស់ យជកភ។ សកម្មភាពទាំងនេះសំខាន់ ប្រសិនបើត្រូវបានកែសំរួល និងកែលំអទៅតាមពេលវេលាប្រកបដោយចីរភាព។ ព្រមជាមួយនេះ សកម្មភាពទាំងនេះត្រូវតែបានសំរបសំរួលយ៉ាងជិតស្និទ្ធជាមួយសកម្មភាពតាមដានដ៏ទៃទៀតនៅក្នុងប្រទេស។ ដូច្នេះអាចជៀសវាងនូវការធ្វើការជាន់គ្នា។ រដ្ឋាភិបាលបានចាត់នូវជំហានសំខាន់ៗក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះដើម្បីកសាងសមត្ថភាពស្ថាប័នរបស់ខ្លួនក្នុងការបង្កើតតាមដាននិងរៀបចំ យជកភ ថែមទៀត។ ក្របខ័ណ្ឌស្ថាប័នតាមដាននិងវិភាគភាពក្រីក្រត្រូវបានបង្កើតឡើងនៅដើមឆ្នាំនេះ (ក្រោមការឧបត្ថមរបស់ UNDP) ហើយនឹងត្រូវរៀបរាប់ដូចខាងក្រោម។ យជកភ ត្រូវបញ្ចូលនូវការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព ស្ថាប័ននានាក្នុងការតាមដាននិងវាយតំលៃដើម្បីធានាឱ្យសមត្ថភាពទាំងនេះមានចីរភាព។

## ៦.១ ការរៀបចំស្ថាប័នសំរាប់តាមដាន និងវាយតំលៃ

ដំណើរការតាមដាននិងវាយតំលៃ យជកភ នឹងកើតឡើងតាមរយៈការចូលរួមទូលំទូលាយនៃក្រុមអ្នកពាក់ព័ន្ធទាំងអស់។ ការចូលរួមនៃសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកក្រីក្រ នឹងត្រូវបានអមដោយការធ្វើអត្តសញ្ញាណច្បាស់លាស់អំពីការទទួលខុសត្រូវខាងស្ថាប័នកណ្តាល និងស្ថាប័នរដ្ឋបាលមូលដ្ឋានព្រមទាំងតម្លាភាពត្រឹមត្រូវ។ តំរូវការតម្លាភាពទាមទារនូវអ្នកចូលរួមពាក់ព័ន្ធទាំងអស់ មានសេរីភាពគ្រប់គ្រាន់ក្នុងការទទួលបានពត៌មាននិងទិន្នន័យដំបូងនិងចុងក្រោយដែលគេត្រូវការដើម្បីអនុវត្តន៏កិច្ចការរបស់គេ។ ដំណើរការតាមដាននិងវាយតំលៃក៏ត្រូវការការបង្កើតនិងការពង្រឹងសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនានា។

ខាងក្រោមនេះជាដ្យាក្រាមក្នុងការរៀបចំស្ថាប័នសំរាប់ការតាមដាននិងការវាយតំលៃ។ ការរៀបចំលំអិត អំពីរូបភាពនេះនឹងបង្ហាញថា តើដំណើរការនេះទាក់ទងយ៉ាងដូម្តេចទៅនឹងការតាមដាន SEDP2 និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF)។ គោលបំណងគឺថាដំណើរការតាមដាន SEDP2 និង យជកភ ត្រូវរួមបញ្ចូលគ្នា ប្រសិនបើអាចធ្វើទៅបានកាន់តែច្រើន។ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទីសំខាន់ក្នុងការតាមដានការប្រតិបត្តិថវិកានិងការអនុវត្តន៏ ដែលមានសារៈសំខាន់ចំពោះ យជកភ។

**រូបភាព ៣ ការរៀបចំស្ថាប័នសំរាប់តាមដាននិងវាយតំលៃភាពក្រីក្រ**




## ៦.១.១ ក្រសួងផែនការ

ក្រសួងផែនការ ជាភ្នាក់ងារសំខាន់ទទួលខុសត្រូវលើកិច្ចសំរបសំរួលនៅក្នុងការតាមដាន យជកភ។ នៅក្នុងក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ (NIS) ជាភ្នាក់ងារបច្ចេកទេសរបស់ក្រសួង ទទួលខុសត្រូវក្នុងការរៀបចំនិងដឹកនាំការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចនានា ព្រមជាមួយនឹងអគ្គនាយកផែនការ ទទួលបន្ទុកក្នុងការវិភាគគោលនយោបាយ។

## ៦.១.២ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

CSD ត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ( RGC ) នៅក្រោមអនុក្រិត្យលេខ NB ៨៩។ CSD ទទួលខុសត្រូវលើការលើកតំកើងការសំរបសំរួល និងការតាមដានគោលនយោបាយអភិវឌ្ឍន៍និងកម្មវិធីនានាទាក់ទងនឹងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ RGC។ CSD ដឹកនាំដោយរដ្ឋមន្ត្រីផែនាការ ។ បច្ចុប្បន្នមានសមាជិក ១៤រូប ជារដ្ឋលេខាធិការមកពីក្រសួងចំនួន១៤ ។ សមាជិក៩ថែមទៀតនឹងចូលរួមក្នុង CSD នាពេលអនាគត ក្នុងនោះមានក្រសួង៨ និង សាលាក្រុងភ្នំពេញ។ CSDនឹងដើរតួនាទីដឹកនាំ ក្នុងការអនុវត្តន៍ យជកភ ដោយទទួលខុសត្រូវ: (១)ពិនិត្យសើរើ វាយតំលៃលើភាពក្រីក្រប្រចាំឆ្នាំ និងការសិក្សាវាយតំលៃផលប៉ះពាល់នៃភាពក្រីក្រ (២) រៀបចំអនុសាសន៍នានា សំរាប់ការកែសំរួលចាំបាច់ទាំងឡាយទៅលើ SEDP2 និង យជកភ ដើម្បីសំរេចបានកាន់តែល្អ និងមានប្រសិទ្ធិភាពលើកម្មវិធីប្រឆាំងភាពក្រីក្រនានា (៣)ធ្វើការតាមដានផ្នែកនានាដែលពាក់ព័ន្ធភាពក្រីក្រក្នុង SEDP2, NPRS និង PIP ហើយ (៤)ពិនិត្យសើរើការបែងចែកថវិការនិងផលប៉ះពាល់របស់វាទៅលើកម្មវិធីកាត់បន្ថយភាពក្រីក្រ។ CSD នឹងទទួលខុសត្រូវលើការរៀបចំនិងបញ្ជូននូវរបាយការណ៍រីកចំរើនប្រចាំឆ្នាំរបស់ យជកភ។

## ៦.១.៣ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

GSCSD ជាផ្នែកអនុវត្តន៍របស់ CSD ដែលទទួលខុសត្រូវក្នុងការរៀបចំពង្រាងរបាយការណ៍រីកចំរើនប្រចាំឆ្នាំ លើការអនុវត្តន៍ យជកភ សំរាប់ឱ្យ CSD ធ្វើការការពិចារណា។ GSCSD ដឹកនាំដោយអនុរដ្ឋលេខាធិការ ក្រសួងផែនការដែលរួមមានមនុស្សសំរាប់ធ្វើទំនាក់ទំនងមកពីក្រសួងពាក់ព័ន្ធដែលមានតំណាងនៅក្នុង CSD។ GSCSD ទទួលខុសត្រូវ: (១)ការសំរបសំរួលនិងរៀបចំបង្កើតកម្មវិធីនិងគោលនយោបាយលើភាពក្រីក្រ ការអនុវត្តន៍ និងការតាមដាន (២)ជួយសំរួលដល់ការកសាងសមត្ថភាពក្នុងការតាមដាន និងវិភាគភាពក្រីក្រ (៣) បង្កើតនូវកុងសង់ស៊ីសក្នុងចំណោមអ្នករួមចំណែកទាំងឡាយលើគោលនយោបាយគាំទ្រអ្នកក្រ។

GSCSD ធ្វើការប្រជុំជាប្រចាំដើម្បីពិភាក្សាលើបញ្ហាបច្ចេកទេសនានាដែលទាក់ទងនឹងវិធីសាស្ត្រនិងការរៀបចំកំរងសំណួរនិងរបកគំហើញនានានៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច។ GSCSD កំណត់នូវទិន្នន័យ និងតំរូវការវិភាគសំរាប់គោលបំណងរៀបចំគោលនយោបាយជាតិ ធ្វើសេចក្តីសំរេចលើពត៌មាន ដែលត្រូវប្រមូលនៅក្នុងការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចនីមួយៗ ហើយថាតើវាត្រូវវិភាគយ៉ាងដូចម្តេច។ នៅក្នុងការអនុវត្តន៍សកម្មភាពទាំងនេះ GSCSD ធ្វើការសំរបសំរួលជាមួយអ្នកធ្វើគោលនយោបាយនានា NGOs អង្គការសង្គមស៊ីវិល (CSOs) ស្ថាប័នសិក្សានិងស្រាវជ្រាវនិងទីភ្នាក់ងារអន្តរជាតិទាំងឡាយដើម្បីធានានូវ វិធីសាស្ត្របំរើឱ្យតំរូវការសំរាប់ការប្រមូលនិងវិភាគទិន្នន័យ។ GSCSD សំរបសំរួលផងដែរដើម្បីធានាកុំឱ្យមានការត្រួតគ្នាលើការប្រមូលទិន្នន័យហើយទិន្នន័យដែលបានប្រមូលដោយទីភ្នាក់ងារនានាអាចទទួលបានដោយទូលំទូលាយ និងជាសាធារណៈ។

### ៦.១.៤ អង្គភាពបច្ចេកទេសតាមដាននិងវិភាគភាពក្រីក្រ

PMATU ជាផ្នែកស្រាវជ្រាវរបស់ GSCSD ។ PMATU ដឹកនាំដោយនាយកបច្ចេកទេសជាតិម្នាក់ និងបុគ្គលិកបច្ចេកទេសជាតិ១០នាក់។PMATU ផ្តល់ការគាំទ្រដល់ GSCSD នៅក្នុងសកម្មភាពនានាដែល ពាក់ព័ន្ធ យជកភ: (១)សំរបសំរួលការប្រមូលទិន្នន័យដោយស្ថាប័នជាតិដ៏ទៃទៀត ដូចជា NIS និងផ្នែកស្ថិតិនៃក្រសួងពាក់ព័ន្ធ (២)សំរបសំរួលលើសកម្មភាពក្នុងការប្រមូលទិន្នន័យ (ឧទាហរណ៍ ការសិក្សាពីគុណភាពការសិក្សាវាយតំលៃផលប៉ះពាល់ការសិក្សាករណីជាក់លាក់នានា) នឹងពង្រឹងសម្ថភាពជាតិក្នុងការប្រមូលនិងវិភាគទិន្នន័យ (៣)ជួយដឹកនាំ (ក្នុងករណីខ្លះ) ការវិភាគទិន្នន័យជាមួយអ្នកស្រាវជ្រាវឯកជន និងអ្នកសិក្សាទៅតាមសំណើរបស់អ្នកធ្វើសេចក្តីសំរេចចិត្ត (៤)ផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាពទាំងអស់ដែលទាក់ទងនឹងការតាមដាននិងវិភាគភាពក្រីក្រ។ PMATU ចងក្រងពតិមានលើស្ថានភាព សូចនាករបច្ចុប្បន្នរបស់ យជកភ ដែលត្រូវបញ្ចូលទៅក្នុងរបាយការណ៏រីកចំរើនប្រចាំឆ្នាំលើការអនុវត្តន៏។ បន្ថែមនេះទៀត PMATU សំរបសំរួលសំរាប់សំភារៈមូលដ្ឋានទិន្នន័យថ្នាក់កណ្តាលដែលទាក់ទងនឹងការស្តុកនិងរក្សាទុកនូវពតិមានឬទិន្នន័យ ដែលមានស្រាប់និងទិន្នន័យឬពតិមានប៉ាន់ប្រមាណដែលត្រូវប្រមូលដោយភ្នាក់ងារផ្សេងៗរួមមាន រដ្ឋាភិបាល NGOs CSOs និងស្ថាប័នសិក្សានិងស្រាវជ្រាវដ៏ទៃទៀតសំរាប់គោលបំណងតាមដាននិងវិភាគ យជកភ ដោយធានាថាមូលដ្ឋានទិន្នន័យដែលមានត្រូវបានចែករំលែកនិងទទួលបានដោយភាគីពាក់ព័ន្ធទាំងអស់និងសាធារណៈជន។

### ៦.១.៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

MEF មានតួនាទីសំខាន់ក្នុងការតាមដានការប្រតិបត្តិថវិកានិងការអនុវត្តន៏ MTEF។ មានន័យថាតាមដានការចាំបាច់ត្រូវផ្តល់ធនធានហិរញ្ញវត្ថុទៅក្រសួងពាក់ព័ន្ធទាន់ពេលវេលាដើម្បីគេអនុវត្តន៏សកម្មភាពអត្ថិភាពសាធារណៈនៅក្នុង យជកភ។

### ៦.១.៦ បណ្តាក្រសួង

ក្រសួងពាក់ព័ន្ធនិងទីភ្នាក់ងាររដ្ឋាភិបាលនានាដែលតំណាងនៅក្នុង CSD ទទួលខុសត្រូវលើការអនុវត្តន៏ SEDP2 និង យជកភ នៅក្នុងផ្នែកពាក់ព័ន្ធរបស់ខ្លួនលើការតាមដានការអនុវត្តន៏របស់ខ្លួនជាធនធានដែលត្រូវការនិងផលដែលទទួលបាននិងទទួលខុសត្រូវលើការប្រមូលនិងនិងការរក្សាទិន្នន័យដែលត្រូវការសំរាប់ការវិភាគភាពក្រីក្រថែមទៀត ។ ក្រសួងពាក់ព័ន្ធរួមមានក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន MoWAV ធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកបច្ចេកទេសរបស់ក្រសួងសំខាន់៤ ដើម្បីធានាថាបញ្ហារួមនានាដូចជាយ៉េនឌ័រ ត្រូវស្ថិតនៅជាផ្នែកនៃដំណើរការវិភាគនិងការអនុវត្តន៏។

### ៦.១.៧ បណ្តាក្រសួងសំខាន់

ក្រសួងពាក់ព័ន្ធសំខាន់៤ ត្រូវការកំណត់ដោយ RGC ដើម្បីដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងនៅក្នុង យជកភ។ ក្រសួងទាំងនោះរួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (MAFF) ក្រសួងសុខាភិបាល (MoH) ក្រសួងអប់រំយុវជននិងកីឡា (MoEYS) និងក្រសួងអភិវឌ្ឍន៏ជនបទ។ បច្ចុប្បន្នក្រសួងពាក់ព័ន្ធសំខាន់ៗបានបង្កើតនូវក្រុមការងារ ដើម្បីធ្វើ

ការជាមួយ GSCSD ក្នុងការរៀបចំ យជកភ ។ ក្នុងពេលអនុវត្តន៏ យជកភ ក្រសួងពាក់ព័ន្ធសំខាន់ៗនឹងបង្កើត និងប្ញពង្រឹងនូវផ្នែកបច្ចេកទេស ចាំបាច់សំរាប់តាមដានការអនុវត្តន៏របស់ខ្លួន ប្រមូលទិន្នន័យចាំបាច់បន្ថែម ហើយធ្វើការយ៉ាងជិតស្និទ្ធិជាមួយ GSCSD ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃការអនុវត្តន៏ យជកភ។

## ៦.១.៨ រដ្ឋសភា/ព្រឹទ្ធសភា

រដ្ឋសភានិងព្រឹទ្ធសភាទទួលខុសត្រូវក្នុងការពិនិត្យសើរើលើការរីកចំរើននៃការអនុវត្តន៏ យជកភ ហើយផ្តល់ពតិមានត្រឡប់មកវិញ និងអនុសាសន៏នានាសំរាប់ការកែតំរូវចាំបាច់ចំពោះ យជកភ។ គេក៏ចូលរួមផងដែរ ក្នុងប្រជុំ សិក្ខាសិលា និងវេទិកាជាតិស្តីពីភាពក្រីក្រដែលរៀបចំដោយ CSD និង GSCSD។

## ៦.១.៩ ក្រុមប្រឹក្សាឃុំសង្កាត់ និងសង្គមស៊ីវិល

ក្រុមប្រឹក្សាឃុំនិងសង្គមស៊ីវិលតំណាងឱ្យក្រុមគោលដៅដែលត្រូវទទួលផលពី យជកភ។ គេដើរតួនាទីសំខាន់ក្នុងការផ្តល់ពតិមានត្រឡប់មកវិញសំរាប់ការតាមដាននិងវាយតំលៃនិងផ្តល់ជាប្រព័ន្ធប្រកាសអាសន្នជាមុនចំពោះបញ្ហាអ្វីមួយដែលកើតឡើងក្នុងពេល អនុវត្តន៏ យជកភ។ បន្ថែមទៀត ក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិលផ្តល់ពតិមានលើការតាមដានគ្រោះមហន្តរាយធម្មជាតិនានា។ គេក៏ចូលរួមផងដែរក្នុងកិច្ចប្រជុំសិក្ខាសាលានិងវេទិកាជាតិស្តីពីភាពក្រីក្រ។

## ៦.១.១០ អង្គការមិនមែនរដ្ឋាភិបាល

NGOs រួមមានអង្គការជាតិនិងអន្តរជាតិដែលផ្តោតខ្លាំងលើការកាត់បន្ថយភាពក្រីក្រ ដែលជាដៃគូសំខាន់ ក្នុងការតាមដាននិងវាយតំលៃ យជកភ។ ជាបន្ថែមលើការផ្តល់មតិលើលទ្ធផលនៃ ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចគ្រួសារនិងការតាមដានលើការរីកចំរើននៃ យជកភ NGOs រំពឹងថានឹងផ្តល់ពតិមាន និងទិន្នន័យសំខាន់ៗពីការអង្កេតនិងការសិក្សាវាយតំលៃក៏រិតមីក្រូរបស់ខ្លួន។NGOs ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលានិងវេទិកាជាតិស្តីពីភាពក្រីក្រ។

## ៦.១.១១ ផ្នែកឯកជន

RGC សំលឹងទៅរកផ្នែកឯកជនដើម្បីដើរតួនាទីក្នុងការកាត់បន្ថយភាពក្រីក្រ ជាពិសេសតាមរយៈការបង្កើតការងារ។ ដូច្នេះផ្នែកឯកជនពាក់ព័ន្ធយ៉ាងសកម្មក្នុងដំណើរការតាមដាននិងវាយតំលៃ NPRS ។ តាមរយៈនេះ សភាពាណិជ្ជកម្មសហព័ន្ធសហជីពកម្មករ និងជំនួញ ជាផ្នែកឯកជន នឹងចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំ សិក្ខាសិលានិងវេទិកាជាតិស្តីពីភាពក្រីក្រ។

## ៦.១.១២ ប្រព័ន្ធពត៍មាន

ដូចទីភ្នាក់ងារដ៏ទៃជាច្រើនទៀតដែរ ប្រព័ន្ធផ្សព្វផ្សាយធ្វើការតាមដានលើភាពក្រីក្រ។ ប្រព័ន្ធផ្សព្វផ្សាយជួយផ្តល់ពតិមានលើការរីកចំរើននិងបញ្ហាដែលប្រឈមមុខនានាក្នុងពេលអនុវត្តន៏ យជកភ ក៏ដូចជាលទ្ធផលទទួលបានភ្លាមៗក្នុងពេលប្រតិបត្តិ

យជកភ ប្រសិនបើគេចូលរួមពាក់ព័ន្ធ។ គេមិនអាចមិនពាក់ព័ន្ធដោយផ្ទាល់ក្នុងការតាមដានជាក់ស្តែង ប៉ុន្តែគេអាចអនុវត្តន៍របាយការណ៍កិច្ចការរបស់គេដោយផ្តោតលើបញ្ហាពាក់ព័ន្ធនឹងភាពក្រីក្រ។ ប្រព័ន្ធផ្សព្វផ្សាយរំពឹងថានឹងចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំសិក្ខាសាលានិងវេទិកាជាតិស្តីពីភាពក្រីក្រ ហើយរាយការណ៍ព្រឹត្តិការណ៍និងលទ្ធផលនៃការអនុវត្តន៍ យជកភ ព្រមពេលនឹងការអនុវត្តន៍កិច្ចការអាជីពរបស់គេ។

## ៦.២ ការតាមដាន យជកភ

ការតាមដានការរីកចំរើនប្រចាំឆ្នាំឆ្ពោះទៅគោលដៅកាត់បន្ថយភាពក្រីក្ររបស់ យជកភ គឺជាផ្នែកសំខាន់សំរាប់ដំណើរការ យជកភ។ វាត្រូវការនូវការជ្រើសរើស នូវសូចនាករនិងទិសដៅសមស្របមួយចំនួនសំរាប់សកម្មភាពជាអាទិភាពសាធារណៈមួយចំនួននៅក្នុង យជកភ។ សូចនាករនិងទិសទៅទាំងនោះត្រូវបំបែកតាមភេទដើម្បីធានាថាគំលាតគ្នាត្រូវបានយកចិត្តទុកដាក់។ លើសពីនេះទៀត សូចនាករនិងទិសដៅរបស់ **យជកភ** ត្រូវសមស្របជាមួយឯកសារផែនការសំខាន់ៗរបស់ RGC (SEDPII,MTEF) ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហសតវត្សរ៍រយៈពេលយូរ (MDGs)។ ការរីកចំរើនឆ្ពោះទៅទិសដៅរបស់ **យជកភ** និងត្រូវតាមដានពីរក៏រិត មានន័យថាក៏រិតអនុវត្តន៍និងក៏រិតទិសដៅហើយត្រូវរាយការណ៍នៅក្នុងរបាយការណ៍រីកចំរើនប្រចាំឆ្នាំ។

### ៦.២.១ សូចនាករ យជកភ

មានសូចនាករពីរប្រភេទដែលត្រូវប្រើដើម្បីតាមដានការរីកចំរើន ក្នុងការអនុវត្តន៍ **យជកភ** ។ ប្រភេទទី១រួមមានសូចនាករធនធាន (Input indicators) សូចនាករដំណើរការ (Process indicators) សូចនាករលទ្ធផលរយៈពេលខ្លី( Output indicators) (ត្រូវប្រមូលទៅតាមសូចនាករអនុវត្តន៍) ដែលត្រូវរៀបចំ ដើម្បីតាមដានការអនុវត្តន៍នៅក្នុងផ្នែកនានាដើម្បីសំរេចបានទិសដៅនិងគោលបំណង **យជកភ** ។ សូចនាករទាំងនេះត្រូវគណនាពីទិន្នន័យដែលត្រូវប្រមូលរក្សាទុកនិងវិភាគដោយក្រសួងនិងទីភ្នាក់ងារពាក់ព័ន្ធនានាហើយដែលបានផ្តល់និងបង្ហាញនៅ ក្នុងម៉ាទ្រីសផែនការសកម្មភាពរបស់ **យជកភ** បច្ចុប្បន្ន។ ប្រភេទទី២រួមមាន សូចនាករ លទ្ធផលរយៈពេលវែង (Outcome indicators)និង សូចនាករផលប៉ះពាល់ត្រូវបានវាស់វែងនៅក៏រិតប្រជាជននិងគ្រួសារហើយផ្អែកលើទិន្នន័យ ដែលប្រមូលបានតាមពេលនៅក្នុងការអង្កេតគ្រួសារ (ឧទាហរណ៍ ការអង្កេតគ្រួសារនិងប្រជាសាស្ត្រ ការអង្កេតពលកម្ម និងការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចដែលដឹកនាំធ្វើដោយ NIS) ឬក៏ជំរឿនប្រជាជននិងផ្ទះសំបែងរាល់១០ឆ្នាំម្តង។ សូចនាករជាច្រើននៅប្រភេទទី២ នេះមួយចំនួនត្រូវបានប្រើសំរាប់តាមដានការរីកចំរើនឆ្ពោះទៅរកការសំរេចបានសរុបនៃ **យជកភ** និងការរក្សាបាន MDGs រយៈពេលវែង (មើលឧបសម្ព័ន្ធ៥)។ សូចនាករផលប៉ះពាល់និងសូចនាករ លទ្ធផលរយៈពេលវែងអាចឆ្លុះបញ្ចាំងពីសកម្មភាពនានា នៃផ្នែកដ៏ទៃទៀតក៏ដូចជា សកម្មភាពផ្សេងទៀតដែលហួសពីការត្រួតត្រារបស់រដ្ឋាភិបាល (ឧទាហរណ៍ អាកាសធាតុ លក្ខខ័ណ្ឌហិរញ្ញវត្ថុនៅក្នុងតំបន់) ។ តារាងសូចនាករផលប៉ះពាល់និងសូចនាករលទ្ធផលរយៈពេលវែង និងទិសដៅមួយចំនួនមាននៅក្នុងឧបសម្ព័ន្ធ៤។ សូចនាករសំរាប់តាមដាននិងវាយតំលៃ **យជកភ** ដូចបង្ហាញនៅក្នុងផែនការសកម្មភាពនិងក្របខ័ណ្ឌតាមដាននិងវាយតំលៃត្រូវជ្រើសរើសដើម្បីឆ្លុះបញ្ចាំងនិងពិនិត្យ

ពីចរិកគោលនយោបាយឆ្លើយតបគាំទ្រអ្នកក្របស់ **យជកភ** សកម្មភាពនានាលទ្ធផលរយៈ ពេលខ្លី លទ្ធផលរយៈពេលវែង ផលប៉ះពាល់។ ការជ្រើសរើសសូចនាករ ទាំងនេះត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យនិងគោលការណ៍ខាងក្រោម។ សូចនាករធនធាននិងសូចនាករលទ្ធផលរយៈពេលខ្លីត្រូវតាមដាននៅក្នុងក៏រិតអនុវត្តន៏ដែលត្រូវបានជ្រើសរើស នៅក្នុងម៉ាទ្រីសផែនការសកម្មភាពដើម្បីពិចារណាៈ (១) ធនធានពីប្រភព RGC និងទីភ្នាក់ងារផ្តល់មូលនិធិសំរាប់គោលនយោបាយសកម្មភាពកម្មវិធីគំរោងផ្សេងៗ (២) ការផ្តល់សមត្ថភាពដល់ស្ថាប័នពាក់ព័ន្ឋ (៣)រយៈពេលកំណត់នៃ **យជកភ** (៤)ចរិកលក្ខណៈដែលអាចវាស់វែងនិងតាមដានបាននៃសូចនាករ (៥)ភាពបត់បែននៃសូចនាករភាពក្រីក្រ (៦)ខ្សែបន្ទាត់ដែល មាននិងមានស្រាប់ (៧)សមត្ថភាពដែលមានស្រាប់ក្នុងការប្រមូលរក្សាទុកនិងវិភាគពតិមានរបស់ទីភ្នាក់ងារពាក់ព័ន្ឋ។ សូចនាករលទ្ធផលរយៈពេលវាស់វែង និងផលប៉ះពាល់ត្រូវតាមដានក៏រិតទិសដៅដែលត្រូវជ្រើសរើសសំរាប់ក្របខ័ណ្ឌតាមដាន និងវាយតំលៃផ្អែកលើគោលការណ៍ដូចតទៅៈ (១) ខ្សែបន្ទាត់ដែលមាននិងមានស្រាប់សំរាប់ធ្វើការប្រៀបធៀប (២) ចរិកលក្ខណៈបត់បែននៃភាពក្រីក្រ (៣)សមត្ថភាពបច្ចុប្បន្នក្នុងការប្រមូលនិងវិភាគពតិមាន (៤) ចរិកលក្ខណៈដែលអាចវាស់វែងនិងតាមដានបាននៃសូចនាករ (៦)ការចូលរួមដើម្បីសំរេចបាន MDGs ។ សូចនាករខ្លះ (សំរាប់សូចនាករធនធាន សូចនាករលទ្ធផលរយៈពេលខ្លី សូចនាករលទ្ធផលរយៈពេលវាស់វែងនិង សូចនាករផលប៉ះពាល់)យកមកដោយផ្ទាល់ពី SEDP2 ដោយសារវាទាក់ទងនឹងភាពក្រីក្រហើយដែលចង់បានដោយ RGC។ ក្នុងពេលអនុវត្តន៏និង **យជកភ** បន្ទាប់ទៀត សូចនាករជាច្រើនទៀតអាចបន្ថែមពេលពតិមានអាចមានឬតារាងអាចលុបចោល ពេលប្រកាសអនុវត្តន៏ **យជកភ**។ លើសពីនេះ ការបំបែកទិន្នន័យតាមភេទត្រូវយកចិត្តទុកដាក់ដើម្បីការតាមដាន និងវាយតំលៃប្រកបដោយប្រសិទ្ធភាពក៏ដូចជាការកំណត់ទិសដៅនាអនាគត។

### ៦.២.២ ចំណុចដៅ យជកភ

ទិសដៅមួយចំនួននៅក្នុង **យជកភ** មានបំណងពីរយ៉ាងៈ គឺជួយឱ្យមានការបង្កើតនូវអាទិភាពនានានិងជំរុញឱ្យមានវប្បធម៌ក្នុងការទទួលខុសត្រូវនៅក្នុងចំណោមអ្នកអង្គការផ្សេងៗដែលទទួលខុសត្រូវលើការអនុវត្តន៏ **យជកភ**។ ការកំណត់ទិសដៅក៏អាចជួយផងដែរ ក្នុងការគៀងគរធនធាន។ ដើម្បីសំរេចបាននូវទិសដៅទាំងនេះ វាសំខាន់ណាស់ទិសដៅ ដែលត្រូវបានជ្រើសរើសត្រូវតែមានភាពប្រាកដនិយមនិងស្របតាមធនធានដែលមាន (រួមមានសមត្ថភាពអនុវត្តន៏ ការរៀបចំស្ថាប័នឬយន្តការសំរបសំរួលការផ្តល់មូលនិធិជាដើម ។ល។) ។

## ៦.៣ ការវាយតំលៃផលប៉ះពាល់ភាពក្រីក្រ

គោលបំណងនៃការវាយតំលៃផលប៉ះពាល់លើភាពក្រីក្រ គឺកំណត់អំពីការចូលរួមពិតប្រាកដនៃគោលនយោបាយឬវិធានការក្នុងការកែប្រែក៏រិតសុខាមាលភាពនៃប្រជាជនបណ្តាគ្រួសារ និងសហគមន៏ដែលជាប់ពាក់ព័ន្ឋ។ ការវាយតំលៃផលប៉ះពាល់បង្ហាញ នូវការសង្កត់ធ្ងន់លើស៊េរីនៃវិធីសាស្ត្រប្រកួតប្រជែងរួមមានភាពឯកកោនៃផលប៉ះពាល់របស់គោលនយោបាយឬកម្មវិធីមួយនៅក្រោមការតាមដានលើភាពក្រីក្រពីកត្តាខាងក្នុងនិងខាងក្រៅដែលអាចប៉ះពាល់ដល់លទ្ធផល នៃភាពក្រីក្រ។ សញ្ញាណនៃការវាយតំលៃផលប៉ះពាល់ក៏បង្ហាញពីការតាមដានឥទ្ធិពលដោយប្រយោលទៅលើសុខាមាលភាព របស់ក្រុមដែលមិន

កំណត់ក្នុងទិសដៅ (ទាហរណ៍ៈកុមារដែលទទួលបានផលពីគំរោងបង្កើតចំណូលសំរាប់ស្ត្រី) ក៏ដូចជាឥទ្ធិពលរយៈពេលមធ្យមនិងយូរនៃគោលនយោបាយឬកម្មវិធីមួយ ។

## ៦.៤ របាយការណ៍រីកចំរើនប្រចាំឆ្នាំនៃការអនុវត្តន៍

របាយការណ៍ចុងក្រោយស្តីពីការអនុវត្ត (APRI) គឺបានធ្វើការរៀបចំ និងបញ្ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។ របាយការណ៍ APRI បានដាក់បញ្ចូលបីចំនុនដូចខាងក្រោមៈ

- ពតិមានស្តីពីការងារសំរេចបាន និងការអនុវត្តន៍ក្នុងយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ( យជកភ )
- ធ្វើការពិភាក្សាតាមសំណូមពរដែលស្នើឡើងដើម្បីធ្វើការផ្លាស់ប្តូរ យជកភ
- ពតិមានអំពីការរំលោភលើ Stakeholders និងភាគីផ្សេងទៀតក្នុងការរៀបចំរបាយការណ៍ ។

**ការសំរេចបាន និងសំរេចពុំបានៈ** របាយការណ៍ APRI នីមួយៗ ត្រូវបញ្ចូលពតិមាន និងបទពិសោធន៍នៃការវិភាគរាល់ការងារសព្វថ្ងៃដែលយើងសំរេចបាន និងមិនទាន់សំរេចបានដែលទាក់ទងដល់ការងារកាត់បន្ថយភាពក្រីក្រ ដែលរួមចំណែកក្នុងការត្រួតពិនិត្យ និងការវាយតំលៃនៅក្នុងយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ។ ដើម្បីសំរេចនូវទិសដៅទាំងនេះ របាយការណ៍ APRI ត្រូវដាក់បញ្ចូលពតិមានដូចខាងក្រោមៈ

- ធ្វើការប្រៀបធៀបទិន្នន័យថ្មីៗ រួមមានទិន្នន័យសង្គម និងភេទដែលជាសូចនាករទាក់ទងទៅនឹងការងារ យជកភ និងធ្វើការវិភាគមូលហេតុដែលសំរេចពុំបានដើម្បីឈានដល់ការកែលំអរ និងកំណត់អាទិភាព
- កំណត់ចំណុចគន្លឹះនៅក្នុងផ្នែកម៉ាក្រូ, រចនាសម្ព័ន្ធ និងគោលនយោបាយបានអនុវត្តន៍កន្លងមក និងពុំបានធ្វើ ដែលមានបង្ហាញនៅក្នុងម៉ាទ្រីសនៃយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ
- ធ្វើការពិភាក្សាទៅលើការវិភាគដែលអាចបង្កើនល្បឿននៃការរីកចំរើន និងជាងនេះទៅទៀតធ្វើការវិភាគប្រព័ន្ធនៃការអនុវត្តន៍ការកែទំរង់ដែលប៉ះពាល់ដល់ភាពក្រីក្រ និងសង្គមទាំងមូល ។
- ធ្វើការប្រៀបធៀបថវិកា ដែលប្រើក្នុងឆ្នាំកន្លងមកជាមួយនឹងគំរោងរបស់ផែនការយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រដោយដាក់បញ្ចូលនូវការចំណាយលើការផ្លាស់ប្តូរទិន្នន័យមួយចំនួនចំពោះកម្មវិធីកាត់បន្ថយភាពក្រីក្រ ។
- ប្រព័ន្ធនៃការត្រួតពិនិត្យ និងវាយតំលៃដែលមានដាក់បញ្ចូលរាល់ទិន្នន័យទាំងអស់ដែលប្រមូលបាន និងការវិភាគផងដែរ និង
- ការរីកចំរើនរបស់ស្ថាប័ន ជាពិសេសលើការគ្រប់គ្រងការចំណាយសាធារណៈ និងប្រព័ន្ធនៃការត្រួតពិនិត្យ និងវាយតំលៃព្រមជាមួយតំរូវការចាំបាច់នៃជំនួយបច្ចេកទេស ។

## ៦.៥ បញ្ហាប្រឈមសំរាប់ការតាមដាន និងវាយតំលៃ យជកភ

ជោគជ័យយូរអង្វែងនៃ **យជកភ** អាស្រ័យទៅលើកត្តាសំខាន់ៗ បួនដែលប៉ះពាល់ដល់សមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប៉ាន់ប្រមាណជាទៀងទាត់អំពីសូចនាករទាក់ទងនឹងភាពក្រីក្រៈ (១) អន្តរកម្មនៃការទទួលខុសត្រូវគ្រប់គ្រង និង

ការលើកកំពស់ក៏រិតជំនាញបុគ្គលិកជាតិជាបន្តនៅក្នុងការអង្កេត និងវិភាគទិន្នន័យ (២) បង្កើនការបែងចែកថវិកាជាតិទៅឱ្យកម្មវិធីវិភាគសេដ្ឋកិច្ចនិងស្ថិតិ។ (៣) ធ្វើឱ្យប្រសើរ និងការធ្វើបទដ្ឋានវិធីសាស្ត្រអង្កេត ឧបករណ៍អង្កេត និងការវិភាគសេដ្ឋកិច្ច-សង្គមកិច្ចហើយ (៤) គឺការបង្កើតនូវតួនាទីជាអចិន្ត្រៃយ៍របស់ GSCSD/ CSD ជាកន្លែងទំនាក់ទំនងក្នុងការសំរបសំរួល និងធ្វើសមាហរណ៍កម្មលើការតាមដាននិងវាយតំលៃលើភាពក្រីក្រនៅក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច-សង្គមកិច្ចទាំងមូល។ បញ្ហាសំខាន់ៗដែលអាចត្រូវបានកំណត់ដើម្បីស្វែងរកដំណោះស្រាយមាន ដូចតទៅ:

- ការទទួលបានពត៌មាននៅថ្នាក់នាយកដ្ឋានរបស់ក្រសួងផ្សេងៗ។ ជាការពិត នៅក្នុងផ្នែកមួយចំនួនគ្មានការប្រមូលផ្តុំជាខ្សែចង្វាក់នូវប្រភេទទិន្នន័យសំខាន់ៗមួយចំនួន។ ជួនកាលមានទិន្នន័យហើយទិន្នន័យទាំងនោះមិនពាក់ព័ន្ធ ទៅនឹងបណ្តាក្រុមឬវិធានការនានាដែលផ្តោតទៅរកអ្នកទទួលផលប្រយោជន៍។ លើសពីនេះទៅទៀត គ្មានធនធានគ្រប់គ្រាន់សំរាប់រក្សាទុកទិន្នន័យដែលប្រមូលបានដែលតែងមិនចែករំលែកហើយមិនអាចទទួល។
- កង្វះខាតធនធានមនុស្សខាងជំនាញបច្ចេកទេសនៅក្នុងចំណោមជំនាញបុគ្គលិកគ្រប់គ្រងជាតិដែលទទួលខុស ត្រូវសំរាប់ប្រមូលពត៌មានដំណើរការនិងការផ្សព្វផ្សាយពត៌មាន។ ពង្រឹងសមត្ថភាពនៅក្នុងវិស័យនេះគឺជាអាទិភាពមួយសំខាន់។

**តារាង ៦.១ សូចនាករប្រើប្រាស់សំរាប់តាមដាន[២៥] និងវាយតម្លៃយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ**

| ទិសដៅ | សូចនាករ | ទិន្នន័យថ្មីៗ (ឆ្នាំ) | គោលដៅ[២៦] (២០០៥) | ប្រភពទិន្នន័យ - ចន្លោះនៃ រយៈពេល |
|---|---|---|---|---|
| **ការផ្តល់កាលានុវត្តភាព** | | | | |
| | សន្ទស្សន៍រាប់មនុស្សនៃភាពក្រីក្រ | ៣៦% (១៩៩៩) | ៣១% ** | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ |
| | អត្រាកំណើនពិតនៃផលិតផលក្នុងស្រុកសរុប | ៧,៧% (២០០០) | ៦-៧% ** (២០០៣-២០០៥) | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |
| | ពន្ធលើប្រាកចំណូលគិតជាភាគរយធៀបផលិតផលក្នុងស្រុកសរុប | ៨,៥% (២០០១) | ១០,១% | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |
| **ការលើកកំពស់ការិតជីវភាពជនបទ** | | | | |
| | ភាគរយគ្រួសារនៅជនបទដែលគ្មានដីប្រើប្រាស់ | ១២-១៥% (២០០២, CDRI) | ៧-១០% | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ |
| | អត្រាកំណើនពិតនៃតំលៃបន្ថែមក្នុងវិស័យកសិកម្ម | -២,៧% (២០០០) | ៣,៥% ** (២០០៣-២០០៥) | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |
| | ទិន្នផលស្រូវជាមធ្យមក្នុងមួយហិកតា, មេទ្រិកតោន | ២,០៧ (២០០១-២០០២) | ២,២ * (២០១០) | ក្រសួងកសិកម្ម (ប្រចាំឆ្នាំ) |
| | ផលិតកម្មមិនមែនស្រូវដែលជាភាគរយនៃផ្ទៃដីដាំដុះ សរុប | ៩% (២០០១-២០០២) | ១៥% (២០០៥) | ក្រសួងកសិកម្ម (ប្រចាំឆ្នាំ) |
| | ផលិតកម្មត្រីសរុប, មេទ្រិកតោន | ៣៨៥.០០០ (២០០១-២០០២) | មិនទាន់កំណត់ | ក្រសួងកសិកម្ម (ប្រចាំឆ្នាំ) |
| | ផលិតកម្មពាហនៈសរុប | ២០៤.៣៣០ (២០០១-២០០២) | មិនទាន់កំណត់ | ក្រសួងកសិកម្ម (ប្រចាំឆ្នាំ) |
| **ការពង្រីកមុខរបរ** | | | | |
| | តំលៃនៃការនាំចេញ (គិតជា US$) | ៦.៧៦៨,៦ (២០០១) | មិនទាន់កំណត់ | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |

[២៥] សូចនាករផ្សេងៗទៀតសំរាប់ការត្រួតពិនិត្យគួរតែបញ្ចូលសូចនាករធាតុចេញនិងធាតុចូលដែលមានបង្ហាញនៅក្នុងម៉ាទ្រីសនៃ ផែនការសកម្មភាព នៅក្នុងតារាងឧបសម្ព័ន្ធទីបី ។

[២៦] គោលដៅត្រូវបានកំណត់ដោយក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ សំរាប់គោលដៅណាដែលមិនទាន់បានកំណត់ តួលេខសំរាប់គោលដៅទាំងនោះនឹងត្រូវបានកំណត់នៅក្នុងអំឡុងពេលអនុវត្ត ឯកសារជាតិស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

| | | | | |
|---|---|---|---|---|
| | តំលៃនៃការនាំចេញគិតជាភាគរយនៃ ផ.ស.ស | ៥០,៦% (២០០១) | មិនទាន់កំណត់ | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |
| | ការងារក្នុងវិស័យមិនមែនកសិកម្មនៅជនបទ | ១៥,៣% (១៩៩៩) | មិនទាន់កំណត់ | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ |
| | កំលាំងពលកម្មជាស្ត្រីក្នុងវិស័យមិនមែនកសិកម្មនៅជនបទ | ១៩,៨% (២០០០) | មិនទាន់កំណត់ | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ, អង្កេតកំលាំងពលកម្ម, ២-៣ ឆ្នាំ |
| | កំលាំងពលកម្មក្នុងវិស័យឧស្សាហកម្មនៅតំបន់ទីប្រជុំជនដែលមិនមែននៅ ទីក្រុងភ្នំពេញ | ៩,២% (១៩៩៩) | មិនទាន់កំណត់ | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ |
| | កំលាំងពលកម្មស្ត្រីក្នុងវិស័យឧស្សាហកម្មនៅតំបន់ទីប្រជុំជន | ៦៨,៤% (២០០០) | មិនទាន់កំណត់ | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ, អង្កេត កំលាំងពលកម្ម, ២-៣ ឆ្នាំ |
| | អត្រាអនិកម្មភាពនៅជនបទ | ២,៣% (២០០០) | មិនទាន់កំណត់ | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ, អង្កេត កំលាំងពលកម្ម, ២-៣ ឆ្នាំ |
| | អត្រាអនិកម្មភាពរបស់ស្ត្រីនៅជនបទ | ២,៧% (២០០០) | មិនទាន់កំណត់ | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ, អង្កេត កំលាំងពលកម្ម, ២-៣ ឆ្នាំ |
| | អត្រាកំណើននៃតំលៃបន្ថែមពិតក្នុងវិស័យឧស្សាហកម្ម | ២៩% (២០០០) | ៧%**(២០០៣-២០០៥) | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |
| | អត្រាកំណើននៃតំលៃបន្ថែមពិតក្នុងវិស័យសេវាកម្ម | ៣,១% (២០០០) | ៨%** (២០០៣-២០០៥) | គណនេយ្យជាតិ (ប្រចាំឆ្នាំ) |
| **ការពង្រឹងសមត្ថភាព** | | | | |
| **ការអប់រំ និងបណ្តុះបណ្តាល** | | | | |
| | ភាគរយនៃកុមារដែលមានអាយុ ១២ ឆ្នាំដែល បានបញ្ចប់បឋមសិក្សា | ៣៣% (១៩៩៨) | ៩០% * | កសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ |

| | | | | |
|---|---|---|---|---|
| | អត្រារួមនៃការចុះឈ្មោះចូលរៀនបឋមសិក្សា | ១០៩,៨ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រារួមនៃការចុះឈ្មោះចូលរៀនបឋមសិក្សារបស់ស្ត្រី | ១0៣,២ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រារួមនៃការចុះឈ្មោះចូលរៀនអនុវិទ្យាល័យ | ២៧ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រារួមនៃការចុះឈ្មោះចូលរៀនអនុវិទ្យាល័យរបស់ស្ត្រី | ២0,៣ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រាពិតនៃការចុះឈ្មោះចូលរៀនបឋមសិក្សា | ៨៣,៨ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រាពិតនៃការចុះឈ្មោះចូលរៀនបឋមសិក្សារបស់ស្ត្រី | ៨0,៧ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រាពិតនៃការចុះឈ្មោះចូលរៀនអនុវិទ្យល័យ | ១៦,៦ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រាពិតនៃការចុះឈ្មោះចូលរៀនអនុវិទ្យាល័យរបស់ស្ត្រី | ១៣,៧ (២000-0១) | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិងកីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមាន អប់រំ) |
| | អត្រាអក្ខរភាពរបស់ស្ត្រីអាយុ ១៥ឆ្នាំ ឡើង | ៦១,៤% (១៩៩៩) | មិនទាន់កំណត់ | កសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ) ២-៥ ឆ្នាំ |
| | អត្រារៀនបញ្ចប់ថ្នាក់ទី ៥ | ៤៥% (១៩៩៧-៩៨) | ថ្នាក់ទី ៥ និងទី ៩: ៩0% * រៀងគ្នា (២00៥) | ក្រសួងអប់រំ , ប្រព័ន្ធគ្រប់គ្រងពតិមានអប់រំ (ប្រចាំឆ្នាំ) |
| | អត្រាអក្ខរភាព ១៥-២៤ ឆ្នាំ<br>ស្ត្រី | ៧៦%<br>៧១% | ៩0%*<br>(២00៥- | កសួងផែនការ (អង្កេតសេដ្ឋកិច្ច សង្គមកិច្ចគ្រួសារ) ២-៥ |

| | | | | |
|---|---|---|---|---|
| | ប្រុស | ៨២% (១៩៩៨) | ២០០៧) | ឆ្នាំ |
| | បឋមសិក្សា<br>ស្ត្រី<br>ប្រុស | <br>៤៦%<br>៥៤% | <br>៥០%<br>៥០%*(២០០៥-២០០៧) | ក្រសួងអប់រំ , ប្រព័ន្ធគ្រប់គ្រងពតិមានអប់រំ (ប្រចាំឆ្នាំ) |
| | អនុវិទ្យាល័យ<br>ស្ត្រី<br>ប្រុស | <br>៣៧%<br>៦៣% | ៤៥%<br>៥៥%*(២០០៥-២០០៧) | ក្រសួងអប់រំ , ប្រព័ន្ធគ្រប់គ្រងពតិមានអប់រំ (ប្រចាំឆ្នាំ) |
| **សុខាភិបាល** | | | | |
| | អត្រាមរណភាពកុមារ | ៩៥ (២000, ក្រសួងសុខាភិបាល) | ៩០ | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាមរណភាពកុមារ ក្នុងគ្រក្នុងគ្រួសារក្រីក្រ | ១១០ (២000) | ១០០ | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ | ១២៥ (២000, ក្រសួងសុខា ភិបាល) | ១១៨ | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាមរណភាពមាតា | ៤៣៧ (១៩៩៨) | ៣៧២ (៣៩០ នៅក្នុងឯកសារយុទ្ធសាស្ត្រ របស់ក្រសួងសុខាភិបាល | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ អត្រាបញ្ចូភាគនៃអ្នកមានបំផុតធៀបនិងអ្នកក្របំផុត | 0,៥ (២000) | 0,៨ | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | ភាគរយកុមារក្រោមអាយុ ១ឆ្នាំ ដែលបានចាក់ថ្នាំបង្ការ សព្វគ្រប់ | ៤០% (២000) | ៧០% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាថយចុះនៃកុមារក្រោមទំងន់កំណត់ ដែលមានអាយុពី ៦-៥៩ ខែ | ៤៥% | ៣៨% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | ភាគរយនៃកំណើតដែលបានប្រសូតដោយបុគ្គលិកជំនាញ | ៣២% | ៤៦% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | ការចំណាយលើផ្នែកសុខាភិបាលក្នុងចំណោមគ្រួសារក្រីក្រ និងគ្រួសារ ងាយរងគ្រោះ គិតជាភាគរយនៃចំណូលរបស់គ្រួសារ | ១១% (១៩៩៩) | ៥,៥% | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ច សង្គមកិច្ច គ្រួសារ) ២-៥ ឆ្នាំ |
| **អាហារូបត្ថម្ភ** | | | | |

| | | | | |
|---|---|---|---|---|
| | ភាគរយនៃកុមារអាយុក្រោម ៥ឆ្នាំដែលមានកំពស់ក្រិនមធ្យម ឬធ្ងន់ធ្ងរ | ៤៤% (២០០០) | ៣៦,៥% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | កង្វះអាហារូបត្ថម្ភជាតិប្រូតេអ៊ីន ក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ | ៤៥% (២០០០) | ៣១% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | កង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រីនៅក្នុងអាយុបន្តពូជ | ២១% (២០០០) | ១៥% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| **ផែនការគ្រួសារ** | | | | |
| | អត្រាលទ្ធភាពបង្កើតកូនសរុប | ៤% (២០០១) | ៣,៨% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាលទ្ធភាពបង្កើតកូនសរុប សំរាប់អ្នកក្រីក្របំផុត | ៦,៨% (២០០០) | មិនទាន់កំណត់ | អង្កេតប្រជាសាស្ត្រ និងសុខភាព (តួលេខបំបែក) |
| | អត្រាពន្យាកំណើត (វិធីសាស្ត្រទំនើប), ស្ត្រីអាយុ ១៥-៤៩ ឆ្នាំ | ១៩% (២០០០) | ២៧% | អង្កេតប្រជាសាស្ត្រ និងសុខភាព |
| | អត្រាពន្យាកំណើត (វិធីសាស្ត្រទំនើប),<br>សំរាប់ស្ត្រីនៅក្នុងគ្រួសារក្រីក្រ បំផុតអាយុ ១៥-៤៩ ឆ្នាំ | ១១% (២០០០) | មិនទាន់កំណត់ | អង្កេតប្រជាសាស្ត្រ និងសុខភាព (តួលេខបំបែក) |
| **ហ៊ីវ អេដស៍** | | | | |
| | អត្រាប្រេវ៉ាឡង់ **HIV/AIDS** អ្នកដែលមានអាយុ ១៥-៤៩ ឆ្នាំ | ២,៦% (២០០២) | ២,៣% | ក្រសួងសុខាភិបាល (ប៉ាន់ស្មានដោយ កម្មវិធី **HIV/AIDS**) |
| **ទឹកស្អាត និងអនាម័យ** | | | | |
| | ភាគរយនៃប្រជាជននៅជនបទដែលមានទឹកស្អាត ប្រើប្រាស់ | ២៩% (១៩៩៩) | ៤០% ** | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ច សង្គមកិច្ចគ្រួសារ,ជំរឿន) ២-៥ ឆ្នាំ |
| | ភាគរយនៃប្រជាជននៅតំបន់ទីប្រជុំជនដែលមាន ទឹកស្អាត ប្រើប្រាស់ | ៦៩,៥% (១៩៩៩) | ៨៧% ** | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ច សង្គមកិច្ចគ្រួសារ,ជំរឿន) ២-៥ ឆ្នាំ |
| | ភាគរយនៃប្រជាជននៅជនបទដែលមានបង្គន់អនាម័យ ប្រើប្រាស់ | ៨,៦% (១៩៩៩) | ២០% ** | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ចគ្រួសារ, ជំរឿន) ២-៥ ឆ្នាំ |
| | ភាគរយនៃប្រជាជននៅតំបន់ទីប្រជុំជនដែលមាន បង្គន់អនាម័យប្រើប្រាស់ | ៤៩% (១៩៩៩) | ៩០% ** | ក្រសួងផែនការ (អង្កេត សដ្ឋកិច្ចសង្គមកិច្ចគ្រួសារ,ជំរឿន) ២-៥ ឆ្នាំ |
| | ភាគរយកុមារដែលមានអាយុក្រោម ៥ ឆ្នាំដែលក្រេះមធ្យម | ៤៤% (២០០០) | ៣៦,៥% ** | អង្កេតប្រជាសាស្ត្រ និង |

| | | | | |
|---|---|---|---|---|
| | ឬធ្ងន់ធ្ងរ | | | សុខភាព |
| **ពលកម្មកុមារ** | | | | |
| | អត្រាចូលរួមពលកម្ម កុមារអាយុ ១០-១៤ ឆ្នាំ | ៨,៣% | ៥,៣% | ក្រសួងផែនការ (អង្កេតសេដ្ឋកិច្ច សង្គមកិច្ចគ្រួសារ, កំលាំងពលកម្ម) ២-៥ ឆ្នាំ |
| **ការកាត់បន្ថយភាពងាយទទួលរងគ្រោះ** | | | | |
| **ការគ្រប់គ្រងគ្រោះមហន្តរាយ** | | | | |
| | ផ្ទៃដីដាំដុះ (ស្រូវ) ដែលបំផ្លាញដោយទឹកជំនន់ (ហិកតា) | ១៩០.៧៧៣ (២០០០-០១) | មិនទាន់កំណត់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ប្រចាំឆ្នាំ) |
| | ផ្ទៃដីដាំដុះ (សំណាប) ដែលបំផ្លាញដោយទឹកជំនន់ (ហិកតា) | ៥.៩៣០ (២០០០-០១) | មិនទាន់កំណត់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ប្រចាំឆ្នាំ) |
| | ការខូចខាតដោយទឹកជំនន់, ដុល្លាអាមេរិក | ៤០ លាន (២០០២) | មិនទាន់កំណត់ | គណកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ |
| | ផ្ទៃដីដាំដុះ (ស្រូវ) ដែលបំផ្លាញដោយគ្រោះរាំងស្ងួត (ហិកតា) | ៥៥.៦២៣ (២០០០-០១) | មិនទាន់កំណត់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ប្រចាំឆ្នាំ) |
| | ផ្ទៃដីដាំដុះ (សំណាប) ដែលបំផ្លាញដោយគ្រោះរាំងស្ងួត (ហិកតា) | ៩.៩២២ (២០០០-០១) | មិនទាន់កំណត់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ប្រចាំឆ្នាំ) |
| | ចំនួនគ្រួសារដែលរងគ្រោះដោយទឹកជំនន់ | ២ លាន (២០០២) | មិនទាន់កំណត់ | គណកម្មាធិការជាតិ គ្រប់គ្រងគ្រោះ មហន្តរាយ (ប្រចាំឆ្នាំ) |
| **សកម្មភាពកំចាត់មីន** | | | | |
| | គ្រោះថ្នាក់,ប្រចាំឆ្នាំ (ស្លាប់ និងរបួស) | ៨១៣ (២០០១) | | អាជ្ញាធរកំចាត់មីន កម្ពុជា (មជ្ឈមណ្ឌល កំចាត់មីន កម្ពុជា, ក្រុមផ្តល់យោបល់ អំពី មីន, ហាឡូទ្រឹស, កងយុទ្ធពលខេមរភូមិន្ទកម្ពុជា) |
| | គ្រោះថ្នាក់, ប្រចាំខែ (ស្លាប់ និងរបួស) | ៦៨ (២០០១) | | អាជ្ញាធរកំចាត់មីន កម្ពុជា (មជ្ឈមណ្ឌល កំចាត់មីន កម្ពុជា, ក្រុមផ្តល់យោបល់ អំពី មីន, ហាឡូទ្រឹស, កងយុទ្ធពលខេមរភូមិន្ទកម្ពុជា) |
| **និរន្តរភាពគ្រប់គ្រងប្រភពធនធាន/បរិស្ថាន** | | | | |
| | ភាគរយផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ | ៥៨,៦% (២០០២) | ៥៨% | នាយកដ្ឋាន រុក្ខា និង |

| | | | | |
|---|---|---|---|---|
| | | | | ប្រមាញ់, ក្រសួងកសិកម្ម |
| **សន្តិសុខស្បៀង** | | | | |
| | អតិរេក អង្ករ, មេទ្រីកតោន | ៣៦៤.១៤៨ (២០០២) | មិនទាន់កំណត់ | ក្រសួងកសិកម្ម (ប្រចាំឆ្នាំ) |
| | ផ្ទៃដីដាំស្រូវ, ហិកតា | ១,៩៣ (២០០១-០២) | ២,៥ | ក្រសួងកសិកម្ម (ប្រចាំឆ្នាំ) |
| | ការចំណាយលើស្បៀងអាហារ គិតជាភាគរយនៃការចំណាយរបស់គ្រួសារ | ៦១,៦ * (១៩៩៩) | មិនទាន់កំណត់ | ក្រសួងផែនការ អង្កេតសេដ្ឋកិច្ច សង្គមកិច្ច, ២-៣ ឆ្នាំ |
| | អត្រាថ្លៃអង្ក រវាងស្រុកដែលថ្លៃជាងគេបំផុត និងស្រុកដែលថោកជាងគេបំផុត | ១១,១ * (២០០១) | មិនទាន់កំណត់ | ក្រសួងផែនការ អង្កេតសេដ្ឋកិច្ច សង្គមកិច្ច, ២-៣ ឆ្នាំ |
| **កម្មវិធីសំណាញ់សុវត្ថិភាពសង្គម** | | | | |
| | ចំនួនប្រជាជនដែលស្ថិតនៅក្នុងកម្មវិធីសំណាញ់ សុវត្ថិភាព | មិនមាន | មិនទាន់កំណត់ | ក្រសួងសង្គមកិច្ច |
| **ជនជាតិភាគតិច** | | | | |
| | អត្រារួមចុះឈ្មោះចូលរៀនសាលាបឋមសិក្សា ក្នុងចំណោមកុមារជនជាតិភាគតិច | មិនមាន | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិង កីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមានអប់រំ), ប្រចាំឆ្នាំ |
| | អត្រារួមចុះឈ្មោះចូលរៀនអនុវិទ្យាល័យ ក្នុងចំណោមកុមារជនជាតិភាគតិច | មិនមាន | មិនទាន់កំណត់ | ក្រសួងអប់រំ យុវជននិង កីឡា (ប្រព័ន្ធគ្រប់គ្រង ពតិមានអប់រំ), ប្រចាំឆ្នាំ |
| | អត្រាអក្ខរភាពបុរស, ភាគរយ | ៥,៣ (២០០០, ក្រសួងអប់រំ) | មិនទាន់កំណត់ | ក្រសួងផែនការ អង្កេតសេដ្ឋកិច្ច សង្គមកិច្ច, ២-៣ ឆ្នាំ |
| | អត្រាអក្ខរភាពស្ត្រី, ភាគរយ | ០,០ (២០០០, ក្រសួងអប់រំ) | មិនទាន់កំណត់ | ក្រសួងផែនការ អង្កេតសេដ្ឋកិច្ច សង្គមកិច្ច, ២-៣ ឆ្នាំ |
| **ការពង្រឹងស្ថាប័ន និងការកែលំអអភិបាលកិច្ច** | | | | |
| **កំណែទំរង់ច្បាប់ និងតុលាការ** | | | | |
| | ភាគរយនៃខេត្ត និងក្រុងដែលមានចៅក្រម និងព្រះរាជអាជ្ញា យ៉ាងតិចបីនាក់ | មិនមាន | មិនទាន់កំណត់ | ក្រសួងយុត្តិធម៌, ប្រចាំឆ្នាំ |
| | ភាគរយនៃស្ត្រីជាព្រះរាជអាជ្ញា | ០ (២០០២) | មិនទាន់កំណត់ | ក្រសួងយុត្តិធម៌, ប្រចាំឆ្នាំ |
| **កំណែទំរង់រដ្ឋបាលស៊ីវិល** | | | | |
| | បៀវត្សរ៍មធ្យមប្រចាំខែរបស់មន្ត្រីរាជការ, ដុល្លាអាមេរិក | ២០ (២០០១) | មិនទាន់កំណត់ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុ និងក្រសួងពាក់ព័ន្ធ, ប្រចាំឆ្នាំ |
| | ការបន្ថយទំហំនៃរដ្ឋបាលស៊ីវិល, សាធារណៈ | ១៦៣.៥២៩ (១៩៩៩) | មិនទាន់កំណត់ | គណៈរដ្ឋមន្ត្រី, មុខងារសាធារណៈ, ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញ វត្ថុ និងក្រសួងពាក់ព័ន្ធ, |

| | | | | |
|---|---|---|---|---|
| | | | | ប្រចាំឆ្នាំ |
| | ការបន្ថយទំហំកងទ័ព | ២៤៨.៦០០ (១៩៩៨) | មិនទាន់កំណត់ | ក្រសួងការពារជាតិ, ប្រចាំឆ្នាំ |
| **វិមជ្ឈការ, អភិបាលកិច្ចមូលដ្ឋាន, ប្រជាធិបតេយ្យនិយម** | | | | |
| | ចំនួនគណៈកម្មាធិការអភិវឌ្ឍន៍ដែលបានបង្កើត និងកំពុងដំណើរការ | ៨.០០០(២០០២) | ៩.០០០ | ក្រសួងអភិវឌ្ឍន៍ ជនបទ, កម្មវិធីសីលា, ប្រចាំឆ្នាំ |
| | ភាគរយស្ត្រីដែលមានអសនៈនៅក្នុងសភាជាតិ | ៩.៣% (២០០២) | មិនទាន់កំណត់ | ក្រសួងកិច្ចការនារី (ប្រចាំឆ្នាំ) |
| **ការប្រឆាំងអំពើពុករលួយ** | | | | |
| | រៀបចំ និងអនុម័តច្បាប់ប្រឆាំងអំពើពុកយ៉ាងយូរឆ្នាំ ២០០៣ | | | រាជរដ្ឋាភិបាល, គណៈរដ្ឋមន្ត្រី |
| **ការគ្រប់គ្រងធនធានសាធារណៈ** | | | | |
| | ទុនបំរុងជារូបិយប័ណ្ណ, ជាចំនួនខែនៃការនាំចូល | ២,៩ (២០០១) | ៣,២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប្រចាំឆ្នាំ) |
